# សកលបចិន្តា

## ចម្ងាល



ផ្នែក

ស្រាវជ្រាវ

សាសនា វិទ្យាសាស្ត្រ ទស្សនវិជ្ជា



ព្រះតេជព្រះគុណ ខៀវ ជុំ ធម្មបាល
វត្តលង្កាកុសុមារាម

# <u>អារម្ភកថា</u>

រឿងមួយទៀត ក្នុងបណ្ដារឿងទាំងឡាយដែលខ្ញុំ បានសរសេរមកហើយ ។ សំនេររបស់ខ្ញុំទោះជាត្រូវចិត្ត អ្នកអានក្ដី មិនត្រូវក្ដី, គោលគំនិតនិងឧត្តមគតិរបស់ខ្ញុំ គឺអភិវឌ្ឍន៍មនុស្សឲ្យដល់ទិសដៅរបស់គេ ដែលអ្នកផងនិយមហៅថា «បរមសុខ» សម្រាប់ជីវិតអស់ភពមួយអន្លើដោយសេចក្ដីសុខធម្មតាសម្រាប់ជីវិតអន្ទោលក្នុងសកលពិភព ។ ទិសដៅនេះ ព្រះសម្មាសម្ពុទ្ធ របស់យើង ព្រះអង្គបានប្រកាន់យកជាផ្លូវសម្ដែងធម៌រំដោះទុក្ខនៃសត្វលោក ។ នៅក្នុងលោកនេះ, អ្នកមានគំនិតមួយណា ក៏ដូចជាមួយណា ។ ទាំងអស់គ្នាសុទ្ធតែបានដឹងថា កំណើតមនុស្សមានទុក្ខ ។ ដំណឹងនេះហើយដែលបង្ខំឲ្យគេទាំងឡាយ ខំបន់ស្រន់បួងសួង, ខំអង្វរ, ខំសំពះគ្រប់ទិស គ្រប់ទីសុំសេចក្ដីសុខអំពីវត្ថុទាំងឡាយមានជាអាទិ៍ ព្រះអាទិទេព, ខ្មោច, ទេព, ឥន្ទព្រហ្ម . . . ដែលគេស្មានថា វត្ថុធាតុទាំងអស់នេះមានភាពស័ក្ដិសិទ្ធិខ្លាំងពូកែ អាចជួយខ្លួនគេបានបើមិនច្រើនក៏តិចដែរ ។ ជំនឿរបស់គេនេះ ត្រូវបានព្រះបរមគ្រូនៃយើងទាត់ចោល ហើយបានធ្វើសេចក្ដីបំភ្លឺថា វត្ថុស័ក្ដិសិទ្ធិខ្លាំងពូកែមិនមែន មាននៅខាងក្រៅនៃខ្លួនរបស់មនុស្សម្នាក់ៗទេ ។ ក្នុងន័យថា កម្លាំងនិងកំសោយ ធាតុទាំងពីរនេះ បើមិនមួយណាក៏មួយណាតែងមាន នៅក្នុងខ្លួនរបស់មនុស្សសត្វជាទូទៅធម្មតា ។ តែកម្លាំងនេះ, វាមិនមែនជាភាពនៅនឹងដដែល គ្មានឡើងគ្មានចុះនោះទេ គឺវាមានដំណើរប្រែប្រួលពីភាពមួយ ទៅភាពមួយទៀតដែរ ប្រសិនបើបូកខ្លួនមនុស្សនិងការងាររបស់គេ ។ ពុទ្ធសាសនា, បានធ្វើសេចក្ដីបញ្ជាក់ថា «គ្មានកម្លាំងដទៃក្រៅពីការងារ» ទេ, គឺមានតែការងារនេះហើយ ដែលជាធាតុមានភាពស័ក្ដិសិទ្ធិ ជួយបន្ធូរសេចក្ដីទុក្ខព្រួយ ។ ជាមួយគ្នានេះ, ជួយបង្កើតសេចក្ដីសុខសប្បាយដល់មនុស្សតាំងពីតូចតាច មធ្យម កណ្ដាល, រហូតដល់សេចក្ដីសុខខ្ពស់បំផុត ដែលត្រូវបានដាក់ឈ្មោះថា បរមសុខ ឬឯកន្តបរមសុខ ឬនិព្វានហ្នឹងឯង ។

អ្នកអានទាំងឡាយ ! កាលណាបើអ្នកទាំងឡាយចង់ដឹងថា ធាតុអ្វីជាប្រភពនៃទុក្ខសុខ ឬជាហេតុនៃទុក្ខសុខ ឬជាមាគ៌ានៃសេចក្ដីសុខទុក្ខ ។ អ្នកត្រូវតែខំប្រឹងយ៉ាងប្តូរផ្ដាច់ អាននិងត្រិះរិះពិចារណា នូវអត្ថបទទាំងឡាយក្នុងសៀវភៅនេះ តាំងពីដើមរហូតដល់ចប់ដោយមនសិការៈមនុស្សជាតិ ។ នៅក្នុងសេចក្ដីត្រិះរិះពិចារណារបស់អ្នក, អ្នកកុំភ្លេចថា មនុស្សលោក ជាមួយសេចក្ដីទុក្ខសុខរបស់គេ គេកំពុងយល់ច្រឡំច្រើនណាស់ ។ តួយ៉ាងដូចសង្គ្រាមជាហេតុនៃទុក្ខសោះ គេច្រឡំថា ជាហេតុនៃសុខទៅវិញ សន្តិភាពជាហេតុនៃសុខពិតប្រាកដណាស់ គេយល់ថា ជាហេតុនៃទុក្ខទៅវិញ ។ នេះមកពីអ្វី? មិនមែនមកពីអវិជ្ជាតណ្ហាទេឬ? ដើម្បីមានពន្លឺក្នុងរឿងសុខទុក្ខនេះ ខ្ញុំយល់ថា មិនមានធាតុអ្វីដទៃ, ក្រៅពីខំប្រឹងអាន, ខំប្រឹងគិតថា មនុស្សគ្រប់គ្នាចង់បានសេចក្ដីទុក្ខ ឬចង់បានសេចក្ដីសុខ? បើអំនាន ឬគំនិតរបស់អ្នកឆ្លើយប្រាប់ថា ចង់បានសុខអ្នកគង់យល់បានថា សុខវាជាផលរបស់សន្តិភាព ។ ផ្ទុយទៅវិញបើអំនាន ឬគំនិតរបស់អ្នកឆ្លើយថា ចង់បានទុក្ខ ចម្លើយនេះខ្ញុំមានគំហើញថាមិនត្រូវព្រោះតាំងពី កាលណាមកគេមិនដែលឮមនុស្សបន់ស្រន់បួងសួងសុំសេចក្ដីទុក្ខទេ ។ តែបើឧបមាថាមាន គឺការមាននោះមិនមែនកើតឡើងដោយលក្ខណៈចិត្តជាប្រក្រតីទេ គឺវាមានខ្លះមួយដងមួយកាល ដោយអាស្រ័យចិត្តមានលក្ខណៈខុសប្រក្រតី ដែលលោកឲ្យឈ្មោះថា អកុសលចិត្ត ឬវិប្បលាសចិត្តប៉ុណ្ណោះ ។

ក្នុងទីបំផុតនេះ, ខ្ញុំសូមអំពាវនាវដល់បងប្អូនខ្មែរគ្រប់មជ្ឈដ្ឋាន ឲ្យនាំគ្នារស់នៅជាមួយព្រះពុទ្ធសាសនា ទាំងគតិលោក ទាំងគតិធម៌ នៅក្នុងក្របខ័ណ្ឌនៃយុត្តិធម៌ និងភាពត្រឹមត្រូវពិតប្រាកដ តាមវត្ថុបំណង, ឧត្តមគតិនិងព្រះគំហើញ នៃព្រះសម្មាសម្ពុទ្ធនៃយើងគ្រប់ៗអាត្មា ។ ដូចនេះ, ទើបសង្គមជាតិយើងនឹងបានសម្រេចនូវយុត្តិធម៌, វឌ្ឍនភាព, សុខុមាលភាព, សុភមង្គល, សេរីភាព, សមភាព, ភាតរភាព, សន្តិភាព, . . . អស់រយៈកាលមិនមាន ទីបំផុតបាន ។

**វត្តលង្កា**

**ថ្ងៃទី ៦ ខែកញ្ញា ១៩៧២**

**ភិក្ខុធម្មបាល**

**ខៀវ ជុំ**

# **មតិអ្នករៀបរៀង**

ព្រះពុទ្ធសាសានា ជាសានាមានហេតុផល ព្រះសម្មាសម្ពុទ្ធលោកមិនបានពោលអួតថា ពុទ្ធសាសនាជាសាសនាល្អទេ ។ ដូច្នេះមុននឹងធ្វើអ្វីត្រូវមានហេតុផលផលច្បាស់លាស់ ។

នៅក្នុងសៀវភៅសកលចិន្តានេះ បានបង្កប់នូវអត្ថន័យយ៉ាងជ្រាលជ្រៅអំពីពុទ្ធសាសនានិងសង្គម ដែលយើងទាំងឡាយមិនបានដឹង ។ ដោយមើលឃើញពីផលប្រយោជន៍នេះ ទើបខ្ញុំបាទបានខំចំណាយពេលវេលាដែលមានតិចតួចបំផុតរបស់ជនទួទៅដើម្បីសរសេរអត្ថបទក្នុងសៀវភៅនេះទាំងស្រុងឡើងវិញ ទុកជាប្រយោជន៍ខ្លះដល់កូនខ្មែរជំនាន់ក្រោយដើម្បីស្រាវជ្រាវជាឯកសារដែលកម្ររកបាននិងមិនសូវមានអ្នកស្គាល់ បានទូលំទូលាយទេ ព្រោះថាសៀវភៅដើមមានលក្ខណៈតួអក្សរមិនសូវច្បាស់ហើយតួអក្សរក៏តូចថែមទៀត ធ្វើឲ្យមានការលំបាកដល់អ្នកដែលមានវ័យចំណាស់និងមានបញ្ហាភ្នែកផង ។ ក្នុងការធ្វើអ្វីមួយពិតជាមានកំហុសមិនខាន ហេតុនេះខ្ញុំសូមអភ័យទោសនៅរាល់កំហុសឆ្គងទាំងឡាយណាដែលបានកើតមានឡើងដោយអចេតនា ។

នៅក្នុងអត្ថបទថ្មីនេះខ្ញុំបាទ បានកែសម្រួលអក្ខរាវិរុទ្ធខ្លះឲ្យត្រូវតាមវចនានុក្រម តែដោយពាក្យមួយចំនួនក្នុងវចនានុក្រមមិនមាន ខ្ញុំសូមសរសេរដូចក្នុងសំនេរដើមដដែលដោយមិនហ៊ានកែប្រែទេ :

ឧទាហរណ៍ : ដូចជាពាក្យថា **ទំរើ កំហំ សំនួ** និងពាក្យដទៃទៀតជាច្រើនដែលមិនមាននៅក្នុងវចនានុក្រម ដូច្នេះប្រសិនបើលោកអ្នកប្រាជ្ញទាំងឡាយដែលជាអ្នកឆ្លៀវឆ្លាត ក្នុងអក្សរសាស្រ្តជាតិ មេត្តាជួយកែសម្រួលដោយមេត្តាចិត្តផងចុះ ។ ដើម្បីជួយលើកតម្កើងអក្សរសាស្រ្តជាតិ និងរក្សាតម្លៃពុទ្ធសាសនាផង ។

ជាទីបញ្ចប់ សូមជូនចំណែកបុណ្យ ដល់ព្រះរស់របស់ខ្ញុំទាំងពីរ និងឧទ្ទិសបុណ្យប្រគេនដល់ **ព្រះភិក្ខុធម្មបាល ខៀវ ជុំ** ដែលបានចំណាយកម្លាំងកាយចិត្ត ដើម្បីចងក្រងសៀវភៅនេះឡើងទុកជាគុណប្រយោជន៍ ដល់កូនខ្មែរគ្រប់ជំនាន់បានសិក្សារៀនសូត្រ ។

បើព្រះករុណាគ្រប់ព្រះអង្គ ឬលោកអ្នកសប្បុរសទាំងអស់ចង់ចូលរួមកែលំអ អាចទាក់ទងមកខ្ញុំព្រះករុណាខ្ញុំបាទ គ្រប់ពេលតាមរយៈទូរស័ព្ទលេខ : ០១២ ៥០៨ ៦២០

ឧបាសក

**ផាន ពុទ្ធានុភាព**

# បទទី១

# ពុទ្ធសាសនាគឺអ្វី?

នេះជាអត្ថបទទី១ ដែលត្រូវបានដាក់ចូលក្នុងសៀវភៅដែលអ្នកកំពុងអាន កំពុងសិក្សាទាំងអស់គ្នា ។ តែអត្ថបទទាំងឡាយ ដែលបានសរសេរក្នុងទីនេះ ពុំមែនមានតែមួយបទថា ពុទ្ធសាសនាគឺអ្វីប៉ុណ្ណោះទេ ។ សំនេររបស់ខ្ញុំក្នុងរឿងនេះត្រូវចែកជាច្រើនបទតទៅទៀត ស្រេចហើយតែធាតុអ្វីៗ ឬរបស់ណា, កិច្ចការណាដែលត្រូវបានជាប់ទាក់ទងដល់ពុទ្ធសាសនា ឬដែលពុទ្ធសាសនាបាននិយាយដល់ ឬដែលត្រូវប្រកប ត្រូវអាស្រ័យដល់គ្នានិងគ្នា ទៅវិញទៅមកជាមួយនឹងព្រះពុទ្ធសាសនា ។

ចំពោះអត្ថបទទី១ យើងត្រូវដឹងថា ព្រះពុទ្ធបរមគ្រូរបស់យើង ព្រះអង្គផ្តើមគិតគូរជាដំបូងដល់ធាតុមានជីវិត, មានចិត្តវិញ្ញាណដូចដែលយើងធ្លាប់ស្គាល់ ធ្លាប់ដឹងយល់គ្រប់គ្នាមកហើយ មិនមែនផ្តើមគិតដោយអាស្រ័យហេតុបច្ច័យអ្វីដទៃក្រៅពីធាតុនេះជាមុនទេ ។ ព្រះអង្គបានធ្វើវិភាគដល់សភាវៈរបស់ជីវិតចិត្តវិញ្ញាណ ហើយព្រមគ្នានេះបានពន្យល់ឲ្យឃើញថា : របស់នេះវាជាអនិច្ចំ មានភាពមិនទៀងទាត់, វាជាទុក្ខំ មានភាពអត់ធន់ទ្រាំ, វាជាអនត្តា មានភាពមិនមែនជាអាត្មាខ្លួនប្រាណ គឺមិនមែនជាអមតៈ ព្រោះថាគ្រប់តែជីវិតសុទ្ធតែមានទីបំផុតដូចៗគ្នា, សុទ្ធតែមានភាពស្របគ្នា គឺឋិតនៅក្នុងលក្ខណៈ ៣ ដែលយើងស្គាល់គ្រប់គ្នាថា «អនិច្ចំ ទុក្ខំ អនត្តា» ។ ព្រោះហេតុនេះធាតុមានជីវិតចិត្តវិញ្ញាណទាំងឡាយ ទើបត្រូវមានការទាក់ទងដល់គ្នានិងគ្នា, មានភាពរស់នៅជាញាតិមិត្ត នៃគ្នានិងគ្នា តាមគោលបំណងនៃធម្មជាតិ ពុំមែនត្រូវទុកដាក់ជាឧត្តមគតិ, ជាគំនិត, ជាពំនោលដូចនេះ ដូចនោះ ឲ្យក្លាយទៅជាល្បែងលេង ឬជាទំរើថោកទាបគ្មានខ្លឹមសារឡើយ ។ ដោយអាស្រ័យហេតុនេះ សំអប់ទាំងឡាយក្តី ទំរើទាំងឡាយក្តី ដែលជាធាតុបង្កើតសង្គ្រាម គឺជារបស់ដែលគេគប្បីតមរៀរបាន តែគេធ្វើមិនកើត គេឈប់មិនបាន ។ ទំរើនេះ, គឺជាសេចក្តីល្ងង់ខ្លៅអាប់តតបញ្ញារបស់មនុស្សទាំងឡាយប៉ុណ្ណោះ ។ ប្រវត្តិសាស្រ្តបាននិយាយប្រាប់យើងថា នៅក្នុងកំលុង ២៥១៥ ឆ្នាំ កន្លងមកនេះ មិនប្រាកដថា មានអ្នកណាម្នាក់ ធ្លាប់បានឃើញ ការបង្ហូរឈាមកើតឡើងក្នុងព្រះនាមរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គមានព្រះមហាករុណាទិគុណដល់សត្វលោកក្នុងគ្រាម្តងណាឡើយ ។

ដើម្បីបញ្ជាក់នូវសេចក្តីពិត នៃសំណួរក្នុងអត្ថបទថា ពុទ្ធសាសនាគឺជាអ្វី ដែលខ្ញុំសរសេរត្រាយផ្លូវ ឬប្រាប់គោលដៅរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គបានត្រាស់ដឹង ហើយបានធ្វើការស្រាវជ្រាវរកសេចក្តីពិត ដែលមាននៅក្នុងធាតុមានជីវិត និងមិនមានជីវិតក្នុងសកលលោកខាងលើនេះ ។ ខ្ញុំមិនឃើញមានរបស់ណាដទៃក្រៅពីសច្ចធម៌ ៤ ឬអរិយធម៌ ៤ ដែលពុទ្ធសាសនិក ស្ទើរតែទាំងអស់ធ្លាប់បានស្គាល់សភាវៈនេះ ទាំងច្បាស់លាស់ទាំងមិនច្បាស់លាស់រួចមកហើយ ។ គឺអរិយសច្ចៈ ៤ នេះហើយ ដែលជាពុទ្ធសាសនាសុទ្ធ ឥតមានលាយឡំដោយគំនិតរបស់សាសនាណាមួយ ឬលទ្ធិទាំងឡាយដទៃក្នុងពិភពលោកយើងនេះសូម្បីបន្តិចបន្តួចឡើយ ។ ព្រោះអ្វី? ព្រោះពុទ្ធសាសនាដែលយើងស្គាល់ថា ពាក្យបង្រៀន ឬដំបូន្មាននោះ គឺបង្រៀនឲ្យស្គាល់នូវសេចក្តីពិតតាមធម្មជាតិហ្នឹងឯង ។ ដំណឹងថា ព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹង ឬបានរកឃើញនូវធម៌ទាំងឡាយ ដោយផ្ទាល់ព្រះអង្គ គ្មានគ្រូណា ឬសាស្រ្តាចារ្យណា ឬទស្សនវិទូណាបង្រៀនព្រះអង្គនោះ ក៏គ្មានធម៌ណាដទៃទេ គឺអរិយសច្ចធម៌ ៤ នេះឯង ។ ធម៌ក្រៅពីនេះ ព្រះអង្គបានចេះដឹង បានរកឃើញដោយអាស្រ័យគំនិតរបស់អ្នកដទៃខ្លះ, គ្រូអាចារ្យខ្លះ ។ គឺព្រះអង្គខំប្រឹងត្រិះរិះពិចារណា លុះត្រាបានសម្រេចវិជ្ជាមួយៗ ក្នុងសំណាក់គ្រូទាំងឡាយ ដូចមនុស្សផង ទាំងពួងដែរ ។

ដូចនេះ, អរិយសច្ចធម៌ ៤ ប្រការ ទើបត្រូវបានជាចម្លើយនៃសំណួរថា ពុទ្ធសាសនាគឺអ្វី? ប្រែថា

អរិយសច្ចធម៌ គឺជាពុទ្ធសាសនា ឬពុទ្ធសាសនាគឺអរិយសច្ចធម៌ដោយពិតប្រាកដ គ្មាននរណាមានសមត្ថភាពប្រកែកមិនទទួលស្គាល់ ឬធ្វើសេចក្តីបដិសេធបានឡើយ ។ ព្រោះហេតុអ្វី? ព្រោះហេតុថា ក្នុងបឋមទេសនា ឬធម្មចក្កប្បវត្តនសូត្រ ដែលព្រះអង្គបានសម្តែងឲ្យបញ្ចវគ្គី (តាបស ៥ រូប ជាមិត្តកម្សត់កម្រ) ក្នុងសម័យកំពុងធ្វើការស្រាវជ្រាវស្តាប់នោះ ។ អ្នកមានចំណេះខាងផ្លូវព្រះពុទ្ធសាសនា ស្ទើរតែទាំងអស់គ្នា បានមានសេចក្តីយល់ឃើញត្រូវគ្នាថា អរិយសច្ចធម៌ដែលព្រះសម្ពុទ្ធលើកមកសម្តែងក្នុងពេលនោះ ជាធម៌មានអត្ថន័យចម្លែកដែលមនុស្សទាំងឡាយមិនធ្លាប់បានឮ ជាធម៌ដែលមិនមានក្នុងសាសនាទាំងឡាយដទៃ មានព្រាហ្មណ៍ជាដើម ។ ម្យ៉ាងទៀតបណ្ឌិតទាំងឡាយ ខាងផ្នែកស្រាវជ្រាវ លោកបានធ្វើសេចក្តីសន្និដ្ឋានថា អរិយសច្ចធម៌ដែលព្រះសម្មាសម្ពុទ្ធសម្តែងក្នុងពេលនោះ ទោះណាជាធម៌នេះមានចំនួនតិចមែន តែធម៌នេះមានន័យទូលំទូលាយដោយក្នុងផ្ទៃនៃធម៌នេះ មានធម៌ប្រាំបីម៉ឺនបួនពាន់រួមចូលផង ។ គឺធម៌ទាំងឡាយ មិនថាធម៌ណាជាធម៌ណាទេ ឲ្យតែធម៌នោះជាពុទ្ធភាសិត ឬសម្តែងចេញដោយ ព្រះពុទ្ធជាបរមគ្រូ សុទ្ធតែមានអរិយសច្ចៈជាលំនៅ ឬជាកំណើត ។ ក្នុងន័យថាបែកចេញពីអរិយសច្ចៈ រួមចូលក្នុងអរិយសច្ចៈ ឬនឹងនិយាយមួយបែបទៀតជាបឋមទេសនារបស់ព្រះសម្មាសម្ពុទ្ធក្នុងពេលនោះ បានស្រូបយកធម៌ទាំងអស់មកនៅក្នុងផ្ទៃ ឬក្នុងគំរោងហើយបានជួបចប់ទៅវិញក៏ជាមួយនឹងធម៌នេះដែរ ។ ប្រែថា ព្រះសម្មាសម្ពុទ្ធបានសម្តែងធម៌ទាំងអស់ចប់ស្រេចហើយក្នុងពេលនោះ លុះពេលជាបន្តបន្ទាប់មក ព្រះអង្គមានការតព្វកិច្ចត្រឹមតែ ពង្រីកជាមួយនឹងការដាក់ឈ្មោះ ដូចនេះ ដូចនោះប៉ុណ្ណោះ ។ ក្នុងពេលសម្តែងបឋមទេសនា ព្រះអង្គបានធ្វើសេចក្តី បញ្ជាក់ឲ្យមិត្តចាស់ទាំង ៥ រូប ចាប់អារម្មណ៍ថា : ចូរអ្នកប្រុងស្មារតីផ្ទៀងស្តាប់ធម៌របស់យើងដោយយកចិត្ត ទុកដាក់ចុះ ។ ព្រះអង្គបានធ្វើពំនោលបន្ថែមចំពោះមិត្តទាំងឡាយនោះថា : ធម៌នេះខ្លួនយើងមិនធ្លាប់ចេះក្នុងកាលមុន, មនុស្សទាំងឡាយដទៃក្រៅពីខ្លួនយើង ដែលយើងធ្លាប់បានជួបធ្លាប់បានពិគ្រោះ ធ្លាប់បានសាកល្បងធ្វើសំណួរជាទូទៅ ក៏គេពុំដែលបានឆ្លើយ ពុំដែលបានធ្វើសេចក្តីបំភ្លឺដល់យើងអំពី ធម៌នេះដល់ម្តងណាសោះឡើយ ។ ខ្ពស់ជាងនេះទៅទៀត, លោកគ្រូរបស់យើងទាំងពីរនាក់ គឺអាឡារៈ និងឧទកៈ ដែលគេចាត់ទុកជាជើងឯក ខាងមានសេចក្តីចេះដឹងជាន់ខ្ពស់ ក៏លោកពុំដែលបានបង្រៀនយើង កុំថាច្រើនសូម្បីត្រឹមតែមួយម៉ាត់ក៏គ្មានដែរ ។ ប្រែថា លោកក៏ពុំបានចេះធម៌នេះដូចអ្នកទាំងឡាយដទៃរួមទាំងខ្លួនយើងផង ។ ប្រសិនណាបើលោកចេះ លោកមុខជាមិនខានបង្រៀនយើង ក្នុងពេលដែលយើងសួរថាលោកគ្រូអស់ចំណេះប៉ុណ្ណឹងហើយ ឬមួយនៅមានចំណេះវិជ្ជាអ្វីទៀតដែរ ។ មិត្តរួមទុក្ករកិរិយាទាំងឡាយ! ភ្នែកទាំងឡាយ, ញាណទាំងឡាយ, ពន្លឺទាំងឡាយដែលពីដើមមក យើងពុំធ្លាប់មាន, ពុំធ្លាប់ជួប, ពុំធ្លាប់ចេះ, ពុំធ្លាប់កើត ។ ពេលនេះ, របស់ទាំងឡាយដែលយើងរាប់ឈ្មោះមកហើយ ត្រូវយើងបានមាន, បានជួប, បានចេះ, បានកើតជាស្រេចហើយ ។ តាមការកត់សម្គាល់របស់យើងក្នុងរឿងនេះ, ប្រសិនបើអ្នកទាំងឡាយ នឹកទៅខាងក្រោយវិញ អ្នកគង់ដឹងគ្រប់គ្នាថា សម្តីនេះយើងមិនដែលនិយាយប្រាប់អ្នក ដល់ម្តងណាទេ ។ ព្រោះសម្តីនេះវាជាអំនួត ដែលយើងគ្មានចូលចិត្តយកមកនិយាយសោះ ព្រោះយើងមិនស្រឡាញ់ពាក្យអំនួត ។ តែពេលនេះ, បើយើងមិនប្រើពាក្យមិនជាទីពេញចិត្តនេះក៏មិនបាន ព្រោះអ្នកទាំងឡាយនៅតែឆ្ងល់, នៅតែមិនមានជំនឿថាយើងបានត្រាស់ដឹងនូវធម៌ដែលគ្មាននរណាចេះដឹង, ទើបយើងនិយាយប្រាប់អ្នកទាំងខំប្រឹង កាត់សេចក្តីអៀនខ្មាសដើម្បីញ៉ាំងអ្នកឲ្យមានជំនឿក្នុងការត្រាស់ដឹងរបស់យើង ។ លទ្ធផលគឺទាញស្មារតីរបស់អ្នក ឲ្យចាប់អារម្មណ៍ចំពោះធម៌ពិត, ធម៌សម្រាប់រំដោះសត្វចេញចាកទុក្ខក្នុងសកលពិភព ដែលរកឃើញដោយ ខ្លួនយើង ។ កាលណាអ្នកចាប់អារម្មណ៍អ្នកនឹងមានជំនឿ មានការគោរពស្តាប់ធម៌របស់យើង ហើយទីបំផុតអ្នកនឹងបានត្រាស់ដឹងធម៌នេះ ដូចយើងជាមិនខាន ។ ព្រះសម្មាសម្ពុទ្ធក្រោយដែលបានសម្តែងអរិយសច្ចធម៌ចប់ហើយ, តាបសទាំង ៥ រូប (បញ្ចវគ្គី)

ក៏បានសម្រេចនូវការចេះដឹង ហើយបានសម្រេចនូវមគ្គផលថ្នាក់ទាប, កណ្តាល, ខ្ពស់ជា បន្តបន្ទាប់គ្នា ជាចុងក្រោយ បង្គស់មានឋានៈជាព្រះអរហន្ត រស់នៅក្នុងលោកនៃមនុស្សយើងរហូតដល់អស់ព្រះជន្ម បាននិព្វានទៅ ។

អត្ថបទពុទ្ធសាសនាគឺអ្វី ដែលខ្ញុំបានសរសេរមកហើយ, ខ្ញុំនឹកឃើញថា អ្នកអានគ្រប់ពេល គ្រប់វ័យ មុខជានឹងមានចម្ងល់ថា តើពុទ្ធសាសនាគឺអរិយសច្ចធម៌, អរិយសច្ចធម៌គឺជាពុទ្ធសាសនាតែប៉ុណ្ណឹង ចុះធម៌ទាំងឡាយដទៃទៀតដែលមានមកក្នុងគម្ពីរត្រៃបិដក ក្រៅពីអរិយសច្ចធម៌នោះនឹងទៅជាអ្វីទៅវិញ? ដើម្បីបន្ធូរនូវចម្ងល់នេះ ខ្ញុំសូមឲ្យអ្នកអាន សិក្សាប្រវត្តិសាស្ត្រនៃពិភពលោកជាមួយនឹងខ្ញុំ ប្រកបដោយគំនិតថ្លៃថ្នូរ មិនមានចិតងាករេទៅតាមអគតិធម៌ ៤ ។ ព្រមគ្នានេះ, ហាក់ដកទិដ្ឋិរបស់ខ្លួនចេញចាកលទ្ធិទាំងឡាយ មួយអន្លើដោយជំនឿដែលធ្លាប់មានក្នុងប្រពៃណីនិយម ហើយទប់ខ្លួនឲ្យនៅនឹងក្នុងភាពកណ្តាល ។ កាលណាបានកាច់បំបាក់ផ្ទត់គំនិតឬជម្រកនៃទិដ្ឋី របស់ខ្លួនដែលធ្លាប់មានមកក្នុងពេលមុនបានហើយ ។ ជាដំបូង, យើងត្រូវសិក្សាថា : ក្នុងពេលមុនព្រះពុទ្ធបានត្រាស់ ក៏មានអ្នកស្គាល់បញ្ហាជីវិតនិងបញ្ហាលោកដែរ ។ តួយ៉ាងដែលគេបានឃើញដោយអាស្រ័យប្រវត្តិសាស្ត្រ មានច្រើនពន់ពេកណាស់ ជាអាទិ៍ គ្រូទាំងឡាយ ៦ ។ល។ ជាពិសេសតាបសឈ្មោះ អាឡារៈ និងឧទកៈ ដែលជាគ្រូរបស់ ពោធិសត្វសិទ្ធត្ថរបស់យើង ។ សាស្ត្រាចារ្យទាំងឡាយនេះ ក្នុងម្នាក់ៗសុទ្ធតែមានសិស្សរៀនវិជ្ជានៅក្នុងសំណាក់ មានចំនួនរាប់រយពាន់ឡើងទៅ ។ ការរស់នៅរបស់មនុស្សក្នុងសម័យនោះ ក៏មានលក្ខណៈច្រើនបែប, ច្រើនយ៉ាង, គំនិតរបស់មនុស្សមានគុណភាពមិនត្រូវគ្នា, វិញ្ញាណរបស់មនុស្សមានភាពល្អអាក្រក់ផ្សេងៗគ្នា ។ល។ គុណសម្បត្តិ និងគុណវិបត្តិរបស់មនុស្សទាំងអស់នេះ លោកថាកើតឡើងដោយអាស្រ័យការសេពគប់, ទំរើក្នុងជាតិមុន, ទំរើក្នុងជាតិនេះ, និងវត្ថុជុំវិញមួយអន្លើដោយធាតុអាកាសក្នុងកន្លែងដែលគេរស់នៅ ។ ដូចនេះ, យើងនឹងដៅស្មានថា ក្នុងពេលមុនព្រះពុទ្ធត្រាស់ មនុស្សទាំងឡាយគ្មានសមត្ថភាព, គ្មានការសិក្សាអប់រំ, គ្មានធ្វើការស្រាវជ្រាវ, គ្មានចំណេះវិជ្ជាខ្ពស់ដូចបច្ចុប្បន្នកាលនេះ ក៏វាពុំត្រូវទាំងអស់ដែរ ។ ព្រោះអ្វី? ព្រោះគេបានដឹងនូវការវិវត្តន៍របស់មនុស្ស តាមផ្លូវប្រវត្តិសាស្ត្រថា មនុស្សបានទទួលសេចក្តីចម្រើនលូតលាស់ តាំងពីមុនពុទ្ធកាលជាច្រើនសតវត្សដែរ តែកម្ពស់នៃវឌ្ឍនភាពក្នុងជំនាន់នោះ ខាងសម្ភារៈនិយមមានកម្លាំងទន់ខ្សោយជាងចិត្តនិយម ។ មកដល់ពុទ្ធសម័យហើយ គេបានដឹងថាមនុស្សមានសមត្ថភាព ចេះបង្ហាត់ចិត្តរបស់ខ្លួន ឲ្យបានសម្រេចនូវគុណសម្បត្តិម៉្យាងដែលគេឲ្យឈ្មោះថា «ឈាន» គុណធម៌នេះបានធ្វើឲ្យគេមានប្រសិទ្ធិភាពជប់និម្មិតតំណែងខ្លួនធ្វើជានេះ ជានោះ រហូតដល់ប្រើឫទ្ធិបែបនេះ ហោះហើរមុជជ្រែកបានផង ។ នេះជាសេចក្តីចម្រើនលូតលាស់ខាងផ្លូវចិត្ត, ផ្លូវវិញ្ញាណដែលមានចែងក្នុងប្រវត្តិសាស្ត្រ សាសនា ក្នុងចំណុចស្តីដល់កម្លាំងចិត្តដែលគេបានហ្វឹកហាត់ តាមកម្មវិធីពុទ្ធយោគនិងព្រាហ្មណ៍យោគ ។ ដោយអាស្រ័យប្រវត្តិសាស្ត្រសាសនាដែលគេបានដឹងទៀតថា ក្នុងសម័យនៃការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ដែលកំពុងប្រព្រឹត្តទៅគឺព្រះអង្គកំពុងសម្តែងធម៌បំភ្លឺសត្វលោក មានសាកលវិទ្យាល័យមួយ ដែលបានបង្កើតក្នុងនគរតក្កសិលា ហើយក្នុងជំនាន់នោះគេឲ្យឈ្មោះថា **«មហាសាលាទិសាបាមោក្ខ»** ក៏មានកម្មវិធីសិក្សា ខាងវិទ្យាសាស្ត្រគ្រប់ផ្នែកដែរ, ជាពិសេសផ្នែកវិជ្ជាពេទ្យ ដែលគេបានដឹងរឿងដោយអាស្រ័យជីវប្រវត្តិនៃកុមារភច្ចៈ ជាកូនចិញ្ចឹមរបស់ស្តេចពិម្ពិសារ បានត្រូវឪពុកចិញ្ចឹមបញ្ជូនទៅរៀនក្នុងសាលានោះ ។ ក្រោយមកយុវជននេះ បានសម្រេចវិជ្ជាពេទ្យ បានទទួលមហាបរិញ្ញាប័ត្រ មានឋានៈជាវេជ្ជបណ្ឌិត មានសម្ថភាពព្យាបាលជម្ងឺគ្រប់យ៉ាង រហូតដល់ធ្វើការពុះវះបានមានប្រសិទ្ធិភាពស្មើនឹងគ្រូពេទ្យសម័យបច្ចុប្បន្ន ឬខ្ពស់លើសទៀតផង បើតាមព័ត៌មានដែលចែងជាប្រវត្តិក្នុងគម្ពីរនៃពុទ្ធសាសនារបស់យើង ។នេះគឺជាសេចក្តីចម្រើនលូតលាស់ខាងសម្ភារៈក្នុងកាលនោះ ដែលពុទ្ធសាសនិកទូទៅនិងអ្នកស្រាវជ្រាវគ្រប់ផ្នែក បានដឹងឮ បើមិនច្រើនក៏តិចដែរ ។

ដោយអាស្រ័យព្រឹត្តការណ៍ខាងលើនេះ, យើងមិនអាចធ្វើជាមិនដឹងមិនឮកើតទេ ។ ព្រមគ្នានេះទៀត, យើងក៏មិនអាចបដិសេធថា មុនពុទ្ធកាលគ្មានធម៌វិន័យ គ្មានការប្រព្រឹត្តប្រតិបត្តិ គ្មានអ្នកស្រាវជ្រាវ គ្មានអ្នកបានសម្រេចគុណសម្បត្តិនាៗ រហូតដល់គ្មានរកឃើញធម៌គ្រប់យ៉ាង វិន័យគ្រប់ជំពូកលើកលែងតែអរិយសច្ចៈ ៤ បានឡើយ ។

**អរិយសច្ចៈ ៤** :

**១- ទុក្ខសច្ចៈ** ភាពពិតនៃទុក្ខ ។

**២- សមុទយសច្ចៈ** ភាពពិតនៃហេតុរបស់ទុក្ខ ។

**៣- និរោធសច្ចៈ** ភាពពិតនៃសេចក្តីរលត់ទុក្ខ ។

**៤- មគ្គសច្ចៈ** ភាពពិតនៃផ្លូវដើរទៅកាន់សេចក្តីរលត់ទុក្ខ ។

ន័យមួយទៀតមានអរិយៈសព្ទនៅក្នុងចន្លោះកណ្តាល :

**១- ទុក្ខអរិយសច្ចៈ** ការស្គាល់ទុក្ខជាភាពពិតប្រសើរ ។

**២- សមុទយអរិយសច្ចៈ** ការលះបង់នូវហេតុនៃទុក្ខជាភាពពិតប្រសើរ ។

**៣- និរោធអរិយសច្ចៈ** សេចក្តីរលត់ទុក្ខជាភាពពិតប្រសើរ ។

**៤- មគ្គអរិយសច្ចៈ** ផ្លូវទៅកាន់ទីរម្លត់ទុក្ខជាភាពពិតប្រសើរ ។

ន័យមួយទៀតមានអរិយៈសព្ទនៅចន្លោះកណ្តាលដូចគ្នាតែគ្មានសេចក្តីប្រែ :

**១- ទុក្ខអរិយសច្ចៈ** សេចក្តីទុក្ខជាភាពពិតនៃព្រះអរិយបុគ្គល ។

**២- សមុទយអរិយសច្ចៈ** ការលះបង់នូវហេតុនៃទុក្ខជាភាពពិតនៃព្រះអរិយបុគ្គល ។

**៣- និរោធអរិយសច្ចៈ** សេចក្តីរម្លត់ទុក្ខជាភាពពិតនៃព្រះអរិយបុគ្គល ។

**៤- មគ្គអរិយសច្ចៈ** ផ្លូវទៅកាន់ទីរម្លត់ទុក្ខជាភាពពិតនៃព្រះអរិយបុគ្គល ។

ន័យមួយទៀតមានតែពាក្យដើម គ្មានកណ្តាលនិងចុង :

**១- ទុក្ខៈ** សេចក្តីទុក្ខ ។

**២- សមុទយៈ** ហេតុនៃសេចក្តីទុក្ខ ។

**៣- នរោធៈ** ភាពនៃសេចក្តីរលត់ទុក្ខ ។

**៤- មគ្គៈ** ផ្លូវទៅកាន់ភាពរលត់ទុក្ខ ។

ពាក្យថា «**ទុក្ខ**» លោកដៅយកភាពអត់, ភាពទ្រាំ, ភាពធុន់, ភាពខំ, ភាពប្រឹង, ភាពទប់, ភាពទល់, ភាពទ្រ, ។ល។ ក្នុងន័យថា ទ្រាំកើត, ទ្រាំរស់, ទ្រាំចាស់, ទ្រាំឈឺ, ទ្រាំស្លាប់, ទ្រាំក្រៀមក្រំ, ទ្រាំខ្សឹកខ្សួល, ទ្រាំលើទ្រាំ, ទ្រាំថ្នាំងថ្នាក់, ទ្រាំសេចក្តីចង្អៀតចង្អល់, ទ្រាំប្រើរបស់មិនជាទីស្រឡាញ់, ទ្រាំបាត់បង់របស់ជាទីស្រឡាញ់, ប្រាថ្នាចង់បានរបស់ណា មិនបានរបស់នោះទ្រាំភាពមិនបាននោះ, ទ្រាំភាពមានខន្ធប្រាំ នេះជាទុក្ខដុំធំៗ ។ ទ្រាំស្រេក, ឃ្លាន, ក្តៅ, ត្រជាក់ ។ ទ្រាំបរិភោគកាម, ទ្រាំស៊ី, ផឹក, ខ្លាច, ហ៊ាន, ដេក, ដើរ, ឈរ, អង្គុយ, ។ល។ នេះជាទុក្ខដុំតូចៗ ។ ទ្រាំស្រឡាញ់, ទ្រាំស្អប់, ទ្រាំជំលោះ, ទ្រាំសប្បាយ, ទ្រាំក្រ, ទ្រាំមាន, ទ្រាំតូច, ទ្រាំធំ ។ល។ នេះជាទុក្ខគ្រាច់ចរ តាមពេលវេលា ។ ក្នុងន័យថា សត្វលោករស់នៅក្នុងទម្រាំទាំងមាន ទាំងក្រ ទាំងគ្មាន គ្រប់ៗអាត្មា គ្រប់ៗភព ។ នេះឯងគឺទុក្ខសច្ចៈ ។

ពាក្យថា «**សមុទយៈ**» ន័យទី ១ លោកដៅយកតណ្ហា (ចំណង់, បំណង, ប្រាថ្នា . . . ) ដោយន័យថា ចង់បានរូប, សំឡេង, ក្លិន, រស, ផ្សព្វ ។ ចង់ថែរក្សាទុកនូវរូប, សំឡេង, ក្លិន, រស, ផ្សព្វ ។ នេះហៅ**កាមតណ្ហា**

ឬ**ចំណង់ក្នុងកាម** ឬ**ចំណូលក្នុងវត្ថុកាម** បានដល់រូប, សំឡេង, ក្លិន, រស, ផ្សព្វ ។

ន័យទី ២ លោកដៅយកភព, លំនៅ, កន្លែង, ជម្រក, ជំរំ, កេរ្តិ៍ឈ្មោះ, យស, ស័ក្តិ, អំណាច, តំណែង, តំណាំង ។ល។ ដោយន័យថា ចង់បានភព, ចង់បានឋានៈ, ចង់បានលំនៅ, ចង់បានកន្លែង, ចង់បានជម្រក, ចង់បានជំរំ, ចង់បានកេរ្តិ៍ឈ្មោះ, ចង់បានយស, ចង់បានស័ក្តិ, ចង់បានអំណាច, ចង់បានតំណែង, ចង់បានតំណាំង ឬ ចង់បានកៅអី ឬចង់បានមកុដ ។ល។

ន័យទី ៣ លោកដៅយកវិភព (គ្មានភព) មិនមានឋាន, មិនមានលំនៅ, មិនមានកន្លែង, មិនមានជម្រក, មិនមានជំរំ, មិនមានកេរ្តិ៍ឈ្មោះ, មិនមានយស, មិនមានស័ក្តិ, មិនមានអំណាច, មិនមានតំណែង, មិនមានតំណាំង ។ល។ បានន័យថា ចង់បានគ្មានភព, ចង់បានគ្មានឋាន, ចង់បានគ្មានលំនៅ, ចង់បានគ្មានកន្លែង, ចង់បានគ្មានជម្រក, ចង់បានគ្មានជំរំ, ចង់បានគ្មានកេរ្តិ៍ឈ្មោះ, ចង់បានគ្មានយស, ចង់បានគ្មានស័ក្តិ, ចង់បានគ្មានអំណាច, ចង់បានគ្មានតំណែង, ចង់បានគ្មានតំណាំង ឬចង់បានគ្មានកៅអី ឬចង់បានគ្មានមកុដ ។ល។

សេចក្តីអធិប្បាយ : សត្វលោកក្នុងសកលពិភព មិនថាសត្វប្រភេទណា មានភេទជាអ្វី, ឋិតនៅក្នុងវ័យណាទេ ។ ជាពិសេសសត្វមនុស្ស រមែងមានធាតុចំណង់មួយៗនៅក្នុងអាត្មា, បើមិនយ៉ាងដូចនេះ ក៏យ៉ាងដូចនោះ ឬគ្រប់យ៉ាងទាំងអស់តែម្តងក៏មាន ។ ពួកខ្លះចង់បានកាម, ខ្លះចង់បានភព, ខ្លះចង់បានគ្មានភព ។ ពួកចង់បានកាមលុះសម្រេចហើយចង់បានភព មិនចង់បានគ្មានភពទៀត ជាបន្តបន្ទាប់គ្នាឥតមានទីបំផុតឡើយ ។ ធាតុចំណង់នេះ ពុទ្ធសាសនាឲ្យឈ្មោះថា ជាធាតុបង្កើតទុក្ខ ឬមូលហេតុនៃទុក្ខ ឬជាប្រភពនៃទុក្ខ ។ ពុទ្ធសាសនាបានចែកអរិយសច្ចៈ ជាពីរគឺ :**ទុក្ខៈ** និង**សមុទយៈ** មួយគូនេះជាលោកិយធម៌ ។**និរោធៈ** និង **មគ្គៈ** មួយគូនេះជាលោកុត្តរធម៌ ។ គឺ**ទុក្ខៈ** ជាផលនៃលោកិយធម៌,**សមុទយៈ** ជាហេតុនៃលោកិយធម៌ ។**និរោធៈ** ជាផលនៃលោកុត្តរធម៌,**មគ្គៈ** ជាហេតុនៃលោកុត្តរធម៌ ។ នេះជាចំណែកដែលលោកបានធ្វើដោយចំពោះគឺក្នុងផ្ទៃនៃអរិយសច្ចធម៌ផ្ទាល់តែម្តង ។ តែក្នុងទីទូទៅ មានត្រឹមតែថា**ទុក្ខសច្ចៈ** ជាផលនៃកុសលផង អកុសលផង ។**សមុទយសច្ចៈ** ជាហេតុនៃកុសលផង អកុសលផង ។ រីឯ**និរោធសច្ចៈ** និង**មគ្គសច្ចៈ** លោកថាជាផលនិងជាហេតុនៃកុសលធម៌តែម៉្យាង ។ **សមុទយសច្ចៈ** អ្នកប្រាជ្ញខ្លះលោកថាជាអកុសល មិនមែនជាកុសលឡើយ ។ តែតំហាររបស់លោកនេះមុខជា នឹងមានចម្ងល់ថា បើ**សមុទយៈ** ជាហេតុនៃកុសលតែម៉្យាង ហេតុម៉េចបានជាទុក្ខទៅជាផលនៃកុសលផង និងអកុសលផង ។ ដោយអាស្រ័យពន្លឺនៃធម្មៈជាទូទៅ ខ្ញុំយល់ថា **សមុទយៈ** ត្រូវតែចាត់ចូលក្នុងផ្នែកកុសលផង អកុសលផងដែរ ទើបអស់បញ្ហាចោទ ហើយជាភាពពិតប្រាកដទៀតផង ប្រសិនបើយោលទៅតាមកុសលហេតុ និអកុសលហេតុដែលមានចែងអំពី កុសលមូល និងអកុសលមូលក្នុងគម្ពីរអភិធម្មនៃពុទ្ធសាសនាយើង ។ **សមុទយៈ** ជាហេតុនៃអកុសលធម៌ បានដល់ចំណង់របស់មនុស្សពួកមួយដែលនាំគ្នាបង្កើតអាវុធសម្រាប់ធ្វើសង្គ្រាម, សម្ភារៈសឹក ឬយោអបរិក្ខានាៗ មួយអន្លើដោយការធ្វើសង្គ្រាមរួមទាំងទំរើអាក្រក់ផ្សេងៗ ដែលគេបានធ្វើឲ្យខូចសន្តិសុខរបស់ មនុស្សសត្វ និងសន្តិភាពនៃពិភពលោកដែលគេបានស្គាល់គ្រប់គ្នាថា ជាទំរើបៀតបៀនអ្នកដទៃ ឬបំផ្លាញសេចក្តីសុខរបស់គេ ឬញ៉ាំងពិភពលោកឲ្យដល់នូវសេចក្តីវិនាស ។ **សមុទយៈ**ជាហេតុនៃកុសលធម៌បានដល់ចំណង់របស់មនុស្ស មួយពួកទៀតដែលខំប្រឹងបង្កើតគ្រឿងប្រដាប់សម្រាប់សន្តិភាព, សម្ភារៈសម្រាប់សន្តិសុខ ឬសុខបរិក្ខានាៗ មានជាអាទិ៍ វត្តអារាម លំនៅដ្ឋាន ផ្លូវថ្នល់ ស្ពាន ផ្សារ មន្ទីរពេទ្យ មណ្ឌលសុខភាព គិលានដ្ឋាន ។ល។ រួមទាំងទំរើល្អ តាមផ្លូវកាយ វាចា ចិត្តនានា ដែលគេបានធ្វើឲ្យមានសន្តិសុខសម្រាប់មនុស្សសត្វ និងសន្តិភាពជាបណ្តោះអាសន្ន ឬជាស្ថាពរសម្រាប់ពិភពលោក ដែលគេស្គាល់គ្រប់គ្នាថា ជាទំរើបម្រើសេចក្តីសុខរបស់អ្នកដទៃ, បង្កើតវឌ្ឍនភាពទាំងផ្លូវចិត្ត ទាំងផ្លូវសម្ភារៈសម្រាប់

មនុស្ស ឬញ៉ាំងពិភពលោកឲ្យដល់នូវភាពលូតលាស់ចម្រុងចម្រើនគ្រប់វិស័យ ចំពោះតែវិស័យសម្រាប់ផ្តល់នូវសេចក្តីសុខសន្តិភាព ។ នេះឯងគឺ**សមុទយសច្ចៈ**។

ពាក្យថា «**និរោធ**» លោកដៅយកភាពរលត់សូន្យឈឹង ឬភាពរលត់ងស់ដោយគ្មានសេសសល់នូវតណ្ហាទាំង ៣ (កាមតណ្ហា, ភវតណ្ហា, វិភវតណ្ហា) ដែលសត្វលោកបានធ្វើការលះកាត់, ការផ្តាច់ជំនាប់ ការស្រាយចំណងដែលធ្លាប់មានក្នុងចិត្តរបស់គេ ដែលតណ្ហាបានបង្កើតតាំងពីយូរណាស់មកហើយ ដោយប្រើអាវុធ និងគ្រឿងសម្រាយ គឺធម្មៈជាន់ខ្ពស់ ឬមជ្ឈិមបដិបទា ។ ដោយអាស្រ័យទំរើនេះ ទើបគេមានចិត្តផុតស្រឡះចាកតណ្ហាចាកភាពអាលោះអាល័យគ្រប់បែបគ្រប់យ៉ាង ដែលបង្កើតឡើងដោយអវិជ្ជានិងតណ្ហា . . . ។ ក្នុងពេលនេះ, សេចក្តីទុក្ខទាំងឡាយ ក៏បានរលត់រលាយអស់ដោយមិនមានសេសសល់សូម្បីបន្តិចបន្តួចឡើយ ។ ក្នុងន័យថាអស់មានភាពទ្រាំទ្រទាំងឡាយ មានជាអាទិ៍ ទ្រាំសេចក្តីក្រីក្រ, ទ្រាំភាពមានទានស្កុកស្គម, ទ្រាំភាពគ្មានភាពខ្វះខាត, ទ្រាំធ្វើអ្នកធំ, ទ្រាំធ្វើអ្នកតូច, ទ្រាំធ្វើអ្នកជិះជាន់គេ, ទ្រាំរស់នៅជាជនរងគ្រោះ, ទ្រាំធ្វើជាអ្នកបំបាត់សេរីភាពគេ, ទ្រាំរស់នៅជាអ្នកគ្មាន ។ល។ ប្រែថា អស់អំណត់, អស់ទម្រាំ, អស់កំហំ, អស់បំរឹង, អស់ទំនប់, អស់ទំនល់, អស់ទំរាន់, អស់ទំហុញ, អស់តំហប់, អស់កម្តៅ, អស់សម្រេក, អស់គិលាន, អស់ចំណាស់, អស់កំណើត, អស់ជំហឺ ។ល។ នេះឯងគឺ**និរោធសច្ចៈ** ។

ពាក្យ «**មគ្គៈ**» លោកដៅយកផ្លូវប្រតិបត្តិ ឬផ្លូវសម្រាប់ដើរទៅកាន់ភាពរលត់ទុក្ខ ដែលគេស្គាល់គ្រប់គ្នាថា មជ្ឈិមាបដិបទា ឬអដ្ឋង្គិកមគ្គ មាន ៨ គឺ :

១- សម្មាទិដ្ឋិ គំហើញត្រូវ

២- សម្មសង្កប្បៈ តម្រិះត្រូវ

៣- សម្មាវាចា ពំនោលត្រូវ

៤- សម្មាកម្មន្តៈ ទំរើត្រូវ

៥- សម្មាអាជីវៈ របស់ត្រូវ (ភាពរស់ត្រូវ)

៦- សម្មាវាយាម កំហំត្រូវ

៧- សម្មាសតិ ពំញាក់ត្រូវ (ភាពរឭកត្រូវ)

៨- សម្មាសមាធិ លំនឹងត្រូវ (ភាពនឹងនត្រូវ)

មគ្គទាំង ៨ នេះ, បើនឹងហៅជាសិក្ខា ៣ វិញក៏បានគឺៈ សម្មាទិដ្ឋិនិង សម្មសង្កប្បៈ លោកសង្គ្រោះចូលបញ្ញាសិក្ខា ។ សម្មាវាចា, សម្មាកម្មន្តៈនិង សម្មាអាជីវៈ លោកសង្គ្រោះចូលក្នុងសីលសិក្ខា ។ សម្មាវាយាម, សម្មាសតិ និងសម្មាសមាធិ លោកសង្គ្រោះចូលចិត្តសិក្ខា ។ តែមានកន្លែងខ្លះអង្គមគ្គទាំង ៣ ខាងចុងនេះលោកសង្គ្រោះចូលក្នុងសមាធិសិក្ខាដូចនេះវិញក៏មាន ។ និរោធៈនិងមគ្គទាំងពីរនេះលោកចាត់ចូលក្នុងពួកលោកុត្តរធម៌ លោកពុំបានចាត់ចូលក្នុងលោកិយធម៌ទេ ដូចបានចែងមកក្នុងខាងដើមម្តងហើយ ។ ដូចនេះ, ពាក្យថាកុសល អកុសលក៏លោកពុំបានសង្គ្រោះចូលក្នុងអរិយសច្ចៈពីរខាងចុងនេះទេ ។ ព្រោះអ្វី? ព្រោះលោកុត្តរធម៌ជាធាតុមិនមានកុសលអកុសលឡើយ ។ ចំណាត់របស់លោកក្នុងរឿងនេះត្រឹមត្រូវហើយ ។ តែដែលលោកចាត់អរិយសច្ចៈពីរខាងចុងជាលោកុត្តរធម៌តែម្យ៉ាង ពុំបានចាត់ចូលក្នុងលោកិយធម៌ផងនោះ, យោបល់ខ្ញុំថា លំបាកយល់, លំបាកអនុវត្តបន្តិចហើយ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយចុះ យើងត្រូវគិតគូរទាំងអស់គ្នាឡើងវិញថា ក្នុងទីទូទៅ ជាពិសេសគម្ពីរអង្គុត្តរនិកាយទុក្កនិបាត លោកបានចាត់ធម៌ទាំងឡាយជាពីរពួកគឺ : ជាលោកិយធម៌ ១, ជាលោកុត្តរធម៌ ១ ដែរ ។ ដោយសំអាងលើចំណាត់ ក្នុងគម្ពីរនោះផង,

លើហេតុផលជាទូទៅក្នុងគម្ពីរទាំងឡាយមួយអន្លើដោយគំនិតរបស់បណ្ឌិតទាំងឡាយក្នុងពុទ្ធសាសនាផង ។ យើងត្រូវតែមានសេចក្តីក្លាហាន សូមអភ័យទោសអំពីលោកដែលបានចាត់អរិយសច្ចៈ ពីរខាងចុងជាលោកុត្តរតែម៉្យាង ថាជាចំណាត់ត្រឹមត្រូវហើយ ព្រោះអរិយសច្ចៈ ៤, ពីរខាងដើមជាលោកិយធម៌ ពីរខាងចុងជាលោកុត្តរធម៌ ។ តែយើងសូមមិនចាត់ទេសូមត្រឹមថា អរិយសច្ចៈពីរខាងចុងនេះ បើមនុស្សបុថុជ្ជកំពុង បានសម្រេច ឬកំពុងដើរ ឬកំពុងប្រតិបត្តិ ឬកំពុងរស់នៅក្នុងធម៌នេះ ឬមួយយកធម៌នេះមកប្រើជាផ្លូវលោកិយ, យើងសូមឲ្យឈ្មោះធម៌នេះថា លោកិយធម៌ លុះបុគ្គល ឬបុថុជ្ជនបានសម្រេចអរិយមគ្គ អរិយផលហើយ យើងសូមឲ្យឈ្មោះធម៌នេះថា លោកុត្តរធម៌ ។ ទំរើនេះ យើងពុំបានធ្វើដោយព្រហើនទេ គឺធ្វើដោយសភាពទន់ភ្លន់ ដើម្បីឲ្យអ្នកគោរពប្រតិបត្តិពុទ្ធសាសនាងាយយល់ ហើយហ៊ានអនុវត្តប៉ុណ្ណោះ ។

ធម៌ទាំងឡាយ, ដែលលោកបានប្រាប់ចំនួនក្នុងបិដកទាំងបីថា មានប្រាំបីម៉ឺនបួនពាន់ធម្មក្ខន្ធនោះ មិនមានខន្ធណាមួយនៅក្រៅអរិយសច្ចៈ ៤ នេះទេ ឬពុំមានខន្ធណាមួយចេញរួចផុតស្រឡះពីអរិយសច្ចៈ ៤ ឡើយ (ចតុរារិយសច្ចវិនិមុត្តោ) អ្នកប្រតិបត្តិធម៌ទាំងអស់ ដែលមានគោលដៅដើម្បីសម្រេចមគ្គផលនិព្វាន គឺត្រូវអាស្រ័យអរិយសច្ចៈ ៤ ជាពិសិដ្ឋដែរ (មគ្គាយុគ្គាផលាចេវ ចតុសច្ចវិនិស្សដ្ឋា) ។ អរិយសច្ចៈ ៤ ដែលត្រាស់ដឹង ឬដែលស្រាវជ្រាវរាវរកឃើញ ដោយព្រះសម្មាសម្ពុទ្ធ ត្រូវបានមុនីទាំងឡាយ ជាពិសេសគឺព្រះសម្មាសម្ពុទ្ធផ្ទាល់តែម្តងទុកដាក់ជាមូលដ្ឋាន ឬជាឫសគល់របស់ធម៌ទាំងឡាយផង ជាកំពូល ឬជាត្រួយរបស់ធម៌ទាំងឡាយផង ។ ដូចនេះព្រោះអ្វី? ព្រោះអ្នកស្រាជ្រាវជាទូទៅផ្នែកសាសនា មួយអន្លើដោយបណ្ឌិតទាំងឡាយក្នុងពុទ្ធសាសនាមានគំហើញត្រូវគ្នា ក្នុងចំណុច ១ គឺបឋមទេសនា ដែលព្រះសម្ពុទ្ធព្រះអង្គបានធ្វើ បានមានព្រះតម្រាស់ដល់តាបសទាំង ៥ រូប ដែលគេស្គាល់គ្រប់គ្នាថា បញ្ចវគ្គីនោះ មិនមែនធម៌ណាដទៃទេ គឺអរិយសច្ចធម៌នេះឯង ។ បើទោះណាជាមានធម៌ទាំងឡាយ ដទៃមានអនិច្ចលក្ខណធម៌ និងអនត្តលក្ខណធម៌ជាដើមនៅក្នុងនោះផង នៅពេលសម្តែងនោះក៏វាមានអត្ថន័យជា អរិយសច្ចធម៌ដដែល ។ បើមិនដូចនេះទេ ព្រះធម្មទេសនារបស់ព្រះសម្មាសម្ពុទ្ធនឹងត្រូវមានឈ្មោះជាច្រើន មិនត្រឹមតែបឋមទេសនាទេ គឺមានទុតិយ ឬតតិយ ឬក៏ចតុត្ថទេសនា ។ល។ ទៅហើយ ។ ក្នុងបឋមទេសនា, កាលណាគេធ្វើការសង្គ្រោះ ឬវែកញែកឲ្យអស់ជើងទៅ គេនឹងឃើញថាក្នុងបឋមទេសនាមានន័យទូលំទូលាយណាស់ មានជម្រៅស្ទើរតែមិនមានទីបំផុត មានអត្ថរសជាពិសេស មិនអាចរករសដទៃមកប្រៀបផ្ទឹមបាន ។ ម៉្យាងទៀត, អ្នកប្រាជ្ញទាំងឡាយដដែលនេះ បានមានយោបល់ស្របគ្នាក្នុងចំណុចមួយថា : អរិយសច្ចធម៌មិនត្រូវទុកដាក់ត្រឹមតែជាមូលដ្ឋាន ឬជាឫសគល់របស់ធម៌ទាំងឡាយប៉ុណ្ណឹងទេ គឺត្រូវចាត់ទុកជាកំពូល ឬជាត្រួយរបស់ធម៌ទាំងឡាយដទៃទៀតផង ។ ហេតុអ្វី? ហេតុថាព្រះសម្មាសម្ពុទ្ធ ទោះជាសម្តែងធម៌ណាក៏ដោយ ពេលបញ្ចប់ព្រះអង្គតែងបញ្ចប់ ដោយអរិយសច្ចធម៌ជាដរាប ។ ក្នុងន័យថា ធម៌ទាំងឡាយត្រូវផ្តើមកើតឡើងមានជាដំបូង ដោយអាស្រ័យអរិយសច្ចៈត្រូវចប់ ឬត្រូវអស់ទៅវិញក៏ដោយអាស្រ័យ អរិយសច្ចៈនេះដូចគ្នា ។

ដើម្បីអ្នកអានមានពន្លឺក្នុងរឿងនេះកាន់តែច្បាស់, ខ្ញុំសូមធ្វើសេចក្តីពន្យល់មានដូចនេះ : បុញ្ញកិរិយាវត្ថុទាំងឡាយ ៣ (ទាន, សីល, ភាវនា) ទានកើតមានព្រោះអ្វី? ព្រោះជីវិតរបស់មនុស្សបានត្រូវជួបប្រទះសេចក្តីទុក្ខ, សេចក្តីទុក្ខបានធ្វើឲ្យជីវភាពរបស់មនុស្សសត្វ ធ្លាក់ចុះដុនដាប ។ សីលកើតមានព្រោះអ្វី? ព្រោះជីវិតរបស់មនុស្សសត្វបានត្រូវជួបប្រទះសេចក្តីទុក្ខ ដោយអាស្រ័យទំរើជិះជាន់ បៀតបៀនរបស់អ្នកដទៃ ។ ភាវនាកើតមានព្រោះអ្វី? ព្រោះជីវិតមនុស្សសត្វបានត្រូវជួបប្រទះសេចក្តីទុក្ខ ដោយអាស្រ័យសម្លាញ់ សំអប់ កម្លាច កម្លៅ ដែលជាធាតុនាំបង្ករឿង, បង្កើតជម្លោះ, និយមសង្គ្រាម, និយមជាតិសាសន៍, ពូជព័ន្ធវង្សត្រកូល អម្បូរវណ្ណៈ, និយមអាត្មា,

និយមអំណាច, និយមយស, និយមស័ក្តិ ។ល។ ក្នុងន័យថា ទាន, សីល, ភាវនា ត្រូវបង្កើតឲ្យមានដើម្បីបំបាត់ ឬបន្ធូរទុក្ខ និងបន្ថយតណ្ហាឲ្យមានកម្លាំងខ្សោយចុះបន្តិចម្តងៗ លុះត្រារលាយសូន្យបាត់ក្នុងទីបំផុត ។ សេចក្តីនេះ, បញ្ជាក់ឲ្យឃើញថា ធម៌ទាំងឡាយមិនថាធម៌ណាជាធម៌ណាទេ ឲ្យតែធម៌ដែលត្រាស់ដឹង ឬសម្តែងដោយព្រះសម្មាសម្ពុទ្ធ សុទ្ធតែកើតឡើងដោយអាស្រ័យអរិយសច្ចៈ ៤ ឬមានអរិយសច្ចៈ ៤ ជាមូលដ្ឋាន ឬជាកំពូល ។ លើកលែងតែធម៌សម្រាប់សូត្របន់ស្រន់ ឬសូត្រអំពាវនាវសុំសេចក្តីសុខ អំពីវត្ថុទាំងឡាយដែលអ្នកផងចូលចិត្តថាខ្លាំងពូកែ ឬមានភាពស័ក្តិសិទ្ធិ ដែលអាចមានព្រះពុទ្ធបរមគ្រូ ឬព្រះត្រៃរ័ត្ននៅក្នុងនោះផង ហើយដែលត្រូវបានឲ្យឈ្មោះថា សទ្ធម្មប្បដិរូប គឺធម៌បន្ថែម បន្ថយថ្មី មិនមែនជាពុទ្ធធម៌ ។ ប៉ុន្តែសូម្បីធម៌នេះក៏ដោយយោបល់ខ្ញុំថា កើតមានឡើងដោយអាស្រ័យអរិយសច្ច ៤ ផងដែរ ។ ដូចនេះព្រោះអ្វី? ព្រោះធម៌បន់ស្រន់បួងសួងសុំសេចក្តីសុខក៏មកតែពីមានទុក្ខហ្នឹងដែរ តែទំរើនេះខុសទេ ។ ហេតុអ្វី? ហេតុថា ព្រះសម្មាសម្ពុទ្ធបានសម្តែងច្បាស់ណាស់ថា សេចក្តីសុខទុក្ខ មិនមែនជាធាតុត្រូវបានដោយអាស្រ័យទំរើបន់ស្រន់ ឬធ្វើសំណូមទេ គឺត្រូវបានដោយអាស្រ័យទំរើដែលគេត្រូវធ្វើការងារ និងទំរើដែលគេបានធ្វើឲ្យអស់តណ្ហាតែប៉ុណ្ណោះ ។

ចំណុចមួយទៀត, ដែលខ្ញុំត្រូវធ្វើសេចក្តីបំភ្លឺក្នុងទីនេះដែរនោះ គឺត្រង់សំណួរមួយដែលខ្ញុំ តែងជួបប្រទះរឿយៗ ថាពុទ្ធសាសនានៃយើង កាលណាអឺយឡើងដល់លោកគ្មានឮអ្វីក្រៅពីទុក្ខទេ ។ នេះក៏ទុក្ខ, នោះក៏ទុក្ខ, ទុក្ខមួយចប់គ្មានសល់អ្វីឡើយ ។ បើដូចនេះ, យើងគួរប្រកាន់យក ឬគួរមានជំនឿថា ពុទ្ធសាសនាជាមួយនឹងលោកមានគំហើញថា **សុទិដ្ឋិនិយម** ឬ **ទុទិដ្ឋិនិយម** ។ ចំពោះសំណួរមួយនេះខ្ញុំសូមឲ្យចម្លើយថា ពុទ្ធសាសនាគ្មានបានធ្វើការកត់សម្គាល់ ឬគ្មានឃើញថាលោកអាក្រក់ទេ ។ ពុទ្ធសាសនាបានធ្វើការកត់សម្គាល់ ឬមានគំហើញថាលោកល្អ, លោកមានលក្ខណៈគួរឲ្យចាប់អារម្មណ៍, គួរឲ្យគយគន់ពេកណាស់ ។ តែមានពេលខ្លះ, លោកប្រែក្លាយទៅជាមិនល្អ ។ ការក្លាយភាពរបស់លោកពីល្អទៅអាក្រក់នេះ វាមិនមែនប្រែក្លាយទៅកើតឯងៗដោយគ្មានហេតុបច្ច័យទេ គឺវាមាន ហេតុបច្ច័យច្រើនណាស់ ហើយក្នុងបណ្តាហេតុបច្ច័យទាំងឡាយនោះមានហេតុ ៦ នៅក្នុងនោះផង ។ ហេតុ ៦ បានដល់អ្វី? លោភៈ ទោសៈ មោហៈ ៣ នេះជាអកុសលធ្វើឲ្យលោកអាក្រក់ ឬធ្វើឲ្យលោកវិនាសអន្តរាយខូចខាតច្រើនតិចតាមកម្លាំងអកុសលមូលនេះ ដែលមានថាមភាពខ្សោយ ឬខ្លាំង ។ អលោភៈ អទោសៈ អមោហៈ ៣ នេះជាកុសលធ្វើឲ្យលោកល្អ ឬធ្វើឲ្យមានវឌ្ឍនភាពលូតលាស់ ដុះដាលច្រើនតិចតាមកម្លាំងកុសលមូលនេះ ដែលមានថាមភាពខ្សោយ ឬខ្លាំង ។ ដោយហេតុពុទ្ធសាសនាមានសុទិដ្ឋិនិយមចំពោះលោកជាទូទៅជាពិសេសមនុស្សលោក ទើបពុទ្ធសាសនាបង្រៀនឲ្យស្គាល់ទុក្ខ, កត់សម្គាល់នូវទុក្ខរំពឹងគិតដល់ទុក្ខ ។ ព្រមគ្នានេះ, ឲ្យលះបង់អកុសលមូល, លះបង់តណ្ហាដែលជាហេតុនៃទុក្ខ ។ ប្រសិនបើពុទ្ធសាសនាមានទុទិដ្ឋិនិយមចំពោះលោកនោះរបៀបដោះស្រាយ ឬផ្លូវ ៨ ប្រការក៏ពុំមាននិយាយដែរ ។ ប្រែថា លោកគ្មានអាក្រក់ទេ, តែហេតុបច្ច័យទាំងឡាយ ដែលមនុស្សយើងមើលមិនឃើញ គិតមិនយល់នោះទេដែលធ្វើឲ្យលោកបានទទួលនូវភាពអាក្រក់, ភាពល្អ ។ កាលណាមនុស្សយើង បានស្គាល់ទុក្ខ, ខ្លាចទុក្ខហើយខំប្រឹងប្រតិបត្តិធម៌តាមការចេះដឹង តាមពាក្យណែនាំរបស់ពុទ្ធសាសនាមិនយូរប៉ុន្មាន យើងនឹងបានរួចចាកសេចក្តីទុក្ខជាមិនខាន ។ ដូចនេះ, ពុំនោលរបស់ពុទ្ធសាសនាថា ទុក្ខៗ ទុក្ខៗ . . . នេះ ពុំមែនមានន័យថា ពុទ្ធសាសនាជា**ទុទិដ្ឋិនិយម** ចំពោះលោកទេ គឺមានន័យថា បន្លាចឲ្យគេមានផ្ចង់គំនិតក្នុងរឿងទុក្ខនេះជាមុនសិនទើបបង្រៀនឲ្យចេះចាំបំភ្លឺឲ្យយល់ស្គាល់ជាក្រោយ ។ លុះចំណេះ និងសម្គាល់របស់យើងបានចាស់ក្លាទុំជោរហើយយើងក៏ច្រានទុក្ខចោល តាមរបៀននិងពន្លឺ ដែលពុទ្ធសាសនាបានធ្វើឲ្យយើងក្នុងពេលនោះទៅ ។

សេចក្តីសរុប : អរិយសច្ចធម៌ ៤ ជាពុទ្ធសាសនា ពុទ្ធសាសនាជាអរិយសច្ចធម៌ ៤ ។ ធម៌ទាំងឡាយមាន

អរិយសច្ចធម៌ជាមូលដ្ឋាន ឬជាឫសគល់ ឬជាកំណើត ។ ទន្ទឹមគ្នានេះ, ធម៌ទាំងឡាយមានអរិយសច្ចធម៌ជាកំពូល ឬជាត្រួយ ឬជាជំនួប ។ ក្នុងន័យថា ធម៌ទាំងឡាយកើតចាកអរិយសច្ចធម៌ ជួបចប់ជាមួយអរិយសច្ចធម៌ ។ អរិយសច្ចធម៌ ៤ ជាធម៌ពិត, ជាធម៌ដែលរកឃើញ ឬសម្ដែងដោយព្រះសម្មាសម្ពុទ្ធបរមគ្រូ, ជាពុទ្ធភាសិតសុទ្ធ មិនមែនជាសាវ័កភាសិត, ឥសិភាសិត, ទេវតាភាសិតដូចធម៌ទាំងឡាយដទៃឡើយ ។ ធម៌ពិតមានន័យថា ពិតជាមានទុក្ខ, ពិតជាមានហេតុនៃទុក្ខ, ពិតជាមានភាពរលត់ទុក្ខ, ពិតជាមានផ្លូវទៅកាន់ភាពរលត់ទុក្ខ ។ គឺមានហេតុនិងផលទាក់ទងគ្នាមួយគូៗ ។ អរិយសច្ចៈ ៤ ក្នុងកន្លែងខ្លះឃើញមានត្រឹមតែពីរគឺ : មានតែហេតុនៃទុក្ខ និងនិរោធជាផលនៃមគ្គប៉ុណ្ណោះ ។ ការបង្រួមអរិយសច្ចៈ ៤ នៅត្រឹមតែពីរ ឬនៅត្រឹមតែមួយគូមាន សំអាងលើថេរវាចារបស់ព្រះអស្សជិដែលលោកបានធ្វើចំពោះ**ឧបតិស្សមាណព** ថា: «**យេធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ តេសញ្ច យោ និរោធោ ច ឯវំ វាទី មហាសមណោ**» «ធម៌ទាំងឡាយណា មានហេតុជាដែនកើត ព្រះតថាគតបានពោលដល់ហេតុនៃធម៌ទាំងឡាយនោះផង ដល់ការរលត់នៃធម៌ទាំងឡាយ នោះផង ព្រះមហាសមណៈ មានពំនោលយ៉ាងនេះជាប្រក្រតី» ។

**ទុក្ខៈ** មាន ១២ កង :

**១- ជាតិទុក្ខ** ព្រោះកំណើត,

**២- ជរាទុក្ខ** ព្រោះចំណាស់,

**៣- ព្យាធិទុក្ខ** ព្រោះជំងឺ

**៤- មរណទុក្ខ** ព្រោះសម្លាប, (ភាពស្លាប់)

**៥- សោកទុក្ខ** ព្រោះក្រៀមក្រំ,

**៦- បរិទេវទុក្ខ** ព្រោះខ្សឹកខ្សួល,

**៧- ទោមនស្សៈ** ព្រោះថ្នាំងថ្នាក់,

**៨- ឧបាយាសៈ** ព្រោះចង្អៀតចង្អល់,

**៩- អប្បិយេហិ សម្បយោគៈ** ព្រោះមានជំនួបរបស់មិនពេញចិត្ត,

**១០- បិយេហិ វិប្បយោគៈ** ព្រោះបាត់បង់របស់ពេញចិត្ត,

**១១- យម្បិច្ឆំ ន លភតិ តម្បិ** ព្រោះមិនបានដូចបំណង,

**១២- ព្រោះខន្ធ ៥** ។

មានទុក្ខក្រៅពីនេះច្រើនទៀត ដែលលោកសង្គ្រោះចូលក្នុងទុក្ខ ១២ ឬ ១៣ កង (ញែកទុក្ខចេញពីទោមនស្សៈ) ដែលមានន័យថា**ទុក្ខ**ហើយ**ទុក្ខ**ទៀត ឬ**ទុក្ខ**ត្រួតលើ**ទុក្ខ** ឬជាតុ**ទុក្ខ**និងជាតុ**ទុក្ខ** ត្រូវបានប៉ះទង្គិចគ្នា ។**ទុក្ខ**ទាំងឡាយនោះមានឈ្មោះផ្សេងៗគ្នា ជា **បកិណ្ណកទុក្ខ**ខ្លះ ជា**គោចរទុក្ខ**ខ្លះ ។ល។ ដែលខ្ញុំសូមមិនសរសេរក្នុងទីនេះទៀតឡើយ ព្រោះក្នុងឃ្លាដែលនិយាយពីអត្ថន័យរបស់ទុក្ខក្នុងខាងដើមនោះ ខ្ញុំបានធ្វើសំនេរអំពីរឿង នេះខ្លះៗមកហើយដែរ ។

**សមុទយៈ**មាន ៣ :

១- កាមតណ្ហា ប្រាថ្នាកាម ។

២- ភវតណ្ហា ប្រថ្នាមាន ។

៣- វិភវតណ្ហា ប្រាថ្នាគ្មាន ។

ដើម្បីកុំឲ្យអ្នកអានលំបាកយល់រឿងនេះ ខ្ញុំសូមធ្វើសេចក្ដីបំភ្លឺយ៉ាងខ្លីថា : ប្រាថ្នាកាម គឺចង់បានតែរូប,

សំឡេង, ក្លិន, រស, ផ្សព្វ, ប៉ុណ្ណោះ ។ ប្រាថ្នាមាន គឺចង់បានកេរ្តិ៍ឈ្មោះ, យស, ស័ក្តិ, អំណាច, កម្លាំង, កម្ពស់, ទំហំ, ទំហត់, ចម្បង, ចម្បាំង, ជម្លោះ ។ល។ ប្រាថ្នាគ្មាន គឺចង់បានអាកាស, វិញ្ញាណ, ឬអាត្មន, របស់ល្អិតផុតវិស័យធម្មតាមិនងាយនឹងកត់សម្គាល់បាន អភិសុខុមសញ្ញា សញ្ញាមានភាពល្អិតជាទីបំផុត ដល់ថ្នាក់ថាមានដូចជាគ្មាន, ថាគ្មានដូចជាមាន ។ ក្នុងន័យថា ចង់បានតែរបស់ណាដែលគ្មានភាពប្រាកដ គ្មានចំណាប់, គ្មានគំហើញ ។ គឺថាចង់បានតែ របស់ណាដែលស្ថិតនៅក្នុងលក្ខណៈចម្លែកត្រកាល ជាកំពូលនៃសេចក្តីល្អដែលមានភាពមិនប្រាកដដល់មនុស្សទូទៅ គ្មានអ្នកណាចាប់បាន គ្មានអ្នកណាមើលឃើញ គ្មានអ្នកណាចង់បាន ។ គឺភាពមិនប្រាកដដល់ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, ចិត្ត របស់មនុស្សទាំងឡាយ ។ បើនឹងស្តីថាចង់បានតែរបស់ណាដែលមិនមែនជាកាម មិនមែន ជាភព ។ តែជារបស់ផ្សេងពីរបស់ទាំងពីរដូចនេះវិញក៏បាន ។ ព្រោះអ្វី? ព្រោះពាក្យថា «វិភព» «វិ» សព្ទនេះមិនមែន មានអត្ថន័យថា «គ្មាន» ទេ គឺមានអត្ថន័យថា ផ្សេង, ខុស, ប្លែក ។ ផ្ទុយគ្នាពីនិព្វាន ដែលមានអត្ថន័យថា របស់ដោយគ្មានសេសសល់ ឬចេញផុតស្រឡះចាកភពទាំង ៣ : កាមភព, រូបភព, អរូបភព ។ អរូបភពគឺវិភពហ្នឹងឯង ។

**និរោធ**ពាក្យវេវចនៈ មានអត្ថន័យ ៨ :

**១- មទនិម្មទនោ** ញាំញីនូវសេចក្តីស្រវឹង,

**២- បិបាសវិនយោ** នាំចេញនូវសេចក្តីស្រេកឃ្លាន,

**៣- អាលយសមុគ្ឃាតោ** ដកចេញនូវសេចក្តីអាល័យ,

**៤- វដ្ដូបច្ឆេទោ** កាត់ផ្តាច់នូវវដ្តសង្សារ,

**៥- តណ្ហក្ខយោ** អស់តណ្ហាគ្រប់ប្រភេទ,

**៦- វិរាគោ** ប្រាចាកតម្រេក,

**៧- និរោធោ** រលត់គ្មានសេសសល់,

**៨- និព្វានំ** ចេញផុតចាកភពទាំង ៣ ។

**មគ្គៈ**ពាក្យវេវចនៈ នឹង**មជ្ឈិមាបដិបទា**ឬ **អដ្ឋង្គិកមគ្គ**មាន ៨ :

**១- សម្មាទិដ្ឋិ,**

**២- សម្មាសង្កប្បៈ,**

**៣- សម្មាវាចា,**

**៤- សម្មាកម្មន្តៈ,**

**៥- សម្មាអាជីវៈ,**

**៦- សម្មាវាយាម,**

**៧- សម្មាសតិ,**

**៨- សម្មាសមាធិ,**

**មគ្គ ៨ ប្រើជាលោកិយ**

**១- សម្មាទិដ្ឋិ** គំហើញត្រូវ គឺឃើញថាធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប ។

**២- សម្មាសង្កប្បៈ** តម្រិះត្រូវ គឺតម្រិះមិនព្យាបាទអ្នកដទៃ, មិនបៀតបៀនអ្នកដទៃ, មិនដេកត្រាំក្នុងកាម ។

**៣- សម្មាវាចា** ពំនោលត្រូវ គឺមិនពោលពាក្យកុហក, ពាក្យជេរប្រទេច, ពាក្យញុះញង់បំបែកបំបាក់,

ពាក្យរោយរាយគ្មានសារប្រយោជន៍ ។

**៤- សម្មាកម្មន្តៈ** ទំរើត្រូវ គឺមិនខំធ្វើទំរើសម្លាប់ជីវិតដទៃ, លួចទ្រព្យសម្បត្តិមានម្ចាស់រក្សា, ប្រព្រឹត្តខុស ក្នុងកាមមានម្ចាស់ហួងហែង ។

**៥- សម្មាអាជីវៈ** រស់ត្រូវ គឺមិនធ្វើជំនួញ ៥ ប្រការ ជំនួញមនុស្ស, ជំនួញសាច់សត្វដែលសម្លាប់ដោយដៃឯង, ជំនួញអាវុធសម្រាប់សង្គ្រាម, ជំនួញគ្រឿងស្រវឹង, ជំនួញថ្នាំមានពិសពុល ឬរស់នៅក្នុងរបរ មានយុត្តិធម៌ ។

**៦- សម្មាវាយាម** កំហំត្រូវ គឺខំធ្វើទំរើល្អដែលមិនទាន់បានធ្វើ, ខំរក្សាទុកនូវទំរើល្អដែលបានធ្វើហើយ, ខំមិនធ្វើទំរើអាក្រក់, ខំលះបង់ទំរើអាក្រក់ដែលបានធ្វើហើយ ។

**៧- សម្មាសតិ** ស្មារតីរឭកត្រូវ គឺរឭកដល់ការងារដែលមិនទាន់បានធ្វើ, រឭកដល់ការងារដែលកំពុងធ្វើ, រឭកដល់ការងារដែលបានធ្វើរួចមកហើយ, រឭកដល់កាយ, វេទនា, ចិត្ត, ធម្មៈដែលកំពុងប្រព្រឹត្តទៅ ។

**៨- សម្មាសមាធិ** តម្កល់ចិត្តត្រូវ គឺតម្កល់ក្នុងអារម្មណ៍ល្អ, តម្កល់ក្នុងមុខការល្អ, តម្កល់ក្នុងទំរើដែលកំពុងធ្វើ, តម្កល់ក្នុងធម្មៈដែលកំពុងសិក្សាហ្វឹកហាត់ ។

**ត្រើជាលោកុត្តរ**

**១- សម្មាទិដ្ឋិ** គំហើញត្រូវ គឺឃើញតាមអរិយសច្ចៈ ៤ ។

**២- សម្មាសង្កប្បៈ** តម្រិះត្រូវ គឺត្រូវ តាមអរិយសច្ចៈ ៤ ។

**៣- សម្មាវាចា** ពំនោលត្រូវ គឺពោល តាមអរិយសច្ចៈ ៤ ។

**៤- សម្មាកម្មន្តៈ** ទំរើត្រូវ គឺធ្វើ តាមអរិយសច្ចៈ ៤ ។

**៥- សម្មាអាជីវៈ** រស់ត្រូវ គឺរស់ក្នុងអរិយសច្ចៈ ៤ ។

**៦- សម្មាវាយាម** កំហំត្រូវ គឺខំ តាមអរិយសច្ចៈ ៤ ។

**៧- សម្មាសតិ** ស្មារតីរឭកត្រូវ គឺរឭក តាមអរិយសច្ចៈ ៤ ។

**៨- សម្មាសមាធិ** កំណល់ចិត្តត្រូវ គឺតម្កល់លើអរិយសច្ចៈ ៤ ។

**សេចក្ដីអធិប្បាយអដ្ឋង្គិកមគ្គលោកិយ** :

១- ទស្សនៈត្រូវពិត (សម្មាទិដ្ឋិ) ភាពសង្ស័យមានទស្សនៈខុសៗត្រឹមតែ ជាសេចក្ដីគិតឃើញទៅលើផ្លូវខុសនីមួយៗ ។ បុគ្គលគប្បីដឹងដល់សេចក្ដីប្លែកផ្សេងនៅក្នុងចន្លោះនៃសេចក្ដីឋិតថេរ និងសេចក្ដីមិនឋិតថេរ ។ (ត្រូវឃើញភាពពិតដែលមាននៅក្នុងភាពមិនពិត មុននឹងធ្វើនូវសេចក្ដីសម្រេចចិត្ត ឬមុននឹងដាក់ជំនឿទៅក្នុងរបស់ណាត្រូវធ្វើការបកស្រាយជាមួយនឹងការស្រាវជ្រាវរកហេតុផល ក្នុងរបស់នោះឲ្យបានគ្រប់គ្រាន់សិន ។

២- សេចក្ដីត្រិះរិះត្រូវ (សម្មាសង្កប្បៈ) សេចក្ដីតាំងចិត្តយ៉ាងប្តូរផ្តាច់ ក្នុងការទ្រទ្រង់នូវជីវភាពជាមួយនឹងការពង្រីកពង្រឹងនូវជីវភាព ដោយអាស្រ័យសេចកដីចេះដឹងជាមូលដ្ឋាន នៅក្នុងការគ្រប់គ្រងខ្លួនឲ្យបានសុខ, ជាបុគ្គលមើលឃើញវែង, ដឹងថាមានផ្លូវបែបណាខ្លះ, មានចំណេះវិជ្ជាបែបណាខ្លះ អាចនឹងដឹកនាំខ្លួនទៅកាន់សេចក្ដីចម្រុងចម្រើនបាន ។

៣- ការនិយាយត្រូវ (សម្មាវាចា) នេះជាកាំជណ្តើរមួយទៀត សម្រាប់ឈានឡើងទៅកាន់ការប្រតិបត្តិដើម្បីគ្រងថែរក្សាខ្លួនឯង ។ ការនិយាយដោយប្រាសចាកស្មារតីប្រុងប្រយ័ត្ន ការនិន្ទាមើលងាយ ស្តីបង្អាប់ជេរប្រទេចផ្តាសានាំឲ្យខ្ទែងចិត្តអ្នកដទៃ ។ សម្តីទាំងអស់នេះត្រូវលះបង់, ត្រូវតមកុំនិយាយ ។ ត្រូវនិយាយតែសម្តីប្រកបដោយចិត្តមេត្តា ករុណាយ៉ាងបរិសុទ្ធ នៅក្នុងក្របខ័ណ្ឌយុត្តិធម៌ គ្រប់ពេលវេលា ។

៤- ទំរើត្រូវ (សម្មាកម្មន្តៈ) បានដល់ទំរើដែលមិនធ្វើឲ្យជនដទៃ មានចិត្តក្តៅក្រហាយព្រួយលំបាក, ជាទំរើមានសេចក្តីសុចរិត, ជាទំរើមានសីលធម៌ ។ ទំរើទាំងឡាយរបស់ខលួនត្រូវទុកដាក់ ឲ្យនៅក្នុងក្របខ័ណ្ឌនៃមនុស្សធម៌ ។ ត្រូវលះបង់នូវទំរើទាំងឡាយណា ដែលបានប្រយោជន៍ខ្លួន ខូចប្រយោជន៍អ្នកដទៃ ក្នុងបច្ចុប្បន្ន ឬក្នុងអនាគតកាល ។ ការសងសឹក ឬការកែកំហឹងត្រូវតមកុំធ្វើ ប្រសិនបើអាចតមបានត្រូវធ្វើនៅក្នុងក្របខ័ណ្ឌនៃច្បាប់លោក ឬច្បាប់ធម៌ត្រូវដឹកនាំទំរើរបស់ខ្លួនដោយសីលធម៌ និងមនុស្សធម៌ត្រូវទុកដាក់ការងាររបស់ខ្លួនឲ្យនៅក្រោមព្រហ្មវិហារធម៌ ៤ (មេត្តា, ករុណា, មុទិតា, ឧបេក្ខា,) ។

៥- ការរស់នៅត្រឹមត្រូវ (សម្មាអាជីវៈ) គ្រប់តែការងារចិញ្ចឹមជីវិតណាៗទាំងអស់ ត្រូវលះបង់កុំធ្វើនូវរបរណា ដែលខ្លួនរស់ហើយគេស្លាប់, ខ្លួនប្រកដោយសេចក្តីសុខចម្រើន គេបានសេចក្តីទុក្ខលំបាក, ខ្លួនមានទានស្តុកស្តម្ភមាំមួនគរទឹកគរដីគេក្រលំបាករហេមរហាម ។ល។ ត្រូវពង្រីកនិងពង្រឹងជីវភាពរបស់ខ្លួននៅលើកម្លាំងនិងសមត្ថភាពដែលខ្លួនមាន ។ ត្រូវធ្វើយ៉ាងណាឲ្យអ្នកដទៃដែលរស់នៅជាមួយខ្លួន មានតុល្យភាពក្នុងជីវិតរបស់គេ, ដោយប្រកាន់យកនូវសុជីវធម៌ ជាគ្រឿងប្រាស្រ័យទាក់ទងនៃការរស់នៅ ។ ទំរើជិះជាន់នូវជីវភាពរវាងគ្នានិងគ្នានឹងមិនអាចកើតឡើងបានទេ ប្រសិនបើគេបានជាន់ស៊ប់លើកាំទី ៣ និងទី ៤ នៃមគ្គៈជាពិតប្រាកដហើយ ។

៦- សេចក្តីព្យាយាមត្រូវ (សម្មាវាយាមៈ) ក្រោយពីមានមេត្តាជាគ្រឿងធ្វើឲ្យត្រជាក់ចិត្ត, មានបញ្ញាជាគ្រឿងធ្វើឲ្យមានសេចក្តីភ្លឺស្វាងក្នុងបញ្ហានៃជីវិតហើយ, បុគ្គលអ្នកប្រកបព្យាយាម នឹងបានស្គាល់ច្បាស់នូវការលៃលកបែងចែកកម្លាំងស្មារតីទាំងអស់របស់ខ្លួនទៅក្នុងមុខងារនៃជីវិត ។ ស្គាល់ការខុសត្រូវក្នុងទំរើ ។ ជាពិសេសគឺស្គាល់ទិសដៅចុងបំផុតនៃទំរើទាំងឡាយនោះផង ។ ប្រតិបត្តិការរាល់យ៉ាងរបស់គេមានសភាពរឹងប៉ឹងមាំមួន ឧបស័គ្គទាំងឡាយមិនហ៊ានចូលមកជិតការងាររបស់គេឡើយ ។ ខ្លួនគេជាមនុស្សមានចិត្តពេញប្រៀបទៅដោយ គុណធម៌ល្អ គុណធម៌ល្អនេះបានក្លាយភាពទៅជាជីវិតរបស់គេ, គេមិនចាំបាច់ត្រូវពិចារណាមើលឡើងវិញ នូវទំរើទាំងឡាយរបស់ខ្លួនក្នុងពេលប្រតិបត្តិការថ្មីៗទៀតទេ, កិច្ចការប្រចាំជីវិតរបស់គេ ចេះតែប្រព្រឹត្តទៅបាន យ៉ាងស្រួលដូចជាបុគ្គលមានអនាម័យល្អ មានសុខភាពគ្រប់គ្រាន់មិនចាំបាច់ត្រូវប្រើឱសថ ជួយគាំទ្ររូបកាយនៃ អាត្មាដូច្នោះដែរ ។

៧- សេចក្តីរឭកត្រូវ (សម្មាសតិ) ភាពចិត្តមានជម្រកត្រូវនៅក្នុងសភាវៈ ដែលហៅថា សេចក្តីភ្ញាក់រឭក ។ ភាពភ្ញាក់រឭកនេះមានមុខងារធ្វើឲ្យគេដឹងបាន, ចាំបាន, ស្គាល់បាននូវអ្វីៗដែលជាប្រយោជន៍សម្រាប់ខ្លួន ឬជាសន្តិភាពនៃជីវិតរបស់គេ ។ បុគ្គលដែលរស់នៅក្នុងសភាពចិត្តបែបនេះ គេនឹងទៅជាបុគ្គលដែលមានសេចក្តីគោរពចំពោះតែសភាវៈពិត គេអាចយល់ស្គាល់របស់ផ្សេងៗបានយ៉ាងច្បាស់លាស់ ព្រោះគេបានរំលាយចោលនូវភាពបោកបន្លំអស់ហើយ, គេមានសេចក្តីពិតនៅក្នុងទីចំពោះមុខ ។ ប្រែថា គេជាបុគ្គលដឹងច្បាស់នូវសេចក្តីពិត ។ជាពិសេសជាងនេះទៅទៀត គឺខ្លួនគេហ្នឹងឯងជាសេចក្តីពិតតែម្តង ។ បុគ្គលមានស្មារតីឈរនៅលើសេចក្តីពិតដូចនេះសកម្មភាពនៃជីវិតរបស់គេ រមែងមិនមានសេចក្តីផ្លាស់ប្តូរសោះឡើយ ។

៨- សេចក្តីសង្រួមចិត្តត្រូវ (សម្មាសមាធិ) នេះគឺជាចិត្តតាំងនៅយ៉ាងខ្ជាប់ខ្ជួនក្នុងភាពស្ងប់ ជាសន្តិភាពនៃជីវិតពិតប្រាកដ, ជាសន្តិភាពដែលមិនមានលាយឡំទៅដោយទុក្ខ ។ កាលណាបុគ្គលបានចូលដល់គុណធម៌ថ្នាក់នេះហើយខ្លួនគេនឹងមិនមានរបស់ណាៗ អាចដឹកនាំឲ្យគេមានសេចក្តីសៅសោកនៅក្នុងសន្តានរបស់គេ និងមិនមានសភាពណាៗទាំងអស់ វៀរលែងតែសភាពដែលនាំមកនូវសេចក្តីសុខស្ងប់ ។ សេចក្តីសង្ស័យ, សេចក្តីតក់ស្លុត, សេចក្តីកង្វល់, សេចក្តីស្មុកស្មាញ, សេចក្តីរវើរវាយ ។ល។ ទាំងអស់នេះបានដល់នូវភាពសោះសូន្យទៅ ។ ជំនឿក្នុងកម្មដែលមិនមានហេតុផលជាមូលដ្ឋាន, សេចក្តីសង្ឃឹមនិងសេចក្តីភ្ញាក់ផ្អើលខុស នឹងត្រូវរលាយបាត់បង់ទៅបន្តិចម្តងៗ ។ ចិត្តនៃបុគ្គលដែលបានចូលដល់គុណធម៌ថ្នាក់នេះ នឹងបានជួបប្រទះនូវសន្តិសុខយ៉ាងខ្ពស់បំផុត

លើសវិស័យនឹងបរិយាយឲ្យចូលចិត្តបាន ។ បុគ្គលណាបានសម្រេច បុគ្គលនោះអស់មានពេលវេលា ប្រែប្រួលប្តូរផ្លាស់ទៀតហើយ ។ នេះជាអដ្ឋង្គិកមគ្គសម្រាប់មនុស្សបុថុជ្ជន ប្រតិបត្តិដើម្បីសុខសន្តិភាពសម្រាប់ជីវិតក្នុងលោកនេះ និងដើម្បីជាស្ពានសម្រាប់ជីវិតអរិយៈក្នុងទីបំផុត ។

## សេចក្តីអធិប្បាយអដ្ឋង្គិកមគ្គជាលោកុត្តរៈ

១- សម្មាទិដ្ឋិ គំហើញត្រូវ គឺឃើញសច្ចៈ ៤ ដោយកិច្ច ៤ យ៉ាងគឺ :

ក/ បរិញ្ញាកិច្ច គំហើញក្នុងសេចក្តីកត់សម្គាល់នូវទុក្ខ,

ខ/ បហានកិច្ច គំហើញក្នុងការលះបង់នូវហេតុនៃទុក្ខ,

គ/ សច្ឆកិរិយាកិច្ច គំហើញក្នុងការធ្វើឲ្យច្បាស់លាស់នូវនិព្វាន,

ឃ/ ភាវនាកិច្ច គំហើញក្នុងការចម្រើនមគ្គ ។

២- សម្មាសង្កប្បៈ តម្រិះត្រូវក្នុងសច្ចៈ ៤ ដោយកិច្ច ៤ យ៉ាងគឺ :

ក/ បរិញ្ញាកិច្ច តម្រិះក្នុងសេចក្តីកត់សម្គាល់នូវទុក្ខ,

ខ/ បហានកិច្ច តម្រិះក្នុងការលះបង់នូវហេតុនៃទុក្ខ,

គ/ សច្ឆិកិរិយាកិច្ច តម្រិះក្នុងការធ្វើឲ្យជាក់ច្បាស់នូវនិព្វាន,

ឃ/ ភាវនាកិច្ច តម្រិះក្នុងការចម្រើនមគ្គ ។

៣- សម្មាវាចា ពំនោលត្រូវក្នុងសច្ចៈ ៤ ដោយកិច្ច ៤ យ៉ាងគឺ :

ក/ បរិញ្ញាកិច្ច ពំនោលក្នុងការកត់សម្គាល់នូវទុក្ខ,

ខ/ បហានកិច្ច ពំនោលក្នុងការលះបង់នូវហេតុនៃទុក្ខ,

គ/ សច្ឆិកិរិយាកិច្ច ពំនោលក្នុងការធ្វើឲ្យជាក់ច្បាស់នូវនិព្វាន,

ឃ/ ភាវនាកិច្ច ពំនោលក្នុងការចម្រើនមគ្គ ។

៤- សម្មាកម្មន្តៈ ទំរើត្រូវក្នុងសច្ចៈ ៤ ដោយកិច្ច ៤ យ៉ាងគឺ :

ក/ បរិញ្ញាកិច្ច ទំរើក្នុងសេចក្តីកត់សម្គាល់នូវទុក្ខ,

ខ/ បហានកិច្ច ទំរើក្នុងការលះបង់នូវហេតុនៃទុក្ខ,

គ/ សច្ឆិកិរិយាកិច្ច ទំរើក្នុងការធ្វើឲ្យជាក់ច្បាស់នូវនិព្វាន,

ឃ/ ភាវនាកិច្ច ទំរើក្នុងការចម្រើនមគ្គ ។

៥- សម្មាអាជីវៈ រស់ត្រូវក្នុងសច្ចៈ ៤ ដោយកិច្ច ៤ យ៉ាងគឺ :

ក/ បរិញ្ញាកិច្ច ភាពរស់ក្នុងសេចក្តីសម្គាល់នូវទុក្ខ,

ខ/ បហានកិច្ច ភាពរស់ក្នុងការលះបង់នូវហេតុនៃទុក្ខ,

គ/ សច្ឆិកិរិយាកិច្ច ភាពរស់ក្នុងការធ្វើឲ្យជាក់ច្បាស់នូវនិព្វាន,

ឃ/ ភាវនាកិច្ច ភាពរស់ក្នុងការចម្រើនមគ្គ ។

៦- សម្មាវាយាមៈ សេចក្តីព្យាយាមត្រូវក្នុងសច្ចៈ ៤ ដោយកិច្ច ៤ យ៉ាងគឺ :

ក/ បរិញ្ញាកិច្ច កំហំក្នុងសេចក្តីកត់សម្គាល់នូវទុក្ខ,

ខ/ បហានកិច្ច កំហំក្នុងការលះបង់នូវហេតុនៃទុក្ខ,

គ/ សច្ឆិកិរិយាកិច្ច កំហំក្នុងការធ្វើឲ្យជាក់ច្បាស់នូវនិព្វាន,

ឃ/ ភាវនាកិច្ច កំហំក្នុងការចម្រើនមគ្គ ។

៧- សម្មាសតិ សេចក្ដីរឭកត្រូវគឺរឭកក្នុងសច្ចៈ ៤ ដោយកិច្ច ៤ យ៉ាងគឺ :

ក/ បរិញ្ញាកិច្ច ភាពរឭកក្នុងសេចក្ដីកត់សម្គាល់នូវទុក្ខ,

ខ/ បហានកិច្ច ភាពរឭកក្នុងសេចក្ដីកត់សម្គាល់នូវទុក្ខ,

គ/ សច្ឆិកិរិយាកិច ភាពរឭកក្នុងធ្វើឲ្យជាក់ច្បាស់នូវនិព្វាន,

ឃ/ ភាវនាកិច្ច ភាពរឭកក្នុងការចម្រើនមគ្គ ។

៨- សម្មាសមាធិ កំណល់ចិត្តត្រូវគឺកំណល់ក្នុងសច្ចៈ ៤ ដោយកិច្ច ៤ យ៉ាងគឺ :

ក/ បរិញ្ញាកិច្ច កល់ក្នុងសេចក្ដីកត់សម្គាល់នូវទុក្ខ,

ខ/ បហានកិច្ច កល់ក្នុងការលះបង់នូវហេតុនៃទុក្ខ,

គ/ សច្ឆិកិរិយា កល់ក្នុងការធ្វើឲ្យជាក់ច្បាស់នូវនិព្វាន,

ឃ/ ភាវនាកិច្ច កល់ក្នុងការចម្រើនមគ្គ ។

អរិយសច្ចៈ ៤ នេះជាបច្ចេកទេសរបស់ពុទ្ធសាសនាផង, ជាមូលដ្ឋាននៃធម៌ទាំងឡាយផង, ជាកំពូលនៃធម៌ទាំងឡាយផង, ជាប្រភព, ជាជម្រក ឬជាទីរួមចូលនៃធម៌ទាំងឡាយ ដែលសម្ដែងចេញដោយព្រះសម្មាសម្ពុទ្ធផង (អ្នកអានចង់ដឹងសេចក្ដីពិស្ដារនៃអារិយសច្ចធម៌នេះ គប្បីអានសៀវភៅឈ្មោះ «និព្វានទស្សនៈ» របស់ខ្ញុំផង) ក្រៅពីនេះមានការមួយទៀតដែលគួរធ្វើសេចក្ដីចងចាំផងដែរ គឺអរិយសច្ចធម៌នេះមានលក្ខណៈជាទស្សនៈវិជ្ជាខ្លះ, ជាទស្សនៈវិជ្ជាសុទ្ធសាធខ្លះៗ ព្រមទាំងមានលក្ខណៈជាវិទ្យាសាស្ត្រខ្លះ ជាវិទ្យាសាស្ត្រសុទ្ធសាធខ្លះដែលនឹងនិយាយខ្លះទៀតក្នុងបទខាងមុខ ។

## មេរៀនទី២
## ព្រះពុទ្ធគឺជានរណា?

បើស្ដីតាមសំឡេង ឬដោយឫសកល់នៃសព្ទ ។ ពាក្យថា «ពុទ្ធ» ប្រែថា «បុគ្គលអ្នកត្រាស់ដឹង» គឺដឹងច្បាស់លាស់តាមសេចក្ដីពិត ដែលជាហេតុឲ្យសត្វលោករួចផុតចាកសេចក្ដីទុក្ខទាំងពួង ។

ពាក្យថា «ព្រះពុទ្ធ» ដែលប្រែថា «លោកអ្នកត្រាស់ដឹង» មានន័យ ២ យ៉ាង ដែលខ្ញុំគួរអធិប្បាយក្នុងទីនេះគឺ :

១- ជាបុគ្គលអ្នកត្រាស់ដឹង សឹងប្រវត្តិសាស្រ្តបានទទួលស្គាល់, បានរក្សាទុកជាឯកសារសម្រាប់ពិភពលោកនោះ ទោះជាមានច្រើន មានជីវប្រវត្តិផ្សេងៗគ្នា តាមការចូលចិត្ត ការនិយមក៏មែនហើយ តែរជ្ជទាយាទ **សិទ្ធត្ថ** នៃក្រុងកបិលពស្ដុ ជាឱរសរបស់**សុទ្ធោទនៈ** និងរាជិនី**មហាមាយា** ។ មហាសត្វព្រះអង្គបានត្រូវគម្ពីរ និងអ្នកប្រវត្តិសាស្ត្រ លើកកម្ពស់នៃការត្រាស់ដឹងរបស់ព្រះអង្គ ឲ្យមានគុណភាពថ្លៃថ្នូរជាពិសេស ។ គឺជាជើងឯកមិនមានតម្រាស់នៃបុគ្គលណាម្នាក់ មានគុណភាពស្មើព្រះអង្គឡើយ ។ មហាសត្វបានសម្រាលចាកផ្ទៃម្ដាយមុនពុទ្ធសករាជ ៨០ឆ្នាំ, ព្រះជន្មាយុបាន ១៦ វស្សា បានទទួលមង្គលាភិសេកជាមួយនាង**យសោធរា** ឬ**ពិម្ពា** ។ ព្រះជន្មាយុ ២៩ ឆ្នាំ, មានឱរសមួយអង្គឈ្មោះ**រាហុល** ។ ក្នុងពេលជាមួយគ្នានេះ បានចេញសាងផ្នួសដើម្បីស្រាវជ្រាវរកសច្ចៈធម៌ ។ ទំរើនេះបានធ្វើអស់រយៈកាល ៦ ឆ្នាំ ទើបបានត្រាស់ដឹង ឬបានជួបប្រទះនូវភាពអាថ៌កំបាំងនៃធម្មជាតិ ។ គឺបានបញ្ចប់នូវកម្មវិធីស្រាវជ្រាវក្នុងជន្មាយុ ៣៥ ឆ្នាំ ។ ក្រោយបានត្រាស់ដឹងហើយ បានប្រកាសពុទ្ធសាសនា ប្រតិស្ថានធម្មៈ ស្ថាបនាគណសង្ឃឡើងក្នុងពិភពលោក ។ ព្រមគ្នានេះ, ព្រះសម្មាសម្ពុទ្ធព្រះអង្គបាននិមន្តទៅកាន់ទិសនានា ដើម្បីធ្វើការផ្សាយពុទ្ធសាសនាអស់រយៈវេលា ៤៥ ឆ្នាំ ទើបរលត់ខន្ធនិព្វានក្នុងជន្មាយុ ៨០ ឆ្នាំ ។ ស្ថានទីសម្រាល, ត្រាស់ដឹង, សម្ដែងធម៌លើកទី ១ និងបរិនិព្វាន នៅមានល័ខឋានប្រាកដសព្វថ្ងៃ សឹងរដ្ឋាភិបាលឥណ្ឌាក្នុងសម័យបច្ចុប្បន្ន បានខំប្រឹងរៀបចំ, ឲ្យមានផ្លូវ, ថ្នល់, កន្លែងស្នាក់អាស្រ័យដើម្បីងាយស្រួលដល់ពួកទេសចរដែលទៅនមស្ការសំវេជនីយដ្ឋានទាំង ៤ អន្លើនោះ ។ នៅក្នុងទីនោះ, មានគ្រឿងសមិទ្ធិ, គ្រឿងសំណង់ចាស់ទុំបរមបូរាណខ្លះ, សិលាចារិកខ្លះជាធាតុ ឬជាគ្រឿងបញ្ជាក់ឲ្យឃើញថា មហាសត្វ**សិទ្ធត្ថ** ជាបុគ្គលដែលបានត្រាស់ដឹងជាព្រះពុទ្ធនោះ ជាមនុស្សពិសេសម្នាក់ក្នុងពិភពលោក ព្រោះមានវត្ថុ ឬធាតុជាតួយ៉ាងប្រាកដជាក់ស្ដែងក្នុងផ្លូវប្រវត្តិសាស្ត្រនៃពិភពលោក ។

២- ព្រះសម្ពុទ្ធ, ព្រះអង្គមានព្រះតំណែងជាសាស្ដាចារ្យឯករបស់ពិភពលោក ។ បុគ្គលណាក៏ដោយ កាលណាបានបំពេញបារមីធម៌ គឺភាពល្អ ភាពថ្លៃថ្នូរគ្រប់យ៉ាង មានចំនួនគ្រប់គ្រាន់ហើយបុគ្គលនោះនឹងបានត្រាស់ដឹងនូវសច្ចធម៌ដែលគេស្គាល់គ្រប់គ្នាថា «ព្រះពុទ្ធ» មានករណីបង្កើតសីលធម៌ ស្ថាបនាធម្មៈទូទៅក្នុងឋានមនុស្សលោកយើងនេះ ។

ក្នុងគោលការណ៍នៃពុទ្ធសាសនា មានសេចក្ដីបញ្ជាក់ថា ព្រះពុទ្ធមិនមែនមានត្រឹមតែមួយអង្គ ដែលយើងគោរពសព្វថ្ងៃប៉ុណ្ណឹងទេ ។ តែមានចំនួនច្រើនរាប់ស្ទើរមិនអស់ ប្រសិនបើបូកអតីតកាល បច្ចុប្បន្នកាល អនាគតកាលចូលគ្នា ។ ព្រះពុទ្ធមួយអង្គបរិនិព្វានទៅ មានព្រះពុទ្ធមួយអង្គទៀតមកត្រាស់ដឹងថ្មីជំនួស, ក្នុងរយៈកាលបរិនិព្វាន និងរយៈកាលត្រាស់ថ្មីរបស់ព្រះពុទ្ធទាំងអស់អង្គនោះ ពុំបានឋិតនៅជិតគ្នាទេ ។ អំពីមួយអង្គទៅមួយអង្គទៀត លោកថាអស់វេលាយូរ រាប់បានទាំងកោដិៗឆ្នាំ ។ ពំនោលបញ្ជាក់នេះអាចឲ្យអ្នកផងចូលចិត្តថា មានទំនាក់ទំនងប្រហែលៗ ទៅលើជំនឿគ្មានហេតុផល ឬពាក្យបរមបរា ។ ប៉ុន្តែគេត្រិះរិះពិចារណាក្នុងន័យមួយទៀត, គេនឹងឃើញថា តំណែងព្រះពុទ្ធមិនមែនជាតំណែងផ្ដាច់មុខសម្រាប់បុគ្គលម្នាក់ៗ ដោយចំពោះទេ ។ នរណាបានសាងបារមី ១០ មហាបរិច្ចាគ ៥ និងចរិយា ៣ ដល់កម្រឹតចាស់ទុំជោរហើយ នរនោះមានឱកាសត្រូវបាន

ត្រាស់ដឹងជាព្រះពុទ្ធ ។នេះគឺជាគោលការណ៍ ឬតំណែងកណ្តាលសម្រាប់សកលមនុស្ស ។ គោលការណ៍នេះមានហេតុផល បរិបូរណ៍ហើយ ។ ព្រោះអ្វី? ព្រោះក្នុងបណ្តាមនុស្សមានចំនួនច្រើនអនេក កាលណាបើម្នាក់ៗ ឬច្រើនក៏ដោយ មានវត្ថុបំណងប្រកបដោយព្យាយាមយ៉ាងមោះមុតសាងបារមីធម៌ ថ្ងៃណាមួយគេគង់នឹងបានទទួលផលនៃសំណាងល្អនោះជាមិនខានឡើយ ។

គោលការណ៍នេះសម្តែងឲ្យឃើញថា ការសម្រេចនូវភាពជាព្រះពុទ្ធ មិនមែនត្រូវប្រើពេលត្រឹមតែបន្តិចបន្តួច ឬបង្កើតសេចក្តីល្អត្រឹមតែស្រាលៗបានទេគឺត្រូវអាស្រ័យសេចក្តីល្អច្រើនក្រៃលែងច្រើន សេចក្តីព្យាយាម ធំក្រៃលែងធំ ។ ជាពិសេសត្រូវមានកម្លាំងចិត្តក្លាហានដាច់ខាត សម្រាប់ច្រានដំណើរទៅមុខជានិច្ច គ្មានទុចគ្មានថយក្រោយទើបបាន សម្រេសនូវបំណងនេះ ។

នៅក្នុងរឿងព្រះពុទ្ធដដែលនេះទៀត មានជនជាតិបស្ចិមប្រទេសខ្លះ បានសរសេរសៀវភៅព្រះពុទ្ធសាសនាដោយធ្វើសេចក្តីបញ្ជាក់របស់ខ្លួនថា ព្រះពុទ្ធសាសនាជាសាសនារបស់មនុស្ស មិនមែនជាសាសនារបស់ទេវតាទេ ។ ការពិត, សាសនារបស់មនុស្សពុំមានគុណភាពថ្លៃថ្នូរស្មើនឹងសាសនារបស់យើងទេ ដែលជាសាសនារបស់ឋានសួគ៌ឡើយ ។ គំហើញរបស់ខ្ញុំក្នុងរឿងនេះឃើញថា : ការដែលគេទុកដាក់ពុទ្ធសាសនា ជាសាសនារបស់មនុស្ស និងការដែលមនុស្សបានត្រាស់ជាព្រះពុទ្ធ ជាការគួរឲ្យពេញចិត្តពេកកន្លង ។ ព្រោះអ្វី? ព្រោះវាជារឿងត្រង់ៗចំៗ ជាមួយមនុស្សនិងមនុស្សគ្នាឯង មានហេតុផលនៅចំពោះមុខតែម្តង ។ ខ្ពស់ជាងនេះទៅទៀត, យុគនេះជាយុគដែល ពិភពលោកកំពុងចម្រើនដោយវិទ្យាសាស្ត្រ មនុស្សគង់ទុកដាក់រឿងទេពនិយមថា ជារឿងគ្មានសេចក្តីពិត ឬត្រឹមតែជា រឿងព្រេងនិទានប៉ុណ្ណោះ ។

សេចក្តីពិត, ការដែលមនុស្សម្នាក់មានសេចក្តីព្យាយាមតស៊ូខំប្រឹងបង្កើតសេចក្តីល្អ, ស្ថាបនាយុត្តិធម៌, បណ្តុះគំនិតថ្លៃថ្នូរលុះត្រាបានជួបប្រទះនូវបញ្ញាជាន់ខ្ពស់ ដែលជាផលកើតឡើង ដោយអាស្រ័យសេចក្តីព្យាយាមយ៉ាងប្តូរផ្តាច់ ហើយបង្ហាត់បង្រៀនប្រជាពលលោកឲ្យស្គាល់ធម្មជាតិតាមភាពពិត ដែលស្រាវជ្រាវឃើញនោះរមែងបង្ហាញថាជារឿងមានហេតុផល និងគួយ៉ាងសម្រាប់ទាក់ទាញចិត្តមនុស្សទូទៅ មិនឲ្យបណ្តែតបណ្តោយជីវិតឲ្យរស់នៅតាមយថាកម្ម ។ និយាយងាយៗខ្លីៗ ក៏គឺព្រះពុទ្ធជាមនុស្សសុទ្ធៗនេះ បានជាតួយ៉ាងមួយ ប្រកបដោយកម្ពស់ថ្លៃថ្នូរបំផុតសម្រាប់មនុស្សលោកដូចគ្នាយកទៅប្រព្រឹត្តប្រតិបត្តិតាម ឬយកទៅអនុវត្ត ។ ប្រែថាជារឿងសម្រាប់មនុស្សទាំងអស់គ្នា មិនមែនជាការផ្តាច់មុខសម្រាប់មនុស្សម្នាក់ៗ ឬសម្រាប់វណ្ណៈ ។ល។ មួយៗឡើយ ។

## ព្រះពុទ្ធមាន ៣ ប្រភេទ

១- សម្មាសម្ពុទ្ធ ព្រះអង្គបានត្រាស់ដឹងដោយខ្លួនឯង ហើយបង្ហាត់បង្រៀនអ្នកដទៃឲ្យត្រាស់ដឹងតាមព្រះអង្គផង ប្រភេទនេះបានដល់ព្រះសម្មាសម្ពុទ្ធដែលប្រតិស្ថានធម្មៈ ស្ថាបនាសាសនាទុកជាពន្លឺសម្រាប់មនុស្សលោក ។

២- ព្រះបច្ចេកពុទ្ធ ព្រះអង្គបានត្រាស់ដឹងចំពោះខ្លួនមិនមានសមត្ថភាព រៀបចំគោលការណ៍បង្ហាត់បង្រៀន ឬមិនបានប្រតិស្ថានធម្មៈ ឬស្ថាបនាសាសនាសម្រាប់អ្នកដទៃ ។ ប្រភេទនេះបានដល់បុគ្គលអ្នកបំពេញបារមីធម៌បន្ទាប់បន្សំមកអំពីព្រះសម្មាសម្ពុទ្ធ ។

៣- សុត្តពុទ្ធ ឬសាវ័កពុទ្ធ បុគ្គលអ្នកត្រាស់ដឹង ដែលត្រូវអាស្រ័យស្តាប់ពាក្យបង្ហាត់បង្រៀនរបស់ព្រះសម្មាសម្ពុទ្ធ បានសម្រេចការត្រាស់ដឹងថ្នាក់ត្រឹមសាវ័ក ឬហៅម្យ៉ាងទៀតថា អនុពុទ្ធ ប្រែថា ត្រាស់ដឹងតាម មិនមែនត្រាស់ដឹងដោយខ្លួនឯងឡើយ ។

## **ធម្មៈជាគោលការណ៍ទូទៅ**

**ព្រះពុទ្ធសាសនាបង្រៀនធម្មៈជាគោលការណ៍ទូទៅមាន ៣ ប្រការ** :

**១- វៀរចាកទំនើរអាក្រក់,**

**២- ប្រព្រឹត្តទំនើរល្អ,**

**៣- ជម្រះចិត្តឲ្យស្អាត ។**

ធម្មៈជាគោលការណ៍ទូទៅនេះ, គេអាចសង្កេតបានថា : ព្រះពុទ្ធសាសនាបង្រៀនសង្កត់ធ្ងន់ទៅលើទំរើប្រព្រឹត្តប្រតិបត្តិ សឹងមានលក្ខណៈប្លែកពីសាសនាប្រភេទធម្មជាតិទេវនិយម ដែលបង្រៀនឲ្យមនុស្សរាប់អាន ឬគោរព បូជាទេវតាក្នុងធម្មជាតិដូច ដី, ទឹក, ភ្លើង, ខ្យល់, ព្រះចន្ទ, ព្រះអាទិត្យ ។ល។ ឬសាសនាប្រភេទទេវនិយម (THEISM) ដែលបង្រៀនឲ្យមានជំនឿ មានសេចក្តីស្វាមីភក្តិក្នុងព្រះអាទិទេពសាងលោក ។

ក្នុងក្បួនតម្រាស្តីដោយវិជ្ជាសាសនា ប្រៀបធៀបមាននិយាយ ពីរបៀបចាត់ប្រភេទសាសនាជាច្រើនបែប តែបែបដែលអ្នកនិយាយ, អ្នកនិពន្ធនិយមជាងគេនោះឃើញមានត្រឹមតែ ៣ យ៉ាងគឺ :

**១- ធម្មជាតិទេវនិយម** ប្រភេទសាសនាដែលមានជំនឿឬមានការគោរពបូជាទេវតាប្រចាំធម្មជាតិ ។

**២- ទេវនិយម** ប្រភេទដែលមានជំនឿ ឬបូជាទេវតាសាងលោក ។

**៣- អទេវនិយម** ជាប្រភេទដែលមិនមានជំនឿ ឬមិនបូជាទេវតាសាងលោក ។

ដើម្បីជាពន្លឺដល់អ្នកអាន, ខ្ញុំសូមអធិប្បាយសាសនាទាំង ៣ ប្រភេទនេះធៀបគ្នានិងព្រះពុទ្ធសាសនារបស់យើងឲ្យដឹងគំនិត គំហើញរបស់ព្រះពុទ្ធសាសនា ក្នុងកាលណានិយាយដល់សាសនាប្រភេទនោះៗ មានដូចនេះ :

១- សាសនាដែលបូជាទេវតាប្រចាំធម្មជាតិ ឬមានជំនឿថា ក្នុងធម្មជាតិនាៗដូច ដី, ទឹក, ភ្លើង, ខ្យល់, ព្រះចន្ទ, ព្រះអាទិត្យ, ដើមឈើ, ភ្នំ, ផ្កាយនពគ្រោះ ។ល។ សុទ្ធតែជាជម្រករបស់ទេវតា ឬមានទេវតានៅប្រចាំ សាសនាប្រភេទនេះហៅថា«**ធម្មជាតិទេវនិយម**» ។ ហេតុការណ៍ដែលគួរឲ្យយើងធ្វើការកត់សម្គាល់ក្នុងសាសនាប្រភេទនេះ គឺគ្មានសាស្តាចារ្យ, គ្មានប្រមុខលិទ្ធិ គឺគ្មានរូបបុគ្គលអ្នកប្រកាស ឬអ្នកដឹកនាំ ។ តែចេះតែមានឥទ្ធិពលទាក់ទាញមនុស្សឲ្យមានជំនឿមានកំណាន់តៗមក តាំងពីកាលណាកាលណីរហូតមកដល់សព្វថ្ងៃ ។ ជាតិឥណ្ឌា, ក្រិក, និងរ៉ូម៉ាំងបូរាណមានជំនឿមានកំណាន់ ក្នុងរឿងទេវតាប្រចាំធម្មជាតិ នេះក៏មានចំនួនច្រើនមិនតិចឡើយ ។ អ្នកស្រាវជ្រាវទាំងឡាយដែលមានខ្លួនខ្ញុំនៅក្នុងនោះផង មានទស្សនៈថាពីធីបណ្តែតកន្ទោង ឬបណ្តែតប្រទីបដែលជាតិទាំងឡាយមានខ្មែរ និងថៃឡង់ដ៍ជាដើម ទម្លាប់ធ្វើក្នុងថ្ងៃ ១៥ កើត ខែកត្តិក ក៏ជាប់ទាក់ទងមកអំពីជំនឿរបស់ឥណ្ឌាបូរាណ ដែលថាទេវតានៅប្រចាំស្ទឹងទន្លេនាៗ ។ ជំនឿនេះហើយដែលជាមូលដ្ឋាននៃគំនិតថា ការបន្ទោរបង់ឧច្ចារៈ បស្សាវៈ ឬចំនោលនៃរបស់ស្មោកគ្រោកទាំងឡាយ ដែលខ្លួនបានធ្វើលើទឹកក្នុងពេលឱកាសខ្លះ ជាទំរើមិនល្អ ឬជាបទល្មើសយ៉ាងធំចំពោះទេវតា ។ ដូចនេះ, ក្នុងមួយខួបឆ្នាំ ឬក្នុងរយៈកាលកន្លងទៅមួយឆ្នាំ ក្នុងបច្ចុប្បន្នកាលនេះ, ប្រជាជាតិខ្មែរដែលបានរស់នៅជាមួយពុទ្ធសាសនា ជាសាសនាមានហេតុផលបរិបូណ៌ អស់រយៈកាលយ៉ាងយូរមកហើយ ជំនឿនិងកំណាន់ដែលជាផ្នែកធម្មជាតិទេវនិយមនិងសាសនាព្រាហ្មណ៍ បានត្រូវរលត់រលាយទៅបន្តិចម្តងៗ មកទល់ពេលនេះជិតតែនឹងអស់ទៅហើយ ។ អាស្រ័យហេតុនេះ, ទើបមានអ្នកធ្វើសេចក្តីបំភ្លឺ ហើយបំបែររឿងបណ្តែតកន្ទោង ឬបណ្តែតប្រទីបនេះថាជាទំរើធ្វើឡើងដើម្បីបូជាសំណាមព្រះពុទ្ធបាត នៅត្រង់កន្លែងផ្នូកខ្សាច់ឆ្នេរស្ទឹងនម្មទា ។ នេះគឺជាដំណូរ, ដើម្បីឲ្យពុទ្ធសាសនិក ធ្វើបានដោយគ្មានខ្មាសអៀន ។ ជំនឿក្នុងរឿង ទេវតានៅប្រចាំផ្កាយនពគ្រោះ គឺព្រះអាទិត្យ,

ព្រះចន្ទ, ព្រះអង្គារ, ព្រះសុក្រ, ព្រះសៅរ៍ជាដើមនោះ មានត្រូវគ្នាទាំង នៅក្នុងប្រទេសឥណ្ឌា ក្រិក និងរ៉ូម៉ាំង, ក្នុងសតវត្សទី ២០ នេះ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រ ផ្នែកសាសនារូបខ្លះ បានធ្វើទស្សនកិច្ចនាស្រុកប៉មប៉េអ៊ីនៅក្នុងប្រទេសអ៊ីតាលី ជាតំបន់មួយរបស់ជាតិរ៉ូម៉ាំងបុរាណ ដែលបានកប់នៅក្រោមផេះធ្យូងនៃភ្នំភ្លើង ។ នៅកន្លែងនោះ គេបានប្រទះឃើញសំណាកវិហារហ្សូពីទែរ៍ (ព្រះព្រហស្បតិ៍) ដែលគេចាត់ទុកថា ជាទេពនៃសេចក្តីចេះដឹងនៃបញ្ញា ជំនឿនេះ, មានសេចក្តីប្រហាក់ប្រហែលនឹងទំនៀមទម្លាប់បុរាណ ដែលប្រកាន់យក ថ្ងៃព្រហស្បតិ៍ជាថ្ងៃរម្លឹកគុណគ្រូ, ក្នុងតំបន់ខ្លះហ្នឹងដែរ ។ នៅក្នុងសម័យអាណានិគម (ខ្មែររស់នៅក្រោមអាណាព្យាបាលបារាំង) កូនសិស្សត្រូវបាន សម្រាកឈប់រៀនថ្ងៃព្រហស្បតិ៍គឺជាថ្ងៃគោរពគ្រូ ជាទម្លាប់ជាប់តៗមកពី បុរាណហ្នឹងឯង ។

ឥរិយាបទពុទ្ធសាសនា ក្នុងរឿងនេះថែងថា «មនុស្សទាំងឡាយដែលត្រូវកម្លាចគំរាមកំហែង រមែងប្រកាន់យកវត្ថុជាទីពឹងច្រើនបែបច្រើនយ៉ាងផ្សេងៗគ្នា ដូចភ្នំ, ព្រៃ, ដើមឈើ, ចេតិយ, (ចេតិយសំដៅយក អនុស្សាវរីយ៍ផ្សេងៗ ដែលគេសាងឡើងក្នុងសម័យមុនពុទ្ធសាសនា និងក្នុងសម័យពុទ្ធកាល) ពំនឹងទាំងអស់នេះ មិនមែនជាពំនឹងក្សេមមិនមែនជាពំនឹងខ្ពង់ខ្ពស់ មិនមែនជាពំនឹងរួចចាកទុក្ខភ័យបានទេ ។ តែបុគ្គលណាបានដល់ ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃជាសរណៈ ឃើញអរិយសច្ចធម៌ ៤ ប្រការ ប្រកបដោយបញ្ញាប្រសើរ គឺឃើញទុក្ខ ឃើញហេតុឲ្យកើតទុក្ខ ឃើញភាពរលត់ទុក្ខ ឃើញផ្លូវប្រតិបត្តិឲ្យដល់ភាពរលត់ទុក្ខ ។ ពំនឹងនោះទើបជាពំនឹងក្សេម, ពំនឹងខ្ពង់ខ្ពស់,ពំនឹង រួចចាកទុក្ខទាំងអស់បាន» ។

កាលបើយើងយកពាក្យពុទ្ធសាសនា ក្នុងចំណុចនេះមកធ្វើវិភាគ យើងនឹងឃើញថា ពុទ្ធសាសនាបានចង្អុលចំទៅលើព្រះរតនៈត្រៃ ទៅលើបញ្ញាស្គាល់ច្បាស់នូវអរិយសច្ចៈ ថាជាពំនឹងមានគុណភាពខ្ពង់ខ្ពស់បំផុត ។ ការយក ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃធ្វើជាពំនឹង ក៏ដូចជាយកបញ្ញាធ្វើជាពំនឹងដែរ ព្រោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គធ្លាប់បាន សម្តែងថា «អ្នកណាឃើញធម្មៈរបស់យើង អ្នកនោះឈ្មោះថា ឃើញយើងតថាគត» ។ សេចក្តីនេះបញ្ជាក់ ឲ្យឃើញថា ព្រះពុទ្ធមិនមែនជាធាតុមួយដទៃអំពីធម៌ ព្រះធម៌មិនមែនជាធាតុមួយដទៃអំពីព្រះពុទ្ធ ។ ក្នុងន័យថា : ព្រះពុទ្ធមិនមែនជាធាតុអ្វីដទៃក្រៅពីសេចក្តីបរិសុទ្ធ, ស្ងប់, ស្វាង ។ ព្រះធម៌ក៏មិនមែនជាធាតុអ្វីដ៏ទៃ ក្រៅពីសេចក្តី បរិសុទ្ធ, ស្ងប់, ស្វាង, ដូចដែលយើងធ្លាប់បានស្គាល់មកហើយ ។ ចំណែកព្រះសង្ឃដ៏ពិតប្រាកដនោះ សំដៅយក បុគ្គលដែលបានត្រាស់ដឹង ធម៌តាមដែលព្រះពុទ្ធសម្តែង ដែលគេស្គាល់ថាព្រះអរិយសង្ឃ បើមិនបាន ត្រាស់ដឹងធម៌ក៏មិនត្រូវបានចាត់ជាព្រះអរិយសង្ឃ ។ សម្រេចសេចក្តីថា ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃទាំង ៣ ត្រូវរួមចូលគ្នានៅត្រឹមតែមួយ គឺរួមចូលក្នុងព្រះធម៌ ។ ការស្គាល់ធម្មៈច្បាស់លាស់ ឬត្រាស់ដឹងនូវធម្មៈបានត្រូវ អាស្រ័យបញ្ញា បញ្ញាដែលមានគុណភាពខ្ពង់ខ្ពស់ បំផុតក្នុងផ្លូវពុទ្ធសាសនានោះ ពុំមែនកើតឡើងបានឯងៗទេ ។ គឺត្រូវកើតឡើងដោយហេតុ ៣ ប្រការ ដែលយើងធ្លាប់ស្គាល់ថា **ចិន្តាមយបញ្ញា** បញ្ញាកើតពី សេចក្តីគិតនឹក ពិចារណា, **សុតាមយបញ្ញា** បញ្ញាកើតពីការសិក្សាស្តាប់ត្រាប់ត្រង **ភាវនាមយបញ្ញា** បញ្ញាកើត ឡើងពីប្រតិបត្តិស៊ីងស្មាធ៏ចម្រើនសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ។ ព្រះបរមសាស្តារបស់យើង ដែលបាន ត្រាស់ជាព្រះពុទ្ធ ក៏ដោយអាស្រ័យការហ្វឹកហាត់អប់រំបញ្ញា សាកល្បង ប្រតិបត្តិឆ្លងកាត់ទំរើត្រូវខ្លះខុសខ្លះ អស់រយៈវេលា ៦ ឆ្នាំ ទើបបានជួបប្រទះនូវសេចក្តីសម្រេចក្នុងទីបំផុត ។ ដូចនេះ ឃើញថា ពំនឹងខ្ពង់ខ្ពស់បំផុត របស់ព្រះពុទ្ធសាសនានោះមិនមែនជារបស់ខាងក្រៅដូចដើមឈើ, ភ្នំ, ដំបូក, វត្ថុអាថ៌កំបាំងដទៃ ។ល។ តែគឺជា សេចក្តីព្យាយាមរបស់ខ្លួននៃមនុស្សម្នាក់ៗ ដែលខំតស៊ូហ្វឹកហាត់ក្នុងផ្លូវដែលត្រូវ ដើម្បីឲ្យកើតបញ្ញាត្រាស់ដឹង សច្ចធម៌ ជាហេតុឲ្យរួចផុតចាកសេចក្តីទុក្ខ ។ មានតែធាតុបញ្ញាដែលអាស្រ័យនៅក្នុងខ្លួន របស់មនុស្សមួយប៉ុណ្ណោះ

ដែលធ្វើឲ្យគេស្គាល់ថា ពំនឹងខ្ពង់ខ្ពស់របស់មនុស្សគឺ : ព្រះពុទ្ធ, ព្រះធម៌ និងព្រះសង្ឃ មិនមែនវត្ថុដទៃក្រៅពីនេះឡើយ ។ ប្រសិនបើរួមពំនឹងទាំងអស់ឲ្យនៅត្រឹមមួយក៏គ្មានអ្វីដទៃទេ គឺអរិយសច្ចធម៌ ហ្នឹងតែម្តង ។ ដូចនេះព្រោះអ្វី? ព្រោះពំនឹងទាំងឡាយមានព្រះពុទ្ធជាដើម ជាពំនឹងផ្តល់ឲ្យនូវអរិយសច្ចធម៌នៅខាងចុងបំផុត ។ ព្រះពុទ្ធសាងបារមីដើម្បីជាស្ពានទៅកាន់សច្ចធម៌ ព្រះសង្ឃទាំងឡាយត្រាស់ដឹងនូវអរិយសច្ចធម៌តាមព្រះពុទ្ធ, ព្រះធម៌របស់ព្រពុទ្ធជាចង្កៀងនៃគំនិតរបស់អ្នកស្វែងរកអរិយសច្ចធម៌ ។ ដោយអាស្រ័យន័យនេះ, ទើបបណ្ឌិតទាំងឡាយនៃពុទ្ធសាសនា លោកថាជាតុទាំងឡាយ មានដើមឈើជាដើម ដែលមនុស្សយកមកធ្វើជាទីពំនឹងនោះ មិនមែនជាពំនឹងផ្តល់ឲ្យនូវអរិយសច្ចធម៌ទេ ។ ផ្ទុយទៅវិញ គឺផ្តល់ឲ្យនូវកំហាកដល់អ្នកស្វែងរកអរិយសច្ចធម៌នៅក្នុងកម្រិតមួយរយភាគរយ ប្រសិនបើគេនៅតែប្រកាន់យក គំនិតនេះរហូតទៅគ្មានប្តូរ ។ ពាក្យថា «ពំនឹង» និងពាក្យថា «រឭក» ជាតុទាំងពីរនេះមានសំឡេងខុសគ្នា តែមានន័យត្រូវគ្នា ។ «ពំនឹង» មានន័យថា «អាង» «រឭក» មានន័យថា «ចងចាំ» ។ «អាង» គឺអាងផ្លូវប្រតិបត្តិ, អាងបារមីធម៌ដែលព្រះពុទ្ធទាំងឡាយធ្លាប់បានដើរ, ធ្លាប់បានសាងមកហើយ ហើយដើរតាម ឬសាងតាម ឬអនុវត្ត ។ «រឭក» គឺចងចាំ ឬដឹងស្គាល់នូវផ្លូវប្រតិបត្តិ ឬបារមីធម៌ដែលព្រះពុទ្ធទាំងឡាយធ្លាប់បានដើរ ធ្លាប់បានសាងមកហើយ ហើយដើរតាម ឬសាងតាម ឬអនុវត្ត ។ ពាក្យទាំងពីរនេះប្រើបានដូចគ្នាប្រសិនបើយើង បានស្គាល់ន័យរបស់ពាក្យនេះជាក់លាក់ហើយ ។ តែបើយើង មិនស្គាល់ន័យ ឬយល់ន័យមិនច្បាស់លាស់ទេ យើងគួរប្រើរឭកល្អជាងប្រើពំនឹង ព្រោះពំនឹងគេច្រើនតែ ចូលចិត្ត ច្រឡំថា ខ្លួនគេម្នាក់ៗ មិនមានការចាំបាច់ត្រូវប្រព្រឹត្តប្រតិបត្តិធម៌ ឬសាងសន្សំបារមីធម៌ ឬអនុវត្តកិច្ចការអ្វីទេ ។ គេមាន ករណីយ៍ត្រឹមតែអំពានាវបន់ស្រន់ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃសុំកុំឲ្យមានទុក្ខ សុំឲ្យបានសុខ គឺគេសុំឲ្យ ព្រះរតនៈត្រៃបំបាត់ទុក្ខផ្តល់សុខឲ្យគេ ។ គេភ្លេចថា ព្រះពុទ្ធទាំងឡាយមានមុខការត្រឹមតែពន្យល់ប្រាប់ផ្លូវ អាក្រក់ល្អ, ព្រះធម៌មានលក្ខណៈត្រឹមតែជាចង្កៀង នៃចិត្តវិញ្ញាណរបស់សត្វលោក ។ ចំណែកការ អនុវត្តទំរើ អាក្រក់ល្អនិងការប្រើពន្លឺចង្កៀង វាជាភារៈរបស់អ្នកដែលមាន ជីវិតកំពុងអន្ទោល ឬអ្នកមានចិត្តធុញ ទុក្ខចំណូលសុខ ។

២- សាសនាដែលគោរពបូជាដល់ទេវតាសាងលោក ។ គេមានជំនឿថា របស់អ្វីៗទាំងអស់ក្នុងលោកនេះ រួមទាំងពិភពលោកផង ត្រូវតែមានទេវតាម្នាក់ដែលមានអំណាចខ្លាំងពូកែបំផុតសាងឡើង ។ មនុស្សទាំងឡាយ ត្រូវតែមានចិត្តភក្តីភាព, មានចិត្តស្មោះត្រង់ បួងសួងបន់ស្រន់នឹងធ្វើសំណូមពរ ចំពោះព្រះអាទិទេពអ្នកមានភាពធំដុំ, មានឫទ្ធិ, មានអំណាច សូមជួយបំបាត់ទុក្ខបង្កើតសុខ ។ សាសនាប្រភេទនេះហៅថា «ទេវនិយម» បានដល់សាសនាគ្រិស្ត, សាសនាអិស្លាម និងសាសនាហិន្ទូ ឬសាសនាព្រាហ្មណ៍ ព្រោះសាសនាទាំងអស់នេះ សូម្បីដាក់ឈ្មោះអាទិទេពផ្សេងគ្នាជា**យ៉ះហូវ៉ា អាឡោះឬអាឡា សិវៈឬឥសូរ**ក៏គង់មានជំនឿស្របគ្នាថា មនុស្សសត្វ ឬពិភពលោក ត្រូវបង្កើតឡើងដោយព្រះអាទិទេព ។ តាមចេតនារម្មណ៍របស់ប្រជាជាតិក្នុងបស្ចិមប្រទេស សឹងធ្លាប់អប់រំគ្នាឲ្យមានជំនឿក្នុងព្រះអាទិទេពមកហើយ បើមាននរណាបង្រៀនមនុស្សឲ្យមានជំនឿផ្ទុយពីនេះ គេទុកដាក់ជាទំរើអាក្រក់ នាំមកនូវភាពសាបសូន្យយ៉ាងខ្លាំងក្លា ។ ដូចនេះបស្ចិមជនដែលរស់នៅក្នុងទ្វីបអឺរ៉ុបដែល មានជំនឿក្នុងព្រះពុទ្ធសាសនា បើកាលណានិពន្ធសៀវភៅស្តីដោយពុទ្ធសាសនា គេមានសេចក្តីលំបាកស្ទាក់ស្ទើរ ក្នុងចិត្តច្រើន គឺថា បើនិយាយដល់ភាពល្អរបស់ព្រះពុទ្ធត្រង់ៗទៅ ខ្លាចក្រែងដឹកនាំមនុស្សមិនបានច្រើន ឧទាហរណ៍ ដូចនិយាយថា ពុទ្ធសាសនាជាអទេវនិយម ពុំបានបង្រៀនថា មានព្រះអាទិទេពសាងលោក ។ តែទោះជាយ៉ាងណា ក៏ដោយ, មានអ្នកនិពន្ធខ្លះហ៊ាន និយាយត្រង់ៗចំៗដែរ ព្រោះគេមានគំនិតថា ការនិយាយប្រាប់ហេតុផល គឺជារឿងរបស់អ្នកនិពន្ធ ។ អ្នកមានជំនឿយ៉ាងណា ឬមានការចាប់អារម្មណ៍យ៉ាងដូចម្តេច វាជរឿងមួយផ្សេងទៀត ។

ឥរិយាបទរបស់ពុទ្ធសាសនា ដែលមានចំពោះសាសនាប្រភេទនេះ យើងអាចនិយាយបានយ៉ាងខ្លីៗថា

សាសនាប្រភេទទេវនិយម អ្នកកាន់មានជំនឿក្នុង **ព្រហ្មលិខិត** គឺជោគវាសនារបស់មនុស្ស មានភាពបែបណាៗ ស្រេចហើយតែព្រះព្រហ្ម ឬព្រះអាទិទេពគួសឲ្យ ។

តែព្រះពុទ្ធសាសនាមានជំនឿក្នុង **កម្មលិខិត** គឺទំរើរបស់មនុស្សដោយន័យថា មនុស្សសាងជោគវាសនាអាក្រក់ល្អខ្លួនឯង, សាងវឌ្ឍនភាពនិងហាយនភាពក៏ដោយខ្លួន មានទំរើអាក្រក់ល្អ របស់ខ្លួនជាធាតុគូសឲ្យ ។ ព្រោះហេតុនេះ, ពាក្យឱវាទពុទ្ធសាសនា ទើបពុំបានដឹកនាំឲ្យ មនុស្សសម្ដែងសេចក្ដីស្វាមីភក្ដិចំពោះព្រះអាទិទេព, ពុំមាននិយាយពីសេចក្ដីអាក្រក់ល្អរបស់មនុស្ស ជាប់ទាក់ទងជាមួយព្រះអាទិទេពទេ ។ វឌ្ឍនភាពនិងហាយនភាពរបស់មនុស្ស ក៏ពុំមែនបានសម្រេចដោយសេចក្ដីប្រោសប្រណីរបស់ព្រះអាទិទេពដែរ គឺសម្រេចដោយទំរើអាក្រក់ល្អរបស់ខ្លួននៃមនុស្សម្នាក់ៗ ។ ពុទ្ធសាសនាបង្រៀនឲ្យមនុស្ស ធ្វើការងារល្អ ឲ្យឈប់ធ្វើការងារអាក្រក់ ព្រមគ្នានេះបញ្ជាក់ថា មានតែការងារអាក្រក់ល្អរបស់មនុស្សប៉ុណ្ណោះទេ ដែលផ្ដល់សុខទុក្ខឲ្យមនុស្ស ។ គោលឱវាទនៃពុទ្ធសាសនា ដឹកនាំឲ្យមនុស្សវៀរចាកទំរើអាក្រក់ បង្កើតទំរើល្អនិងជម្រះចិត្តឲ្យស្អាតបរិសុទ្ធ ដូចបាននិយាយមកហើយ ក្នុងគោលធម៌ទូទៅ ។

សំនេរដូចនេះ, អាចមានសំណួរថា : បើពុទ្ធសាសនាប្រកាន់យកកម្មអាក្រក់ល្អ ជាប្រភពនៃសេចក្ដីសុខទុក្ខ ឬគុណសម្បត្តិ និងគុណវិបត្តិកើតឡើងដោយអាស្រ័យទំរើល្អអាក្រក់ ហេតុអ្វីបានជាពុទ្ធសាសនិកជន សូត្រធម៌សូមសិរីសួស្ដីជ័យមង្គលអំពីពួកទេវតា សូមសេចក្ដីសុខចម្រើនអំពីព្រះរតនៈត្រៃដែរ? ។ ខ្ពស់ជាងនេះទៅទៀត, ភិក្ខុសាមណេរមានសូត្រមន្តបំបាត់ទុក្ខ ចម្រើនសុខ តើទំរើនេះមានន័យដូចម្ដេចដែរ? ចំពោះសំណួរនេះ ខ្ញុំសូមឲ្យចម្លើយថា : ធម៌សូត្រមន្តចំណែកខ្លះ និងធម៌សូត្រធ្វើសំណូមពរខ្លះ គេទើបនឹងតែងក្នុងពេលខាងក្រោយពុទ្ធបរិនិព្វានហើយគេ យកធម៌សូត្រមន្តថ្មី និងសូត្រសំណូមពរថ្មី ដាក់ចូលជាមួយធម៌សូត្រមន្តចាស់ ឬកម្មផល, ដែលអ្នកស្រាវជ្រាវយល់ថា ទំរើនេះគេធ្វើឡើងដើម្បីប្រមូលយកមនុស្សឲ្យបានច្រើន ព្រោះមនុស្សជំនាន់នោះគេបានបាក់ចិត្តជឿសាសនាព្រាហ្មណ៍ និងសាសនាធម្មជាតិ ជាសានាប្រកាន់យកការសូត្រមន្តបួងសួងបន់ស្រន់ជាធំ ។ សេចក្ដីពិតការសូត្រមន្តដែល កើតមានក្នុងព្រះពុទ្ធសាសនានោះ ដំបូងឡើយប្រហែលទន្ទេញឲ្យចាំ ដើម្បីប្រព្រឹត្តប្រតិបត្តិ ឬអនុវត្តហ្នឹងទេ ព្រោះអត្ថន័យធម៌សូត្រមន្តដែលមិនមែនទើបតែនឹងបង្កើតថ្មី ឬមិនមែនជារបស់ខ្ចីពីសាសនាដទៃគឺជាពុទ្ធភាសិនមែនៗ ដូចសូត្រទាំងឡាយមានមង្គលសូត្រ និងករណីយមេត្តសូត្រជាដើម មិនមែនឃើញពាក្យសូត្រសូមពរ, សូមការពារទេ ឃើញមានតែពាក្យប្រាប់ផ្លូវប្រតិបត្តិ និងការអនុវត្ត ។ ពុទ្ធភាសិតមង្គលសូត្រ, បើគេប្រព្រឹត្តតាមបាន គេនឹងបានទទួល នូវសេចក្ដីចម្រើនជាមិនខាន ។ ក្នុងករណីយមេត្តសូត្រ, បើគេអនុវត្តបានគេនឹងមានចិត្តល្អ គ្មានចងពំនៀរ, គ្មានខ្ញប់គំនុំ ។ គេដេកលក់ស្រួល គ្មានសុបិនអាក្រក់ ។ល។ ព្រះសម្មាសម្ពុទ្ធព្រះអង្គធ្លាប់មានព្រះតម្រាស់ថា អ្នកណាឃើញធម៌, ស្រឡាញ់ធម៌, គោរពធម៌, បូជាធម៌, ប្រតិបត្តិធម៌ អ្នកនោះឈ្មោះថាបានឃើញ, បានស្រឡាញ់, បានគោរព, បានបូជា, បានប្រតិបត្តិតាមព្រះអង្គ ។ សេចក្ដីនេះបញ្ជាក់ឲ្យឃើញថា ការឃើញព្រះពុទ្ធក្ដី ការសូត្រធម៌ក្ដី ការចាំធម៌ក្ដី ការចេះធម៌ក្ដី ទាំងអស់នេះជាការធម្មតាទេ ។ ការប្រតិបត្តិធម៌ ឬអនុវត្តធម៌ទើបជាការមានកម្ពស់, មានតម្លៃ, មានសុភមង្គល, មានវឌ្ឍនភាព, មានលក្ខណៈត្រឹមត្រូវតាមគោលគំនិតនៃពុទ្ធសាសនា ក្នុងចំណុចបំបាត់ទុក្ខ ចម្រើនសុខរបស់ប្រជាសត្វលលោក នៅលើការអនុវត្តនូវទំរើ ពុំមែននៅលើការសូត្រមន្តបួងសួងឡើយ ។

ការកត់សម្គាល់ជាទូទៅ ធម៌សូត្រមន្តក្នុងព្រះពុទ្ធសាសនា មានមកក្នុងត្រៃបិដកជាចំណែកច្រើន ។ ចំណែកធម៌សូត្រមន្តដែលទើបនឹងបង្កើតថ្មី ហើយដាក់ចូលមកក្នុងបិដក មិនសូវជាមានច្រើនប៉ុន្មានទេ ។ នេះគឺជាធម្មតា, នៅក្នុងពិភពលោកនៃមនុស្សនេះ គេលំបាកនឹងរកឲ្យបាននូវរបស់សុទ្ធ, របស់គ្មានធាតុផ្សំលាយនោះពន់ពេកណាស់

។ ទំនិញក្តី ដំណូរក្តី ច្រើនលាយផ្សំជាមួយធាតុដទៃ ដើម្បីបង្កើនបរិមាណនិងទម្ងន់ ក្នុងគំនិតលោកចង់បានចំណេញ, ចង់បានប្រសិទ្ធភាព ខុសភាពពិតក៏មានច្រើនណាស់ដែរ ។ ជាមួយគ្នានេះទៀត, ការលោមចិត្ត, ការបោកបញ្ឆោត ដោយកលឧបាយផ្សេងៗ បំភាន់គំនិត, បំបិទបញ្ញា ធ្វើឲ្យមនុស្សបាក់ចិត្តជឿស្តាប់ចុះចូលរាប់អានសាសនា, ទំនៀមទម្លាប់, ប្រពៃណីនិយមរបស់ខ្លួនក្នុងបំណងទាញយកប្រយោជន៍ យកកេរ្តិ៍ឈ្មោះក៏មានច្រើនអនេក ។ ទំរើអស់ទាំងនេះ មិនមែនជាគោលគំនិតរបស់ពុទ្ធសាសនាទេ ។ ពុទ្ធសាសនានិយមទំរើពិត, ទំរើយុត្តិធម៌ ។ ពុទ្ធសាសនាបញ្ជាក់ជាឪឡារិកថា ការបន់ស្រន់សូមសេចក្តីសុខ ការអំពាវនាវសុំជោគជ័យអំពីវត្ថុទាំងឡាយ មានព្រះអាទិទេពជាដើម កុំថាឡើយត្រឹមតែមួយដងមួយកាល, ទោះជានិច្ចនិរន្តរ៍ ក៏ពុំបានសម្រេចដែរ ។ ព្រះសម្មាសម្ពុទ្ធ, ព្រះអង្គទន្ទេញជាប់ថា : សេចក្តីសុខទុក្ខកើតអំពីការងារល្អអាក្រក់ បុគ្គលណាសាងកម្មល្អ បានផលជាសុខបុគ្គលណាសាងកម្ម អាក្រក់បានផលជាទុក្ខ ។ ក្នុងរឿងដដែលនេះ ព្រះអង្គបានធ្វើសេចក្តីបញ្ជាក់បន្ថែមថា «**សព្វេ សត្តា កម្មសកា** . . . . សត្វទាំងឡាយទាំងពួងមានការងារជារបស់ខ្លួន មានខ្លួនជាមរតករបស់ការងារ មានការងារជាកំណើត មានការងារជាញាតិមិត្ត មានការងារជាទីរឭក ឬជាបង្អែក ។ សត្វទាំងឡាយ ធ្វើការងារណា អាក្រក់ក្តី ល្អក្តី សត្វទាំងឡាយនោះនឹងជា មរតកនៃការងាររបស់ខ្លួន» អ្នកអានទាំងឡាយ គួរធ្វើការកត់សម្គាល់ថា ពុទ្ធភាសិតនេះ ពុំបានសំដៅយកការសូត្រ, ការចេះដឹង, ការចងចាំ ទុកជាធាតុបង្កើតផលបង្កើនប្រយោជន៍ទេ គឺសំដៅយកការប្រព្រឹត្តប្រតិបត្តិ ឬអនុវត្ត ជាធាតុបង្កើតផល បណ្តុះវឌ្ឍនភាព ឬហាយនភាពស្រេចហើយ តែការងារអាក្រក់ល្អ ។ ដូចនេះ, ការសូត្រធម៌ដែលមានលក្ខណៈជាធម៌បន់ស្រន់ក្តី ការសូត្រធម៌គ្មានអនុវត្តក្តី ។ល។ វាមិនត្រឹមតែមិនបានសម្រេចប្រយោជន៍អ្វីប៉ុណ្ណឹងទេ គឺវានាំឲ្យខាតពេលឥតអំពើទៀតផង ។ រឿងពូកែសូត្រធម៌ មិនពូកែអនុវត្ត ឬពូកែបន់ស្រន់មិនពូកែធ្វើការ វាមិនខុសគ្នានឹង រឿងពូកែចាំតម្រាផ្សំឱសថ តែមិនបានផ្សំឱសថ ឬមានឱសថហើយ មិនចេះប្រើព្យាបាលតំហឺ (ជម្ងឺ) ។ ទំរើទាំងពីរ យ៉ាងនេះ មានលទ្ធផលសូន្យដូចគ្នា ។

រួមសេចក្តីក្នុងឃ្លានេះថា : ពុទ្ធសាសនាពុំបានបង្រៀនរឿងអាទិទេពសាងលោក, ពុំបានបង្រៀនរឿងឫទ្ធិអំណាច តេជៈ បង្កើតជានេះ បណ្តាលជានោះ របស់វត្ថុធាតុទាំងឡាយមានជាអាទិទេពជាដើម ដែលគេមានជំនឿថា ខ្លាំងពូកែឡើយ ។ តែពុទ្ធសាសនា, បង្រៀនឲ្យមនុស្សសាងសេចក្តីចម្រើនរុងរឿងដល់ខ្លួនតាមភាពពិត ដោយធ្វើការល្អ គ្រប់យ៉ាង មិនធ្វើការងារអាក្រក់ជាទូទៅ ។

៣- សាសនាដែលពុំបានបង្រៀនអំពីរឿងអាទិទេពសាងលោកមានឈ្មោះថា «អទេវនិយម» បានដល់សាសនាពុទ្ធនិងសាសនាជេន ។ សាសនាទាំងពីរនេះមានគំនិតខុសគ្នាច្រើនដែរ តែគោលគំនិតធំ គឺមិនបង្រៀនអំពីរឿងព្រះអាទិទេពសាងលោក, មិនទទួលស្គាល់ថា ពិភពលោកមួយអន្លើដោយមនុស្សសត្វ . . ត្រូវសាងឡើងដោយព្រះអាទិទេព ។

សាសនាជេន (JAINISM) ជាសាសនាបង្កើតឡើងដោយសាស្តាចារ្យឈ្មោះ**មហាវីរៈ**។ សាសនានេះមានឈ្មោះម៉្យាងទៀតថា**និគ្រន្ថ**ក៏ត្រូវបានគេហៅផងដែរថា សាសនាជេន, មានគោលធម្មៈនៅចន្លោះ សាសនាព្រាហ្មណ៍ និងសាសនាពុទ្ធ ។ មិនត្រូវនឹងព្រាហ្មណ៍ក្នុងរឿងអាទិទេពសាងលោក ត្រូវគ្នានឹងពុទ្ធក្នុងរឿងបង្រៀនគោលការណ៍អហិង្សា ។ តែមិនស្របគ្នាជាមួយនឹងពុទ្ធ ត្រង់ចំណុចដែលសាសនាជេនបង្រៀនរឿងមានអត្តា ព្រះពុទ្ធសាសនា បង្រៀនរឿងអនត្តា ។ សាសនាជេនចែកចេញជាពីរនិកាយ គឺនិកាយមានគ្រឿងសម្លៀកបំពាក់ពណ៌ស និងនិកាយមិនមានសម្លៀកបំពាក់ ។ មានរឿងមួយទៀត, ដែលគួរធ្វើការកត់សម្គាល់ជាមួយគ្នានេះដែរគឺសាសនាជេន មិនត្រឹមតែ មិនទទួលស្គាល់ថា ពិភពលោក . . ត្រូវសាងឡើងដោយ

ព្រះអាទិទេពប៉ុណ្ណឹងទេការបដិសេធថាមិនមាន ព្រះអាទិទេព ក៏ជាទំរើដែលសាសនានេះ បានធ្វើយ៉ាងចេញមុខទៀតផង ។

ព្រះពុទ្ធសាសនារបស់យើង ពុំបានបង្រៀនរឿងអាទិទេពសាងលោក តែមិនបានធ្វើសេចក្ដីបដិសេធ, មិនបានដឹកនាំពុទ្ធបរិស័ទឲ្យប្រមាថមើលងាយ សាសនាដែលបង្រៀនរឿងព្រះអាទិទេពសាងលោក ។ ព្រះសម្មាសម្ពុទ្ធនៃយើង បានត្រឹមតែឲ្យចម្លើយថា ពិភពលោកទោះកើតឡើងដោយមានអ្នកសាងក្ដី គ្មានអ្នកសាងក្ដី បញ្ហានេះវាហួសពេល ដោះស្រាយទៅហើយ ។ បញ្ហាដែលគេត្រូវដោះស្រាយជាបន្ទាន់ គឺពិភពលោក . . . ជាធាតុឋិតនៅក្នុងភាពមិនទៀង, ភាពធន់ទ្រាំ, ភាពគ្មានខ្លឹមសារដែលអ្នកសាងលោក ទោះជាអាទិទេពក្ដី ព្រហ្មក្ដីប្រសិនបើមាន ។ល។ ក៏ពុំអាចគេចផុតអំពីធាតុទាំង ៣ (**អនិច្ចំ, ទុក្ខំ, អនត្តា**) នេះបានឡើយ ។ ដោយហេតុថាពុទ្ធសាសនាមិនបានធ្វើសេចក្ដី បដិសេធព្រះអាទិទេព មិនបានបង្រៀនបរិស័ទឲ្យស្អប់ សាសនាមានព្រះអាទិទេព, ទើបមានអ្នកនិពន្ធរឿងពុទ្ធសាសនា ខ្លះ ខំធ្វើសេចក្ដីបំភ្លឺថា ពុទ្ធសាសនាមិនមែនទាំងទេវនិយម ទាំងអទេវនិយម ។ គំហើញរបស់ខ្ញុំថា ការចាត់ពុទ្ធសាសនាចូលក្នុងប្រភេទអទេវនិយម ជាចំណាត់ត្រឹមត្រូវគួរដល់ហេតុផលហើយ ព្រោះពុទ្ធសាសនាមិនត្រូវការឲ្យមនុស្សធ្វើការ ឬរាប់អាន ឬប្រកាន់យកនូវអ្វីៗ ផ្អែកលើជំនឿតែម៉្យាងប៉ុណ្ណឹងទេ ។ ព្រះសម្មាសម្ពុទ្ធបង្រៀនហើយបង្រៀន ទៀតថា មនុស្សត្រូវមានបញ្ញាពិចារណារកខុសរកត្រូវ ក្នុងទំរើដែលខ្លួនមានជំនឿនោះផង មុននឹងចាប់ធ្វើការ ឬមុននឹង ការរាប់អាន ឬប្រកាន់យក ។ អ្នកប្រតិបត្តិធម៌ ប្រសិនបើមានជំនឿនិងបញ្ញាទាំងគូនេះហើយ, ការអនុវត្តរបស់គេមុខជា នឹងបានត្រឹមត្រូវតាមគោលការណ៍សីលធម៌ និងមាគ៌ារលត់ទុក្ខជាមិនខាន ។ ភាពល្អអាក្រក់របស់មនុស្ស មិនមែននៅលើមានជំនឿក្នុងព្រះអាទិទេព ។ តែនៅលើទំរើនិងការប្រព្រឹត្តប្រតិបត្តិ ។ បើនឹងស្ដីម៉្យាងទៀតថា ពុទ្ធសាសនា មិនត្រូវការឲ្យមនុស្ស ធ្វើការដោយគ្មានប្រើបញ្ញាដូច្នេះវិញក៏បាន ។ ព្រោះហេតុដូចនោះ, គោលការណ៍ សំខាន់ៗរបស់ពុទ្ធសាសនា ទើបត្រូវឋិតនៅលើគោលធម៌ផ្អែកណាដែលបង្រៀនឲ្យ ត្រិះរិះពិចារណារកហេតុផល ជាមុន ទើបអនុវត្តជាខាងក្រោយ ដូចនឹងមាននិយាយតទៅ ។

លក្ខណៈនៃការបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធមាន ៣ យ៉ាង

១- បង្រៀនឲ្យចេះដឹងស្គាល់សេចក្ដីពិតនៅក្នុងធម៌ដែលគួរដឹង គួរឃើញ ។

២- បង្រៀននៅក្នុងក្របខ័ណ្ឌនៃហេតុផល ដែលអ្នករៀនអានត្រិះរិះពិចារណាតាមឃើញភាពពិតដោយខ្លួនឯង ។

៣- បង្រៀននៅក្នុងក្របខ័ណ្ឌនៃភាពអស្ចារ្យ ដែលអ្នកប្រតិបត្តិរមែងបានទទួលផល តាមសមគួរដល់ការបរតិបត្តិរបស់ខ្លួន ។

កាលណាបើអ្នកអាន, បានស្ដាប់ចំណាត់សាសនានានា ដូចបានពោលមកហើយ អ្នកអាននឹងបានដឹងថា : សាសនាណាចូលចិត្តបង្រៀនរឿងអ្វី, មានធម៌អ្វីជាមូលដ្ឋាននៃការបង្រៀន ។ គឺ**សាសនាធម្មជាតិ**ទេវនិយមចូលចិត្តបង្រៀនឲ្យមនុស្សស្គាល់ធម្មជាតិផ្សេងៗ ដែលគេទុកដាក់ថា មានអាទិទេពនៅអាស្រ័យ ។ **សាសនាទេវនិយម** ចូលចិត្តបង្រៀនឲ្យមនុស្សស្គាល់ ហើយគោរពកោតខ្លាចព្រះអាទិទេព ។ **សានាអទេវនិយម** ជាពិសេសគឺព្រះពុទ្ធសាសនា ចូលចិត្តបង្រៀនឲ្យមនុស្ស ចេះដឹងស្គាល់នូវសេចក្ដីពិតនៃ សភាវៈធម៌ ឬសច្ចធម៌, សឹងមានលក្ខណៈប្លែកពីសាសនាទាំងឡាយដទៃ ដែលចូលចិត្តដឹកនាំមនុស្សឲ្យស្គាល ឫទ្ធិអំណាចរបស់ធម្មជាតិ, របស់វត្ថុស័ក្ដិសិទ្ធិរហូតដល់ភាពខ្លាំងពូកែនៃព្រះអាទិទេព ។

តាមទស្សនៈរបស់អ្នកស្រាវជ្រាវជាទូទៅ និងតាមសេចក្ដីសង្កេតរបស់ខ្ញុំ, ខ្ញុំយល់ឃើញថា ការបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធដូចបានចែងមកហើយ ជាធាតុសមគួរល្មមដល់ចិន្ដានៃមនុស្សក្នុងសម័យនោះហើយ ។ តែដើម្បីឲ្យស្របតាមគំនិតថ្មីរបស់មនុស្ស ក្នុងសម័យបច្ចុប្បន្ន ឬសម័យរុងរឿងនៃវិទ្យាសាស្ត្រទាំងផ្នែករូប ទាំងផ្នែកចិត្ត ប្រសិនបើ ចែកលក្ខណៈនៃការបង្រៀនជា ៣ យ៉ាងដូចគ្នានេះទៀត តែមានន័យផ្សេងៗគ្នា គឺប្រហែលគ្មានទាស់ខុសអ្វីដែរគឺ :

១- បង្រៀននៅក្នុងក្រខ័ណ្ឌនៃការបដិវត្តន៍ គឺលុបបំបាត់ទាំងស្រុងនូវគោលគំនិតដើម ឬជំនឿចាស់របស់សាសនាប្រពៃណី ហើយដាក់គំនិតថ្មី ឬធម្មៈថ្មីជំនួស ។

២- បង្រៀននៅក្នុងក្របខ័ណ្ឌនៃបដិរូបគឺជួសជុលបានដល់ការដកចេញខ្លះ ដាក់ចូលខ្លះ ។

៣- បង្រៀនដោយបង្កើតក្របខ័ណ្ឌថ្មី គឺបង្រៀនធម្មៈដែលគ្មាននរណាទាន់បង្រៀន ដែលមិនធ្លាប់មានក្នុងសាសនាដទៃ បានដល់បង្រៀនអំពីសច្ចធម៌ ៤ ប្រការ ដែលព្រះសម្មាសម្ពុទ្ធព្រះអង្គឯង បានស្រាវជ្រាវរាវរកឃើញ ។ ដើម្បីឲ្យអ្នកអានបានយល់ន័យ នៃការបង្រៀនទាំង ៣ ប្រការនេះ ខ្ញុំសូមធ្វើសេចក្ដីបំភ្លឺក្នុងទីនេះខ្លះដូចមានតទៅ :

ក- ដែលថាបង្រៀននៅក្នុងក្របខ័ណ្ឌនៃការបដិវត្ត ឬរបៀបបដិវត្តនោះ ដោយកការដូរគោលការណ៍ចាស់ ឬរបបទាំងអស់ ដែលគេធ្លាប់បង្រៀនមក ឬធ្លាប់មានជំនឿក្នុងបូរាណកាល ដូចជាសាសនាព្រាហ្មណ៍ធ្លាប់បង្រៀនមនុស្សឲ្យសម្លាប់សត្វបូជាយញ្ញ ។ ព្រះពុទ្ធបរមគ្រូបានបដិសេធចោល ហើយបង្រៀនធម្មៈនៅក្នុងក្របខ័ណ្ឌថ្មី ដែលមានលក្ខណៈផ្ទុយគ្នាពីក្របខ័ណ្ឌចាស់ស្រឡះ គឺបង្រៀនឲ្យមនុស្សមានចិត្តមេត្តាករុណាដល់សត្វជំនួសវិញ ។ គេមានទម្លាប់បង្រៀនមនុស្សឲ្យធ្វើទារុណកម្មខ្លួនឯងក្នុងការប្រតិបត្តិធម៌ ដើម្បីលុះមគ្គផលជាន់ខ្ពស់ ព្រះអង្គបានពិសោធន៍មើលឃើញថា មិនមែនជាផ្លូវសម្រាប់ត្រាស់ដឹងនូវមគ្គនិងផល បានបដិសេធចោល ហើយបង្រៀនរបៀបថ្មីដែលយើងស្គាល់ថា**មជ្ឈិមាបដិបទា**ជំនួសវិញ ។ នៅក្នុងសាសនាព្រាហ្មណ៍គេធ្លាប់បង្រៀនថា មនុស្សមានអាត្ម័ន ព្រះអង្គលុបបំបាត់ចោល ហើយបង្រៀនផ្ទុយពីនេះ គឺអត្តាជំនួសវិញ ។ សូមបញ្ជាក់ថា «បដិវត្ត» (REVOLUTION) ពាក្យនេះនៅជិតគ្នានឹងពាក្យ «វិវត្ត» (EVOLUTION) បដិវត្តមានន័យថា ផ្លាស់ទាំងស្រុង ឬត្រឡប់ទាំងមូល ឬលុបបំបាត់ទាំងអស់ ។ «ផ្លាស់ទាំងស្រុង» ដូចរុះផ្ទះចាស់ចោលសង់ផ្ទះថ្មីជំនួស ។ «ត្រឡប់ទាំងមូល» ដូចត្រឡប់បាតដៃជាខ្នងដៃ «លុបបំបាត់ទាំងអស់» ដូចលុបពណ៌សចេញដាក់ពណ៌ខ្មៅជំនួស ។ ចំណែកបដិវត្ត ឬវិវឌ្ឍនៈ ដោយកភាពចម្រើន ឬភាពផ្លាស់ប្ដូរសន្សឹមៗ បន្តិចម្ដងៗទាំងខាងធម្មជាតិ ទាំងខាងជីវភាពរបស់មនុស្ស ។ ដើម្បីពង្រីកនិងពង្រឹងវឌ្ឍនភាពទូទៅ កម្មវិធីសិក្សា ឬកម្មវិធីបង្រៀនធម្មៈរបស់ព្រះសម្មាសម្ពុទ្ធ ត្រូវបានរៀបចំនៅក្នុងក្របខ័ណ្ឌ ។

ខ- ដែលបង្រៀននៅក្នុងក្របខ័ណ្ឌបដិរូប (REFORM) គឺច្នៃរបស់ចាស់ឲ្យមានភាពល្អលើសដើមឡើង ដោយឲ្យន័យថ្មីខ្លះ ដោយឲ្យហេតុផលថ្មីខ្លះ ដូចជាសាសនាព្រាហ្មណ៍បង្រៀនថា ព្រាហ្មណ៍ជាមនុស្សមានតម្លៃខ្ពង់ខ្ពស់ដោយកំណើត (កើតមកខ្ពង់ខ្ពស់ឯងៗតែម្ដង) ។ ព្រះសម្មាសម្ពុទ្ធព្រះអង្គឲ្យន័យថ្មីថា មនុស្សយើង ពុំមែនមានតម្លៃព្រោះជាតិត្រកូលពូជអម្បូរ ។ល។ ឡើយ, តែតម្លៃរបស់មនុស្សកើតមានព្រោះទំរើល្អ ឬការព្រឹត្តប្រតិបត្តិត្រឹមត្រូវ ។ សាសនាព្រាហ្មណ៍បង្រៀនថា មនុស្សសាងបាប កាលណាបានចុះងូតទឹកក្នុងស្ទឹងទន្លេស័ក្ដិសិទ្ធិនឹងបានជ្រះបាបបានទទួលសេចក្ដីបរិសុទ្ធ ។ ព្រះសម្មាសម្ពុទ្ធបង្រៀនឲ្យមនុស្សងូតទឹកក្នុងស្ទឹងស៊ីល បានដល់ការរស់នៅក្នុងសីលធម៌ ។ ការងូតទឹកគ្មានទទឹកខ្លួន តែធ្វើឲ្យខ្លួនមានសេចក្ដីស្អាតបរិសុទ្ធ ល្អជាងងូតទឹក ដែលមានគេទុកដាក់ថា ស័ក្ដិសិទ្ធិនោះទៅទៀត ។ ព្រះអង្គបញ្ជាក់ថា អ្នកនៃការបដិវត្តច្រើនជាងទុកឲ្យនៅ ក្នុងភាពវិវត្តន៍ ។ មានខ្លួនប្រព្រឹត្ត ប្រតិបត្តិល្អហើយ ទោះណាជាមិនបានងូតទឹកក្នុងស្ទឹងស័ក្ដិសិទ្ធិ, ងូតទឹកធម្មតា, ផឹកទឹកធម្មតា,

ទឹកទាំងអស់នេះនឹង ទៅជាទឹកបរិសុទ្ធរបស់អ្នកងូតអ្នកផឹក ឬជាទឹកស័ក្តិសិទ្ធរបស់គេហើយ ។ ចំពោះរឿងទេវតា, ដែលគេបង្រៀនគ្នាជាទូទៅថា មាននៅក្នុងភពដទៃ ឬលោកខាងមុខ ព្រះពុទ្ធសាសនាបង្រៀនថា មនុស្សយើងដែលរស់នៅក្នុងលោកសព្វថ្ងៃ នេះក៏ជាទេវតាដូចគ្នាអញ្ចឹងដែរ ប្រសិនបើក្នុងចិត្តរបស់គេមានធម៌ ទេវតាគឺ : សទ្ធា, សីលៈ, ចាគៈ, សុត្តៈ, បញ្ញា ឬហិរិ, ឱត្តប្បៈ ។ ដើម្បីអ្នកអានមានពន្លឺកាន់តែច្រើនក្នុងរឿងនេះ, ខ្ញុំសូមបញ្ជាក់ថា អ្នកមានមនុស្សធម៌ វេលាអស់ជីវិតទៅ កើតជាមនុស្ស, អ្នកមានទេវធម៌វេលាអស់ជីវិតទៅកើត ជាទេវតា ។ គឺថាបើគ្មានទេពក្នុងឋានមនុស្ស ក៏គ្មានទេពក្នុង ឋានសួគ៌ដែរ បើគ្មាននរកនៅក្នុងលោកនេះ ក៏គ្មាននរកនៅក្នុងលោកដទៃដែរ ។ល។ ព្រោះហេតុនេះបានជា ព្រះសម្មាសម្ពុទ្ធ ព្រះអង្គចែកសត្វជា ៥ ប្រភេទគឺ : សត្វមនុស្ស, សត្វទេព, សត្វនរក, សត្វប្រេត និងសត្វតិរច្ឆាន ។ ក្នុងន័យថាបុគ្គលណា មានធម៌មនុស្សជាសត្វមនុស្ស មានធម៌ទេពជាសត្វទេព មានធម៌នរកជាសត្វនរក មានធម៌ប្រេតជាសត្វប្រេត មានធម៌តិរច្ឆានជាសត្វតិរច្ឆាន ។ សត្វទាំងឡាយនេះ វេលាស្លាប់ត្រូវទៅកើតជាថ្មី មានកំណើតទៅតាមធម៌ដែលខ្លួនមាន អ្នកមានធម៌មនុស្ស កើតជាមនុស្ស អ្នកមានធម៌ទេពកើតជាទេព ។ល។ ក្នុងសាសនាព្រាហ្មណ៍គេឲ្យ កំណើតទេពមានតម្លៃខ្ពស់ជាង កំណើតមនុស្ស, តែពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធបានឲ្យកំណើតមនុស្សខ្ពស់ជាង កំណើតទេព ។ ចំពោះបញ្ហា ដាក់តម្លៃនេះ ប្រសិនបើមានចម្ងល់ យើងមើលហើយគិតឡើងវិញនូវពុទ្ធភាសិតនេះ (**កិច្ឆោ មនុស្សបដិលាភោ... ទុល្លភញ្ចមនុស្សត្តំ**...) ។

គ- ការបង្ហាត់បង្រៀនដោយបង្កើតគោលការណ៍ថ្មី វាជាធាតុមានការចាំបាច់ពន់ពេកណាស់ព្រោះពុទ្ធសាសនា ត្រូវបានបង្កើតឡើងនៅក្នុងលោកជាមួយនិងសាសនាទាំងឡាយដទៃ ប្រសិនបើមិនមានធាតុ អ្វីមួយជារបស់ខ្លួនដាច់មុខ ក៏មិនត្រូវបានឈ្មោះថា ជាសាសនាបង្កើតថ្មីទេ ។ ដូចនេះហើយបានជាគេទុកដាក់ អរិយសច្ចធម៌ ៤ ដែលគ្មាននរណារកឃើញ ហើយដែលរកយលញដោយព្រះសម្មាសម្ពុទ្ធថា ជាគោលគំនិតទំនើបឬក្របខ័ណ្ឌថ្មី ។ គោលការណ៍ថ្មីនេះ ព្រះសម្មាសម្ពុទ្ធបានប្រកាសយ៉ាងឱឡារិក នៅចំពោះមុខឥសីទាំង ៥ រូប (កោណ្ឌញ្ញៈ, វប្បៈ, ភទ្ទិយៈ, មហានាមៈ, អស្សជិ) ថាព្រះអង្គបានរកឃើញនូវធម៌ ដែលគ្មាននរណាទាន់រកឃើញ, ត្រាស់ដឹងនូវធម៌ដែលគ្មាននរណាទាន់ត្រាស់ដឹងនោះឡើយ ។ អ្នកទាំងឡាយ ! ចូរផ្ទៀងត្រចៀកប្រុងប្រៀបស្មារតី ស្តាប់ធម៌ដែលមានអាថ៌កំបាំងនេះចុះ ។ អរិយសច្ចធម៌ ៤ ជាគោលការណ៍ធម៌ថ្មី ។ ជាធម៌ប្រកាសឲ្យប្រើដោយ ព្រះសម្មាសម្ពុទ្ធនោះ ខ្ញុំសូមមិនសរសេរក្នុងទីនេះដោយពិស្តារទៀតទេ ព្រោះសំនេរទូលំទូលាយមានក្នុងបទទី ១ ហើយ, តែដើម្បីដឹងជាបន្ទាន់ សូមប្រាប់ត្រឹមតែចំនួននិងហេតុផលរបស់ធម៌នេះជាថ្មីទៀតមានដូច្នេះ :

**១- ទុក្ខសច្ចៈ** ភាពពិតនៃទុក្ខ,

**២- សមុទយសច្ចៈ** ភាពពិតនៃហេតុរបស់ទុក្ខ,

**៣- និរោធសច្ចៈ** សេចក្តីពិតនៃភាពរលត់ទុក្ខ,

**៤- មគ្គសច្ចៈ** ភាពពិតនៃផ្លូវរលត់ទុក្ខ ។

អរិយសច្ចៈលោកចាត់ថាហេតុផលមានដូចនេះ :

**ទុក្ខសច្ចៈ**ជាផល,**សមុទយសច្ចៈ**ជាហេតុ ។**និរោធសច្ចៈ**ជាផល,**មគ្គសច្ចៈ**ជាហេតុ ។

សេចក្តីសារុប : ព្រះពុទ្ធគឺជានរណា? គឺភាពល្អបរិសុទ្ធ, ភាពស្ងប់ស្ងាត់, ភាពភ្លឺស្វាង, ភាពត្រជាក់ត្រជុំ ។ មានចំនួនប៉ុន្មាន? មាន ៣ គឺ : សម្មាសម្ពុទ្ធ, បច្ចេកពុទ្ធ, សាវ័កពុទ្ធ ឬអនុពុទ្ធ ។ ព្រះពុទ្ធទាំងឡាយ, ព្រះអង្គមានបញ្ញាញាណត្រាស់ដឹងនូវហេតុផល នៃសេចក្តីទុក្ខ, ព្រះអង្គបង្ហាត់បង្រៀនមនុស្សឲ្យ លះបង់នូវហេតុនៃទុក្ខ ឲ្យសាងសន្សំនូវហេតុនៃសុខ ។ អ្វីជាហេតុនៃទុក្ខ? បាបអកុសលជាហេតុនៃទុក្ខ ។ អ្វីជាហេតុនៃសុខ? បុណ្យកុសលជាហេតុនៃសុខ ។ ខ្ពស់ជាងនេះ, ព្រះពុទ្ធព្រះអង្គបង្រៀនមនុស្សឲ្យស្គាល់ទុក្ខ, ឲ្យកត់សម្គាល់នូវភាពនៃទុក្ខ,

ឲ្យចងចាំ នូវភាពនៃទុក្ខទាំងអស់ ។ កាលណាគេស្គាល់ទុក្ខ . . . ហើយ ព្រះអង្គបង្រៀនឲ្យស្គាល់ហេតុនៃទុក្ខ ឲ្យស្គាល់ថាតណ្ហា ជាហេតុនៃទុក្ខ, ឲ្យលះបង់តណ្ហាទាំងអស់ចោល ។ បន្ទាប់មកទៀតព្រះអង្គបង្រៀនឲ្យស្គាលភាពរលត់ទុក្ខ ។ កាលណាគេស្គាល់ភាពរលត់ទុក្ខហើយ ព្រះអង្គបង្រៀនឲ្យស្គាល់ផ្លូវសម្រាប់ធ្វើដំណើរទៅកាន់ភាពរលត់ទុក្ខ ។ ដូចនេះ ខ្មោច, បិសាច, ទេវតា, ឥន្ទព្រហ្ម . . . . ធាតុទាំងអស់នេះមិនមែនជាហេតុនៃសេចក្តីសុខទុក្ខទេឬ? មិនមែន ! ព្រោះអរិយសច្ចៈ ៤ ក្តី, កុសលមូលក្តី, អកុសលមូលក្តីពុំបានចែងថាវត្ថុធាតុទាំងអស់នេះជាហេតុនៃ សេចក្តីសុខទុក្ខ ឡើយ ។ មានតែប្រាប់ថា សកលពិភព សកលមនុស្ស សកលសត្វ សកលវត្ថុទាំងនៅក្នុងទុក្ខ ឬរស់ក្នុងទុក្ខ ។ បើមិនមែន ! ដូចម្តេចក៏ពុទ្ធសាសនិកខ្លះ សូត្រធម៌បន់ស្រន់បួងសួងសូមសុខអំពីវត្ថុអស់ទាំងនោះដែរ ។ សូត្រមែន ! ប៉ុន្តែធម៌សូត្រសូមជំនួយនេះ មិនមែនជាធម្មៈសុទ្ធរបស់ពុទ្ធសាសនាទេ, គឺជាសទ្ធម្មបដិរូប ។ សទ្ធម្មបដិរូប មានន័យ យ៉ាងម៉េច? មានន័យជាធម្មៈ មានលក្ខណៈមិនស្រប ឬផ្ទុយពីធម្មៈដើមរបស់ព្រះសម្មាសម្ពុទ្ធ ព្រោះធម្មៈនេះគេបានខ្ចី មកពីសាសនាព្រាហ្មណ៍ ដែលនិយមសូត្រធម៌បន់ស្រន់ទេវតា សូមផ្តល់សុខបំបាត់ទុក្ខ ។ អ្នកខ្ចីមានគំនិតយ៉ាងណា? មានគំនិតចង់ឲ្យពុទ្ធសាសនាមានគ្នាច្រើន ព្រោះមនុស្សធ្លាប់មានជំនឿក្នុងសាសនាព្រាហ្មណ៍ ដែលមានទេវតាបង្កើត មនុស្សសត្វនិងពិភពលោក ព្រមទាំងផ្តល់សុខទុក្ខដល់មនុស្សផង ។ ប្រសិនបើមិនមានសទ្ធម្មបដិរូបខ្លះ ពុទ្ធសាសនា ក៏មិនសម្បូរអ្នកចុះចូលដែរ ។ គេអាចស្គាល់សទ្ធម្មបដិរូបយ៉ាងណា? ពាក្យខ្មែរគេស្គាល់បានដូចពាក្យ «ចូរ» ឬ «សូម» ជាពាក្យនាំមុខការបន់សុំជំនួយដូចជា :

សូមទេវតាទាំងឡាយរក្សានូវខ្ញុំ ចូរអ្នកមានអាយុវែង ឬពាក្យបាលីគេស្គាល់បានដោយមាន «តុ» ឬ «អន្តុ» នៅខាងចុងដូច សព្វរោគោវិនស្សតុ . . . . . សព្វីតិយោ វិវជ្ជន្តុ . . . . . ។ ចំណែកពុទ្ធធម៌សុទ្ធ បើជាពាក្យខ្មែរយើង គេស្គាល់បានដោយមានពាក្យ «នឹង» នាំមុខ ដូចជាគេធ្វើនូវទំរើល្អ នឹងបានសុខ . . . . . បើជាពាក្យបាលីគេអាចស្គាល់បានដោយមាន «តិ» ឬ «អន្តិ» នៅខាងចុង ដូចជា ធម្មំវទតិ . . . . . ចត្តារោធម្មាវឌ្ឍន្តិ . . . . . ។ សូមបញ្ជាក់ថា ព្រះសម្មាសម្ពុទ្ធពុំដែលមានពំនោលថាចូរ ឬសូមអ្នកមានអាយុវែងដល់ម្តងណាឡើយ ព្រោះព្រះអង្គបានទេសនាថា សកលពិភពលោក និងសកលមនុស្សសត្វមានភាពមិនទៀង, ភាពទុក្ខ, ភាពគ្មានខ្លួនប្រាណជាស្រេចមកហើយ ។ ដើម្បីចូលចិត្តរឿងសទ្ធម្មបដិរូបនេះ យើងត្រូវគិតថា នៅក្នុងលោកយើងនេះ របស់ណាដែលបង្កើតដោយមនុស្ស សុទ្ធតែត្រូវអាស្រ័យបែបចាស់ បើមិនច្រើនក៏តិចដែរ ។ សាសនាព្រាហ្មណ៍កើតមុនសាសនាពុទ្ធ ក៏មិនមែនកើតឯងៗ ដោយគ្មានគំរូគ្មានសំណាមទេ ។ សាសនាព្រាហ្មណ៍ កើតឡើងដោយខ្ចីបែបលំនាំនៃសាសនាធម្មជាតិ ។ សាសនាធម្មជាតិកើតតៗគ្នា មកតាំងពីមានមនុស្សនៅលើពិភពលោក ។ សាសនាពុទ្ធកើតក្រោយសាសនាព្រាហ្មណ៍ក៏ពុំអាចទាត់ចោលគំនិតព្រាហ្មណ៍ទាំងអស់បានដែរ ។ សាសនាគ្រិស្តនិងសាសនា ឥស្លាម ។ល។ កើតក្រោយសាសនាពុទ្ធ ទើបគេឃើញមានបញ្ញត្តិខ្លះ ជាពិសេសបញ្ញត្តិ ១០ ប្រការនៃសាសនាគ្រិស្ត មានលក្ខណៈប្រហាក់ប្រហែលសីល ៥ សីល ៨ ឬសីល ១០ របស់ពុទ្ធសាសនាយើងដែរ ។ ក្នុងន័យថា សាសនាធម្មជាតិជាទីមករបស់សាសនាព្រាហ្មណ៍ សាសនសព្រាហ្មណ៍ជាទីមកនៃពុទ្ធសាសនា សាសនាពុទ្ធជាទីមក ឬជាប្រភពនៃសាសនាទាំងឡាយដទៃទៀត ដែលមនុស្សលោកកំពុងមានជំនឿសព្វថ្ងៃនេះ ។ នៅក្នុងសាសនាមួយៗ គេឃើញមានធម៌សម្រាប់សូត្រថ្វាយព្រះ បន់ស្រន់បួងសួងអំពាវនាវ សូមកម្ចាត់ទុក្ខចម្រើនសុខ ។ តែធម្មៈសុទ្ធនៃពុទ្ធសាសនា គ្មានសទ្ធម្មបដិរូប គ្មានធម៌សូត្របន់ស្រន់ទេ មានតែធម៌សម្រាប់ប្រតិបត្តិកម្ចាត់ទុក្ខ ។ ដូចនេះ, អ្នកអានគប្បីធ្វើការកត់សម្គាល់ថា ធម៌សូត្របន់ស្រន់ គឺជាសទ្ធម្មបដិរូប ដែលអ្នកខាងក្រោយខ្ចីមកពីសាសនាព្រាហ្មណ៍ ។ ការខ្ចីធម៌គ្នាទៅវិញទៅមកនៃសាសនាទាំងឡាយ មិនមែនជាធាតុចម្លែកទេ ។ ភាសាវិទូក្តី កាលណាមានគំហើញថា ពាក្យពេចន៍ក្នុងភាសានោះ

ធម្មវិន័យក្នុងសាសនា នេះមានប្រយោជន៍ដល់ភាសា ដល់សាសនារបស់គេ, គេសុខចិត្តខ្ចីមកប្រើ ដើម្បីវឌ្ឍនភាពនៃភាសានៃសាសនារបស់គេ ដូចជាខ្មែរយើងខ្ចីពាក្យបាលីសំស្ក្រឹតមកប្រើក្នុងភាសារបស់ខ្លួនអញ្ចឹងដែរ ។ តែអ្នកប្រើនូវកម្មវីរបស់គេនោះត្រូវ មានស្មារតីប្រុងប្រយ័ត្ន កុំឲ្យបាក់គំនិតប្រកាន់យកថា ការសូត្របន់ស្រន់ជាធាតុផ្តល់ឲ្យនូវសេចក្តីសុខ បំបាត់សេចក្តី ទុក្ខឲ្យសោះ ព្រោះព្រះពុទ្ធសាសនា ពុំបានបង្រៀនយើងថា សេចក្តីទុក្ខរលាយបាត់ទៅដោយការបន់ស្រន់ទេ ។ ព្រោះអ្វី? ព្រោះព្រះពុទ្ធសាសនាបានបង្រៀនថា សេចក្តីសុខកើតពីទំរើត្រូវសេចក្តីទុក្ខកើតពីទំរើខុស ។ ខ្ពស់ជាងនេះទៅទៀត, ពុទ្ធសាសនាមានអរិយសច្ចធម៌ជាពំនោល មានបុណ្យបាប ឬកុសលអកុសលជាប្រភពនៃសុខទុក្ខស្រេចទៅហើយ ។ ដូចនេះ, ការសូត្រធម៌បន់ស្រន់របស់យើង ត្រូវធ្វើនៅ ក្នុងស្មារតីអនុគ្រោះ, គំនិតស្រោចស្រង់, សម្បជញ្ញៈ ករុណាដល់ពុទ្ធសាសនិកថ្មី ដើម្បីឲ្យគ្នាមានជំនឿក្នុង ពុទ្ធសាសនា ជាមួយនិងយើងផង ។ ប្រសិនបើទំរើនេះ ធ្វើទៅបានចំណេញមនុស្ស គេត្រូវតែប្រព្រឹត្តធ្វើទៅទៀត ។ តែបើធ្វើទៅហើយនាំខាតមនុស្សគេត្រូវតែឈប់ធ្វើវិញដែរព្រោះទំរើនេះ មានភាពផ្ទុយពីអរិយសច្ចៈ ដែលជាគំនោល ធំរបស់ពុទ្ធសាសនាយើង ។

## បទទី៣
## រស់នៅដោយហេតុផលនិងទំនើល្អ

«ទោះណាជាកាត់ចោលអស់នៅជំនឿក្នុងរឿងឫទ្ធិតេជៈ អំណាចបដិហារិយ៍ ក៏ពុំបានធ្វើពុទ្ធសាសនា មានគុណវិបត្តិអ្វីសូម្បីបន្តិចបន្តួចឡើយ ព្រោះពុទ្ធសាសនាពុំបាន មានឫសគល់នៅលើធាតុទាំងអស់នោះទេ ។ តែតាំងនៅលើហេតុផល និងទំរើថ្លៃថ្នូរដែលអាចពិចារណាឃើញបានពិតៗ» ។

អ្នកសិក្សាវិជ្ជាពុទ្ធសាសនា បានចេះដឹងយល់ស្គាល់សារៈសំខាន់ល្មមសមគួរហើយ រមែងមានយោបល់ស្របគ្នាថា យើងមិនបានទទួលស្គាល់ ឬរាប់អានព្រះសម្មាសម្ពុទ្ធ ព្រោះព្រះអង្គហោះហើរដើរតាមអាកាសបាន, មុជជ្រែកចូលក្រោមដីបាន, ប្រសូតភ្លាមដើរបាន ៧ ជំហានទេ ។ សូម្បីព្រះអង្គគ្មានឫទ្ធិ, គ្មានរបស់អស្ចារ្យ ក៏មិនធ្វើឲ្យយើងផ្លាស់ប្តូរចិត្តគំនិតលែងគោរពរាប់អានព្រះអង្គឡើយ ។ ដូចនេះព្រោះអ្វី? ព្រោះយើងបានអប់រំគ្នាឲ្យស្គាល់គុណរបស់ព្រះពុទ្ធ ពុំមែនឲ្យស្គាល់ភាពអស្ចារ្យរបស់ព្រះពុទ្ធទេ ។ គុណព្រះពុទ្ធដែលយើងបានស្គាល់គ្រប់គ្នាមាន ៣ គឺ :

១- បញ្ញាគុណ គុណគឺបញ្ញាសេចក្តីចេះដឹងជ្រៅជ្រះក្នុងភាពនៃសេចក្តីពិត ឬភាពភ្លឺស្វាងរុងរឿងក្នុងសកលធម្មជាតិ ។

២- បរិសុទ្ធិគុណ គុណគឺសេចក្តីបរិសុទ្ធ ស្អាតកាយ វាចា ចិត្ត ឬភាពស្អាតស្អំក្នុងការប្រព្រឹត្ត, ការប្រតិបត្តនិងការអនុវត្ត ។

៣- មហាករុណាគុណ គុណគឺសេចក្តីករុណា ទូលំទូលាយគ្មានកំណត់ព្រំដែន ដែលមានដល់សកលសត្វក្នុងសកលពិភព ។

ព្រះគុណទាំង ៣ នេះ សូម្បីតែមួយក៏គ្មានផង ដែលកើតមានឡើង ដោយអាស្រ័យឫទ្ធិតេជៈ ។ គុណទី ១ បានដល់បញ្ញា យកយកសេចក្តីចេះដឹងយ៉ាងទូលំទូលាយ កើតឡើងដោយអាស្រ័យកំហំព្យាយាមអបរំប៉ុណ្ណោះ ឬស្រាវជ្រាវរកអស់កាលជានិច្ចនិរន្តរ៍ លុះទីបំផុតបានត្រាស់ដឹងនូវសេចក្តីពិត, នូវអាថ៌កំបាំងរបស់ធម្មជាតិ ។ សេចក្តីបរិសុទ្ធនិងសេចក្តីករុណា គុណភាពល្អទាំងពីរនេះ ក៏ពុំមែនកើតឡើងដោយអាស្រ័យឥទ្ធិបាដិហារិយ៍ណាមួយទេ គឺអាស្រ័យការតស៊ូខំប្រឹង, ខំប្រតិបត្តិ, ខំដុះ, ខំសំអាត ទីបំផុតព្រះទ័យរបស់ព្រះអង្គ ក៏បានទទួលនូវភាពស្អាតភាពស្ងប់ ភាពត្រជាក់ត្រជុំ កើតបានជាតួយ៉ាងជាបែប ជាច្បាប់ល្អដល់ប្រជាពលករក្នុងលោក ។

ព្រះគុណដែលយើងគោរពបូជាទាំង ៣ប្រការនេះ, ប្រសិនបើយើងខំប្រឹងធ្វើឲ្យរឹតតែច្រើន ក៏រឹតតែល្អ ។ តែកុំគោរពបូជា ឬថ្វាយបង្គំប្រកបដោយគំនិតផ្គាប់ផ្គុណ ឬយកគួរយកសមនឹងព្រះពុទ្ធ ដូចដែលអ្នកខ្លះបានយល់ច្រឡំមកហើយ ។ ការពិតក្នុងរឿងនេះ, គឺគេថ្វាយបង្គំនៅក្នុងគំនិតអបរំហ្វឹកហាត់ដុះខាត់ចិត្តវិញ្ញាណរបស់ខ្លួន ឲ្យបានទទួលគុណភាពល្អរបស់ព្រះពុទ្ធបន្តិចម្តងៗ រៀងរាល់ពេលឡើង ។ ព្រោះអ្វី? ព្រោះការគោរពបូជាថ្វាយបង្គំមិនមែនជាទំរើ ដើម្បីគួរសម, ដើម្បីប្រដាប់បុណ្យបារមី ដើម្បីឃើញនូវកម្ពស់នៃគុណវិសេសរបស់ព្រះពុទ្ធប៉ុណ្ណឹង ។ ខ្ពស់ជាងនេះ, គឺបណ្តុះសេចក្តីល្អ ឬចម្លងភាពស្អាតស្អំ ភាពភ្លឺស្វាង ភាពត្រជាក់ត្រជុំរបស់ ព្រះពុទ្ធឲ្យកើតជារបស់យើង ។ ក្នុងន័យថា: បង្ខិតចិត្តរបស់ខ្លួនទៅរកគុណព្រះពុទ្ធ ឬចតយកគុណព្រះពុទ្ធមកធ្វើជាគុណរបស់យើងឲ្យមាត្រដ្ឋានច្រើនឡើងៗ បើមិនដល់ខ្នាតព្រះពុទ្ធក្នុងពេលខ្លី ក៏គង់បានដល់ក្នុងពេលវែងដែរ ។

កាលណាគេពិចារណាដល់កត្តាហេតុផល គេនឹងឃើញថា «ឫទ្ធិ» ប្រែថា «សេចក្តីសម្រេច» មនុស្សទាំងឡាយ ក្នុងសកលលោកមិនមានអ្នកណាម្នាក់ មិនត្រូវការសេចក្តីសម្រេចទេ ។ ទាំងអស់គ្នាសុទ្ធតែត្រូវការសេចក្តីសម្រេចទេ ។ គេឲ្យពរឲ្យជ័យដល់គ្នានិងគ្នា ក៏មកពីដឹងថា សេចក្តីសម្រេចជាធាតុមានគុណវិសេសមនុស្សចូលចិត្តគ្រប់ៗគ្នា ។ ដើម្បីបង្ហាញនូវភាពរាប់អានស្មោះត្រង់និងគ្នា គេតែងឲ្យពរឲ្យមិត្តភក្តិរបស់គេ បានជួបប្រទះនូវ

សេចក្ដីសម្រេចតាមប្រាថ្នារបស់ខ្លួន ។ ព្រះសម្មាសម្ពុទ្ធ បានសម្ដែងគោលធម៌ ឲ្យជួបប្រទះសេចក្ដីសម្រេចដែលយើងធ្លាប់ស្គាល់ថា «ឥទ្ធិបាទ» ធម៌នេះប្រែបានពីរន័យ, ន័យមួយប្រែថា : សេចក្ដីប្រតិបត្តិដែលឲ្យបានដល់នូវឫទ្ធិ ឬបានលុះនូវឫទ្ធិ (BASIC OF PSYCHIC POWER) ប្រែដូចនេះដៅដល់ឫទ្ធិតេជៈខ្លាំងពូកែពិតៗ ដែលកើតឡើងដោយកម្លាំងអានុភាពរបស់ចិត្ត នៃមនុស្សអ្នកបានឈាន ។ ន័យមួយទៀតថា : សេចក្ដីប្រតិបត្តិ ដែលឲ្យលុះដល់សេចក្ដីសម្រេច ដែលគេបានប្រាថ្នា ទុកជាមុនមកហើយ (LAW OF SUCCESS) ។

## ឥទ្ធិបាទធម៌ ៤

១- ឆន្ទៈ ពំនេញចិត្ត ឬចំណូលចិត្តក្នុងរបស់ណាមួយ (PREFERENCE) ។

២- វីរិយៈ កំហំពុះពារ (ENERGY) ។

៣- ចិត្តៈ យកចិត្តទុកដាក់មិនទម្លាក់ចោល (THOUGHT) ។

៤- វិមង្សា ពិនិត្យស្រាវជ្រាវសាកល្បង (INVESTIGATION) ។

យើងអាចពិចារណាឃើញបានថា បណ្ដាភាពនៃសេចក្ដីសម្រេចទាំងឡាយ ដែលនៅក្នុងវិស័យមនុស្សយើងមានផ្លូវឡើងទៅចាប់យកបានដោយគុណធម៌គឺ ឥទ្ធិបាទដែលបានពោលមកនេះ សឹហប្រកបដោយហេតុផលពិតៗ ។

ការស្រាជ្រាវរកវត្ថុធាតុមានអាថ៌កំបាំងក្ដី ការបង្កើតគ្រឿងប្រដាប់ថ្មីៗក្ដី ដែលគេធ្វើបានសម្រេចសមតាមប្រាថ្នានៅក្នុងពិភពលោកយើងរាល់ថ្ងៃនេះ មិនមាននរណាអាចបដិសេធឥទ្ធិបាទណាមួយ ឬទាំងអស់ដែលព្រះសម្មាសម្ពុទ្ធសម្ដែងមកហើយថា មិនមានចំណែកទាក់ទងក្នុង មុខងារទាំងអស់នោះបានឡើយ ទោះជាដោយចំពោះក្ដី មិនចំពោះក្ដី ។

ដើម្បីអ្នកអានមានមានពន្លឺក្នុងរឿងឫទ្ធិតេជៈបាដិហារិយ៍ កាន់តែច្រើនឡើងទៀត សូមមេត្តាសិក្សាតាមទស្សនៈ នៃពុទ្ធសាសនាជាមួយនឹងខ្ញុំ ដើម្បីប្រកបការពិចារណារបស់យើងដូចមានតទៅ :

រឿងឫទ្ធិតេជៈបាដិហារិយ៍មានឬគ្មាន វាជាធាតុដែលគេយកចិត្តទុកដាក់ច្រើន ។ ដោយរឿងនេះមានអ្នកខ្លះជឿ អ្នកខ្លះមិនជឿ អ្នកខ្លះពាក់កណ្ដាលជឿមិនជឿ ទើបត្រូវពិចារណាឲ្យបានល្អិតល្អន់បន្តិច ។ ជាមួយគ្នានេះ, ត្រូវតែរកគតិ ឬប្រយោជន៍អំពីរឿងនេះឲ្យបានបើមិនច្រើនក៏តិចដែរ ។

ដោយហេតុថា : រឿងឫទ្ធិតេជៈបាដិហារិយ៍ ជាធាតុមានរចនាសម្ព័ន្ធជាប់ទាក់ទងជាមួយនឹងពុទ្ធសាសនា ឬជារឿងមានចែងទុកមកក្នុងគម្ពីរខ្លះនៃពុទ្ធសាសនារបស់យើងផង ប្រសិនបើយើងរួមគ្នាវិភាគ ឲ្យមានការចូលចិត្តល្អដូចគ្នា ឬមានយោបល់ស្របគ្នាហើយ គតិគឺដំណើរដែលយើងត្រូវប្រកាន់យក ឬផលប្រយោជន៍ដែលយើងត្រូវបានដោយអាស្រ័យការគោរពប្រតិបត្តិធម្មៈនៃពុទ្ធសាសនា ក៏មុខជានឹងកើតមានដល់យើងយ៉ាងច្រើនមិនតិចឡើយ ។

ដំបូង, យើងត្រូវរួមគ្នាពិចារណាដល់សាច់រឿងឫទ្ធិតេជៈបាដិហារិយ៍ ។ ដើម្បីឆាប់ចូលចិត្តយើងត្រូវត្រួតពិនិត្យមើលឡើងវិញនូវគំនោលធម្មៈ នៃពុទ្ធសាសនាជាថ្មីថា ព្រះពុទ្ធសាសនារបស់យើង ប្រសិនណាកាត់ចេញឲ្យអស់នូវឫទ្ធិតេជៈបាដិហារិយ៍ តើនៅមានអ្វីជាខ្លឹមសារគួរដល់ការគោរពរាប់អាន របស់យើងឬទេ? ក្រោយការពិនិត្យពិចារណា របស់យើងយ៉ាងមធ្យ័ត យើងមុខជានឹងឲ្យចម្លើយថា ដរាបណាយើងនៅតែរាប់អាន ពុទ្ធសាសនាព្រោះពេញចិត្តក្នុង ឫទ្ធិតេជៈបាដិហារិយ៍ ដរាបនោះយើងនឹងទៅជាមនុស្សឈ្មោះថា មិនស្គាល់ ឬមិនចូលចិត្តធម្មៈរបស់ពុទ្ធសាសនាយ៉ាងពិតប្រាកដតែម្ដង ។ ព្រោះពុទ្ធសាសនាមិនបានមានភាពអាថ៌កំបាំង ឬឫទ្ធិតេជៈបាដិហារិយ៍ជាឫសគល់ ឬជាមូលដ្ឋានឡើយ ។ ដូចនេះ, ទោះណាជាយើងកាត់ចោលនូវ ឫទ្ធិតេជៈបាដិហារិយ៍ទាំងអស់ក៏ពុំបានធ្វើឲ្យពុទ្ធសាសនាមានកម្លាំងខ្សោយចុះក្នុងចំណែកណាមួយឡើយ ។ ផ្ទុយទៅវិញ, ទំរើនេះរឹតធ្វើឲ្យ

ពុទ្ធសាសនាមានភាពច្បាស់លាស់ នៅក្នុងក្របខ័ណ្ឌនៃអរិយសច្ចៈ ដែលជាធម៌តែមួយ របស់ពុទ្ធសាសនាទៀតផង ឬជាសានាមានហេតុផលដល់កម្រិត មួយរយភាគរយ ដូចដែលយើងចូលចិត្តមក ។ ចំណែកសាសនាដទៃ, ខ្ញុំឃើញថា មានសេចក្ដីលំបាកច្រើនណាស់ ប្រសិនបើកាត់ចោលឫទ្ធិតេជៈបាដិហារិយ៍ ទាំងអស់ដូចពុទ្ធសាសនា នោះនឹងមានផ្លូវតែមួយគឺរលាយតែម្ដង ។ ព្រោះសាសនាទាំងអស់នោះ ភាគច្រើនសុទ្ធតែ ទេវនិយម (THEISM) មានជំនឿថា ពិភពលោកនិងមនុស្សសត្វសាងឡើងដោយព្រះអាទិទេព បើគ្មានជំនឿលើ ឫទ្ធិតេជៈរបស់ព្រះអាទិទេព ក៏ត្រូវដកចេញនូវសេចក្ដីគោរពរាប់អាន បើនៅរាប់អានក៏ត្រូវតែមានជំនឿទើបអាច ប្រព្រឹត្តទៅបាន ។

ឥឡូវនេះ, យើងត្រឡប់មកគិតគូរជាមួយគ្នា ពុទ្ធសាសនាម្ដងទៀត ។ ដែលថា : បើកាត់ឫទ្ធិតេជៈបាដិហារិយ៍ចេញទាំងអស់យើងរឹតតែឃើញច្បាស់នូវភាពពិត ឬភាពមានហេតុផលរបស់ពុទ្ធសាសនា ។ ក្នុងចំណុចនេះ ចង់ដឹងថា មានសេចក្ដីអធិប្បាយយ៉ាងណាដែរ? ចំពោះចម្ងល់នេះ ខ្ញុំសូមឲ្យចម្លើយនិងធ្វើសេចក្ដីបំភ្លឺដូចតទៅ :

ប្រការទី ១, ព្រះសម្មាសម្ពុទ្ធជាមនុស្សធម្មតា មិនមែនជាទេវតា, មិនមែនជាមនុស្សរស់នៅក្នុងភាពមានអាថ៌កំបាំងក្នុងចំណុចណាមួយទេ ។ ភាពថ្លៃថ្នូររបស់ព្រះពុទ្ធ កើតមានដោយអាស្រ័យសេចក្ដីព្យាយាម មិនមែនកើត, មិនមែនបានទទេៗឡើយ ។ ព្រះអង្គជាតួយ៉ាង ឬជាគំរូនៃបុគ្គលអ្នកកសាងខ្លួនក្នុងផ្លូវត្រូវជាទូទៅ ។ ព្រះអង្គរស់នៅក្នុងស្មារតីភ្ញាក់រឭករឹងប៉ឹងអត់ធន់ ។ ព្រះអង្គហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីឧត្តមគតិ នៅក្នុងកម្រិតខ្ពង់ខ្ពស់គឺជួយឲ្យមនុស្សលោករួចផុតចាកទុក្ខ, ប្រសព្វសុខដោយចេញមុខតស៊ូសំពោះឧបសគ្គ និងសកលវិបត្តិគ្មានរាថយគ្រប់កាលវេលា ។

ប្រការទី ២, ទោះជាមានក្បួនតម្រា ឬគម្ពីរសាស្ត្រាណាស្ដីដល់សេចក្ដីអស្ចារ្យនានាៗទាក់ទងដល់ព្រះពុទ្ធ ដូចជាប្រសូតហើយភ្លាមៗដើរបាន ៧ ជំហាន, មានផ្កាឈូកទ្រព្រះបាទ, មានវាចឧទានដល់ភាពខ្ពង់ខ្ពស់ ភាពធំដុំ ភាពថ្លៃថ្នូរ ក្នុងបច្ឆិមកំណើតនេះយ៉ាងណាក៏ដោយ ។ ប្រសិនបើយើងមិនយកចិត្តទុកដាក់ ក្នុងរឿងទាំងអស់នេះ យើងប្រកាន់យក ត្រឹមថា ព្រះអង្គប្រសូតដូចកុមារធម្មតាទាំងឡាយដទៃ, គ្មានដើរ, គ្មានផ្កាឈូក, គ្មានពំនោលអំនួត, គ្មានទឹកក្ដៅ ទឹកត្រជាក់របស់ឋានសួគ៌លាងជម្រះកាយ ក៏វាគ្មានធ្វើឲ្យព្រះអង្គខូចកិត្តិយសអ្វីឡើយ ។ អ្នកគ្មានជំនឿក្នុងរបស់ទាំងនេះ ក៏គ្មានឃើញត្រូវសម្លុត ឬពិន័យទោសឲ្យមានបាប ឬឲ្យធ្លាក់នរកអ្វីទេ ។ សាសនាវិទូដែលមានគំនិតចង់ឲ្យមនុស្សស្គាល់ខ្លឹមសារពិតប្រាកដរបស់ពុទ្ធសាសនា ។ លោកបានសរសេរបំភ្លឺថា : ពុទ្ធប្រវត្តិដែលអ្នកប្រាជ្ញពីមុនបាននិពន្ធរឿងឫទ្ធិតេជៈបាដិហារិយ៍របស់មហាបុរស (ពោធិសត្វ) នោះ វាមិនមែនជារឿង ធ្វើកំណែមិនបាន, ឲ្យន័យថ្មីមិនកើត ឬហាមឃាត់មិនឲ្យធ្វើជម្រើសឡើយ ។ លោកបញ្ជាក់ថា : របស់ចាស់ ទាំងឡាយ បើគ្មានកំណែថ្មី, គ្មានឲ្យន័យថ្មី ឬគ្មានជម្រើស វាមុខជាប្រើមិនបានផលគ្រប់គ្រាន់, មិនមានលទ្ធភាព ក្នុងការអនុវត្តទេ ។ លោកឲ្យគំនិតថា : ធម្មៈនៃពុទ្ធសាសនាលើកលែងតែអរិយសច្ចៈ ៤ ចេញ ត្រូវមានកំណែ មានជម្រើស ឬយ៉ាងហោចណាស់ត្រូវឲ្យន័យថ្មីទើបប្រើការបាន ។ សូម្បីអរិយសច្ចៈ ៤ នេះទៀតក៏ត្រូវឲ្យន័យថ្មីដែរព្រោះអ្វីៗទាំងឡាយក្នុងលោកយើងនេះកាលណាប្រាសចាកន័យ, ប្រាសចាកកំណែ ប្រាសចាកជម្រើសវាពុំដែលហុចប្រយោជន៍ឲ្យអ្នកប្រើបានគ្រប់ចំនួនឡើយ ។ លោកឲ្យសេចក្ដីប្រៀបថា ការប្រតិបត្តិធម៌ក៏ដូចជាការទាំងឡាយដទៃដែរ ។ អ្នកបរិភោគអាហារករណីយ៍របស់គេគឺ ស្គាល់គុណសម្បត្តិនិងគុណវិបត្តិរបស់អាហារ ។ កាលណាគេមានសម្គាល់ហើយគេក៏ចាំបាច់ត្រូវជ្រើសរើស ។ អាហារសាច់សត្វធំៗ គេបរិភោគសាច់, តែគេចោលឆ្អឹង ។ មច្ឆាទាំងឡាយគេបិរភោគសាច់, ចោលឆ្អឹង ឬគេរម្លាយឆ្អឹងធ្វើអាហារក៏មាន ។ តែផ្លែឈើទាំងឡាយ ផ្លែខ្លះដូចមង្ឃុតគេបរិភោគសាច់ចោលសម្បក ខ្លះទៀតគេបរិភោគទាំងសាច់ទាំងសម្បក ។ល។ គេតមអាហារមានពិស អាហារបង្ខូចសុខភាពអាហារចម្លងជម្ងឺ ។ល។ ក្នុងគម្ពីរពុទ្ធសាសនារបស់យើង មានស្ដីអំណពីគុណសម្បត្តិ និងគុណវិបត្តិរបស់

ដើមឈើប្រៀបធៀបនឹងធម៌មានខ្លឹមឥតខ្លឹម ។ អ្នកកាប់ឈើធ្វើផ្ទះ ជ្រើសរើសយកឈើមាន គុណសម្បត្តិធ្វើសំណង់របស់គេ ។ ឈើជាប់សម្បកក្រមរសាច់ស្រាយ គេយកសម្បកក្រមរសាច់ស្រាយចេញ ។ អ្នកប្រតិបត្តិធម៌, គេមិនចេះតែប្រតិបត្តិទាំងខុសទាំងត្រូវទេ ។ ធម៌ណាគ្មានខ្លឹមសារគេទាត់ចោល, ធម៌ណាមាន ខ្លឹមសារគេរើសយកមកប្រតិបត្តិ ។ ព្រះពុទ្ធសាសនាមានធម៌ជាពិធីការ, ជានិទាន, ជាទស្សនៈវិជ្ជា ដូចសាសនា ទាំងឡាយដទៃដែរ ។ ពិធីការនិងនិទានមិនមែនជាធាតុពិត, ជាធាតុត្រូវ, ធាត់ផ្តល់ប្រយោជន៍គ្រប់កាលសម័យ ឡើយ ។ របស់អស់ទាំងនេះវាគ្រាន់តែ ធ្វើឲ្យយើងស្តាប់ពីរោះត្រចៀក, សប្បាយភ្នែក ចម្លែកចិត្តប៉ុណ្ណោះ ។ វាពុំអាច ធ្វើយើងឲ្យបានសម្រេចសម្បត្តិមនុស្ស, សម្បត្តិទេព, សម្បត្តិនិព្វានដូចសេចក្តីសង្ឃឹម របស់យើងឡើយ ។ ដូចនេះភាពអស្ចារ្យទាំងឡាយដូចជាកើតភ្លាមចេះនិយាយ, ចេះដើរ, មានផ្កាឈូកទ្រ, មានទឹកក្តៅ ទឹកត្រជាក់ប្រស់ព្រំដោយឋានសួគ៌រហូតដល់ចេះហោះកាត់អាកាស ចេះជ្រែកដីពីកន្លែងមួយទៅកន្លែងមួយ ចេះមុជទឹកកាត់ផ្ទៃជលសា ចេះដើរកាត់គំនរភ្លើងចេះបំបាត់ខ្យល់ព្យុះមានកម្លាំងខ្លាំងក្លា ។ ចំពោះឫទ្ធិតេជៈបាដិហារិយ៍ ទាំងអស់នេះទោះមានក្តី គ្មានក្តីវាមិនទៅជាអ្វីទេវានៅត្រឹមមាន ត្រឹមគ្មានតែប៉ុណ្ណឹង ។ ព្រោះអ្វី? ព្រោះព្រះពុទ្ធសាសនាពុំបានចែងថា និព្វានត្រូវបានសម្រេចដោយហេតុហោះជ្រែកមុជទម្លាយ ។ល។ ឬធាតុទាំងឡាយឯទៀតក្រៅពីធាតុសីល, សមាធិ, បញ្ញាដែលពុទ្ធសាសនិកបានអនុវត្តមកហើយ ។ ដូចនេះ, ការជម្រុះ ចោលក្តី ការប្រកាន់យកក្តី នូវឫទ្ធិតេជៈបាដិហារិយ៍នាៗវាជាសិទ្ធិរបស់ពុទ្ធសាសនិកម្នាក់ៗ សម្រេចវិនិច្ឆ័យអារកាត់ ខ្លួនឯង ដោយផ្អែកលើគំនិត ឬពំនោលណាមួយស្រេចហើយតែខ្លួនរកបាន ។

ប្រការទី ៣, ធាតុឫទ្ធិតេជៈបាដិហារិយ៍ក្នុងពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពុំបានទុកដាក់លើកតម្កើងថាជារបស់ល្អកំពូលទេ ព្រះអង្គបានញែកបាដិហារិយ៍ចេញជា ៣ គឺ :

១- ឥទ្ធិបាដិហារិយៈ (ឫទ្ធិអស្ចារ្យទូទៅ)

២- អាទេសនាបដិហារិយៈ (ឫទ្ធិអស្ចារ្យទស្សន៍ទាយចិត្ត)

៣- អនុសាសនីបាដិហារិយៈ (ឫទ្ធិអស្ចារ្យនៃពាក្យបង្ហាត់បង្រៀន)

ព្រះអង្គបញ្ជាក់ថា ការបង្រៀនធម៌ជាធាតុអស្ចារ្យ នៅក្នុងកម្រឹតកំពូល ។ ចំណែកបាដិហារិយ៍ដទៃពុំបានមានកម្ពស់ដល់កម្រឹតកំពូលទេ ព្រោះធម្មៈដែលសម្តែងចេញ ដោយព្រះពុទ្ធទាំងឡាយ (អ្នកចេះដឹងជ្រៅជ្រះ) ជាធាតុផ្តល់ប្រយោជន៍ ផ្តល់ដំណើរ ផ្តល់ពន្លឺ ឲ្យសត្វលោកគ្រប់កាលសម័យ ។ ក្នុងន័យថា អនុសាសនីបាដិហារិយ៍ជាធាតុមានគុណភាពខ្ពង់ខ្ពស់ កម្រមានអ្នកសម្តែងកើត, កម្រមានអ្នកក្លែងបន្លំបាន ។ ឯបាដិហារិយ៍ក្រៅនេះសម្បូរអ្នកសម្តែង, សម្បូរអ្នកបោកបញ្ឆោត ឬបើនឹងនិយាយម៉្យាងទៀតថា ធម្មៈបាដិហារិយ៍ ជាបាដិហារិយ៍របស់អ្នកស្គាល់ហេតុផល អ្នកមានចិត្តធុញលោក អ្នកមានព្រហ្មវិហារធម៌ ។ល។ ឯបាដិហារិយ៍ពីរទៀត ជាបាដិហារិយ៍របស់អ្នកកាម, ស្រវឹងភព, ស្រវឹងអភព ។ តាមធម្មតា, អ្នកដែលមានសេចក្តីស្រវឹងអស់ហើយ, រមែងមានពន្លឺ នៅក្នុងគំនិត, មានព្រហ្មវិហារធម៌ នៅក្នុងចិត្តជានិច្ច ។ ជារៀងរាល់ពេលគេតែងគិតគូរធ្វើខ្លួនរបស់គេ និងអ្នកដទៃ ឲ្យអស់ទុក្ខ ។ ផ្ទុយទៅវិញអ្នកមានសេចក្តីស្រវឹងក្នុងកាម, រមែងមានភាពងងឹត, ភាពច្រឡំជាប្រក្រតី ។ ព្រមគ្នានេះគេគ្មានគំនិតព្រហ្មវិហារ, គ្មានគំនិតសង្គ្រោះ, គ្មានគំនិតរំដោះទុក្ខសព្វសត្វក្នុងសកលពិភពឡើយ ។ ទាំងយប់ទាំងថ្ងៃគេគិតតែប្រើឫទ្ធិតេជៈបាដិហារិយ៍ និម្មិតធ្វើជានេះជានោះ បង្ហាញភាពនេះភាពនោះ គ្រប់មធ្យោបាយដែលខ្លួនគេមាន, ដើម្បីបំភាន់គំនិតមនុស្សល្ងង់ឲ្យគ្នាជឿ, គ្នាកោតខ្លាចខ្លួន ក្នុងកលឧបាយ បោកប្រាស់ឲ្យអ្នកដទៃសុខចិត្តបម្រើសេចក្តីសប្បាយរបស់ខ្លួន ។ អ្នកអានទាំងឡាយប្រហែលជា បានចេះដឹងយល់ ស្គាល់ឫទ្ធិតេជៈបាដិហារិយ៍ដែលមាននិយាយក្នុងពុទ្ធសាសនារបស់យើងហើយ បើមិនច្រើនក៏តិចដែរ តែដើម្បីបានជាពន្លឺថ្មីទៀត សូមមេត្តាគិត

ជាមួយនឹងខ្ញុំមានតទៅនេះ :

អនុសាសនីបាដិហារិយ៍ លោកចាត់ទុកជាធាតុមានគុណភាពខ្ពង់ខ្ពស់ ជាងបាដិហារិយ៍ដទៃ ព្រោះពាក្យបង្ហាត់បង្រៀនដែលមានគុណភាពល្អ មានហេតុផលគ្រប់គ្រាន់ ជាធាតុរស់នៅក្នុងលោក បានយូរជាងតិបរិមា, ជារបស់ទាន់សម័យជានិច្ច, ជារបស់ផ្តល់ប្រយោជន៍ឲ្យអ្នកប្រតិបត្តិតាមបានយ៉ាងពិសាល ! ចំណែកឫទ្ធិបាដិហារិយ៍ដទៃៗនោះ បានត្រឹមតែល្អមើលស្រួលភ្នែក បើគេមិនមើលក៏គ្មានឃើញ, គ្មានឆ្ងល់, គ្មានបញ្ហាចោទ ។ របស់នេះយូរៗទៅវាក្លាយ, វាសាបបន្តិចម្តងៗ ក្នុងទីបំផុតវារលាយបាត់ ដូចជារឿងព្រេងនិទាន ដែលរស់នៅមិនបានយូរព្រោះគ្មានហេតុផលហ្នឹងដែរ ។ រឿងនិទាន, មនុស្សកើតក្រោយៗមិនសូវមានជំនឿ, មិនសូវយកចិត្តទុកដាក់ព្រោះវាគ្មានប្រយោជន៍ដល់អ្នកស្តាប់, វាគ្មានចំណេញដល់អ្នកមានជំនឿ វាពីរោះតែមនុស្សបូរាណដែលរស់នៅ ដោយគ្មានហេតុផល, គ្មានពំនឹងលើការងារ ។ ព្រោះអ្វី? ព្រោះមនុស្សក្នុងបូរាណកាល, គ្មានសាសនា, គ្មានទស្សនវិជ្ជាប្រកបដោយហេតុផល ចូលចិត្តផ្ញើជីវិតនៃអាត្មានិងសេចក្តីសុខទុក្ខរបស់ខ្លួនលើអាទិទេព លើវត្ថុដែលខ្លួនឃើញថាស័ក្តិសីទ្ធិខ្លាំងពូកែ, ខ្មោច, បិសាច, អសុរៈ, នាគ, គ្រុឌ ។ល។ គេរស់នៅដោយផ្សងព្រេង ពុំបានរស់នៅដោយផ្សងកម្មដូចមនុស្សក្នុងសម័យសាសនាមានហេតុផល ឬវិទ្យាសាស្ត្រឡើយ ។ ឫទ្ធិតេជៈ ប្រសិនបើមានពិតឬសម្តែងបានមែន ក៏បានជាប្រយោជន៍ក្នុងការ ទាក់ទាញចិត្តមនុស្សឲ្យកើតជំនឿ, កើតសេចក្តី រាប់អានដែរ ។ ដូចនេះ, ទើបពុទ្ធសាសនា ពុំបានធ្វើសេចក្តីរិះគន់ ពុំបានទាត់ចោល តែក៏ពុំបានឲ្យតម្លៃស្មើ នឹងឫទ្ធិនៃធម្មៈដែលសម្តែងដោយព្រះសម្មាសម្ពុទ្ធ ។ ក្រៅពីនេះ, ព្រះបរមគ្រូរបស់យើង ព្រះអង្គបានដាក់ បម្រាមសម្តែងឫទ្ធិនៅក្នុងគណសង្ឃ គឺហាមសម្តែងឫទ្ធិនៅក្នុងក្របខ័ណ្ឌមួយថា «ភិក្ខុណាសម្តែងឫទ្ធិទោះជា ក្នុងគំនិតណា មធ្យោបាយណាក៏ដោយភិក្ខុនោះត្រូវទទួលកំហុសជាអាបត្តិទុក្កដ» សេចក្តីនេះបញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនាមិននិយមឫទ្ធិមិនប្រើឫទ្ធិសម្រាប់កៀរគរប្រមូលយកមនុស្សទេ ។ ព្រោះអ្វី? ព្រោះព្រះពុទ្ធសាសនា មានគំហើញថាឫទ្ធិជាធាតុសម្រាប់ប្រមូលលាភសក្ការៈ ប្រមូលកេរ្តិ៍ឈ្មោះ ប្រមូលសម្ញើច ។ ជាធាតុដែលគេអាច ក្លែងបន្លំបាន ប្រសិនបើបើកដៃឲ្យធ្វើយូរៗទៅ នឹងមានមនុស្សគ្មានឫទ្ធិ, បង្កើតជាឫទ្ធិក្លែង, ឫទ្ធិបន្លំដើម្បីចិញ្ចឹមជីវិត ក្នុងព្រះពុទ្ធសាសនានាំមានមន្ទិលសៅហ្មងដល់បុគ្គលដែលមានឫទ្ធិតេជៈពិតៗ ។ ជាមួយគ្នានេះទៀត, ពុទ្ធសាសនា មិននិយមអំនួត, មិននិយមសម្ញើយ, មិនយល់ឃើញថា ឫទ្ធិនាៗខាងផ្លូវចិត្តអាចចម្លង មនុស្សចាកទុក្ខគ្រប់យ៉ាងបាន ។ ដូចនេះប្រសិនបើបង្រៀនច្រើនខាងឫទ្ធិ ឬសង្កត់ធ្ងន់លើឫទ្ធិមនុស្សមុខតែបាក់ចិត្ត ចាប់អារម្មណ៍ក្នុងឫទ្ធិ ច្រើនជាងធម៌ ។ បំណាក់ ឬបំណាប់នេះមិនត្រឹមតែបង្កើនការប្រកួតប្រណាំងគ្នា រវាងអ្នកមានឫទ្ធិ និងមានឫទ្ធិប៉ុណ្ណឹងទេ ។ គឺវាអាចធ្វើឲ្យមនុស្សគ្មានឫទ្ធិ បង្កើតឫទ្ធិដោយរៀន ឬដោយក្លែងបន្លំ ។ ធំជាងនេះទៀត, គឺគ្មានអ្នកប្រតិបត្តិ ដើម្បីសម្បត្តិមនុស្សសួគ៌និព្វាន គ្មានមនុស្សរស់នៅក្នុងសីលធម៌, គ្មានជីវិតស្ងប់, គ្មានជីវិត សន្តោសទេ ។ វានឹងមានតែជីវិតហ៊ឺហាឡូឡាដណ្តើមធំ ដណ្តើមមុខមាត់ ។ល។ ដោយអាស្រ័យហេតុនេះ, ទើបពុទ្ធសាសនាបង្រៀនសង្កត់ធ្ងន់ទៅលើការងារ ទៅលើមនុស្សធម៌ ទៅលើសង្គមកិច្ច ទៅលើយុត្តិធម៌ជំនួសវិញ ។

ប្រការទី ៤, ពុទ្ធសាសនាមាននិយាយ អធិប្បាយអំពីឫទ្ធិតេជៈដូចសាសនាដទៃដែរ តែនិយាយនៅក្នុងក្របខ័ណ្ឌនៃហេតុផល នៃគតិវិទ្យាសាស្ត្រនិងទស្សនវិជ្ជាត្រង់ៗ មិនបាននិយាយប្រកបដោយគំនិតបោកប្រាស់ ដើម្បីបញ្ឆោតឲ្យគេមានជំនឿ ក្នុងគោលបំណងចង់បានប្រយោជន៍អ្វីមួយឡើយ ។ ពុទ្ធសាសនា, ទទួលស្គាល់ឫទ្ធិតេជៈដែលកើតមកអំពីចិត្តស្ងប់របស់អ្នកប្រតិបត្តិធម៌ ហើយបានសម្រេចឈានទាំងលោកិយ ទាំងលោកុត្តរៈ ។ ពុទ្ធសាសនាទុកដាក់គុណធម៌ផ្នែកនេះ សម្រាប់មនុស្សទាំងអស់គ្នាគ្មានការចង, ការផ្តាច់មុខ ឬហួងហែងទុកសម្រាប់ប្រដាប់បុណ្យបារមីរបស់បុគ្គលណាម្នាក់ដោយចំពោះ ។ ពុទ្ធសាសនា, បានចាត់កម្មវិធីប្រតិបត្តិធម៌ខាងចិត្ត ទុកជា

របស់កណ្ដាល ឬជាសធារណៈ ។ អ្នកណាបានហ្វឹកហាត់ចិត្ត តាមមាគ៌ាសមថកម្មដ្ឋាន ឬសមថវិបស្សនា លុះត្រាកើតសមាធិ ឬកើតមគ្គផល មានចិត្តស្ងប់ រស់នៅក្នុងអារម្មណ៍ត្រជាក់ អ្នកនោះត្រូវមានឫទ្ធិខាងផ្លូវចិត្តដូចៗគ្នា ។ តែឫទ្ធិទាំងអស់នេះមិនមែនជាធាតុនាំខ្លួនឲ្យ រួចផុតចាកទុក្ខប្រចាំភពបានទេ ប្រសិនបើគ្មានវិបស្សនាធម៌ជួយរុញច្រាន ឬគ្មានបន្តប្រតិបត្តិធម៌ដោយវិបស្សនា ។ ជាមួយគ្នានេះទៀត, ឫទ្ធិនេះប្រសិនបើគេប្រើប្រកបដោយអកុសលចិត្តណាមួយ វានឹងរលាយបាត់ភ្លាមមួយរំពេច វាពុំអាចរស់នៅបានទេ ។ អ្នកចម្រើនធម៌, មានគោលដៅធ្វើចិត្តឲ្យស្ងប់, ក្នុងខណៈចិត្តស្ងប់ សមាធិកើតឈានមានឫទ្ធិកើតជាបន្តបន្ទាប់គ្នាណ ។ ក្នុងពេលនេះ យោគីបុគ្គលត្រូវធ្វើការកត់សម្គាល់ថា ឈានក្ដី ឫទ្ធិក្ដី មិនមែនជាធាតុមានភាពទៀងទាត់ទេ, មិនមែនជារបស់រំដោះទុក្ខនៃសង្សារវដ្តដែលមនុស្សកំពុងជួបប្រទះបានទេ ។ តែជាស្ថានរបស់ចិត្តមួយក្នុងដំណើរឆ្លងចាកលោកទៅកាន់បរលោក ។ គំនិតពុទ្ធសាសនាក្នុងរឿង ប្រតិបត្តិធម៌ជាទូទៅត្រូវការត្រឹមតែស្ងប់កាយ, ស្ងប់ចិត្ត, ស្ងប់កិលេសប៉ុណ្ណឹង, គ្មានត្រូវការឫទ្ធិអំណាចតេជៈអ្វីទេ ។ ដូចនេះ, អ្នកប្រតិបត្តិធម៌កាលណាបានសម្រេចឫទ្ធិណាមួយដែលកើតឡើងដោយអាស្រ័យភាពស្ងប់ទាំងឡាយនេះ កុំគប្បីប្រើឫទ្ធិនេះក្នុងផ្លូវខុស ផ្លូវអកុសលឡើយ ។ ជាពិសេស, កុំស្មានថាឫទ្ធិទាំងឡាយជាសម្បត្តិរបស់ពុទ្ធសាសនា ។ ជាមួយគ្នានេះ, កុំកោងព្រហើន សម្លុត ប្រមាទមើលងាយអ្នកដទៃប្រកបដោយផ្ទត់គំនិតជាអមនុស្សធម៌ឡើយ ។ កាតព្វកិច្ចរបស់អ្នកប្រតិបត្តិធម៌ ខាងក្រោយមានចិត្តស្ងប់ ឬកើតអប្បនាសមាធិ ឬបានឈានលោកិយហើយត្រូវរក្សាទុក្ខឲ្យគង់ ហើយចាប់បម្រើ វិបស្សនា ដើម្បីដុះខាត់ឈានចិត្តជាលោកិយៈឲ្យបានសម្រេចឈានចិត្តជា លោកុត្តរៈប៉ុណ្ណោះ ។ តាមន័យនេះ, យើងអាចកត់សម្គាល់បានថា : ឫទ្ធិត្រឹមជាឫទ្ធិ, វាមិនអាចជូនមនុស្សឲ្យដល់អ្វីដែលពុទ្ធសាសនាចង់ថា ទីបំផុតនៃទុក្ខ បានឡើយ ។ ក្នុងរឿងដដែលនេះគេអាចនិយាយបានម៉្យាងទៀតថា : ឫទ្ធិវាត្រឹមតែជាកីឡាមួយបែបរបស់អ្នក អប់រំចិត្តឲ្យស្ងប់, វាជារបស់ចម្លែកសម្រាប់មនុស្សគ្មានឫទ្ធិ, តែវាជារបស់ធម្មតា សម្រាប់មនុស្សមានឫទ្ធិដូចគ្នា ។ បើគេចូលចិត្តថាឫទ្ធិតេជៈបាដិហារិយ៍ ជាធាតុមានពិតប្រាកដមែន ក៏វាជារឿងស្គាល់ រឿងចូលចិត្តក្នុងហេតុផល នៃច្បាប់ នៃទម្លាប់របស់ធម្មជាតិខាងផ្លូវវិញ្ញាណហ្នឹងឯង ។ គេអាចប្រៀបប្រដូចបាននឹង គ្រឿងប្រដាប់ទាំងឡាយ របស់វិទ្យាសាស្ត្រមានជាអាទិ៍ វិទ្យុ, ទូរស័ព្ទ, ទូរលេខ, ទូរគមនាគមន៍, ទូរបញ្ជា, អាកាសយាន, យានអវកាស ។ល។ បើនឹងថារបស់អស់ទាំងនេះ ជារបស់មានគុណភាពគួរអស្ចារ្យ, គឺគង់ភាពអស្ចារ្យនេះមានតែលើ មនុស្សដែលធ្វើ មិនកើត ។ សម្រាប់អ្នកធ្វើកើត, វាជាធម្មតាទៅវិញ ។ អ្នកវិទ្យាសាស្ត្រ, ខាងផ្នែកបង្កើតគ្រឿងប្រដាប់ ប្រើផ្សេងៗ កាលណាគេបានស្គាល់ច្បាប់, ស្គាល់កម្លាំង, ស្គាល់ជាភាពរបស់ធម្មជាតិ គេរមែងធ្វើបានតាមការ ស្ទាត់ជំបនាញរបស់គេ ។ ឫទ្ធិតេជៈបាដិហារិយ៍ក៏មានទំនាក់ទំនងដូចគ្នា, អ្នកប្រតិបត្តិធម៌ កាលណាបានស្គាល់ច្បាប់, ស្គាល់កម្លាំង, ស្គាល់ថាមភាពរបស់ចិត្តគេក៏អាចធ្វើបានដែរ បើមិនច្រើនក៏តិច ស្រេចហើយតែបរិមាណនៃការ ស្ទាត់ជំនាញរបស់ខ្លួន ។ ដូចនេះគេអាចទុកដាក់រឿងឫទ្ធិតេជៈបាដិហារិយ៍ ដែលមានក្នុងពុទ្ធសាសនា ដូចជារបស់ធម្មតា មិនមែនជាធាតុអស្ចារ្យចម្លែកអ្វី ក្នុងលោកនៃមនុស្សយើងនេះទេ ។ គឺវាមានន័យត្រឹមតែឲ្យអ្នកផង ធ្វើការកត់សម្គាល់នូវផលថ្មីនៃគំនិតក្នុងចំណុចខ្លះ របស់អ្នកវិទ្យាសាស្ត្រខាងចិត្តវិញ្ញាណប៉ុណ្ណោះ ។

បញ្ហាថា ឫទ្ធិតេជៈបាដិហារិយ៍ជារបស់មានពិតមែន ឬគ្មានទេ បញ្ហានេះត្រូវបានសង្គមមនុស្សចោទសួរគ្នាជានិច្ច, ហើយដែលគេបានទទួលចម្លើយមកហើយខ្លះថាមាន, ខ្លះថាគ្មាននោះ ។ បញ្ហានេះប្រសិនជាយើងឆ្លើយកណ្ដាលៗកុំទាន់អាលឲ្យស្របនឹងពួកណាមួយ ក្នុងបណ្ដាពួកទាំងពីរគឺ ពួកបដិសេធ មិងពួកទទួល ។ យើងត្រូវឲ្យចម្លើយថា មានផងគ្មានផង ព្រោះឫទ្ធិតេជៈបាដិហារិយ៍ខ្លះវាជារបស់ពិត ព្រោះវាកើតពីចិត្តអ្នកប្រតិបត្តិធម៌ត្រឹមត្រូវ ។ ខ្លះវាជារបស់ក្លែង ព្រោះវាកើតពីចិត្តអ្នកបម្រើតណ្ហា បម្រើសេចក្ដីសប្បាយរបស់ខ្លួន ។ ដែលថាមាន ព្រោះវា

មានមែនតាមសេចក្ដីពិត ។ ដែលថាគ្មាន ព្រោះវាគ្មានហើយបន្លំធ្វើមាន ។ តាមធម្មតា, របស់ពិតនិងរបស់ក្លែងធាតុទាំងពីរនេះវានៅជិតគ្នាណាស់ ដូចយើងបានឮរឿយៗក្នុងសង្គមជនថា ប្រាក់សុទ្ធ, ប្រាក់ក្លែង, មាសសុទ្ធ, មាសក្លែង ។ល។ គឺថា របស់ពិតនៅត្រង់ណា របស់ក្លែងនៅត្រង់នោះ ធម៌ពិតនៅត្រង់ណា ធម៌ក្លែងនៅត្រង់នោះ ឫទ្ធិពិតនៅត្រង់ណា ឫទ្ធិក្លែងនៅត្រង់នោះ ។ ក្នុងករណី, ឫទ្ធិតេជៈបាដិហារិយ៍ជារបស់មានក្នុងពុទ្ធសាសនានោះ, យើងត្រូវដឹងថារបស់នេះ មិនមែនជារបស់មាននៅក្នុងទិសដៅរបស់ពុទ្ធសាសនាយើងទេ ។ ទិសដៅដែលពុទ្ធសាសនាដើរទៅរក ឬប្រកាន់យកនោះ គឺទីបំផុតនៃទុក្ខ, សន្តិភាពនៃជីវិត, វឌ្ឍនភាពនៃយុត្តិធម៌, សម្បូរសប្បាយនៃសង្គមមនុស្ស ។ល។ បើបកស្រាយតាម គំនិតពុទ្ធសាសនាសុទ្ធៗ ឫទ្ធិទាំងឡាយមានជាអាទិ៍ហោះ មុជជ្រែក . . . . . របស់នេះវាជាផលរបស់លោកិយឈាន, លោកិយឈានជាជណ្ដើររបស់លោកុត្តរឈាន ប្រសិនបើគេ ប្រើជណ្ដើរនេះមិនត្រូវ ។ ឫទ្ធិរបស់គេនឹងរលាយបាត់ទៅវិញ ។ ដូចនេះអ្នកប្រតិបត្តិធម៌គប្បីដឹងថា ឫទ្ធិទាំងឡាយរបស់ចិត្តនៃបុគ្គលអ្នកចម្រើនសមថកម្មដ្ឋាន (ឈានលោកិយ) គេមិនអាចយកទៅប្រើក្នុងផ្លូវខុស ដូចហោះលេងតាមអាកាស, ជ្រែកលេងក្នុងផ្ទៃដី, មុជចុះលេងក្នុងទឹក ។ល។ បានទេព្រោះគុណធម៌ផ្នែកនេះ ពុទ្ធសាសនាពុំបានអនុញ្ញាតឲ្យប្រើក្នុងផ្លូវអាក្រក់, ផ្លូវកាម, ផ្លូវផ្តន្ទាព្យាបាទទេ ។ល។ តែដោយចិត្តទាំង ៣ ប្រភេទ ដែលមនុស្សលោកបានរកឃើញបានទម្លាប់ប្រើមកហើយ, បានទទួលផលគួរសមដែរ ព្រះសម្មាសម្ពុទ្ធរបស់យើង មិនត្រឹមតែពុំបដិសេធចោលទេ ។ ព្រះអង្គបានធ្វើការកែសម្រួលជាថ្មី ដើម្បីឲ្យមានលក្ខណៈជាវិទ្យាសាស្រ្ត ហើយប្រកាសឲ្យប្រើជាមួយលោកុត្តរចិត្តដែលព្រះអង្គទើបរកឃើញថ្មី ដោយចាត់លំដាប់ពីទាបទៅកណ្ដាលខ្ពស់គឺ : កាមាវចរចិត្តជាទី១, រូបាវចរចិត្តជាទី២, អរូបាវចរចិត្តជាទី៣ និង លោកុត្តរចិត្តជាទី៤ ។ ក្នុងន័យថា ពុទ្ធសាសនា ជួយស្រាយបញ្ហាមនុស្សតាមលំដាប់ថ្នាក់ដែលគេធ្លាប់ដឹងថា ប្រោសសត្វតាមនិស្ស័យហ្នឹងឯង ។ អ្នកណាចង់ រស់នៅក្នុងកាមលោក ព្រះអង្គពន្យល់នៃនាំថាដើម្បីវឌ្ឍនភាពក្នុង កាមសុខបច្ចុប្បន្ន កាមភោគីបុគ្គល ត្រូវបំពេញ សម្បទាបច្ចុប្បន្ន ៤ (ឧដ្ឋានៈ, អរក្ខៈ, កល្យាណមិត្តតា, សមជីវិតា) ។ ដើម្បីវឌ្ឍនភាពក្នុងកាមសុខនាបរលោក កាមភោគីបុគ្គលត្រូវបំពេញសម្បទាបរលោក ៤ (សទ្ធា, សីលៈ, ចាគៈ, បញ្ញា) ដើម្បីវឌ្ឍនភាពក្នុងរូបសុខ និងអរូបសុខ រូបសុខីបុគ្គល និអរូបសុខីបុគ្គលត្រូវបំពេញរូបឈាន ៤ និងអរូបឈាន ៤ ។ ដើម្បីឆ្លងចាកទុក្ខទាំងអស់ ឬដើម្បីដល់ទីបំផុតនៃទុក្ខ ភយទស្សីបុគ្គលត្រូវបំពេញបរមត្ថសម្បទា ៤ (ទុក្ខៈ, សមុទយៈ, និរោធ, មគ្គ) ។

ឫទ្ធិតេជៈបាដិហារិយ៍ ដែលគេបានដឹងឮតៗគ្នាមក ទោះជារបស់សាសនាទាំងឡាយក្ដី របស់លទ្ធិណាមួយក្ដី របស់តួឯកម្នាក់ៗដែលមាននិយាយក្នុងរឿងព្រេងក្ដី ។ ធាតុនេះគេប្រើតែក្នុងផ្លូវបោកប្រាស់ ជិះជាន់ សង្កត់សង្កិនគ្នា ឬបើមានជួយគ្នាខ្លះក៏ជួយក្នុងកលល្បិចរកប្រយោជន៍ រកចំណេញពីមនុស្សគ្នាឯង ។ ធំជាងនេះ, ការសម្ដែងបាដិរិយ៍របស់អ្នកមានឫទ្ធិ ដែលគេបានសង្កេតឃើញជាទូទៅ មកហើយនោះមិនមែនជាវិទ្យាសាស្រ្តសេដ្ឋកិច្ចទេ ។ ដូចនេះ ព្រោះអ្វី? ព្រោះទីណាសម្បូរអ្នកបាដិហារិយ៍នៅអាស្រ័យ ទីនោះវឌ្ឍនភាពខាងកសិកម្ម, បសុកម្ម, ពាណិជ្ជកម្មនិងឧស្សាហកម្មគ្មានទេ ។ល។ ឫទ្ធិបាដិហារិយ៍មានលក្ខណៈត្រឹមតែជានិតិន័យ ពុំបានមានលក្ខណៈជាព្រិត្តិន័យគឺបានតែអួតហោះហើរមុជជ្រែកជប់និម្មិតតំណែងក្រឡា ។ល។ ឲ្យមនុស្សកោតខ្លាចសរសើរប៉ុណ្ណោះ ។ ពុំបានបង្កើតរបស់គ្រប់បែបយ៉ាង ឲ្យមនុស្សរស់នៅស្រួលផងឡើយ ។ ពោលឲ្យចំៗ គឺអ្នកមានឫទ្ធិក្រៅពីសម្ដែងបង្អួតអ្នកដទៃគ្មានអ្វីទៀតទេ មានតែសង្កត់កគេដណ្ដើមយកកូនប្រពន្ធ ទ្រព្យសម្បត្តិរបស់គេតាមចិត្តពាលយង់ឃ្នងរបស់ ខ្លួនព្រោះអាងខ្លួនមានឫទ្ធិ គ្មានអ្នកណាហ៊ានតដៃប៉ុណ្ណឹងឯង ។

ក្នុងបច្ចុប្បន្ននេះ អ្នកស្រាវជ្រាវខាងផ្លូវចិត្ត ក្នុងបស្ចិមប្រទេសខ្លះ បានបង្កើតស្ថាប័នដើម្បីកិច្ចការនេះដោយឲ្យឈ្មោះថា (INSTITUTE FOR ISYCHICAL RESEARCH) ភាសាខ្មែរយើងថា ស្ថាប័នស្រាជ្រាវខាងផ្លូវចិត្ត ក្នុងគោលគំនិត

ពិសោធឫទ្ធិនានា ដែលមនុស្សហ្វឹកហាត់ចិត្តបានសម្រេច ហើយបានសម្តែងឲ្យអ្នកដទៃមើលឃើញបានប្លែកៗគ្នា តាមការស្ទាត់ជំនាញដែលខ្លួនគេមានក្នុងប្រភេទណា មានកម្រិតខ្ពស់ទាបថ្នាក់ណាប៉ុណ្ណោះ ។ ដើម្បីរកមធ្យោបាយ ឬគំនិតថ្មីថ្មែបំបែរឫទ្ធិទាំងឡាយនោះ ឲ្យមានលក្ខណៈជាវិទ្យាសាស្រ្តខាងផ្លូវចិត្តប្រាកដឡើង ។ មានសាស្រ្តាចារ្យ ជាច្រើនរួមគំនិតគ្នាធ្វើការនេះ ដោយគ្មាននឹកនាដល់សេចក្តីនឿយហត់ សម្បីបន្តិចបន្តួចឡើយ ។ ប្រទេសដែលយក ចិត្តទុកដាក់ច្រើនជាងគេក្នុងរឿងនេះ គឺសហរាជាណាចក្រអង់គ្លេស, និងសហរដ្ឋអាមេរិក ។ សាស្រ្តាចារ្យដែល ខំប្រឹងច្រើនជាងគេ គឺសាស្រ្តាចារ្យដែលមានជាតិ ឬសញ្ជាតិអង់គ្លេស អាមេរិកកាំង ។ ការពោសោធន៍របស់គេ, គេធ្វើដោយល្អិតមធ្យ័តមានកំណត់ហេតុ មានស្ថិតិប្រកបដោយលក្ខណៈច្បាស់លាស់ទៀងទាត់ ។ តួយ៉ាងពិសោធ អំពីភ្នែកទិព្វ គេយកវត្ថុមួយដាក់ចូលក្នុងប្រអប់បិទយ៉ាងជិត ហើយគេឲ្យមនុស្សដែលបានហ្វឹកហាត់ចិត្ត កើតពីឫទ្ធិ ខាងភ្នែកដែលគេហៅម្យ៉ាងទៀតថា មនុស្សមានភ្នែកទិព្វ មើលរបស់ក្នុងហិបនោះ ។ ជាមួយគ្នានេះ, គេឲ្យទាយថា ហិបនោះមាន របស់អ្វីនៅខាងក្នុងខ្លះ ។

អ្នកចិត្តវិទ្យាសម័យទំនើប, បានទទួលស្គាល់ថា ក្រសៃប្រសាទ ឬថាមពលដែលកើតក្នុងរបបប្រាសាទបាន ធ្វើសេចក្តីរាយការណ៍បញ្ជូនទៅឲ្យខួរក្បាលដឹងហេតុការណ៍ផ្សេងៗ ។ នៅខាងចុង ឬនៅទីបំផុតប្រាសទចំណែកខ្លះ នៃមនុស្សយើង ដែលមានមុខងារខាងទទួលដំណឹងនោះ គឺជាថាមពលនៃអគ្គិសនីមួយបែប ។ កាលណាថាមពល រួមភាពចូលគ្នាក៏កើតបានជារបបប្រាសាទ (NERVOUS SYSTEM) ។ នៅក្នុងរបបប្រាសាទនោះ មានថាមពលអគ្គិសនី ផ្សាំលាយយ៉ាងច្រើន ។

អ្នកវិទ្យាសាស្រ្តរូបនិយម ឬកាយភាព (PHYSICAL SCIENTISTS) ក្នុងសម័យមួយ ធ្លាប់បាននិយាយថា រូបធាតុ ទាំងឡាយកាលណាបើគេ ធ្វើការវែកញែកឲ្យដល់ទីបំផុត តាមក្បួនវិទ្យាសាស្រ្តនោះ របស់ដែលគេឃើញនៅសល់ ឬចំណិតចុងបំផុតរបស់វាគឺបរមាណូ ។ បរមាណូគឺជាធាតុមានភាគតូចបំផុត ដែលញែកទៅទៀតលែងកើត ។ តែក្នុងសម័យបច្ចុប្បន្នអ្នកវិទ្យាសាស្រ្តអស់ទាំងនោះបានទទួលដឹងថា បរមាណូបើគេវែកញែកតទៅទៀត លទ្ធផលគឺ ថាមពលអាគ្គិសនីហ្នឹងឯង ។ ដោយគែស្គាល់វិធីញែកបរមាណូ ទើបគេបង្កើតគ្រាប់បែកបរមាណូ មាណពលានុភាព ខ្លាំងពូកែ ទម្លុះទម្លាយបំផ្លិចបំផ្លាញរបស់ផងទាំងពួង ឲ្យវិនាសហិនហោច លើសកម្លាំងគ្រាប់បែកធម្មតាច្រើពាន់ ច្រើនម៉ឺនភាគ ។

អ្នកវិទ្យាសាស្រ្តជាតិអាមេរិកកាំងម្នាក់បាននិយាយថា នៅក្នុងរូបកាយនៃមនុស្សយើងនេះ មានថាមពល អគ្គិសនីអាចធ្វើគ្រាប់បែកបរមាណូ បានមួយគ្រាប់មានកម្លាំងកម្ទេចក្រុងញីវយ៉កទាំងមូល ឲ្យសូន្យក្នុងរយៈកាល ត្រឹមមួយដង្ហើមចង្រឹត ។ អ្នកវិទ្យាសាស្រ្តនេះបានធ្វើសេចក្តីបញ្ជាក់បន្ថែមថា នៅក្នុងខ្លួនមនុស្សម្នាក់ៗ មានធាតុ ថាមពលច្រើន ។ កំណប់អាថ៌កំបាំងនេះ ជារបស់មានប្រយោជន៍ដល់មនុស្សជាតិពិតៗមែន ។ តែការនាំចេញយក ថាមពលនេះមកប្រើដោយវិធីណា, ប្រើធ្វើជាអ្វីខ្លះ បញ្ហានេះនៅលើគំនិតរបស់មនុស្ស, ពុំមែននៅលើឫទ្ធានុភាពនៃ ព្រះអាទិទេពទេ ។ កាលបើថាមពលអាគ្គិសនី មានប្រយោជន៍សំខាន់ទាំងក្នុងវត្ថុនៅខាងក្រៅ, ទាំងក្នុងរបបប្រាសាទ ខាងក្នុងរបស់មនុស្សដូចនេះ ។ អ្នកណាចង់សម្តែងឥទ្ធិបាដិហារិយ៍ នៅក្នុងកម្រិតណា ថ្នាក់ណា ជាន់ណាគេអាច ធ្វើបានឲ្យតែគេចេះហ្វឹកហាត់អប់រំចិត្ត ឬស្គាល់វិធីនាំចេញនូវថាមពលបរមាណូ យកទៅប្រើក្នុងកិច្ចការណា ឬក្នុងទំរើ ណាដែលខ្លួនគេត្រូវការ ។

បុគ្គលមានចិត្តស្ងប់ ថ្នាក់បានសម្រេចឈានក្តី ជិតតែនឹងបានឈានក្តី គេអាចប្រមូលផ្តុំថាមពលអគ្គិសនី ក្នុងខ្លួនរបស់គេបានច្រើនជាងមនុស្សធម្មតា ។

ព្រមគ្នានេះ, កាលណាគេហាត់ថាមពលនេះជានិច្ច លុះត្រាតែមានភាពស្ទាត់ជំនាញមែនទែន គេអាចធ្វើនូវ

ទំរើប្លែកៗបាន ។ ទំរើរបស់គេនេះអ្នកផងឃើញហើយលំបាកនឹងជឿ តែការមានជំនឿក្តី គ្មានជំនឿក្តីរបស់មនុស្សយើងវាជាការធម្មតាទេ ។ ការដែលសំខាន់ក្នុងរឿងនេះ គឺយើងធ្លាប់បានឃើញថាមពលអគ្គិសនី ធ្វើការឲ្យ កើតពន្លឺកំដៅរហូតដល់ពង្វិលផ្លិត, គ្រឿងចក្រ, គ្រឿងយន្ត, ប្រដាប់អូស, ប្រដាប់ទាញ, ប្រដាប់កាប់, ប្រដាប់អារ, ប្រដាប់លើក ។ល។ និង ។ល។ ដែលកម្លាំងមនុស្សម្នាក់ ឬច្រើនពាន់ច្រើនម៉ឺននាក់ធ្វើមិនកើត ហើយថាមពល អគ្គិសនីធ្វើកើតយ៉ាងងាយៗធូរៗស្រួលៗ ជាយូរមកហើយ ។ នេះជាចម្លើយចំពោះសំណួរថា ថាមពលអគ្គិសនី មានឫទ្ធិតេជៈធ្វើអ្វីបានខ្លះ ។ នេះជាផ្នែកមួយខាងរូបធាតុ ។ ខាងចិត្តវិញ្ញាណវិញ ក៏ត្រូវឲ្យចម្លើយដូចគ្នានេះដែរ គឺចិត្តកាលណាបើគេបានអប់រំហ្វឹកហាត់ត្រឹមត្រូវតាមធម្មៈ ខាងផ្នែកចិត្តហើយ ក៏មុខជានឹងកើតថាមពល ធ្វើឲ្យបុគ្គលអ្នកអប់រំ សម្តែងឫទ្ធិបាដិហារិយ៍នាៗបាន មិនចាញ់ថាមពលខាងវត្ថុដូច វិទ្យុ, ទូរទស្សន៍, ទូរស័ព្ទជាដើម ដែលបាននិយាយមកហើយ ។ កាលណាគេស្គាល់វិធីធ្វើ ឬគេចេះធ្វើ ឬគេខំសិក្សាយ៉ាងប្តូរផ្តាច់ អំពីធាតុជា អាថ៌កំបាំងរបស់ធម្មជាតិ ទាំងខាងរូបធាតុ ទាំងខាងអរូបធាតុ គេអាចមានសមត្ថភាពធ្វើឲ្យកើតរបស់ផ្សេងៗ ប្រកប ដោយគុណភាពយ៉ាងចម្លែកអស្ចារ្យ ដែលអ្នកផងមិនធ្លាប់បានឃើញ មិនធ្លាប់បានប្រើប្រាស់ ។ និយាយយ៉ាងខ្លីៗ គឺគេចេះសើរើរៀបចំអំណាច ឬថាមពលក្នុងខ្លួនរបស់គេដែលមានចិត្តជាប្រភព, ជាមូលដ្ឋានហ្នឹងឯង ។ ភាពចម្លែក អស្ចារ្យមិនដែលកើតមានក្នុងចិត្តរបស់អ្នកធ្វើកើត ឬបង្កើតទេ, តែភាពដដែលនោះវាតែងកើតមាន ក្នុងចិត្តរបស់អ្នក មិនធ្វើ ឬធ្វើមិនកើត ។ ព្រោះអ្វី? ព្រោះអ្នកបង្កើតរបស់ផ្សេងៗគេបានរៀនចេះ, បានគិតយល់, បានពិសោធ ឃើញស្រេចបាត់អស់មកហើយ ។ គេធ្វើកើតតាមវិជ្ជា, តាមគំនិត, តាមការពិសោធន៍របស់គេ ។ ចំណែក អ្នកមិនបានរៀន ឬរៀនមិនចេះមិនបានគិត ឬគិតមិនយល់ មិនបានពិសោធ ឬពិសោធមិនឃើញ ។ កាលណាឃើញគេធ្វើអ្វីកើត រង្វាន់បេះដូងដែលអ្នកធ្វើកើត បានអំពីអ្នកធ្វើមិនកើត គឺកោតស្ញើចអស្ចារ្យហ្នឹងឯង ។ តែទោះជាយ៉ាងណាក៏ដោយ, ព្រះពុទ្ធសាសនារបស់យើង នៅតែប្រកាន់យកភាពស្ងប់រម្ងាប់, ភាពអស់ទុក្ខព្រួយ, ភាពអស់កំដៅដែលបណ្តាលមកពីកិលេសជាផ្លូវប្រតិបត្តិ ឬជាទិសដៅដដែល ។ ទំរើទាំងឡាយណាដែលធ្វើទៅហើយមិនប្រព្រឹត្តទៅដើម្បីរលត់សេចក្តីទុក្ខ សេចក្តីក្តៅក្រហាយ ទំរើទាំងឡាយនោះមិនមែនជាមាគ៌ា ជាឧត្តគតិ ជាវត្ថុបំណងរបស់ពុទ្ធសាសនាឡើយ ។

ដូចនេះ, ពុទ្ធសាសនិកណាចង់លេងកីឡាខាងឫទ្ធិតេជៈបាដិហារិយ៍ ក្រោយពីបានហ្វឹកហាត់អប់រំចិត្តកើតអំណាច, កើតឈានមានសមត្ថភាពក្នុងការសម្តែង ឫទ្ធិបាដិហារិយ៍បានហើយ ចង់បញ្ចេញឲ្យអ្នកផងឃើញតាមរបៀបណា ហោះក្តី មុជក្តី ជ្រែកក្តី ។ ដើម្បីជៀសវាងនូវកំហុសក្នុងរឿងនេះ, អ្នកសម្តែងឫទ្ធិត្រូវគួសបន្ទាត់គំនិតនៅលើភាពសន្តោស, ភាពមេត្តាប្រណី ។ ក្នុងន័យថា កុំសម្តែងឫទ្ធិព្រោះសេចក្តីលោភចង់បានលាភសក្ការៈ ព្រោះកំរោធចង់ព្យាបាទសេចក្តីសុខសាន្តអ្នកដទៃ ព្រោះសេចក្តីសង្វេគស្រវឹងសប្បាយក្នុងឫទ្ធិតេជៈរបស់ខ្លួន ។ ទំរើនេះ, អាចធ្វើខ្លួនឲ្យបានសម្រេចសេចក្តីសុខធម្មតា និងសេចក្តីសុខស្ងប់ជាន់ខ្ពស់ ដែលជាទីដៅនៃពុទ្ធសាសនា និងជាទីប្រាថ្នារបស់អ្នកប្រតិបត្តធម៌គ្រប់ប្រភេទ គ្រប់ជាន់ថ្នាក់ ដែលមានចែងក្នុងប្រយោជន៍ ៣ នៃពុទ្ធសាសនា របស់យើង ។

សេចក្តីសរុប : ពុទ្ធសាសនាជាសាសនាហេតុផល ជាសាសនាស្តីអំពីកម្មល្អកម្មអាក្រក់ ។ ដូចនេះធម្មៈណាគ្មានហេតុផល គ្មានសម្រេចថា កម្មអាក្រក់ល្អតាក់តែងសត្វឲ្យមានលក្ខណៈខុសប្លែកផ្សេងគ្នា ទាំងរូបកាយ, ទាំងពាក្យសម្តី ទាំងចិត្តវិញ្ញាណ ។ ខាងរូបកាយ, មានស, ខ្មៅ, ខ្ពស់, ទាប, ធាត់, ស្គម, ខ្វាក, ខ្វិន, គរថ្លង់ ។ល។ ខាងពាក្យសម្តី, មានមពីរោះ, ទ្រគោះ, ផ្អែម, ទន់ភ្លន់, ចោលដឹងទាំងដង, សុភាព, ទទឹងទិស ។ល។ ខាងចិត្តវិញ្ញាណ, មានឆ្លាត, ល្ងង់, ចេះ, វៃ, ប្រសព្វ, ប៉ិន, មឹងម៉ាំង, ភ្លើ, ល្ងឹត ។ល។ ទាំងអស់នេះ ជាផលរបស់កម្មអំពីអតីតៈខ្លះ ក្នុងបច្ចុប្បន្នខ្លះ ។ ចំណែកហេតុផល, បើខ្ញុំមិនសរសេរក្នុងបទនេះទៀតក៏បាន ព្រោះមានសំនេររបស់ខ្ញុំ ក្នុងបទទីមួយហើយ ។ តែដើម្បីដឹងជា បន្ទាន់ហើយច្បាស់លាស់ផង ។ ខ្ញុំសូមអ្នកអានពិនិត្យ ពិចារណាមើលហេតុផលក្នុង

បដិច្ចសមុប្បាទ ជាមួយនឹងខ្ញុំក្នុង ទីនេះទៀតមានដូចនេះ :

អវិជ្ជាជាហេតុ, សង្ខារជាផល, សង្ខារជាហេតុ, វិញ្ញាណជាផល, វិញ្ញាណជាហេតុ, នាមរូបជាផល, នាមរូបជាហេតុ, សឡាយតនជាផល, សឡាយតនជាហេតុ, ផស្សៈជាផល, ផស្សជាហេតុ, វេទនាជាផល, វេទនាជាហេតុ, តណ្ហាជាផល, តណ្ហាជាហេតុ, ឧបាទានជាផល, ឧបាទានជាហេតុ, ភពជាផល, ភពជាហេតុ, ជាតិជាផល, ជាតិជាហេតុ, មរណៈជាផល ។ នេះជាបទពិនិត្យ ពិចារណាបណ្តោយ ឬពីដើមទៅចុង ។

មរណៈជាផលរបស់ជាតិ, ជាតិជាផលរបស់ភព, ភពជាផលរបស់ឧបាទាន, ឧបាទានជាផលរបស់តណ្ហា, តណ្ហាជាផលរបស់វេទនា, វេទនាជាផលរបស់ផស្សៈ, ផស្សៈជាផលរបស់អាយតន, អាយតនជាផលរបស់នាមរូប, នាមរូបជាផលរបស់វិញ្ញាណ, វិញ្ញាណជាផលរបស់សង្ខារ, សង្ខារជាផលសបស់អវិជ្ជា ។ នេះជាបទពិនិត្យពិចារពណាច្រាស់ ឬពីចុងទៅដើម ។ អ្នកអានគប្បីសង្កេតថា បទបណ្តោយដែលយើងធ្លាប់និយមហៅថា »អនុលោម»នោះ សំនេររបស់ខ្ញុំមានដូរហេតុជាផល ផលជាហេតុ ព្រោះបដិច្ចសមុប្បាទធម៌ មានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដែលលោកប្រៀបប្រដូចនឹងកាំច្រវាក់ គឺធម៌មួយដដែលហ្នឹងម្តងកាន់មុខងារជាហេតុម្តងកាន់មុខងារជាផល ។ ចំណែកបទច្រាស់ដែលយើងនិយមហៅថា «បដិលោម» នោះ ក្នុងសំនេររបស់ខ្ញុំ គ្មានហេតុទេ មានត្រឹមតែផល ។ហេតុអ្វី? ហេតុថា បើសរសេរទាំងពីរទៅ សេចក្តីនឹងជាន់គ្នានាំឲ្យលំបាក ស្តាប់ទៅវិញ ។ ក្រៅពីហេតុផលក្នុង បដិច្ចសមុប្បាទ មានហេតុផលទូទៅយ៉ាងច្រើនទៀតដូច :

ទានជាផលនៃអលោភហេតុ សីលជាផលនៃអទោសហេតុ ភាវនាជាផលនៃអមោហហេតុ ។ គ្មានទានជាផលនៃលោភហេតុ គ្មានសីលជាផលនៃទោសហេតុ គ្មានភាវនាជាផលនៃមោហហេតុ ។ សុខជាផលនៃហេតុគឺបុណ្យ ទុក្ខជាផលនៃហេតុគឺបាប វិជ្ជាជាផលនៃហេតុគឺរៀន ទ្រព្យជាផលនៃហេតុគឺរក សេចក្តីថ្លៃថ្នូរជាផលនៃហេតុគឺ ប្រព្រឹត្តល្អ ។ល។ និង ។ល។ ដើម្បីជាគូគំនិតរបស់អ្នកអាន ខ្ញុំសូមធ្វើសេចក្តីបំភ្លឺយ៉ាងខ្លី :

អស់រយៈកាលយូរណាស់ហើយ មនុស្សយើងកាលណាមានជម្ងឺអ្វីមួយកើតឡើង គេមានជំនឿថា ជម្ងឺជាផលនៃទំរើរបស់ខ្មោច គេនាំគ្នាអង្វរខ្មោច សូមឲ្យខ្មោចអាណិតមេត្តាឲ្យគេជា គេនឹងធ្វើការតបស្នងសងគុណខ្មោចដោយឲ្យរបស់ផ្សេងៗ ស្រេចហើយតែខ្មោចចង់បាន ។ នេះគឺជាជំនឿគ្មានហេតុផល, គ្មានពន្លឺ, គ្មានត្រឹមត្រូវតាមគំហើញរបស់អ្នកប្រាជ្ញទាំងផ្លូវសាសនាទាំងផ្លូវវិទ្យាសាស្ត្រ ។ ព្រោះអ្វី? ព្រោះថាព្រះពុទ្ធក្តី អ្នកវិទ្យាសាស្ត្រក្តីពុំបានថែងថា ជម្ងឺជាផលនៃទំរើរបស់ខ្មោច ឬខ្មោចមិនមែនជាហេតុនៃផលគឺជម្ងឺរបស់មនុស្សឡើយ ។ ការពិត, ទាំងពុទ្ធសាសនា ទាំងវិទ្យាសាស្ត្របានមានមតិស្របគ្នាថា ជម្ងឺកើតពីកំហុសនៃទំរើរបស់មនុស្ស ដូចជាបរិភោគអាហារមានសត្វមេរោគ ទឹកដំណេកមានសត្វមេរោគ សម្លៀកបំពាក់មានជាប់សត្វមេរោគ រស់នៅជាមួយមនុស្សមានជម្ងឺមានសត្វមេរោគ ។ល។ ព្រះពុទ្ធសាសនាមាននិយាយអំពីសមុដ្ឋាននៃជម្ងឺ ៨ យ៉ាង ដែលពុទ្ធសាស និកធ្លាប់ចេះចាំស្រាប់ ។ ក្នុង ៨ យ៉ាង នោះមានមួយផង, កម្មគឺទំរើ ឬអំពើរបស់មនុស្សហ្នឹងឯង ។ ទំរើពុទ្ធសាសនាបានចែកជាពីរគឺ : ទំរើក្នុងបច្ចុប្បន្នកាល ១, ទំរើក្នុងអតីតកាល ១ ។ ក្នុងបច្ចុប្បន្នកាលបានដល់ ទំរើដែលគេធ្វើខុសក្បួនអនាម័យ ។ ក្នុងអតីតកាលបានដល់ទំរើ ដែលគេធ្វើអាក្រក់ក្នុងជាតិមុន ។ បើតាមនៃនេះ ខ្មោចគ្មានបានបង្កើតជម្ងឺទេ អ្នកបន់ខ្មោចសូមជាជម្ងឺគ្មានត្រូវហេតុផលទេ ។ ព្រោះអ្វី? ព្រោះខ្មោចកាលរស់ជាមនុស្សនៅឡើយ បានធ្វើកម្មអាក្រក់ ឬបានប្រព្រឹត្តទំរើខុសក្បួនអនាម័យ កើតជម្ងឺ, មើលខ្លួនឯងមិនជាខូចខ្លួនទៅ គេហៅថា «ខ្មូច» ក្រោយមកពាក្យ «ខ្មូច» នេះមកជាខ្មោចវិញ ដោយផ្លាស់ស្រៈអូ មកជាស្រៈអោ ឬយ៉ាងម៉េចមិនដឹងដែរ ! តែកាលដើម គេហៅថា ខ្មូច ។ ឧទាហរណ៍ ពូរឹងមានជម្ងឺ ថ្ងៃមួយស្លាប់ មានមិត្តភក្តិមកសួរថា ម៉េចទៅពូឈឺ កូនចៅឆ្លើយថា : គាត់ខូចពីថ្ងៃអាទិត្យទៅហើយ ។ មនុស្សឈឺមើលខ្លួនឯងមិនជាខូចទៅ អ្នកឈឺក្រោយមិនបានជាគិត ទៅនិយាយនឹងអ្នកខូច

ឬខ្មោចឲ្យជួយខ្លួនកាលណាបានជា នឹងថ្វាយនេះថ្វាយនោះ តើគ្មានហេតុផលមែនទេ ។ អ្នកមានជំនឿក្នុងកម្មផល ត្រឹមត្រូវតាមធម្មៈគំនោលនៃ ពុទ្ធសាសនាក្នុងចំណុចថា «កម្មុនា វត្តតិ, លោកោ កម្មុនា វត្តតិ បជា» «ពិភពលោកប្រព្រឹត្តទៅតាមការងារប្រជាសត្វប្រព្រឹត្តទៅតាមការងារ» ក្នុងន័យថា ពិភពលោកក្តី មនុស្សសត្វទាំងឡាយដែលអាស្រ័យនៅក្នុងពិភពលោកក្តី បានចម្រើនរុងរឿងក៏ដោយសារកម្ម, បានទុក្ខលំបាកក៏ដោយសារកម្ម ។ គតិនេះហាក់ដូចចប់ស្រេចប៉ុណ្ណឹហើយ ហេតុអ្វីបានជានាំគ្នា សូត្រធម៌បន់ស្រន់អំពាវនាវសូមទេវតា ឲ្យជួយផ្តល់សេចក្តីសុខសួស្តីជ័យមង្គលថែមទៀត តើទំរើវនេះបើ ចាត់ថា គ្មានហេតុផលបានដែរឬទេ? នេះជាសេចក្តីយល់ឃើញរបស់ខ្ញុំ អ្នកអានមានគំនិតយ៉ាងណា ខ្ញុំមិនដឹងដែរ ។

ពុទ្ធសាសនាបង្រៀនសត្វលោកឲ្យរស់នៅជាមួយហេតុផលជាមួយការងារល្អ ។ កាលណាជីវិតមានហេតុផល, វឌ្ឍនភាពរបស់ជីវិតនឹងមានកម្រឹតខ្ពស់ ។ ជាមួយគ្នានេះ, ជីវិតនឹងមានពំនឹងយ៉ាងមាំ, មានជំហរយ៉ាងរឹងប៉ឹងគ្មានឧបសគ្គណាអាចច្រានរលំ, អាចធ្វើឲ្យរង្គោះរង្គើបាន ។ ព្រោះអ្វី? ព្រោះអ្នកមានហេតុផល គេគ្មានគំនិតទំរើពំនោលប្រាសចាកហេតុផលសូម្បីបន្តិចបន្តួចឡើយ ។ ខាងគំនត, គេគិតថា គុណសម្បត្តិនិងគុណវិបត្តិ មិនមែនជារបស់ត្រូវបង្កើតដោយព្រះអាទិទេព . . . . . ទេ ។ អ្នកបង្កើតធាតុទាំងពីរនេះ គឺមនុស្សសត្វធម្មជាតិ ។ ខាងទំរើ, គេខិតខំធ្វើយ៉ាងណាឲ្យជីវិតរបស់គេ បានទទួលនូវគុណសម្បត្តិ, ប្រាសចាកគុណវិបត្តិ ។ ទាំងខាងពំនោល, គេពោលថា ជីវិតមានគុណសម្បត្តិក្តី គុណវិបត្តិក្តី វាមិនមែនមានដោយព្រះប្រោស, ទេពប្រទាន, ខ្មោចឲ្យទេ ។ ការពិត, គឺវាមានដោយគំនិតមានពន្លឺ គ្មានពន្លឺ ទំរើអាក្រក់ល្អ ពំនោលត្រូវខុស ។ គេមានគំហើញថា នៅក្នុងខ្លួនរបស់មនុស្សមានវត្ថុស័ក្តិសិទ្ធិ មានថាមពល មានភាពខ្លាំងពូកែជាប់មកជាមួយកំណើត ។ តែជាធាតុមានអាថ៌កំបាំងគ្មាននរណាមើលឃើញ ។ របស់ទាំងអស់នេះ បើមនុស្សចេះគាស់កាយយកមកប្រើ ចេះរៀបចំឲ្យត្រូវរបៀបចេះទុកដាក់ឲ្យត្រូវទំនង ចេះអនុវត្តឲ្យត្រឹមត្រូវតាមពន្លឺនៃគំនិត ឬគំនោលនៃវិជ្ជានានាៗនោះ ។ មនុស្សធម្មតានឹងទៅជាខ្លាំងពូកែ លុះត្រាបាត់ឈ្មោះមនុស្ស, មានឈ្មោះ ដទៃមកជំនួស ដូចព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធ, ព្រះវិស្វករ, ព្រះគ្រូ, ព្រះពោធិសត្វ ។ល។ ដទៃពីនេះទៀត, មនុស្សមានហេតុផល គេគ្មានជំនឿថា សុភមង្គលសិរីសួស្តី និងភ័យវិបត្តិ គ្រោះថ្នាក់ផ្សេងៗ កើតឡើងដោយការប្រសិទ្ធិ៍, ការផ្តន្ទា របស់ខ្មោចបិសាច ទេពតន្ទព្រហ្មឡើយ ។ល។ គឺកើតតាមហេតុ, តាមដំណើរតាមការវិវត្តនិងការប្រែប្រួលរបស់ធម្មជាតិ ឬទំរើអាក្រក់ល្អរបស់មនុស្ស ជាមួយគ្នានេះទៀត, ពុទ្ធសាសនាបង្រៀនឲ្យសត្វលោក រស់នៅជាមួយទំរើល្អ ឬទំរើយុត្តិធម៌ ។ ពុទ្ធសាសនាថា ទំរើល្អជាហេតុនៃសន្តិភាព, ទំរើអាក្រក់ជាហេតុនៃសង្គ្រាម ។ ខាងផ្លូវកាយ, មិនសម្លាប់ជីវិតនៃគ្នានិងគ្នា, មិនលួចទ្រព្យសម្បត្តិនៃគ្នានិងគ្នា, មិនលួចប្រពៃណីបុរសស្ត្រីនៃគ្នានិងគ្នា ។ ខាងផ្លូវសម្តី, មិនពោលពាក្យកុហក, មិនពោលពាក្យជេរប្រទេច, មិនពោលពាក្យញុះញង់បំបាក់បំបែក មិនពោលពាក្យ គ្មានហេតុផល គ្មានកើតផលប្រយោជន៍ ។ ខាងផ្លូវចិត្ត, មិនមានគំនិតរំពៃចង់បានរបស់គេ នៅក្នុងក្របខ័ណ្ឌ លួចតាមផ្លូវចិត្ត, មិនមានគំនិត ព្យាបាទគុំកួនបំផ្លាញសេចក្តីសុខសាន្តរបស់គេ នៅក្នុងក្របខ័ណ្ឌផ្តន្ទាគេតាមផ្លូវចិត្ត, មិនមានសេចក្តីយល់ខុស នៅក្នុងក្របខ័ណ្ឌនៃគំនិតគ្មានបុណ្យបាប, គ្មានវិបាកនៃបុណ្យបាប ។

ពុទ្ធសាសនា, ដឹកនាំមនុស្ស ឲ្យរស់នៅលើហេតុផលនិងទំរើល្អ (កុសលកម្ម) កាលណាមនុស្សយើងសុខចិត្តព្រមរស់នៅក្នុងក្របខ័ណ្ឌនេះហើយ ទោះណាជាមិនមានឫទ្ធិបាដិហារិយ៍ ក៏គ្មានបញ្ហាអ្វីចោទឡើងដែរ ។ ព្រោះអ្វី? ព្រោះសុភមង្គលនិងសន្តិភាពនៃជីវិតរបស់គេបានកើតមានអស់ហើយ ។

ក្នុងទីបំផុតនៃអត្ថក្នុងបទនេះ អ្នកអានទាំងឡាយ សូមកត់សម្គាល់ថា : ព្រះពុទ្ធសាសនារបស់យើង ទោះណាជាកាត់ឫទ្ធិតេជៈបាដិហារិយ៍ចេញ ឬទុកឫទ្ធិតេជៈបាដិហារិយ៍ដដែល តែដកជំនឿចេញក៏វាគ្មានរឿងអ្វីនាំឲ្យប៉ះពាល់

ទង្គិចទង្គុកដល់គំនោលធម្មៈរបស់ពុទ្ធសាសនា សូម្បីបន្តិចបន្តួចឡើយ ។ ដូចនេះព្រោះអ្វី? ព្រោះពុទ្ធសាសនាពុំបានមានឫសគល់នៅលើឫទ្ធិតេជៈបាដិហារិយ៍ឡើយ ។ ឬបើនឹងនិយាយម៉្យាងទៀតថា : ឫទ្ធិតេជៈបាដិហារិយ៍ ធាតុនេះវាមិនមែនជាមូលដ្ឋាន, មិនមែនជាប្រភពនៃគំនោលធម្មៈរបស់ពុទ្ធសាសនាវិញក៏បាន ។ ហេតុការណ៍មួយទៀតដែលគួរឲ្យយើងចងចាំក្នុងទីនេះដែរនោះ គឺវត្ថុវិទ្យាសាស្ត្រទំនើបក្តី កសិកម្មទំនើបក្តី បសុកម្មទំនើបក្តី ពាណិជ្ជកម្មទំនើបក្តី ។ល។ របស់ទាំងនេះសុទ្ធតែកើតឡើងដោយអាស្រ័យថ្វីដៃ ថ្វីគំនិតរបស់មនុស្សដែលរស់នៅ លើហេតុផលលើការងារ មិនមែនសម្រាលចេញពីម្រាមដៃនៃ វត្ថុស័ក្តិសិទ្ធិទាំងឡាយមានទេវតាជាដើម ដែលអ្នកផងធ្លាប់ដៅស្មានធ្លាប់ទុកដាក់ មកហើយនោះទេ ។ នេះគឺជាសេចក្តីពិត គ្រប់ជ្រុងគ្មាននរណាអាចបដិសេធបានឡើយ ។ ព្រោះអ្វី? ព្រោះរោងចក្រ ផលិតវត្ថុទាំងឡាយ ជារថយន្តក្តី អាកាសយានក្តី គ្រឿងប្រដាប់រថភ្លើងក្តី គ្រឿងប្រដាប់អគ្គិសនីក្តី ។ល។ គេឃើញមនុស្សអ្នកបង្កើត មនុស្សអ្នកចាត់ការឲ្យរោងចក្រដើរ ។ គេមិនដែលឃើញទេវតាអ្នកបង្កើត, អ្នកចាត់ការឲ្យរោងចក្រដើរដល់ម្តងណាឡើយ ។ ក្នុងរឿងព្រេង រឿងនិទានមានដំណាលថា ទេវតាចេះនិម្មិតប្រដាប់ប្រប្រាស់ ប្រដាប់រស់គ្រប់ បែបយ៉ាង តែភ្នែករបស់មនុស្សយើង មិនដែលបានឃើញវត្ថុនិម្មិតរបស់ទេវតាទេ ។ ពំនោលនេះ ពុំមែនជាពំនោលបង្អាប់មុខទេវតាទេ ។ ប៉ុន្តែពំនោលនេះ, ខ្ញុំធ្វើនៅក្នុងក្របខ័ណ្ឌនៃសេចក្តីពិតដើម្បីឆ្លើយតបនឹងសំណួរថា នរណាសាងរបស់ប្រើប្រាស់ក្នុងលោកប៉ុណ្ណោះ ។ ម៉្យាងវិញទៀតពំនោលនេះពុំមែនជាពំនោលគ្មានបង្អែក គ្មានអំណាងទេ ។ ពំនោលនេះខ្ញុំធ្វើឡើងផ្អែកលើពុទ្ធភាសិតថា ការងារតាក់តែង មនុស្សសត្វ (កម្មំ សត្តេ វិភជ្ជតិ) អន្លង់ទុក្ខគ្រប់យ៉ាងគេឆ្លងរួច ឬឆ្លងកាត់បានដោយព្យាយាមធ្វើការ (វីរិយេន ទុក្ខមច្ចេតិ) គ្មានកម្លាំងអ្វីមានឥទ្ធិពលស្មើកម្លាំងការងារទេ ។ ដូចនេះ, ទេវតាត្រឹមតែជាទេវតា មិនមែនជា ទីពំនឹងរបស់យើង មិនមែនជាវត្ថុផ្តល់អ្វីឲ្យយើងបានឡើយ ។ ប្រសិនបើទេវតាលោកជួយយើងបាន, ប្រហែលជាលោកជួយហើយ ព្រោះយើងបានធ្វើការអំពាវនាវបន់ស្រន់ សុំជំនួយអំពីលោក ស្ទើរបែកបាក់ធ្មេញអស់ទៅហើយ លទ្ធផលគឺសូន្យ ។ តែទោះជាយ៉ាងណាក៏ដោយចុះ សម្រាប់ខ្លួនយើងជាពុទ្ធសាសនិក ដែលព្រះពុទ្ធបរមគ្រូ របស់យើងបានបង្រៀនឲ្យយើងរស់នៅក្នុងព្រហ្មវិហារធម៌ យើងសូមឲ្យអស់លោកទេវតារស់នៅ ប្រកបដោយសេចក្តីសុខសប្បាយតាមឈ្មោះរបស់លោកថា «ទេវតា» ដែលមានអត្ថន័យថា អ្នកលេង, អ្នកសប្បាយ, អ្នកមានបញ្ចកាមគុណជាកីឡា ។ ចំណែកយើងមនុស្សជាតិត្រូវលាត់ជើងខោមូរដៃអាវធ្វើអាជីវកម្ម គ្រប់ប្រភេទ, មួយប្រភេទក្តី ច្រើនប្រភេទក្តី ស្រេចហើយនឹងជ្រើសរើសឲ្យស៊ីតាមសមត្ថភាពនិងកម្លាំងរបស់ខ្លួន ។ លុះរស់នៅបានស្រួលដោយអាស្រ័យកម្លាំងការងារ ក្នុងលោកនេះហើយកុំភ្លេចឆ្លៀតធ្វើបុណ្យទានខ្លះផង ព្រោះជីវិតសត្វលោកមិនទៀងទេ ។ ជាមួយគ្នានេះទៀតត្រូវចងចាំគ្រប់គ្នាថា អ្នកស្លាប់ត្រូវព្រាត់ប្រាសទ្រព្យសម្បត្តិយសស័ក្តិ ញាតិមិត្ត ទាំងអស់ជាធម្មតា ។ ប៉ុន្តែអ្នកស្លាប់មានបុណ្យដែលធ្វើដោយដៃរបស់ខ្លួន (សយំ កតានិ បុញ្ញានិ តំ មិត្តំ សម្បរាយិក) ជាទ្រព្យសម្បត្តិយសស័ក្តិញាតិមិត្តរបស់ខ្លួនក្នុងជីវិតថ្មី ។

**បទទី៤**

**ការលុបបំបាត់វណ្ណៈ**

**«ព្រះពុទ្ធសាសនា, ជាសាសនាដំបូង ដែលបានបង្រៀនឲ្យមនុស្ស បញ្ឈប់នូវទំនើជិះជាន់វណ្ណៈ ដោយសំអាងជាតិសាសនា និងអម្បូរវង្សត្រកូល ។ល។ ដែលគេបានបែងចែកនៅក្នុងលក្ខណៈផ្សេងៗគ្នា ប្រកបដោយកម្ពស់, ទំនាប, ទំហំ, តំណូច, តម្លៃ, តំហោក ។ល។ ព្រមគ្នានេះ បានបង្កើតឲ្យមានធាតុមួយ ដែលមានឈ្មោះថា «សីលធម៌» ធាតុសីលធម៌នេះគឺជាទិស, ជាទីកន្លែងសម្រាប់ណាត់ជួបគ្នារបស់មនុស្សទាំងឡាយ ។ នរណាកើតក្នុងត្រកូលទាបខ្ពស់មានក្រតូចធំ . . . . នៅក្នុងថ្នាក់ណា ជាន់ណា គេឈប់រវល់ឈប់ប្រកាន់រើសអើង គេបំបាត់ចោលនូវជំនឿខុសក្នុងចំណុចថា : មនុស្សត្រូវមានទាបខ្ពស់ធំតូច ថ្លៃថោក ដោយអាស្រ័យធាតុទាំងឡាយ មានអំបូរត្រកូលទ្រព្យសម្បត្តិយសស័ក្តិ ។ល។ ឬដោយអាស្រ័យការបង្កើត, សន្មតិតែងតាំងនិងបែងបែច ដែលមនុស្សនាំគ្នាធ្វើឡើង ប្រកបដោយគំនិតកម្លៅ, គំនិតជិះជាន់ ។ ដំណាលគ្នានេះ, គេសុខចិត្តនាំគ្នាមករស់នៅក្នុងសីលធម៌ ព្រោះគេមានគំហើញថា មានតែ សីលធម៌ទេ ដែលជាធាតុធ្វើនាទីវាយតម្លៃ, លើកតម្កើង, ឲ្យពិន្ទុល្អដល់មនុស្សលោក ។ ផ្ទុយទៅវិញ, បើមនុស្សមិនព្រមរស់នៅក្នុងសីលធម៌ទេ, ទោះណាជាខ្លួនកើតក្នុងត្រកូលខ្ពស់មានកម្រិតដល់ថ្នាក់ ជាអតិបរិមា តាមការកត់សម្គាល់របស់ខ្លួនក៏ដោយ ក៏នៅតែជាមនុស្សពាល, មនុស្សថោក គួរដល់ការ រិះគន់របស់អ្នកផងដដែល» ។**

មុននឹងស្តីដល់ធម្មៈខាងព្រះពុទ្ធសាសនា ដែលបង្រៀនឲ្យលើកចោលជាន់វណ្ណៈ ។ ខ្ញុំសូមនាំរឿងផ្សេងៗ ដែលមានក្នុង វណ្ណកម្មនៃពុទ្ធសាសនា មកសរសេរក្នុងទីនេះ ដើម្បីប្រកបការពិចារណារបស់អ្នកអាន ក្នុងពេលមានចម្ងល់កើតឡើង ។ នៅក្នុង ប្រទេសឥណ្ឌាសម័យបូរាណ, ការប្រកាន់ជាន់វណ្ណៈ បានប្រព្រឹត្តទៅ យ៉ាងខ្លាំងក្លាជាទីបំផុត ដែលអ្នកអានគួរដឹង, គួរធ្វើការ កត់សម្គាល់ នៅក្នុងក្របខ័ណ្ឌនៃមនុស្សជាតិ ។

រឿងទី ១, គឺរឿងជីវិតនៃជនចណ្ឌាល ដែលត្រូវគេជិះជាន់ប្រមាថមើលងាយ, ត្រូវគេប្រព្រឹត្តនៅទំនើបំពារបំពានលើរូបកាយយ៉ាងសាហាវ, ព្រោះហេតុត្រឹមតែចូលទៅបង្ហាញខ្លួន នៅចំពោះមុខជនជាន់ខ្ពស់តែក្រោយមកគេត្រូវការមិនស្រួលកើតឡើងក្នុងជីវិត ដូចជាមានយល់សប្តិមិនល្អរឿយៗ ព្រួយចិត្តច្រើនមិនដឹង មកពីរឿងអ្វី, នឹកស្រម័យខ្លួនឯង ឬមានហោរទស្សន៍ទាយឲ្យថា គ្រោះកាចនឹងកើតក្នុងថ្ងៃណាមួយ ។ គេក៏រៀប ពិធីសូត្រមន្តនៅក្នុងផ្ទះ ឬទៅវត្តនិមន្តព្រះសង្ឃស្រោចទឹកមន្តឲ្យ, លុះបានធ្វើពិធីកម្មនេះហើយ គេមានការ សប្បាយចិត្តច្រើន ។ ទំនើនេះ បើស្តីតាមរឿងចិត្តសាស្ត្រប្រាកដជាមានផលល្អច្រើនខាងផ្លូវចិត្តដែរ ។ ប្រសិនបើ អ្នកទទួលទឹកមន្តនោះមានជំនឿថា ទឹកមន្តជាធាតុមួយមានអានុភាពរំដោះគ្រោះកាចបាន ។

ក្នុងសាសនាព្រាហ្មណ៍គេមានជំនឿថា ទឹកទន្លេខ្លះមានភាពស័ក្តិសិទ្ធិ ។ ជាពិសេសទឹកទន្លេគង្គា គេចូលចិត្តថា ហូរមកអំពីឋានសួគ៌ ចាក់ស្រោចលើព្រះកេសព្រះអាទិទេពរបស់គេ មានព្រះនាម «**សិវៈ**» ពលានុភាពនៃព្រះកេសព្រះសេវៈ បានធ្វើឲ្យខ្សែទឹកហូរមកមានកម្លាំង (ព្រាហ្មណ៍) ទៅយកបុរសស្ត្រីក្នុងវណ្ណៈទាប ជាស្វាមីភរិយាពេលមានកូនគេទុកដាក់កូននោះជាចណ្ឌាល ជាទីស្អប់ខ្ពើមជិជាន់ ប្រមាថមើលងាយរបស់មនុស្សទាំងឡាយ ។ លើសនេះទៅទៀត គឺគេទុកដាក់ជាមនុស្សចង្រៃ អប្បលក្ខណ៍ ដល់ថ្នាក់រកអ្វីប្រៀបគ្មាន ។

ដោយហេតុថា ដែលខ្លួនកើតក្នុងត្រកូលចណ្ឌាល, ជាត្រកូលដែលសង្គមថ្នាក់ខ្ពស់ គេស្អប់ខ្ពើម, គេធ្វើបាបគ្មានលោះវេលា, ។ បុរសឈ្មោះ**មាតង្គៈ**ក៏ពុំអាចនឹងរកមធ្យោបាយឯណាដើម្បីរស់នៅកើតក្រៅពីដើរសូមទានគេ ។

គាប់ជួនថ្ងៃមួយ, មានពិធិបុណ្យជាផ្លូវរដ្ឋ, មានការស៊ីផឹករាំច្រៀងកម្សាន្តសប្បាយសម្រាប់វណ្ណៈខ្ពស់ ។ ពួកសេដ្ឋីកុដុម្ពិក៍សឹងមានរទេះផ្ទុកពេញ ដោយម្ហូបអាហារ នំចំណី សុរា ភេសជ្ជៈ . . . . ដើម្បីជប់លៀងគ្នានៅក្នុងគំនិតបម្រើសេចក្ដីសប្បាយរៀងៗខ្លួន ។

ក្នុងពេលនោះ, មានសេដ្ឋីធីតាម្នាក់ ឈ្មោះ**ទិដ្ឋមង្គលិកា**ជានារីរស់នៅក្នុងវណ្ណៈព្រាហ្មណ៍មហាសាល (ព្រាហ្មណ៍មហាសាលមានន័យថា ព្រាហ្មណ៍មានឋានៈជាសេដ្ឋី) នាងមានរូបល្អដាច់នារីទាំងឡាយ ក្នុងស្រុកភូមិរបស់នាង ។ **ទិដ្ឋមង្គលិកា**, មានវ័យពេញក្រមុំ ។ នារីឆើតឆាយនៃត្រកូលនេះ មួយអន្លើដោយស្ត្រីបម្រើច្រើនរយនាក់កំពុងធ្វើដំណើរទៅកាន់ទីនោះដោយក្បួនរទេះ ដែលផ្ទុកពេញដោយគ្រឿងឧបភោគបរិភោគ និងជនអ្នករទេះ ។ គេឃើញ**ទិដ្ឋមង្គលិកា**ជិសេះ តែម្នាក់ឯង នៅចំពាក់កណ្ដាលក្បួន ជាសញ្ញាបញ្ជាក់ឲ្យដឹងថា ខ្លួននាងត្រូវបានចោមរោមដោយបរិវារ មុខក្រោយឆ្វេងស្ដាំ ដើម្បីការពារសន្តិសុខជាធម្មតាផង, ដើម្បីដេញមនុស្សជាន់ទាបមិនឲ្យមាននៅក្នុងបរិវេណជិតខាងដែលនាងកំពុងឆ្លងកាត់នោះផង ។

**មាតង្គៈ**ជនដែលត្រូវមនុស្សក្នុងសង្គមថ្នាក់ខ្ពស់ គេឲ្យឈ្មោះ «ចណ្ឌាល» មានដៃកាន់ត្រដោកដែលគាត់ធ្វើដោយបំពង់ឫស្សីពីរកង់ សម្រាប់គោះធ្វើសព្ទសញ្ញាក្នុងពេលចូលទៅក្នុងទីប្រជុំជន ។ សំណូរនេះបានផល ពីរយ៉ាងគឺឲ្យដំណឹងដល់ជនមានព្រហ្មវិហារធម៌ដើម្បីធ្វើអំណោយផ្សេងៗ ដល់មនុស្សដែលកំពុងសុំទាន ។ ទន្ទឹមគ្នានេះ, ដើម្បីជាដំណឹងដល់ជនណា ដែលជាអ្នកមានសេចក្ដីស្អប់ខ្ពើមមនុស្សចណ្ឌាលយ៉ាងខ្លាំងក្លា, មិនចង់ឃើញមុខ, មិនចង់ចូលជិត, មិនចង់ទៅបៀត, ឲ្យប្រញាប់ជៀសចេញទៅ ។ ក្នុងន័យថា ប្រាប់អ្នកចិត្តល្អដើម្បី បំពេញបុណ្យ, ប្រាប់អ្នកចិត្តអាក្រក់ដើម្បីជៀសចេញឲ្យឆ្ងាយ ។ គឺកុំឲ្យមានសេចក្ដីរិះគន់ថា ចូលមកដល់ក៏គ្មានប្រាប់, ចេញទៅវិញក៏គ្មានឲ្យដឹង ។ តាមធម្មតាជនជាន់ទាប គ្មាមិនដែលហ៊ានចូលទៅជិតជនជាន់ខ្ពស់, មិនហ៊ានប៉ះពាល់រូបកាយឬចាប់កាន់វត្ថុផ្សេងៗ របស់ជនជាន់ខ្ពស់ទេ, គ្មាខំព្យាយាមគេចមុខចេញពីគេជានិច្ច ។

ក្នុងខណៈដែល**មាតង្គៈ**កំពុងគោះត្រដោកប៉ុកៗតាមដំណើររបស់ខ្លួន ក៏វាក់គ្នានឹងក្បួនរទេះសេដ្ឋីធីតាមកដល់ល្មមដែរ ។ នៅក្នុងក្បួនពាហនៈនេះ, ក្រៅពីពួកមនុស្សបម្រើធម្មតា មានតម្រួតរក្សាសន្តិសុខនិងបំពេញមុខងារដេញមនុស្សជាន់ទាបគ្រប់ទីកន្លែងដែល**ទិដ្ឋមង្គលិកា**ត្រូវធ្វើដំណើរឆ្លងកាត់ ឬត្រូវនៅស្នាក់អាស្រ័យ ។ សេដ្ឋីធីតា, ក្រោយពីបានចោលកន្ទុយភ្នែកឃើញហើយបានទទួលចម្លើយពីពួកបរិវារថា ជននេះជាមនុស្សរស់នៅក្នុងអម្បូរថោកទាប ។ នាងនឹកក្នុងចិត្តថា : នេះឯងគឺមនុស្សចណ្ឌាល, វាមានមុខអាក្រក់គួរឲ្យស្អប់ខ្ពើម, វាជាមនុស្សបង្កើតចង្រៃអពមង្គលដល់ភ្នែករបស់អញ, វាជាមនុស្សបង្ហូរចង្រៃសព្វបែបយ៉ាង ដល់ត្រកូលខ្ពស់នេះមនុស្សទាំងឡាយ រួមទាំងត្រកូលអាត្មាអញផង ។ ចង្រៃមែន ! ចម្រៃមែន ! ចង្រៃមែន ! ។ គ្មានសុភមង្គលទេ គ្មាន . . គ្មាន . . . ។

សេដ្ឋីធីតា, មិនត្រឹមតែជេរស្ដីត្មះតិះដៀលតាមផ្លូវគំនិតអមនុស្សធម៌ប៉ុណ្ណឹងទេ, ជាមួយគ្នានេះ នាងបានបញ្ជាឲ្យក្បួនរទេះវិលត្រឡប់ទៅកាន់គេហដ្ឋានវិញ ដោយលះបង់ចោលនូវដំណើរកម្សាន្តក្នុងពិធីបុណ្យរដ្ឋនោះទៅ ។ នៅក្នុងដំណើរត្រឡប់, នាងបានបង្គាប់ឲ្យស្រីបម្រើយកទឹកអប់មកលាងភ្នែកភ្លាម ដើម្បីបំបាត់ចង្រៃដែលកើតមាននោះកុំឲ្យឆ្លងដល់ទៅគ្រួសារនៅឯផ្ទះ ។

ដំណើរវិលត្រឡប់នៃសេដ្ឋីធីតា, វាជាហេតុមួយធ្វើឲ្យមហាជនខុសបំណង, អស់សេចក្ដីសង្ឃឹមព្រោះគេទាំងឡាយខានបានបរិភោគអាហារមានរសជាតិខ្ពស់, ខានបានផឹកសុរាមានតម្លៃច្រើន ដែលជាអំណោយរបស់នាង ។ មហាជនមានការធ្លាក់ទឹកចិត្ត, ព្រមគ្នានេះគេទាំងអស់បានធ្វើនូវការកត់សម្គាល់នូវពិធីបុណ្យនេះថាជាបុណ្យគ្មានន័យសម្រាប់ខ្លួនគេម្នាក់ៗ ។ គេទាំងឡាយមិនត្រឹមតែមានកំហឹងនឹងបុរស**មាតង្គៈ**ទទេៗ ប៉ុណ្ណឹង

ទេ ។ គេបានបន្ធូរនូវកំហឹងរបស់ខ្លួនដោយទំរើវាយតប់ទាត់ធាក់យ៉ាងខ្លាំងលុះត្រា **មាតង្គៈ** ដួលសន្លប់បាត់ស្មារតីក្នុងពេលនោះទៅ ។ ដោយគេនឹកស្មានថា គាត់ស្លាប់ហើយ គេក៏នាំ គ្នាអូសយកទៅកប់ចោលក្នុងគំនរសម្រាម ។

**មាតង្គៈ**ភ្ញាស្មារតីឡើងវិញ គាត់ក្រោកឈរពត់ដៃពត់ជើង ដើម្បីបំបាត់នូវសេចក្តីចុកចាប់ ហើយគាត់ខំគិតដល់ហេតុការណ៍ដែលកើតឡើងថ្មីៗនេះ ។ គាត់នៅចាំបានថា ខ្លួនគាត់បានត្រូវទទួលទារុណកម្ម ដោយទំរើរបស់ប្រជាជនព្រោះតែ គាត់បានដឹកនាំនូវរូបកាយរបស់ខ្លួនឲ្យមានភាពប្រាកដនៅចំពោះមុខសេដ្ឋីធីតា ។ **មាតង្គៈ** ក្រោយពីបានដឹងថា ខ្លួនជាដើមហេតុដើមផលនៃអំពើប្រទុស្តយង់ឃ្នង, ដោយមិនសមហេតុសមផល មិនត្រឹមត្រូវតាមគន្លងធម៌របស់មនុស្សជាតិ, គាត់ក៏សម្រេចថា នឹងឆ្លើយតបទៅវិញតាមមធ្យោបាយដែលគាត់មាន ។ ដើម្បីរកសំឡេងយុត្តិធម៌ឲ្យបានច្រើន,**មាតង្គៈ**មិនបណ្តែតបណ្តោយឲ្យខាតពេលទេ, គាត់បានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ដើម្បីធ្វើសេចក្តីបំភ្លឺមតិនិងសុំសេចក្តីយល់ឃើញពីប្រជាជន ជំពោះរឿងបង្កទំរើអាក្រក់ ដែលជនពួកមួយបានធ្វើមកលើរូបកាយរបស់គេ ។

តើទំរើនេះត្រូវចាត់ចូលក្នុងយុត្តិធម៌ ឬអយុត្តិធម៌ជាពិសេស, គាត់សួរថាទ្វារនគរនេះគេស្ថាបនាឡើងសម្រាប់ឲ្យតែមនុស្សមួយពួកចេញចូល ឬសម្រាប់ប្រជាពលរដ្ឋទាំងអស់ចេញចូល? ចំពោះសំណួរនេះ, ប្រជាពលរដ្ឋភាគច្រើនបានឲ្យចម្លើយដល់គាត់ថា : សម្រាប់ចេញចូលទាំងអស់គ្នា ។ លុះបានទទួលចម្លើយ ដូចនេះហើយ **មាតង្គៈ**បានធ្វើនូវសេចក្តីថ្លែងការណ៍ភ្លាមថា ខ្ញុំចូលមកសុំទានតាមទ្វារ ដែលគេស្ថាបនាសម្រាប់ មនុស្សទូទៅចេញចូល, តែខ្ញុំត្រូវគេវាយធ្វើបាប ដោយហេតុត្រឹមតែ សេដ្ឋីធីតាឃើញខ្ញុំហើយស្អប់ខ្ពើម ។ ខ្ញុំមិនសុខចិត្តទេ, ចាប់តាំងពីថ្ងៃនេះទៅ សូមមហាជនជ្រាបថា ខ្ញុំនឹងទៅដេកខាំងទ្វារផ្ទះមហាសេដ្ឋី អស់រយៈកាលគ្មានកំណត់, បើមិនបានសេដ្ឋីធីតាមកធ្វើភរិយារបស់ខ្ញុំ, ខ្ញុំនឹងមិនក្រោកចេញចាកទីនេះជាដាច់ខាត ។

ការដែល **មាតង្គៈ**សម្រេចចិត្តដូចនេះ ព្រោះមានប្រពៃណីថា : បើមនុស្សចណ្ឌាល ដេកត្រង់ទ្វារផ្ទះរបស់អ្នកណាដោយមានសេចក្តីប្តេជ្ញាចិត្តអត់បាយអត់ទឹកសម្លាប់ខ្លួនក្តីដោយធ្វើអត្តឃាតតាមមធ្យោបាយដទៃក្តី ជនដែលមានផ្ទះនៅក្នុងបរិវេណជុំវិញ រាប់ពីផ្ទះនោះទៅ ៧ ផ្ទះ នឹងត្រូវធ្លាក់ខ្លួនក្លាយទៅជាចណ្ឌាលទាំងអស់គ្នា ។ ទំរើរបស់ **មាតង្គៈ**នេះ បានធ្វើឲ្យអ្នករួមភូមិ ដែលរស់នៅជុំវិញមហាសេដ្ឋី មានសេចក្តីភិតភ័យលាយឡំដោយសេចក្តីក្តៅក្រហាយយ៉ាងខ្លាំង ។ កម្លាចនិងកម្លៅដែលមានកម្រឹតជាអតិបរមារបស់ប្រជាជន, គឺកើតឡើងព្រោះគ្រួសាររបស់មហាសេដ្ឋី ដែលជាដើមរឿងហ្នឹងតែម្តង ។

ក្នុងទីបំផុត, សេដ្ឋីក៏បានធ្វើសេចក្តីសម្រេចចិត្តទិញទំរើ **មាតង្គៈ**ដោយប្រាក់ គឺថាឲ្យតែគាត់សុខចិត្តលើកចោលនូវកម្មវិធីដេកខាំងទ្វារអត់អាហារ ដើម្បីសម្លាប់ខ្លួនរបស់គាត់ ។ សេដ្ឋីសុខចិត្តឲ្យប្រាក់តាំងពី មួយកហាបណៈ រហូតដល់សែនកហាបណៈ មួយអន្លើដោយប្រេងសម្រាប់លាបខ្លួន ឲ្យបានជាសេចក្តីចុកចាប់ ជាច្រើនទៀតផង ។ (ទំនៀមប្រើប្រេងលាបខ្លួន ប្រាណដៃជើងខ្ញុំមិនធ្លាប់បានឃើញក្នុងប្រទេសឥណ្ឌាទេ, ព្រោះមិន ធ្លាប់បានទៅ ។ តែសម័យបូរាណ ដូចជាកាលណាមានមនុស្សអាគន្តុកៈមករក, ប្រសិនបើមកអំពីទីឆ្ងាយៗ ម្ចាស់ផ្ទះច្រើនតែយកប្រេងមកជូនភ្ញៀវឲ្យលាបដៃជើងខ្លួនប្រាណ ។ សេចក្តីសន្និដ្ឋានរបស់ខ្ញុំ : ការប្រើប្រេងដែលគេទម្លាប់ធ្វើនេះ ប្រហែលមិនប្រើជាគ្រឿងសំអាងទេ, តែប្រើជាគ្រឿងកែស្រពន់ចុកចាប់ . . . ឬប្រើដើម្បីស្រួលខ្លួនប្រាណតាមការពិសោធឃើញរបស់គេជាទូទៅ ឬម្នាក់ៗ ។ របៀបនេះមិនមែនមានតែក្នុងសង្គមគ្រហស្ថទេ, ភិក្ខុក្នុងពុទ្ធសាសនា, កាលណាធ្វើដំណើរទៅកាន់ទីឆ្ងាយៗ ក៏មានប្រើប្រេងនេះដូចគ្នាដែរ) ។

**មាតង្គៈ**ទាត់ចោលនៅលើពាក្យមួយម៉ាត់ថា ត្រូវការសេដ្ឋីធីតាធ្វើភរិយា ។ ដើម្បីរក្សាទុកននូវកូនរបស់ខ្លួនមិនឲ្យធ្លាក់ចូលទៅក្នុងដៃមនុស្សដែលប្រពៃណីទុកដាក់ថាចង្រៃ ។ មហាសេដ្ឋីមិនមានមធ្យោបាយណា ដទៃទៀត

ក្រៅពីបង្កើនប្រាក់អំណោយបន្តិចម្តងៗ ជាមួយនឹងពាក្យអង្វរសូមទោស ដែលកូនរបស់ខ្លួនធ្វើលុះត្រា ដល់កម្រិតលែងទៅរួច ។ **មាតង្គៈ**នៅតែបដិសេធមិនទទួល, មិនបានបញ្ចប់សកម្មភាព ដែលបានគ្រោងទុក ក្នុងកម្មវិធី ។ គាត់គង់នៅក្នុងឥរិយាបថដេកស្ងៀមស្ងាត់ដដែល, ការផ្លាស់ប្តូរឥរិយាបថរបស់គាត់ សូម្បីមួយចំណិតក៏គ្មានអង្គីមានឡើយ ។ ពេលវេលាបានប្រព្រឹត្តកន្លងទៅដល់ ៤ ថ្ងៃហើយ, មនុស្សទាំងឡាយចេះតែនាំគ្នាមក ចោមរោមមើលកាន់តែច្រើនឡើងៗ, ពាក្យនិយាយរបស់មនុស្សមានសំណួរ កាន់តែវែងទៅៗ បង្កើតបានជាដំណឹងយ៉ាងធំធេងមានលក្ខណៈជារឿងស្លាប់រស់របស់សេដ្ឋីនិងគ្រួសារទាំងឡាយ ដែលរស់នៅជុំវិញសេដ្ឋី ។ ព្រោះអ្វី? ព្រោះបើ**មាតង្គៈ** ស្លាប់ក្នុងថ្ងៃណាមួយ មនុស្សក្នុងភូមិនៃបរិវេណទាំងអស់, ក៏នឹងក្លាយទៅជាមនុស្ស ចណ្ឌាល សឹងគេមានជំនឿថា ចណ្ឌាលវាជាធាតុនាំមកនូវភាពហាយនៈ សាបសូន្យធំបំផុតដល់ជីវិតរបស់គេតែម្តង ។

ក្នុងបណ្តាមនុស្សដែលកំពុងចោមរោមមើលនោះ, មានមនុស្សខ្លះជួយគាំទ្រ **មាតង្គៈ**ដោយបានធ្វើកាយវិការឱនខ្សិបលើកចិត្តថា អ្នកខំអត់ទ្រាំមកអស់រយៈកាលយូរហើយ ភាពសម្រេចរបស់អ្នកនៅពុំទាន់បាន, អ្នកខំអត់ធន់តទៅទៀតមិនយូរ ប៉ុន្មានទេ ពីរបីថ្ងៃខាងមុខអ្នកនឹងបានសេដ្ឋីធីតា យកមកធ្វើភរិយាហើយ ។

ប្រាំពីរថ្ងៃកន្លងទៅ, ប្រជាជនដែលនៅផ្ទះជិតខាងសុទ្ធសឹងតែត្រកូលព្រាហ្មណ៍មហាសាល (អ្នកមានធំ) បាននាំគ្នាទៅបង្គាប់សេដ្ឋីឲ្យលើកធីតារបស់ខ្លួនប្រគល់ឲ្យ**មាតង្គៈ**ដោយបានធ្វើសេចក្តីបញ្ជាក់ថា ការចចេស រឹងត្អឹងរបស់អ្នកវានាំឲ្យមាន វិបត្តិដល់ខ្លួនរបស់អ្នកផង ដល់គ្រួសារទាំងឡាយរបស់យើងគ្រប់គ្នាផង ។

សេដ្ឋីទាល់បញ្ញារកផ្លូវណាចេញមិនរួច ក៏សុខចិត្តប្រគល់ធីតានិងទ្រព្យសម្បត្តិយ៉ាងច្រើន ឲ្យបុរសឈ្មោះ **មាតង្គៈ**ជាមួយនឹងពាក្យថា : សូមអ្នកអញ្ជើញចេញចាកទីនេះទៅនៅក្នុងទីដទៃ ឲ្យបានប្រកបដោយសេចក្តីសុខចម្រើនចុះ ។

នេះគឺជាជោគជ័យធំបំផុត, ដែល**មាតង្គៈ**ជនចណ្ឌាលបានសម្រេចលើវណ្ណៈជាន់ខ្ពស់ (ព្រាហ្មណ៍មហាសាល) គឺបានសេដ្ឋីធីតាធ្វើជាភរិយា ។ ចំពោះរឿង**មាតង្គៈ**នេះ, ខ្ញុំមានជំនឿថា វាជាធាតុមួយធ្វើ ឲ្យអ្នកអានទាំងឡាយបានឃើញភាពរឹករវ ច្របូលច្របល់ក្នុងសង្គមមនុស្សសម័យនោះ ព្រោះរឿងប្រកាន់វណ្ណៈបានយ៉ាងច្បាស់លាស់ជាមិនខាន ។

រឿងទី ២, កើតមានឡើងដល់ព្រះពុទ្ធបរមគ្រូរបស់យើងតែម្តង គឺថ្ងៃមួយក្នុងរដូវទឹកកកធ្លាក់ (រដូវត្រជាក់) ព្រះសម្មាសម្ពុទ្ធ ព្រះអង្គដណ្តប់សំពត់គ្របព្រះកេសគង់ក្រោមដើមឈើមួយ ។ ពេលនោះព្រាហ្មណ៍ម្នាក់ឈ្មោះ **សុន្ទរិកៈ**, ភារទ្វាជៈដើរចូលទៅជិត ។ ព្រះអង្គឮស្នូរសំឡេងជើងទើបបើកសំពត់គម្របព្រះកេស ។ ព្រាហ្មណ៍សួរថា អ្នកមានជាតិជាអ្វី? កើតក្នុងត្រកូលណា? រស់នៅក្នុងវណ្ណៈណា? ព្រះសម្ពុទ្ធមានព្រះតម្រាស់ថា «អ្នកកុំសួរយើងដល់ជាតិឡើយ . . . . . ចូលសួរ យើងដល់ទំរើនិងការប្រព្រឹត្តវិញល្អជាង» ចំពោះសំណួរនេះ, ប្រសិនបើព្រះអង្គត្រូវការឆ្លើយ អាចឆ្លើយបានយ៉ាងធូរ គ្មានបារម្ភក្រែងគេមើលងាយទេ ព្រោះព្រះអង្គខាងជាតិជាស្តេចស្រាប់ទៅហើយ ។ តែម៉្យាងដើម្បីនឹងដាស់តឿនស្មារតីព្រាហ្មណ៍ ឲ្យឃើញថា ទមវើរបសមនុស្សជាធាតុមានតម្លៃជាងជាតិត្រកូល ទើបព្រះអង្គធ្វើសេចក្តីបំភ្លឺដូចនេះទៅវិញ ។

រឿងទី ៣, មានប្រធានដូចរឿងទី ២ ដែរ ដំណើរសេចក្តី មានពោលដល់ភាពធំដុំក្នុងវណ្ណៈរបស់មាណពម្នាក់ឈ្មោះ **អម្ពដ្ឋៈ**បានទៅសួរព្រះសម្ពុទ្ធពីរឿងវណ្ណៈ ។ ព្រះសម្មាសម្ពុទ្ធដោយអាស្រ័យសេចក្តីចេះដឹងតាមផ្លូវប្រវត្តិសាស្ត្រ, ព្រះអង្គឆ្លើយសំណួររបស់មាណពជាមួយនឹងសេចក្តីបំភ្លឺឲ្យឃើញថា ពីដើមមកត្រកូល របស់មាណពនោះ ជាមនុស្សបម្រើរបស់ពួកសក្យៈ ។ ក្នុងចំណុចដទៃទៀត, ដែលមាណពនោះមានជំនឿថា ខ្លួនគេកើតក្នុងត្រកូលព្រាហ្មណ៍ ទើបគេត្រូវមើលងាយមនុស្សដែលកើតក្នុងត្រកូលដទៃៗបាននោះ ។ ព្រះសម្មាសម្ពុទ្ធព្រះអង្គបាន

ធ្វើការពិសោធន៍ ឲ្យគេឃើញប្រកបដោយហេតុផលថា បើគេគិតដល់ ខ្សែស្រឡាយ ទាំងខាងមាតាទាំងខាងបិតា ចរិយាប្រពៃណីក៏នៅតែប្រកាន់យកថាស្តេចខ្ពស់ជាង ។ តែបើគេមិនគិតយក ខ្សែស្រឡាយជាធំជាមូលដ្ឋាន គឺមាន ខ្សែស្រឡាយផ្សេងគ្នា ដូចជាខត្តិយកុមារទៅយកស្ត្រីក្នុងត្រកូលព្រាហ្មណ៍ ជាភរិយាកើតកូនមក, កូននោះរមែងត្រូវ បានកន្លែងអង្គុយ, កន្លែងផឹកស៊ីនៅក្នុងពួកព្រាហ្មណ៍ ឬមានវណ្ណៈជាព្រាហ្មណ៍ប៉ុណ្ណឹងឯង, ពុំអាចនឹងអភិសេកទៅជា ស្តេចបានទេ ព្រោះមិនមានសេចក្តីបរិសុទ្ធខាងមាតា ។ ព្រាហ្មណ៍កុមារ, បានស្ត្រីក្នុងត្រកូលស្តេចជាភរិយា មានបុត្រកើតមកនោះមានឋានៈគ្រប់យ៉ាងជាព្រាហ្មណ៍ ។ គេពុំអាចនឹងអភិសេកជាស្តេចបានទេ ព្រោះមិនមាន សេចក្តីបរិសុទ្ធខាងបិតា ។ សរុបសេចក្តីថា បុត្រដែលកើតពី ឪពុកម្តាយមានវណ្ណៈផ្សំគ្នា រវាងស្តេចនិងព្រាហ្មណ៍ នោះ រស់នៅជាព្រាហ្មណ៍បាន តែរស់នៅជាស្តេចមិនបាន ។ បន្ទាប់មកទៀត ព្រះសម្មាសម្ពុទ្ធ ព្រះអង្គតាំងសំណួរឲ្យ មាណពឆ្លើយ មានសេចក្តីថា ព្រាហ្មណ៍ដែលត្រូវគេបណ្តេញចេញពីពួកព្រាហ្មណ៍ មានសក់ជាសញ្ញាសម្រាប់ សម្គាល់ត្រូវគេកោរអស់ហើយ តើត្រូវរួមទីដេក ទីអង្គុយនិងតុបាយជាមួយពួកព្រាហ្មណ៍បានឬទេ? **អម្ពដ្ឋៈ** ថ្វាយ ចម្លើយថា បាន ។ ព្រះសម្មាសម្ពុទ្ធ, ព្រះអង្គបានបន្តសំណួរថា ស្តេចដែលត្រូវគេបំបរបង់ពីពួកស្តេចមានសក់ ជាសញ្ញាសម្រាប់សម្គាល់ ត្រូវគេកោរអស់ហើយ តើត្រូវរួមទីដេកទីអង្គុយនិងតុបាយបានឬទេ? **អម្ពដ្ឋៈ**ឆ្លើយថា បានខ្លះដែរ, ព្រោះប្រពៃណីស្តេចមិនសូវប្រកាន់ តឹងតែងដូចវណ្ណៈទាំងឡាយដទៃទេ ។ ព្រះសម្មាសម្ពុទ្ធ កាលបើ បានពន្យល់ពីហេតុផលរបស់វណ្ណៈឲ្យមាណពស្តាប់, លុះត្រាមានសេចក្តីពេញចិត្តរលាយទិដ្ឋិមានៈអស់ច្រើន ហើយ ។ ព្រះអង្គក៏ផ្លាស់ពំនោល គឺសម្តែងពីវិជ្ជាសេចក្តីដឹង និងចារណៈសេចក្តីប្រព្រឹត្តប្រតិបត្តិ ដែលជាធាតុ សម្រាប់ធ្វើឲ្យ បុគ្គលមានកម្ពស់ទាំងគុណភាពទាំងសមត្ថភាព នៅក្នុងកម្រឹតជាអតិបរមា ដោយមិនចាំបាច់ត្រូវខ្វាច ត្រូវព្រួយបារម្ភដល់សេចក្តី រាយមាយទន់ខ្សោយក្នុងកិច្ច វត្តរបស់វណ្ណៈទាំងឡាយ ។ ប្រែថា ព្រះអង្គទាត់ចោលនូវ ការបែងចែកវណ្ណៈ និងភាពប្រកាន់, ភាពយល់ច្រឡំថា មនុស្សមានកម្ពស់និងទំនាបដោយអាស្រ័យវណ្ណៈ ។ សេចក្តី ក្នុងសូត្រនេះ, សឹងមានន័យត្រូវគ្នានិងសុភាសិត មួយបទជាភាសាបាលីថា :

**«ខត្តិយោ សេដ្ឋោ ជនេតស្មឹ យេ គោត្តប្បដិ សារិនោ វិជ្ជាចរណសម្បន្នោ សោ សេដ្ឋោ ទេវ មានុសេ»**

«ក្នុងបណ្តាជនដែលមានសេចក្តីក្តៅក្រហាយព្រោះប្រកាន់គោត្ត, (លោកថា) មានក្សត្រជាបុគ្គលប្រសើរ បំផុត, តែជនដែលសម្បូរដោយសេចក្តីដឹង និងសេចក្តីប្រព្រឹត្តប្រតិបត្តិត្រឹមត្រូវ (លោកថា) ជាបុគ្គលប្រសើរបំផុត ក្នុងពិភពលោកមនុស្សនិង ទេវតា» ។

សុភាសិតនេះបង្ហាញឲ្យឃើញថា : បើតាមប្រពៃណីប្រកាន់វណ្ណៈ, ពួកស្តេចជាបុគ្គលមានកម្ពស់ជាងគេ, តែបើតាមសេចក្តីពិត (សច្ចធម៌) មនុស្សដែលមានសេចក្តីចេះដឹងច្រើន, មានការប្រព្រឹត្តប្រតិបត្តិត្រឹមត្រូវជា មនុស្ស មានកម្ពស់ដល់ថ្នាក់ ទីបំផុតក្នុងសកលពិភព ។

រឿងទី ៤, ជារឿងរបស់ពួកសក្យៈ ជាញាតិរបស់ព្រះសម្មាសម្ពុទ្ធ ។ អ្នកស្រាជ្រាវខាងប្រវត្តិសាស្ត្របាន ចាត់ទុករឿងនេះថា ជាធាតុអាក្រក់ បណ្តាលឲ្យមនុស្សស្លាប់យ៉ាងច្រើន ព្រោះតែហេតុដែលមនុស្សយើងនាំគ្នា បង្កើតវណ្ណៈ ហើយនាំគ្នាប្រកាន់វណ្ណៈ ជ្រុលហួសពេក ។

ដំណើរសេចក្តីមានមកថា ស្តេចបសេនទិគ្រប់គ្រងរដ្ឋកោសល មានអាណាខេត្តរហូតដល់រដ្ឋកាសី និងរដ្ឋ សក្កៈផង ។ សក្កៈដែលមានរាជធានីឈ្មោះកបិលពស្តុនោះ ក៏នៅក្រោមអំណាចរបស់កោសលដែរ, តែតាមដែល មានចែងក្នុងវណ្ណកម្មបាលី មិនឃើញថា ក្សត្រកបិលពស្តុឡើងសួយសារអាករទៅរដ្ឋកោសលទេ ។

ស្តេចបសេនទិ, មិនត្រឹមតែមានសេចក្តីជ្រះថ្លាចំពោះ អង្គព្រះសម្មាសម្ពុទ្ធប៉ុណ្ណឹងទេ រាជាថែមទាំងមាន

សេចក្តីវិសាសៈ ស្និទ្ធស្នាលជិតដិតនៅក្នុងគំនិតខ្ពស់ទៀតផង ។ រាល់តែពេលដែលស្តេចយាងទៅក្រាបបង្គំគាល់មហារាជតែងតែឱបព្រះបាទ ព្រះសម្មាសម្ពុទ្ធបញ្ជាក់នូវសេចក្តីរាប់អានយ៉ាងខ្ពស់របស់ខ្លួន ។ ដើម្បីចំណងមេត្រីភាពរបស់ខ្លួនឲ្យកាន់តែមានភាពប្រសើរឡើងទៀត, រាជាបសេនទិបានបញ្ជូនទូតទៅកាន់កបិលពស្តុស្នើសុំម្ចាស់ក្សត្រិយមួយអង្គក្នុងវង្សសក្យៈ មកអភិសេកធ្វើមហេសីដើម្បីធ្វើវង្សពីរឲ្យរលាយចូលគ្នាជាវង្សមួយស្រេចតែម្តង ។ អ្នកស្រាជ្រាវ, បានធ្វើសេចក្តីបញ្ជាក់ថា : តាមប្រពៃណីតណ្ហាបូរាណការមានមហេសីច្រើន គ្មានចោទជាបញ្ហាអ្វីទេ ព្រោះរឿងនេះវាក្លាយទៅជាធាតុធម្មតារបស់គេទៅហើយ ។

ខាងក្រុងកបិលពស្តុ, ក្សត្រសក្យវង្សដែលធ្លាប់តែល្បីឈ្មោះ ខាងប្រកាន់អំបូរត្រកូលយ៉ាងខ្លាំងក្លាក៏បានកោះប្រជុំភ្លាម ។ អង្គប្រជុំក្រោយពីបានជជែកយ៉ាងវែង ក្នុងបរិយាកាសដ៏សែនអាប់អួរនោះមក បានធ្វើសេចក្តីសម្រេចចិត្តមិនឲ្យធីតាក្នុងវង្សសក្យៈ, តែដោយមានសេចក្តីព្រួយបារម្ភ ក្រែងមានរឿងធំរហូតដល់បង្ហូរឈាមរវាងកោសលនិងកបិលពស្តុនោះ សក្យៈមហានាមបានស្នើអង្គប្រជុំថា : ខ្ញុំបានយកស្ត្រីបម្រើម្នាក់មកធ្វើជាភរិយាបានមានបុត្តនិងភរិយានោះម្នាក់ឈ្មោះវាសភខត្តិយា ។ បើអង្គប្រជុំមិនយល់ទាស់ទេ, ខ្ញុំយល់ថាយើងត្រូវចាត់ការបញ្ជូនធីតានោះទៅឲ្យកោសលតាមពាក្យស្នើសុំរបស់គេជាការស្រេច ។ យើងធ្វើដូចនេះ រឿងរវាងកោសល និងកបិលពស្តុក៏គ្មាន, សក្យវង្សក៏មិនខូច, សាមគ្គីធម៌រវាងយើងនិងគេប្រាកដជាមាននៅដូចធម្មតា ។ ពេលនោះអង្គប្រជុំបានសម្រេចយល់ព្រមតាម គំហើញរបស់សក្យៈមហានាមដោយមតិជាឯកច្ឆន្ទ ។ បន្ទាប់មក, គេបានចាត់ បញ្ជូននាងវាសភខត្តិយាទៅឲ្យកោសល, ជាមួយនិងសារលិខិតមួយច្បាប់បញ្ជាក់ថា ព្រះអង្គម្ចាស់ក្សត្រិយ មានព្រះនាមវាសភខត្តិយា ជាព្រះរាជធីតារបស់មហានាមសក្យៈ ។

នាងវាសភខត្តិយា, បានមានឱរសជាមួយនិងរាជាបសេនទិមួយអង្គ ឈ្មោះវិឌូឌភៈ ។ រាជកុមារមានវ័យគួរដល់ការសិក្សា, រាជាបសេនទិបានទំនុកបម្រុងឲ្យរៀនសិល្បវិជ្ជាការផ្សេងៗ ។ ព្រមគ្នានេះ, រាជបិតាបានតែងតាំងរាជបុត្តឲ្យរស់នៅក្នុងតំណែងជាអគ្គមហាសេនាបតីនៃរដ្ឋកោសល ។ ថ្ងៃមួយ, វិឌូឌភៈ មានប្រាថ្នាចង់ទៅជួបញាតិខាងមាតា, បាននាំបំណងនេះស្នើសុំអនុញ្ញាតពីមាតារបស់ខ្លួន ។ វាសភខត្តិយា, ក្រោយពីបានអនុញ្ញាតហើយនាងបានលបបញ្ជូនដំណឹងទៅកបិលពស្តុដើម្បីជ្រាបជាព័ត៌មានមុន ។ តាមធម្មតា, ការឲ្យដំណឹងមុន, វាមិនមែនជាធាតុចម្លែកទេ ព្រោះប្រពៃណីធ្លាប់មានជានិច្ចមកហើយ សម្រាប់អ្នកធំ តែទំរើរបស់វាសភខត្តិយាក្នុងរឿងនេះ ប្រហែលជាមានធាតុអ្វីជាអាថ៌កំបាំងខ្លះមិនខានឡើយ ។ ដូចនេះព្រោះអ្វី? ព្រោះក្នុងក្រសែភ្នែករបស់រាជវង្សសក្យៈខាងក្រុងកបិលពស្តុ, វិឌូឌភៈអគ្គមហាសេនាបតី, គេទុកជាមនុស្សជាន់ទាប មិនគួររួមទីអង្គុយ មិនគួររួមទីដំណេក, ជាពិសេសគឺមិនគួររួមតុបាយ ជាមួយនិងសក្យៈបានទេ ។ ប្រហែលជារឿងនេះទេដឹង ! បានជានាង លបឲ្យដំណឹងមុនដើម្បីកុំឲ្យពួកសក្យៈដាក់កំហុសដល់នាង ក្នុងពេលដែលមានរឿងមិនស្រួលកើតឡើង ។

ការប្រជុំជាបន្ទាន់, ត្រូវបានគេបើកម្តងទៀតក្នុងក្រុងកបិលពស្តុ ដើម្បីចាត់ការទទួលវិឌូឌភៈ ឬដើម្បីស្រាយបញ្ហាដែលគេមិនសប្បាយចិត្ត ។ ពេលបើកប្រជុំភ្លាម, គេបានជជែកដេញដោលគ្នា ដល់កំហុសដែលបាន ប្រព្រឹត្តកន្លងទៅ, ដោយទាំងអស់គ្នាចង់ប្រានចោលនូវសេចក្តីសម្រេចរបស់ខ្លួនព្រោះសំអាងថា ការឲ្យវាសភខត្តិយាទៅធ្វើជាអគ្គមហេសីបសេនទិទោះណាជាបាន មតិជាឯកច្ឆន្ទក៏ដោយ ក៏វាពុំមែនឯកច្ឆន្ទដោយសេរីទេ ។ គឺឯកច្ឆន្ទដោយអាស្រ័យគេដឹកនាំ គេថាធ្វើយ៉ាងនេះបានផលល្អ ។ ឥឡូវនេះ, មានបានទទួលផលល្អឯណាវាប្រែជាបានកំហុសមួយយ៉ាងធំដែលត្រកូលសក្យៈមិនធ្លាប់បានជួបប្រទះ ។ យើងធ្លាប់រស់នៅស្រួលក្នុងត្រកូលសក្យៈដូចគ្នាព្រោះត្រកូលនោះមានវណ្ណៈខ្ពស់ជាងគេ ។ ប្រពៃណីអាពាហ៍ពិពាហ៍របស់យើង ធ្លាប់ធ្វើក្នុង វង្សសក្យៈគ្នាឯង ឬវង្សកោលិយៈដែលមានកម្ពស់និងតម្លៃស្មើគ្នា ។ ដូចនេះកោសល, សុំសក្យៈកញ្ញាទៅធ្វើអគ្គមហេសី បើយើងមិនឲ្យវា

អាចចប់ត្រឹមហ្នឹង ព្រោះយើងមិនធ្លាប់ចេញពីវង្សខ្ពស់ ទៅរស់នៅជាមួយវង្សទាប នេះគឺជាការត្រឹមត្រូវ តាមប្រពៃណីរបស់យើង តែការឲ្យវាសភខត្តិយាជំនួសសក្យធីតា គឺជាកំហុសមួយដែលយើងត្រូវតែទទួលខានមិនបាន ទោះជាដោយចេតនាក្តី អចេតនាក្តី ។ ព្រោះអ្វី? ព្រោះទំរើវនេះវាជាធាតុបោកគេមែនៗ មានកម្រិតដល់ មួយរយភាគរយតែម្តង ។ ក្នុងទីបំផុត, អង្គប្រជុំសម្រេចឲ្យយុវសក្យៈ ដែលមានអាយុតិចជាងវិឌូឌភៈចេញក្រៅនគរ ហើយឲ្យសក្យៈមានអាយុច្រើនៗទៅទទួល ដើម្បីកុំឲ្យអាប់កិត្តិយសសក្យវង្ស ដោយទំរើវន្ទនកិច្ចដែលជនមានអាយុតិចត្រូវធ្វើដល់ជនមានអាយុច្រើន ។ នេះគឺជាកំហុសមួយថ្មីទៀត ដែលពួកសក្យវង្សប្រកាន់វណ្ណៈជ្រុលហួសពេកបានព្រមព្រៀងគ្នាធ្វើក្នុងគ្រាប្រជុំលើកទី ២ ។

ក្នុងពេលមកដល់, វិឌូឌភៈបានជួបតែនិងសក្យៈមានអាយុច្រើនជាងខ្លួន ដែលមានអាយុតិចជាងខ្លួនសម្បីតែម្នាក់ក៏គ្មាន ។ វិឌូឌភៈខំក្រាបថ្វាយបង្គំសក្យៈចាស់ៗតាំងពីព្រឹករហូតដល់ថ្ងៃត្រង់ហាត់ស្ទើរដាច់ខ្យល់ស្លាប់ទម្រាំតែគ្រប់គ្នា ។ ដំណើររបស់វិឌូឌភៈ, ដើម្បីជួបប្រាស្រ័យញាតិជាផ្លូវមិត្តភាពក្នុងពេលនោះ គ្មានសារប្រយោជន៍អ្វីបន្តិចបន្តួចទេ ព្រោះគេទទួលយុវអគ្គមហាសេនាបតីនៃរដ្ឋកោសល ប្រកបដោយទឹកមុខស្ងួត, ឥរិយាបទគ្រប់យ៉ាងរបស់គេនៅក្នុងភាពព្រងើយកន្តើយ, ការសន្ទនាប្រាស្រ័យធ្វើឡើងដោយសោះអង្គើយ ។ គឺគេទទួលដោយស្អប់ខ្ពើមដោយទើសទាល់ពុំមែនដោយមេត្រីរាប់អាន អាឡោះអាល័យឡើយ ។ វិឌូឌភៈ, ក្រោយពីបានអានចរិយារបស់គេរួចគ្រប់ចំណុចទាំងអស់ហើយ, ក៏ក្រាបសំពះលាគេទៅកាន់ កោសលរដ្ឋវិញ ដោយជាប់ជាមួយនិងវិញ្ញាណរបស់ខ្លួននូវកំហឹងមួយដែលខ្លួនពុំអាចនឹងរម្លាយបាន ។

គ្រាន់តែវិឌូឌភៈចុះផុតភ្លាម, សក្យៈទាំងឡាយកែនបាវព្រាវរបស់ខ្លួនឲ្យយកសំពត់ជ្រលក់ទឹកជូតក្តារត្រង់កន្លែងអង្គុយរបស់វិឌូឌភៈ, ជាបង្កើយឲ្យយកទឹកដោះសុទ្ធ លាងជម្រះដើម្បីបំបាត់ចង្រៃអពមង្គលដែលប្រពៃណីគេនិយមថា កើតមានពីជនដែលរស់នៅក្នុងវណ្ណៈទាប ។ ក្នុងពេលកំពុងលាងជម្រះ, ពួកទាសីទាំងឡាយបានប្រើពាក្យជេរប្រទេចត្មះតិះដៀលថា អាកូនខ្ញុំគេមិនគួរមកក្នុងទីនេះនាំឲ្យយើងលំបាកសោះ ។

បុរសបម្រើវិឌូឌភៈម្នាក់ បានវិលត្រឡប់ទៅកាន់ទីនោះវិញដើម្បីយករបស់ដែលខ្លួនគេភ្លេច ។ លុះបានឮពាក្យដំនៀលនេះគេក៏ទៅប្រាប់ ។ វិឌូឌភៈបានឮហើយមានកំហឹងយ៉ាងខ្លាំងរហូតដល់ឧទានចេញមកថា បើបានធ្វើស្តេចផែនដីវេលាណា នឹងលើកទ័ពទៅវាយសម្លាប់សក្យៈឲ្យអស់ ។ ជាមួយគ្នានេះ, យកខ្សែចងកវា ចាក់បង្ហូរឈាមយកទៅលាងបន្ទះក្តារដែលអញ អង្គុយ ហើយត្រូវគេលាងដោយទឹកដោះសុទ្ធ លុះត្រាតែបាន ។

មិនយូរប៉ុន្មាន, វិឌូឌភៈបានធ្វើស្តេចមែន, ការលើកទ័ពក៏បានធ្វើដូចពាក្យថា ។ តែពេលនោះជួនជាព្រះសម្មាសម្ពុទ្ធ ព្រះអង្គគង់សម្រាកឥរិយាបថនៅកណ្តាលផ្លូវ ក្នុងព្រះគំនិតចង់ធ្វើអន្តរាគមន៍ ។ វិឌូឌភៈលើកទ័ពទៅ ៣ ដង បានជួបនឹងអន្តរាគមន៍របស់ព្រះសម្មាសម្ពុទ្ធទាំង ៣ ដង ។ រាល់តែដង, រាជាកោសលលើកទ័ពត្រឡប់វិញ, ដោយគោរពព្រះពុទ្ធបរមគ្រូ ។ ក្នុងគ្រាទី ៤, ព្រះបរមសាស្តាចារ្យរបស់យើង ព្រះអង្គព្រះអង្គពុំបានទៅកាន់ទីនោះ (ផ្លូវដើរទ័ព) ព្រោះមាព្រះគំហើញថា នេះជាកម្មរបស់សត្វលោក, គ្មាននរណាអាចជួយដោះស្រាយជំនួសបានឡើយ ។ កោសលរាជា, លើកទ័ពចូលទៅវាយលុកកបិលពស្តុ ចាប់ពួកសក្យៈអារកច្របាច់យកឈាមលាងបន្ទះក្តារសងគំនុំបានដូចសេចក្តីប្រាថ្នាក្នុងពេលនោះទៅ ។

គុណវិបត្តិនៃការប្រកាន់វណ្ណៈ ដែលកើតមានដល់សក្យៈ បានក្លាយជាកម្មវត្ថុ គឺជាហេតុដែលមនុស្សទាំងឡាយចាប់គំនិតយ៉ាងខ្លាំង ។ អ្នកស្រាជ្រាវមានគំហើញក្នុងរឿងនេះថា ប្រសិនបើរាជាសក្យវង្ស មានជំនឿក្នុងគោលធម៌របស់ព្រះសម្មាសម្ពុទ្ធ, ហើយកាត់បន្ថយនេះទិដ្ឋិមានះរបស់ខ្លួនបន្តិចម្តងៗ, គេមុខជាមិនទទួលគ្រោះកាចដល់ថ្នាក់ធំសម្បើម យ៉ាងនេះទេ ។

ដើម្បីសេចក្តីច្បាស់លាស់របស់រឿងខ្ញុំសូមធ្វើសេចក្តីបំភ្លឺបន្តិច, ដើម្បីងាយស្រួលដល់គំនិតរបស់អ្នកអាន ។ តាមវណ្ណកម្មខាងពុទ្ធសាសនាថា : មនុស្សមានវណ្ណៈខុសគ្នានេះ រមែងមានសេចក្តីដឹងពិសេសក្នុងរឿងវណ្ណៈរបស់ខ្លួន ។ ហើយធាតុដែលត្រូវគេបិទបាំងជាសេចក្តីសម្ងាត់ គឺវង្សត្រកូលហ្នឹងតែម្តង ដូចជាកើតក្នុងត្រកូលស្តេចកាលណាធ្លាក់ខ្លួនទៅនៅក្នុងទីណាក៏ដោយ ប្រសិនបើគេចង់សម្តែងខ្លួនថាជាស្តេច, គេប្រើចំណេះដែលហៅថា ខត្តិយមាយា គឺកាលណាគេនិយាយគ្នារវាងស្តេចនិងស្តេចគ្នាគេ, គេចេះស្តាប់គ្នាបានទាំងអស់ ។ មនុស្សកើតក្នុងត្រកូលចណ្ឌាលក្លែងខ្លួនធ្វើជាព្រាហ្មណ៍រៀនសិល្ប៍ វិជ្ជានានាជាមួយនិងពួកសិស្សជាព្រាហ្មណ៍, មានពេលខ្លះភ្លេចខ្លួននិយាយភាសាពិសេសរបស់មនុស្សចណ្ឌាលនោះទៅ ។ កាយវិការនេះ, ធ្វើឲ្យអ្នកសិក្សាទូទៅស្តាប់មិនបានកើតសេចក្តីឆ្ងល់សង្ស័យ ធ្វើសំណួរដេញដោលហើយចាប់បានវណ្ណៈ ក្លែងក្លាយបន្លំនោះទៅក៏មាន ។

## **គោលធម៌ដែលបង្រៀនឲ្យលុបវណ្ណៈចោល**

១- ក្នុងសុន្ទរិកសូត្រ, ព្រះសម្ពុទ្ធត្រាស់តបសំណួរសុន្ទរិកភារទ្វាជៈដែលបានសួរព្រះអង្គថា មានជាតិជាអ្វី? ព្រះអង្គឆ្លើយថា កុំសួរដល់ជាតិធ្វើអ្វី ចូរសួរដល់សេចក្តីប្រព្រឹត្តប្រតិបត្តិវិញល្អជាង ដូចបានពោលមកហើយ ក្នុងខាងដើមនោះ ។ បន្ទាប់ពីព្រះចម្លើយនេះ, ព្រះអង្គបានសម្តែងធម្មៈមានហេតុផលប្រកបចូលសឹងមានអត្ថន័យថា :

«**ភ្លើងកើតពីឈើ (គ្រប់បែប) អ្នកចេះដឹងសូម្បីកើតក្នុងត្រកូលទាប, តែជាអ្នកមានសេចក្តីព្យាយាមខ្លាំងក្លា ជាអ្នកការពារនូវទំនើងអាក្រក់ដោយធាតុអៀនខ្មាស ជាអ្នកនិយាយតែពាក្យពិត ជាអ្នកហ្វឹកហាត់ខ្លួនឲ្យរស់នៅក្នុងផ្លូវនៃចរិយាល្អ គេក៏ទៅជាបុរសអាជានេយ្យ (បុរសខ្ពង់ខ្ពស់) បាន**» ។

២- ក្នុងសីលវិមង្សាជាតក, មានឲ្យធម្មៈជាគោលគំនិត សម្រាប់ប្រៀបធៀបសីលនិងវណ្ណៈ ដោយលើកយកភាសិត របស់ព្រាហ្មណ៍ម្នាក់មានន័យថា :

«**យើងមានចម្ងល់ថា : សីល (ការប្រព្រឹត្តកាយវាចាឲ្យមានរបៀបរៀបរយ) សុត្ត : (សេចក្តីចេះដឹងដែលកើតពីការរៀន, ការស្តាប់) ធាតុទាំងពីរនេះ មួយណាមានកម្ពស់ជាងមួយណា ។ ក្រោយពី យើងបានត្រិះរិះពិចារណាយ៉ាងយូរមក, យើងបានបាត់ឆ្ងល់ ដោយយើងមានគំហើញថា សីលមានកម្ពស់ ជាងសុត្តៈ**»

«**ជាតិនិងវណ្ណៈ ធាតុទាំងពីរនេះវាជារបស់ទទេ, មិនមានកម្ពស់តម្លៃអ្វីឡើយ, សីលទេដែលជា របស់មានកម្ពស់តម្លៃ ។ បើគ្មានសីលហើយ, សុត្តៈរបស់មនុស្សយើង ក៏វាក្លាយទៅជារបស់គ្មាន ប្រយោជន៍អ្វីបន្តិចបន្តួចឡើយ**»

«**ជាស្តេច, តែមិនរស់នៅក្នុងធម៌, ជាឈ្មួញតែគ្មានអាស្រ័យពឹងពាក់ធម៌, ជនទាំងនេះឈ្មោះថា បានលះបង់ចោលនូវលោកទាំងពីរ (គឺលោកទេពនិងលោកមនុស្ស) ហើយរស់នៅក្នុងលោក អបាយភូមិ**»

«**ស្តេច, ព្រាហ្មណ៍, វេស្សៈ, សូទ្រៈ និងចណ្ឌាល ដែលរស់នៅដោយប្រកបអាជីវកម្មដុតខ្មោចឬ មនុស្សឈ្នួលបម្រើដែលមានមុខងារជាអ្នកបោសសម្រាម ឬលាងបង្គន់ក៏ដោយបើបានប្រព្រឹត្តប្រតិបត្តិ ធម៌ត្រឹមត្រូវក្នុងលោកនេះហើយ គេរមែងបានរស់នៅក្នុងភាពស្មើគ្នា (សមភាព) ក្នុងសកលពិភព (គឺក្នុងលោកទេព ឬមានធម៌ទេពដូចគ្នា)**»

«**ព្រោះវេទក៏ដោយ ជាតិត្រកូលក៏ដោយ ពូជពង្សក៏ដោយ មិនមែនដើម្បីសេចក្តីសុខក្នុងសម្បរាយិកភព, តែសីលបរិសុទ្ធរបស់មនុស្សនាំមកនូវសេចក្តីសុខក្នុងសម្បរាយិកភព**»

៣- ក្នុងកណ្ណកត្ថសូត្រ, ព្រះពុទ្ធទ្រង់សម្តែងថា :

**«វណ្ណៈទាំង ៤ គឺ ក្សត្រ, ព្រាហ្មណ៍, វេស្សៈ, សូទ្រៈ បើមានគុណធម៌ដូចគ្នា ក៏ត្រូវមានកម្ពស់ស្មើគ្នា ។ ព្រះអង្គបានធ្វើសេចក្តីប្រៀបធៀបថា បើគេប្រមូលដើមឈើ ទាំងឡាយមានជាអាទិ៍ ដើមស្រឡៅ, ដើមផ្តៀក, ដើមត្រស, ដើមស្វាយ, ដើមដូង ដែលអស់សំងួត មកដុតភ្លើងក្នុងទីរួមគ្នា ឬក្នុងគុក់តែមួយ លទ្ធផលគឺអណ្តាតភ្លើង, ពន្លឺភ្លើង, ពណ៌សម្បុរ ភ្លើងនិងផ្សែងភ្លើងដូចៗគ្នា មិនមានខុសគ្នាសូម្បី បន្តិចបន្តួចឡើយ គឺថាវាគ្មានផ្សេងគ្នា ទៅតាមពូជឈើមួយមុខៗ ដែលគេយកមកដាក់ចូលគ្នានោះទេ»**

៤- ក្នុងអគ្គញ្ញសូត្រ, ព្រះពុទ្ធ ព្រះអង្គបានមានព្រះតម្រាស់ជាមួយនិងព្រាហ្មណ៍ពីរនាក់ គឺវាសេដ្ឋៈ និងភារទ្វាជៈ ដែលទាំងពីនាក់បានសួរពីរឿងវណ្ណៈ ។ នៅក្នុងព្រះតម្រាស់នោះ ព្រះអង្គបានចង្អុលបង្ហាញនូវ សេចក្តីពិតថា :**ការដែលពួកព្រាហ្មណ៍ នាំគ្នាលើកតម្កើងនូវវណ្ណៈមួយរបស់ខ្លួនថា ជាវណ្ណៈស, ពួកដទៃជាវណ្ណៈខ្មៅ, ពួកព្រាហ្មណ៍ជាមនុស្សបរិសុទ្ធ, ពួកដទៃមិនបរិសុទ្ធនោះ ព្រោះមកពី មិនមាននឹកដល់រឿងចាស់របស់ខ្លួនប៉ុណ្ណោះទេ ។ ការពិត, ដែលពួកព្រាហ្មណ៍និយាយថា ពួកខ្លួនកើតពីមាត់ព្រហ្ម, ជាឱរសរបស់ព្រហ្មនោះ ក៏មិនមែនជាសេចក្តីពិតទេ ។ ព្រោះព្រាហ្មណ៍ រាល់រូបសុទ្ធតែកើតមកពីម្តាយរបស់ខ្លួន ដែលជាព្រាហ្មណ៍ មានទម្ងន់គ្រប់ខែ, សម្រាលចេញ បៅដោះម្តាយ, ដូចគេដូចឯង មិនមានអ្វីជាពិសេសជាងមនុស្ស ទាំងឡាយដទៃឡើយ ។**

**មនុស្សដូចគ្នា, ទោះជាកើតក្នុងត្រកូលណា, វណ្ណៈណាក៏មានសិទ្ធិធ្វើនូវអ្វីៗទាំងអស់ ដែលសកលមនុស្សគេធ្វើបាន មានជាអាទិ៍ សិទ្ធិធ្វើការដើម្បីរស់, សិទ្ធិធ្វើបុណ្យទាន, សិទ្ធិវៀរចាកទំនើរអយុត្តិធម៌, សិទ្ធិកាន់សាសនា, សិទ្ធិថែរក្សាបូរណភាពរូបកាយ, សិទ្ធិទុកដាក់ទ្រព្យសម្បត្តិ ។ល។**

ជាបន្ទាន់, ព្រះអង្គបានសម្តែងដល់រឿងចាស់ ដែលជាហេតុនៃការបែងចែកវណ្ណៈថា: **ក្នុងជាន់ដំបូង គេបែងចែក មនុស្សត្រឹមតែតាមករណីយ៍ ឬមុខងារ ប្រហាក់ប្រហែលគ្នានិងការបែងចែកការងារ** (DIVISION OF LABOUR) **ក្នុងក្បួនសេដ្ឋកិច្ច ពោលគឺអ្នកណាមានមុខងារខាងអ្វីក៏បែងចែកប្រភេទមនុស្សទៅតាមនោះដែរ ។ តែតមកខាងក្រោយគេមានគំនិតយល់ច្រឡំក្នុងរឿងចែកការតាមសមត្ថភាពមនុស្សទៅជាបែងចែកវណ្ណៈ ហើយប្រកាន់យកនូវវណ្ណៈនេះសម្រាប់ប្រើជាមធ្យោបាយ ប្រាមាថមើលងាយជិះជាន់ គ្នាទៅវិញ ។** ក្នុងទីបំផុត, ព្រះអង្គបានបំព្រួញសេចក្តីថា :**«ម្នាលវាសេដ្ឋៈ, ភារទ្វាជៈ! ធម្មៈជាធាតុមានកម្ពស់, ជាធាតុមានតម្លៃច្រើនបំផុតនៅក្នុងសង្គមប្រជាជន ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត»**

៥- ក្នុងមធុរសូត្រ, មានស្តីដល់ការឆ្លើយឆ្លងរបស់ព្រះមហាកច្ចាយនត្ថេរៈ ព្រះអរហន្តសាវ័កដែលព្រះសម្មាសម្ពុទ្ធបានទទួលស្គាល់ថ្វីមាត់របស់លោក, ហើយព្រះអង្គបានប្រទានពិន្ទុដល់កម្រឹទីបំផុត ជាមួយនិងសេចក្តីបញ្ជាក់របស់ព្រះអង្គថា ភិក្ខុកច្ចាយនៈជាបុគ្គលឆ្លាតក្នុងការធ្វើអត្ថាធិប្បាយសេចក្តីសង្ខេបឲ្យពិស្តារ ក្នុងពេលជួបគ្នានិងមធុរាជអវន្តីបុត្តដែលបានសួរ លោកដល់មរតករបស់ព្រាហ្មណ៍ ពីរឿងវណ្ណៈត្រង់ចំណុចថា មានតែពួកព្រាហ្មណ៍មួយប៉ុណ្ណោះ ប្រសើរដាច់គេក្នុងពិភពមនុស្ស ។ មធុរាជាបានវែកញែកសំណួររបស់ខ្លួន ជាវគ្គៗមានដូចនេះ :

**១- វណ្ណៈទាំងឡាយ ៤, វណ្ណៈណាខ្លះដែលមានភាពខ្ពង់ខ្ពស់ជាងគេ, មានវណ្ណៈដទៃ**

**គោរព ចុះចូល ប្រគល់ខ្លួនជាសាវ័ក**?

**២- វណ្ណៈណាខ្លះដែលបានប្រព្រឹត្តអកុសលកម្មបថ ពេលស្លាប់ទៅកើតក្នុងអបាយភូមិ ស្មើគ្នា ទាំងអស់គ្មានពិសេស**?

**៣- វណ្ណៈណាខ្លះដែលបានប្រព្រឹត្តកុសលកម្មបថ ពេលស្លាប់ទៅកើតក្នុងសគតិភូមិ ស្មើគ្នា ទាំងអស់ដោយគ្មានរើសមុខ**?

**៤- វណ្ណៈណាខ្លះដែលបានធ្វើចោរកម្មបរទារិកកម្មហើយត្រូវ ទទួលទោស ទណ្ឌកម្ម របស់រដ្ឋ ដូចគ្នា ដោយគ្មានឲ្យអភ័យឯកសិទ្ធិ**?

**៥- វណ្ណៈណាខ្លះដែលចេញបួស, រស់នៅក្នុងសីលធម៌ ហើយត្រូវបានទទួលសេចក្ដីគោរពរាប់អាន, ទទួលការទំនុកបម្រុងនិងការការពារសន្តិសុខគ្រប់គ្នា ដោយគ្មានយោគយល់មុខ**?

ចំពោះសំណួររបស់អរន្តីបុត្ត ព្រះមហាថេរៈបានឲ្យចម្លើយមួយៗ មានដូចនេះ :

` **ក- វណ្ណៈណាក៏ដោយ, ឲ្យតែលះបង់នូវភាពប្រកាន់, ភាពប្រមាថមើលងាយ, ភាពជិះជាន់ សង្កត់សង្កិនវណ្ណៈនោះត្រូវមានវណ្ណៈដទៃគេគោរពរាប់អាន, គេប្រគល់កាយ ថ្វាយខ្លួនជាសាវ័កហើយ ។**

**ខ- វណ្ណៈណាក៏ដោយ, កាលបើបានប្រព្រឹត្តអកុសលកមបថហើយ វណ្ណៈនោះក្នុង ពេលស្លាប់ ត្រូវតែទៅកើតក្នុងអបាយភូមិទាំងអស់គ្នា គ្មានទុកនរណាម្នាក់ជាពិសេសទេ ។**

**គ- វណ្ណៈណាក៏ដោយ, តែបានប្រព្រឹត្តកុសលកម្មបថហើយ វណ្ណៈនោះក្នុងពេលស្លាប់ ត្រូវតែទៅកើតក្នុងសុគតិភូមិស្មើគ្នាទាំងអស់ ដោយគ្មានរើសមុខទេ ។**

**ឃ- វណ្ណៈណាក៏ដោយ, កាលបើបានប្រព្រឹត្តនូវទំរើចោរកម្ម, បរទារិកកម្ម . . . ហើយ វណ្ណៈ នោះ ត្រូវទោសទណ្ឌកម្មរបស់រដ្ឋដូចគ្នាទាំងអស់ ដោយគ្មានអភ័យឯកសិទ្ធិឡើយ ។**

**ង- វណ្ណៈណាក៏ដោយ, កាលបើបានចេញបួស, រស់នៅក្នុងភាពមិនមានវណ្ណៈ មានសីល បានរក្សាត្រឹមត្រូវហើយ, មានធម៌បានប្រព្រឹត្តមធ្យ័តហើយ ។ វណ្ណៈនោះ រមែងបានទទួល សេចក្ដីរាប់អាន, ការទំនុកបម្រុង, ការគ្រប់គ្រងរក្សា ។ល។ ស្មើគ្នាទាំងអស់ គ្មានលះបង់ចោល នរណាម្នាក់ឡើយ ។**

មធុររាជា, បានវាយតម្លៃយ៉ាងខ្ពស់ដល់ភាសិតរបស់ព្រះមហាថេរៈ, ព្រមគ្នានេះបានថ្វាយខ្លួនជាពុទ្ធសាសនិក ។ តែក្នុង ពេលនោះ ព្រះបរមគ្រូរបស់យើងនិព្វានហើយ, មធុររាជាមានសេចក្ដីសោកស្ដាយយ៉ាងខ្លាំង រហូតដល់បញ្ចេញឧទានថា : ប្រសិនបើព្រះបរមសាស្ដាចារ្យគង់ព្រះជន្មនៅ ទោះជាកន្លែងគង់សម្រាក ព្រះឥរិយាបថនោះ ឆ្ងាយដាច់ស្រយាលប៉ុន្មានក៏ដោយ ។ ខ្ញុំព្រះអង្គនឹងធ្វើដំណើរទៅកាន់ទីនោះ, ដើម្បីក្រាបបង្គំគាល់ព្រះអង្គលុះត្រាតែបាន ។ ឥឡូវព្រះមានព្រះភាគនិព្វានហើយ, ខ្ញុំព្រះអង្គសូមប្រគល់កាយ ថ្វាយចិត្តវិញ្ញាណដល់ព្រះមានព្រះភាគដែលនិព្វានហើយ, ព្រះធម៌ដែលសម្ដែងដោយ ព្រះមានព្រះភាគ និងព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគជាសរណៈ ចាប់តាំងពីពេលនេះតរៀងទៅ ។

តាមប្រវត្តិនិងគោលការណ៍, ដែលខ្ញុំបានសរសេរមកហើយ យើងអាចឃើញបានយ៉ាងច្បាស់លាស់ថា : ពុទ្ធសាសនា គ្មានបានបង្រៀនមនុស្សឲ្យរស់នៅក្នុងទិដ្ឋិមានៈទេ ។ ផ្ទុយទៅវិញ, ព្រះសម្មាសម្ពុទ្ធរបស់យើង ព្រះអង្គខំព្យាយាមអស់ពីសមត្ថភាព ដើម្បីពន្យល់ឲ្យគេយល់នៅក្នុងព្រះគំនិតមួយ, ចង់ឲ្យគេលុបចោលនូវវណ្ណៈទាំងឡាយច្រឡំរបស់គេនោះវិញទៅ ។ សេចក្ដីបំភ្លឺរបស់ព្រះអង្គ ក្នុងរឿងបែងចែកវណ្ណៈនោះ មានប្រើតាំងពីពាក្យធម្មតា

រហូតដល់មធ្យមនិងខ្ពស់បំផុត ។ ពាក្យធម្មតា, ដូចជាគេថា ស្តេចកើតពីទេវតា (កូនទេវតា) ព្រាហ្មណ៍កើតពីព្រហ្ម (កូនព្រហ្ម) ។ល។ ព្រះសម្មាសម្ពុទ្ធបដិសេធថា មិនមែន នៅក្នុងពិភពមនុស្ស, គេមិនធ្លាប់ដែលឃើញទេវតា ឥន្ទ ព្រហ្មបង្កើតមនុស្សទេ ។ គេឃើញតែមនុស្សបង្កើតមនុស្ស មានឪពុក ម្តាយជាមនុស្ស, កើតមកបៅដោះមនុស្ស, ស៊ីអាហារមនុស្ស, រស់ជាមនុស្ស, ស្លាប់ជាមនុស្ស ដូចបានសរសេរមកហើយ ។ល។ ពាក្យជាមធ្យម, ព្រះអង្គពន្យល់ថា មនុស្សណាមានទេវធម៌ (សទ្ធា, សីល, ចាគៈ, សុត្ត, បញ្ញា) នៅក្នុងវិញ្ញាណរបស់ខ្លួន, មនុស្សនោះត្រូវបានដូរឈ្មោះពីមនុស្សទៅជាទេព, លុះដល់ពេលស្លាប់វិញ្ញាណរបស់គេត្រូវបានទៅកើត ក្នុងពិភពទេព ។ មនុស្សណាមានព្រហ្មវិហារធម៌នៅក្នុងវិញ្ញាណរបស់ខ្លួន, មនុស្សនោះត្រូវបានដូរឈ្មោះពីមនុស្សទៅជា ព្រហ្មណ៍, លុះដល់ពេលស្លាប់វិញ្ញាណរបស់គេត្រូវបានទៅកើតក្នុងពិភពព្រហ្ម ។ នៅក្នុងសម័យនោះ, ព្រះសម្មាសម្ពុទ្ធចង់មានព្រះតម្រាស់ថា មនុស្សត្រូវបង្កើតដោយមនុស្ស, មិនមែនត្រូវបង្កើតដោយទេវតាឥន្ទព្រហ្មទេ ។ តែវិញ្ញាណទេវតាឥន្ទព្រហ្មអាចចូលមកចាប់បដិសន្ធិក្នុងផ្ទៃមនុស្សបាន ព្រោះកំណើតរបស់សត្វត្រូវអាស្រ័យធាតុ ៣ គឺ : មាតាបិតាបានរួមប្រពៃណី ១, មាតាមានរដូវ ១, មានថាមពលនៃវិញ្ញាណមក ចាប់បដិសន្ធិ ១ ។ ពាក្យខ្ពស់ បំផុត, ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានប្រទានពន្លឺដល់គំនិតមនុស្សទាំងឡាយថា នៅក្នុងខ្លួនរបស់ មនុស្សម្នាក់ៗ មានធាតុមានចំនួនស្មើគ្នាគឺ : មហាភូតរូប ៤, បសាទរូប ៥, វិស័យរូប ៤, ភាវរូប ២, ជីវិតរូប ១, អាហាររូប ១, បរិច្ឆេទរូប ១, វិញ្ញត្តិរូប ២, វិការរូប ៣, លក្ខណរូប ៤ ។ ចម្លើយនេះ, អាចឲ្យយើងយល់បានថា មនុស្សរស់នៅក្នុងភាពស្មើគ្នា (សមភាព) ព្រមគ្នានេះ, ព្រះសម្មាសម្ពុទ្ធ, បានធ្វើសេចក្តីបញ្ជាក់ជាឱឡារិកថា សេចក្តីពិតរបស់ធាតុទាំងឡាយមានមនុស្សធាតុនេះជាដើម មាន ៤ យ៉ាងគឺ ទុក្ខៈ, ទុក្ខសមុទយៈ, ទុក្ខនិរោធៈ, ទុក្ខនិរោធគាមិនីបដិបទា ។ សេចក្តីបញ្ជាក់របស់ព្រះសម្មាសម្ពុទ្ធក្នុងរឿងនេះ យើងធ្លាប់ចេះចាំមកគ្រប់គ្នាហើយ បើមិនច្រើនក៏តិចតដែរ ។ ដូចនេះ, ដើម្បីឲ្យដំណើរសេចក្តីបាន លឿនទៅមុខ, ខ្ញុំសូមឲ្យអ្នកអានចាប់អារម្មណ៍ លើពាក្យថា**ទុក្ខសមុទយៈ** ដែលមានន័យថា**ទុក្ខ**កើតពីតណ្ហា ឬ**ទុក្ខ**កើតព្រោះតណ្ហា តើការបង្កើត ឬបែងចែក វណ្ណៈ វាជាតណ្ហារបស់មនុស្សមែនឬ? ព្រះសម្មាសម្ពុទ្ធព្រះអង្គពុំបានមានព្រះគំហើញថា មនុស្សត្រូវបានខ្ពង់ខ្ពស់ ថោកទាបជាងគ្នា ដោយអាស្រ័យសាច់ឈាម ឬត្រកូលវណ្ណៈឡើយ ។ តែដោយអាស្រ័យធម្មៈល្អ ដែលខ្លួនមនុស្ស ម្នាក់ៗបានប្រព្រឹត្ត, បានកាន់ហ្នឹងឯង ។

ក្នុង**ទសធម្មសូត្រ**, ព្រះបរមសាស្តាចារ្យរបស់យើង ក្រោយពីបានទាត់ចោលនូវវណ្ណៈទាំងឡាយ មិនឲ្យមានក្នុង សាសនារបស់ព្រះអង្គ ដោយព្រះតម្រាស់ថា «**វេវណិយម្ហិ អជ្ឈុគតោតិ បព្វជិតេន អភិណ្ហំបច្ចវេក្ខិតព្វំ**» ស្រេច ហើយ ។ ព្រះអង្គបានចែកមនុស្សចេញជា ៥ ពួក តាមលក្ខណៈដូចនេះ :

**១- មនុស្សនេរយិកោ**មនុស្សសត្វនរក

**២- មនុស្សតិរច្ឆានោ**មនុស្សសត្វតិរច្ឆាន

**៣- មនុស្សបេតោ**មនុស្សសត្វប្រេត

**៤- មនុស្សមនុស្សោ**មនុស្សជាសត្វមនុស្ស

**៥- មនុស្សទេវោ**មនុស្សសត្វទេព ។

មនុស្សជាសត្វនរក, បានដល់មនុស្សណា ដែលប្រព្រឹត្តធ្វើទំរើអាក្រក់ទាំងឡាយ មានមនុស្សឃាតជាដើម, ដែលក្នុង ជីវិតនេះ ត្រូវទទួលទណ្ឌកម្មរបស់រដ្ឋ ដោយជាប់គុក ឬដោយបទពិន័យណាមួយនៅក្នុងកម្រិតធ្ងន់បំផុត ។ មនុស្សសត្វតិរច្ឆាន, បានដល់មនុស្សដែលបាប្រព្រឹត្តនូវ ទំរើមិនល្អដល់មនុស្សគ្នាឯងដូចសត្វតិរច្ឆាន ។ មនុស្សបេតោ, បានដល់មនុស្សដែលមានចិត្ត ប្រកបដោយលោភៈ ទោសៈ មោហៈ រស់នៅមិនត្រឹមត្រូវតាមវិន័យ សង្គម ហើយត្រូវសង្គមទាត់ចោល, រស់នៅតែឯកឯង, មានសេចក្តីលំបាកវេទនាច្រើន រហូតដល់រស់ពាក់កណ្តាល

ស្លាប់ពាក់កណ្តាល ។ មនុស្សមនុស្សោ, បានដល់មនុស្សដែលយល់ ស្គាល់ធម៌សម្រាប់សង្គម ហើយរៀនរស់នៅក្នុងធម៌របស់សង្គម មានជាអាទិ៍ រស់នៅក្នុងសីល ៥ ឬរស់នៅក្នុងភាពមិនមានការ ជិះជាន់គ្នា ។ មនុស្សទេព, បានដល់មនុស្សដែលមានធម៌ទេព (សទ្ធា, សីល, ចាគៈ, សុត្តៈ, បញ្ញា) ហើយរស់នៅក្នុងធម៌នេះ រហូតអស់ជីវិត ។ សេចក្តីនេះ, បញ្ជាក់ឲ្យយើងឃើញយ៉ាងច្បាស់ថា ព្រះសម្មាសម្ពុទ្ធពិតជាបានលុបវណ្ណៈដែលគេបានបង្កើត មុនព្រះអង្គគឺបានបែងចែកមនុស្សជា ៤ ពួក ។ គឺព្រះអង្គពុំបានដាក់តម្លៃ ឬតំហោករបស់មនុស្សនៅលើទ្រព្យសម្បត្តិ អម្បូរត្រកូលវណ្ណៈទេ ។ តែព្រះអង្គបានដាក់តម្លៃនិងតំហោករបស់មនុស្សទៅលើចរិយា (ការប្រព្រឹត្តអាក្រក់ល្អ) វិញ ។ ដើម្បីឲ្យអ្នកអានមានពន្លឺ និងជំនឿកាន់តែច្រើនឡើងទៀត, ខ្ញុំសូមថយទៅក្រោយ ដើម្បីធ្វើសេចក្តីបំភ្លឺលើអត្ថបទនៃទសធម្មសូត្រ ដែលខ្ញុំបានសរសេរជាបាលីរួចមកហើយ ។ បាលីនោះមានន័យថា «បព្វជិតគប្បីពិចារណារឿយៗថា អាត្មាអញចេញចាកផុតពីវណ្ណៈទាំងអស់ ហើយ» «វណ្ណៈ» ក្នុងទីនេះ យើងទម្លាប់ប្រែថា «ភេទ» ហើយដាក់ពាក្យថា «ផ្សេង» ចូលមកទៀត ។ កើតបានជាឃ្លាមួយថា «បព្វជិតគប្បីពិចារណាថា អាត្មាអញមានភេទផ្សេងពីគ្រហស្ថហើយ . . . . . ។ សេចក្តីបកប្រែនេះត្រូវហើយ, តែមានសេចក្តី ទូលំទូលាយពេក ព្រោះមិនដឹងជាគ្រហស្ថនោះបានដល់ជនពួកណាខ្លះ ហេតុដូចម្តេចទើបត្រូវកាន់ចរិយាខុសពីគេ? អ្នកស្រាវជ្រាវ ប្រវត្តិសាស្ត្រខាងសាសនា មានគំហើញថា គួរទុកសព្ទ «វណ្ណៈ» នៅដដែល មិនចាំបាច់ប្រែថា «ភេទ» ទេ ។

ចំណែកពាក្យថា «បព្វជិត» តាមយោបល់របស់អ្នកស្រាវជ្រាវថា : ពុំមែនដៅយកតែភិក្ខុ, ភិក្ខុនី, សាមណេរ, សាមណេរី, សិក្ខាមានាទេ ។ តាបសតសីរហូតដល់ឧបាសក ឧបាសិកា ក៏អាចហៅថា បព្វជិត ដោយបរិយាយបានដែរ ។ ដូចនេះព្រោះអ្វី? ព្រោះបព្វជិតមានន័យថា វៀរចាកបាប វៀរចាកទំរើអាក្រក់ ។ ដើម្បីបំបាត់នូវចម្ងល់ខ្លះប្រសិនបើមាន, អ្នកអានគ្រាន់តែសើរើពិនិត្យ ឡើងវិញនូវការលះបង់របស់តាបសតសី, ការចូលសាសនាពុទ្ធរតន៍របស់ឧបាសក ឧបាសិកា និងការសូមបព្វជ្ជាឧបសម្បទារបស់ សាមណេរ ភិក្ខុ, តែប៉ុណ្ណឹងសេចក្តីងឿងឆ្ងល់ក៏អាចនឹងរលាយទៅឯងដោយស្វ័យប្រវត្តិ ។ តែបើមិនទាន់អស់សេចក្តីងឿងឆ្ងល់ទេ យើងត្រូវហាត់ធ្វើសំណួរខ្លួនឯង, ហាត់ឲ្យចម្លើយខ្លួនឯងឲ្យបានញយៗទៅ យើងគង់បានយល់មិនខានឡើយ ។ របៀបធ្វើ សំណួរ : តើគេលះបង់នូវអ្វី? ហេតុអ្វីបានជាគេនាំគ្នាចូលសាសនាពុទ្ធរតន៍? ដូចម្តេចទើបគេសូមបព្វជ្ជាឧបសម្បទា? ចម្លើយ គេលះបង់នូវវណ្ណៈ, គេយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីរឭកជំនួសវណ្ណៈ ។ គេចេះចាកចោលវណ្ណៈ, មករស់នៅក្នុងអវណ្ណៈ ។ នេះឯងគឺជាលំនៅនៃជីវិតមនុស្ស, ដែលយើងធ្លាប់ស្គាល់មកហើយ, ហើយនិងចេះតែស្គាល់តទៅទៀត ។ គឺអ្នកខ្លះ រស់នៅក្នុងបុណ្យ, អ្នកខ្លះរស់នៅក្នុងបាប, អ្នកខ្លះរស់នៅក្នុងភាពខុស, អ្នកខ្លះរស់នៅក្នុងភាពត្រូវ, អ្នកខ្លះរស់នៅ ក្នុងភាពកុសល, អ្នកខ្លះរស់នៅក្នុងភាពអកុសល, អ្នកខ្លះរស់នៅក្នុងវណ្ណៈ, អ្នកខ្លះរស់នៅក្នុងអវណ្ណៈ ។ល។ អ្នកអានសូមកុំភ្លេចធ្វើការកត់សម្គាល់ថា វណ្ណៈក្នុងទីនេះ (វណ្ណៈ ៤) លោកពុំបានសំដៅយកសម្បុរស្បែករបស់ មនុស្ស ឬគ្រឿងស្លៀកពាក់របស់មនុស្សតាមដែលអ្នកខ្លះធ្លាប់យល់នោះទេ ។ គឺលោកសំដៅយកឋានៈ គឺកម្ពស់និង ទំនាបរបស់មនុស្សដែលគេបានបែងចែកមកហើយ នៅក្នុងគោលគំនិតមួយដែលលោកឲ្យ ឈ្មោះថា របបជិះជាន់ មនុស្ស ប្រកបដោយក្របខ័ណ្ឌ នៃការគិតទុកជាមុន ឬរបបជិះជាន់ អាស្រ័យច្បាប់ ។

ដើម្បីលះបង់នូវវណ្ណៈ ឬភាពប្រកាន់ជាប់ស្អិតក្នុងវណ្ណៈ យើងគួរចាប់អារម្មណ៍លើពុទ្ធភាសិតមួយទៀតថា :

**«ន ជច្ចា វសលោ ហោតិ ន ជច្ចា ហោតិ ព្រាហ្មណោ កម្មុនា វសលោ ហោតិ កម្មុនា ហោតិ ព្រាហ្មណោ»** «សេចក្តីថង្រៃអប្បលក្ខណ៍មិនមែនជាធាតុមានមកពីកំណើតទេ, សេចក្តីថ្លៃថ្នូរក៏មិនមែនជាធាតុមានមកពីកំណើតដែរ ។ (ផ្ទុយទៅវិញ) សេចក្តីចង្រៃអប្បលក្ខណ៍ជាធាតុកើតចេញមកពីកម្ម, សេចក្តីថ្លៃថ្នូរ

ក៏ជាធាតុកើតមកពីកម្ម (ដូចគ្នា)» បំណងពុទ្ធភាសិតនេះ ព្រះបរមគ្រូរបស់យើងព្រះអង្គចង់និយាយថា : «ភាពថ្លៃថ្នូរ និងភាពថោកទាបរបស់មនុស្ស ពុំមែនកើតមកពីជាតិសាសន៍អំបូរត្រកូលវណ្ណៈទេ ។ល។ ជាមួយគ្នានេះ, សេចក្តីថ្លៃថ្នូរនិងសេចក្តីថោកទាបរបស់មនុស្ស វាជាធាតុកើតមកពីកម្ម, នេះគឺជាមូលដ្ឋាននៃព្រះគំនិត របស់ព្រះសម្មាសម្ពុទ្ធ ក្នុងរឿងទាត់ចោលនូវធាតុវណ្ណៈ, ហើយស្ថាបនានូវធាតុអវណ្ណៈ សម្រាប់ប្រើជំនួស ។ ដូច្នេះព្រោះអ្វី? ព្រោះមានតែធាតុកុសលកម្ម(**កុសលាធម្មា**)និងធាតុអកុសលកម្ម(**អកុសលាធម្មា**)តែពីរ ប៉ុណ្ណោះដែលវាយនូវតម្លៃ និងឲ្យនូវតំហោកដល់មនុស្សលោក ។

ក្នុងបច្ចុប្បន្នកាលនេះ, ប្រទេសឥណ្ឌាបានអនុវត្តច្បាប់រដ្ឋធម្មនុញ្ញ ឲ្យមនុស្សគ្រប់វណ្ណៈមានសិទ្ធិស្មើគ្នា ។ ការអនុវត្តច្បាប់នេះ, មានពួកមនុស្សដែលត្រូវគេជិះជាន់ប្រមាថមើលងាយ ព្រោះខ្លួនកើត ឬរស់នៅក្នុងវណ្ណៈទាបច្រើនសែននាក់ ។ បានសូមប្រគល់កាយ ថ្វាយខ្លួនជាពុទ្ធសាសនិក ក្នុងពុទ្ធសករាជ ២៤៩៩ ។ ទន្ទឹមគ្នានេះ, បានប្រកាសប្តេជ្ញាខ្លួនគោរព ព្រះពុទ្ធសាសនា ជាសាសនារបស់ជីវិតមនុស្ស ព្រោះពេញចិត្តនឹងព្រះពុទ្ធសាសនា ដែលពុំបានមើលហួសមនុស្សជាន់ទាប ដែលកំពុងត្រូវគេធ្វើបាបសព្វថ្ងៃ ។ ខ្ពស់ជាងនេះ, ព្រះពុទ្ធបរមគ្រូបានលុបចោលវណ្ណៈនៅក្នុងក្របខ័ណ្ឌនៃនិតិន័យ ។ ហើយព្រះអង្គបានលើកតម្កើងវណ្ណៈជាន់ទាប ឲ្យមានកម្ពស់ស្មើនឹងវណ្ណៈជាន់លើបំផុត ដោយគ្មានខ្វីវល់ដល់ខ្លួនព្រះអង្គដែលកើតក្នុងវណ្ណៈស្តេច ។ ព្រះអង្គគ្មានចំណុចខ្សោយ, ក្នុងសំនូ, ក្នុងមុខងារដែលត្រូវធ្វើដើម្បីរំដោះមនុស្សដែលរស់នៅក្នុងភាពទុក្ខ, ភាពទន់ខ្សោយ, ភាពថោកទាប ។ល។ តែព្រះទំរើរបស់ព្រះអង្គ មួយណាក៏ដូចជាមួយណា ព្រះអង្គពុំបានចេះតែធ្វើទៅៗ ដោយគ្មាន ព្រំដែនទេ ។ គឺធ្វើនៅក្នុងក្របខ័ណ្ឌនៃសភាពពិត ដែលយើងធ្លាប់ស្គាល់ថា : សច្ចៈ ៤ ហ្នឹងឯង ។ ដូចនេះ, ជនណាដែលមានត្រៃសរណគមន៍ហើយ, ជននោះគេមុខជានឹងមិនភ្លេចន័យរបស់ធាតុថា «សរណៈ» ទេ ។ ការរំដោះខ្លួនរបស់គេចេញចាកវណ្ណៈជាទំរើមួយដែលគេត្រូវធ្វើក្នុងពេលណាមួយ បើមិនឆាប់ក៏យូរដែរ ។ ព្រោះអ្វី? ព្រោះសរណៈមានន័យថា ភ្ជាក់រឭកនៅក្នុងក្របខ័ណ្ឌនៃសម្បជញ្ញៈរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គបាន លះបង់វណ្ណៈអស់ហើយ ។

នៅក្នុងសុន្ទរកថានាៗ របស់អ្នកដឹកនាំប្រទេសឥណ្ឌា គេច្រើនតែបានឮពាក្យសរសើរជាប់ជានិច្ចថា ព្រះសម្មាសម្ពុទ្ធបរមគ្រូ ព្រះអង្គបានប្រទានពន្លឺមានគុណភាពខ្ពង់ខ្ពស់បំផុត ទុកឲ្យប្រទេសឥណ្ឌាយូរយាណាស់មកហើយដើម្បីបានជាគិតគូរ ពិចារណាដល់រឿងបែងចែកវណ្ណៈ ដែលខ្លួនធ្វើឡើងដោយអាស្រ័យកំលោរបស់ខ្លួន ។ តែឥណ្ឌាទើបតែអនុវត្តបាន ខាងផ្លូវ និតិន័យ ក្នុងកាលមានរដ្ឋធម្មនុញ្ញនេះឯង ។ ចំណែកខាងផ្លូវព្រឹត្តន័យវិញនោះ មិនមាននរណាដឹងឲ្យបានប្រាកដថា ឥណ្ឌានឹងចាប់ផ្តើមអនុវត្តក្នុងកាលណា ។ អ្នកសង្កេតការណ៍បរទេសមានគំហើញថា : ការអនុវត្តរបស់ឥណ្ឌាក្នុងរឿងវណ្ណៈ មិនងាយធ្វើបានក្នុងកាលខ្លីទេ ។ ព្រោះអ្វី? ព្រោះលិទ្ធិ សាសនា ប្រពៃណី ទំនៀមទម្លាប់ ជំនឿកំណាន់របស់ឥណ្ឌា មួយណាក៏ដូចជា មួយណា វាសុទ្ធតែជាធាតុមានអាយុច្រើនពាន់ឆ្នាំមកហើយ ។

សព្វថ្ងៃពិភពលោក, កំពុងតែខំប្រឹងលើកតម្កើងសមភាព, សេរីភាពនិងភាតរភាពរបស់មនុស្ស ឲ្យដល់ទៅកម្រិតខ្ពស់នៅថ្នាក់ជាអតិបរមា ដែលគេត្រូវការនោះហើយ ។ តែកំហំនិងបំរឹងនេះ, វាពុំទាន់បានសម្រេចដល់ទៅខ្នាតនៃសមភាព . . . . . ដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានប្រទាននៅឡើយទេ ។

## បទទី៥
## ការបង្រៀនឲ្យរស់នៅតាមភាពពិតតាមពំនោលត្រង់ៗចំៗ

«ព្រះពុទ្ធសាសនា ជាសាសនាដឹកនាំមនុស្សឲ្យដើរកាត់តម្រង់ទៅរកសេចក្តីពិត ឲ្យប្រឈមមុខនឹងភាពពិតដូចសចក្តៅ កើតចាស់ឈឺស្លាប់ជាដើម ហើយឲ្យស្វែងរកប្រយោជន៍ អំពីសេចក្តីពិតនោះលុះត្រាតែបាន ។ ទន្ទឹមគ្នានេះ, បង្រៀនត្រង់ៗចំៗ ចំពោះបញ្ហាខ្លះដែលពីដើមមក គេមិនធ្លាប់បង្រៀន មិនធ្លាប់ចេះចាំត្រង់ៗចំ ដូចបញ្ហាឫក្សល្អយាមល្អនិងទឹកស័ក្តិសិទ្ធិជាដើម ។ បង្រៀនឲ្យមនុស្សធ្វើជាទេវតានៅក្នុងជីវិតនេះ, កុំចាំស្លាប់សិន ទើបបានធ្វើជាទេវតាដោយធ្វើសេចក្តីពន្យល់ថា ការប្រព្រឹត្តប្រតិបត្តិ ល្អ ជាធាតុធ្វើមនុស្សឲ្យទៅជាទេវតាបាន»

ការបង្រៀនឲ្យដើរផ្លូវកាត់ សំដៅទៅរកសេចក្តីពិត ឬការបង្រៀនត្រង់ៗចំៗនោះ គឺការហ៊ានចេញមុខនិយាយសេចក្តីពិត បដិសេធជំនឿខុស, ជំនឿគ្មានហេតុផលហ្នឹងឯង ។ អ្នកអានដឹងហើយថា ពួកព្រាហ្មណ៍បានបង្រៀនគ្នា, បានប្រកាន់យកថា ពួកខ្លួនមានតម្លៃខ្ពស់ ព្រោះពួកខ្លួនកើតអំពីមាត់ព្រហ្ម ។ ព្រះពុទ្ធបរមគ្រូ ព្រះអង្គហ៊ានឆ្លើយសងត្រង់ៗចំៗថា ពួកព្រាហ្មណ៍កើតពីស្ត្រីជាម្តាយរបស់ខ្លួន សម្រាលតាមទ្វារយោនីដូចសកលមនុស្សដទៃក្នុងពិភពលោក ។ មនុស្សមានកំណើតដូចគ្នា សម្រាលតាមយោនីដូចគ្នា មានឪពុកប្រុស ម្តាយស្រីដូចគ្នាមានការរស់នៅដោយអាហារដូចគ្នា ចេះសើច ចេះយំ ចេះដេក ចេះខ្លាចដូចគ្នា ។ល។ គ្មានពិសេសថ្លៃថ្នូរអ្វី ជាងគ្នាឡើយ តម្លៃតំហោករបស់មនុស្ស ពុំមែននៅលើជាតិវណ្ណៈឡើយ, វានៅលើទំរើ អាក្រក់ល្អឯនោះវិញទេ ។

ដើម្បីបានជាពន្លឺដល់អ្នកអានក្នុងរឿងពុទ្ធតម្រាស់ ដែលធ្វើតាមសេចក្តីពិត, ក្នុងរឿងពុទ្ធតម្រាស់ដែលធ្វើត្រង់ៗចំៗ តាមហេតុការណ៍ដែលកើតមានឡើងភ្លាមៗ ក្នុងបច្ចុប្បន្ន ឬហេតុការណ៍ដែលនឹងត្រូវកើតក្នុងអនាគតដែលព្រះសម្មាសម្ពុទ្ធរបស់យើង បានឆ្លងកាត់ប្រកបដោយសេចក្តីក្លាហាន យ៉ាងប្តូរផ្តាច់នោះ ។ ខ្ញុំសូមលើកយករឿងក្នុងគម្ពីរពុទ្ធសាសនារបស់យើង មកប្រកបការពិចារណាមានដូចនេះ :

**១- តិកនិបាតអង្គុត្តរនិកាយ**, ព្រះសយម្ភូបានមានព្រះតម្រាស់ថា បុគ្គលដែលគ្មានគំនិតលោភ, គំនិតកំណាច, គំនិតភាន់ច្រឡំគ្របសង្កត់គេ រមែងមានពំនោលត្រូវកាលជានិច្ច (**កាលវាទី**) ពំនោលស្របតាមភាពជាប្រក្រតី (**ភូតវាទី**) ពំនោលស្របតាមប្រយោជន៍ជានិរន្តរ៍ (**អត្ថវាទី**) ពំនោល ស្របជាមួយធម្មៈ (**ធម្មវាទី**) ពំនោលជាវិន័យ (**វិនយវាទី**)។

ពុទ្ធភាសិតនេះ បានសម្តែងអង្គប្រកបនៃការធ្វើពំនោល គឺពំនោលត្រូវតាមកាល, ពំនោលត្រូវតាមសេចក្តីពិត, ពំនោលស្របតាមផលប្រយោជន៍ ។ ជនសប្បុរសមុននឹងធ្វើពំនោល លោករមែងប្រើគំនិតជ្រើសរើសជានិច្ច ។ ពាក្យពិតតែមិនស្របនឹង ផលប្រយោជន៍លោកមិននិយាយ, ពាក្យល្អតែកាលៈទេសៈមិនអនុញ្ញាតក៏លោក មិនស្តី ។ ក្រៅពីពំនោលត្រូវកាល, ត្រូវតាមសេចក្តីពិត, ស្របតាមផលប្រយោជន៍ដូចបានពោលមក ។ មានពំនោលមួយទៀតដែលសប្បុរសលោកមិនធ្វើ ដោយអាស្រ័យអគតិធម៌ ៤ ឬប្រាសចាកគំនោលនៃវិន័យ ។ គឺពំនោលណាមានលក្ខណៈស្របតាមផលប្រយោជន៍ហើយ, តែខុលគំនោលធម៌ និងមាត្រាវិន័យ, ពំនោលនោះ សប្បុរសលោកពុំធ្វើឡើយ ។ ម៉្យាងទៀតពំនោលណាមានលក្ខណៈជាធម៌ គ្មានលក្ខណៈជាវិន័យ ក៏លោកពុំធ្វើដែរ ព្រោះធម៌បូកនឹងវិន័យកើតបានជាសីលធម៌ សីលដៅយកការវៀរចាកទំរើអាក្រក់ ធម៌ដៅយកការប្រព្រឹត្តទំរើល្អ ។ ធម៌និងវិន័យគឺជាឱវាទដំបូន្មានរបស់ព្រះសម្មាសម្ពុទ្ធ ។ បុគ្គលអ្នកប្រព្រឹត្តប្រតិបត្តិតាមធម៌វិន័យឈ្មោះថា បានបណ្តុះភាពល្អបំបាត់ភាពអាក្រក់និងរំដោះចិត្តឲ្យស្អាតបរិសុទ្ធ ។ វិន័យដែលលោកដៅយកការវៀរចាកទំរើអាក្រក់នោះ ។ ទំរើអាក្រក់ក្នុងទីនេះ, លោកសំដៅយកទំរើអាក្រក់ដែលកើតតាមផ្លូវកាយនិងវាចា រហូតដល់ចរិយាមារយាទវាយរងតូចតាចមានជាអាទិ៍ ចរិយាក្នុងការ ស្លៀកពាក់, ចរិយាក្នុងការបរិភោគអាហារ ។ ពំនោលពិត, ពំនោលត្រូវកាល,

ពំនោលស្របផលប្រយោជន៍ មិនមែនជាពំនោល គ្មានវិន័យ, គ្មានទិសដៅ, គ្មានជញ្ជីងថ្លឹងគំនិត ថ្លឹងនិស្ស័យទេ ។ ពំនោលទាំងឡាយ សប្បុរសលោកធ្វើផ្អែកលើ ទស្សនវិចារណញ្ញាណ នៅក្នុងក្របខ័ណ្ឌនៃធម្មវិន័យ ប្រកបដោយប្រាកដនិយមគ្រប់កាលវេលា ។

២- ចម្លើយមួយ, ដែលព្រះសម្មាសម្ពុទ្ធបានធ្វើជាមួយនិងអភ័យរាជកុមារ សឹងមានមកក្នុងគម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ មានសេចក្ដីថា :

«ម្នាលរាជកុមារ ! តថាគតស្គាល់ថា សម្ដីណាមិនពិត, មិនប្រាកដ, មិនប្រកបដោយប្រយោជន៍ សម្ដីនោះ ទោះជាត្រូវចិត្ត ពេញចិត្តអ្នកផងក្ដី មិនត្រូវចិត្តមិនពេញចិត្តអ្នកផងក្ដី តថាគតមិនស្ដីមិននិយាយនូវសម្ដីនោះ ។ តែសម្ដីណាដែលតថាគត បានដឹងបានស្គាល់ថា ជារឿងពិត រឿងប្រាកដ រឿងមានប្រយោជន៍សម្ដីនោះទោះ ជាមិនត្រូវចិត្តអ្នកដទៃក៏ដោយ បើពេលវេលាតម្រូវឲ្យនិយាយ តថាគតតែងតែនិយាយនូវសម្ដីនោះជានិច្ចព្រោះសម្ដី នេះជាធាតុផ្ដល់សុខឲ្យសត្វលោកត្រូវតាមឧត្ដមគតិ របស់តថាគត»

ពុទ្ធវាចាសង្ខេបនេះ សម្ដែងឲ្យឃើញថា ពាក្យមិនពិតមិនមានប្រយោជន៍ ទោះជាត្រូវចិត្តអ្នកផងក៏ដោយ មិនត្រូវចិត្តអ្នកផងក៏ដោយ ព្រះសម្មាសម្ពុទ្ធព្រះអង្គមិនពោលពាក្យនោះ, តែបើពាក្យនោះជាពាក្យពិត ពាក្យមានប្រយោជន៍ទោះជាត្រូវចិត្ត អ្នកផងក្ដី មិនត្រូវចិត្តអ្នកផងក្ដី ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យនោះ ប្រសិនបើកាលៈទេសៈបើកឲ្យ ។ ក្នុងន័យថា ព្រះសម្មាសម្ពុទ្ធមុននឹងពោលនូវវាចាពិត វាចាមានប្រយោជន៍ ព្រះអង្គមិនដែលខានត្រិះរិះពិចារណាមើលកាលៈទេសៈឡើយ ។ ព្រោះអ្វី? ព្រោះវាចាពិត វាចាមានប្រយោជន៍ បើកាលៈទេសៈមិនអនុញ្ញាត, មិនបើក ទោះជាខំនិយាយដល់បាក់ធ្មេញអស់ក៏នៅតែគ្មានផលគ្មានចំណេញដែរ ។ ចំណុចនេះ, ត្រូវនឹងសប្បុរសធម៌ត្រង់ថា «កាលញ្ញុតា» ដែលពុទ្ធសាសនិកធ្លាប់ចេះចាំ គ្រប់គ្នាមកហើយ ។ ដូចនេះអ្នកនិយាយទាំងអស់គ្នា ប្រសិនបើចង់ឲ្យសម្ដីរបស់ខ្លួនមានតម្លៃ គប្បីត្រាប់តាមព្រះសម្មសម្ពុទ្ធ គឺកុំនិយាយត្រង់ៗចំៗ ប្រឆាំងនឹងកាលៈទេសៈ ត្រូវនិយាយគៀនៗក្បៀរៗសិន ទម្រាំកាលៈទេសៈបើក ឬអនុញ្ញាតឲ្យ សឹមនិយាយត្រង់ៗ ឬចំៗ តាមភាពពិតដែលមាននៅក្នុងទីចំពោះមុខដូចដែលព្រះសម្មាសម្ពុទ្ធបានធ្វើមកហើយ ។

## ការហ៊ានប្រឈមមុខនឹងភាពពិតកើតចាស់ឈឺស្លាប់

តាមធម្មតាមនុស្សទូទៅ មិនសូវហ៊ាននិយាយគ្នាអំពី សេចក្ដីកើតចាស់ឈឺស្លាប់ទេ ព្រោះគេប្រកាន់ថា សម្ដីនេះជាធាតុមិនល្អប្រាសចាកមង្គល ។ ដើម្បីបំបាត់នូវកម្លាចនេះ កាលណាគេនិយាយដល់ធាតុទាំងឡាយនេះគេថាខ្លួនគេកើតត្រូវថ្ងៃខែឆ្នាំល្អ គេនឹងបានរស់នៅយូរ ។ ពូជគេមានអាយុវែង ៨០ ៩០ ឆ្នាំ មិនដែលមានជម្ងឺរបេង, មិនដែលធ្លាប់ស្លាប់ដោយគ្រោះថ្នាក់ ។ ប្រពៃណីក្នុងកន្លែងខ្លះ, ហាមនិយាយគ្នាដល់ទៅរឿង កើតចាស់ឈឺស្លាប់ ដូចជាហាមសំណួរថា កើតថ្ងៃអីខែណាឆ្នាំណាសព្វថ្ងៃ មានអាយុប៉ុន្មានហើយ ធ្លាប់មានជម្ងឺអ្វីខ្លះ មើលទៅមិនទាន់អីទេឬ? គេប្រកាន់ថាពាក្យនេះគ្មានមង្គលមិនត្រូវសួរ មិនត្រូវនិយាយទេ, ពាក្យដទៃមានច្រើនដូចម៉េចមិនសួរមិននិយាយ ។ មានខ្លះភ្ញាក់ផ្អើលរហូតថា ការនិយាយគ្នាក្ដី ការគិតគូរគ្នាក្ដី ដល់ភាពកើតចាស់ឈឺស្លាប់ ពំនោលនេះ គំនិតនេះមិនល្អទេ ។ គេត្រូវនិយាយត្រូវគិតគ្នាដល់រឿងទាំងឡាយណា ដែលធ្វើឲ្យមនុស្សសប្បាយចិត្តកុំទៅនិយាយយករឿងទុក្ខ រឿងព្រួយក្ដៅក្រហាយ មកនិយាយនាំឲ្យកើត សេចក្ដីតក់ស្លុត ក្រៀមក្រំក្នុងសង្គមមនុស្សទទេៗមិនល្អឡើយ ។

ក្នុងចំណុចនេះ, អ្នកអានគួរធ្វើការពិចារណាជាមួយនឹងការកត់សម្គាល់ដូចនេះ :

បើយើងនិយាយរឿងចាស់ឈឺស្លាប់ ប្រកបដោយគំនិតតក់ស្លុត ក្រែងធាតុនេះវាចូលមកក្នុងខ្លួនយើងតាមគំនិតតាមពាក្យសម្ដី ឬក្រែងចង្រៃកើតមានដល់ខ្លួនយើង ព្រោះគំនិតសម្ដីនេះមែន ។ មតិសកលនឹងប្រកាន់យកថា

ពុទ្ធសាសនាគ្មានសច្ចធម៌, គ្មានគំនិតច្បាស់លាស់ទេ ។ អ្នកមានគំនិតសច្ចៈ, មានពំនោលទៅតាម សភាវៈពិតជាមនុស្សគ្មានមង្គល ។ ផ្ទុយទៅវិញគំនិតនិងពំនោលជាអភិណ្ហបច្ចវេក្ខណៈ នៃពុទ្ធសាសនិកវាជាមង្គល, ជាប្រភពនៃកុសលធម៌គ្មានប្រកែកបានឡើយ ។ ពិតមែនហើយ, សេចក្ដីចាស់ឈឺស្លាប់ទោះជាមានអ្នកគិត អ្នកនិយាយដល់វាក្ដី គ្មានក្ដីរបស់នេះវាមានជាធម្មតា ។ ខ្ពស់ជាងនេះទៅទៀត, ធាតុចាស់ឈឺស្លាប់ ចង់អ្នកណា ស្គាល់វាក៏ដោយមិនស្គាល់វាក៏ដោយក៏វានៅតែកើត នៅតែមានជានិច្ចនិរន្តរ៍ ។ ព្រះពុទ្ធសាសនារបស់យើងពុំបានបន្ទោសមនុស្សដល់ថ្នាក់មិនស្គាល់ធាតុទាំងឡាយនេះទេ ។ តែព្រះពុទ្ធតម្រាស់ក្នុង អភិណ្ហបច្ចវេក្ខណធម្មសូត្រនោះក្រៅពីស្គាល់ធាតុទាំងឡាយនេះ, ព្រះសម្មាសម្ពុទ្ធរបស់យើង ត្រូវការឲ្យមនុស្សមានស្មារតីមានសម្បជញ្ញៈជាធម្មបច្ចវេក្ខណៈ គឺភ្ញាក់រឭកចងចាំជានិច្ចថា ធាតុនេះជារបស់ធម្មតា, វាមិនមែនជាធាតុសម្រាប់អ្នកចង់បាប, ហើយវាក៏មិនមែនជាធាតុសម្រាប់អ្នកមិនចង់បានទេ ។ ជាមួយគ្នានេះ, ពេលវេលារបស់វា ក៏គ្មាននរណាកំណត់បាន, គ្មានអ្នកណាទស្សន៍ទាយត្រូវ ។ បុគ្គលណាមានស្មារតី, មានសម្បជញ្ញៈ មានគំនិតប្រព្រឹត្តទៅលើធាតុទាំងឡាយនេះ អស់កាលជាប់មិនដាច់ជានិរន្តរ៍ ។ បុគ្គលនោះ, ត្រូវបានពុទ្ធសាសនាឲ្យឈ្មោះថា អ្នករស់នៅក្នុងសេចក្ដីមិនប្រមាទ, រស់នៅក្នុងភាពប្រុងប្រយ័ត្ន ។ អ្នកអានគប្បីចូលចិត្តថា អភិណ្ហបច្ចវេក្ខណធម៌ដែលបង្រៀនដោយព្រះសម្មាសម្ពុទ្ធនោះពុំមែនមានន័យថា បង្រៀនឲ្យស្គាល់ទេ គឺមានន័យថា បង្រៀនឲ្យមានស្មារតីចងចាំ មានគំនិតត្រិះរិះ, មានសម្បជញ្ញៈបច្ចវេក្ខណៈគ្រប់ពេល ។ កាលណាគេមានស្មារតី ចងចាំនូវដំណើរ វិវត្តរបស់ធម្មជាតិពីដំណាក់មួយទៅដំណាក់មួយ, គេមុខតែឆ្លៀតឱកាសបំពេញបុណ្យ កុសលក្នុងវ័យក្មេង ឬវ័យកណ្ដាល គេនឹងមិនបណ្ដោយខ្លួនឲ្យខករហូតដល់បច្ឆិមវ័យឡើយ ។ គួរកត់សម្គាល់ថា អភិណ្ហបច្ចវេក្ខណៈមិនមែន ជាធាតុសម្រាប់រំដោះសេចក្ដីចាស់ឈឺស្លាប់ភ្លាមៗទេ ។ តែជាធាតុធ្វើឲ្យបច្ចវេក្ខណបុគ្គលចាកផុតសេចក្ដីចាស់ឈឺ ស្លាប់ក្នុងអនាគតកាលបានដល់ទីបំផុតទុក្ខដោយកម្លាំងបុណ្យបារមី ដែលគេសាងបន្តិចម្ដងៗ នៅក្នុងក្របខ័ណ្ឌនៃ សេចក្ដីភ្ញាក់រឭកហ្នឹងឯង ។ កំណត់សម្គាល់ជ្រៅជាងនេះ, គឺសេចក្ដីចាស់ឈឺស្លាប់ វាជាធាតុមិនល្អ មិនត្រូវចិត្តមនុស្សយើងពិតៗ តែបើយើងមានគំនិតប្រកបដោយពន្លឺ យើងក៏អាចរកប្រយោជន៍អំពីរបស់មិនល្អនេះបាន យ៉ាងច្រើនជាមិនខាន ប្រសិនបើយើងមានគំនិតបញ្ញាធួនល្មម ។ ព្រះសម្មាសម្ពុទ្ធធ្លាប់មានព្រះតម្រាស់ថា បើគ្មានបញ្ហាកើតចាស់ឈឺស្លាប់ចោទក៏គ្មានព្រះពុទ្ធទាំងឡាយត្រាស់ក្នុងលោក គ្មានបណ្ឌិតអ្នកប្រាជ្ញ គ្មានទស្សនវិទូបញ្ចេញពន្លឺ, ឲ្យទស្សនៈនានាៗដែរ ។ បើនិយាយតាមសំនួនវោហារម៉្យាងទៀតថា ព្រះពុទ្ធរបស់យើង ទាំងឡាយ មួយអន្លើដោយអ្នកប្រាជ្ញ និងទស្សនវិទូជាទូទៅបាន ស្រាវជ្រាវរាវរកប្រយោជន៍មានតម្លៃខ្ពង់ខ្ពស់ឃើញ ក៏ព្រោះមានភាពកើតចាស់ឈឺស្លាប់នេះក៏រិតតែត្រូវ ។ ព្រោះអ្វី? ព្រោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គរកឃើញភាពមិនកើតនៅក្នុងកំណើត រកឃើញភាពមិនចាស់នៅក្នុងភាពចំណាស់ រកឃើញភាពឈឺនៅក្នុងជម្ងឺ រកឃើញភាពមិនស្លាប់នៅ ក្នុងភាពស្លាប់, ដូចជាគេរកឃើញភាពស្អុយនៅក្នុងរាងកាយដែលមិនស្អុយអញ្ចឹងដែរ ។ ព្រោះហេតុដូចនេះ, ការមានសេចក្ដីអង់អាចក្លាហាន ហ៊ានប្រឈមមុខនឹងភាពពិតគ្រប់យ៉ាង មិនមែនជាការអួតហ៊ានអួតល្អរបស់ អ្នកស្វែងប្រយោជន៍ជាន់ខ្ពស់ទេ, តែជាការតស៊ូរុករកប្រយោជន៍ដែលមាននៅក្នុងភាពពិត ដែលសត្វលោកមិនពេញចិត្ត, មិនចង់ជួបប្រទះ ។ ដូចនេះទំរើប្រឈមមុខជាមួយនឹងភាពពិត ឬអនុវត្តសេចក្ដីព្យាយាមតាមភាពពិតរបស់បុគ្គលអ្នក ប្រតិបត្តិធម៌ទើបមិនមែនជាទំរើអាក្រក់ឬជាធាតុដែលអ្នកផងចូលចិត្តថា គ្មានមង្គលឡើយ ។

បញ្ហាមួយទៀត, ដែលគេត្រូវស្រាយជាប្រញាប់ដែរនោះ គឺបញ្ហាដែលយើងមកកើតក្នុងលោក មានពេលរស់នៅមិនយូរប៉ុន្មានយើងនឹងស្លាប់ ។ យើងគួរស្វែងសុខ ស្វែងកម្មល្អ ឲ្យបានច្រើនបំផុតតាមដែលយើងអាចធ្វើកើតឲ្យហើយទៅ ។ យើងមិនត្រូវបណ្ដែតបណ្ដោយឲ្យខាតពេល ដោយសម្លឹងមើលលោក ប្រកបដោយគំនិតទុដ្ឋិនិយម

នាំឲ្យភាពអស់អែកស្ទាក់ស្ទើរ កើតឡើងក្នុងចិត្តហើយរស់នៅទទេៗ គ្មានបានប្រកបអាជីវកម្មអ្វី ជាដុំកំភួនសម្រាប់រស់នៅក្នុងលោកនេះឲ្យបានស្រួល, គ្មានបានបំពេញបុណ្យកុសល សម្រាប់ជាមិត្តរបស់ខ្លួនក្នុងពេលស្លាប់ ។ តើគេត្រូវរស់ក្នុងលក្ខណៈណា នៅលើពិភពនៃមនុស្សនេះ? ចម្លើយ : គេមិនត្រូវឃើញសេចក្តីកើតចាស់ឈឺស្លាប់នៅក្នុងគំនិតជាទុទិដ្ឋិនិយមទេ, តែគេត្រូវឃើញនៅក្នុងគំនិតជាសុទិដ្ឋិនិយម ឬពាក់កណ្តាលនៃទិដ្ឋិទាំងពីរ, ព្រោះព្រះសម្មាសម្ពុទ្ធរបស់យើង បានមានព្រះតម្រាស់ថា «ជីវិតមនុស្សលំបាក» »តែកំណើតមនុស្ស ជាលាភ» ក្នុងចំណុចនេះគឺព្រះអង្គចង់និយាយថា ជីវិតរបស់មនុស្សមានសេចក្តីលំបាកពិត, តែសេចក្តីលំបាក នេះមិនមែនគ្មានផ្លូវដោះស្រាយទេ ។ ជាមួយគ្នានេះទៀត, ព្រះពុទ្ធអង្គមានតម្រាស់ថា «កំណើតមនុស្សគេមិនងាយ នឹងរកបាន» ក្នុងចំណុចនេះព្រះអង្គចង់និយាយថា មានតែកំណើតមនុស្សមួយទេ ដែលជាកំណើតមានតម្លៃខ្ពង់ខ្ពស់ ជាងកំណើតទាំងអស់, ជាកំណើតគួរដល់ការងារ, គួរដល់មគ្គផលនិព្វាន ។ ការរស់នៅក្នុងលោកជាមួយនឹងគំនិត សុទិដ្ឋិនិយម យើងអាចប្រៀបបាននឹងនិស្សិតពេទ្យ, ការសិក្សាវិជ្ជាពេទ្យ គេត្រូវតែមានសេចក្តីអង់អាចក្លាហាន ហ៊ានប្រឈមមុខជាមួយនឹងភាពពិតនៃលក្ខណៈនៃអាការៈរបស់រោគនាៗ យ៉ាងម៉ឺងម៉ាត់មិនត្រូវរុញរាមិនត្រូវ ច្រិមច្រុមក្នុងកិច្ចប្រតិបត្តិការដែលមានចែងក្នុងទ្រឹស្តី គឺហ៊ានដេកនៅក្នុងបន្ទប់ខ្មោច ដើម្បីធ្វើការវះកាត់បញ្ជាក់ទ្រឹស្តី បញ្ជាក់គំនិតរបស់ខ្លួនក្នុងការពិសោធសេចក្តីពិត ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវតាមគំនោលនៃវិជ្ជាប្រភេទនេះ ។ល។ ការសិក្សាវិជ្ជាពេទ្យគេត្រូវមានចិត្តក្លាហាន ហ៊ានប្រឈមមុខជាមួយនឹងភាពពិតនៃវត្ថុវិទ្យាសាស្ត្រ ដើម្បីផ្តល់ សេចក្តីសុខដល់មនុស្សលោកយ៉ាងណាមិញ ។ ការប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនាក៏ត្រូវមានចិត្តក្លាហាន ហ៊ានប្រឈមមុខជាមួយនឹងភាពពិតនៃវត្ថុធម្មជាតិចាស់ឈឺស្លាប់ដើម្បីទាញយកប្រយោជន៍ពីវត្ថុទាំងអស់នេះ តាំងពីតូចៗ រហូតដល់ធំ បំផុតគឺមគ្គផលនិព្វាន ។ ម៉្យាងទៀត, ពាក្យថាឃើញលោកប្រកបដោយ គំនិតជាទុទិដ្ឋិនិយម (PESSIMISM) នោះលោកបានឲ្យន័យថា មិនឃើញមានផ្លូវដោះស្រាយ, ចំពោះតែមនុស្សមួយពួកដែល ឃើញនេះក៏ទុក្ខឃើញនោះក៏ទុក្ខ, តែគ្មានគំនិតបញ្ញាបង្កើតសុខនៅក្នុងទុក្ខ ឬគ្មានមធ្យោបាយធ្វើទុក្ខឲ្យទៅជា សុខ ។ ដូចនេះ, អ្នកប្រាជ្ញពុទ្ធសាសនាខ្លះ ដែលលោកមានយោបល់ថា គំនោលធម្មៈនៃពុទ្ធសាសនា ជាធាតុមាន ភាពនៅក្នុងចន្លោះកណ្តាល ឬជាមជ្ឈិមបដិបទា គឺមិនមែនជាសុទិដ្ឋិនិយម (OPTIMISM) និងមិនមែនជា ទុទិដ្ឋិនិយម (PESSIMISM) គឺមិនឃើញលោកនៅក្នុងភាពអាក្រក់ និងមិនឃើញលោកនៅក្នុងភាពល្អ ។ យោបល់ របស់លោកនេះគឺ ត្រឹមត្រូវណាស់ដែរ ។ ព្រោះអ្វី? ព្រោះថាលោក, បើគេអនុវត្តត្រូវក៏មាន លទ្ធផលល្អ បើគេអនុវត្ត ខុសក៏បានលទ្ធផលអាក្រក់ ។

## **ឫក្សយាម**

ព្រះសម្មាសម្ពុទ្ធ, មានសេចក្តីក្លាហានប្រកាសយ៉ាងត្រង់ៗចំៗដល់អ្វីដែលព្រះអង្គហៅថា **«ឫក្សយាម»** ឲ្យចូលក្នុង គំនោលនៃធម្មៈរបស់ព្រះអង្គមានដូចនេះ :

១- មនុស្សល្ងង់ខ្លៅ គេប្រកាន់យកនូវឫក្សយាមជាធំ ។ ប្រយោជន៍គ្រប់បែបយ៉ាងរបូតអស់រលីង ពីដៃរបស់គេ គេចាប់មិនទាន់ព្រោះតែគំនិតរបស់គេយល់ខុស ។ គេយល់ថា ប្រយោជន៍ទាំងឡាយកើតមានឡើងដោយអាស្រ័យដួងផ្កាយ, តើផ្កាយបានផ្តល់ប្រយោជន៍អ្វីខ្លះដល់មនុស្ស ប្រសិនបើមនុស្សខ្លួនឯងមិនព្រមធ្វើការងារ ។

២- សត្វលោកបានប្រព្រឹត្តល្អដោយកាយវាចាចិត្តក្នុងពេលព្រឹក, ពេលព្រឹកនោះជាពេលល្អរបស់សត្វអស់ទាំងនោះ ។ ប្រព្រឹត្តល្អដោយកាយវាចាក្នុងថ្ងៃត្រង់, ពេលថ្ងៃត្រង់នោះជាយាមល្អរបស់សត្វទាំងឡាយនោះ ។ ប្រព្រឹត្តល្អដោយកាយ វាចាចិត្តក្នុងពេលល្ងាច, ពេលល្ងាចនោះជាពេលល្អរបស់សត្វទាំងអស់នោះ ។

បើស្តីតាមល័ខគោលនៃពុទ្ធសាសនា មនុស្សយើងមិនត្រូវគិតគូរដល់ឫក្សយាម (ពេលថ្ងៃខែឆ្នាំ) ឡើយ ។

មនុស្សនាំគ្នា ធ្វើការប្រកបដោយសុចរិតធម៌ទៅក៏ហើយគ្នាប៉ុណ្ណឹងហើយ ។ តែបើឲ្យស្រួលជាងនេះទៀត, គេត្រូវកុំខ្ជីរវល់ជាមួយមនុស្សប្រកាន់ពេលវេលា, អ្នកនិយមជឿពេលវេលា គេចង់ធ្វើអីស្រេចនឹងគេចុះ ។ បញ្ហានៅត្រង់ថា អ្នកណាមានគំនិតប្រកបដោយពន្លឺ មានចិត្តរឹងប៉ឹងមាំមួន មានសេចក្ដីព្យាយាមមោះមុតអ្នកនោះគេឈប់រវល់ពីឫក្សយាម គេគ្រវែងចោលនូវភាពសេះសុញ្ញ ដែលបណ្ដាលមកពីគិតគូរដល់ពេលល្អ ពេលអាក្រក់ដោយគ្មានអាឡោះអាល័យបន្តិចបន្តួចឡើយ ។

នៅក្នុងសង្គមមនុស្សយើង, មានជនខ្លះបានអានក្បួនតម្រា ឬប្រក្រតីទិនមហាសង្ក្រានប្រចាំឆ្នាំ (ក្នុងសម័យបូរាណ) ឃើញមានសំនេរក្នុងរឿងសង់ផ្ទះថ្មី, រោងការ, រោងធ្វើបុណ្យ, ដំណើរចេញជួញ, ដំណើរចេញច្បាំង, ទំរើកាត់សក់កាត់ក្រចក ។ល។ ហាមសង់ផ្ទះថ្ងៃនេះថ្ងៃនោះ កាត់កោរថ្ងៃនេះថ្ងៃនោះ ។ល។ តែក្រោយមក, អ្នកប្រកាន់ក្បួន, អ្នកមានជំនឿក្នុងរឿងទាំងឡាយនេះ បានសាកល្បងធ្វើក្នុងថ្ងៃដែលក្បួនហាម ដោយប្រើគំនិតត្រិះរិះគំនិតហេតុផលមួយនិងភាពក្លាហានរបស់ខ្លួន, ទាត់ចោលនូវជំនឿខុសនិងជោគវាសនាប្រសេកប្រសាចគ្រប់បែបយ៉ាង ។ ទំរើខុសក្បួនរបស់គេ, ក៏គ្មានឃើញបណ្ដាលឲ្យមាន គ្រោះថ្នាក់អ្វីសូម្បីបន្តិចបន្តួចឡើយ ។

ពុទ្ធពំនោលត្រង់ៗចំៗដូចនេះ, អ្នកប្រកាន់ឫក្សយាមយ៉ាងចាស់ដៃគេមិនពេញចិត្តទេ ។ តែអ្នកប្រាជ្ញទាំងឡាយខ្លះក្នុងព្រះពុទ្ធសាសនា ដែលខ្ញុំបានរស់នៅជាមួយនិងលោក លោកមានគំហើញថា រឿងនេះនៅមានផ្លូវសម្របសម្រួលគ្នាបាន ។ ព្រោះអ្វី? ព្រោះពុទ្ធសាសនា មានវត្តប្រតិបត្តិច្រើនជាន់ច្រើនស្រទាប់ណាស់, ប្រសិនបើអ្នកប្រតិបត្តិធម៌ចង់លើកយកជាន់ណា ស្រទាប់ណាមកអនុវត្តក៏អាចធ្វើបាន ស្រេចហើយតែសេចក្ដីប្រាថ្នារបស់ខ្លួន គឺអ្នកណានិយមឫក្សយាមក៏អនុវត្តការងារតាមឫក្សយាមទៅ, អ្នកណានិយមកម្មផល, ក៏ធ្វើបុណ្យទាននៅក្នុងគំនិតប្រកបដោយហេតុផលទៅ ។ អ្នកទាំងពីរគង់ត្រូវបានជួប គំនិតគ្នាក្នុងពេលណាមួយមិនខាន ប្រសិនបើគេមានគំហើញថា ជីវិតរបស់មនុស្សគឺជាការងារ ។ ដូចនេះ, អ្នកប្រកាន់យកឫក្សយាមជាធំ ក៏មកពីមានគំនិតចង់ឲ្យការងាររបស់ខ្លួនមានគុណភាព មានបរិមានគួរជាទីពេញចិត្ត ។ អ្នកប្រកាន់យកហេតុផលជាធំ ក៏មកពីមានបំណងចង់ឲ្យទំរើរបស់ខ្លួនបានដល់ទិសដៅ គឺវឌ្ឍនភាពនិងគុណភាពយ៉ាងទូលំទូលាយ ។ ព្រះបរមគ្រូ, មិនហាមអ្នកឫក្សយាមមិនឲ្យប្រតិបត្តិធម៌របស់ព្រះអង្គទេ, តែព្រះអង្គបានពន្យល់ថា ការងារល្អជាឫក្សយាមល្អរបស់មនុស្ស ។ ព្រះពុទ្ធតម្រាស់នេះ យើងអាចបកស្រាយបានថា ព្រះអង្គបានទទួលស្គាល់ បានទទួលយល់ព្រមថា ការងារល្អគឺជាឫក្សយាមល្អរបស់សត្វ ។ ក្នុងន័យថា ភាពល្អអាក្រក់របស់សត្វនៅលើការងារអាក្រក់ល្អ, ពុំមែននៅលើឫក្សយាម (ពេលថ្ងៃខែឆ្នាំ) ឡើយ ។ ប៉ុន្តែព្រះសម្មាសម្ពុទ្ធរបស់យើង បានទទួលយល់ព្រមឲ្យអ្នកប្រកាន់ឫក្សយាមចូលខ្លួនមកធ្វើជាពុទ្ធសាសនិក ប្រតិបត្តិធម៌វិន័យរបស់ព្រះអង្គដែរ ។ សេចក្ដីនេះ, បញ្ជាក់ឲ្យឃើញថា, ពុទ្ធសាសនាគ្មានគោលធម៌អ្វីក្រៅពីអរិយសច្ចៈ, ការងារ, ហេតុផលដូចដែលយើងធ្លាប់ចេះចាំមកហើយឡើយ ។ តែដោយអាស្រ័យព្រហ្មវិហារធម៌, ពុទ្ធសាសនាព្រមទទួលមនុស្សពីគ្រប់មជ្ឈដ្ឋាន ឲ្យធ្វើពុទ្ធសាសនិក ប្រសិនបើស្ម័គ្រចិត្តធ្វើ ព្រោះពុទ្ធសាសនាមានធម៌ថ្នាក់ទាប, កណ្ដាល, ខ្ពស់សម្រាប់ពុទ្ធសានិកប្រតិបត្តិ ឬអនុវត្តនៅក្នុងក្របខ័ណ្ឌនៃចំណូលចិត្ត នៃឧបនិស្ស័យរបស់ខ្លួនបណ្ដើរៗ ។

ក្នុងទីបំផុតគេអាចទម្លាក់ចោលធម្មៈគ្មានហេតុផល ហើយប្រកាន់យកនូវធម្មៈមានហេតុផលវិញដោយអាស្រ័យដោយគំនិតថ្មីរបស់ពុទ្ធសាសនា ដែលខ្លួនគេបានមករស់នៅជាមួយ ក្នុងពេលណាដែលគំនិតរបស់គេមានពន្លឺគ្រប់គ្រាន់ ។ ប្រសើបើមានបញ្ហាចោទថា អ្នកប្រកាន់ឫក្សយាមប្រតិបត្តិធម្មៈនៃពុទ្ធសាសនាមិនបាន ព្រោះមិនព្រមលះបង់ជំនឿចាស់ ឬប្រពៃណីនិយមពេលល្អអាក្រក់នោះ ។ យើងត្រូវឲ្យចម្លើយថា ឫក្សយាមបើគេមានចិត្តរឹងប៉ឹង អង់អាចក្លាហានគ្រវែងចោលភ្លាមៗបាននោះ, ជាទំរើមួយ មានគុណភាពប្រសើរខ្ពង់ខ្ពស់ណាស់ ។ តែបើ

គេកាត់ចោលមិនទាន់បាន ក៏គង់ប្រតិបត្តិធម៌ ឬកាន់ពុទ្ធសាសនាបានដែរ ។ ព្រោះអ្វី? ព្រោះរឿងមិនសមស្រប នឹងផលប្រយោជន៍ ឬមិនល្អពុំមែនមានត្រឹមឫក្សយាមប៉ុណ្ណឹងទេ ។ រឿងក្រៅពីនេះ, ដែលពុទ្ធសាសនាថាមិនល្អ, គ្មានប្រយោជន៍ក៏មានច្រើនដែរ ដូចសេចក្តីលោភ សេចក្តីក្រោធ សេចក្តីវង្វេងការប្រកាន់ខ្លួនប្រាណ ។ល។ ដែលពុទ្ធសាសនាតម្រូវឲ្យយើងលះបង់ចោល, យើងគ្មានលះបង់កើតទេ ហើយយើងនៅតែប្រតិបត្តិធម៌បាន នៅតែធ្វើជា ពុទ្ធសាសនិកកើត ។ ព្រះសម្មាសម្ពុទ្ធរបស់យើងព្រះអង្គជ្រាបថា ការធ្វើកំណែនជាទូទៅឲ្យមនុស្ស ហ្វឹកហាត់ចិត្ត ឲ្យមានភាពបរិសុទ្ធ មានការប្រព្រឹត្តល្អដោយកាយវាចាដូចគ្នាទាំងអស់, ទំរើនេះវាពុំអាចទៅបានទេ ។ សេចក្តីពិត, ការបង្កើត ឬប្រតិស្ថានពុទ្ធសាសនាទុកក្នុងលោក ក៏មិនមែនធ្វើឡើងសម្រាប់បុគ្គលពិសេស ឬបុគ្គល មានឧបនិស្ស័យខ្ពស់ទេ ។ ព្រោះអ្វី? ព្រោះមនុស្សមានធម៌ខ្ពស់ បានសម្រេចនិព្វានអស់ទៅហើយ គ្មានការចាំបាច់អ្វី នឹងប្រតិស្ថានពុទ្ធសាសនាទុកទៀតទេ ។ តែព្រោះមានជន ច្រើនប្រភេទ ដែលនៅមានកិលេសញាំញីសន្តានចិត្ត, មានអវិជ្ជាបិទបាំងគំនិត ទើបត្រូវតាំងត្រូវប្រតិស្ថានឲ្យមានពុទ្ធសាសនានៅក្នុងលោកសម្រាប់ដុះខាត់ ចិត្តវិញ្ញាណ របស់គ្នាឲ្យកើតភាពស្អាតបរិសុទ្ធ, ភាពភ្លឺស្វាង, ភាពស្ងប់ស្ងាត់ដើម្បីបានសម្រេច និព្វានក្នុងអនាគតកាល ។ គំនិត ពុទ្ធសាសនាត្រូវការសណ្តោងមនុស្សតាំងពីថ្នាក់ទាប ឲ្យបានរស់នៅក្នុងថ្នាក់កណ្តាល ពីថ្នាក់កណ្តាល, ឲ្យដល់ថ្នាក់ ខ្ពស់ជាបន្តបន្ទាប់គ្នា ។ ប្រសិនបើពុទ្ធសាសនា ជួយស្រោចស្រង់តែមនុស្សមានពន្លឺ កាត់កាល់ចោល មនុស្សគ្មានពន្លឺ ពុទ្ធសាសនាក៏ក្លាយទៅជាសាសនាគ្មានន័យ, គ្មានប្រយោជន៍សម្រាប់មនុស្សលោកឡើយ ។ ដូចនេះ, បញ្ហា ឫក្សយាម ប្រសិនបើគេប្រកាន់ក៏វាគ្មានបណ្តាលឲ្យមានគ្រោះថ្នាក់ជាធំដុំ ឬមានបាបអកុសល ឬមានទោសធ្លាក់នរក ណាមួយទេ ។ តែបើគេមានចិត្តក្លាហានដកជំនឿ, ដកកំណាន់របស់គេបានភ្លាមៗ ក៏ជាទំរើ មួយប្រសើរបំផុត រកអ្វីប្រៀបផ្ទឹមគ្មាន នៅក្នុងជីវិតអន្ទោលរបស់មនុស្ស ។

នៅក្នុងពិភពលោកយើងនេះ, មានមនុស្សខ្លះនៅមានការជំពាក់ចិត្តគាំទ្រឫក្សយាម ដោយសម្តែងជំនឿផ្អែក លើវិទ្យាសាស្ត្រថា ដួងផ្កាយទាំងឡាយដែលមាន នៅក្នុងផ្ទៃមេឃជាធាតុមានរចនាសម្ពន្ធជាមួយមនុស្សសត្វ និងពិភពលោកយើងយ៉ាងច្រើន ដូចព្រះចន្ទមានមានការទាក់ទងជាមួយនឹងទឹកឡើងចុះ (ជោរនាច) ជាមួយនឹង រដូវរបស់ស្ត្រី ។ល។ ធាតុផ្សេងៗក្នុងដួងផ្កាយរមែងមានរចនាសម្ពន្ធជាមួយនឹងធាតុនានាក្នុងលោកយើង, ក្នុងរាងកាយរបស់មនុស្សដែលអាស្រ័យនៅលើពិភពលោក ។ ចំណុចរលត់ក្នុងដួងអាទិត្យដែលមានឈ្មោះថា SUNSPOT រមែងធ្វើឲ្យកើតខ្យល់ព្យុះមេដែកនៅក្នុងលោកយើង ជាឧបសគ្គដល់ការបញ្ជូនរលកវិទ្យុផ្សាយសំឡេង ។ល។ ដូចនេះ, ឥទ្ធិពលរបស់ដួងផ្កាយប្រហែលជាមានមែន បើតាមការស្រាវរបស់អ្នកប្រាជ្ញប្រភេទនេះ ។ ក្នុងគម្ពីរ ពុទ្ធសាសនាខ្លះ ក៏មាននិយាយអំពីរឿងផ្កាយនេះដែរ, ទោះនិយាយតាមតម្រារបស់ ព្រាហ្មណ៍ក៏ដោយ ។ ដូចមាន សំនេររបស់ព្រះពុទ្ធឃោសាចារ្យក្នុងគម្ពីរធម្មបទថា : មានតាបសពីរនាក់ជាមិត្តនឹងគ្នានៅអាស្រ័យ លើកំពូលភ្នំមួយ ម្នាក់ ។ ថ្ងៃមួយតាបសម្នាក់, បានដឹងថា តាបសម្នាក់ទៀតដែលជាមិត្តរបស់ខ្លួនបានធ្វើមរណៈកាល ដោយអាស្រ័យ ការពិនិត្យមើលដួងផ្កាយប្រចាំជីវិតនៃតាបសនោះឃើញសញ្ញាអាប់រស្មី ។ ហេតុនេះ, ការប្រកាន់ឫក្សយាមនឹងថា គ្មានហេតុផលបន្តិចបន្តួចសោះ ក៏ដូចជាមិនទាន់មែនដែរ ។ គួររង់ចាំមើលការពិសោធ របស់អ្នកតារាសាស្ត្រដែល គេកំពុងសាងគ្រឿងប្រដាប់ពិសេសៗសម្រាប់ធ្វើការស្រាវជ្រាវក្នុងផ្ទៃអាកាស, ក្នុងមណ្ឌលសុរិយចក្រវាឡ ដើម្បី បញ្ជាក់នូវសេចក្តីពិតក្នុងរឿងនេះថ្មីទៀតដូចយើងកំពុងចម្រើនកម្មដ្ឋាន ដើម្បីបញ្ជាក់នូវធម៌មានអាថ៌កំបាំងដែល មាននៅក្នុងទ្រឹស្តីកម្មដ្ឋាន គឺឈានហ្នឹងឯង ដែរ ។

ដើម្បីជាពន្លឺដល់គំនិតអ្នកអានភ្លាមៗ ក្នុងរឿងដដែលនេះ, ខ្ញុំសូមឲ្យចម្លើយថា បើតាមពំនោលធម្មៈនៃ ពុទ្ធសាសនា ចំណុចទិសដៅ ឬគំហើញដែលមនុស្សប្រកាន់យកជារឿងមួយផ្សេង ពុទ្ធធម៌ជារឿងមួយផ្សេង,

ពុទ្ធសាសនាត្រូវការឲ្យមនុស្សធ្វើ សេចក្តីល្អ ដោយមិនចាំបាច់ត្រូវអាស្រ័យហេតុខាងក្រៅ ឬគឺឫក្សយាមទឡើយ ។ ពុទ្ធសាសនាបញ្ជាក់ថា : ចិត្តជាប្រធានលើទំរើទាំងឡាយ កុសលចិត្តជាប្រធានរបស់បុណ្យ អកុសលចិត្តជាប្រធានរបស់បាប កាលណាចិត្តត្រូវបានហ្វឹកហាត់អប់រំល្អហើយ ភាពល្អរបស់ចិត្តវាជាមូលដ្ឋាននៃកុសលធម៌ វាទាក់ទាញឲ្យអ្វីៗនៅជាមួយនឹងវា ឬជុំវិញវាបានល្អដូចវាផង ដូចយើងដឹងគ្រប់គ្នា ថាចិត្តល្អ កាយក៏ល្អ វាចាក៏ល្អ កើតឡើងជាបន្តបន្ទាប់គ្នា កាលបើចិត្តល្អកាយល្អវាចាល្អអស់ហើយ ទំរើរបស់កាយវាចាចិត្តម៉េចនឹងទៅជាមិនល្អកើត គឺវាត្រូវតែល្អហ្នឹងឯង ។ តួយ៉ាងដូចជាព្រះពុទ្ធ ព្រះអង្គមានភាពស្អាតបរិសុទ្ធ, ភាពស្ងប់ស្ងាត់, ភាពត្រជាក់ត្រជុំ ភាពភ្លឺស្វាងនៅក្នុងព្រះទ័យ ។ ធាតុល្អទាំងឡាយនេះ, ក្រៅពីផ្តល់សេចក្តីរុងរឿងថ្លៃថ្នូរឲ្យខ្លួនព្រះអង្គផ្ទាល់ដោយចំធាតុដដែលនេះវាបានធ្វើឲ្យកន្លែងប្រសូត កន្លែងត្រាស់ដឹង កន្លែងនិព្វានរបស់ព្រះអង្គ នៅជាកន្លែងគោរពសក្ការៈបូជាទៀតផង ។ ថ្ងៃប្រសូត ត្រាស់ដឹង និព្វានទៅជាថ្ងៃវិសាខបូជាមានភាពរុងរឿង ដែលគេចាត់ទុកជាថ្ងៃសំខាន់របស់ពិភពលោក ។ ដុំថ្ម, ដុំឥដ្ឋ, ដុំដី, លោហធាតុ, ស្ពាន់សំណ, ឆ្អឹងសត្វ, ភ្លុងដំរី, កំណាត់ឈើ ។ល។ ដែលគេយកមកឆ្លាក់ ឬសូន្យធ្វើព្រះពុទ្ធរូប បានក្លាយទៅជារបស់គួរដល់ការគោរពបូជាក្រាប សំពះនមស្ការ ។ តើអ្វីទាក់ទាញចិត្តមនុស្សឲ្យមានជំនឿ ឲ្យគោរពបូជា? គ្មានអ្វីដទៃទេ គឺសេចក្តីល្អបរិសុទ្ធរបស់ព្រះសម្មាសម្ពុទ្ធ ធាតុនេះបានទាក់ទាញចិត្តបានធ្វើឲ្យវត្ថុទាំងឡាយ មានដុំថ្មជាដើមក្លាយទៅជាល្អ, ជាវត្ថុមានតម្លៃប្រសិនបើព្រះពុទ្ធ ព្រះអង្គគ្មានវិសុទ្ធគុណ បញ្ញាគុណ ករុណាគុណនៅក្នុងព្រះអង្គ កន្លែងប្រសូតក្តី ត្រាស់ដឹងក្តី និព្វានក្តី ព្រះពុទ្ធរូបទាំងឡាយក្តីក៏ពុំអាចទៅជាវត្ថុគួរដល់ការគោរពសក្ការៈបូជាឡើយ ។ ក្នុងពេលសព្វថ្ងៃនេះ, បើគេល្បងប្រើគំនិតពិចារណានៅក្នុងក្របខ័ណ្ឌនៃហេតុផល គេមុខនឹងបានឃើញថា មានមនុស្សច្រើនណាស់ដែលមានថ្ងៃខែឆ្នាំកំណើតត្រូវនឹងព្រះពុទ្ធ, តែមនុស្សទាំងឡាយនោះ គ្មានបានត្រាស់ជាព្រះពុទ្ធ, គ្មានឃើញបានសម្រេចគុណធម៌អ្វីសម្រាប់ទាក់ទាញចិត្តមនុស្សឲ្យមានជំនឿ, ឲ្យកោតសរសើរ, ឲ្យធ្វើសក្ការៈបូជាដូចព្រះពុទ្ធបានឡើយ ។ ដើម្បីគាំទ្រនូវសច្ចធម៌, យើងអាចនិយាយតាមហេតុផលខាង ហោរាសាស្ត្រក្នុងចំណុចថា មនុស្សកើតថ្ងៃខែឆ្នាំត្រូវគ្នា, តែខុសពេលគ្នា សូម្បីបន្តិចបន្តួចក៏ត្រូវតែរស់នៅក្នុភាពផ្សេងគ្នាដែរ ។ នេះគ្រាន់តែជាសម្តីយករួចខ្លួនទេ ប្រសិនបើគេសួរត្រង់ៗចំៗថា តើពិតឬមិនពិតសម្តីថា ឫក្សយាមសាងសេចក្តីល្អឲ្យមនុស្ស សាងសេចក្តីសម្រេចឲ្យអ្នកមានជំនឿ ។ ចំពោះសំណួរនេះ, អ្នកហោរាសាស្ត្រក្តី អ្នកប្រកាន់ឫក្សយាមក្តី មិនសូវឲ្យចម្លើយចំៗត្រង់ៗតាមប្រធានទេ ច្រើនតែចាកប្រធានហើយគ្មានកន្លែងចប់ ទៀតផង ។ គឺវាមិនពិតដូចគំនោលធម្មៈនៃពុទ្ធសាសនាដែលស្តីថា សេចក្តីល្អអាក្រក់ ឬកុសលកម្ម អកុសលកម្មដែលមនុស្សបានធ្វើបានប្រព្រឹត្ត ជាធាតុរចនាតាក់តែង មនុស្សឲ្យរស់នៅក្នុងកម្រិតខ្ពស់ទាប ឬឲ្យមានជីវភាពផ្សេងៗគ្នា ។

ដោយអាស្រ័យហេតុនេះ, យើងត្រូវពិចារណាដល់រឿងព្រហ្មលិខិត ដែលមានចែងក្នុងសាសនាព្រាហ្មណ៍ធៀបគ្នានឹងកម្មលិខិត ដែលមានចែងក្នុងពុទ្ធសាសនារបស់យើង ឲ្យបានច្បាស់លាស់ជាថ្មីទៀតទៅ ។ ខាងព្រាហ្មណ៍គេមានជំនឿថា សេចក្តីអាក្រក់ល្អរបស់មនុស្សត្រូវលិខិត (គូស) ដោយព្រះព្រហ្មនៅត្រង់ថ្ងាសរបស់មនុស្សគ្មាននរណាកែបានក្រៅពីព្រះព្រហ្មខ្លួនឯង ។ ចំណែកពុទ្ធសាសនាប្រកាន់ថា សេចក្តីអាក្រក់ល្អរបស់ មនុស្សត្រូវលិខិត (គូស) ដោយកម្មអាក្រក់ល្អដែលមនុស្សខ្លួនឯងជាអ្នកសាង ។ អ្នកធ្វើកម្មល្អបានផលល្អ អ្នកធ្វើកម្មអាក្រក់បានផលអាក្រក់ ។ ដូចនេះ, ទើបគេឃើញមនុស្សមានលក្ខណៈខុសគ្នា, ខ្លះមានរូបល្អ ខ្លះមានរូបអាក្រក់ ខ្លះមានបញ្ញាច្រើន ខ្លះមានបញ្ញាតិច ។ល។ នៅក្នុងរឿងដដែលនេះមានពេលខ្លះកម្មផលរបស សត្វអាចត្រឡប់គំនូសខ្មៅទៅជាស, សទៅជាខ្មៅវិញក៏មានខ្លះដែរ ។ ការប្រែត្រឡប់ខុសធម្មតារបស់កម្មនេះ វាជារបស់មានអាថ៌កំបាំងលំបាកចូលចិត្តពន់ពេកណាស់ ។ ពុទ្ធសាសនា, បានពន្យល់ថា ការដើរខុសទិសរបស់កម្ម មកពីមានវិបត្តិ

ខាងផ្លូវចិត្តខ្លះ មកពីមនុស្សម្នាក់បានធ្វើកម្មខ្មៅផង កម្មសផងខ្លះ ។ ជ្រៅជាងនេះ, លោកថា មនុស្សបុថុជ្ជនពុំអាចចៀសវាងវិបត្តិបានទេ ព្រោះកុសលចិត្តជាកាមាវចរក្តី រូបាវចរក្តី អរូបាវចរក្តី សុទ្ធតែជាចិត្ត នៅមានការប្រែប្រួលមិនទាន់មានលំនឹងទៀងទាត់ដូចលោកុត្តរចិត្ត របស់អរិយជនដែលមានលំនឹងមាំមួន, មានជំហរ លើអរិយមគ្គអរិយផល, មានពលានុភាពយ៉ាងខ្លាំងក្លាដែលសន្តានមនុស្សសាមញ្ញមិនទាន់បានជួបប្រទះ ។ ក្នុងន័យថា : មានតែអរិយបុគ្គលទេដែលកម្មរបស់លោកគ្មានវិបត្តិ ។ អ្នកសិក្សាខាងហោរាសាស្ត្រ, គេខំពន្យល់ថា ដួងផ្កាយឬផ្ទៃមេឃធាតុនេះមានលក្ខណៈប្រហាក់ប្រហែលនឹងផែនដីទីសម្រាប់ បង្ហាញឲ្យឃើញវិថីនៃជីវិតរបស់មនុស្ស ដែលមានភាពខុសៗគ្នា ។ គេបញ្ជាក់ថា : មនុស្សដែលធ្វើកម្មល្អពេលកើត, ផែនទីមេឃប្រាប់គេមុនថា នឹងបានផលល្អ អ្នកដែលធ្វើកម្មអាក្រក់ផែនទីប្រាប់គេមុនថា នឹងបានទទួលផលអាក្រក់ ។ ពាក្យពន្យល់របសអ្នកហោរាសាស្ត្រនេះ, បើយើងធ្វើសេចក្តីសង្កេតឲ្យដិតដល់ទៅ ក៏គ្មានឃើញគំនិតណាដទៃ ក្រៅពីគនិតសម្រប់ជាមួយ នឹងគំនោលធម្មៈនៃពុទ្ធសាសនាដែលចែងថា ធ្វើអាក្រក់បានអាក្រក់ ធ្វើល្អបានល្អហ្នឹងទេ ។ ព្រោះអ្វី? ព្រោះដួងផ្កាយក្តី ផែនមេឃក្តីធាតុនេះ វាមានមុខងារត្រឹមតែជាផែនទី បង្ហាញផ្លូវអ្នកធ្វើកម្មអាក្រក់កម្មល្អប៉ុណ្ណឹង, វាគ្មានសមត្ថភាពចាត់ចែងមនុស្សឲ្យទៅជាយ៉ាងនេះ យ៉ាងនោះបានទេ ដូចគ្នានឹងចម្បាំងត្រូវនឹងផែនទីតែជ័យជំនះ វានៅលើយុទ្ធជនពូកែអីចឹងដែរ ។ ម៉្យាងទៀត, អ្នកហោរាសាស្ត្រក៏ បានទទួលយល់ព្រមថា ទំរើអាក្រក់ល្អរបស់ មនុស្សវាអាចទាក់ទាញ, អាចផ្តល់ឲ្យនូវរបស់គ្រប់យ៉ាងរួមទាំងកំណើតផង គឺវាឲ្យមនុស្សឬសត្វកើតក្នុងខណៈ ដែលដួងផ្កាយកំពុងថិតនៅក្នុងភាពលក្ខណៈល្អអាក្រក់ ។ ក្នុងន័យថា មិនមែនដួងផ្កាយដាក់បញ្ជាឲ្យមនុស្សល្អ អាក្រក់ទេ ។ តែមនុស្សចាប់កំណើតក្នុងពេលដែលដួងផ្កាយ កំពុងមានគុណសម្បត្តិនិងគុណវិបត្តិ ។ តួយ៉ាង មួយទៀត, លោកថាកម្មអាក្រក់ល្អដឹកនាំមនុស្សសត្វឲ្យទៅកើតក្នុងកន្លែងដែលមានសេចក្តីសុខចម្រើន និងកន្លែងដែលមានសេចក្តីទុក្ខព្រួយ ។ ចំណែកដួងផ្កាយ, ធាតុនេះវាមានមុខងារត្រឹមតែជាផែនទីបង្ហាញផ្លូវប៉ុណ្ណោះ ។ ចំពោះគំនិតពុទ្ធសាសនាវិញព្រះសម្មាសម្ពុទ្ធបានគូសដៅយ៉ាងជាក់លាក់ថា កម្មល្អជាចង្កៀងរបស់អ្នកស្លាប់, កម្មអាក្រក់ជាយប់របស់អ្នកស្លាប់ ។ ប្រសិនបើនិយាយជាផែនទី តាមពាក្យរបស់អ្នកហោរាសាស្ត្រកម្ម ល្អអាក្រក់ទាំងពីរនេះ គឺជាផែនទីរបស់វិញ្ញាណនៃអ្នកស្លាប់ ។ មិនមែន ដួងផ្កាយ ឬផែនមេឃ ឬវត្ថុអ្វីដទៃឡើយ ។

យ៉ាងណាក៏ដោយ, ខ្ញុំសូមអ្នកអានកត់សម្គាល់ថា ព្រះពុទ្ធសាសនាត្រូវការបណ្តុះសេចក្តីល្អខាងក្នុងគឺធ្វើយ៉ាងណាឲ្យក្នុងខ្លួននៃមនុស្សម្នាក់ៗមានសេចក្តីល្អ, គ្មានត្រូវការបញ្ចូល ឬភ្ជាប់សេចក្តីល្អពីវត្ថុខាងក្រៅទាំងឡាយមានផ្កាយជាដើមទេ ។ ព្រោះភាពល្អខាងក្នុងជាធាតុថិតថេរ ជាធាតុមានភាពជាក់លាក់ ដែលអ្នកប្រព្រឹត្តបានដឹងដោយខ្លួនឯង ។ ចំណែកភាពល្អ ខាងក្រៅជាធាតុមានភាពមិនជាក់លាក់, មុខគួរឲ្យមានសេចក្តីសង្ស័យ បើមិនច្រើនក៏តិចដែរ ។ ឧទាហរណ៍ ឈ្មោះក, ប្រឡងជាប់ ព្រោះពេលប្រឡងឫក្សយាមល្អ ។ ជាមួយគ្នានេះ, ឈ្មោះខ, ប្រឡងជាបព្រោះមានសេចក្តីចេះដឹងច្រើន មានសមត្ថភាពគ្រប់គ្រាន់ ។ ជនទាំងពីរនាក់, គេអាចមើលឃើញថាមានកម្ពស់និងទំនាបខុសគ្នាឆ្ងាយណាស់ ។ ជនដែលប្រឡងជាប់ព្រោះប៉ះលើឫក្សយាមល្អ (សន្មតថាមាន) នោះជំនាប់របស់គេគ្មានខ្លឹមសារអ្វីបន្តិចបន្តួចឡើយ, ព្រោះគ្មានចំណេះវិជ្ជា, គ្មានសមត្ថភាព ។ តែជនដែលប្រឡងជាប់ព្រោះមានចំណេះវិជ្ជាបរិបូរណ៌ មានសមត្ថភាពគ្រប់គ្រាន់ ។ ជំនាប់របស់គេនេះមាន ខ្លឹមសារ, មានឋានៈខ្ពង់ខ្ពស់ណាស់ ព្រោះអ្វី? ព្រោះគេអាចធ្វើឲ្យជីវិតរបស់គេ មានប្រសិទ្ធភាពក្នុងការងារដែលគេប្រកបក្នុង អនាគត ។

ក្នុងរឿងដដែលនេះ មុខជានឹងមានបញ្ហាមួយទៀតចោទឡើងថា : ព្រះពុទ្ធសាសនាគ្មានបានបង្រៀនឲ្យមនុស្សមានជំនឿ, មានកំណាន់ក្នុងផលប្រយោជន៍, ដែលកើតឡើងព្រោះឫក្សយាម ឬឫក្សយាមជាធាតុផ្តល់ឲ្យមនុស្សនូវជោគជ័យណាមួយឡើយ ។ ហេតុអ្វីបានជាពុទ្ធសាសនាមានកំណត់ពេលធ្វើបុណ្យផ្សេងៗ ដូចជាថ្ងៃ

មាឃបូជា, វិសាខបូជា, ចូលវស្សា, ឧបោសថកម្ម, ធ្វើបវារណាកម្មសុំសីល ។ល។ សុទ្ធតែមានការទាក់ទងដោយឫក្សផ្កាយទាំងអស់ដែរ ។ ពោលគឺថ្ងៃមាឃបូជាកំណត់យកថ្ងៃព្រះចន្ទពេញវង់ គោចរឆ្លងកាត់ពួកផ្កាយ ឫក្សឈ្មោះមេឃៈថ្ងៃវិសាខបូជា កំណត់យកថ្ងៃព្រះចន្ទពេញវង់ គោចរឆ្លងកាត់ផ្កាយឫក្សវិសាខ ។ ថ្ងៃចូលវស្សាកំណត់យកថ្ងៃព្រះចន្ទពេញវង់ គោចរឆ្លងកាត់ពួកផ្កាយឫក្សឈ្មោះអាសាឡ្ហ កន្លងទៅបានមួយថ្ងៃ ។ល។ បញ្ហានេះនឹងថាពុទ្ធសាសនា, មិនខ្វីរវល់អើពើឬមិនជាប់ទាក់ទងជាមួយនឹងឫក្សយាមដូចម្ដេចបាន?

ចំពោះបញ្ហានេះ, បើយើងបានដឹងវិធីរាប់ថ្ងៃខែរបស់ឥណ្ឌាក្នុងសម័យបូរាណ យើងនឹងចូលចិត្តកាន់តែច្បាស់ថាការកំណត់ពេលរបស់ពុទ្ធសាសនានោះ ប្រាកដជាធ្វើតាមប្រក្រតីទិនរបស់ឥណ្ឌាហ្នឹងឯង ។ ពោលគឺប្រក្រតីទិនជំនាន់ចាស, គេពុំបានបោះពុម្ពជាសៀវភៅ ឬជាផែនក្រដាសដូចសព្វថ្ងៃនេះទេ ។ តែគេយកផ្ទៃមេឃ ផ្ទៃអាកាសជាផែនប្រក្រតីទិន ។ វិធីរាប់ថ្ងៃ គេកំណត់ដោយដួងចន្ទ ក្នុងពេលដួងចន្ទមានពន្លឺច្រើន មកឲ្យឈ្មោះពេលថាខ្នើតឬខាងខ្នើត ។ ក្នុងពេលព្រះចន្ទមានពន្លឺតិច គេយកពន្លឺតិច គេយកពន្លឺតិចរបស់ព្រះចន្ទមកឲ្យឈ្មោះពេលថា រនោចឬខាងរនោច ។ គេចែកពេលខ្នើតមាន ១៥ ថ្ងៃ, ពេលរនោចមាន ១៤ ឬ ១៥ ថ្ងៃ តាមខែគ្រប់និងខែខ្វះដែលគេបានកំណត់បាននិយមប្រើក្នុងពេលនោះ ។ វិធីរាប់ខែនិងហៅ ឈ្មោះខែគេកំណត់យកថ្ងៃព្រះចន្ទពេញដួងជាគំនោល ។ ព្រះចន្ទពេញដួងខែណា គោចរឆ្លងកាត់ពួកផ្កាយណា គេឲ្យឈ្មោះខែ តាមពួកផ្កាយនោះទៅ ។ ដូចជាព្រះចន្ទពេញដួងឆ្លងកាត់ពួកផ្កាយឈ្មោះកត្តិកា គេហៅខែនោះថៃខែកត្តិកៈ ។ ព្រះចន្ទពេញដួងឆ្លងកាត់ពួកផ្កាយឈ្មោះមាឃា គេហៅខែនោះថាខែមាឃៈ ព្រះចន្ទពេញដួងគោចរឆ្លងកាត់ពួកផ្កាយឈ្មោះវិសាខា ។ គេហៅខែនោះថាវិសាខៈ ។ល។ ចំណែកថ្ងៃចូលវស្សាគេកំណត់តាមរដូវកាល ដែលគេចែកជា ៣ គឺ រដូវក្ដៅរាប់ពី ១ រោចខែផល្គុនដល់ ពាក់កណ្ដាលខែអាសាធ, (រួម ៤ ខែ) រដូវភ្លៀងរាប់ពី ១ រោច ខែអាសាធដល់ពាក់កណ្ដាល ខែកត្តិក (រួម ៤ ខែ) រដូវត្រជាក់រាប់ពី ១ រោច ខែកត្តិកដល់ពាក់កណ្ដាលខែផល្គុន (រួម ៤ ខែ) ។ កាលណាយើងស្គាល់របៀបកំណត់របៀបរាប់ខែ . . . . ដូចនេះហើយ យើងត្រូវពិនិត្យមើលផ្ទៃមេឃ ដែលជាផ្ទាំងប្រក្រតីទិនធំ របស់គេ ។ ដើម្បីបញ្ជាក់គំនិតយើងថា ដួងចន្ទគោចរទៅដល់ណាឆ្លងកាត់ពួកផ្កាយណាខ្លះ ។ កាលណាយើងយល់ រឿងនេះហើយ, យើងអាចកំណត់រដូវខែថ្ងៃបាន យ៉ាងជាក់លាក់ជាមិនខាន ឡើយ ។ ដោយអាស្រ័យគំនិត ជាក់លាក់នេះ, យើងអាចវិនិច្ឆ័យបានថា ថ្ងៃមាឃបូជា, វិសាខបូជា, ចូលវស្សា ។ល។ មិនមែនជា ថ្ងៃមានឫក្សល្អយាមល្អអ្វីទេ ។ ឬបើនឹងស្ដីម៉្យាងទៀតថា មាឃបូជា, វិសាខបូជា, ចូលវស្សាពុំបានធ្វើដោយរើសរក ឫក្សយាម ដែលយើងធ្លាប់ដឹងថាពេលល្អ ពេលអាក្រក់ឡើយ ។ តែធ្វើដោយអាស្រ័យឫក្សផ្កាយ ២៧ ពួក, ពួកណាមួយដែលមានចែងក្នុងក្បួនតារាសាស្ត្រសម័យបូរាណរបស់ឥណ្ឌា ដើម្បីជាគ្រឿងកំណត់ប្រក្រតីទិន ប៉ុណ្ណោះ ។

សេចក្ដីពិតគំនោល ៣ ប្រការ ដែលតាំងឡើងដើម្បីកំណត់ខែ គឺ ១-ព្រះចន្ទពេញវង់ ។ ២-គោចរកាត់ពួកផ្កាយឫក្សដែល ជាឈ្មោះរបស់ខែ ។ ៣-តិថីនោះត្រូវជាតិថីទី ១៥ ដែលរាប់ពីថ្ងៃ ១ កើតមក ។ យើងឃើញថាការកំណត់ទាំង ៣ ប្រការនេះ មានការឃ្លៀងឃ្លាតជានិច្ច ដូចជាព្រះចន្ទពេញវង់ហើយតែនៅមិនទាន់សោយឫក្សឃើញថានៅខ្វះ ១ ឫក្សទៀត ឬតិថីឃ្លៀងឃ្លាតទៅ ១ ថ្ងៃ ។ តែទោះជាយ៉ាងនេះក្ដី យើងត្រូវប្រកាន់យកភាគត្រូវច្រើន ឬភាគទៀងទាត់ច្រើនជាប្រមាណ ។ អ្នកស្គាល់ប្រយោជន៍, គេកំណត់យកពេលវេលាត្រឹមតែជាប្រក្រតីទិន ។ ចំណែកអ្នកមានសេចក្ដីយល់ខុស ឬអ្នកមិនស្គាល់ប្រយោជន៍ គេចូលចិត្តថាឫក្សយាម ។ ព្រះសម្មាសម្ពុទ្ធ, ព្រះអង្គមានព្រះគំនិតថា ការប្រើផ្ទៃមេឃជាប្រក្រតីទិនអាចនឹងមានគំហើញផ្សេងគ្នាខ្លះ ។ ជាមិនខាន ។ ដូចនេះ, ក្នុងវិន័យបិដក ទើបមានពុទ្ធានុញ្ញាតថា ថ្ងៃឧបោសថក្ដី ថ្ងៃបវារណាក្ដី ប្រសិនបើមានគំហើញខុសគ្នារវាងភិក្ខុអាវាសិកៈ និងភិក្ខុអាគន្តុកៈ គឺម្ខាងយល់ថា ថ្ងៃនេះគួរដល់ឧបោសថកម្ម ឬបវារណាកម្មហើយ ។

ម្ខាងទៀតឃើញថា មិនគួរឬមិនទាន់ដល់ ។ ព្រះអង្គឲ្យអនុវត្តតាមសំឡេងភិក្ខុអាវាសិកៈ ។ ព្រះសម្មាសម្ពុទ្ធគ្មានត្រូវការឲ្យកើតភាពច្របូកច្របល់ ក្នុងរឿងឫក្សយាមនេះ សូម្បីបន្តិចបន្តួចឡើយ ។ ហេតុនេះអ្នកអានទាំងឡាយគប្បីចូលចិត្តថា ផ្កាយឫក្សដែលមានទាក់ទងជាមួយ នឹងពុទ្ធសាសនាយើងនេះវាគ្មានការអ្វីក្រៅពីការកំណត់ពេលវេលាដោយ ថ្ងៃខែឆ្នាំហ្នឹងទេ ។ ពិធីគិតគូរប្រក្រតីទិន ឬបដិទិនបែបនេះមានជាទូទៅហើយក្នុងសម័យនោះហើយមានជាប់ទាក់ទងដល់សម័យនេះផង ។ ឬនឹងនិយាយម៉្យាងទៀតថា ប្រក្រតីទិន ឬបដិទិនក្នុងសម័យបូរាណជាមូលដ្ឋាននៃប្រក្រតីទិន ឬបដិទិនក្នុងសម័យបច្ចុប្បន្ននេះក៏បាន ។ ដូចប្រក្រតីទិន ឬបដិទិនរបស់ស៊ីសនិងចិនដែលហៅថា បដិទិនចន្ទគតិ (LUNAR CALENDAR) គឺប្រក្រតីទិនតាមវិថីគោចររបស់ដួងចន្ទ ដែលនិយមប្រើក្នុងសម័យនោះ ។ ប្រក្រតីទិន ឬបដិទិនក្នុងសម័យបច្ចុប្បន្នគេកំណត់បដិទិនតាមវិថីគោចររបស់ដួងអាទិត្យទើបបានគេឲ្យឈ្មោះថា បដិទិនសុរិយគតិ (SOLAR CALRNDAR) ។

ដើម្បីចូលចិត្តងាយ, ខ្ញុំសូមធ្វើសេចក្តីបញ្ជាក់យ៉ាងខ្លី ក្នុងរឿងឫក្សយាមតាមគតិខាងព្រះពុទ្ធសាសនាសម្រាប់អ្នកអាន ពិចារណាដូចមានតទៅនេះ៖

១- ព្រះពុទ្ធសាសនារបស់យើងមិនប្រកាន់យកឫក្សយាមជាធំ, ជាសំខាន់ទេ ។ តែប្រកាន់យកសេចក្តីល្អជាធំ ជាសំខាន់ប្រសិនបើភាពល្អ ភាពត្រឹមត្រូវមានក្នុងថ្ងៃណាពេលណា ថ្ងៃនោះពេលនោះជាឫក្សយាមល្អ, មង្គលល្អរបស់ មនុស្សហើយ ។

២- ព្រះពុទ្ធសាសនាមិនប្រកាន់យកឫក្សល្អយាមល្អថា ជាធាតុទាក់ទាញឲ្យកើតសេចក្តីល្អ, កើតភាពសម្រេចផលនានាទេ ។ តែប្រកាន់ថា ភាពល្អជាធាតិទាក់ទាញឲ្យកើតសេចក្តីសម្រេចផលជាមួយគ្នានេះទៀតទាក់ទាញឲ្យកើតឫក្សល្អ យាមល្អផង ។ តួយ៉ាង : បើព្រះសម្មាសម្ពុទ្ធមិនបានធ្វើទំរើល្អ, ទំរើត្រឹមត្រូវ, ក្នុងកាលមុនទេ, ថ្ងៃប្រសូត ថ្ងៃត្រាស់ដឹង ថ្ងៃសម្តែង ធម្មចក្ក ថ្ងៃបរិនិព្វានរបស់ព្រះអង្គក៏ជាថ្ងៃគ្មានន័យ, គ្មានសក្ការៈបូជា ។ ជាពិសេសគ្មានបានជាអនុស្សាវរីយ៍ថ្លៃថ្នូររហូតដល់សព្វថ្ងៃនេះទេ ។ តែព្រោះព្រះអង្គបានក៏សាងសេចក្តីល្អយ៉ាងច្រើនមហិមា ក្នុងអតីតជាតិនិងបច្ចុប្បន្នជាតិ ទើបរបស់គ្រប់បែប គ្រប់យ៉ាងដែលទាក់ទងជាមួយនឹងជីវិតនៃ ព្រះអង្គដូចជាថ្ងៃខែឆ្នាំ ។ ដុំឥដ្ឋ, ដុំថ្ម, កំណាត់ឈើនិងលោហធាតុនានាដែលគេយក ធ្វើជាព្រះពុទ្ធរូប, ធាតុនិងរបស់ទាំងឡាយនេះប្រែជារបស់ល្អ, មានតម្លៃច្រើនប្រហាក់ប្រហែលគ្នានឹងខ្លួនរបស់ព្រះអង្គដែរ ។ នេះបញ្ជាក់ឲ្យឃើញថា របស់ល្អមានអំណាចទាក់ទាញរបស់អាក្រក់ ឬរបស់ធម្មតាឲ្យល្អតាមបានដែរ ។

៣- ទោះណាជាព្រះពុទ្ធសាសនា, មានកំណត់កាលវេលាទាក់ទងដោយផ្កាយឫក្ស ក៏មិនមែនកំណត់ឡើងដោយមានការជាប់ជំពាក់ទាក់ទិនដល់ឫក្សល្អយាមល្អអ្វីទេ ។ តែដោយអាស្រ័យផ្កាយឫក្សជាប្រក្រតីទិន ឬបដិទិនតាមវធីការគន់គិត ឬគណិតសាស្ត្ររបស់ឥណ្ឌាក្នុងសម័យបូរាណប៉ុណ្ណោះ ។ ថ្ងៃខែឆ្នាំដែលគេបានបង្កើត, បានកំណត់មកហើយ ក៏មិនមែនជាធាតុខ្លាំងពូកែស័ក្តិសិទ្ធិអ្វីឡើយ ។ សេចក្តីសំខាន់របស់មនុស្ស នៅលើធ្វើការត្រូវ, ប្រព្រឹត្តប្រតិបត្តិល្អនិងជីវិតមានហេតុផល ។ល។ គឺទំរើល្អរបស់មនុស្សនេះហើយ ដែលធ្វើឲ្យធាតុទាំងឡាយ មានថ្ងៃខែឆ្នាំជាដើមមានន័យ មានប្រាកដការណ៍ជាក់លាក់ឡើងរហូត ដល់សព្វថ្ងៃនេះ ។

## ទឹកស័ក្តិសិទ្ធិឬទឹកមន្តគ

សូមមេត្តាចូលចិត្តថា ទឹកមន្តដែលគេនិយមថា ពូកែស័ក្តិសិទ្ធិមានស្ទើរតែគ្រប់សាសនា ។ ជាពិសេស, សាសនាព្រាហ្មណ៍ គ្រីស្ត និងពុទ្ធសាសនា ។ តែពុទ្ធសាសនាពុំបានប្រកាន់យកទឹកមន្តថា ជារបស់ស័ក្តិសិទ្ធិទេ គឺប្រកាន់យកទំរើល្អ, ទំរើ មានហេតុផលថាជារបស់ស័ក្តិសិទ្ធិ ។

ករណីដែលពុទ្ធសាសនា យល់ព្រមឲ្យមានទឹកមន្តដូចសាសនាដទៃ មិនមែនជាគំនោលនៃធម្មៈ របស់

ពុទ្ធសាសនាត្រង់ៗទេ ។ តែជារឿងរាយរងបន្ទាប់បន្សំ, បើគ្មានក៏មិនមានទំនាស់ដល់គំនោលធម្មៈរបស់ពុទ្ធសាសនាសូម្បីបន្តិចបន្តួចឡើយ ។ អ្នកស្រាវជ្រាវបានរកឃើញថា គម្ពីរឬតម្រាផ្នែកនេះ ទើបតែកើតមានខាងក្រោយពុទ្ធបរិនិព្វានប្រមាណជា ១០០០ ឆ្នាំ គឺជំនាន់គម្ពីរអដ្ឋកថា ។ បើស្ដីដោយចំពោះ, រឿងនេះមានមកក្នុងអដ្ឋកថា ខុទ្ទកបាឋៈនៃសូត្រមួយមានឈ្មោះថា រតនសូត្រ ដែលនិយាយពីភ័យ ៣ ប្រការគឺ : ទុព្ភិក្ខភ័យ, អមនុស្សភ័យ, និងរោគភ័យ ។ ភ័យនេះកើតឡើងក្នុងក្រុងវេសាលី រាជធានីវជ្ជី ។ ភ័យធំជាងគេ ក្នុងពេលនោះគឺភ័យអំពីរោគឆ្លង ដែលភាសាបាលីហោថា **អហិវាតករោគ** ។ បច្ចុប្បន្នគេនិយមហៅថា អាសន្នរោគ ។ តាមដំណាលថា ជីវិតមនុស្សក្នុងគ្រួសារមួយៗស្លាប់ស្ទើរតែទាំងអស់, ហើយរាលដាលឆ្លងរហូតដល់សត្វនាៗផង ។ ស្ដេចលិច្ឆវីទាំងឡាយមានការព្រួយបារម្ភជាខ្លាំង ។ ក្នុងពេលបើកសម័យប្រជុំប្រឹក្សាគ្នាជាចុងក្រោយបង្អស់, បានសម្រេចចាត់គណៈប្រតិភូ មួយឲ្យទទួលបេសកកម្មទៅនិមន្តព្រះសម្មាសម្ពុទ្ធ ដើម្បីព្រះអង្គធ្វើពុទ្ធដំណើរទៅកាន់កន្លែងរងគ្រោះកាចនោះ ។ ព្រះសម្មាសម្ពុទ្ធ លុះបានទទួលនិមន្តហើយ ព្រះអង្គបាននិមន្តចាករដ្ឋមគធៈទៅកាន់រដ្ឋវជ្ជី ដោយឆ្លងកាត់ទន្លេគង្គាដែលជាខ្សែបន្ទាត់នៃព្រំដែនរបស់រដ្ឋទាំងពីរ ។ និមិត្តតែព្រះសម្មាសម្ពុទ្ធដាក់ព្រះបាទជាន់លើរដ្ឋវជ្ជីភ្លាម, មហាមេឃក៏បង្អុរភ្លៀងយ៉ាងធំ បណ្ដាលឲ្យរោគឆ្លងស្ងប់ ។ ក្នុងពេលគង់ប្រថាប់ក្នុងក្រុងវេសាលី, ព្រះអង្គបានបង្រៀនព្រះអានន្ទនូវអត្ថបទនៃរតនសូត្រ(**យានីធ ភូតានិ សមាគតានិ**)។ល។ ព្រះអានន្ទក្រោយពីបានទន្ទេញចាំហើយ, លោកបានយកបាត្រដាក់ទឹកប្រស់ព្រំក្នុងបរិវេណ ក្រុងជាទូទៅពួកអមនុស្សក៏រត់គេចអស់ទៅ, ហេតុកំណាចផ្សេងៗក៏បានបាត់ស្ងាត់អស់ក្នុងពេលនោះ ។

ដោយអាស្រ័យពំនោលក្នុងអដ្ឋកថានេះ ទើបមានការតម្កល់ទឹកមន្តក្នុងពេលមានការចម្រើនព្រះបរិត្ត ក្នុងកន្លែងនានា លុះចប់ពិធីចម្រើនព្រះបរិត្តហើយគេ និមន្តព្រះសង្ឃត្ថេរ ឲ្យប្រស់ព្រំទឹកព្រះពុទ្ធមន្តដល់គ្រួសារទាំងអស់ផង ដល់គេហដ្ឋានរបស់គេផង ដើម្បីជោគជ័យសិរីមង្គល និងដើម្បីកម្ចាត់គ្រោះកាចចង្រៃដែលគេគ្មានប្រាថ្នាគ្មានត្រូវការចង់បាន ។ ទម្លាប់ប្រស់ព្រំទឹកមន្តនេះ, ក្រោយមកបានក្លាយមកជាបាចទឹកមន្តទៅវិញ ។ មូលហេតុនៃកម្លាយនេះ អ្នកស្រាជ្រាវជាទូទៅយល់ឃើញថា ប្រហែលមកពីខ្ជិលឲ្យមានដំណាក់កាលច្រើនដង គឺមានសូត្រមន្តមួយលើក ប្រស់ព្រំមួយលើក ។ ប៉ុណ្ណោះហើយ, នៅតែមិនទាន់ល្មមដល់កម្មិលរបស់មនុស្ស, គេក៏និមន្តព្រះសង្ឃស្រោចទឹកត្រង់ៗតែម្ដងទៅ ។ នេះជាកម្លាយដែលកើតជាបន្តបន្ទាប់គ្នាម្ដងបន្តិចៗ ដែលយើងគួរធ្វើសេចក្ដីកត់សម្គាល់ថា រឿងទឹកមន្តកាលដើមដំបូងគេធ្វើយ៉ាងនេះ បន្ទាប់មកយ៉ាងនេះ ចុងក្រោយបង្អស់ ឬសព្វថ្ងៃយ៉ាងនេះ ។ តែយ៉ាងណាក៏ដោយចុះ រឿងទឹកមន្តទោះជាប្រស់ព្រំក្ដី, បាចក្ដី, ស្រោចក្ដី ។ ពិធីនេះច្រើនធ្វើ ច្រើនទទួលក្នុងពេលមានហេតុការណ៍មិនស្រួលកើត ឡើងក្នុងជីវិតដូចជាមានយល់សប្ដិមិនល្អរឿយ ។ ព្រួយចិត្តច្រើនមិនដឹងមកពីរឿងអ្វី, នឹកស្រម័យខ្លួនឯង ឬមានហោរទស្សន៍ទាយឲ្យថា គ្រោះកាចនឹងកើតក្នុងថ្ងៃណាមួយ ។ គេក៏រៀបចំពិធីសូត្រមន្តនៅក្នុងផ្ទះ ឬទៅវត្តនិមន្តព្រះសង្ឃស្រោចទឹកមន្តឲ្យ, លុះបានធ្វើពិធីកម្មនេះហើយ គេមានការសប្បាយចិត្តច្រើន ។ ទំរើនេះបើស្ដីតាមរឿងចិត្តសាស្ត្រ ប្រាកដជាមានផលល្អច្រើនខាងផ្លូវចិត្តដែរ ។ ប្រសិនបើអ្នកទទួលទឹកមន្តនោះមានជំនឿថា ទឹកមន្ត ជាធាតុមួយ មានអានុភាពរំដោះគ្រោះកាចបាន ។

ក្នុងសាសនាព្រាហ្មណ៍គេមានជំនឿថា ទឹកទន្លេខ្លះមានភាពស័ក្ដិសិទ្ធិ ។ ជាពិសេសទឹកទន្លេគង្គា គេចូលចិត្តថាហូរមកអំពីឋានសួគ៌ចាក់ស្រោចលើព្រះកេសព្រះអាទិទេពរបស់គេមានព្រះនាម «**សិវៈ**» ពលានុភាពនៃព្រះកេសព្រះសិវៈបានធ្វើឲ្យខ្សែទឹកហូរមានកម្លាំងខ្សោយច្រើន ។ បើកុំដូចនេះ, ទឹកនឹងជន់លិចពិភពលោក ។ ដោយទឹកហូរកាត់លើព្រះកេសព្រះសិវៈ ទើបគេប្រកាន់ថា ទឹកមានភាពស័ក្ដិសិទ្ធិ ភាពបរិសុទ្ធលាងបាបបាន ។ អ្នកណាមានបាប, គេចុះងូតទឹកក្នុងទន្លេនេះ, ទឹកអាចធ្វើ ឲ្យបានអណ្ដែតអស់ ។ សេចក្ដីបរិសុទ្ធកើតមានដល់ខ្លួនគេ ។ ក្នុងមួយឆ្នាំៗ

កំពង់ងូតទឹកក្រុងពារាណសី មានមនុស្សទៅងូតទឹក ធ្វើពិធីលាងបាបរាប់លាននាក់ ។

វណ្ណកម្មដែលពុទ្ធសាសនាបាននិយាយថា ទន្លេស័ក្តិសិទ្ធិដែលពួកព្រាហ្មណ៍ប្រកាន់ថា ពូកែស័ក្តិសិទ្ធិ មិនមែនមានតែទន្លេគង្គាមួយទេ ។ ទន្លេដទៃទៀតមានច្រើន ដែលពួកព្រាហ្មណ៍មានជំនឿ ប្រហាក់ប្រហែលនិងគង្គានេះ ។ ដើម្បីកុំឲ្យអ្នកអាន មានសេចក្តីធុញទ្រាន់ ខ្ញុំសូមមិនសរសេរឈ្មោះទន្លេទាំងនោះក្នុងទីនេះទេ អ្នកអានចង់ដឹងសូមពិនិត្យមើលវណ្ណកម្មពុទ្ធសាសនា យើងជាថ្មីទៀតចុះ ។ ជាពិសេស, វណ្ណកម្មផ្នែកនេះ មានក្នុងគម្ពីរវិសុទ្ធិមគ្គត្រង់សីលនិទ្ទេស ។

ព្រះពុទ្ធសាសនារបស់យើង ពុំបានបង្រៀនឲ្យយើងមានជំនឿក្នុងភាពស័ក្តិសិទ្ធិនៃទឹកស្ទឹងទន្លេនា១ ដូចពួកព្រាហ្មណ៍ឡើយ ។ ដើម្បីអ្នកអានស្តាប់បានចូលចិត្តភ្លាម១ ក្នុងរឿងនេះ ខ្ញុំសូមឲ្យចម្លើយមួយ ដែលព្រះសម្មាសម្ពុទ្ធបានធ្វើជាមួយនឹង សុន្ទរិកៈភារទ្វាជព្រាហ្មណ៍មានសេចក្តីដូចនេះ :

ម្នាលព្រាហ្ម៍ ! ចូរអ្នកងូតទឹកធម្មវិន័យ (ទន្លេធម្មវិន័យ) នេះរបស់តថាគត ចូររស់នៅក្នុងភាពក្សេមក្សាន្ត ជាមួយនិងសត្វទាំងឡាយ ។ បើអ្នកមិនពោលពាក្យកុហក, មិនបៀតបៀនសត្វមានជីវិត, មិនកាន់យករបស់គេ ដែលម្ចាស់គេមិនបានឲ្យ ។ អ្នកមានជំនឿក្នុងក្របខ័ណ្ឌនៃហេតុផល, លះបង់សេចក្តីកំណាញ់ ច្រើនតិចតាមដែលអ្នកអាចធ្វើបាន ។ ទំរើទាំងអស់នេះ កាលបើអ្នកបានធ្វើហើយ អ្នកមិនចាំបាច់ធ្វើដំណើរទៅកាន់ស្ទឹងគយាទេ ។ ទឹកងូតទឹកផឹកសព្វថ្ងៃរបស់អ្នកទោះជាផង ឬយកអំពីស្ទឹងស្ទឹងណាទន្លេណាកន្លែងណា ស្ទឹងនោះទន្លេនោះ កន្លែងនោះជាគយារបស់អ្នកហើយ ។

ព្រះអង្គបញ្ជាក់ថា ភាពស្អាតបរិសុទ្ធនៃចិត្តរបស់មនុស្ស មិនមែនកើតមានឡើងព្រោះទឹក ដែលអ្នកផងទម្លាប់ជឿ ទម្លាប់ងូតទេ ។ អ្នកណាមានសច្ចៈ, មានធម្មៈ អ្នកនោះជាបុគ្គលមានចិត្តស្អាតបរិសុទ្ធ, ជាអ្នកបានឈ្មោះថា ព្រាហ្មណ៍ហើយ» ពុទ្ធភាសិតនេះបានបញ្ជាក់ប្រាប់សេចក្តីពិតត្រង់១មែន១ គ្មាននរណាអាចបដិសេធបានទេ ប្រសិនបើគេព្រមយកបញ្ញាត្រិះរិះ ពិចារណានៅជុំវិញហេតុផលជាមុនសិន ។

នៅក្នុងបញ្ហានេះ, ខ្ញុំសូមទាក់ទាញអារម្មណ៍អ្នកអាន ឲ្យពិចារណានៅក្នុងគំនិតហេតុផល ជាមួយនិងខ្ញុំលើកថេរីភាសិត មួយមានដូចនេះ :

«ប្រសិនបើមនុស្សយើងមានផ្លូវរួចផុតចាកបាបកម្មបាន, ព្រោះអាស្រ័យការងូតទឹក (ដែលគេចូលចិត្តថាស័ក្តិសិទ្ធិ) ហើយ ។ សត្វទាំងឡាយដែលមានជីវិតរស់នៅក្នុងទឹកមានជាអាទិ៍ ត្រី, កង្កែប, អណ្តើក, អន្ទង់, ពស់, ក្រពើ វាមុខជាត្រូវបានជ្រះ បាបអស់ហើយ ។ ព្រមគ្នានេះ, វាត្រូវបានរស់នៅក្នុងឋានសួគ៌ទៀតផង ព្រោះវាគ្មានបាប, វាមានសេចក្តីបរិសុទ្ធ»

កាលបើគំនោលធម្មៈ នៃពុទ្ធសាសនាមានដូចនេះ, ការធ្វើទឹកមន្តក្តី, ប្រើប្រាស់ទឹកមន្តក្តី ដែលពុទ្ធសាសនិកនិយមធ្វើ និយមប្រើគ្រប់គ្នាសព្វថ្ងៃនេះមានន័យយ៉ាងណាដែរ? ក្នុងរឿងនេះ ខ្ញុំបានសរសេរមកហើយថា ល័ខឋាននៃទឹកមន្តដែលមានក្នុងពុទ្ធសាសនា អ្នកស្រាវជ្រាវទួទៅបានមានគំហើញត្រូវគ្នាថា ទឹកមន្តមានក្នុងគម្ពីរអត្ថកថាដែលទើបនឹងតែងខាងក្រោយពុទ្ធបរិនិព្វានប្រមានមួយពាន់ឆ្នាំ ។ ក្នុងព្រះត្រៃបិដកបាលីសុទ្ធ១ ពុំបាន បង្រៀនឲ្យធ្វើទឹកមន្ត ឬងូតទឹកមន្តឡើយ ។ អ្នកមានជំនឿកំណាន់ក្នុងរឿងទឹកមន្ត គេអាចធ្វើអាចប្រើបានដែរ ប្រសិនបើគេយល់ថា ទឹកមន្តមានលក្ខណៈត្រឹមតែប្រពៃណីនិយម មិនមែនជាអរិយសច្ចធម៌ ។ ដូចនេះព្រោះអ្វី? ព្រោះប្រពៃណីព្រាហ្មណ៍គេចុះងូតទឹក ក្នុងស្ទឹងទន្លេប្រកបដោយគំហើញថាជ្រះបាប, ហើយមានសិរីសួស្តីជ័យមង្គលផង ។ ព្រះអត្ថកថា, បានកែប្រែទំរើរបស់ព្រាហ្មណ៍មកជាទំរើពុទ្ធសាសនា ដោយឲ្យពុទ្ធសាសនិក ងូតទឹកមន្តជំនួសទឹកស្ទឹងទន្លេវិញ យើញថាទៅរួចដែរ សម្រាប់អ្នកមានជំនឿក្នុងប្រពៃណីនិយម ។ ចំណែកអ្នកសច្ចធម៌និយម,

គ្មានបញ្ហាអ្វីត្រូវដោះស្រាយទេ ព្រោះគេមានគំនិតជឿនលឿន, មានវិញ្ញាណបង្កប់ដោយអរិយសច្ចធម៌ស្រេចទៅហើយ ។

ប្រសិនបើស៊ីតាមគំនោលធម្មៈ នៃពុទ្ធសាសនាត្រង់ៗចំៗតែម្តង ។ ព្រះសម្មាសម្ពុទ្ធរបស់យើង ព្រះអង្គជាកម្មវាទីបុគ្គល មិនមែនជាម្តវាទីបុគ្គលទេ ។ គឺព្រះអង្គបានមានគំនោលជានិច្ចថា ភាពសុខទុក្ខ, កម្ពស់ទំនាប, តម្លៃតំហោក ។ល។ របស់មនុស្ស សត្វ កើតមកពីកម្ម, ពុំមែនកើតមកអំពីព្រមាមដៃនៃព្រះអាទិទេព ឬវត្ថុស័ក្តិសិទ្ធិណាមួយតាមគំនិតដៅស្មាន ឬជំនឿប្រាសចាកហេតុផល ដែលតែងកើតមានក្នុងវិញ្ញាណគ្មានពន្លឺរបស់មនុស្ស, អស់រយៈកាលយ៉ាងយូរ ដំណាលគ្នានិងការកើតឡើងនៃ ពិភពលោក ។ ដូចនេះពុទ្ធតម្រាស់ថា : នរណាធ្វើកម្មល្អបានផលល្អ នរណាធ្វើកម្មអាក្រក់បានផលអាក្រក់ ។ ពំនោលនេះ, ពុំមែនជាពំនោលខ្វះការគាំទ្រ, ខ្វះជំនឿពីមតិគ្រប់មជ្ឈដ្ឋានឡើយ ។ ការពិត, មានមតិគាំទ្រជាងពាក់កណ្តាលនៃចំនួនមនុស្សក្នុងពិភពលោកទៅហើយ ។ ចំណែកទឹកមន្ត, អ្នកស្រាវជ្រាវមានយោបល់ស្របគ្នាថា គ្មានកម្លាំងគ្មានអានុភាពធ្វើមនុស្សអាក្រក់ឲ្យល្អ, ធ្វើមនុស្សល្អឲ្យអាក្រក់បានទេ គឺមានប្រយោជន៍ត្រឹមតែធ្វើមនុស្សឲ្យកើតសេចក្តីសប្បាយខាងផ្លូវចិត្ត ដែលជាផលនៃ ចិត្តវិទ្យាប៉ុណ្ណោះ ។ ខ្ញុំសូមបញ្ជាក់ថា, សំនេររបស់ខ្ញុំក្នុងរឿងនេះពុំមែនជាសំនេរលើកខ្លួនឯងបង្អាប់អ្នកដទៃ ក្នុងគំនិតប្រឆាំងនិងអ្នកមានជំនឿក្នុងទឹកមន្តទេ ។ មនុស្សខ្លះរួមទាំងអ្នកនិយមទឹកមន្តផង គេអាចមានចរិយា អធ្យាស្រ័យល្អជាងអ្នកដែលនិយមធម៌ជាន់ខ្ពស់ សម្រាប់តែនិយាយបង្អាប់បន្តុះអ្នកដទៃដើម្បីកេរ្តិ៍ឈ្មោះ ដើម្បីលើកតម្កើងខ្លួន តែគ្មានអនុវត្តតាមការចេះដឹង, តាមគំនោលធម្មៈពិតប្រាកដរបស់ពុទ្ធសាសនាឡើយ ។ ដោយអាស្រ័យ ហេតុនេះពុទ្ធសាសនិកគ្រប់ប្រភេទគួរយល់ស្គាល់ចិត្តថ្លើមគ្នា, កុំប្រមាថមើលងាយគ្នាឲ្យសោះ ។ អ្នកប្រតិបត្តិធម៌មានទំនាបកម្ពស់ដល់ថ្នាក់ជាន់ណានាំគ្នាជួយកោត, ជួយសរសើរនៅក្នុងក្របខ័ណ្ឌនៃការលើកទឹកចិត្ត ឲ្យគ្នាខំប្រឹង ប្រព្រឹត្តប្រតិបត្តិឲ្យកាន់តែប្រសើរឡើងទៀត ។ កុំឲ្យរករឿងបង្អាប់បន្តុះគ្នា នាំខាតពេលឥតប្រយោជន៍ ព្រោះទិសដៅរបស់ពុទ្ធសាសនាមិនមែននៅត្រង់លើកខ្លួនឯងឲ្យខ្ពស់, ដាក់អ្នកដទៃឲ្យទាបទេ គឺនៅត្រង់ការអនុវត្ត ការប្រតិបត្តិធម៌របស់ខ្លួន, ឲ្យស្របជាមួយពុទ្ធចិន្តាគ្រប់យ៉ាងឯណោះវិញទេ ។

## បង្រៀនអំពីរឿងទេវតា

ព្រះពុទ្ធសាសនាមានបង្រៀនរឿងទេវតាច្រើនប្រភេទរួមទាំងប្រភេទធម្មតា, ប្រភេទសំខាន់ ។ ជាពិសេស, គឺបង្រៀនឲ្យ មនុស្សធ្វើទេវតាបានក្នុងជាតិនេះ ដោយគ្មានរង់ចាំស្លាប់ជាមុន ទើបបានធ្វើជាទេវតាក្នុងខាងក្រោយ ។ ដូចនេះព្រោះអ្វី? ព្រោះទេវតា ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពុំបានសំដៅយករូបធម៌ទេ គឺសំដៅយកនាមធម៌ ដែលយើងធ្លាប់ស្គាល់ថា សទ្ធា, សីល, ចាគៈ, សុត្តៈ, បញ្ញា ។ ឬស៊ីម៉្យាងទៀតថា ព្រះអង្គសំដៅយកគុណធម៌ មិនសំដៅយកទេសនាធម៌, បរិយត្តិធម៌, និស្សិតនិជ្ជីវធម៌, ដូចនេះវិញក៏បាន ។ ការបង្រៀនយ៉ាងនេះ គ្មានត្រូវការអ្វីក្រៅពីឲ្យអ្នករៀន, អ្នកស្តាប់បានស្គាល់ផលប្រយោជន៍ពិតៗ កុំឲ្យមានធុញទ្រាន់ ។ ព្រោះអ្វី? ព្រោះស្តាប់រឿងទេវតាលើឋានសួគ៌យូរៗទៅ ក៏គ្មានខុសអ្វីនិងការស្តាប់រឿងព្រេង ។ ស្តាប់ហើយ, ដឹងហើយ, ក៏ហើយទៅ មិនដឹងប្រតិបត្តិយ៉ាងណា អនុវត្តយ៉ាងម៉េចឲ្យខ្លួនបានជាទេវតា ឬឲ្យមានជំនឿថា ខ្លួនហ្នឹងហើយបាន ទៅកើតជាទេវតាលើឋានសួគ៌រស់នៅយ៉ាងនេះ យ៉ាងនោះ ។ ផ្ទុយទៅវិញ, កាន់តែចេះ កាន់តែចាំ ក៏កាន់តែរសាត់អណ្តែតទៅម្តងបន្តិចៗ ប្រសិនបើគ្មានរៀនស្តាប់ គ្មានបានបណ្តុះជំនឿថ្មីទៀត ក៏គ្មានបានសប្បាយរីករាយបន្តិចបន្តួចសោះ ។ ព្រោះហេតុនេះ, ទើបព្រះសម្មាសម្ពុទ្ធបង្រៀនឲ្យមនុស្សធ្វើខ្លួនជាទេវតាក្នុងជាតិនេះ ដោយធ្វើយ៉ាងណាឲ្យខ្លួនម្នាក់ៗ មានទេវធម៌ គឺហិរិ ឱត្តប្បៈ ឬសទ្ធា, សីល, ចាគៈ, សុត្តៈ, បញ្ញា ។ បុគ្គលណាបានធ្វើឲ្យមាននូវធម៌ទាំងឡាយនេះ ក្នុងចិត្តវិញ្ញាណរបស់ខ្លួន បុគ្គលនោះត្រូវបានជាទេវតាភ្លាមៗ ដោយគ្មានចាំបាច់ស្លាប់ហើយទើបបានជាទេវតា ។ បុគ្គល

ដែលបានជាទេវតាក្នុងជីវិតនេះ, ដោយអាស្រ័យទេវធម ឬគុណធម៌ដូចបានពោលមកនេះ គេបានដឹងខ្លួនគេយ៉ាងច្បាស់លាស់ គេបានសប្បាយខ្លួនគេយ៉ាងអស្ចារ្យរកពាក្យនិយាយប្រាប់អ្នកដទៃឲ្យចូលចិត្ត, ឲ្យសប្បាយផងដូចខ្លួនគេមិនបាន ។ នេះឯងគឺសន្និដ្ឋិកោ ដែលសម្តែងដោយ ព្រះសម្មាសម្ពុទ្ធ ត្រង់ៗចំៗតែម្តង ។

ប្រភេទទេព ឬទេវតាដែលសម្តែងដោយព្រះសម្មាសម្ពុទ្ធមាន ៣ គឺ ៖

**១- សម្មតិទេព** ទេពដោយសន្មតបានដល់រាជា រាជិនី ប្រធានាធិបតី ប្រធានាធិបតានី រាជកុមារ រាជកុមារី បុត្តប្រធានាធិបតី ធីតាប្រធានាធិបតី ........។

**២- ឧប្បត្តិទេព** ទេពដោយកំណើតបានដល់ទេពដែលមានធម៌កើតក្នុងចិត្ត ។

**៣- វិសុទ្ធិទេព** ទេពដោយសេចក្តីបរិសុទ្ធថ្នាក់ទាប បានដល់សោតាបន្នបុគ្គល សកទាមិបុគ្គល ។ ថ្នាក់កណ្តាលបានដល់ អនាគាមិបុគ្គល ថ្នាក់ខ្ពស់បានដល់ព្រះអរហន្ត, ព្រះបច្ចេកពុទ្ធ, ព្រះសម្មាសម្ពុទ្ធ ។

ទេវតាទាំង ៣ ប្រភេទនេះ អ្នកផងមើលឃើញច្បាស់នឹងភ្នែករបស់ខ្លួន ។ គឺសម្មតិទេពមានដោយមនុស្សតែងតាំង ឬតាំងដោយខ្លួនឯង ។ តាំងខ្លួនជារបបរាជាធិបតេយ្យផ្តាច់ការ ឬរបបគ្មានរដ្ឋធម្មនុញ្ញ ឬរបបប្រជាធិបតេយ្យស្តេចរស់នៅក្រោមក្របខ័ណ្ឌនៃច្បាប់ ។ រីឯរបបប្រធានាធិបតីមានន័យប្រហាក់ប្រហែលគ្នានិងរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញដែរ ។ តែសម្រេច ដោយរាស្ត្របោះឆ្នោតតែម៉្យាង ។ ចំណែកឧប្បត្តិទេពនឹងវិនិច្ឆ័យក្នុងឃ្លាទីបំផុត ដែលស្តីដោយសួគ៌នរកមានពិតមែន ឬមិនពិតទេ ។ ឧប្បត្តិទេព, ពោលតាមគំនោលនៃធម្មៈ របស់ពុទ្ធសាសនាបានដល់មនុស្សមួយពួក ដែលធ្លាប់ធ្វើបុណ្យទានក្នុងជីវិតនេះ, ពេលស្លាប់ទៅបានទៅកើតក្នុងពិភពនៃទេវតា សឹងមាននិយាយគ្រប់សាសនា ។ តែមនុស្សសម័យថ្មី ឬសម័យវិទ្យាសាស្ត្រ ជឿនលឿន, គេមិនសូវយកចិត្តទុកដាក់ មិនសូវមានជំនឿ ។ គេរិះគន់ចោទប្រកាន់ថា រឿងនេះជាធាតុគ្មានការពិត ជាសម្ដីកុហកបោកប្រាស់ យកឋានសួគ៌មកបញ្ឆោតលួងលោមមនុស្សឲ្យធ្វើសេចក្តីល្អប៉ុណ្ណោះ ។ រឿងនេះលើកទុកដោយឡែកសិនចាំត្រិះរិះ ពិចារណាជាថ្មីឡើងវិញក្នុងឃ្លាខាងមុខទៀត ។ យ៉ាងណាក៏ដោយរឿងទេវតាពួកនេះគេឃើញថាពុទ្ធសាសនាបានប្រើគំនិតចំៗ ក្នុងគំនោលធម្មៈពិតៗ មកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យ ។ ទេវតាដែលងាយស្រួលដល់ការវិនិច្ឆ័យ គឺវិសុទ្ធិទេព ឬទេពបរិសុទ្ធ ។ សេចក្តីបរិសុទ្ធក្នុងទីនេះ ដោយយកភាពស្អាតបរិសុទ្ធខាង កាយវាចាចិត្តដែលមនុស្សម្នាក់ៗបានប្រព្រឹត្តប្រតិបត្តិ ដើម្បីធ្វើឲ្យជីវិតរបស់ខ្លួនរស់នៅក្នុងភាពល្អ, ភាពត្រឹមត្រូវ ជាទូទៅហ្នឹងឯង ។

បុគ្គលដែលមានខ្លួនប្រព្រឹត្តល្អ មានខ្លួនរស់នៅក្នុងភាពបរិសុទ្ធ ត្រូវបានឈ្មោះជាទេវតា ។ ទេវតាប្រភេទនេះមានតម្លៃច្រើនជាងទេវតាដោយសន្មត, មានកម្ពស់ខ្ពស់ជាងទេវតាលើឋានសួគ៌ ។ នេះបញ្ជាក់ឲ្យឃើញថាព្រះពុទ្ធសាសនាពុំបានឲ្យកិត្តិយស ពុំបានឲ្យតម្លៃដល់ទេវតាលើឋានសួគ៌នៅក្នុងកម្រឹតច្រើន, កម្រឹតខ្ពស់ជាងមនុស្សដែលបានប្រព្រឹត្តធម៌ល្អឡើយ ។ គេអាចនឹងនិយាយបានថា ពុទ្ធសាសនាជាសាសនាដំបូងក្នុពិភពលោកដែលបានបង្រៀនឲ្យមនុស្សធ្វើទេវតា នៅលើផែនដីផ្ទៃ ពិភពរបស់មនុស្ស ដែលអ្នកណាៗក៏ដោយ ប្រសិនបើមានចិត្តចង់ធ្វើទេវតាអាចធ្វើបានដោយគ្មានរើសជាន់ថ្នាក់វណ្ណៈ ពណ៌សម្បុរឡើយ ។ ហើយវិសុទ្ធិទេពនេះទៀតសោតក៏មានតម្លៃខ្ពង់ខ្ពស់ជាងទេវតាគ្រប់ប្រភេទ ដែលមានស្តីក្នុងសាសនានានាៗផង, មានហេតុផលគ្រប់គ្រាន់អាចឲ្យគេស្គាល់យល់ គេជឿបានក្នុងពេលប្រតិបត្តិធម៌ ដើម្បីយកតំណែងទេវតាប្រភេទនេះទៀត ។

ទេវតាដោយសេចក្តីប្រព្រឹត្តប្រតិបត្តិប្រភេទនេះ ថ្នាក់ខ្ពស់បានដល់ព្រះអរហន្តទូទៅ, ថ្នាក់ទាបបានដល់បុគ្គលពួកមួយមានសន្តានចិត្តជាបុថុជ្ជននៅឡើយ ។ តែមានហិរឱត្តប្បៈចេះខ្មាសបាបខ្លាចបាប ។ លះបង់ធម្មៈខ្មៅ

(អកុសលធម៌) ប្រព្រឹត្តប្រតិបត្តិធម៌ស (កុសលធម៌) រស់នៅក្នុងអាជីវកម្មប្រកបដោយសុចរិត លះបង់អាជីវកម្មប្រកបដោយទុច្ចរិត តម្កល់ក្នុងគុណធម៌ល្អ មានឈ្មោះថា ទេវធម៌ ដែលសម្តែងដោយព្រះសម្មាសម្ពុទ្ធ ។

ក្នុងសាសនាព្រាហ្មណ៍, គេមានបង្ហាត់បង្រៀនសាសនិករបស់គេ ឲ្យស្គាល់ព្រះព្រហ្មដោយរូបលក្ខណៈ (ទម្រង់រូប) មានមុខ ៤, មានខ្លួនមួយ មានឥរិយាបថអង្គុយលើអាសនៈផ្កាឈូក ។ ពុទ្ធសាសនរបស់យើង ក៏ពុំបានរិះគន់, ពុំបានបដិសេធទេ ។ តែបានសម្តែងជាថ្មីឲ្យពុទ្ធសាសនិកស្គាល់ព្រះព្រហ្ម ដោយប្រកាន់យកនាមធម៌ជាធំជាទីតាំង ។ ព្រមគ្នានេះបានដូរន័យជាថ្មី ដោយបញ្ជាក់ថា ព្រហ្មមិនមែនសំដៅយករូបជាធំទេ គឺសំដៅយកចិត្តដែលគេបានបំពាក់ដោយធម៌ប្រសើរថ្លៃថ្នូរ បានដល់បុគ្គលដែលរស់នៅក្នុងធម៌ ៤ ប្រការ មានឈ្មោះថា ព្រហ្មវិហារគឺ :

១- មេត្តា, ជាមនុស្សមានគំនិតភក្តីភាព ចង់ឲ្យសកលសត្វរស់នៅជាសុខ (ប្រាសចាកទណរើបៀតបៀន) ។

២- ករុណា, ជាមនុស្សមានគំនិតអាសូរ ស្រណោះចង់ជួយឲ្យសកលសត្វដែលកំពុងរងទុក្ខ ឲ្យរួចចាកទុក្ខទាំងពួង (ប្រាសចាកគំនិតយករួចខ្លួននិងគនិតកំណាច) ។

៣- មុទិតា, ជាមនុស្សសុខចិត្តព្រមជួយសប្បាយអ្នកដទៃ ក្នុងពេលដែលគេមានភ័ព្វសំណាងជាងខ្លួន (ប្រាសចាក សេចកដីច្រណែន) ។

៤- ឧបេក្ខា, ជាមនុស្សដាក់ចិត្តនៅកណ្តាល គ្មានភាពលំអៀង (ប្រាសចាកអគតិធម៌ ៤) ។

គុណធម៌ល្អ ៤ ប្រការនេះ ជាគុណធម៌សម្រាប់រស់នៅរបស់មនុស្សមានភាពធំដុំពិតៗ បុគ្គលមានជីវិតរស់នៅប្រកប ដោយគុណធម៌បែបនេះខ្លួនគេត្រូវបានឈ្មោះថា ព្រហ្មជាទេវតាថ្នាក់ខ្ពស់ ។ ជាមួយគ្នានេះទៀត, មាតាបិតាណាមាន ព្រហ្មវិហារធម៌នេះ ដល់បុត្តធីតារបស់ខ្លួន មាតាបិតានោះត្រូវបានជាព្រហ្មរបស់កូន ។ គំនិតនិងពំនោលរបស់ពុទ្ធសាសនាក្នុង រឿងនេះ, កើតបានជាពន្លឺដល់គំនិតរបស់ជនសម័យថ្មីយ៉ាងច្រើន ។ គេទាំងឡាយបានយល់ឃើញថា ពុទ្ធសាសនាជាសានាល្អ, ជាសាសនាបានឲ្យគំនិតទាន់សម័យ ។ ព្រោះអ្វី? ព្រោះមនុស្សជាទូទៅអាចអនុវត្តទេវធម៌ បានគ្រប់ពេលវេលា ប្រសិនបើគេមាន ចិត្តចង់ធ្វើទេវតាក្នុងជីវិតនេះ ឬបើមិនបានជាទេវតាពេញទី ក៏គង់បានជាមនុស្សត្រឹមត្រូវដែរ ។ ការវិនិច្ឆ័យត្រង់ៗចំៗ ដោយចង្អុល ទៅលើសេចក្តីល្អ អាចធ្វើឲ្យមនុស្សធម្មតាបានល្អប្រសើរជាងទេវតាសម្មតិទេព ឬទេពដោយសន្មត ឬទេពពិតៗដែលរស់នៅលើឋានសួគ៌នោះ បានធ្វើឲ្យអស់សេចក្តីលំបាកគ្រប់យ៉ាង ដែលបានចោទជាបញ្ហាសព្វថ្ងៃនេះ ។ ព្រោះអ្វី? ព្រោះសេចក្តីល្អប្រសើរទាំងប៉ុន្មាន វាមិនមែនជារបស់សម្រាប់ជនណាម្នាក់ ឬបក្សពួកណាមួយឡើយ ។ គឺជារបស់កណ្តាលសម្រាប់សកលមនុស្ស អ្នកណាចង់បានសេចក្តីល្អ អ្នកនោះខំប្រឹងធ្វើការល្អ ឬអនុវត្តនៅទំរើរបស់ខ្លួនឲ្យត្រឹមត្រូវទៅក៏ហើយគ្នា គ្មានចាំបាច់បន់ស្រន់ សូមសេចក្តីល្អអំពីទេវតាឥន្ទព្រហ្ម ឬសូមការតែងតាំង ឬសូមសញ្ញាប័ត្រអំពីអាទិទេពណាឡើយ ។ អ្នកចង់ធ្វើទេវតានៅលើឋាន សួគ៌ក៏ស្រួលម៉្យាងដែរ តែតំណែង ឬភាពទេវតានោះគេមិនអាចទទួលយកបានក្នុងជីវិតបច្ចុប្បន្នទេ ។ គេត្រូវទទួលយកសេចក្តី ស្លាប់ជាមុនសិន ទើបទទួលតំណែង ឬទទួលភាពនោះបាន ។ ចុះបើយើងទាំងអស់គ្នាខ្លាចស្លាប់, គ្មានចង់ស្លាប់សោះយ៉ាងនេះ វាមិនផ្ទុយគ្នានិងគំនិតចង់បាននោះទៅហើយឬ? ដើម្បីកុំឲ្យខកពេលនិងសេចក្តីប្រាថ្នារបស់មនុស្ស ។ ព្រះសម្ពុទ្ធ, ទើបបង្រៀនមនុស្សឲ្យធ្វើទេវតាក្នុងជាតិនេះ ឲ្យស្រេចតែម្តង ។ លុះកំណើតនេះយើងបានជាទេវតាហើយ តើកំណើតថ្មីរបស់យើងមានអ្វីមករារាំងមិនឲ្យយើងបានទេវតាទៀត, បើពុទ្ធភាសិតបានចែងថា អ្នកណាមានធម៌ទេវតា អ្នកនោះស្លាប់ទៅកើតជាទេវតា, អ្នកណាមានធម៌សត្វតិរច្ឆាន ស្លាប់ទៅកើតជាតិរច្ឆាន ។ល។ ទន្ទឹមគ្នានេះ, ភាសិតបូរាណខ្មែរក៏មានចែងផងដែរថា ភ្លឺពីភពលោកនេះ រហូតដល់សួគ៌នាយ ។ នៅក្នុងសម័យនេះ, ឃើញថា ពុទ្ធសាសនា

បង្រៀនឲ្យមនុស្សធ្វើជាទេវតាក្នុងលោកនេះ ល្អជាងសាសនា ព្រាហ្មណ៍ដែលបង្រៀនមនុស្សឲ្យធ្វើទេវតា ក្នុងលោកខាងមុខតែម៉្យាង ឬបង្រៀនឲ្យមនុស្សគោរពប្រតិបត្តិថ្វាយបង្គំព្រះអាទិទេព ដើម្បីខ្លួនស្លាប់ទៅកើតក្នុងឋានសួគ៌ រស់នៅជាមួយនិងព្រះអាទិទេពរបស់ខ្លួន ។ ម៉្យាងទៀត, ពុទ្ធសាសនារបស់យើងមិនសូវ ត្រូវការឲ្យមនុស្សទៅកើតក្នុងឋានសួគ៌ក្នុងលោកខាងមុខទេ ។ ព្រោះអ្វី? ព្រោះកន្លែងនោះ, វាមិនមែនជាទិសដៅរបស់ពុទ្ធសាសនាផង វានាំឲ្យតែឃឹតដំណើររបស់បុគ្គល ដែលជាបេក្ខភាពនៃនិព្វានផង វាធ្វើឲ្យវិញ្ញាណរបស់មនុស្សរស់នៅក្នុភាព ច្របូកច្របល់ផង ។

ខ្ពស់ជាងនេះ, ឋានសួគ៌ក្នុងលោកដទៃ ឬទេវតាក្នុងកាមភព, រូបភព, អរូបភពនោះ, ព្រះសម្ពុទ្ធរបស់យើង, ព្រះអង្គបាន ប្រាប់ទោសក្នុងអនុបុព្វីកថាទី ៤ ហើយ បានច្រានចោលដោយអនុបុព្វីកថាទី ៥ ជាស្រេចទៅហើយ ។ ដូចនេះរឿងទេវតា ឋានសួគ៌នាយ មិនមែនជាធាតុមានតម្លៃប៉ុន្មានទេ ស៊ូទេវតាក្នុងឋានមនុស្សពុំបានឡើយ ។ ដើម្បីជាពន្លឺដល់គំនិតអ្នកអាន ក្នុងរឿងនេះទៀត, ខ្ញុំសូមធ្វើសេចក្ដីពន្យល់ថា ប្រពៃណីនិយម ឬគំនោលធម្មៈរបស់ពុទ្ធសាសនា ជាមួយនិងឋានសួគ៌និងទេវតា ក្នុងបរលោក, ព្រះបរមគ្រូរបស់យើងគ្មានដឹកនាំមនុស្សឲ្យប្រកាន់យក, គ្មានបង្រៀនឲ្យសាសនិកធ្វើបាបបុណ្យទាន ដើម្បីដូរ កំណើតមនុស្សជាកំណើតទេវតា, ដូរឋានមនុស្សជាឋានសួគ៌ដល់ម្ដងណាទេ ។ ពុទ្ធសាសនាយើង, មានគម្រោងធម៌ បង្រៀន សត្វលោកឲ្យធ្វើមនុស្ស (**ភិន្នោ មនុស្សបដិលាភោ ទុលល្លភញ្ច មនុស្សសត្តំ**) ឬបង្រៀនមនុស្សឲ្យធ្វើទេវតាក្នុងលោកនេះ តែម្ដង ។ ក្នុងទីបំផុត, បង្រៀនមនុស្សនិងមនុស្សទេពឲ្យបដិបត្តិ ឬច្នៃឋាបមនុស្សជាឋានសួគ៌ ។ គឺក្នុងចំណុចនេះហើយ ដែលពុទ្ធសាសនាមានគោលធម៌ ទាន, សីល, ភាវនា ឬសីល, សមាធិបញ្ញា ឬទិដ្ឋធម្មិកត្ថៈ, សម្បរាយិកត្ថៈ និងបរមត្ថប្រយោជន៍ ។ល។ ទានសម្រាប់ធ្វើឲ្យអស់នូវភាពឯយុត្តិធម៌ក្នុងសង្គម, ភាវនាសម្រាប់ធ្វើឲ្យអស់នូវភាពប្រកែប្រកាន់ជាតិសាសន៍វណ្ណៈ ពណ៌សម្បុរអម្បូរត្រកូល រហូតដល់ទំរើប្រណាំងប្រជែងគ្នា ខាងទ្រព្យសម្បត្តិ យសស័ក្តិ ឫទ្ធិអំណាចដោយអូតមាន, អួតធំ, អួតចេះ ។ល។ លែងខ្វីវល់ពីសកលសង្គមកិច្ច សកលយុត្តិធម៌សង្គម និងសកលមនុស្សធម៌ ។ មានកត្តាមួយទៀតដែលយើង ត្រូវដឹងជាមួយគ្នានេះដែរ គឺពុទ្ធសាសនាគ្មានបានបង្ហាត់មនុស្សឲ្យមានពំនឹងអំណាងលើទេវតា ឬលើនរណាដទៃក្រៅពីខ្លួន របស់ខ្លួន (**អត្តាហិ អត្តនោនាថោ** . . . .) អំពីពំនឹងនេះសូម្បីព្រះពុទ្ធ ព្រះអង្គឯងក៏ពុំបានយល់ព្រមធ្វើជាពំនឹង ធ្វើជាតំណាងឲ្យមនុស្សណាម្នាក់ឡើយ ។ ភាពច្បាស់លាស់ក្នុងរឿងនេះ, គឺពុទ្ធពំនោលដែលបានធ្វើជាមួយនិងភិក្ខុវក្កលិមានសេចក្ដីថា : ម្នាលវក្កលិអ្នណាឃើញធម៌ អ្នកនោះឃើញតថាគត, អ្នកស្គាល់ធម៌, អ្នកនោះស្គាល់តថាគត, អ្នកណារាប់អានធម៌, អ្នកនោះ រាប់អានតថាគត, អ្នកណាគោរពប្រតិបត្តិធម៌, អ្នកនោះគោរពប្រតិបត្តិតថាគត ។ ប្រសិនបើមានសំណួរថាអ្វីជាធម៌? ចម្លើយ ទំរើ ទូទៅជាធម៌ ។ ពុទ្ធសាសនាចែកធម៌ជា ៤ប្រភេទគឺ : គុណធម៌ ១ ទេសនាធម៌ ១ បរិយត្តិធម៌ ១ និស្សិតនិជ្ជិវធម៌ ១ ។ ធម៌ក្នុងតម្រាស់ខាងលើនេះ, លោកដៅយកគុណធម៌ ។ គុណធម៌មានពីរយ៉ាងគឺ : ទំរើអាក្រក់ហៅថាគុណវិបត្តិ ទំរើល្អហៅថាគុណសម្បត្តិ ដែលយើងធ្លាប់ចេះចាំមកថា កុសលកម្ម អកុសលកម្ម ឬបុណ្យបាបហ្នឹងឯង ។ ព្រះសម្មាសម្ពុទ្ធ, ពុំបានទុកដាក់ខ្លួន ព្រះអង្គជាពំនឹងរបស់សកលសត្វ ។ សេចក្ដីនេះយើងអាចវិនិច្ឆ័យបានថា ក្រៅពីធាតុមួយដែលមានឈ្មោះថា «កម្ម» គ្មានធាតុណាដទៃទៀតជាពំនឹងរបស់សត្វលោកទេ ។ សេចក្ដីវិនិច្ឆ័យរបស់យើងនេះបានស្របទាំងស្រុងលើពុទ្ធភាសិតក្នុង អភិណ្ហបច្ចវេក្ខណសូត្រ ដែលមានសំនេររបស់ខ្ញុំក្នុងខាងដើមហើយ ។ បើព្រះពុទ្ធបរមគ្រូរបស់យើង ព្រះអង្គមិនហ៊ានប្រទានខ្លួន ព្រះអង្គជាពំនឹងរបស់សកលសត្វទៅហើយ, តើមាននរណាហ៊ានចេញមុខប្រគល់ខ្លួនឲ្យជាពំនឹង, ឲ្យជាអំណាងរបស់យើងទៀត? តើអ្នកពឹកពាក់លើទេវតានាំគ្នាបន់ស្រន់បួងសួងសុំជំនួយពីទេវតាសពហរថ្ងៃនេះ មានចម្លើយអំពីទេវតាអស់ទាំងនោះដែរឬទេ? តើទេវតារស់នៅ

លើឋានសួគ៌នោះបានប្រគល់ខ្លួនគេឲ្យជាពំនឹងរបស់យើង ដូចយើងដៅស្មានមែនឬ? តើជាតុទេវតាជារបស់សាសនាព្រាហ្មណ៍ ឬពុទ្ធសាសនា? សំណួរទាំងឡាយនេះ, សូមអ្នកអានរកគំនិតឲ្យចម្លើយខ្លួនឯងចុះ ។ ការធ្វើបុណ្យទាន, រង់ចាំស្លាប់បានទៅកើតជាទេវតា វាមិនសូវទៀងទាត់ដូចធ្វើខ្លួនជាទេវតាក្នុងជីវិតនេះ ធ្វើលោកឲ្យទៅជាលោកឋានសួគ៌ទេ ។ ព្រោះអ្វី? ព្រោះមនុស្សយើងម្នាក់ៗ មិនសូវមានអ្នកធ្វើតែបុណ្យ គ្មានធ្វើបាបទេ វាច្រើនតែមានបុណ្យបាបចម្រុះគ្នា ។ ជាធម្មតា, តែងមានបុណ្យខ្លះបាបខ្លះ វាត្រូវមានវិបត្តិកំណើតបើមិនច្រើនក៏តិចដែរ ។ ការវិបត្តិកំណើតបានន័យថា អាចកើតក្នុងឋានសួគ៌ក៏មាន ឋាននរកក៏មានឋានប្រេតក៏មាន ឋានណាដទៃទៀតក៏មាន ។ល។ អ្នកអានធ្លាប់បានឃើញសំនេររបស់ខ្ញុំក្នុងសៀវភៅនានា នឹងបានស្តាប់សម្តែងរបស់ខ្ញុំក្នុងទីផ្សេងៗ គង់នៅចាំបានថាខ្ញុំបានផ្អែកលើគំនោលធម្មៈនៃពុទ្ធសាសនាហើយទេសន៍និង សរសេរថា មនុស្សដែលបានប្រព្រឹត្តទំរើល្អ, មានជីវិតនៅក្នុងសីល, សមាធិ, បញ្ញាមានតម្លៃខ្ពស់ជាងពួកមនុស្សនិងទេវតាដែល មានទំរើមានការ រស់នៅផ្ទុយពីនេះ ។ ក្នុងន័យថា ទេវតាក្នុងឋានសួគ៌ ឬទេវតាពិតៗ អាចទាបថោកជាងមនុស្សបានប្រសិនបើទេវតានោះគ្មានធម៌ល្អ, គ្មានគំនិតថ្លៃថ្នូរ ។ កំណើតទេពបានដោយផលបុណ្យក៏ពិតមែនហើយ តែបើបានហើយ ខ្លួនអ្នកមិនបានប្រព្រឹត្តប្រតិបត្តិធម៌មិនបានអនុវត្តជីវិតក្នុងផ្លូវសុចរិតយុត្តិធម៌ ឲ្យសមជាទេវតាក៏ស៊ូមនុស្សប្រព្រឹត្តល្អពុំបានឡើយ ។ ដូចនេះគុណលក្ខណៈល្អពិសេសនៃពុទ្ធសាសនា ដែលមានសេចក្តីក្លាហាននិយាយថា មនុស្សធម្មតាអាចល្អជាង, ខ្ពស់ជាងទេវតាទើប ជាធាតុពិសេសពិតៗដែលគេពុំអាចនឹងរកបានក្នុងសាសនាដទៃ ។ ព្រោះអ្វី? ព្រោះសាសនាដទៃគេថាទេវតាល្អប្រសើរជាង ចង់ទេវតានោះមានចិត្តគំនិតមិនល្អ មិនត្រឹមត្រូវយ៉ាងណាក៏ដោយ ។ គឺគេគ្មានគិតគួរដល់តម្លៃគុណធម៌ល្អ ដែលជាធាតុសម្រាប់ថ្នៃសត្វទេ, គេគិតត្រឹមតែឋានរបស់មនុស្ស ទេវតាតែម៉្យាង ។ អ្នកណាមានឋានៈធំ, ចង់មានមារយាទអាក្រក់យ៉ាងម៉េចក៏នៅតែធំ នៅតែល្អដដែល, អ្នកណាមាន ឋានៈជាទេវតាចង់មានពុតត្បុតអាក្រក់អាក្រីដូចម្តេច ក៏នៅតែជាទេវតាមានភាពថ្លៃថ្នូរដដែល ។ បើនិយាយឲ្យងាយស្តាប់ជាងនេះ គឺតំណែងឬកំណើតទេវតានេះគេចងផ្តាច់មុខជាស្រេចតែម្តង, គេគ្មានអនុញ្ញាត ឬទទួល ស្គាល់មនុស្សណាដែលគ្មាមានធម៌ល្អបានប្រព្រឹត្ត បានកាន់ធ្វើជាទេវតាផងបានទេ ។ ចំណែកព្រះពុទ្ធសាសនាគ្មាន ចងផ្តាច់មុខ នូវតំណែងនូវកំណើតណាមួយទេ ។ តំណែងជាទេវតាថ្នាក់ជាន់ណាក្តី តំណែងជាព្រះពុទ្ធប្រភេទណាមួយក្តី អ្នកណាត្រូវការអ្នកនោះខំបំពេញទេវធម៌និងពុទ្ធការកធម៌ នៅក្នុងក្របខ័ណ្ឌនៃការតស៊ូ ដើម្បីតំណែងនោះទៅ ថ្ងៃណាមួយខ្លួនគេនឹងទៅដល់តំណែងដែលខ្លួនត្រូវការជាមិនខានឡើយ ។ ប្រែថាពុទ្ធសាសនាទុកឋានៈ, ឬតំណែងកំណើត ។ល។ ជារបស់សាធារណៈ សម្រាប់សកលមនុស្សក្នុងលោក អ្នកណាចង់បានឋានៈជាអ្វី ចង់រស់នៅក្នុងតំណែងណាចង់មានកំណើតជាមនុស្ស ឬជាទេវតា ។ល។ អាចប្រើសិទ្ធិ ឬប្រតិបត្តិធម៌ ឬធ្វើការងារដើម្បីយកឋានៈ ឬតំណែង ឬកំណើតនោះៗ ស្រេចហើយតែចំណង់ របស់ខ្លួន ។ នៅក្នុងចំណុចនេះឯង, ដែលអ្នកស្រាវជ្រាវជាច្រើនបានទទួលស្គាល់ថាពុទ្ធសាសនាជាសាសនាវិទ្យាសាស្ត្រមិនមែន ជាសាសនាអាទិទេព ឬសាសនាធម្មជាតិឡើយ ។ ក្នុងន័យថាសាសនានេះ មិនត្រឹមតែប្រមូលមនុស្សឲ្យរស់នៅជាមួយនិងបញ្ញា ប្រកបដោយហេតុផលប៉ុណ្ណឹងទេ គឺជាសាសនាមានសេចក្តីស្មោះត្រង់ចំពោះសកលមនុស្ស ដោយគ្មានឲ្យនូវអភ័យឯកសិទ្ធិ ឬអភ័យឯកសិទ្ធិណាមួយមាននៅក្នុងគំនោលធម្មៈសូម្បីបន្តិចបន្តួចឡើយ ។

ដើម្បីឲ្យអ្នកអាន ក្នុងរឿងឋាននរកឋានសួគ៌ប្រៀបធៀបនឹងទេវតា ដែលមានមកហើយក្នុងសំនេររបស់ខ្ញុំ ខ្ញុំសូមធ្វើសំណួរថា នរកមានឬគ្មាន? ដែលខ្ញុំធ្លាប់បានធ្វើការវិនិច្ឆ័យខាងផ្លូវទេសន៍និងផ្លូវសំនេរខ្លះៗ មកហើយក្នុងក្របខ័ណ្ឌនៃគំនិតប្រកប ដោយហេតុផល ។

យ៉ាងណាក៏ដោយ, ខ្ញុំយល់ឃើញថា ក្នុងបច្ចុប្បន្នកាលនេះ ដរាបណាយើងកាន់តែប្រើធម្មៈនៃពុទ្ធសាសនា

ប្រកបដោយហេតុផល ឬយើងធ្វើការពិសោធន៍ធម៌នៃព្រះពុទ្ធសាសនា ឲ្យមានលក្ខណៈជាវិទ្យាសាស្ត្រជរាបនោះ យើងកាន់តែមានជំនឿមាំមានសេចក្តីពេញចិត្តខ្លាំង ដោយសារយើងមានបញ្ញាកាន់តែច្រើន ។ គឺបញ្ញានេះហើយ ដែលធ្វើឲ្យយើងរស់នៅជាមនុស្សប្រកប ដោយហេតុផល ។ គឺហេតុផលនេះហើយ ដែលធ្វើឲ្យ ពុទ្ធសាសនាទាន់សម័យ ឬនាំសម័យ ។ ពំនោលខ្លីគឺពុទ្ធសាសនាជា វិទ្យាសាស្ត្រ វិទ្យាសាស្ត្រជាពុទ្ធសាសនា ។ កាលបើដូចនេះ ពុទ្ធសាសនារបស់យើងមុខជាមិនអស់អាយុក្នុងគម្រប់ ៥០០០ ដូចការស្មានរបស់មនុស្សពួកខ្លះដែលយើងបានដឹងឮមកហើយនោះទេ ។

## នរកសួគ៌មានពិតឬគ្មានទេ?

បញ្ហានរកសួគ៌មានឬគ្មាននេះ ជាបញ្ហាដែលសង្គមបច្ចុប្បន្នចាប់អារម្មណ៍យ៉ាងខ្លាំង ព្រោះបើយើងអាចស្រាយបញ្ហានេះ បានច្បាស់លាស់ ឬអាចធ្វើសេចក្តីបំភ្លឺឲ្យមនុស្សសាមញ្ញចូលចិត្តបានងាយ ។ ការរាប់អាន ឬកាន់ពុទ្ធសាសនារបស់យើងនឹង កាន់តែមានហេតុផល មានប្រសិទ្ធិភាពយ៉ាងពេកកូវ ។ ជាពិសេសគឺយើងត្រូវបានឈ្មោះថា ជាអ្នកមានជំនឿក្នុងព្រះពុទ្ធសាសនា ប្រកបដោយបញ្ញាមួយអន្លើនិងគំនិតពិចារណាយ៉ាងមធ្យ័ត ។ ទន្ទឹមគ្នានេះ, ពុទ្ធសាសនិកយើងនឹងអស់សេចក្តីសង្ស័យ, អស់មានខ្វែងមតិ ខ្វែងយោបល់គ្នាជារឿយៗ ក្នុងពេលនិយាយគ្នាដល់សាសនាដែលខ្លួនកាន់ ខ្លួនប្រព្រឹត្តប្រតិបត្តិក្នុងចំណុចថា មានហេតុផល ឬគ្មាន, បើមានក្តី គ្មានក្តីតើមានកម្រិតនៅក្នុងថ្នាក់ជាន់ណា?

មុននឹងវិនិច្ឆ័យសម្រេច, យើងសូមចែកនរកសួគ៌ជាថ្នាក់ៗ មានដូចនេះ :

១- នរកសួគ៌នៅក្នុងចិត្តវិញ្ញាណរបស់មនុស្ស,

២- នរកសួគ៌មើលឃើញដោយភ្នែកក្នុងពិភពលោកបច្ចុប្បន្ន,

៣- នរកសួគ៌មើលមិនឃើញដោយភ្នែក គឺនរកសួគ៌ក្នុងពិភពលោកដទៃ ។

សេចក្តីបំភ្លឺ នរកសួគ៌ដែលបានចែកជា ៣ ប្រភេទតាមលំដាប់ ។

### ប្រភេទទី ១
### នរកសួគ៌ក្នុងចិត្តវិញ្ញាណរបស់មនុស្ស

ពុទ្ធសាសនាមានជំនឿថា ចិត្តវិញ្ញាណរបស់មនុស្សយើងនេះជាធាតុមានភាពសំខាន់ជាទីបំផុតធាតុនេះវាមានសមត្ថភាពដាក់បញ្ជាឲ្យរូបកាយ ពាក្យសម្តីធ្វើការអ្វីៗ បានទាំងអស់ទោះជាការអាក្រក់ក្តី ល្អក្តី ស្រេចហើយតែចិត្តដឹកនាំ ។ ឯកាយវាចា ធាតុទាំងពីរនេះ មានមុខងារមានភាពត្រឹមតែជាទីអាងសម្រាប់តែចិត្តទាញញាក់ប៉ុណ្ណោះ ។ ចិត្តចង់ឲ្យកាយវាចា ដើរតួជាអ្វី ធ្វើនូវទំរើណា ពោលនូវពំនោលណា ធាតុទាំងពីរនេះក៏ទទួលអនុវត្តតាមបញ្ជារបស់ចិត្តទៅ ។ ចិត្តជាធាតុទទួលដឹង ទទួលស្គាល់ ទទួលខុសត្រូវចំពោះមុខងារទាំងអស់ដែលកាយវាចាបានធ្វើ ។ ក្នុងពេលមានមនុស្សដទៃវាយប្រហាររូបកាយ ដោយរូបកាយក្តីឆ្លើយឆ្លងសម្តីដោយសម្តីក្តី ចិត្តចេញមុខធ្វើការជំនួស ។ ពេលដំណេកលក់, ចិត្តក៏សម្រាកសម្ងំស្ងៀម, ក្នុងពេលនោះអ្នកណាមកជេរស្តី ត្មិះតិះដៀលយ៉ាងណាអ្នកដំណេកលក់គ្មានកំហឹងតំណប ព្រោះចិត្តមិនដឹង ។ នេះបញ្ជាក់ឲ្យឃើញថា រូបកាយប្រាសចាកឬគ្មានចិត្តធ្វើការក៏គ្មានខុសគ្នានឹងដុំដី ។ ដោយចិត្តមានមុខងារទទួលខុសត្រូវចំពោះទំរើផ្សេងៗ ដែលខ្លួនបានបញ្ជាទៅលើកាយវាចាដូចនេះហើយ បើពុទ្ធសាសនាដាក់បញ្ជាឲ្យសាសនិកសិក្សាអំពីរឿងរបស់ចិត្ត នៅក្នុងកម្រិតខ្ពស់ជាពិសេស ។

កាលណាចិត្តធ្លាក់ចូលក្នុងភាពអាក្រក់ (កិលេសជាតិ) បញ្ជាដែលចិត្តបានធ្វើទៅលើកាយវាចា ក៏ជាធាតុមានភាពអាក្រក់ ។ ទំរើរបស់កាយវាចាក៏មានភាពអាក្រក់អាក្រីថោកទាបដូចគ្នានិងចិត្តដែរ ។ ចិត្តមានលក្ខណៈដូចនេះ

ជាចិត្តពោរពេញទៅដោយកម្តៅ ព្រោះម៉្យាងត្រូវដុតដោយភ្លើងកិលេស (រាគៈ ទោសៈ មោហៈ) ម៉្យាងទៀតព្រោះផលវិបាកនៃទំរើអាក្រក់ដែលខ្លួនបានធ្វើ, បានប្រព្រឹត្តស្វែងរកឱកាសតាមផ្តន្ទាធ្វើទុក្ខបុកម្នេញអស់កាលជានិច្ច ។ ជនរស់នៅដោយទំរើទុច្ចរិតលួចប្លន់បោកប្រាស់អ្នកដទៃ ឬជនដែលក្រាស់ទៅដោយភាពកំណាញ់កំហឹង កម្ដៅគំលាន មួយអន្លើដោយសេចក្ដីច្រណែនឫស្យាគ្នាន់ក្នាញ់ដុកដាន់ រមែងមានចិត្តក្ដៅក្លួលឆេះអន្ទះសាស្លឈាមអស់កាលទាំងយប់ទាំងថ្ងៃនេះគឺជាឋាននរកក្នុងលោកនេះ គឺជានរកខាងផ្លូវចិត្តហ្នឹងឯង ។ ផ្ទុយទៅវិញ, បើចិត្តប្រកបដោយគុណធម៌ល្អ ដូចជាព្រហ្មវិហារធម៌ ៤, បុញ្ញកិរិយាវត្ថុ ១០ ។ល។ ចេះមេត្តារាប់រកមនុស្សដទៃ, មានគំនិតមនុស្សធម៌ចង់ឲ្យអ្នកមានទុក្ខរួចផុតចាកទុក្ខ, ឃើញគេបានសុខជួយអរជួយសប្បាយ, ជួបគេឈ្លោះគ្នា ជួយរកយុត្តិធម៌, មិនច្រណែនឫស្យានឹងភាពរុងរឿងអ្នកដទៃ, គ្មានឥរិយាបថព្រហើនកោងកាច, ស្គាល់បុណ្យស្គាល់បាប, ស្គាល់តម្លៃមនុស្សរស់នៅក្នុងភាពស្ងប់ស្ងាត់ ក្នុងសន្តិភាពនៃជីវិត ។ល។ នេះគឺជាឋានសួគ៌របស់ជីវិតក្នុងលោកនេះ គឺឋានសួគ៌ផ្លូវចិត្តហ្នឹងដែរ ។ ព្រោះអាស្រ័យហេតុនេះ, មនុស្សអាចធ្លាក់នរកឡើងឋានសួគ៌បាន ឬទៅជាសត្វនរក, សត្វតិរច្ឆាន, សត្វប្រេត, សត្វមនុស្ស, សត្វទេព, សត្វព្រហ្ម, សត្វអរូបព្រហ្មបាន ។ល។ ខ្ពស់បំផុត, គឺទៅជាព្រះអរិយបុគ្គល, ព្រះសម្មាសម្ពុទ្ធ, ព្រះបច្ចេកពុទ្ធ ស្រេចហើយតែទំរើអាក្រក់ល្អ ដែលមនុស្សបានធ្វើ បានប្រកបនៅក្នុងកម្រិតតិចច្រើន ថ្នាក់ណាជាន់ណាប៉ុណ្ណោះ ។

## ប្រភេទទី ២
## នរកសួគ៌ដែលមើលឃើញបានដោយភ្នែក

ជនដែលធ្លាប់បានចូលទៅមើលក្នុងគុក គង់បានឃើញមនុស្សដែលធ្លាក់នរកក្នុងជីវិតនេះ ។ មនុស្សជាប់គុកគ្មានរស់នៅក្រោមទំរើជិះជាន់បៀតបៀនធ្វើបាប ដែលប្រព្រឹត្តដោយភ្នាក់ងាររក្សាគុក គ្នាខំប្រឹងទ្រាំរស់, ទ្រាំសេចក្ដីលំបាក, ទ្រាំខាំមាត់ទទួល ទារុណកម្មយ៉ាងកំណាចពីអជ្ញាធរគុក នៅក្នុងលក្ខណៈផ្សេងៗគ្នា អស់រយៈកាលឆាប់ខ្លះយូរខ្លះ មួយជីវិតខ្លះតាមគួរដល់ ទោសានុទោស ដែលខ្លួនគេបានវិនិច្ឆ័យឲ្យ ទំនងជួបគ្នានឹងជនដែលបានប្រព្រឹត្តល្អ, ជាពលរដ្ឋត្រឹមត្រូវ មិនល្មើសច្បាប់របស់ប្រទេស ឧស្សាហ៍ធ្វើការងាររកស៊ីចិញ្ចឹមជីវិត, លើកឋានៈជីវភាព, លើកកម្ពស់របស់ជីវិតនៅក្នុងក្របខ័ណ្ឌមានស៊ី មានចាយ មានផ្ទះ មានដីស្រែចម្ការ យន្តយានពាហនៈប្រើប្រាស់ប្រកបដោយសេចក្ដីសុខសប្បាយ ។ ទ្រព្យសម្បត្តិទាំងឡាយដែលជាទីពេញចិត្ត ជាទីប្រាថ្នា ក៏មានគ្រប់គ្រាន់បរិបូណ៌ ។ ឋានៈជននេះ, បើប្រៀបទៅនឹងឋានៈរបស់ជនអ្នកទោស ដូចពោលមកក៏អាច ឃើញបានថា មានកម្រិតខុសគ្នាដូចមេឃនិងដី ឬដូចទិសខាងកើតនិងទិសខាងលិចយ៉ាងច្បាស់ក្រឡែត ។ នេះគឺជានរកសួគ៌ដែលពុទ្ធសាសនាបង្រៀនឲ្យមនុស្សមើលឃើញនូវផលវិបាក នៃទំរើអាក្រក់ល្អដើម្បីបណ្ដុះគំនិតចងចាំ នៅក្នុងក្របខ័ណនៃសេចក្ដីផ្សេងគ្នាក្នុងបច្ចុប្បន្នទាន់ភ្នែក ។

## ប្រភេទទី៣
## នរកសួគ៌ពិតដែលឃើញមិនបានដោយភ្នែក

យើងធ្លាប់បានឮពាក្យថ្លែងរឿងនរកសួគ៌ ប្រកបដោយភាពវិចិត្រពិស្ដារពន់ពេកណាស់ គ្មានមនុស្សណាម្នាក់ឮហើយមិនចាប់អារម្មណ៍ មិនយកចិត្តទុកដាក់ទេ តែសេចក្ដីបំព្រួញខ្លីមានត្រឹមថា នរកមានមកសម្រាប់ធ្វើទោសអ្នកប្រព្រឹត្តទំរើអាក្រក់ ។ សួគ៌មានមកសម្រាប់ឲ្យរង្វាន់អ្នកប្រព្រឹត្តទំរើល្អ ។ បញ្ហាសំខាន់ក្នុងរឿងនេះ នៅត្រង់ថានរកសួគ៌ដូចមាននៅក្នុងពំនោលនោះ, វាជាធាតុមានមែន ឬពុំមានទេ ។ បើមានម៉េចយើង មើលមិនឃើញ ។ ប្រសិនបើនិយាយគ្នាត្រឹមឃើញ មិនឃើញ បញ្ហានេះពុំសូវលំបាកប៉ុន្មានទេ ។ ព្រោះអ្វី? ព្រោះកុំថា ដល់នរកសួគ៌ដែលគេចូលចិត្តថា មានលំនៅក្នុងលោកដែមិនមែនមានលំនៅក្នុងលោក ជាមួយនិង យើងឡើយសូម្បីប្រទេស

ឬនគរដែលនៅក្នុងលោកជាមួយនិងយើង តែនៅឆ្ងាយពីប្រទេសយើងក៏មើល គ្មានឃើញដូចគ្នា ។ អ្នកស្គាល់ស្រុកប្រទេសអស់ទាំងនោះក្រៅពីធ្វើដំណើរទៅឲ្យបានដល់ដោយខ្លួនឯង គេត្រូវ អាស្រ័យដំណឹងពីពួក ទេសចរណ៍ ។ បញ្ហានរកសួគ៌មានពិតប្រាកដនោះ គម្ពីរពុទ្ធសាសនាយើងក៏បានចែងថាមាន, អ្នកប្រព្រឹត្តធម៌ជាន់ខ្ពស់បាន សម្រេចអភិញ្ញាមានភ្នែកទិព្វក៏ប្រាប់ថាមានដូចគ្នា ។ ចំណែកពាក្យថ្លែងពណ៌នាថា ល្អអាក្រក់យ៉ាងទូលំទូលាយនោះ វាជារឿងអួត ឬរឿងបង្អាប់ទេ, យើងដឹងក៏បាន មិនដឹងក៏បាន វាគ្មានកើតបុណ្យបាបអំពីរឿងនេះឡើយ ។ ករណីយ៍របស់យើងក្នុងរឿងនេះ គឺខ្លាចបាប, ហ៊ានបុណ្យ, ស្អប់ទុក្ខ, ស្រឡាញ់សុខ, លះបង់កម្មអាក្រក់ កសាងកម្មល្អ ។ល។ ជាពិសេសគឺកុំញៀននឹងឋានសួគ៌ កុំព្រហើននឹងឋាននរក ។ នេះគឺជាមុខងាររបស់អ្នកមានជំនឿ មានសេចក្ដីចូលចិត្តថា នរកសួគ៌មានប្រាកដ ដោយអាស្រ័យតាមដំណឹងជើង គម្ពីរនៃពុទ្ធសាសនារបស់យើងខ្លះ ឬសំអាងលើពាក្យប្រាប់របស់អ្នកបានសម្រេចធម៌ជាន់ខ្ពស់ខ្លះ, ជាហូរហែមកហើយ ។ ជំនឿនិងចំណូលចិត្តនេះ វាចប់ស្រេចប៉ុណ្ណឹងហើយ គ្មានចោទជាបញ្ហាអីទៀតទេ ។ សម្រាប់អ្នកគ្មានជំនឿ ចំណូលចិត្តតាមជើងគម្ពីរ ឬបម្រាប់, ពួកនេះនៅមានបញ្ហាចោទរឿងនរកសួគ៌មានគ្មាននៅឡើយ ។ ដើម្បីវិនិច្ឆ័យរឿងនរកសួគ៌ក្នុងចំណុចមាន ឬគ្មានសម្រាប់មនុស្សពួកក្រោយនេះ ប្រសិនបើគ្មានផ្អែក, គ្មានអាស្រ័យ, គ្មានពឹងគំនិតវិទ្យាសាស្ត្រសម័យបច្ចុប្បន្ន មកជួយជាគូខ្វែរក្បាលផងទេនោះ គ្មានមុខនរណាមានសមត្ថភាពអាចបំភ្លឺ ឲ្យយល់បានក្នុងរឿងមាន ឬគ្មាននរកសួគ៌ទេ ទោះណា ជាពុទ្ធសាសនាយើងមានលក្ខណៈវិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រ តែម្តងក៏ដោយ ។

ដើម្បីបំភ្លឺពួកអ្នកគ្មានជំនឿ, មុនដំបូងយើងត្រូវធ្វើសំណួរទៅគេជាមុនថា ម៉េចក៏មិនជឿ? តើមានគំនិតដូចម្តេច? មានហេតុផលក្នុងរឿងគ្មាននរកសួគ៌យ៉ាងណាខ្លះ? ចំពោះសំណួរនេះ យើងនឹងបានទទួលចម្លើយថា ព្រោះមិនដឹង, មិនឃើញ, មិនប្រាកដ ឬនាំមកបង្ហាញមិនបាន ។ ចំណែកយើងវិញ ការវិនិច្ឆ័យបញ្ហាណាៗក៏ដោយ, យើងនឹងប្រកាន់យក ឬអាងដល់សេចក្ដីមិនដឹង មិនឃើញច្បាស់លាស់មកធ្វើជាហេតុផល, ជាមូលដ្ឋានហើយវិនិច្ឆ័យថា របស់នេះ របស់នោះ ហេតុការណ៍ ដូចនេះ ហេតុការណ៍ដូចនោះ មិនពិត មិនមែន ឬគ្មានពុំបានឡើយ ។ អ្នកប្រព្រឹត្តល្មើសច្បាប់, ដោយអាងថាខ្លួនមិនបានស្គាល់ ច្បាប់ អំណាងនេះគ្មានទម្ងន់ គ្មានមូលហេតុត្រឹមត្រូវទេ តុលាការមិនលែងខ្លួនឡើយ ។ មនុស្សមិនស្គាល់ភ្លើងថាជាធាតុមានកម្តៅ ហើយក៏យកដៃទៅចាប់ភ្លើង, ភ្លើងក៏មិនទទួលដឹងនូវភាពមិនស្គាល់របស់គេ ។ ភ្លើងមិនឈប់ធ្វើសកម្មភាពឲ្យយើងរលាកដៃឡើយ ។ អ្នកស្រាយបញ្ហាមួយៗ ត្រូវតែចេះ, ត្រូវតែដឹង, ត្រូវតែស្គាល់មូលហេតុសម្រាប់ស្រាយ ។ បើមិនចេះ, មិនដឹង, មិនស្គាល់មូលហេតុ . . . . វាអាចធ្វើឲ្យសម្រាយរបស់ខ្លួនគ្មានតម្លៃខ្ពស់ ព្រោះទំរើនេះគេត្រូវធ្វើនៅលើមូលដ្ឋាននៃសេចក្ដីចេះដឹង វៃឆ្លាត បើមិនបានដឹងទាំងអស់ក៏ត្រូវតែបានដឹងខ្លះ ដើម្បីប្រកបជាមួយនិងហេតុផល ដែលជាប្រធានធំបំផុតសម្រាប់បំភ្លឺគំនិតអ្នកវិនិច្ឆ័យ ។ ក្នុងចំណុចមួយទៀត, ដែលអាងថា ពុំអាចនឹងវិនិច្ឆ័យបានព្រោះនាំយកវត្ថុដែលត្រូវគេសង្ស័យមកបង្ហាញឲ្យមើលមិនបាននោះ អំណាងនេះហួសត្រូវហួសនិយាយទៅហើយ, ព្រោះវាគ្មានមុខនរណាទៅលើកឋាននរកសួគ៌មកបានទេ បើនរកសួគ៌ជាធាតុមួយឋិតនៅក្នុងលោកដទៃ ក្រៅពីលោកយើងនេះទៅហើយ ។ កុំបាច់ស្ដីដល់នរកសួគ៌ ដែលឋិតនៅក្នុងលោកដទៃ សូម្បីភ្នំហិមាល័យដែលឋិតនៅក្នុងលោកយើងនេះ ក៏គ្មានមុខនរណាទៅលើកយកមកបង្ហាញគ្នាបានឡើយ ។ អ្នកស្គាល់ភ្នំហិមាល័យក៏ដោយសារពួកទេសចរណ៍ ដែលគេបានទៅដល់ហើយគេនិយាយប្រាប់ ឬសរសេរសៀវភៅ ដើម្បីអ្នកមិនធ្លាប់បានទៅ បានអាន បានស្គាល់ផងប៉ុណ្ណោះ ។ ប្រសិនណាបើយើងបានឮពាក្យគេនិយាយប្រាប់ ឬបានអានសៀវភៅរបស់គេដែលស្ដី អំពីភ្នំហិមាល័យមានភាពលក្ខណៈយ៉ាងនេះ យ៉ាងនោះ ហើយយើងនៅតែគ្មានជំនឿថា មានភ្នំហិមាល័យនោះទៀត ។ ភ្នំហិមាល័យ, ក៏វានៅភ្នំហិមាល័យដដែល វាគ្មានរលតរលាយបាត់ទៅ ព្រោះតែយើងគ្មានជំនឿពុំបានទទួលស្គាល់វាថា ជាភ្នំមាន

ពិតប្រាកដនោះឡើយ នរកសួគ៌ក៏មានទំនាក់ទំនងដូចគ្នានឹងភ្នំហិមាល័យដែរ ។ តាមសេចក្ដីបំភ្លឺរបស់អ្នកអប់រំហ្វឹកហាត់ចិត្តជាន់ខ្ពស់ថា នរកសួគ៌មានកំណើត មានលំនៅផ្សេង មិនមែននៅក្នុងលោកមនុស្សទេ ។ ទាំងឋានទាំងកំណើតជាធាតុមាន ឯកទេសពិសេសដោយឡែក ។ អ្នកចង់ស្គាល់ចង់ឃើញ ត្រូវមានគ្រឿងឧបករណ៍គឺភ្នែកទិព្វ ។ ជាមួយគ្នានេះទៀត, ត្រូវបង្កើនការហ្វឹកហាត់អប់រំចិត្តឲ្យមានកម្លាំងខ្លាំងក្លា ទើបមានសមត្ថភាពអាចមើលឃើញបាន ។ អ្នកវិទ្យាសាស្ត្រខាងចិត្តវិញ្ញាណ ក្នុងសម័យបច្ចុប្បន្នដូចដុកទ័រថៅលេស្ស, ដុកទ័រថៃរេស, ដុកទ័រីសូល, ដុកទ័រហោតទិងគ្គីរ៍ ដែលមានជីវិតរស់នៅក្នុងប្រទេសអង់គ្លេស និងដុកទ័ររ៉ែន៍ដែលមានជីវិតរស់នៅក្នុងសហរដ្ឋអាមេរិកទាំងអស់គ្នាបានព្យាយាមពិសោធន៍ សមត្ថភាពដែលមាន និយាយក្នុងរឿងភ្នែកទិព្វរឿងចេតោបរិយញ្ញាណ (កំណត់ដឹងចិត្តអ្នកដទៃ) តាមកម្មវិធីខាងវិទ្យាសាស្ត្រ ហើយបានធ្វើសេចក្ដី បញ្ជាក់ឲ្យឃើញថា មនុស្សយើងបើបានហ្វឹកហាត់អប់រំចិត្ត តាមផ្លូវសមាធិបានបទហើយគេអាចនឹងមានសមត្ថភាពបានដឹង, បានមើលឃើញរបស់ផ្សេងៗ ដែលកើត ដែលមាននៅក្នុងភាពអាថ៌កំបាំង ដែលមនុស្សធម្មតា គ្មានសមត្ថភាពអាចដឹង អាចមើលឃើញបាននោះ ។

អ្នកវិទ្យាសាស្ត្រដែលបានធ្វើការស្រាវជ្រាវរកជម្ងឺរបស់សត្វទាំងឡាយ មានសត្វមាន់ជាដើមក្ដីរកជម្ងឺទាំងឡាយ របស់មនុស្សមានជម្ងឺពិសក្លាយ, អុតធំ, អាសន្នរោគជាដើមក្ដី គេត្រូវមានប្រដាប់កែ ប្រដាប់ឆ្លុះគ្រប់បែបគ្រប់យ៉ាង ជាពិសេសគឺគ្រឿងឧបករណ៍មួយ ដែលមានឈ្មោះអតិសុខុមទស្សន៍ ដោយអាស្រ័យគ្រឿងឆ្លុះ ឬគ្រឿងពង្រីកនេះហើយទើបគេមើលឃើញ មេរោគទាំងឡាយ មានមេរោគពិសក្លាយជាដើមបាន, ព្រោះគ្រឿងឧបករណ៍ទាំងនេះ វាមានសមត្ថកិច្ចធ្វើឲ្យគ្រូពេទ្យមានសម្ថភាព រុករកមេរោគឃើញ អតិសុខុមប្រាណទាំងឡាយនេះយើងមើលវាដោយភ្នែកធម្មតាមិនឃើញទេ ។ ប្រសិនបើយើងមិនព្រមទទួលស្គាល់មិនព្រមមានជំនឿ, មិនព្រមទទួលប្រើប្រាស់ឧបករណ៍ទាំងឡាយនេះទេ យើងមុខជាគ្មានចូលចិត្តថា មានសត្វមេរោគ បង្កើតជម្ងឺក្នុងខ្លួនរបស់យើងឡើយ ។ ដូចនេះព្រោះអ្វី? ព្រោះមើលមិនឃើញហ្នឹងឯង ។ បើលោជាមានជំនឿតាមពាក្យពន្យល់ របស់គ្រូពេទ្យឬអ្នកវិទ្យាសាស្ត្រផ្នែកស្រាវជ្រាវណាមួយជំនឿ ឬគំហើញនោះ ក៏គ្មានបានជាពិសេសថ្លៃថ្នូរប៉ុន្មានទេ ។ ព្រោះជឿតាមគេពុំបានល្បងពិសោធន៍ដោយខ្លួនឯង ជំនឿបែបនេះយូរៗទៅអាចរលាយបាត់ទៅវិញក៏មានដែរ ។ បញ្ហានេះក៏មានទំនាក់ទំនងប្រហាក់ប្រហែលគ្នានឹងរឿងនរកសួគ៌ហ្នឹងដែរ បើមិនទាន់ពិសោធន៍ឃើញខ្លួនឯង, ក៏ពុំអាចនឹងតម្កល់ជំនឿទុកបានឡើយ ។ ដូចនេះ, បើយើងចង់ស្គាល់, ចង់ឃើញនរកសួគ៌, ត្រូវធ្វើការ ពិសោធ ។ ដើម្បីពិសោធឲ្យបានផលល្អ ត្រូវសាងគ្រឿងឧបករណ៍សម្រាប់ធ្វើឲ្យខ្លួនយើងមានភ្នែកទិព្វ ។ តែរហូតមកដល់សព្វថ្ងៃនេះយើងគ្មានគំនិតបង្កើតគ្រឿងឧបករណ៍នេះទេ យើងចេះតែនាំគ្នាបង្រួញកម្មវិធី ឬចេះនាំគ្នាដើរផ្លូវកាត់ដើម្បីឆាប់បានស្គាល់, ឆាប់បានឃើញឋានសួគ៌ ឋាននរក ។ ទំរើនេះហើយ ដែលនាំឲ្យកាន់តែគ្មានស្គាល់ គ្មានឃើញនរកសួគ៌ដែលជារបស់ប្រាកដជាមាន តាមការអះអាងនៃជើងគម្ពីរនិងតាមទស្សនៈ នៃអ្នកស្រាជ្រាវជាន់ខ្ពស់ ។ និយាយខ្លី, មនុស្សខ្ជិលគ្មានអ្នកណាអាចមានសមត្ថភាពជួយបង្រៀន, ជួយពន្យល់ឲ្យស្គាល់ ឋាននរកសួគ៌បានទេ ។

ក្នុងរឿងនរកសួគ៌ដដែលនេះ, អ្នកតារាសាស្ត្រក៏មានមុខងារជួយទម្លាយរបាយការណ៍អំពីរឿងមេឃអាកាសរហូតដល់អវកាស ដែលអវកាសយានិកអាមេរិកកាំងទើបនឹងបានដាក់ជើងជាន់លើផែនដីព្រះចន្ទ ដោយយានអាប៉ូឡូក្នុងចុងនៃសតវត្សទី ២០ នេះ ។ អ្នកអាកាសវិទ្យាទាំងអស់មានយោបល់ស្របគ្នាថា ក្នុងអាកាសក្ដី អវកាសក្ដី ។ ពោរពេញទៅដោយជុំវិញពិភពលោក ឬជុំចក្រវាលច្រើនលាន ច្រើនកោដិ ។ គំហើញរបស់អ្នកប្រាជ្ញទាំងឡាយនេះ ពុំមែនជាគហើញគ្មានតំណឹកតំណាងទេ គឺមានហេតុផលដែលមានចែងក្នុងតារាសាស្ត្រ ឬអាកាសវិជ្ជាដែលមានយូរណាស់មកហើយ ។ ហើយក្នុងសតវត្សទី ២០ នៃ គ.ស នេះ, ថែមមានអវកាសយានិកជាច្រើននាក់

ដែលបានទទួលបេសកកម្មរុករកវត្ថុធាតុមានអាថ៌កំបាំងក្នុងផ្ទៃអវកាស បានបរយានអាប៉ូឡូទៅរហូតដល់ឋានព្រះចន្ទទៀត ។ នេះគឺការរុករកមួយថ្មីបំផុតនៅក្នុងសតវត្សនេះ ។ ពេលត្រឡប់កាន់ផែនដីវិញ គេបានធ្វើរបាយការណ៍បញ្ជាក់លក្ខណៈផ្សេងៗ នៃរូបធាតុដែលមាននៅលើពិភពព្រះចន្ទឲ្យមនុស្សលោកទូទៅបានដឹង ។ ជាពិសេសគឺ អំណោយដល់គំនិតអ្នកស្រាវជ្រាវខាងផ្នែកអវកាសជាបន្តទៅទៀត ។ ព្រោះហេតុនេះនរកសួគ៌ក្នុងលោកដទៃ ក្រៅពីពិភពលោកយើងនេះវាមុខតែមានប្រាកដហើយ គ្មាននរណាអាចបដិសេធថា គ្មានដូចមុនបានទេ ។ សេចក្ដីសុខទុក្ខរបស់មនុស្សក៏មុខជាមានសុខ ។ គ្នាក្នុងពិភពលោកទូទៅ ពិភពលោកខ្លះមានសេចក្ដីចម្រើនរុងរឿងជាងពិភពលោកយើង ខ្លះអន់ជាង ខ្លះទុក្ខច្រើន ខ្លះទុក្ខតិច ខ្លះល្ងង់ ខ្លះចេះ ។ល។ ដើម្បីអ្នកអានយល់ភ្លាមៗ, ខ្ញុំសូមធ្វើសេចក្ដីបំភ្លឺថា បើពិភពលោនៃមនុស្សយើងមាននរកសួគ៌ ដូចដែលយើងបានស្គាល់ បានដឹងគ្រប់គ្នាតាមសំនេររបស់ខ្ញុំក្នុងសៀវភៅនេះក្ដី សៀវភៅទាំងឡាយដទៃរបស់ខ្ញុំក្ដី សំនេរនិង សៀវភៅទាំងឡាយរបស់អ្នកស្រាវជ្រាវដទៃក្ដី ។ ពិភពលោកដទៃ, ក៏មាននរក មានសួគ៌ដូចពិភពលោកយើងដែរ វាមិនអាចទៅជាគ្មានបានទេ ព្រោះពិភពលោកជាពិភពលោកដូចគ្នា ។ តែកុំភ្លេចថា របស់ដែលសកលពិភពលោកមានដូចគ្នានោះមានតែនាមធាតុ និងរូបធាតុទេ ។ ចំណែកគុណធាតុមានពុំបានដូចគ្នាទេ សូម្បីរូបធាតុនិងអរូបធាតុសោត ក៏មានពុំបានគ្រប់ចំនួន ទាំងអស់ដូចគ្នាឡើយ ។ ព្រោះអ្វី? ព្រោះពិភពលោកមួយៗ វាមានធាតុអាកាសសឹងមាន «សីតុណ្ហភាព» មានកម្រឹតតិចច្រើន ខ្លាំងខ្សោយជាងគ្នា ។ មានដី, ទឹក, ភ្លើង, ខ្យល់នៅក្នុងលក្ខណៈខុសគ្នាប្លែកគ្នា ។ល។ អ្នកតារាសាស្ត្រនិងអ្នកអវកាសរួមទាំង អ្នកភូមិសាស្ត្រផង បានមានពំនោលត្រូវគ្នាថា : ពិភពលោកដែលមានចំនួនស្ទើរតែកំណត់មិនបាននេះ, ខ្លះនៅជាភ្លើងមានកម្ដៅយ៉ាងខ្លាំង ខ្លះមានកម្ដៅមធ្យម, ខ្លះមានកម្ដៅខ្សោយ ។ គឺអាស្រ័យលក្ខណៈនេះហើយ, ដែលធ្វើឲ្យពិភពលោកមួយ ។ មានមនុស្ស សត្វ នរក សួគ៌ ព្រៃព្រឹក្សាលតាវល្លិ៍ មានរ៉ែធាតុតេលជាតិលោហធាតុ ។ល។ មានកំណើតសម្រស់ទំហំ ទម្រង់ជីវិត ជីវភាពផ្សេងៗគ្នា ។ ពិភពលោកដែលជាដំភ្លើង ឬដែលមានកម្ដៅភ្លើងច្រើននោះ, មិនទាន់មានមនុស្សសត្វព្រៃព្រឹក្សាធម្មជាតិ កើតបាន, នៅបានទេ ។ នេះគឺជាយោបល់របស់អ្នកស្រាជ្រាវខាងផ្នែកចក្រវាល ។ ជីវិតទាំងឡាយក្នុងលោកដទៃវាអាចមាន វឌ្ឍនភាពខ្ពង់ខ្ពស់ជាងជីវិតទាំងឡាយ ក្នុងលោកយើងនេះទៅទៀតក៏មាន ។ វាអាចខ្សត់ខ្សោយជាងមនុស្សក្នុងលោកយើងយ៉ាងច្រើនក៏មាន ។ ព្រោះអ្វី? ព្រោះតែក្នុងលោកយើងមួយ មានសត្វរាប់សែន រាប់លានបែបតាំងពីសត្វតូចៗដែលភ្នែកធម្មតា របស់យើងខំមើលយ៉ាងណាក៏មិនឃើញ រហូតដល់ធំបំផុតដែលភ្នែក យើងគ្មានខំមើលសោះក៏ឃើញដែរ ។ ចំណែកសត្វមនុស្ស វិញក៏មានមិនតិចទេ បើរាប់ទាំងមនុស្សដែលមានជីវិតចម្រើនហើយ, ទាំងនៅពាក់កណ្ដាលសេចក្ដីចម្រើន និងដែលគ្មានសេចក្ដីចម្រើនបន្តិចបន្តួចសោះ (មនុស្សព្រៃ) ក៏គង់មានច្រើនរយច្រើនពាន់ជាតិសាសន៍ដែរ ។ ក្នុងជំពូកសត្វតិរច្ឆានវាមានរូបកាយខុសៗគ្នា ស៊ីអាហារផ្សេងគ្នា, មានលំនៅមិនដូចគ្នា ខ្លះនៅក្នុងទឹក, ខ្លះនៅលើដី, ខ្លះនៅក្រោមដើមឈើ ។ រីឯដើមឈើក៏វាមាន ច្រើនពូជ, ច្រើនព័ន្ធុ, ច្រើនប្រភេទ, ដែលមនុស្សធម្មតាក្រៅពីអ្នកសិក្សាខាងរុក្ខវិទ្យា ពុំអាចស្គាល់អស់បានឡើយ ។ អ្នកស្រាវជ្រាវ ខាងពុទ្ធសាសនាបានចែកប្រភេទសត្វយ៉ាងខ្លីមាន ៦ គឺ :

១- សត្វមនុស្ស,

២- សត្វទេព,

៣- សត្វនរក,

៤- សត្វប្រេត,

៥- សត្វតិរច្ឆាន,

៦- សត្វអសុរកាយ ។

ព្រះសម្មាសម្ពុទ្ធបានចែកសត្វជា ៤ គឺ :

១- មនុស្សទេវោ,

២- មនុស្សនិរយកោ,

៣- មនុស្សតិរច្ឆានោ,

៤- មនុស្សបេតោ ។

អ្នកវិទ្យាសាស្ត្រខាងផ្នែកជីវិត បានធ្វើការពិសោធន៍ហើយបានសម្តែងយោបល់ថា នៅក្នុងពិភពលោកយើងនេះមានមនុស្សសត្វប៉ុន្មានប្រភេទ ពិភពលោកដទៃ ក៏មានសត្វ មានមនុស្សគ្រប់ប្រភេទដូចគ្នានឹងពិភព យើងដែរ ។ ដូចនេះយោបល់អ្នកវិទ្យាសាស្ត្រ និងយោបល់ពុទ្ធសាសនាពុំបានខ្វែងគ្នាទេ ក្នុងរឿងកំណើតនៃជីវិត មួយអន្លើនិងលោកនេះនិងលោកដទៃ គឺមាន លោកនេះនិងលោកដទៃដូចគ្នា ។

សេចក្តីសរុប : នរកស្ឋានពិត, វាជារឿងមួយដែលគេលំបាកនឹងយល់ ។ ព្រោះអ្វី? ព្រោះរឿងនេះវាមានមុនពុទ្ធសាសនា, វាជារឿងដែលមានចែងក្នុងគម្ពីរនៃសាសនារបស់ព្រាហ្មណ៍ ។ ហើយពុទ្ធសាសនាយើងក៏បានយករឿងនេះមកប្រើខ្លះដែរ ដើម្បីផ្ចាប់ចិត្តមនុស្សដែលគេមានជំនឿមកយូរហើយ ។ អ្នកអានប្រសិនបើចង់យល់សូមដូរគំនិតព្រាហ្មណ៍ចេញ បើមិនបានទាំងអស់ ក៏ឲ្យបានខ្លះ, ហើយដាក់គំនិតថ្មីនៃពុទ្ធសាសនាជំនួសវិញ ។ ដំណូរនេះអាចធ្វើឲ្យយើងឆាប់យល់ ឆាប់ចេះក្នុងរយៈកាលមិនយូរ ប៉ុន្មានឡើយ ។ តើអ្វីជាគំនិតពុទ្ធសាសនា? សំណួរនេះខ្ញុំសូមឲ្យចម្លើយដូចមានតទៅនេះ :

១- កម្ម,

២- វិបាកនៃកម្ម,

៣- អរិយសច្ចៈ ។

ធាតុទាំង ៣ នេះ ជាគំនិតរបស់ពុទ្ធសាសនា ជាមាគ៌ាប្រសើរបំផុត សម្រាប់អ្នកគិតគូរស្វែងរកសន្តិភាពឲ្យជីវិតរបស់ខ្លួន ។ ដូចនេះ, នរកស្ឋានប្រសិនបើយើងត្រិះរិះពិចារណា រុករកដោយផ្អែកលើគំនិតប្រកបដោយបញ្ញារបស់ខ្លួន, លើពុទ្ធចិន្តា, លើពុទ្ធតម្រាស់ក្នុងចំណុចថា គ្មានភ្លើងឯណាមានកម្តៅជាងភ្លើងគឺ : រាគគ្គិ ទោសគ្គិ មោហគ្គិ។ ក្នុងន័យថា : មានតែភ្លើង ៣ នេះទេ ដែលមានកម្តៅជាងភ្លើងអុស, ភ្លើងប្រេង, ភ្លើងជ័រ ។ល។ តើភ្លើងទាំង ៣ នេះមានជើងក្រាននៅឯណា? ឬមានធាតុអ្វីជាទីកើតនៃភ្លើងនេះ? ឬមានរបស់អ្វីសម្រាប់ឲ្យភ្លើងនេះឆេះ? ចម្លើយ : មានតែមនោធាតុ ឬវិញ្ញាណធាតុរបស់មនុស្សតែមួយប៉ុណ្ណោះជាជើងក្រាន, ជាទីកើត, ជាទីឆេះរបស់ភ្លើងនេះ ។ តើមនោធាតុហ្នឹងនៅឯណា? នៅក្នុងដើមទ្រូងឬខួរក្បាល របស់មនុស្ស ។ ដូចនេះ, បើយើងរកមើលនរកស្ឋានដ៏មានអាថ៌កំបាំងមិនទាន់ឃើញ ឬយើងមិនទាន់ស្គាល់នរកស្ឋាន ប្រកបដោយអាថ៌កំបាំងនោះ ។ យើងឃើញ, យើងស្គាល់ត្រឹមតែនរកស្ឋានដែលមាននៅក្នុងចិត្ត ឬក្នុងដើមទ្រូង ឬក្នុងខួរក្បាលរបស់យើងសិនទៅក៏បាន ។ ព្រោះអ្វី? ព្រោះយើងត្រូវធ្លាក់នរកត្រូវឡើងស្ឋានក្នុងខ្លួនយើងនេះមុន ។ លុះដល់ថ្ងៃណាសេចក្តីស្លាប់មកដល់ ទើបយើងត្រូវធ្លាក់នរក ឬឡើងស្ឋានដែលយើងមើលមិនឃើញជាខាងក្រោយ ។ ពាក្យខ្លីថា : ឋានស្ឋាននៅក្នុងចិត្តនរកនៅក្នុងដើមទ្រូង ។ នេះគឺជាសេចក្តីពិតដល់កម្រិតមួយរយភាគរយតែម្តង ។ ព្រោះអ្វី? ព្រោះអ្នកណាក៏បានឮ, បានដឹងដែរថា មនុស្សយើងក្នុងពេលណាមានទុក្ខធំក្របសង្កត់ អស់មធ្យោបាយនឹងដោះស្រាយបាន, គេតែងស្រែកថា បែកទ្រូងស្លាប់ឥឡូវហើយ, ក្នុងពេលណាចិត្តរបស់គេមានសេចក្តីរីករាយខ្លាំង គេតែងស្រែកថា សុខណាស់, ស្រួលណាស់ដូចបានឡើងឋានស្ឋាន ។ ព្រះសម្មាសម្ពុទ្ធរបស់យើងសព្វព្រះទ័យ សម្តែងអំពីធម៌

(ធម្មាធិដ្ឋានៈ) មិនសូវសព្វព្រះទ័យសម្ដែងអំពីមនុស្ស (បុគ្គលាធិដ្ឋានៈ) ។ ចំណែកព្រាហ្មណ៍គេ ចូលចិត្តនិយាយអំពីមនុស្ស (បុគ្គលាធិដ្ឋានៈ) ។ ដូចនេះហើយ, ទើបសាសនាទាំងពីរ មានទិសដៅខាងចុងបំផុត ខុសគ្នាស្រឡះ ។ គឺពុទ្ធសាសនាមាននិព្វានជាទិសដៅជាត្រួយ, ជាកំពូល, ជាទីរលត់របស់ជីវិតអន្ទោល ។ ពុទ្ធសាសនិកទាំងអស់ត្រូវបានទៅដល់ទីនោះក្នុងពេលណាមួយ ។ ក្នុងទីនោះគ្មានដី, ទឹក, ភ្លើង, ខ្យល់, ។ គ្មានអាកាសនញ្ចាយតនៈ, គ្មានវិញ្ញាណញ្ចាយតនៈ, គ្មានអាកិញ្ចញ្ញាយតនៈ, គ្មាននេវសញ្ញាយតនៈ ។ គ្មានព្រះអាទិត្យ, គ្មានព្រះចន្ទ ។ គ្មានដំណើរទៅ, គ្មានដំណើរមក ។ គ្មានគិត, គ្មានភាពឋិតនៅ, គ្មានភាពចុតិ, គ្មានភាពឧប្បត្តិ ។ល។ នេះឯងគឺជានិព្វាន, ជាទីបំផុតនៃទុក្ខ ដែលជាដំណាក់ចុងក្រោយបង្អស់នៃអ្នកប្រតិបត្តិធម៌ ក្នុងពុទ្ធសាសនារបស់យើង ។ ខាងសានា ព្រាហ្មណ៍, មានអាទិទេព, (ព្រហ្មៈ សិវៈ វិស្ណុ) ជាទិសដៅ ។ នៅក្នុងអាទិទេព មានអាត្មន, មានរូប, មានភាពទៀងទាត់, មានពួកទេពជាបរិវារ, មានឋានសួគ៌ជាលំនៅ ។ អ្នកប្រតិបត្តិធម៌ក្នុងសាសនាព្រាហ្មណ៍ទាំងអស់នឹងបានទៅដល់ទីនោះ បានជួបនឹងព្រះអាទិទេពរបស់ខ្លួន ហើយរស់ជាមួយនិងព្រះអង្គ រហូតទៅគ្មានវិលត្រឡប់មកវិញទេ ។ នេះគឺជាដំណាក់ចុងក្រោយបង្អស់នៃ អ្នកប្រតិបត្តិធម៌ក្នុងសាសនាព្រាហ្មណ៍ ដែលជាសាសនាមួយមានវត្ថុបំណង និងឧត្តមគតិប្រហាក់ប្រហែលគ្នានិង ពុទ្ធសាសនាដែរ ។ តែមានរបៀបបង្រៀនខុសគ្នា, សាសនាព្រាហ្មណ៍យកមានជាធំ, ដូចមានអាត្មន, មានអាទិទេព, មានទេវតារាប់មិនអស់ ។ ចំណែកពុទ្ធសាសនាយើង, របៀបបង្រៀនយកគ្មានជាធំ, ដូចគ្មានអាត្មន, គ្មានទៀង, គ្មានអាទិទេព ។ល។ ចំពោះរឿងនរកសួគ៌, ទោះជាយើងទុកដាក់ថា ជារបស់ព្រាហ្មណ៍ ហើយពុទ្ធសាសនាខ្ចីមកប្រើក្តី ទោះជារបស់ពុទ្ធសាសនា តែម្តងក្តី វាស្រេចតែសេចក្តីយល់ឃើញរបស់យើងទេ, ព្រោះសាសនាមួយៗ បើគ្មានខ្ចីអ្វីពីសាសនាមួយទៀតមកប្រើក៏ទៅមិនរួចដែរ ។ ព្រោះអ្វី? ព្រោះសាសនាត្រូវបង្រៀនមនុស្ស, បើគ្មានមនុស្សបង្រៀនក៏មិនដឹងយកអ្វីមកបង្រៀនដែរ ។ ដូចនេះយើងចង់បង្រៀនមនុស្សពីនរកសួគ៌ក្នុងចិត្តក៏បាន, នរកសួគ៌ក្នុងលោកបច្ចុប្បន្នដែលគេមើលឃើញដោយភ្នែកបាន, នរកសួគ៌ដែលមើលមិនឃើញដោយភ្នែក គឺនរកសួគ ក្នុងលោកដទៃក៏បាន ស្រេចហើយតែគរុកោសល្យរបស់យើង ។ តែទោះជាយ៉ាងណាក៏ដោយ, កុំភ្លេចថា ព្រះសម្មាសម្ពុទ្ធរបស់យើង ព្រះអង្គបានធ្វើសេចក្តីបដិសេធឋានសួគ៌យ៉ាងឧឡារិកក្នុងអនុបុព្វីកថាទី ៤ និងទី ៥ ដែលជាធម្មទេសនារបស់ព្រះអង្គស្រេចហើយ ។ ចំណែកនរកព្រះអង្គគ្មានបានធ្វើការបដិសេធទេ, តែព្រះអង្គសព្វព្រះទ័យ បង្រៀននរកក្នុងចិត្តនិងនរកក្នុងលោកនេះច្រើនជាង នរកក្នុងលោកដទៃ ។ សម្រាប់ពុទ្ធសាសនិកវិញ ប្រសិនបើគេគ្មានជំនឿ ក្នុងនរកនាឋានបរលោកក៏មិនទាន់ជាអ្វីដែរ ។ តែយើងត្រូវប្រយ័ត្នខំប្រឹងពន្យល់យ៉ាងណា កុំឲ្យគេគ្មានជំនឿក្នុងនរកដែលមាននៅ ក្នុងចិត្តនិងនរកដែលមាននៅក្នុងលោកបច្ចុប្បន្ននេះ ។ ព្រោះនរកក្នុងចិត្តរបស់មនុស្ស វាជាមូលហេតុ, ធ្វើឲ្យមនុស្សធ្លាក់នរកក្នុង លោកនេះនិងលោកដទៃទៀត ។ នរកក្នុងលោកបច្ចុប្បន្ន, វាជាមូលហេតុធ្វើឲ្យមនុស្សខ្លាចបាបអកុសល ។ កាលណាគេមានចិត្តខ្លាចបាបអកុសល គេមុខជាឈប់ប្រព្រឹត្តនូវទំរើបាប, នរកដែលជាផលវិបាករបស់បាប, ក៏ត្រូវរលាយបាត់អស់ខានធ្លាក់, ខានជួបជាប្រាកដ ។ នេះគឺជាករណីយ៍សំខាន់របស់ពុទ្ធសាសនិកម្នាក់ៗ ត្រូវបំពេញ, ត្រូវបង្កើតឲ្យមាននៅក្នុងក្របខ័ណ្ឌនៃការជ្រើសរើស, ការប្រកាន់យក, ទោះជាបង្រៀនក្តី ប្រព្រឹត្តប្រតិបត្តិក្តី អនុវត្តក្តី ។ ទើបមានលក្ខណៈគ្រប់គ្រាន់ជាពុទ្ធសាសនិកមានហេតុផល ឬជាពុទ្ធសាសនិកជឿនលឿន ។ ក្នុងទីបំផុតនៃបទនេះ ខ្ញុំសូមរម្លឹកឡើងវិញថា ព្រះពុទ្ធសាសនាពុំបានបង្រៀនមនុស្ស ឲ្យរស់នៅប្រកបដោយវឌ្ឍនភាព ត្រឹមតែក្នុងលោកមនុស្សសួគ៌ប៉ុណ្ណោះទេ ។ គឺបង្រៀនមនុស្សឲ្យទៅរហូតដល់និព្វាន, ព្រោះពិភពមនុស្សនិងពិភពទេព ទោះជាមានវឌ្ឍនភាពខ្ពង់ខ្ពស់ នៅក្នុងកម្រិតណាក៏ដោយ ក៏គង់នៅក្រោមអំណាចធម្មជាតិគឺ អនិច្ចំ, ទុក្ខំ, អនត្តាដដែល ។ ដូចនេះយើងត្រូវដឹងថា វឌ្ឍនភាពរបស់មនុស្សក្តី របស់ទេពក្តីវាមានប្រយោជន៍ត្រឹមតែជាផ្លូវ ឬជាស្ពានរបស់មនុស្ស

ដែលត្រូវការដើរឆ្លងទៅនិព្វានប៉ុណ្ណោះ ។ វាពុំអាចប្រឆាំង ឬកំទេចចោលនូវអនិច្ចំ, ទុក្ខំ, អនត្តាបានឡើយ ។ អ្នកប្រាជ្ញទាំងឡាយលោកមានគំនិតដូចពោលមក ទើបលោកខំប្រឹងធ្វើការងារគ្រប់បែបគ្រប់យ៉ាង ដើម្បីវឌ្ឍនភាពនៃជីវិតរបស់លោក រៀងរាល់ជាតិភព រហូតដល់ សម្រេចនិព្វាន ដែលជាទីបំផុតនៃទុក្ខហ្នឹងឯង ។

# បទទី៦
## ស្លាប់ហើយកើតទៀតឬ?

ជាដំបូង, ខ្ញុំសូមធ្វើសេចក្តីបំភ្លឺសព្ទវិទ្យាសាស្ត្រចំពោះពាក្យ «**ថាមពល**» ឬ «**ថាមភាព**» (ENERGY) ។ ពាក្យនេះ បើយោលទៅតាមទំនួលសេចក្តី ឬភាវការណ៍ ឬភាវធាតុ ដែលអ្នកវិទ្យាសាស្ត្រកឃើញ ។ គេអាចឲ្យន័យបាន ៤ យ៉ាងគឺ :

១-ថាមពលគឺជារបស់អ្វីមួយយ៉ាង (នាមធម៌) ដែលគំនិតអ្នកវិទ្យាសាស្ត្របានចាត់ ឬបានប្រកាន់យកភាពនេះទុកជាដើមហេតុរបស់ភាពមាន «កម្លាំងទាំងឡាយ» (FORCES) ឧទាហរណ៍ : នាឡិកាមានកម្លាំងដើរបាន ព្រោះវាមាន ថាមពលសន្សំទុក (POTENTIAL ENERGY) នៅក្នុងឡានរបស់វាសព្វគ្រប់អស់ហើយ ។

២- ធាតុថាមពលនេះ វាជារបសើមួយមាននៅក្នុងពិភពលោកអស់កាលជានិរន្តរ៍ ដោយគ្មាននរណាធ្វើឲ្យកើតបាន, គ្មាននរណាធ្វើឲ្យសូន្យកើត គឺធ្វើឲ្យកើតក៏មិនបាន, ធ្វើឲ្យសូន្យក៏មិនកើត តែជាធាតុមានចលនាប្រែប្រួលផ្លាស់ប្តូរភាពមួយដង បែបនេះ មួយដងបែបនោះ ដោយអាស្រ័យទំរើរបស់វាប៉ុណ្ណោះ ។

៣- តំណតមក, មានអ្នកប្រាជ្ញម្នាក់ឈ្មោះអែន៍ស្តែន៍ (EINSTEIN) បានសម្តែងគំហើញរបស់លោកអ្នកក្នុងទ្រឹស្តីមួយថា «រូបធាតុទាំងអស់ មានពេលខ្លះត្រូវបានផ្លាស់ភាពមកជាថាមពលវិញ (E ប៉ុនគ្នានិង Me2) សេចក្តីយល់ឃើញរបស់ អ្នកប្រាជ្ញរូបនេះ មានភាពជាក់លាក់ច្បាស់លាស់តាមការពិត ដែលអ្នកស្រាជ្រាវទូទៅទាំងពិភពលោក បានប្រកាន់យក, បានអនុវត្តរួចមកហើយ ។ ជាពិសេសក្នុងការផ្តើមគំនិតស្ថាបនាគ្រាប់បែកបរមាណូ ដែលជាគ្រាប់បែកមានឥទ្ធិពលខ្លាំងពូកែ បំផុតក្នុងសតវត្សទី ២០ ក៏ដោយទ្រឹស្តីនេះឯង ។

៤- ប្រភពនៃកំណើត ឬអគតដ្ឋាន ឬកន្លែងធ្វើថាមពលទាំងឡាយនោះគឺ : ដួងអាទិត្យ ។ ភាពច្បាស់លាស់ដែល គេបានឃើញពិតប្រាកដទូទាំងពិភពលោក នៅក្នុងរយៈកាលមួយដែលគំនិតមនុស្សបានផ្គុំគ្នាស្ថាបនាគ្រាប់បែកអ៊ីដ្រូហ្សែន បានសម្រេចផល ឬកើតជារូបរាងជាក់ស្តែងដល់ភ្នែកមនុស្ស ។

គោលគំនិតផ្សេងៗ ដែលកើតមានក្នុងរឿងថាមពលអស់ទាំងនេះ ប្រសិនបើប្រមូលមកនិយាយតាមភាសាសាមញ្ញ ឬតាមគំនិតធម្មតា គេអាចធ្វើបានទៀតដូចមានតទៅនេះ :

១- រូបធាតុ (វត្ថុ) ទាំងឡាយ ដែលមនុស្សទាំងឡាយមើលឃើញថា មានរូបរាងនិងមានឈ្មោះផ្សេងៗ នោះវាមិនមែនមានចំពោះតែរូបទាំងឡាយ ដែលយើងមើលឃើញដោយភ្នែកនិងឈ្មោះទាំងឡាយ ដែលយើងនិយាយដល់ប៉ុណោះទេ ។ អ្នកប្រាជ្ញវិទ្យាសាស្ត្រក្រោយពីបានស្រាវជ្រាវឃើញហើយ លោកបានកំណត់ទុកដាក់ឲ្យមានថាមពលដើម ឬថាមពលនៅប្រចាំជានិរន្តក្នុងរូបធាតុមួយៗនោះទៀតផង ។ ក្នុងន័យថា រូបធាតុមួយៗរមែងមានរបស់បីនៅរួមគ្នាគឺ ទម្រង់, ឈ្មោះនិងថាមពល ដើម ឬថាមពលប្រចាំ ។

២- ថាមពលដើម, ធាតុនេះជារបស់មាននៅក្នុងរូបធាតុទូទៅទាំងអស់ គ្មានសល់រូបធាតុណាមួយទេ, តែវាជារបស់កប់កំបាំង ពុំបានបញ្ចេញភាពជាក់ស្តែងមកខាងក្រៅឡើយ ។ ធាតុនេះវាគ្មានកើត, ព្រោះវាជាដើមរបស់ធាតុទាំងឡាយ, វាគ្មានស្លាប់ ព្រោះវាជារបស់មិនចេះសូន្យ មិនចេះបាត់ទៅជាមួយនិងប្ររាង ឬវត្ថុដែលជាធាតុមានបច្ច័យសម្រាប់ធ្វើឲ្យកើត, ឲ្យសូន្យ ។ ដៅសេចក្តីថា : កាលណារូបត្រូវផ្លាស់ភព ឬស្លាប់ (PHYSICAI CHANZE) ថាមពលប្រចាំរបស់រូប វាមិនស្លាប់ទៅជាមួយនិងរូបទេ, វាតែងទៅកើត, ទៅនៅក្នុងរូបថ្មី, ភពថ្មីទៀត ។ ឧទាហរណ៍ : ក្នុងកាលណាទឹកផ្លាស់ពីសភាពដើមទៅជាអាកាស ថាមពលប្រចាំរបស់ទឹកវាពុំបានសូន្យទៅជាមួយនិងទឹកទេ, តែវាត្រូវផ្លាស់លំនៅជាទីអាស្រ័យ គឺវាទៅនៅក្នុងទឹកដូចគ្នានេះទៀត ក្នុងកន្លែងណាមួយទីទៃ ។

៣- កាលណារូបធាតុផ្លាស់ប្តូរកំណើត (CHEMICAL CHANZE) ដោយការញែកធាតុ ផ្សំធាតុ ថាមពល

ដើមដែល នៅអាស្រ័យក្នុងរូបធាតុដែលមានចលនាធ្វើឲ្យ ធាតុប្រែប្រួលផ្លាស់ប្តូរទៅវិញទៅមករវាងគ្នានិងគ្នានោះ វាពុំបានសូន្យបាត់ទៅតាម រូបរាងរបស់វត្ថុ ឬធាតុដែលត្រូវសូន្យបាត់ទៅក្នុងខណៈផ្លាស់ប្តូរនោះទេ ។ តែវាត្រូវផ្លាស់ប្តូរភាពពីថាមពលមួយទៅថាមពលមួយ គឺវាផ្លាស់ប្តូរវាងថាមពលនិងថាមពលដូចគ្នា ហើយដូរអាស្រ័យនៅជាមួយនិងវត្ថុធាតុដែលកើតថ្មីទៀត ។ ឧទាហរណ៍ : ឈើស្ងួតដែលត្រូវគេយកទៅដុតភ្លើង ក្នុងពេលដែលឈើស្ងួតត្រូវឆេះចេញជាអណ្តាតភ្លើងនោះ ធាតុការ៍បោន និងធាតុអុកស៊ីហ្សែនរួមគ្នា ប្រែភាពកើតទៅជាធាតុការ៍បោនដៃអុកសៃដ៍ ($CO_2$) មានកម្តៅនិងពន្លឺកើតឡើងព្រមគ្នា ។ រូបរាងឈើស្ងួតសូន្យបាត់ពីភាពដើម ក្លាយទៅជាធ្យូង ។ នៅក្នុងឈើស្ងួតនោះមានថាមពលដើម ឬថាមពលប្រចាំ ដែលមនុស្សធម្មតាពុំអាចស្គាល់បាន ព្រោះវាជាធាតុកប់ ឬជាធាតុកំបាំង ។ កាលណាត្រូវគេដុតភ្លើង រូបធាតុគឺឈើនោះត្រូវបានសូន្យបាត់អស់ហើយ ។ ថាមពលប្រចាំ ឬថាមពលដើមដែលអាស្រ័យនៅក្នុងឈើស្ងួតនោះ ពុំបានសូន្យបាត់ទៅផងទេ ។ តែធាតុនេះវាបានសម្តែងភាពជាកម្តៅជាពន្លឺ, ដែលអ្នកវិទ្យាសាស្ត្រឲ្យឈ្មោះចលនានោះថា ការប្រែធាតុ, ផ្សំធាតុ ។

៤- ព្រោះហេតុដូចនេះ, ទើបអ្នកវិទ្យាសាស្ត្រមានគំហើញស្របគ្នាថា ថាមពលប្រចាំរបស់រូបធាតុ ឬវត្ថុធាតុមិនបាន សូន្យបាត់ទៅជាមួយនិងរូបធាតុទាំងឡាយរបស់វាដែលតែងតែរលាយបាត់ ដោយហេតុបច្ច័យសម្រាប់ធ្វើឲ្យរលាយបាត់នោះទេ ។

ក្នុងលក្ខណៈបែបនេះ, ប្រសិនបើយើងត្រិះរិះពិចារណាតាមគំនិតធម្មតា ក៏គង់ឃើញ គង់យល់បានថា រូបធាតុទាំងឡាយ ទោះជាមានទម្រង់, មានទំហំ, មានតណ្ហច . . . . . យ៉ាងណា ប៉ុណ្ណាដែលគេស្គាល់, គេទុកដាក់ថាជាភាពមួយៗ វាសុទ្ធតែត្រូវមានថាមពលប្រចាំ ឬថាមពលដើមកប់នៅក្នុងនោះមួយទៀត ។ ធាតុកប់ ឬធាតុអាស្រ័យនេះ, កាលណារូបធាតុត្រូវរលាយសូន្យបាត់ទៅ (ស្លាប់) ថាមពលប្រចាំ វាពុំបានសូន្យបាត់ទៅជាមួយផងទេ, តែវាត្រូវផ្លាស់លំនៅ, ផ្លាស់ជម្រក, ទៅនៅ ទៅជ្រកក្នុងរូបធាតុដទៃ ឬក្នុងរូបធាតុដែលទើបតែនឹងកើតថ្មី ។ ម៉្យាងទៀត, បើរូបធាតុឋិតនៅក្នុងសភាពជារូបធាតុដរាបណាទម្រង់របស់ រូបធាតុក៏ផ្លាស់ប្តូរកើតស្លាប់, ផ្លាស់ប្តូរភាព, ផ្លាស់ប្តូរកំណើតញយៗ រឿយៗ ដរាបនោះដែរ ។ តែបើរូបធាតុរលាយភាពទៅជា ថាមពល (ប្រចាំ) ក្នុងពេលណា, សភាព ឬទម្រង់រូបធាតុក៏ត្រូវផុតរលត់អស់ក្នុងពេលនោះដែរ ។ គឺសល់នៅតែថាមពលដែលមានឈ្មោះថា ថាមពលប្រចាំ ឬថាមពលដើមប៉ុណ្ណោះ ។ ធាតុថាមពលនេះបើនិយាយតាមគោលការណ៍វិទ្យាសាស្ត្រដោយចំពោះគេមិនឃើញមានអំណាចណាៗទាំងអស់ សម្រាប់ធ្វើ, សម្រាប់រំលាយឲ្យធាតុនេះសូន្យបាត់ពីពិភពលោកបានទេ ។ ដៅសេចក្តីថា : ធាតុថាមពលនេះ វាគ្មានភាពកើត, ភាពស្លាប់, ភាពអស់ភព, អស់ជាតិទេ គឺវាមានតែភាពផ្លាស់, ភាពក្លាយទម្រង់ពីបែបមួយទៅបែបមួយទៀត ជាពិសេសពីរូបធាតុទៅជាថាមពលហ្នឹងឯង ។ ក្នុងន័យថា, ធាតុនេះវាឋិតនៅក្រៅ ឬនៅលើភាពផ្លាស់ប្តូរក្នុងហ្វីស៊ីកស៍ និងគីមីទាំងអស់តែម្តង ។ ហេតុដូចនេះហើយ បានជាកាលណាមានផ្ទុះគ្រាប់បែកបរមាណូម្តងៗ អ្នកវិទ្យាសាស្ត្រសង្កេតឃើញរូបធាតុចំណែកមួយ ក៏ត្រូវបានឱកាសប្រែភាពថាមពល (ប្រចាំ) សុទ្ធៗ តាមទម្លាប់របស់វា ។ ប្រែថា វាគ្មាននៅក្រោមអំណាចការផ្លាស់ប្តូរណាៗទាំងអស់ ។ ជាមួយគ្នានេះ វាថែមទាំងមានកម្លាំងស្រូបទាញរូបធាតុទាំងឡាយ ដែលនៅក្នុងទីជិតខាងបរិវេណផ្ទុះ ឲ្យប្រែក្លាយភាពទៅជាថាមពលដូចវាទៀតផង ។ លក្ខណៈឆក់ស្រូបដូចនេះ ហៅតាមភាសា វិទ្យាសាស្ត្រថា «រ៉េឌីអូអែកទិហ្វអេហ្វហ្វេកទ៍» (RADIOACTIVE-EFFECT) ។

## ការកើតស្លាប់របស់សត្វ

ពោលដោយទូទៅ វត្ថុទាំងឡាយ (OTGANIC ឬ INORGANIC) រុក្ខជាតិទាំងឡាយ និងសត្វទាំងឡាយសុទ្ធតែជារបស់មានបច្ច័យ តុបតែងឲ្យកើតឡើងឲ្យប្រព្រឹត្តទៅឲ្យរស់នៅក្នុងពិភពលោកយើងនេះដូចគ្នាទាំងអស់ ។

ហេតុដូចនេះគោលការណ៍ធំៗ ប្រកបដោយលក្ខណៈនិងភាពច្បាស់លាស់ភ្លឺស្វាង ដែលអ្នកវិទ្យាសាស្ត្របានជួបប្រទះ ហើយបានធ្វើសេចក្ដីបំភ្លឺថា នៅក្នុងរូបធាតុមួយៗ ឬវត្ថុធាតុមួៗនោះសុទ្ធតែមានភាពរស់ឋិតថេរដែលអ្នកវិទ្យាសាស្ត្រហៅថា ថាមពលដើម ឬថាមពលប្រចាំនោះ, វាមិនមែនជាគ្មានន័យ គ្មានហេតុផល, យ៉ាងណាមិញសត្វលោកទាំងឡាយក៏វាមានគោលការណ៍ សំខាន់ៗតុបតែងឲ្យកើត, ឲ្យមាននៅក្នុងលក្ខណៈ ប្រហែលៗគ្នាយ៉ាងនោះដែរ ។ ការស្រាវជ្រាវឃើញរបស់អ្នកវិទ្យាសាស្ត្រគ្រប់ ចំណុចទាំងឡាយមានចំណុចថា ថាមពលមិនសូន្យបាត់ទៅចាកពិភពលោក ១, ថាមពលមិនរលត់រលាយទៅព្រមគ្នាជាមួយ និងការផ្លាស់ប្ដូរ, ការសូន្យបាត់នៃទម្រង់, នៃភាពរបស់រូបធាតុ១, វត្ថុទាំងឡាយសុទ្ធតែមានទម្រង់ មានភាពនិងមានថាមពល ប្រចាំ ឬថាមពលដើមកប់នៅខាងក្នុង១, រូបធាតុទាំងអស់វារមែងត្រូវផ្លាស់ភាព ជាថាមពលបានរាល់ៗតែពេលណាដែលវាត្រូវធ្វើបន្លាស់នេះ១, ។ ជាមួយគ្នានេះទៀត, កាលណាបើរូបធាតុបានដូរភាពមកជាថាមពលហើយរបស់ទាំងឡាយដែលឋិតនៅក្នុងបរិវេណជិតខាងនោះក៏ត្រូវបានក្លាយភាព, ក្លាយទម្រង់ទៅជាថាមពលផងដែរ១ ។ គំហើញទាំងឡាយ របស់អ្នកវិទ្យាសាស្ត្រដូចបានពោលមកនេះមិនមែនជាធាតុផ្សេងដោយឡែក ឬទីទៃពីគ្នាទេ ។ តាមការពិចារណាជាទូទៅសត្វលោកទាំងឡាយក៏វា ឋិតនៅក្នុងលក្ខណៈដូចគ្នាអញ្ចឹងដែរ ។ កាលណាគេបានដាក់ គោលគំនិតនៅលើបន្ទាត់នេះហើយគេអាចនឹងសម្ដែងយោបល់បានថា ជំនឿក្នុងរឿងស្លាប់ហើយកើត និងជំនឿទាំងឡាយដទៃទៀត តាមគោលការណ៍របស់ព្រះពុទ្ធសាសនានោះ វាសុទ្ធតែមាន ហេតុផលស្របគ្នាជាមួយនិង គោលការណ៍នៃវិទ្យាសាស្ត្រគ្រប់ចំណុច ។ ដូចនេះព្រោះអ្វី? ព្រោះវិទ្យាសាស្ត្រធាតុនេះ វាមិនមែនជា ធាតុមួយដទៃ គឺវាជាធាតុរបស់ពុទ្ធសាសនាហ្នឹងឯង ។ ដើម្បីជាពន្លឺដល់គំនិតជនសាមញ្ញក្នុងរឿងនេះ ខ្ញុំសូមធ្វើសេចក្ដីមាន តទៅៈ

ក/ វិទ្យាសាស្ត្ររាល់ប្រភេទ មុនដំបូងគេធ្វើការពិសោធន៍សិន រួចទើបគេនាំមកសម្ដែងឲ្យយើងឃើញច្បាស់ថា វត្ថុធាតុទាំងឡាយវាសុទ្ធតែមានរូប, មានទម្រង់ហើយក្នុងរូបធាតុមួយៗ ដែលយើងចាប់បាន មើលឃើញសព្វថ្ងៃនេះ វាមិនមែនជាសុញ្ញភាព គឺគ្មានអ្វីនោះទេ ។ ការពិត, វាមានថាមពលដើម ឬថាមពលប្រចាំអាស្រ័យនៅឬកប់បាត់នៅក្នុងរូបរបស់វាដែល គ្មាននរណាដឹងថា វាកើតតាំងពីកាលណាមក វារស់នៅអស់រយៈកាលប៉ុន្មានទៅទៀត ចំពោះរឿងកើត, រឿងមាន ឬភាពប្រាកដ នៃថាមពលប្រចាំដែលអ្នកវិទ្យាសាស្ត្ររកឃើញ, សម្ដែងចេញមកក្នុងបច្ចុប្បន្នកាលនេះក៏គ្មាន ខុសពីទស្សនៈនៃពុទ្ធសាសនា របស់យើងដែលគេទទួលស្គាល់, ទទួលយល់ព្រមថាជាសាសនាមានលក្ខណៈជាវិទ្យាសាស្ត្រ គ្រប់ចំណុចទាំងអស់ក្នុងឃ្លាដែល ស្ដីអំពីបរមត្ថធម៌និងអភិទស្សនៈវិទ្យា ។ តាមផ្លូវវិទ្យាសាស្ត្រព្រះសម្មាសម្ពុទ្ធមានទស្សនៈថា សត្វលោកគ្រប់ប្រភេទមិនមែនមាន ត្រឹមតែរូប, ទម្រង់, ភាព . . . . ប៉ុណ្ណឹងទេ ។ គឺមានថាមពលដើម ឬថាមពលប្រចាំកប់ជ្រកខាងក្នុងជំនុំនៃរូប, នៃទម្រង់, នៃភាព . . . . របស់សត្វលោកដូចគ្នាអញ្ចឹងដែរ ។ តែព្រះអង្គបានហៅធាតុថាមពលប្រចាំរបស់សត្វលោកថា «ចិត្ត» ទៅវិញ ជាមួយគ្នានេះ ហៅរូបធាតុរបស់សត្វលោកថា «កាយ» ។ ចំពោះកាយនេះក្នុងធម៌ជាន់ខ្ពស់ (បរមត្ថអភិធម្ម) លោកហៅថា រូបផង, ធាតុផងគឺ លោកគ្មានហៅថា «កាយ» ដូចធម៌ថ្នាក់ក្រោមនិងថ្នាក់កណ្ដាលទេ ។ នេះគឺជាកត្តាមួយទៀតបញ្ជាក់ឲ្យយើងឃើញថា ពុទ្ធសាសនាជាវិទ្យាសាស្ត្រដើម ឬវិទ្យាសាស្ត្រចាស់ទុំ ។ ហេតុនេះ, ទើបជំនឿរបស់ពុទ្ធសាសនិកក្នុងចំណុចថា សព្វសត្វទាំងឡាយ មានភាពប្រាកដជាក់ស្ដែងឡើងប្រកបដោយកាយនិងចិត្ត ឬរូបនិងនាមយ៉ាងនេះឯង ជាមួយនិងដំរារនៃ អ្នកវិទ្យាសាស្ត្រសម័យបច្ចុប្បន្នក៏ពុំឃើញមានខុស គ្នាត្រង់ចំណុចណាជាមួយនិងគំនិតពុទ្ធសាសនិកសូម្បីបន្តិចបន្តួចឡើយ ។

ខ/ គោលការណ៍ស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រ ក្នុងចំណុចដែលស្ដីថា : កាលណារូបធាតុត្រូវបានផ្លាស់ភាព, ផ្លាស់ទម្រង់ ឬត្រូវរលត់រលាយបាត់បង់ពីរូបដើមរបស់វា (ស្លាប់ទៅ) ថាមពលប្រចាំរបស់រូប ឬរបស់វត្ថុនោះ

ពុំបានសូន្យបាត់ទៅជាមួយ, តែត្រូវបានផ្លាស់ប្តូរទីកន្លែងអាស្រ័យនៅទៅជ្រក, ទៅបង្កប់ខ្លួននៅក្នុងរូបថ្មី ឬភពថ្មី ឬទៅនៅអាស្រ័យជាមួយនិងរបស់ ដែលកើតថ្មី ។ គោលការណ៍ស្រាវជ្រាវនេះ ក៏គេមិនអាចនឹងបដិសេធថា : គ្មានស្របជាមួយនិងមេរៀនរបស់ពុទ្ធសាសនាក្នុង ចំណុចដែលស្តីថា ស្លាប់ហើយកើតថ្មីទៀតនោះទេ ។ ការស្លាប់របស់សត្វនោះ, របស់ដែលត្រូវសូន្យបាត់ទៅ, អស់ឃើញ, អស់ចាប់កាន់បានជាពិតប្រាកដនោះ បានដល់រូបកាយ ។ ព្រោះរូបកាយដែលយើងកំពុងមើលឃើញ កំពុងចាប់កាន់រាល់ៗថ្ងៃ ។ ធាតុនេះ, វារតលាយសាបសូន្យបាត់ទៅពិតៗ ។ តែការស្លាប់របស់សត្វនោះ វាមាននៅសល់របស់ដែលមិនបានសូន្យបាត់ដែរ ។ របស់នោះគឺចិត្តដែលពុទ្ធសាសនិកធ្លាប់ស្គាល់គ្រប់គ្នាមកហើយ ។ តែក្នុងទីនេះ, យើងគប្បីយល់ថា : ពាក្យថា ចិត្តដែលមិនបានសាបសូន្យបាត់បង់ទៅនោះ ពុទ្ធសាសនាពុំបានដឹកនាំយើងឲ្យមានគំនិតជាប់ជំពាក់ ក្នុងភាពទៀងទាត់គ្មានការប្រែប្រួល, គ្មានការដូរ, គ្មានការផ្លាស់របស់ចិត្តដូចជាអាត្ម័នរបស់ព្រាហ្មណ៍នោះទេ ។ ពាក្យចិត្តមិនសូន្យ, មិនរលាយបាត់មានន័យត្រឹមថា ចិត្តធាតុនេះ វាមានការត ការភ្ជាប់ពីភពមួយទៅភពមួយ នៅក្នុងភាព ឬក្នុងខ្លួនរបស់វាប៉ុណ្ណោះ ។ គឺវាមិនឋិតនៅក្នុងភាពដដែល, ក្នុងទីកន្លែងតែមួយៗឡើយ ។

ដូចនេះ, ជំនឿថា ស្លាប់ហើយសូន្យបាត់អស់គឺពិតជាជំនឿខុស និងគោលការណ៍វិទ្យាសាស្ត្រយ៉ាងក្រៃលែងតែម្តង ។ ការពិត, រូបធាតុ ឬរាងកាយធម្មជាតិនេះ, វារលត់រលាយបាត់ទៅមែនព្រោះនរណាៗក៏បានដឹង បានឃើញយ៉ាងនោះដែរ ។ តែចិត្ត ឬថាមពលដើមរបស់រូបធាតុ ឬថាមពលប្រចាំរូបធាតុដែលជាធាតុជ្រក, ធាតុកប់នៅក្នុងរូបកាយ ឬនៅជាមួយនិងរូបកាយនោះ ។ ធាតុនេះវាជានាមធម៌ ឬអរូបធម៌ដែលយើងមើលវាមិនឃើញចាប់វាមិនបាន ។ ដោយអាស្រ័យហេតុដូចនេះហើយ ទើបយើងគិតមិនយល់, ស្តាប់មិនចេញ, ឆ្ងល់មិនបាត់, និយាយមិនកើតអស់រយៈកាលយូរយារណាស់ហើយ ។ តែជាភ័ព្វវាសនារបស់យើងដែរ ចាប់តាំងពីអ្នកវិទ្យាសាស្ត្រ បានធ្វើការស្រាជ្រាវសាកល្បងពិសោធដោយប្រើសុទ្ធតែគ្រឿងឧបករណ៍ពិសេសៗ កាលណាមក, គេក៏បានមាន គំហើញស្របគ្នាថា ថាមពលដើម ឬថាមពលប្រចាំរបស់រូបធាតុ ឬវត្ថុធាតុ ។ ធាតុនេះវាពុំបានសូន្យបាត់ទៅ តាមដំណុំរបស់រូបធាតុ ឬវត្ថុធាតុដែលជាជម្រករបស់វាទេ ។ ព្រោះហេតុដូចនោះជំនឿថា កាលណារូបកាយស្លាប់ ដល់នូវភាពសាបសូន្យបាត់ទៅហើយ ចិត្តគង់នៅជាធម្មតា មិនសូន្យបាត់ទៅជាមួយនិងរូបកាយ ។ តែត្រូវផ្លាស់ទីជ្រកទីអាស្រ័យ ទៅបង្កប់ ទៅផ្ញើខ្លួន (ភាព) នៅជាមួយនិងសត្វដែលកើតថ្មី ដូចធ្លាប់ចូលចិត្តមកហើយនោះ ។ ជំនឿនេះ, ពិតជាមានមូលហេតុ, មានហេតុផល, មានល័ខឋាន ស្របគ្នានិងជំរាវរបស់អ្នកវិទ្យាសាស្ត្រគ្រប់ចំណុចហើយ, ទោះណាជារឿងនេះពុំអាចនិងល្បងពិសោធ ឬសម្តែងភាពឲ្យមើលឃើញដោយភ្នែកពិតៗ មិនបានព្រោះចិត្តជាអរូបធម៌ក៏ដោយ ។ តែចិត្តថ្មីបើគ្មានចិត្តចាស់វាក៏ ពុំអាចនឹងមាន, ពុំអាចនឹងកើតបានទេ ។ ដូចនេះព្រោះអ្វី? ព្រោះថា ធាតុទាំងឡាយមួយណា ក៏ដូចមួយណាដែរ ។ តែគ្មានដើមហើយវាមិនដឹងជាបានកណ្តាលបានចុងមកពីណាទេ ។ ក្នុងគម្ពីរអភិធម្ម, ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានធ្វើសេចក្តីបញ្ជាក់អំពីតំណ ឬជំនាន់របស់ចិត្តជាចិត្តដំបូង ឬចិត្តដើមវាជាអនន្តរប្បច្ច័យរបស់ចិត្តបន្ទាប់ ឬចិត្តដែលត្រូវកើតត្រូវមានតៗ ទៅទៀត ។ ក្នុងន័យថា ចិត្តចាស់វាជាគ្រាប់ ឬជាពូជចិត្តថ្មីដោយសេចក្តីថា ចិត្តចាស់ចេះតែរលត់ទៅ តែចិត្តថ្មីក៏ចេះតែកើតជំនួសចិត្តចាស់ ដូចគ្នានឹងគ្រាប់ផ្លែស្វាយចាស់ វាចេះតែរលួយបាត់ទៅក្នុងដី តែគ្រាប់ផ្លែថ្មីក៏ចេះតែកើតជំនួស ។ នៅក្នុងរឿងនេះ, យោបល់ព្រះនាគសេនត្ថេរថា : រូបចាស់រលត់ កើតរូបថ្មីជំនួស, វេទនាចាស់រលត់ កើតវេទនាថ្មីជំនួស, សញ្ញាចាស់រលត់កើតសញ្ញាថ្មីជំនួស, សង្ខារចាស់រលត់ កើតសង្ខារថ្មីជំនួស, វិញ្ញាណចាស់រលត់ កើតវិញ្ញាណថ្មីជំនួស ។ ព្រះថេរៈបានធ្វើសេចក្តីបំភ្លឺតាម គំហើញរបស់លោកមកទៀតថា ខន្ធ ៥ ចាស់ស្លាប់មែនពិត តែខន្ធ ៥ ដដែលនេះវាមានថាមភាព តុបតែងបង្កបង្កើតខន្ធ ៥ ថ្មីជំនួស ។ បើតាមយោបល់ព្រះមហាថេរៈអង្គនេះ របស់ដែលស្លាប់ហើយ

កើតទៀតមិនមែនមានតែរូបធាតុទេ អរូបធាតុក៏ត្រូវកើតថ្មីដែរ ។ តែកំណើតថ្មីនៃរបស់ទាំងអស់នេះ លោកបានបញ្ជាក់ថា វាមិនមែនជាតួនៃកំណើតចាស់ទេ ។ ប៉ុន្តែ, កំណើតថ្មី បើគ្មានកំណើតចាស់ជាបច្ច័យក៏វាគ្មានលទ្ធភាពនឹងកើតឡើងបានទេ ។ ថេរៈគំហើញនេះ, ក៏ពុំបានខុសនឹងព្រះគំហើញរបស់ ព្រះសម្មាសម្ពុទ្ធ ក្នុងចំណុចថា ចិត្តក្នុងខណៈដំបូងវាជាអនន្តរប្បច្ច័យរបស់ចិត្តក្នុងខណៈតមក ។ ក្នុងន័យថា : ចិត្តត្រូវដូរទី, ដូរភាព, ដូរជីវិត, ដូរកំណើតគ្មានចន្លោះ, គ្មានចំហនៅគ្រប់តែពេលដែលត្រូវដូរ ត្រូវផ្លាស់ គឺពេលស្លាប់ហ្នឹងឯង ។ អ្នកអានគប្បី ដឹងថា «ស្លាប់» ពាក្យនេះប្រើបាន និយាយបាន ចំពោះតែជីវិតនិងរូបកាយប៉ុណ្ណឹងទេ ។ ចំណែកចិត្ត គម្ពីរអភិធម្មលោក ពុំបានប្រើពាក្យស្លាប់ឡើយ ។ តែលោកបានប្រើពាក្យ «ចុតិ» ជំនួសវិញ សឹងមានបាលីចែងថា «ចុតិចិត្ត» ដូចដែលយើងធ្លាប់បានដឹងគ្រប់គ្នាមកហើយ ។ «ចុតិ» សព្ទនេះប្រែថា «ឃ្លាត» ឧទាហរណ៍ : ឃ្លាតចេញចាកស្រុកកំណើត, ឃ្លាតចេញចាកភព, ឃ្លាតចេញចាករូបកាយ ។ល។ ដោយអាស្រ័យសំឡេងប្រែនេះ យើងអាចចូលចិត្តបានថា សំឡេង «ដំណូរ» «បន្លាស់» . . . ដូចមានក្នុង សំនេរខាងដើម ក៏មានន័យត្រូវគ្នានឹងសំឡេង «ឃ្លាត» នេះដែរ ។ គឺចិត្តរបស់យើងក្នុងពេលរូបកាយ ឬជីវិតត្រូវស្លាប់ ចិត្តវាមិន ស្លាប់ទេ តែវាត្រូវធ្វើចលនា គឺការដូរភព, ដូរភាព . . . ផ្លាស់ទីកន្លែងនៅអាស្រ័យឃ្លាតចេញចាករូបកាយ . . . . ដែលយើងធ្លាប់និយាយខុសថា «ស្លាប់» ហ្នឹងឯង ។ រឿងស្លាប់កើត, ជារឿងមានការលំបាកដល់អ្នកនិយាយផង ដល់អ្នកស្តាប់ផង ។ តែរឿងនេះ, វាមិនទាន់ហួសវិស័យផុតគំនិតរបស់យើងទេ ។ ដូចនេះព្រោះអ្វី? ព្រោះធាតុនេះវានៅមានផ្លូវគំនិតនិងល័ខឋាន ទាំងឡាយសម្រាប់គំនិត, សម្រាប់និយាយគ្នាដែរ ។ ឯផ្លូវគំនិតនិងល័ខឋានទាំងឡាយនោះ, ខ្ញុំសូមមិននិយាយក្នុងសំនេរនេះទាំងអស់ទេ ។ តែមានល័ខឋាន ឬមេគំនិតមួយដែលជាធាតុសំខាន់បំផុតសម្រាប់ឲ្យពន្លឺដល់យើង ដែលខ្ញុំសូមទាញគំនិតអ្នកអាន ឲ្យចាប់អារម្មណ៍ច្រើនជាងគេនោះ គឺការរឭកជាតិបានរបស់ជនទាំងឡាយដែលមានកំណើតថ្មី ព្រោះធាតុនេះព្រះពុទ្ធសាសនាបាននិយាយដល់ជាញឹកញយក្នុងសម័យបុរាណកាលផង មានអ្នករឭកជាតិជាច្រើន ដែលត្រូវបានគេប្រាស្រ័យទាក់ទងដើម្បីធ្វើសំណួរក្នុងបច្ចុប្បន្នកាលផង ។ យ៉ាងណាក៏ដោយ, គោលការណ៍របស់ពុទ្ធសាសនាយើងក្នុងចំណុចថា ចិត្តមិនសូន្យបាត់ ទៅដូចរូបកាយសឹងមានហេតុ មានបច្ច័យច្រើន តម្រូវឲ្យសូន្យបាត់ទៅនោះ ពុំបានខុសគ្នានិងគោលការណ៍វិទ្យាសាស្ត្រដែលស្ដីថា ថាមពលដើម ឬថាមពលប្រចាំរបស់រូបធាតុមិនបានសាបសូន្យបាត់បង់ទៅតាមទម្រង់ ឬដំណុំរបស់រូបធាតុទេ ។ ជំនឿរបស់ ពុទ្ធសាសនិកថា ស្លាប់ហើយកើតជាថ្មីទៀតជាជំនឿត្រឹមត្រូវតាមគោលការណ៍វិទ្យាសាស្ត្រក្នុងចំណុចថា : ថាមពលជាធាតុមួយ ធ្វើឲ្យកើតក៏មិនបានធ្វើឲ្យ សូន្យក៏មិនកើត ។ តែគេអាចធ្វើឲ្យវាផ្លាស់ទៅជានេះ ជានោះបាន ។ ចិត្តក៏ដូចគ្នា, ធ្វើឲ្យកើតក៏មិនបានធ្វើឲ្យសូន្យក៏មិនកើត តែការផ្លាស់ទីអាស្រ័យនៅរបស់វាទៅជានេះម្ដង ទៅជានោះម្ដងជាមួយនិងការដូរភាព, ធាតុនេះតែងមានជាធម្មតា ។ ពំនោលពុទ្ធសាសនាបានគូសបញ្ជាក់ថា ជម្រក ឬទីអាស្រ័យរបស់ចិត្តមានលក្ខណៈ ផ្សេងៗគ្នា, មានឈ្មោះខុសគ្នា, មានបរិមាណច្រើនបែប ច្រើនប្រការ ដូចជាកាយសត្វតិរច្ឆាន, កាយមនុស្ស, កាយទេព, កាយប្រេត, កាយអសុរៈ, ពិភពមនុស្ស, ពិភពនរក, ពិភពសួគ៌ ។ល។

គ/ វិទ្យាសាស្ត្របច្ចុប្បន្នបានពិសោធន៍ឃើញ, បានឲ្យទស្សនៈយ៉ាងច្បាស់ថា រូបធាតុ ឬវត្ថុធាតុផ្លាស់ភាពមកជាថាមពលដើម ឬថាមពលប្រចាំរបស់វាបាន (E ប៉ុនគ្នានឹង MC2) ចំណុចនេះបានស្របគ្នាជាមួយនិងធម្មៈពុទ្ធសាសនាមនុស្សមានសមត្ថភាពចូលទៅដល់និព្វានបានដៅសេចក្ដីថា មនុស្សយើងម្នាក់ៗមានសមត្ថភាពធ្វើខ្លួនឯងឲ្យរួចផុតចាកទុក្ខ, ឲ្យរស់នៅលើកង្វល់ ឬឲ្យរស់នៅក្នុងត្រើយមួយខាងទៀត ដែលជាត្រើយគ្មានបន្លាស់គ្មានដំណូរណាៗទាំងអស់ ដែលគេធ្លាប់បានជួបប្រទះ ក្នុងលោកបច្ចុប្បន្ន បានដល់ភាពទុក្ខ, ភាពកើត, ភាពស្លាប់ ឬភាពដូរ, ភាពផ្លាស់ខាងផ្នែកសេដ្ឋកិច្ចនយោបាយ, វប្បធម៌, ចិត្តវិទ្យា ។ល។ ទំនងដូចគ្នានឹងរូបធាតុ កាលណា

ផ្លាស់មកជាថាមពលដើម ឬថាមពលប្រចាំរបស់វាវិញស្រេចបាច់ហើយ វាក៏មានសភាព រួចផុតស្រឡះ វាត្រឡប់មកនៅលើភាពដូច ភាពផ្លាស់ណាៗទាំងអស់ ដែលវាធ្លាប់មាន, ធ្លាប់ជួបប្រទះ ក្នុងពេលកំពុងជ្រកនៅ ជាមួយនិងរូបធាតុសឹងមានលក្ខណៈដូចជាការដូរ ការផ្លាស់ខាងគីមី, និងការដូរ ការផ្លាស់ខាងហ្វីសិក្ស ជាដើមហ្នឹងដែរ ។

ព្រះពុទ្ធសាសនាបានបង្រៀនឲ្យដឹងថា : មនុស្សរាល់រូបមានលទ្ធភាពចូលកាន់សភាពចិត្តល្អបរិសុទ្ធ របស់ខ្លួនដោយវិធី ខំប្រឹងព្យាយាមហ្វឹកហាត់រំលត់រំលាយធម្មជាតិបង្កើតរោគចិត្តទាំងបី គឺរាគៈ ទោសៈ មោហៈ ។ លុបបំបាត់ឲ្យអស់នូវអាការៈ របស់ចិត្តទាំង ៦ គឺវេទនា, សញ្ញា, សង្ខារ, វិញ្ញាណ, តណ្ហា, ឧបាទាន ។ លុះត្រាដល់កម្រិតសូន្យអស់គ្មានសេសសល់ ។ ប្រែថា ធ្វើយ៉ាងណាឲ្យអស់ចិត្តសៅហ្មង បានដល់នូវប្រក្រតីភាពជាធម្មតាឡើងវិញ ។ ទំរើនេះយើងត្រូវធ្វើហើយធ្វើទៀត រហូតដល់អស់ជីវិតរៀងៗខ្លួន កុំខ្ជិល កុំឈប់ កុំទម្លាក់ចោលឲ្យសោះ ។ ព្រោះអ្វី? ព្រោះប្រក្រតីចិត្ត ព្រះសម្មាសម្ពុទ្ធរបស់យើង ព្រះអង្គបានមានពំនោលថា មានតែប្រក្រតីចិត្តទេដែលជាធាតុមានភាពល្អបរិសុទ្ធមធ្យ៉តផូរផង់ ។ ព្រមគ្នានេះទៀត, ព្រះអង្គបានបន្តព្រះពំនោលថា មានតែប្រក្រតីចិត្តប៉ុណ្ណោះ ដែលជាធាតុមានពន្លឺរស្មីថ្លាត្រចះត្រចង់យ៉ាងចម្លែក គ្មានគូប្រៀប គូប្រដូច ។ ជាចុងក្រោយបង្អស់ ព្រះសម្ពុទ្ធ, ព្រះអង្គបានធ្វើសេចក្តីបំភ្លឺថា : ប្រក្រតីចិត្តនេះ, ក្រោយមកត្រូវបាត់បង់ភាពល្អ បរិសុទ្ធអស់រលីង, ពន្លឺរស្មីយ៉ាងចម្លែក អស្ចារ្យរបស់ប្រក្រតីចិត្តនេះ ក៏ត្រូវរលត់ឈឹងសូន្យ ដំណាលគ្នានិងការបាត់ ភាពល្អបរិសុទ្ធនៃប្រក្រតីចិត្តហ្នឹងឯង ។ ព្រះអង្គបានធ្វើសំណួរថា ហេតុអ្វីបានជាប្រក្រតីចិត្តផ្លាស់ភាពល្អមកជា អាក្រក់, ផ្លាស់ភាពភ្លឺស្វាងមកជាភាពងងឹតសូន្យដូចនេះ? ចម្លើយរបស់ព្រះអង្គថា : ព្រោះអាគន្តុកកិលេស (គ្រឿងសៅហ្មងដែលទើបមកដល់ថ្មី ឬដែលទើបនឹងកើតក្រោយ) ធាតុនេះ វាបានចូលធ្វើអន្តរាគមន៍អាក្រក់ ឲ្យចិត្តរបស់សត្វប្រែភាព, ប្រែទំនង, ប្រែលក្ខណៈគ្រប់បែបយ៉ាងដែលប្រក្រតីចិត្តធ្លាប់មាន, ធ្លាប់ប្រើ ទើបចិត្តមាន ភាពខុសប្រក្រតីទៅ ។

ឃ/ កាលបើកិលេសទាំងឡាយមានតណ្ហា, ឧបាទានជាដើម ត្រូវបានមនុស្សណាធ្វើឲ្យរលាយអស់ដោយគ្មានសេសសល់ហើយ ។ មនុស្សនោះរមែងត្រូវបានប្រែសភាពពីអាក្រក់មកល្អ, ពីងងឹតមកជាភ្លឺ, ពីតក់ម៉ក់មកជាស្លូតបូត ។ ក្នុងន័យថា : មនុស្សមានចិត្តល្អកើតឡើងក្នុងពេល ណាពេលនោះទំរើទាំងឡាយរបស់គេដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៣ គឺ : កាយ, វាចា, ចិត្ត ក៏តាំងនៅក្នុងភាពល្អគ្រប់ពេលវេលា ។ សភាពចិត្តសុទ្ធ ដែលមិនទាន់មានអាគន្តុកកិលេសចូលមកញាំញីហ្នឹងឯង គឺថាមពលដើមរបស់រូបធាតុ ឬជាថាមពលប្រចាំរបស់រូបកាយនៃមនុស្សសត្វ ។ មនុស្សទាំងឡាយ, កាលបើបានធ្វើចិត្តរបស់ខ្លួន ឲ្យមានសភាពល្អបរិសុទ្ធដោយប្រើមធ្យោបាយពីរគឺ : សមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ប្រកបដោយសេចក្តីព្យាយាមយ៉ាង មធ្យ៉តប្តូរផ្តាច់ គេមុខជានឹងត្រូវបានសម្រេចនូវអរិយមគ្គ អរិយផលតាំងពីថ្នាក់ខាងដើមរហូតដល់ថ្នាក់ទីបំផុត ។ គេត្រូវបានផុត រួចចាកភាពផ្លាស់ប្តូរប្រែប្រួលណាៗទាំងអស់ ដែលខ្លួនគេធ្លាប់បានជួបប្រទះ ។ ពោលដោយចំពោះ គឺគេមានសមត្ថភាពលះបង់ចោលនូវលោកិយធម៌ ហើយទទួលយកនូវលោកុត្តរធម៌ ព្រមគ្នាក្នុងពេលនោះតែម្តង ។

ង/ ការជួបភាពពិតប្រាកដតាមជំរាវរបស់អ្នកវិទ្យាសាស្ត្រក្នុងចំណុចថា រូបធាតុ ឬវត្ថុធាតុ ដែលគេយកមកធ្វើគ្រាប់បែកបរមាណូ ដើម្បីឲ្យធាតុនោះបំផ្លែងឫទ្ធិ រំលាយភាពរបស់វាទៅជាថាមពលដូចដើមវិញនោះ ។ ទំរើនេះគេធ្វើនៅក្នុងមាន កំណត់ព្រំដែន គឺមិនមែនចេះតែធ្វើ, ចេះតែយករូបធាតុណា, វត្ថុធាតុណាមកប្រើបានទាំងអស់ទេ ។ គឺមានកំណត់លក្ខ័ណ្ឌ ជាក់លាក់ទាំងប្រភេទ ទាំងបរិមាណរបស់ធាតុ ។ ក្នុងបច្ចុប្បន្នកាលនេះ, ភាពច្បាស់លាស់ក្នុងទំរើនេះ (ការធ្វើគ្រាប់បែកបរមាណូ) គេគ្មានយកធាតុអ្វីក្រៅពីធាតុអ៊ុយរ៉ានីយ៉ូម (URANIUM) តែប៉ុណ្ណោះមកធ្វើជាគ្រឿងផ្ទុះនេះ ដោយគេមានគំហើញថា មានតែធាតុមួយនេះទេដែលមានគុណភាព, មានប្រយោជន៍ដល់ទំរើរបស់គេ ដែលកំពុងប្រព្រឹត្តទៅក្នុងសតវត្សទី ២០ ស្តីដោយការស្ថាបនា កម្លាំងបរមាណូ ដើម្បីបម្រើសង្គ្រាម

និងសន្តិភាព ។ តែការស្ថាបនាកម្លាំងបរមាណូ គេមិនអាចនឹងធ្វើបានភ្លាមៗទេ, គេត្រូវប្រើពេលក្នុងទំរើនេះយ៉ាងយូរ ចាប់តាំងពីនាំយកធាតុនេះដាក់ចូលក្នុងជើងក្រានរំលាយបរមាណូ ឲ្យវាផ្លាស់ភាពទៅជាធាតុ ព្លុយតូនីយ៉ូម (PLUTONIUM) ជាមុនសិនទើបគេយកទៅស្ថាបនាកម្លាំងផ្សេងៗ តាមសេចក្ដីត្រូវការរបស់គេ ។

សត្វលោកទាំងឡាយ, ដែលកំពុងធ្វើដំណើរឆ្លងកាត់សមុទ្ររបស់ជីវិត ក៏ត្រូវអនុវត្តកិច្ចការធម្មតានិងការអភិវឌ្ឍន៍នៅក្នុងក្របខ័ណ្ឌរំដោះខ្លួន គឺធ្វើយ៉ាងណាឲ្យដំណើររបស់ខ្លួនបានដល់ទិសដៅមួយ ដែលមិនមែនជាអ្វីដទៃក្រៅពីសន្តិភាពរបស់ជីវិត, យុត្តិធម៌របស់សង្គម ដូចគ្នានឹងគោលការណ៍នៃវិទ្យាសាស្ត្រដែលកំពុងត្រូវបានអភិវឌ្ឍន៍ដើម្បីធ្វើឲ្យជីវិតមនុស្សមានប្រសិទ្ធិភាពគ្រប់វិស័យ នៅក្នុងឧត្តមគតិបម្រើជីវិត ឲ្យមានសេចក្ដីសុខខ្ពស់ឡើងលុះត្រាដល់កម្រិតមួយរយភាគរយតែម្ដង ។ ដើម្បីទៅឲ្យដល់នូវសេចក្ដីត្រូវការជាចុងបង្អស់របស់មនុស្ស ។ ព្រះសម្មាសម្ពុទ្ធរបស់យើង ព្រះអង្គបានដាក់បញ្ញាឲ្យពុទ្ធសាសនិកអនុវត្តវិទ្យាសាស្ត្របច្ចុប្បន្ន (ប្រយោជន៍បច្ចុប្បន្ន) ៤ ជាទីមួយអនុវត្តវិទ្យាសាស្ត្រអនាគត (ប្រយោជន៍បរលោក) ៤ ជាទីពីរ, អនុវត្តវិទ្យាសាស្ត្រនិព្វាន (ប្រយោជន៍បរមត្ថ) ៤ ជាទីបី ។ ជាមួយគ្នានេះទៀត ព្រះអង្គបានធ្វើសេចក្ដីបំភ្លឺថា ក្នុងបណ្ដាសត្វទាំងឡាយ ៤ (មនុស្ស, ទេព, ព្រហ្ម, អបាយ) មានតែសត្វមនុស្សមួយប៉ុណ្ណោះទេ ទើបមានលទ្ធភាពហ្វឹកហាត់ចម្រើន ធម៌រម្លត់តណ្ហា រម្លាយឧបាទានឲ្យអស់ពីវិញ្ញាណ (ឋាមពលដើមរបស់រូបកាយ) បាន ។ សត្វមនុស្សក្រោយពេល ដែលខ្លួនបានធ្វើចិត្ត ឬថាមពលប្រចាំរូបកាយឲ្យបានដល់នូវភាពបរិសុទ្ធគ្មានគ្រឿងសៅហ្មង នៅក្នុងក្របខ័ណ្ឌនៃពោធិបក្ខិយធម៌ ៣៧ ដែលមានបារមី ១០, ចរិយា ៣, មហាបរិច្ចាគ ៥, ជាមូលដ្ឋាន មានខន្តិភាព និងសុរភាពជាគ្រឿងប្រកប, មានសំនួនិងចំនោលជាជំនួយ ។ ខ្លួនគេក៏បានចូលទៅដល់ភាពគ្មានប្រែប្រួល, គ្មានច្របូកច្របល់ដែលភាសាពុទ្ធសាសនាហៅថា «និព្វាន» ហ្នឹងឯង ។

ច/ កាលណារូបធាតុបានបំផ្លែងឫទ្ធិចំនៃភាពរបស់វាជាថាមពលដើម (ក្នុងពេលផ្ទុះគ្រាប់បែកបរមាណូ) រមែងមាន អំណាចធ្វើឲ្យរូបធាតុដទៃៗ ក្នុងបរិវេណជិតខាងមានសំលាយជាថាមពលព្រមៗគ្នាក្នុងពេលនោះ ។ សេចក្ដីក្នុងចំណុចនេះ ក៏គ្មានខុសគ្នានឹងគោលការណ៍ខាងដើមរបស់ព្រះពុទ្ធសាសនាដែលថា : បើគេត្រូវការចង់ឲ្យមនុស្សដទៃមានសីលធម៌ល្អ, មានចរិយាថ្លៃថ្នូរ គេត្រូវតែធ្វើខ្លួនគេឲ្យមានសីលធម៌ល្អ មានចរិយាថ្លៃថ្នូរជាមុនសិន ។ ព្រោះសីលធម៌ល្អដែលខ្លួនគេបានប្រតិបត្តិហើយ, ចរិយាថ្លៃថ្នូរដែលខ្លួនគេបានប្រព្រឹត្តហើយនោះ វារមែងមានអំណាចធ្វើឲ្យមនុស្សដទៃ ដែលរស់នៅក្នុងទីជិតខាងគ្រាប់គឺ ធ្វើតាម, កាន់តាម, ប្រតិបត្តិតាម, ប្រព្រឹត្តតាមជាមិនខានឡើយ ។ បើស្ដីឲ្យចំតាមលំនាំវិទ្យាសាស្ត្រគេស្ដីថា កាលណាមនុស្ស យើងបានរំលាយចោលនូវពិសកំណាចរបស់តណ្ហា, ឧបាទានដែលជ្រកនៅក្នុងចិត្តវិញ្ញាណ (ថាមពលប្រចាំ) របស់ខ្លួនអស់ហើយនោះ, អំណាស់នេះវាមានអំណាចធ្វើឲ្យអ្នកដទៃ យកទៅអនុវត្តជាទំរើរបស់គេ លុះត្រាបានសម្រេចនិព្វានគ្រប់ៗគ្នា ។ ផ្ទុយទៅវិញ, មនុស្សដែលប្រព្រឹត្តនូវទំរើអាក្រក់, គ្មានសីលធម៌, គ្មានចរិយាថ្លៃថ្នូរនោះមិនមែនជានរណាដទៃ គឺជាមនុស្សដែលត្រូវការឲ្យមនុស្សផងគ្នា (មនុស្សក្នុងភូមិផងរបងជាមួយ) នោះ ប្រព្រឹត្តទំរើអាក្រក់រស់នៅក្នុងភាពគ្មានសីលធម៌ល្អ, គ្មានចរិយាថ្លៃថ្នូរ, គ្មានលក្ខណៈជាមនុស្សមែនទែនដូចខ្លួន ដែលមានចែងក្នុងប្រភេទមនុស្ស ៥ យ៉ាងដោយព្រះសម្មាសម្ពុទ្ធបរមគ្រូរបស់យើង ។

កាលណាយើងលើកយកចំណុចសំខាន់ ដែលវិទ្យាសាស្ត្របានរកឃើញ មកប្រៀបធៀបជាមួយនិងធម្មៈរបស់ពុទ្ធសាសនាតាមបន្ទាត់គំនិតដូចមានក្នុងពំនោលខាងដើមនោះ យើងក៏មិនឃើញអ្វីជាទីទំនាស់ទំនាក់គ្នា សូម្បីបន្តិចបន្តួច ឡើយ ។ គំហើញនិងទំរើទាំងអស់សុទ្ធតែនៅក្នុងភាព ក្នុងលក្ខណៈត្រូវគ្នា ស្របគ្នា ។ បើទោះណាជាមានល្អៀងគ្នាបន្តិចបន្តួច ក៏គង់អាចអនុលោមចូលគ្នាបានគ្រប់ចំណុចទាំងអស់ នេះជាធម្មតា, មិនមែនជាការចម្លែក

ឡើយ នេះជាសេចក្តីបញ្ជាក់មួយទៀត ដល់យោបល់មនុស្សណាដែលមានគំហើញថា ពុទ្ធសាសនាប្រៀបបាននឹងវិទ្យាសាស្ត្រ មានលក្ខណៈជាវិទ្យាសាស្ត្រ ។ ចំណែកអ្នកដែលយល់ឃើញថា ពុទ្ធសាសនាជាវិទ្យាសាស្ត្រ, វិទ្យាសាស្ត្រជាពុទ្ធសាសនាទៅហើយនោះ វាគ្មានបញ្ហាចោទដូចនេះ ដូចនោះទៀតទេ គឺវាចប់ស្រេចតែម្តង ។ សម្រាប់ខ្លួនខ្ញុំអ្នកសរសេរ, ខ្ញុំយល់ឃើញយ៉ាងច្បាស់ថា ពុទ្ធសាសនាជាវិទ្យាសាស្ត្រផង, ជាទស្សនៈវិជ្ជាផង, ជាសាសនាផង, ជានិទានផង, ជាវណ្ណកម្មផង, ជាពិធីការផង ។ ដូចនេះព្រោះអ្វី? ព្រោះការងារទាំងឡាយមានទិដ្ឋធម្មិកត្ថប្រយោជន៍ជាដើម គឺជាវិទ្យាសាស្ត្រ, ពុទ្ធធម៌ក្នុងចំណុចមានហេតុផល ជាទស្សនៈវិជ្ជាបាប គុណទោស . . . . ជាសាសនា ។ល។ និង ។ល។ នៅក្នុងន័យនេះ ពុទ្ធសាសនិកក៏ជាអ្នកវិទ្យាសាស្ត្រ អ្នកវិទ្យាសាស្ត្រក៏ជាពុទ្ធសាសនិក ព្រោះអ្នក ទាំងពីរបានធ្វើការស្រាវជ្រាវប្រកបដោយគំនិតបញ្ញា, នៅក្នុងក្របខ័ណ្ឌនៃហេតុផលនៃវិចារណញ្ញាណដូចៗគ្នា ។ ប្រសិនបើមានសំណួរថា : អ្នកវិទ្យាសាស្ត្រជាពុទ្ធសាសនិកដូចម្តេចកើត បើគ្មានរក្សាសីល? ចំពោះសំណួរនេះ, ខ្ញុំសូមមិនឆ្លើយទេ ព្រោះគ្មានពេល ។ តែខ្ញុំសូមបំភ្លឺម្ចាស់សំណួរថា : សីល, ធាតុនេះមិនមែនមាននៅតែក្នុងខ្លួនអ្នកបួស, អ្នកសមាទានទេគឺ : មាននៅក្នុងខ្លួនរបស់នរណា ដែលគ្មានធ្វើទំរើបាបគ្មានធ្វើទំរើជិះជាន់សង្កត់សង្កិនគេ ។ ដូចនេះអ្នកបួសណានៅប្រព្រឹត្តទំរើបៀតបៀនគេ, អ្នកបួសនោះ មិនមែនជាអ្នកបួស, មិនមែនជាអ្នកមានសីលទេ ។ អ្នកវិទ្យាសាស្ត្រណាបង្កើតរថយន្ត ឲ្យអ្នកដំណើរ ប្រើប្រាស់បានស្រួល, អ្នកវិទ្យាសាស្ត្រនោះមានសីល ព្រោះបានធ្វើសេចក្តីសុខឲ្យកើតដល់មនុស្ស ។ អ្នកវិទ្យាសាស្ត្រនោះមានសីល ព្រោះបានធ្វើសេចក្តីសុខឲ្យកើតដល់មនុស្ស ។ អ្នកវិទ្យាសាស្ត្រណាបង្កើតផ្សែងពិសពុលសម្រាប់សម្លាប់មនុស្ស, អ្នកវិទ្យាសាស្ត្រនោះមិនមែនជាអ្នកមានសីលឡើយ ។ សំនេរខាងលើនេះ បញ្ជាក់ឲ្យឃើញថា : ទាំងពុទ្ធសាសនិក ទាំងអ្នកវិទ្យាសាស្ត្រមួយណាក៏ដូចមួយណា គឺទាំងពីរនាក់មានឧត្តមគតិនិងគោលគំនិតត្រូវគ្នា ។ ដូចនេះព្រោះហេតុអ្វី? ព្រោះហេតុថា : សេចក្តីចេះដឹងទាំងឡាយណាក៏ដោយ ប្រសិនបើគេបានបង្កើត ឬគេបានជួបប្រទះដោយការស្រាវជ្រាវឲ្យត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រ (SCIENTISIC METHOD) ប្រកបដោយរបៀបរៀបរយយ៉ាងខ្ពង់ខ្ពស់ហើយ សេចក្តីចេះដឹងទាំងឡាយនោះគឺធម្មៈ ជាប្រចាំលោកក៏មិនមែនជាធាតុអ្វីដទៃទេ គឺជាពុទ្ធធម៌ដែលយើងកំពុងសិក្សា កំពុងប្រតិបត្តិគ្រប់គ្នាសព្វថ្ងៃ ។

## សរុបសេចក្តី

មនុស្សលោកយើង, ដែលរស់នៅក្នុងសម័យសតវត្សទី ២០, វិទ្យាសាស្ត្របានបង្រៀនឲ្យឃើញច្បាស់ថាមានសមត្ថភាព ផ្លាស់ប្តូររូបធាតុឲ្យក្លាយភាពជាថាមពលដែលអ្នកវិទ្យាសាស្ត្របានធ្វើការកត់សម្គាល់ បានទុកដាក់ថា នៅគ្រប់រូបធាតុ ឬវត្ថុធាតុទាំងអស់ មួយណាដូចជាមួយណា សុទ្ធតែមានថាមពលមួយៗ នៅខាងក្នុង ។ ថាមពលនេះ បានត្រូវអ្នកវិទ្យាសាស្ត្រឲ្យឈ្មោះថា «ធាតុដើម» ឬ «ធាតុប្រចាំ» គឺធាតុដែលមាននៅជានិរន្តរ៍ក្នុងសកលពិភព ។ ធាតុនេះ, វាមានរូបធាតុជាលំនៅ ឬជាជម្រក, តែវា ពុំបានស្លាប់ដូចរូបធាតុទេ ។ វាគ្រាន់តែដូរទីដូរកន្លែង ដូរភពក្នុងពេលដែលរូបធាតុជាសម្បុករបស់វាត្រូវស្លាប់ ត្រូវសូន្យប៉ុណ្ណោះ ។ ដូចនេះ, ដំណួរនិងបន្លាស់របស់ធាតុនេះ យើងត្រូវនិយាយឲ្យនៅក្នុងក្របខ័ណ្ឌមានព្រំដែន គឺពាក្យ «ស្លាប់» សម្រាប់និយាយដល់ រូបធាតុទូទៅទាំងអស់, ពាក្យ «ដូរ» សម្រាប់និយាយដល់ថាមពលទាំងឡាយ ដែលអាស្រ័យនៅក្នុងរូបធាតុមួយៗ ។ អ្នកវិទ្យាសាស្ត្រ បានឲ្យសេចក្តីសង្កេតរបស់ខ្លួនថា : ថាមពលវាមិនមែនមានត្រឹមតែដំណូរទេ គឺវាមានកំលាយ (ភាពប្រែ ភាពក្លាយ) ខ្លះៗដែរ តែមានមិនច្រើនប៉ុន្មានទេ ។

ព្រះពុទ្ធសាសនារបស់យើងក៏មាននិយាយថា : មនុស្សរាល់រូបមានសមត្ថភាពផ្លាស់ប្តូរខ្លួនឯង ឲ្យមានសភាពខុសប្រក្រតី គឺផ្នែកភាពចិត្តដែលត្រូវអាគន្តុកកិលេស ធ្វើឲ្យសៅហ្មង ឲ្យទៅជាចិត្តបរិសុទ្ធតាមភាពដើម ។

កាលណាចិត្តវិលមកដល់ភាពដើម, ភាពផ្លាស់ប្តូរប្រែប្រួលរបស់សត្វក៏ចប់ត្រឹមហ្នឹងឯង ។ អ្នកអានសូមកុំភ្លេចធ្វើការកត់សម្គាល់ថា «ចិត្ត» ជាភាសាពុទ្ធសាសនា, «ថាមពល» ជាភាសាវិទ្យាសាស្ត្រ ។ ពាក្យទាំងពីរនេះ មានសំឡេងខុសគ្នាតែមានន័យដូចគ្នា ។ ក្នុងសម័យនេះ ប្រសិនបើយើងហៅចិត្តថា «ថាមពល» វិញ ក៏គ្មានទាស់ខុសអ្វីទេ ដើម្បីងាយស្រួលដល់ការពន្យល់ ដែលយើងត្រូវធ្វើក្នុង កាលៈទេសៈបច្ចុប្បន្ននេះ ។ សមត្ថភាពរបស់ ជនទាំងពីរពួក (អ្នកសាសនានិងអ្នកវិទ្យាសាស្ត្រ) បានបង្ហាញថ្មីគំនិតរបស់ខ្លួន ឲ្យពិភពលោកឃើញច្បាស់ដោយ មានផ្ទុះគ្រាប់បែកបរមាណូឡើងក្នុងពិភពលោកបច្ចុប្បន្ននេះផង ដោយមានការឧប្បត្តិឡើងនៃព្រះសម្មាសម្ពុទ្ធរបស់ យើងជាងពីរពាន់ឆ្នាំមកហើយផង ។ តាមការសង្កេតឃើញរបស់ខ្ញុំ ពុទ្ធសាសនាក្តី, វិទ្យាសាស្ត្រក្តី ទាំងពីរនេះអស់ មានបញ្ហាចោទទៀតហើយ ។

បញ្ហាដែលត្រូវចោទលើមនុស្ស មាននៅត្រឹមថា តើមនុស្សត្រូវអនុវត្តទ្រឹស្តីសាសនា ឲ្យមានលក្ខណៈជាវិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រឬទេ? ព្រមគ្នានេះទៀត, តើមនុស្សអនុវត្តទ្រឹស្តីវិទ្យាសាស្ត្រ ឲ្យមានលក្ខណៈជាពុទ្ធសាសនា ឬជាពុទ្ធសាសនាឬទេ? កាលណាគេអនុវត្តពុទ្ធសាសនា ឲ្យមានលក្ខណៈជាវិទ្យាសាស្ត្រ ឬជាវិទ្យាសាស្ត្រគ្រប់ចំណុចក៏រឹតតែត្រូវ ព្រោះពុទ្ធសាសនានោះ ជាវិទ្យាសាស្ត្រស្រាប់ដូចបានពោលមកហើយ ។ ក្រោយទំរើនេះ, គេមុខជានឹងប្រានចោលនូវជំនឿទាំងឡាយ មានជំនឿថា : ខ្មោច, ទេព, ព្រហ្ម, ដី, ទឹក, ភ្លើង, ខ្យល់ជាដម ជាធាតុខ្លាំងពូកែ ឬជាវត្ថុស័ក្តិសិទ្ធិអាចប្រសិទ្ធិពរ ប្រទានជោគជ័យ ដល់មនុស្ស តាមដែលគេត្រូវការ, ត្រូវការយ៉ាងណា បានយ៉ាងនោះ ។ គឺថា គេលែងខ្វីរវល់ពឹងផ្អែកលើអ្វីៗ ដែលខ្ញុំចង់ ថា ជំនឿល្ងង់, ប្រពៃណីខុស, សាសន៍ព្រៃ ។ល។ គេលែងពឹងអ្វីៗទាំងអស់ ក្រៅពីពឹងកម្លាំងក្នុងខ្លួនរបស់គេ, ពឹងកម្លាំងការងារដែលខ្លួនគេបានធ្វើ នៅក្នុងពុទ្ធគំនិតថា : មនុស្សមានការងារជារបស់ខ្លួន, មានខ្លួនជាមរតកនៃ ការងារ, មានការងារជាធាតុតុបតែងកំណើត, មានការងារជាញាតិមិត្ត, មានការងារជាទីពឹង ។ សុខទុក្ខរបស់មនុស្ស កើតមកពីការងារល្អនិងការងារអាក្រក់ ពុំមែនកើតមកពីធាតុទាំងឡាយមានខ្មោចជាដើមឡើយ ។ នេះជាលទ្ធផលនៃ ការអនុវត្តពុទ្ធសាសនាត្រូវ ឬអនុវត្តពុទ្ធសាសនាជាវិទ្យាសាស្ត្រ ។

កាលណាគេអនុវត្តវិទ្យាសាស្ត្រ ឲ្យមានលក្ខណៈជាពុទ្ធសាសនា ឬជាពុទ្ធសាសនាគ្រប់ចំណុចទាំងអស់ ព្រោះវិទ្យាសាស្ត្រជាធាតុរបស់ពុទ្ធសាសនាស្រាប់ ។ គេមុខជានឹងប្រានចោលនូវទំរើទាំងឡាយណា ដែលជាទំរើអាក្រក់, ទំរើអកុសល ។ គេមិនយកវត្ថុវិទ្យាសាស្ត្រទាំងឡាយមានធាតុបរមាណូជាដើម មកធ្វើអាវុធសម្រាប់ប្រហារជីវិតមនុស្ស ។ តែគេយកមកប្រើជាគ្រឿងប្រដាប់សម្រាប់រស់, សម្រាប់ធ្វើការអភិវឌ្ឍន៍គ្រប់វិស័យ ដើម្បីស្ថាបនាពិភពមនុស្សជាពិភពទេព ឬស្ថាបនាសន្តិភាពសម្រាប់មនុស្សនៅក្នុងក្របខ័ណ្ឌ នៃការជឿនលឿនខាង អរិយធម៌របស់ពិភពលោកដែលកំពុងមានភាពនៅជាសុបិនសព្វថ្ងៃ ។ នេះគឺជាលទ្ធផលនៃការអនុវត្តវិទ្យាសាស្ត្រត្រូវ ឬអនុវត្តវិទ្យាសាស្ត្រជាពុទ្ធសាសនា ។ ក្នុងឃ្លានេះទៀត, អ្នកអានគប្បីដឹងថា : ទ្រឹស្តីពុទ្ធសាសនាកន្លែងណាក៏ដូចជាកន្លែងណាដែរ, ព្រះសម្មាសម្ពុទ្ធរបស់យើង ព្រះអង្គគ្មានបាននិយាយដល់អាត្ម័នទេ, តែព្រះអង្គបាននិយាយដល់ចិត្ត ។ អាត្ម័នជាធាតុមួយមានក្នុងទ្រឹស្តីនៃសាសនាព្រាហ្មណ៍, ធាតុនេះមានលក្ខណៈបែបណា, វារស់នៅយ៉ាងដូចម្តេច, ជាសកម្មភាពនិង ចលនាយ៉ាងម៉េចខ្លះខ្ញុំមិនសរសេរក្នុងទីនេះទេ ។ អ្នកអានចង់ដឹង (មើលបញ្ហាអនាគតនិងទស្សនៈសកល) ។ ដើម្បី ជាពន្លឺក្នុងរឿងស្លាប់កើតនេះ, ខ្ញុំសូមធ្វើសេចក្តីបញ្ជាក់ម្តងទៀតថា : មនុស្សស្លាប់, អាត្ម័នក្នុងរូបមនុស្សវាទៅកើតទៀត ។ ចំណែកពុទ្ធសាសនា, ទោះណាជាមាននិយាយដល់ចិត្ត ក៏គ្មានថា ចិត្តទៅកើតទៀតទេ ។ តែមាននិយាយថា ចិត្តជាធាតុមួយសម្រាប់កើតរលត់ៗ ចិត្តដំបូង ឬចិត្តដើម, ឬក៏ចិត្ត ប្រចាំរលត់, កើតចិត្តទីពីរ ទីបី . . . . . បន្តបន្ទាប់គ្នា ។ ក្នុងន័យថា : ភវង្គចិត្តរលត់, កើតវិថីចិត្ត, វិថីចិត្តរលត់, កើតចុតិចិត្ត, ចុតិចិត្តរលត់,

កើតបដិសន្ធិចិត្ត . . . . . គឺនៅក្នុងចន្លោះចិត្តនិមួយៗ វាមានធាតុមួយៗ ដែលលោកដាក់ ឈ្មោះថា«**សន្តតិ**»(ភាពតភាពបញ្ចប់) គឺខណៈចិត្តមួយ ទៅខណៈចិត្តមួយ ដែលយើងធ្លាប់កត់សម្គាល់ថា : ធាតុនេះមាននៅក្នុងខ្លួនរបស់មនុស្សសត្វ ។ តាមការពិត, ជីវិតទាំងឡាយ លោកប្រៀបប្រដូចទៅនឹងខ្សែទឹកណា ដែលមានចលនាហូរជាប់មិនដាច់ ។ ចលណានេះវាបានរុញ បានច្រានបន្តបន្ទាប់គ្នារជឹកគ្មានឈប់បន្តិចបន្តួច ឡើយ ។ ចលនានេះ, វាមានលក្ខណៈរបស់វាបីគឺ កើតឡើង, មាននៅ, រលត់ទៅ (ឧបាទៈ, ឋិតិ, ភង្គៈ) ។ ចលនានៃជីវិតនេះ វាបានផ្តល់ឲ្យនូវថាមពលបន្តគ្នា ពីចន្លោះមួយទៅ ចន្លោះមួយ ឬពីភាពមួយទៅភាពមួយ បង្កើតបានជាខ្សែភ្ជាប់ (សន្តតិ) ដែលគ្មានអ្វីធ្វើឲ្យវាបែកចេញពីគ្នាបាន គឺខ្សែធាតុសន្តតិនេះឯងហើយ ដែលវាបានតភ្ជាប់ជីវិតចាស់ ជាមួយនិងជីវិតថ្មីដូចជាខ្សែទឹក ឬអណ្តាតភ្លើងដែលយើង មើលឃើញហាក់ដូចជា វាមានសភាព តែមួយជាប់គ្នាគ្មានចន្លោះ ។ តែសភាពពិតនោះ វាមិនមែនដូចគំនិតយើងស្មាននោះទេ គឺវាមានចន្លោះ មានដំណាច់នៅក្នុងខ្សែ ក្នុងអណ្តាតរបស់វាយ៉ាងញឹកល្អិតលុះត្រាយើងមើលមិនឃើញ ។

ដូចនេះ, គំនិតថា ចិត្តចាស់គឺចិត្តសព្វថ្ងៃនេះ ត្រូវទៅកើតក្នុងភពថ្មីទៀត ក្នុងពេលរូបកាយស្លាប់នោះ មិនទាន់សង្គ្រោះចូលក្នុងគំនិតត្រឹមត្រូវតាមបរមត្ថធម៌ទេ ។ តែគំនិតនេះ, ក៏នៅជាធាតុប្រើការបានតាមផ្លូវព្រះសូត្រដែរ ។ ចិត្តនិងថាមពល, ធាតុពីរនេះមានន័យត្រូវគ្នា ត្រង់មិនចេះស្លាប់, មិនចេះសាបសូន្យបាត់បង់ទៅជាមួយនិងរូបធាតុ ។ គឺពេលណារូបធាតុដែលជាសម្បុក ជាទីនៅអាស្រ័យរបស់វាត្រូវស្លាប់ ឬត្រូវបែកធ្លាយម្តងៗ វាតែងចេញទៅរកជម្រកថ្មីទៀតដោយអាស្រ័យហេតុនេះ ទើបគេឃើញកំណើតថ្មី, ជីវិតថ្មីជាមនុស្សខ្លះ, ជាសត្វខ្លះ, ជារុក្ខជាតិនានាខ្លះ ។ល។ ចេះតែមាននៅក្នុងលោកនេះជានិច្ច ។ ពិសេសជាងនេះទៅទៀត, ជីវិតទាំងឡាយ មួយណាក៏ដូចជាមួយណា សុទ្ធតែ មានសកម្មភាព, មានចលនាទាំងអស់, មនុស្សចេះធ្វើការរកស៊ី . . . . , សត្វគ្រប់ប្រភេទចេះស្វែងរកចំណីអាហារ ប្រហាក់ប្រហែលនឹងមនុស្សដែរ, រុក្ខជាតិគ្រប់ពូជ គ្រប់អម្បូរចេះដកដង្ហើមតាមស្លឹក ចេះស៊ីអាហារចំណីតាមឫស, ចេះយកកម្តៅ, ពន្លឺមកប្រើប្រាស់សម្រាប់ការរស់នៅរបស់វា រហូតដល់ចេះខំដុះ, ខំធំ, ខំខ្ពស់, ខំលូន, ខំវារ, ខំប្រតោង ។ល។ តើសកម្មភាពនិងចលនាទាំងអស់នេះ វាមិនមែនជារបស់ចិត្តវិញ្ញាណ ឬថាមពលដែលនៅអាស្រ័យក្នុងរូប មនុស្ស, សត្វ, ដើមឈើទេឬ?

តើចំណេះ, គំនិត, ដំណឹង, កម្លាច, កំលៅ, កំណាច, កំជិល, សំលូត, ទាំងឡាយនេះ ។ល។ ជារបស់រូបធាតុ ឬជារបស់នាមធាតុ? អ្នកអានបានដឹងតៗគ្នាមកហើយថា មានដើមឈើខ្លះៗ វាចេះបង្កើតសត្វបានដូចដើមត្រស់វាបង្កើតអន្ទង់, ត្រួយត្បែងវាបង្កើយចាប, ផ្លែល្វាវាបង្កើតមមង់, ត្រួយម្លិះវាបង្កើតកណ្តូប, ថ្នាំឈូកវាបង្កើតមនុស្ស (រឿងព្រេង) ។ កំណើត ឬជីវិតរបៀបនេះ ប្រសិនបើយើងពុំបានប្រើគំនិតតាមគោលការណ៍ទាំងឡាយមានធម្មៈនៃ ពុទ្ធសាសនានិងវិទ្យាសាស្ត្រជាដើមទេ ។ យើងមុខជាមានជំនឿថា គ្មានជីវិតដូចនេះកើតឡើងដោយអាស្រ័យដើមឈើ សូម្បីបន្តិចបន្តួចឡើយ ។ តែបើយើងប្រើគំនិតតាមគោលការណ៍ពុទ្ធសាសនាក្នុងចំណុចវិទ្យាសាស្ត្រ យើងនឹងបានជួប ទ្រឹស្តីមួយដែលបានចែងថា ប្រភពនៃកំណើត ឬជីវិតមាន ៤ គឺ : ១- កើតពីមេបា, ២- កើតពីស៊ុត, ៣- កើតពីកំអែល, ៤- កើតដោយគ្មានអាស្រ័យរបស់បីខាងដើម ។ ជាមួយគ្នានេះទៀត, គោលការណ៍ខាងវិទ្យាសាស្ត្រ ក៏មានទ្រឹស្តី សម្រាប់បង្រៀនឲ្យដឹងថា : អាកាសជាធាតុស្រាល, ធាតុល្អិត, ផែនដីជាធាតុធ្ងន់, ធាតុគ្រោតគ្រាត, ។ អាកាសជា ជម្រក ឬជាលំនៅថាមពលចិត្តវិញ្ញាណដែលពុំទាន់ចូលកាន់សំណង់, ផែនដីជាឃ្លាំងដាក់សម្ភារៈសំណង់ដែល វិញ្ញាណ ឬថាមពលត្រូវអាស្រ័យ ។ ដូចនេះ បើមេធាតុទាំងពីរ គឺអាកាសនិងផែនដីមាននៅដរាបណា, ដរាបនោះជីវិត នៅតែមាន, កំណើតនៅតែកើត ។ ដូចនេះព្រោះអ្វី? ព្រោះធាតុទាំងពីរនេះមានគ្រឿងឧបករណ៍និងមធ្យោបាយគ្រប់បែប គ្រប់យ៉ាងសម្រាប់បង្កើតសត្វ, សម្រាប់ធ្វើឲ្យសត្វរស់នៅ ។ ថ្ងៃណា

មួយធាតុដើម ឬធាតុប្រចាំ គឺអាកាសនិងផែនដីនេះ ត្រូវរលាយបាត់ភាព ទោះជារលាយទាំងពីរព្រមគ្នាក្តី រលាយបាត់មួយ សល់នៅមួយក្តី ជីវិតទាំងអស់នឹងត្រូវស្លាប់ កំណើតទាំងអស់នឹងត្រូវគ្មានភ្លាម ។ មនុស្សលោក កាលបើដឹងថាចិត្ត ឬវិញ្ញាណ ឬក៏ថាមពលមានកម្លាំងច្រើន មានភាពប្រែប្រួលផ្លាស់ប្តូរពីកន្លែងមួយ ទៅកន្លែងមួយ ឬពីជីវិតមួយទៅជីវិតមួយ មិនមែនជាធាតុស្លាប់សូន្យបាត់ដូចរូបធាតុ ។ គេត្រូវខំប្រឹងបណ្តុះ ឲ្យមានក្នុងធាតុនោះនូវគំនិតល្អ, សម្តីល្អ, ទំរើល្អ, ដែលពុទ្ធសាសនាបានឲ្យឈ្មោះថា «បុណ្យ» ព្រោះអ្វី? ព្រោះបុណ្យមានមុខងារធ្វើឲ្យចិត្តល្អ, វិញ្ញាណល្អ, ថាមពលល្អ ។ កាលណាមនុស្សមានចិត្តល្អក្នុងជីវិតនេះ ជីវិតថ្មីទៀតក៏ត្រូវមានចិត្តល្អដូចគ្នានោះទៀត ។ សេចក្តីល្អរបស់មនុស្ស, មិនមែនជាធាតុគ្មានប្រយោជន៍ទេ វាគ្រាន់ តែមានប្រយោជន៍ច្រើនតិចតាមបរិមាណនៃសេចក្តីល្អ និងតាមបរិមាណនៃមនុស្សដែលធ្វើសេចក្តីល្អ ។ ប្រសិនបើ មនុស្សទាំងអស់គ្នាខំឈប់មិនធ្វើទំរើអាក្រក់ដល់គ្នានិងគ្នា ហើយខំប្រឹងធ្វើទំរើល្អដល់គ្នានិងគ្នាទៅវិញ ។ ពិភពមនុស្សយើងមិនត្រឹមតែគ្មានអាវុធចម្បាំងនិងធាតុចម្បាំងប៉ុណ្ណឹងទេ ។ គឺឋានមនុស្សនឹងទៅជាឋានសួគ៌ ជីវិតមនុស្សនឹងទៅជាជីវិតទេព ។ ជាពិសេស គឺសន្តិភាពស្ថាពរ នឹងត្រូវកើតមានដល់ជីវិតមនុស្សសត្វជាពុំខានឡើយ (មើលវិញ្ញាណទស្សនៈប្រកបផង) ។

# បទទី៧
# សេដ្ឋកិច្ចនិងខ្លួនមនុស្ស

«ព្រះពុទ្ធសាសនាថា ជាសាសនាមួយដែលបង្រៀនឲ្យស្រាបញ្ហាសាបសូន្យតម្លៃសីលធំ, តែក៏បានមើលហួស ឬរំលងបញ្ហាសេដ្ឋកិច្ច ។ បង្រៀនឲ្យស្រាយសេចក្ដីអាក្រក់ដោយសេចក្ដីល្អ ។ ព្រមគ្នានេះបង្រៀនឲ្យស្រាយបញ្ហាដែលមានចោទលើខ្លួនឯងជាមុន កុំរស់នៅក្នុងគំនិតឃឹត គំនិតបណ្តែតបណ្តោយ ទុកពេលឲ្យមនុស្សក្នុងពិភពលោក គេធ្វើសេចក្ដីល្អទាំងអស់មុនខ្លួន ហើយខ្លួនសម្រេចចិត្តធ្វើទំរើល្អជាចុងក្រោយបំផុត ។ សូម្បីបង្រៀនឲ្យមានមេត្តចិត្តក៏ឲ្យ ហ្វឹកហាត់ផ្សាយមេត្តាដល់ខ្លួនឯងមុន ដើម្បីបានជាសក្ខីភាពថា អាត្មាអញស្រឡាញ់សុខស្អប់ទុក្ខយ៉ាងណាជនដទៃក៏គេស្រឡាញ់សុខស្អប់ទុក្ខយ៉ាងនោះដែរ» ។

ដើម្បីងាយស្រួលដល់ការពិចារណារបស់អ្នកអានរឿងនេះ, ខ្ញុំសូមញែកសេចក្ដីក្នុងបទនេះចេញជា ៣ ចំណែក គឺ ៖

១- បង្រៀនមិនឲ្យមើលហួស ឬរំលងបញ្ហាសេដ្ឋកិច្ច,

២- ស្រាយចំណងអាក្រក់ដោយចំណងល្អ,

៣-កុំមើលហួស ឬរំលងខ្លួនឯងក្នុងការដោះស្រាយបញ្ហាសីលធម៌ ។

នេះគឺជាគោលការណ៍សំខាន់ក្នុងបទនេះ សម្រាប់ជនអ្នកស្រាយបញ្ហាជីវិត ដែលពុទ្ធសាសនារបស់យើងបានផ្ដល់គំនិតនិងគម្រោងឲ្យបុគ្គលអ្នកមានចិត្តចង់ធ្វើ ចង់អនុវត្តបានជួបប្រទះនូវភាពងាយស្រួល បើមិនច្រើនក៏តិចតាមកម្ពស់និងទំនាបនៃគំនិត នៃឧប្បនិស្ស័យរបស់ខ្លួន នៃមនុស្សម្នាក់ៗ ដែលអ្នកស្រាវជ្រាវផ្នែកនេះមានគំហើញថា ព្រះពុទ្ធបរមគ្រូពិតជាមានព្រះមហាករុណាទិគុណដល់សត្វលោកគ្មានអ្នកណាអាចបដិសេធបានឡើយ ។

## ១-បង្រៀនមិនឲ្យមើលហួសបញ្ហាសេដ្ឋកិច្ច

ក្នុងបញ្ហាទាំងឡាយដែលមានចោទដល់ជីវិតមនុស្ស ។ បញ្ហាសេដ្ឋកិច្ចគឺជាបញ្ហាចោទមុន, ចោទរឿយៗ ចោទខ្លាំងៗ ហើយជាបញ្ហាសំខាន់ជាងបញ្ហាដទៃទៀតផង ។ ព្រោះអ្វី? ព្រោះមនុស្សយើងទាំងអស់គ្នាត្រូវចោទដោយបញ្ហានេះ មិនត្រឹមតែក្នុងពេលសម្រាលចាកផ្ទៃម្ដាយហើយទេ ។ កាលរស់នៅក្នុងពោះម្ដាយក៏ត្រូវចោទដោយបញ្ហានេះដែរ, តែយើងមិនទាន់ចេះដឹង មិនទាន់ចេះដោះស្រាយ, អ្នកមានគុណរបស់យើងលោកដោះស្រាយជំនួស ។ ចំណោទទាំងឡាយមានភាពរស់, ភាពលំបាក, លំនៅដ្ឋាន, ស្បៀងអាហារ, គ្រឿងស្លៀកពាក់, គ្រឿងឱសថ, គ្រឿងឧបករណ៍នៃការងារ, របស់កណ្ដាលគឺមាសប្រាក់ កែវកងសម្រាប់ចាយវាយ សម្រាប់ប្រដាប់តុបតែងខ្លួនប្រាណ សម្រាប់បំពេញ សេចក្ដីត្រូវការបំបាត់កង្វះកំហាត ។ល។

បើអ្នកអានបានមើលតម្រាសេដ្ឋកិច្ចរបស់អ្នកប្រាជ្ញ ផ្នែកសេដ្ឋកិច្ចក្នុងបស្ចិមប្រទេសច្រើនៗ អ្នកអាននឹងមានមនោសញ្ចេតនាត្រូវក្នុងចំណុចមួយថា វត្ថុបំណងរបស់សេដ្ឋកិច្ចនោះបានដល់កំហំបំបាត់ ឬស្នងសេចក្ដីត្រូវការរបស់មនុស្ស (TO TRY TO, SATISFY HUMAN WANTS) ។

ពុទ្ធសាសនាបានស្នើគំនោលសីលធម៌ ដែលជាប់ទាក់ទងដល់គំនោលសេដ្ឋកិច្ចមានពីរស្ថានគឺ : ជាន់ទាបជាគំនោលស្នង (TOSATISFY) ជាន់ខ្ពស់ គឺជាគំនោល (TO SUBDUE) ។ គំនោលស្នងដៅដល់ការបង្រៀនមនុស្សឲ្យគេខំប្រឹងតាំងខ្លួនពង្រឹងជំហរឲ្យមាំមួនរឹងប៉ឹងក្នុងឋានៈសេដ្ឋកិច្ច ព្យាយាមលើកឋានៈរបស់ខ្លួនឲ្យរស់នៅក្នុងកម្រិតខ្ពស់ ប្រកបដោយកំហំនិងសំនួរយ៉ាងមោះមុតជាមួយនិងកម្មវិធីដទៃៗ ទៀត ។ ចំណែកគំនោលបំបាត់នោះ ដៅដល់ការបង្រៀនឲ្យស្គាល់ការកម្ចាត់បង់ ឬបន្ថយសេចក្ដីត្រូវការដែលមានកម្លាំងខ្លាំងក្លាពេក ដែលអាចក្លាយទៅជាតណ្ហាទូលំទូលាយគ្មានកំណត់ព្រំដែន ត្រឡប់ផ្ដល់ឲ្យនូវសេចក្ដីទុក្ខទៅវិញ គឺថាមនុស្សយើងចេះតែពុលចេះតែស្រវឹង

សេចក្តីសប្បាយ ហើយខំស្ទុះស្ទារស្វែងរករបស់ស្នេង, របស់ត្រូវការយកមកបម្រើចំណង់របស់ខ្លួនម្នាក់ៗ ដោយគ្មានខ្វីរវល់ដល់សេចក្តីទុក្ខព្រួយខ្វះខាតរបស់អ្នកដទៃ, គ្មានគំនិតព្រហ្មវិហារ, គ្មានសម្បជញ្ញៈនៃមនុស្សជាតិនោះៗ ចំណង់របស់គេ, វារឹតតែគ្មានចេះចប់, គ្មានចេះល្មមទីបំផុតអ្នកបម្រើសេចក្តីសប្បាយ (តណ្ហា) របស់ខ្លួនវាមិនត្រឹមតែសប្បាយខ្លួនឯង ភ្លេចទុក្ខព្រួយរបស់អ្នកដទៃប៉ុណ្ណឹងទេ គឺវាបញ្ជាឲ្យប្រព្រឹត្តនូវទំរើជិះជាន់បៀតបៀនអ្នកដទៃដើម្បីសេចក្តីសប្បាយរបស់ខ្លួន ។ លោកឲ្យន័យថា តណ្ហាបើគេកាន់តែធ្វើខ្ញុំបម្រើវាកាន់តែច្រើន វាក៏កាន់តែមានកម្លាំងខ្លាំងឡើងៗ ដូចគ្នានឹងភ្លើងបើគេចេះតែបន្ថែមអុស បន្ថែមប្រេងគ្មានឈប់ វាក៏ចេះតែឆេះខ្លាំងឡើងៗ គ្មានពេលរលត់សោះឡើយ ។ ឬពុំនោះសោត, ក៏ដូចគ្នានឹងមហាសមុទ្រដែលគ្មានទឹកពេញប្រៀបឡើងច្រាំងដោយចំណាក់នៃទឹកស្ទឹងទន្លេ ឬចំណាក់នៃទឹកភ្លៀងដែលមានជាប្រក្រតីខួបប្រាំងខួបវស្សា ។ ព្រោះហេតុនេះ, ទើបត្រូវមានគំនោលលុបបំបាត់បន្តិចម្តងៗ ឬបន្ធូរបន្ថយតណ្ហាខ្លះកុំចេះតែបណ្តោយឲ្យទៅៗ គ្មានទំនប់គ្មានកំណត់ព្រំដែន, ដែលអាចដូរសុខទៅជាទុក្ខវិញក្នុងពេលណាមួយមិនខានឡើយ ។

## បង្រៀនអំពីគំនោលសេដ្ឋកិច្ចជាន់ទាប

គំនោល ឬគម្រោងបង្រៀននៃពុទ្ធសាសនា ដែលគេបានឃើញថា មានការទាក់ទងជាមួយនិងសេដ្ឋកិច្ចផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ ឬគ្រួសារជាទូទៅគឺ ៖

**១- ទិដ្ឋធម្មិកត្ថៈ (ប្រយោជន៍បច្ចុប្បន្ន) បានដល់ការបង្រៀនឲ្យតាំងខ្លួននៅក្នុងឋានៈមាំទាំ តាមផ្លូវសេដ្ឋកិច្ច ប្រកបដោយអង្គ ៤ ប្រការគឺ** :

ក/ ការសំភីសង្វាតស្វែងរកទ្រព្យគ្រប់ប្រភេទទាំងមានរូប ទាំងគ្មានរូប . . . . . ,

ខ/ ការចេះស្គាល់របៀបទុកដាក់ទ្រព្យសម្បត្តិ ឬចេះសន្សំ ចេះសំចៃ . . . . . ,

គ/ ការចេះសេពគប់នឹងមិត្តសំឡាញ់មានចរិយាថ្លៃថ្នូរ ឬចេះច្នៃមិត្តអាក្រក់ឲ្យបានជាមិត្តល្អ . . . . . ,

ឃ/ ការចេះចាយវាយឲ្យសមគួរល្មមដល់ឋានៈនៃទ្រព្យសម្បត្តិ ឬចេះរៀនរស់ក្នុងភាពសន្តោស, ឬភាពល្មមគ្រប់គ្រាន់ជានិច្ច . . . . . , ។

**២- ការវៀរចាកអបាយមុខ (ហេតុនាំឲ្យសូន្យទ្រព្យ) ៤ ប្រការគឺ** :

ក/ ជាអ្នកប្រព្រឹត្តល្បែងបុរស ស្ត្រី,

ខ/ ជាអ្នកប្រព្រឹត្តល្បែងផឹកសុរា,

គ/ ជាអ្នកប្រព្រឹត្តល្បែងស៊ីសង,

ឃ/ ជាអ្នកគប់មនុស្សអាក្រក់ ដោយគ្មានកែ គ្មានច្នៃឲ្យល្អសិនជាមិត្ត ។

អ្នកអានគប្បីធ្វើការកត់សម្គាល់ថា អបាយមុខដែលគេគួរវៀរចាកទាំង ៤ ប្រការនេះ លោកសំដៅយកពាក្យលេង ឬមានលក្ខណៈលេងជាធំ គឺអ្នកប្រព្រឹត្តមានគំនិតជាលេង រហូតដល់មានទម្លាប់ប្រកបកម្មនោះរឿយៗជានិច្ច ជាប្រក្រតី លុះត្រាញៀនលែងមិនរួច, ឈប់មិនកើត ។ ក្នុងទីបំផុតត្រូវបានគេឲ្យឈ្មោះថា អ្នកស្ត្រី, នាងប្រុស, អ្នកប្រមឹក, អ្នកបាំងឆ្លិត, អ្នកបួកម៉ាក ។

**៣- សុខរបស់គ្រហស្ថមាន ៤ ប្រការគឺ** :

ក/ សុខកើតអំពីការមានទ្រព្យ (ដោយកម្លាំងធ្វើការរបស់ខ្លួន),

ខ/ សុខកើតអំពីបានចាយវាយទ្រព្យសម្បត្តិផ្ទាល់ខ្លួន,

គ/ សុខកើតអំពីការគ្មានជំពាក់បំណុលគេ,

ឃ/ សុខកើតអំពីការប្រកបអាជីវកម្មដែលគ្មានទោស ។

ក្នុងចំណុចនេះ, បញ្ជាក់ឲ្យឃើញនូវសេចក្ដីសំខាន់នៃធាតុសេដ្ឋកិច្ចត្រង់ថា មានទ្រព្យដោយកម្លាំងខ្លួន, ចាយវាយទ្រព្យសម្បត្តិផ្ទាល់ខ្លួន គ្មានជំពាក់បំណុលគេ ធ្វើការអាជីវកម្មត្រឹមត្រូវតាមក្បួនសេដ្ឋកិច្ច, គ្មានល្មើសច្បាប់រដ្ឋ, គ្មានជិះជាន់កម្លាំងអ្នកដទៃ ។

**៤- ត្រកូលស្ដុកស្ដម្ភមាំមួនមិនតាំងនៅយូរមិនបានព្រោះហេតុ ៤ ប្រការគឺ** :

ក/ របស់ណាបាត់ទៅមិនរកមកវិញ,

ខ/ របស់ណាទ្រុឌទ្រោមដាច់ដាចមិនជួសជុលជាថ្មី,

គ/ គ្មានចេះដឹងស្គាល់ប្រមាណក្នុងការប្រើប្រាស់ទ្រព្យ,

ឃ/ ប្រគល់មុខងារធំដុំក្នុងគ្រួសារឲ្យស្ត្រី ឬបុរសគ្មានសីល គ្មានវិន័យ . . . ទុកដាក់ទ្រព្យ ។

គំនោលនេះបញ្ជាក់ឲ្យឃើញថា ត្រកូលមួយៗ ទោះជាមានស្ដុកស្ដម្ភមាំមួន នៅក្នុងកម្រិតខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ បើខ្វះចំណេះ ខ្វះដំណឹងក្នុងគំនោលនៃសេដ្ឋកិច្ចនិងសីលធម៌ ដែលគេត្រូវស្គាល់, ត្រូវប្រព្រឹត្តប្រតិបត្តិ ឬត្រូវអនុវត្ត ដូចធ្លាប់មានមកក្នុងលោកនេះហើយ ក៏ស្ទុះមិនរួចពីធ្លាក់ចុះដុនដាបក្នុងទីបំផុតឡើយ ។

ខ្ញុំសូមបញ្ជាក់ថា គំនោលនៃប្រយោជន៍ក្នុងបច្ចុប្បន្នរបស់ពុទ្ធសាសនា ទី ១ គឺកំហំក្នុងការប្រកបអាជីវកម្មឲ្យកើត, ឲ្យមានទ្រព្យសម្បត្តិនោះ ត្រូវគ្នានឹងគំនោលសេដ្ឋកិច្ចជាបឋមគឺ PRODUCTION (ផលិតកម្ម) ដូចបានណាត់បាននិយាយគ្នាទុកជាមុនព្រោះវិជ្ជាសេដ្ឋកិច្ចទើបតែនឹងកើតខាងក្រោយពុទ្ធសាសនា តាមស្មានប្រហែលជាងមួយពាន់ឆ្នាំ ។

ចំណែកគំនោលទី ២ គឺការចេះដឹង ស្គាល់របៀបទុកទ្រព្យសម្បត្តិដែលគេរកបានមកហើយ ត្រូវគ្នានឹងគំនោលសន្សំ ឬសំច័យទ្រព្យសម្បត្តិ (SAVING) ។ គំនោលទី ៣ គឺការចេះគប់មិត្ត មានចិត្តស្មោះត្រង់មានសេចក្ដីវៃឆ្លាតមានគំនិតជួយគ្នាទៅវិញទៅមក ។ គំនោលនេះ, ប្រៀបបាននឹងអង្គារសមាគមន៍, ឬបរិស័ទ ឬសហករណ៍ដែលមានការចាំបាច់ ត្រូវជ្រើសរើសបុគ្គលដែលមានឧត្តមគតិខ្ពស់ នៅក្នុងចំណោមបុគ្គលជាសមាជិក ដើម្បីចាត់ការ ឬដឹកនាំសមាគមន៍ . . . . . ក្នុងឋានៈជាក្រុមអភិបាល ឬគណៈកម្មការនាយក នៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ជីវភាពរបស់សមាជិកដោយប្រកាន់យកប្រយោជន៍រួមជាធំ ។ ចំណែកគំនោលចុងក្រោយបង្អស់ គឺការប្រើប្រាស់ចាយវាយទ្រព្យសម្បត្តិ ឲ្យនៅក្នុងកម្រិតសមល្មមគួរដល់ឋានៈរបស់ខ្លួន ឬរស់នៅត្រឹមតែរស់នោះ ក្នុងភាសាសេដ្ឋកិច្ចគេប្រើពាក្យ HOUSE HOLD BUDGET ប្រែថា ថវិការប្រចាំគ្រួសារនេះជាផ្លូវឯកជន ។ បើជាផ្លូវរដ្ឋគេហៅថា THE NATIONS ECONOMIE BUDGET ប្រែថា ថវិការសេដ្ឋកិច្ចនៃជាតិ ។ និយាយខ្លី, បានដល់ការពិនិត្យក្បិតក្បៀតចំណូល ចំណាយឲ្យមានតុល្យភាពស្មើគ្នាត្រូវ នឹងពុទ្ធសាសនាថា សមជីវិតាដែលមានចែងក្នុងទិដ្ឋធម្មិកត្ថៈ (ប្រយោជន៍ បច្ចុប្បន្នហ្នឹងឯង) ។

ចំណែកខាងគំនោលបង្រៀនដទៃៗទៀតដូចជាវៀរចាកភាពខាតបង់ទ្រព្យសម្បត្តិ (អបាយមុខ) គ្រប់ប្រភេទ, ការស្គាល់ថា អ្វីជាសេចក្ដីសុខរបស់គរហស្ថ, ការធ្វើឲ្យត្រកូលមានស្ថេរភាពអស់រយៈកាលយូរអង្វែង ទាំងអស់នេះជាសេដ្ឋកិច្ចមួយទៀត ដែលត្រូវជាគូជាមួយនិងសីលធម៌ ។ ក្នុងចំណុចនេះបញ្ជាក់ឲ្យដឹងថា ពុទ្ធសាសនាបានមើលឃើញយ៉ាងច្បាស់ហើយថា សីលធម៌របស់មនុស្សលំបាកនឹងមានណាស់ប់សេដ្ឋកិច្ចផ្ទាល់ខ្លួននៃមនុស្សម្នាក់ៗពុំមានវឌ្ឍនភាព ឬពុំបានប្រព្រឹត្តទៅក្នុងភាពថ្លៃថ្នូរ ។ ដោយអាស្រ័យហេតុនេះ, ទើបព្រះសម្មាសម្ពុទ្ធបង្រៀនសង្កត់ធ្ងន់ទៅលើសេដ្ឋកិច្ចរដ្ឋនិងសេដ្ឋកិច្ចគ្រួសារ នៅក្នុងក្របខ័ណ្ឌសាងជំហរ គឺធ្វើយ៉ាងណាឲ្យរដ្ឋនិងឯកជនមានសេដ្ឋកិច្ចស្ថិត នៅក្នុងកម្រិតខ្ពស់ ឬមធ្យម តាមដែលអាចធ្វើទៅកើត ។

ដើម្បីឆាប់យល់, អ្នកអានគប្បីពិនិត្យមើលឡើងវិញនូវរឿងមួយ មានមកក្នុងគម្ពីរពុទ្ធសាសនារបស់យើង

ដែលមានដំណាលថា ថ្ងៃមួយព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានណែនាំកូដទន្តព្រាហ្មណ៍ដែលគាត់បានធ្វើសំណួរចំពោះព្រះអង្គអំពីបញ្ហាបូជាយញ្ញ, ព្រះសម្មាសម្ពុទ្ធពុំបានឲ្យចម្លើយចំណុចនៃបញ្ហានេះទេ, តែព្រះអង្គបានឆ្លៀតឱកាសបំភ្លឺព្រាហ្មណ៍នោះក្បែរៗសំណួររបស់គាត់ថា, ខ្លួនអ្នកជាបុគ្គលមានមុខងារគ្រប់គ្រងរក្សាពួកព្រាហ្មណ៍ ក្នុងស្រុកមានភូមិមានសង្កាត់ច្រើន ។ អ្នកជាមនុស្សម្នាក់ដែលព្រាហ្មណ៍ទាំងអស់ទទួលស្គាល់, ទទួលស្គាល់ឱវាទដំបូន្មាន ។ អ្នកត្រូវចាត់សេដ្ឋកិច្ចក្នុងស្រុកនេះឲ្យបានត្រឹមត្រូវ, មានវឌ្ឍនភាពខ្ពស់មានស្ថេរភាពនឹងន នៅក្នុងកម្រិតល្អប្រសើរមុនដែលខ្លួនអ្នកនឹងត្រូវធ្វើអ្វីៗទៀត ។ ម្នាលព្រាហ្មណ៍! កម្មវិធីបំរាបចោរកម្ម គេមិនត្រូវធ្វើដោយដាក់ទណ្ឌកម្មណាៗរហូតដល់កាប់សម្លាប់ទេ ព្រោះទំរើអស់ទាំងនេះ, វាគ្មានប្រសិទ្ធិភាព គឺវាមិនអស់មនុស្សប្រព្រឹត្តទំរើចោរកម្មទេ ។ ព្រោះអ្វី? ព្រោះមានរូបមនុស្សទុច្ចរិតផ្សេងទៀតមកជំនួស, មកប្រព្រឹត្តទំរើចោរកម្មជាថ្មីទៀត ។ តែបើគេបានចាត់ការសេដ្ឋកិច្ចល្អ, ឲ្យមនុស្សមានការងារតាមគួរដល់សមត្ថភាព, ដល់សេចក្ដីចេះដឹងរបស់គេ ។ ជាមួយគ្នានេះ គេត្រូវមានផែនការណ៍ជួយទំនុកបម្រុងកសិករ, ពាណិជ្ជករ, ភ្នាក់ងាររដ្ឋការឲ្យរស់នៅក្នុងករណីយ៍ ក្នុងអាជីវកម្ម របស់ខ្លួនឲ្យបានស្រួលនោះ ស្រុកប្រទេសរបស់អ្នកនឹងបានឋិតនៅក្នុងភាពសុខសាន្តចម្រុងចម្រើនជាមិនខានឡើយ ។

ដោយអាស្រ័យល័ខហ៊ាន, ដែលព្រះសម្មាសម្ពុទ្ធបានបង្ហាត់បង្រៀនទាក់ទងដល់សេដ្ឋកិច្ច និងសីលធម៌ដូចបានពោលមកនេះ ។ យើងអាចឆ្លើយបញ្ហាដែលចោទថា ព្រះពុទ្ធសាសនាបង្រៀនមនុស្សឲ្យខ្ជិល, ឲ្យរស់នៅដោយអាស្រ័យជំនួយទេវត, ឲ្យដេកផ្សងព្រេង ។ល។ ដែលពុទ្ធសាសនាគ្មានបានបង្រៀនយ៉ាងនេះ សូម្បីត្រឹមតែមួយម៉ាត់ក៏គ្មានផង ។ ក្រៃលែងជាងនេះទៀត, ក្នុងករណីខ្លះព្រះពុទ្ធបរមគ្រូ ព្រះអង្គបានសម្ដែងអំពីធម្មសម្បត្តិ ក្នុងការប្រកបអាជីវកម្មប្រភេទខ្លះ ដូចការលក់ដូរដោយបានបញ្ជាក់យ៉ាងច្បាស់លាស់ថា អ្នកលក់ដូរប្រសិនបើខ្លួនគេបានប្រកបដោយធម្មសម្បត្តិ ៣ ប្រការ គេមុខជានឹងមានកម្រៃយ៉ាងខ្ពស់ជាមិនខាន ។ ធម្មសម្បត្តិ ៣ គឺះ

១/ គេជាបុគ្គលមានភ្នែកល្អ ឬភ្នែកភ្លឺ ដោយយកសេចក្ដីចេះដឹងប៉ិនប្រសប់ក្នុងមុខរបរជំនួញ, ស្គាល់ដើមទុន, ស្គាល់កម្រៃ ។ ជាពិសេសចេះក្បួនសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ។

២/ គេជាបុគ្គលមានសេចក្ដីព្យាយាមយ៉ាងមោះមុត ដោយកកំហំយ៉ាងទូលំទូលាយ ចេះស្ទង់, ចេះពិចារណា, ចេះពិនិត្យកាលៈទេសៈ ។ មានគំនិតបច្ចេកទេស មានសេចក្ដីវៃឆ្លាតក្រៅតម្រា ដឹងកិច្ច, ដឹងកលដូចជាដឹងថាទៅទិញរបស់នៅកន្លែងណាមានតម្លៃថោក, យកទៅលក់ផ្សារណាមានតម្លៃខ្ពស់ ។ ជាពិសេសបើបានចំណេញច្រើន គេមិនភ្លេចស្មារតីខាតទុន គេមិនសុខចិត្តលះបង់ចោល ឬរាងចាល ។

៣/ គេជាបុគ្គលមានមនុស្សនិយមរាប់អានច្រើន សូម្បីមិត្តសំឡាញ់, ស្គាល់របៀបធ្វើខ្លួនឲ្យមនុស្សគ្រប់មជ្ឈដ្ឋានទូទៅបាក់ចិត្តនិយម, មានជំនឿ, មានសេចក្ដីទុកចិត្តទុកថ្លើម រហូតដល់ស៊ូខាតស៊ូចំណេញជាមួយគ្នាផងទៀត ។

## គំនោលសេដ្ឋកិច្ចជាន់ខ្ពស់

កាលបើនិយាយដល់គោលគំនិតរបស់ពុទ្ធសាសនា, ដែលបង្រៀនឲ្យមនុស្សយកចិត្តទុកដាក់ធ្វើខ្លួន ឲ្យមានវឌ្ឍនភាពក្នុងផ្លូវសេដ្ឋកិច្ចថ្នាក់ទាប, ដែលជាបុព្វហេតុសម្រាប់ធ្វើឲ្យងាយស្រួលដល់ការប្រតិបត្តិតាមសីលធម៌ក៏គួរនិយាយដល់គំនោលសេដ្ឋកិច្ចជាន់ខ្ពស់ ដែលលោកឲ្យឈ្មោះមួយបែបទៀតថា កម្ពស់ចិត្តក្នុងទីនេះផងព្រោះពុទ្ធសាសនាមិនមែនមានបំណងត្រឹមតែដឹកនាំជីវិតមនុស្ស ឲ្យរស់នៅប្រកបដោយវឌ្ឍនភាពក្នុងលោកនេះនិងលោកដទៃទៀតប៉ុណ្ណឹងទេ, គឺត្រូវការឲ្យមនុស្សធ្វើជាម្ចាស់នៃតណ្ហាទៅទៀត ។ ក្នុងន័យថា, ដំបូងមនុស្សត្រូវខំប្រឹងធ្វើការសេដ្ឋកិច្ចគ្រប់យ៉ាង ឲ្យមានវឌ្ឍនភាពនៅក្នុងកម្រិតមធ្យមរហូតដល់កម្រិតខ្ពស់ ដើម្បីផ្ដល់សេចក្ដីសុខស្រួលដល់ជីវិតរបស់ខ្លួន ។ តែវឌ្ឍនភាពនៃជីវិតខាងសម្ភារៈវាមិនមែនជាធាតុមានកម្ពស់ដល់ថ្នាក់បំផុតទេ ។ ព្រោះអ្វី?

ព្រោះចិត្តរបស់មនុស្សយើង វាជាធាតុមួយដែលគេមិនអាចបំបាត់ ឬបំពេញសេចក្តីត្រូវការរបស់វាបានទេ ។ គឺវាចេះតែចង់កើត, ចង់បានចង់មានគ្មានចប់ គ្មានអស់ហើយឡើយ តួយ៉ាងដំបូងវាចង់បាននាលិកា, យើងរកនាឡិកាឲ្យវាបានឈ្មោះថា យើងបានបំបាត់ចំណង់ ឬសេចក្តីត្រូវការរបស់វាបានមួយហើយ ។ តែកង្វះរបស់វានៅតែមានតទៅទៀត បើមិននាឡិកាដដែលក៏អ្វីផ្សេងៗដទៃៗទៀតគ្មានចេះគ្រប់គ្រាន់ឡើយ ។ តើមានបុគ្គលណាម្នាក់អាចបំពេញកង្វះនេះបាន ឬទេ? ចម្លើយគ្មាន ! នេះហើយដែលព្រះសម្មាសម្ពុទ្ធបានមានព្រះពំនោថា សត្វលោកមានកង្វះជានិច្ច, មានមិនឆ្អែត, មិនស្កប់ស្កល់ជាប្រក្រតី, ជាមួយគ្នានេះសត្វលោកជាទាសៈនៃកង្វះ, នៃចំណង់, នៃសេចក្តីត្រូវការរបស់ខ្លួន (**ឩនោ លោកោ អតិតោ តណ្ហា ទាសោ**) ។ ពុទ្ធសាសនិកម្នាក់ៗត្រូវតែដឹងថា របស់ណាខ្លះដែលចាំបាច់ត្រូវមាន, របស់ណាខ្លះដែលមិនចាំបាច់ត្រូវមាន និងរបស់ណាខ្លះទៀតដែលមានហើយ វាមានពលានុភាពដុតចិត្តវិញ្ញាណយើងឲ្យ ក្តៅក្រហាយរោលរាលប្រាណចាកសេចក្តីសុខស្ងប់, ប្រាសចាកគំនិត សន្តិ ។

ប្រសិនបើយើង, នាំគ្នាពិនិត្យមើលកម្មវិធីបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធក្នុងចំណុចនេះ យើងនឹងមានក្តីអស្ចារ្យស្ញើចក្នុងចិត្តចំពោះចំណាត់ការមួយអន្លើ និងបញ្ហាសេដ្ឋកិច្ចជាន់ខ្ពស់ ដែលព្រះអង្គបានធ្វើដោយសេចក្តីឆ្លៀវឆ្លាតញឹកល្អិត សឹងគ្មានបុគ្គលណាអាចមានសមត្ថភាពធ្វើតាមបាន ។

ការប្រតិស្ឋានពុទ្ធសាសនាក្នុងលោក ជាទំរើធំក្រៃលែង បើប្រៀបធៀបទៅនឹងចំណាត់ការផ្សេងៗក្នុងលោកយើងអាចឃើញបានថា រហូតមកដល់ពេលនេះ ពុទ្ធសាសនាមានអាយុ២៥១៦ឆ្នាំហើយ, គង់ស្ថិតនៅក្នុងភាពមាំមួន, មានរបៀបបែបផែននៅក្នុងក្របខ័ណ្ឌនឹងនរឹងប៉ឹងដដែល ។ ចំណែកអង្គការទូទៅនៃពិភពលោកគេគ្មានឃើញអង្គការណាមួយស្ថិតនៅក្នុងភាពមាំមួនរឹងប៉ឹងដដែលដោយគ្មានកំណែ, គ្មានចំណាត់ជាថ្មីឡើយ ។

វិធានការខាងផ្លូវលោកមួយណាក៏ដូចជាមួយណា, សុទ្ធតែចោទឡើងដោយបញ្ហាលុយកាក់ដូចៗគ្នា ។ ចំណោទនេះវាបានក្លាយទៅជាផ្នត់គំនិត លុះត្រាមនុស្សខ្លះលាន់មាត់ថា បញ្ហាធំបំផុតនៃជីវិតមនុស្សគឺលុយកាក់ ។ បញ្ហាសំខាន់ៗក្នុងមុខការធំៗ ត្រូវអាស្រ័យពឹងផ្អែកលើលុយកាក់ទាំងអស់, គ្មានលុយកាក់ធ្វើមិនចេញទេ ។ ប្រសិនបើចែកអង្គការជា៣ គេនឹងឃើថា ក្នុងអង្គការមួយៗគ្មានចំណុចត្រង់ណាដែលគ្មានទាក់ទងដល់លុយកាក់ឡើយគឺ ១-លុយ, ២-លុយ, ៣-លុយ អញ្ជឹងតែម្តង ។

ព្រះសម្មាសម្ពុទ្ធរបស់យើងព្រះអង្គឃើញថា គំរោងការរបស់មនុស្សលោក ត្រូវការយកប្រាក់ជាសរណៈជាទីពឹង ជាធាតុចាំបាច់របស់គេដូចនេះហើយ ទើបព្រះអង្គចាត់វិធានការសេដ្ឋកិច្ចជាន់ខ្ពស់របស់ព្រះអង្គ ផ្ទុយពីគេវិញម្តង គឺក្នុងន័យនេះហើយដែលអ្នកស្រាវជ្រាវជាទូទៅមានគំហើញស្របគ្នាថា វិធានការឬគំរោងសេដ្ឋកិច្ចរបស់ពុទ្ធសាសនាថ្នាក់ទាបនិងថ្នាក់កណ្តាល មានលក្ខណៈត្រូវគ្នានឹងគំរោងការសេដ្ឋកិច្ចរបស់អ្នកសេដ្ឋសាស្ត្រក្នុងពិភពលោក ។ តែគំរោងការសេដ្ឋកិច្ចជាន់ខ្ពស់របស់ពុទ្ធសាសនា មានលក្ខណៈនិងកម្រិតនៃគុណភាពខ្ពស់ជាងសេដ្ឋកិច្ចនៃអ្នកសេដ្ឋសាស្ត្រទូទៅ ។ ព្រោះអ្វី? ព្រោះសាសនាគ្មានប្រើប្រាក់ដូចគេ, ហើយអ្នកអនុវត្តនៅតែមានជីវិតប្រព្រឹត្តទៅបានដដែល ។

ក្នុងវិន័យ, ព្រះសម្ពុទ្ធបានបញ្ញត្តិសិក្ខាបទហាមភិក្ខុចាប់កាន់ ឬទទួលមាសប្រាក់ ។ ជាមួយគ្នានេះ តម្រូវឲ្យមានអាបត្តិដល់ភិក្ខុដែលបានប្រព្រឹត្តល្មើស ។ នេះគឺជាទំរើមួយដែលពុទ្ធសាសនាបានបង្ហាញឲ្យពិភពលោកឃើញថាមិនប្រើមាសប្រាក់ក៏អាចធ្វើការធំៗ បានសម្រេចផលពិតៗ ដូចអ្នកប្រើប្រាក់ដែរ ។

គំនោលការដែលហៅថា សេដ្ឋកិច្ចជាន់ខ្ពស់ ឬជាន់លើបំផុតរបស់ព្រះសម្មាសម្ពុទ្ធ គឺខំប្រឹងធ្វើខ្លួនឲ្យជាម្ចាស់នៃតណ្ហា ឬរស់នៅពីលើតណ្ហា នៅក្នុងគំនិតសិក្សាថា អ្វីខ្លះ មានប៉ុន្មាន ជារបស់ចាំបាច់ដល់ការរស់នៅ ។ អ្វីខ្លះមានប៉ុន្មាន ដែលធ្វើឲ្យជីវិតហ៊ឺហា, លុះក្លាយខ្លួនជាទាសភាពនៃតណ្ហា ។

ព្រះបរមគ្រូយើង បានអនុញ្ញាតរបស់ចាំបាច់សម្រាប់ភិក្ខុរសមាន ៤ ប្រការ ដែលយើងស្គាល់គ្រប់គ្នាថា បច្ច័យ ៤ ដែលត្រូវនឹងពាក្យអង់គ្លេសថា FOUR REQUISTES គឺសំពត់ស្លៀកដណ្តប់ (ចីវរ) អាហារចិញ្ចឹម (បិណ្ឌបាត្រ) ទីស្នាក់អាស្រ័យ (សេនាសនៈ) និងឱសថសម្រាប់ព្យាបាលជំងឺ (គិលានភេសជ្ជ) ។ គ្រឿងសម្រាប់រស់ទាំង ៤ ប្រការ នេះ, ព្រះអង្គបញ្ជាឲ្យភិក្ខុជាឧបជ្ឈាយ៍ ឬឧបសម្បទាចារ្យ . . . សូត្រប្រកាសប្រាប់ភិក្ខុដែលទើបនឹងបួសថ្មីឲ្យបានដឹងភ្លាមៗ ដើម្បីខំរស់, ខំអនុវត្តសេដ្ឋកិច្ចនេះតាមពុទ្ធានុញ្ញាត ។ ភិក្ខុគ្មានសំពត់ល្អប្រើអនុញ្ញាតរើសកំណាតសំពត់ដែលគេចោលទីនេះបន្តិច ទីនោះបន្តិច យកមកប៉ះប៉ុនដេរភ្ជាប់ជាចីវរសម្រាប់ប្រើប្រាស់ ។ គ្មានអាហារល្អបរិភោគ, ឲ្យអាស្រ័យអាហារបិណ្ឌបាត្រតាមតែគេឲ្យតិចក្តី ច្រើនក្តី ឆ្ងាញ់ក្តី មិនឆ្ងាញ់ក្តីទៅតាមរឿង ។ គ្មានលំនៅដ្ឋានល្អនៅ, ឲ្យយកដើមឈើជាទីនៅអាស្រ័យ ។ គ្មានឱសថប្រកបដោយគុណភាពព្យាបាលជំងឺឲ្យត្រងទឹកមូត្រ ឲ្យស្អាតប្រើជំនួស, លុះត្រាតែកើត ។

ក្រៅពីនេះទៀត, នៅមានបញ្ញត្តិជាច្រើនប្រការ ដែលអ្នកអានគួរដឹងជាមួយគ្នានេះដែរ ដូចជាហាមមិនឲ្យប្រើគ្រឿងប្រដាប់ ដែលគេធ្វើដោយមាសប្រាក់ ឬអ្វីទៅទៀតដែលមានភាពប្រហាក់ប្រហែលនឹងមាសប្រាក់ ឬរបស់ដែលគេសង្គ្រោះចូលក្នុងមាសប្រាក់ ឬរបស់ដែលមានតម្លៃខ្ពស់ជាងមាសប្រាក់ ហើយជារបស់សម្រាប់តុបតែងខ្លួនប្រាណ ។ ហាមមិនឲ្យសុំរបស់ពីជនណា ដែលគេគ្មានបានបវារណា ឬអនុញ្ញាតទុកជាមុន ។ បើគ្មានការចាំបាច់ជាពិសេស, ហាមមិនឲ្យប្រមូលសន្សំរបស់ស្តុកទុកដើម្បីអួតមាន, អួតសម្បូរ ។ តឹងរឹងជាងនេះទៀតជាពីរដង ឬច្រើនជាងនេះក្នុងថ្ងៃខាងមុខ ។

គោលការធំៗ ដែលព្រះសម្មាសម្ពុទ្ធបានចាត់, បានធ្វើសេចក្តីបំភ្លឺមានដូចនេះ ៖

១- ចំណង់គ្មានព្រំដែន ជាហេតុឲ្យកើតទុក្ខ, រំលត់ចំណង់គ្មានព្រំដែនបាន ដោយគ្មានសេសសល់, សេចក្តីទុក្ខ ត្រូវបានរលត់ភ្លាម គ្មានចាំបាច់សុំសេចក្តីប្រោសប្រាណពីអាទិទេពណាឡើយ ។

២- ភិក្ខុទាំងឡាយណា, ពុំបានធ្លាក់ខ្លួនជាទាសភាពរបស់តណ្ហា ដែលជាធាតុមានកម្លាំងប្រអូសប្រទាញតាមច្បាប់ធម្មជាតិ ភិក្ខុទាំងឡាយនោះឈ្មោះថា មានវឌ្ឍនភាពខាងផ្លូវចិត្ត ដែលជាគុណធម៌មានតម្លៃកម្រនឹងមានដល់មនុស្សជាតិក្នុងសកលលោក ។

គំនោលរបស់ខ្ញុំក្នុងខាងដើមថា គំនោលសេដ្ឋកិច្ចគឺ ការស្វែងសេចក្តីត្រូវការរបស់មនុស្ស ។ តែគនោលសេដ្ឋកិច្ចជាន់ខ្ពស់របស់ពុទ្ធសាសនា, មិនមែនជាការស្វែងសេចក្តីត្រូវការទេ គឺជាការបញ្ឈប់នូវសេចក្តីត្រូវការដែលមិនចាំបាច់ ។ ទន្ទឹមគ្នានេះ, ខំប្រឹងធ្វើខ្លួនឲ្យបានជាថៅហ្វាយនាយលើសេចក្តីត្រូវការនោះ ។ លុះត្រាតែបានបើមិនបាន, កុំឈប់, កុំថយឲ្យសោះ ប្រសិនបើចង់កម្ទេចសេចក្តីទុក្ខឲ្យអស់, ព្រោះគ្មានទំរើណាដទៃទៀតក្រៅអំពីទំរើនេះទេក្នុងរឿងរំលត់រំលាយទុក្ខ ដែលយើងកំពុងជួបប្រទះក្នុងជីវិតសព្វថ្ងៃនេះ ។ នេះជាសេដ្ឋកិច្ចជាន់ខ្ពស់ ឬជាន់លើសម្រាប់ភិក្ខុ ឬគ្រហស្ថដែលមានកម្ពស់ចិត្តខ្លាំងក្លាមានកម្រិតអរិយសច្ចៈ ដែលពុទ្ធសាសនារបស់យើងឲ្យឈ្មោះថា «បរមត្ថប្រយោជន៍» ។ ប្រសិនបើនិយាយពីសេដ្ឋកិច្ចនៃពុទ្ធសាសនាតាមលំដាប់លេខរៀងនឹងមានដូចនេះគឺ :

១- ទិដ្ឋធម្មិកត្ថប្រយោជន៍, សេដ្ឋកិច្ចសម្រាប់ជីវិតបច្ចុប្បន្ន ។

២- សម្បរាយិកត្ថប្រយោជន៍, សេដ្ឋកិច្ចសម្រាប់ជីវិតថ្មី ។

៣- បរមត្ថប្រយោជន៍, សេដ្ឋកិច្ចសម្រាប់ជីវិតបាននិព្វាន ។

អ្នកអានគប្បីដឹងថា សេដ្ឋកិច្ចទាំង ៣ ប្រភេទនេះ បើស្តីអំពីលំដាប់ដែលគេត្រូវធ្វើ, ត្រូវប្រកបណាមុនណាបន្ទាប់ ណាក្រោយធាតុនេះមានខ្ទង់លេខដូចសរសេរមកហើយនេះ ។ តែបើស្តីអំពីគុណភាព, ពុទ្ធសាសនា

យើងពុំបានទុកដាក់ឲ្យមានកម្ពស់ទំនាបជាងគ្នាទេ ។ ពំនោលថា ទិដ្ឋធម្មិកត្ថប្រយោជន៍ទាប, សម្បរាយិកត្ថប្រយោជន៍កណ្ដាល, បរមត្ថប្រយោជន៍ខ្ពស់នោះ វាមានលក្ខណៈត្រឹមតែស្រួលបង្រៀន, ស្រួលពន្យល់, ស្រួលទេសន៍ប៉ុណ្ណោះ ។ ដោយអាស្រ័យគំនិតនិងសំនេរក្នុងខាងដើមរបស់ខ្ញុំក៏បានដាក់ថា បច្ចុប្បន្នទាប, បរលោកថ្នាក់កណ្ដាល, និងនិព្វានថ្នាក់ខ្ពស់អ៊ីចឹងដែរ ។ រីឯសេចក្ដីពិតក្នុងរឿងនេះវិញ, គឺជីវិតបច្ចុប្បន្នក៏ជា ធាតុមានថ្នាក់ទាបកណ្ដាលខ្ពស់, បរលោកក៏មានថ្នាក់ទាបកណ្ដាលខ្ពស់ និព្វានក៏មានថ្នាក់ទាបកណ្ដាលខ្ពស់ដូចៗ គ្នា ក្នុងបច្ចុប្បន្នសេដ្ឋកិច្ចទាប, ជីវភាពមនុស្សទាប, សេដ្ឋកិច្ចមធ្យម ជីវភាពមនុស្សកណ្ដាល, សេដ្ឋកិច្ចខ្ពស់ ជីវភាពមនុស្សខ្ពស់ ។ ក្នុងបរលោកក៏មានសេដ្ឋកិច្ចទាបកណ្ដាលខ្ពស់ ដូចបច្ចុប្បន្នដែរ ។ ចំណែកសេដ្ឋកិច្ចនិព្វាន សោតាបន្នបុគ្គលនិងសកទាគាមីបុគ្គលថ្នាក់ទាប, អនាគាមីបុគ្គលថ្នាក់កណ្ដាល, អរហត្តបុគ្គលថ្នាក់ខ្ពស់ ។ បើយោលទៅតាមរឿងជាតកនៃព្រះពោធិសត្វ គឺព្រះពុទ្ធបរមគ្រូរបស់យើងកាលមិនទាន់បានត្រាស់ ព្រះអង្គខំប្រឹង តស៊ូយ៉ាងប្តូរផ្តាច់ប្រកបអាជីវកម្មគ្រប់យ៉ាង នៅក្នុងក្របខ័ណ្ឌនៃសេដ្ឋកិច្ចរបស់គ្រួសារនិងសង្គមប្រជាជាតិ គឺធ្វើឲ្យកម្រិតជីវភាពទាំងបច្ចុប្បន្ន ទាំងបរលោកស្ថិតនៅក្នុងថ្នាក់ខ្ពស់បំផុតដើម្បីជាស្ពានចម្លងអាត្មានៃព្រះអង្គ ឲ្យបានដល់ សេដ្ឋកិច្ចចុងក្រោយបង្អស់ គឺនិព្វានហ្នឹងឯង ។ ដូចនេះព្រោះអ្វី? ព្រោះប្រយោជន៍បច្ចុប្បន្ន (ឧដ្ឋាន, អារក្ខៈ, កល្យាណមិត្តតា, សមជីវិតា) ត្រូវបានជាស្ពាននៃប្រយោជន៍បរលោក (សទ្ធា, សីលៈ, ចាគៈ, បញ្ញា) បរមត្ថ ប្រយោជន៍ (ទុក្ខៈ, សមុទយៈ, មគ្គ) កើតមានបានដោយអាស្រ័យស្ពាន គឺប្រយោជន៍បរលោកជាបន្តបន្ទាប់គ្នា ។ ដូចនេះកម្រិតមួយៗត្រូវធ្វើសេដ្ឋកិច្ច គឺខំប្រកបអាជីវកម្មរាល់ប្រភេទដើម្បីរស់ នៅខ្ពង់ខ្ពស់ក្នុងលោកនេះផង, ខំធ្វើបុណ្យទានដើម្បីរស់នៅថ្លៃថ្នូរក្នុងលោកខាងមុខផង, ខំចម្រើនអរិយសច្ចធម៌ ដើម្បីសម្រេចមគ្គផលនិព្វានក្នុង ជីវិតចុងក្រោយបង្អស់ផង ។

ដើម្បីឲ្យពុទ្ធសាសនិក បានស្គាល់សេដ្ឋកិច្ច មានគុណភាពខ្ពង់ខ្ពស់បណ្ដើរៗ នៅក្នុងក្របខ័ណ្ឌមួយថ្មីទៀត ។ ព្រះពុទ្ធសាសនានៅបានស្នើអរិយទ្រព្យ ៧ ប្រការ ដែលគេធ្លាប់ស្គាល់គ្រប់គ្នាមកហើយថា ទ្រព្យនេះមានតម្លៃខ្ពស់ជាង ទ្រព្យធម្មតា ដែលមនុស្សយើងធ្លាប់មាន ធ្លាប់បានប្រើប្រាស់មកហើយ មានដូចនេះគឺ :

១- សទ្ធា,

២- សីល,

៣- ហិរិ,

៤- ឱត្តប្បៈ,

៥- ពហុសច្ចៈ,

៦- ចាគៈ,

៧- បញ្ញា ។

ពុទ្ធសាសនាមានយោបល់ថា បើជនណាមានទ្រព្យខាងក្នុង ឬទ្រព្យប្រសើរដែលហៅថា «អរិយទ្រព្យ» នេះហើយ, ទ្រព្យសម្បត្តិខាងក្រៅនឹងកើតមានដល់គេ ដោយស្វ័យប្រវត្តិ ក្នុងពេលណាមួយមិនខានឡើយ ។ ផ្ទុយទៅវិញ, ជនដែលមានទ្រព្យសម្បត្តិខាងក្រៅ, តែខ្លួនពុំបានរស់នៅក្នុងសីលធម៌ ឬគ្មានអរិយទ្រព្យខាងក្នុង ៧ ប្រការជួយគ្រទ្រផងទេ ។ លោកថា ទ្រព្យសម្បត្តិខាងក្រៅនោះ មុខជាពុំអាចស្ថិតស្ថេរបានយូរ ឬបានរហូតតាមចំណង់ របស់ខ្លួនឡើយ ។

## ២-កំណែភាពអាក្រក់ដោយភាពល្អ

ក្នុងចំណុចទី ២, ដែលពុទ្ធសាសនាបង្រៀន ឲ្យធ្វើកំណែភាពអាក្រក់ដោយភាពល្អនោះ មានបញ្ហាសំខាន់

ដែលយើងត្រូវធ្វើការពិចារណាបកស្រាយមិនតិចឡើយ ។ តែមុននឹងពិចារណាឲ្យល្អិតល្អន់តាមរបាយការណ៍ដទៃៗ យើងគួរធ្វើសេចក្តីសង្កេតដល់គំនោលធំៗនៃពាក្យបង្រៀនអស់ទាំងនេះជាមុនសិន :

១- គប្បីយកឈ្នះកំរោធដោយគ្មានកំរោធ, គប្បីឈ្នះមនុស្សមិនល្អ ដោយសេចក្តីល្អ, គប្បីយកឈ្នះមនុស្សកំណាញ់ ដោយអំណោយ, គប្បីយកឈ្នះមនុស្សពោលពាក្យឡេះឡោះ ដោយពោលពាក្យស័ត្យទៀងត្រង់ ។

២- គ្រប់ទី គ្រប់កន្លែងពៀរគ្មានរម្ងាប់ ដោយចំណងឡើយ, ពៀររមែងរម្ងាប់ ដោយគ្មានចំណង ធម៌នេះគឺជាធម៌ មានមកតាំងតែពីបរមបុរាណ ។

៣- ភាពអាក្រក់ដែលបានធ្វើមកហើយ អ្នកណាខំប្រឹងបិទចោលដោយទំរើល្អរបស់ខ្លួន (គឺឈប់ធ្វើទំរើអាក្រក់តទៅទៀត ធ្វើទំរើល្អជំនួសវិញ) អ្នកនោះឈ្មោះថា បានធ្វើលោកនេះឲ្យមានពន្លឺភ្លឺស្វាង ដូចគ្នានឹងដួងចន្ទដែលបាន ចាកផុតដុំពពកដូច្នោះដែរ ។

ដែលឲ្យធ្វើកំណែភាពអាក្រក់ ដោយភាពល្អ, ព្រោះពុទ្ធសាសនាមានគំនិតថា បើយកធាតុអាក្រក់មកកែធាតុអាក្រក់ លទ្ធផលគឺវារឹតតែអាក្រក់ឡើង ។ សេចក្តីប្រៀបធៀប : ដូចគេយកទឹកសម្អុយទៅលាងរបសកខ្វក់ ឬដូចគេយកទឹកលាងកន្តោរទៅគក់បោកខោអាវ លទ្ធផលគឺគគ្រិចប្រើលែងកើត ។

កំណែរបៀបនេះនៃពុទ្ធសាសនារបស់យើង កាលបើយើងគិតត្រឹមតែផ្លូវចាញ់ ឃើញថា តំណាញ់បានមកពុទ្ធសាសនិក ជំនះបានទៅជនពាល ។ ឬបើយើងឈ្នះទំរើអាក្រក់របស់ជនពាល ដោយទំរើល្អរបស់យើងពិតៗវិញ ក៏គង់តែជំនះរបស់យើងមិនមែនជាខ្លាំងក្លារឹងប៉ឹងទេ គឺជាជំនះមានភាពទន់ខ្សោយ ជិតតែនឹងដល់លេខសូន្យហ្នឹងតែម្តងប្រសិនបើយើងគិតគួរខ្លីៗ ។ តែបើយើងរើសើគន់គិតឲ្យវែង ចាប់តាំងពីបិណ្ឌមួយនៃពុទ្ធភាសិត ក្នុងគំនោលធំៗ ឬមេៗ ដូចជាកុំធ្វើទំរើអាក្រក់, ធ្វើតែទំរើល្អ, និងខិតខំជុសខាត់ជម្រះចិត្តឲ្យបរិសុទ្ធ ។ យើងអាចបកប្រែបានថា ទំរើអាក្រក់ដើម្បីអាក្រក់ ទំរើល្អដើម្បីល្អ សម្អាតដើម្បីសម្អាត ឬមួយទំរើអាក្រក់ដើម្បីល្អ សម្អាតដើម្បីសម្អុយ ។ អាក្រក់ដើម្បីអាក្រក់ ដូចវាយគេឲ្យស្លាប់ដើម្បីយកទ្រព្យសម្បត្តិប្រពន្ធកូនគេ ។ល។ ល្អដើម្បីល្អ ដូចធ្វើបុណ្យដើម្បីបុណ្យ មិនមែនដើម្បីកេរ្តិ៍ឈ្មោះយសស័ក្តិទ្រព្យសម្បត្តិ ។ល។ ស្អាតដើម្បីស្អាត ដូចចម្រើនធម៌ដើម្បីមគ្គផលនិព្វាន មិនមែន ដើម្បីអំនួត ឬបំភាន់គំនិតអ្នកដទៃដើម្បីលាភសក្ការៈ អាក្រក់ដើម្បីល្អ ដូចវាយកូនដើម្បីវឌ្ឍនភាព មិនមែនដើម្បីពន្លិច ។ល។ ល្អដើម្បីអាក្រក់ ដូចចិញ្ចឹមមនុស្សមានគំនិតដើម្បីបម្រើ មិនមែននៅក្នុងគំនិតព្រហ្មវិហារដើម្បីស្រង់គ្នាឲ្យអស់សេចក្តីទុក្ខលំបាក ។ល។ សម្អាតដើម្បីសម្អុយ, គឺចម្រើនកម្មដ្ឋានដើម្បីអំនួត មិនមែនដើម្បីពន្លឺ ឬភាពបរិសុទ្ធភាពស្ងប់ និងត្រជាក់ត្រជុំនៃចិត្តវិញ្ញាណ ។ ដូចនេះ, ឃើញថាគំនិតពុទ្ធសាសនាក្នុងរឿងនេះ ជាគំនិតដាច់ខាត គំនិតមានភាព ប្រាកដនិយម គំនិតព្រហ្មវិហារ ។ល។ ក្នុងន័យថា : មិនធ្វើទំរើអាក្រក់លើមនុស្សសត្វណាដើម្បីឆ្លើយតបនឹងទំរើអាក្រក់របស់គេ, តែបើទំរើអាក្រក់នោះ អាចកែមនុស្សអាក្រក់ឲ្យល្អបានក៏ត្រូវតែធ្វើខ្លះ បើមិនធ្វើក៏គ្មានផ្លូវប្រោសសត្វបាន ។ ព្រោះអ្វី? ព្រោះមនុស្សខ្លះមាននិស្ស័យត្រូវនឹងគ្រូកាច, មនុស្សខ្លះមាន និស្ស័យត្រូវនឹងគ្រូស្លូត ។ល។ អ្នកអានគប្បីដឹងថា ពុទ្ធសាសនារបស់យើងគ្មានចំណុចរឹងលុះត្រាគ្មានមនុស្សទៅជិតហើគ្មានចំណុចខ្សោយលុះត្រាគេដើរជាន់ឡើយ ។ ទំរើទាំងឡាយដែលពុទ្ធសាសនាអនុវត្តត ប្រាកដជានៅក្នុងក្របខ័ណ្ឌនៃមជ្ឈិមាបដិបទា គឺថាបើកាចក៏ដើម្បីយុត្តិធម៌នៃសង្គមមនុស្ស បើស្លូតគឺដើម្បីវឌ្ឍនភាពនៃអរិយធម៌របស់មនុស្ស ដូចដែលគេបានដឹងគ្រប់គ្នាមក ហើយ ។

ពុទ្ធសាសនាមានគំនិតល្អិតបង្រៀនឲ្យធ្វើកំណែបញ្ហា មុនកំណើតនៃបញ្ហាមួយៗ ត្រូវមានឡើងដូចជាបង្រៀនមិនឲ្យសាងសត្រូវ បង្រៀនឲ្យចងមិត្ត បង្រៀនឲ្យបំពេញសង្គហវត្ថុ គឺស្គាល់ចំណងមិត្តភាពនៃចិត្តរបស់មនុស្ស ដោយធ្វើអំណោយ ដោយពំនោលពីរោះ ដោយបំពេញប្រយោជន៍, និងដោយទុកដាក់ខ្លួនប្រាណក្នុង

ភាពស្មើៗជាមួយនឹងមនុស្សក្នុងសង្គម ។ បង្រៀនឲ្យស្អប់ខ្ពើមជម្លោះ បង្រៀនឲ្យមានចិត្តមេត្តាករុណាដល់មនុស្សទូទៅនៅក្នុងក្របខ័ណ្ឌចងមិត្តបំបាត់សត្រូវ ។ ការធ្វើឲ្យជីវិតរស់នៅក្នុងធម៌ល្អ, ក្នុងចរិយាថ្លៃថ្នូរ, ក្នុងនិស្ស័យឧត្តុង្គឧត្តមលោកថាគ្មានការចាំបាច់ធ្វើកំណែបញ្ហាអាក្រក់ៗ ដែលអាចកើតមានក្នុងពេលខាងមុខឡើយ ។ ប្រសិនបើមានបញ្ហាចោទថា បើយើងចេះតែខំប្រឹងធ្វើទំរើល្អដល់គេ ហើយគេចេះតែខំប្រឹងធ្វើទំរើអាក្រក់ដល់យើងជានិច្ច តើយើងត្រូវធ្វើយ៉ាងណា? ចម្លើយ : បើកុំឲ្យខូចប្រយោជន៍ច្រើន យើងត្រូវខំប្រឹងធ្វើសេចក្ដីល្អប្រកបដោយសំនូយ៉ាងខ្ពស់តទៅទៀត, តែបើនៅតែមិនកើតយើងត្រូវប្រើកំណាចណាមួយទល់នឹងកំហុចរបស់គេ នៅក្នុងក្របខ័ណ្ឌនៃកំណែ គឺធ្វើមនុស្សអាក្រក់ឲ្យកើតបានជាមនុស្សល្អ ដោយគ្មានគំនិតបំផ្លាញ ដូចដែលព្រះសម្មាសម្ពុទ្ធរបស់យើងធ្លាប់បានអនុវត្តមកហើយ ។

គំនិតតាមសំនេររបស់ខ្ញុំដូចមានតទៅ៖

## សេចក្ដីព្យាបាទ

ប្រសិនបើគេតាំងសំណួរថា : ពាក្យថាពៀររមែងរម្ងាប់ដោយគ្មានចំណងនោះ តើមតិនោះមានអ្វីជាមូលដ្ឋានជាផ្លូវវិនិច្ឆ័យ? ព្រោះបើយើងមិនឆ្លើយតប ទុកដូចជាយើងបើកដៃឲ្យសត្រូវរបស់យើង កាន់តែបានចិត្ត, កាន់តែឈ្លានពានឡើង គឺកាន់តែធ្វើបាបយើងធ្ងន់ឡើងៗ ព្រោះវាគ្មានឃើញយើងតដៃនឹងវា ។ ប្រសិនបើយើងឆ្លើយតបតាមមធ្យោបាយណាមួយដែលយើងមាន វាក៏គិតមុខគិតក្រោយ មិនហ៊ានធ្វើបាបយើងតទៅទៀត ។

បញ្ហាពៀររម្ងាប់ដោយគ្មានចំណង ខ្ញុំយល់ថាមានផ្លូវសម្រាប់គិតពីរយ៉ាង : ១- គិតតាមអត្ថរបស់ពាក្យ ២- គិតតាមន័យរបស់ពាក្យ ។ ប្រការ ១ : ពៀររម្ងាប់ដោយគ្មានចំណង ឬគ្មានចម្លើយ បើយើងមើលតាមវិស័យនៃសីលធម៌តែម៉្យាង វាមុខជាទៅមិនរួចទេ គឺយ៉ាងម៉េចក៏រម្ងាប់មិនបានជាដាច់ខាត ។ យើងនឹងធ្លាក់ខ្លួនជាមនុស្សត្រូវគេជេរប្រទេចជានិច្ច ។ល។ តែបើយើងពូកែអត់ធន់, យើងខំទប់ខ្លួនមិនឲ្យធ្លាក់ទៅជាទាសភាពនៃកំរោធ នៅក្នុងក្របខ័ណ្ឌធ្វើមិនដឹង មិនឮយូរៗ ទៅវាក៏អាចបាត់ឯងៗ ទៅដែរ គឺយើងសុខចិត្តប្រើខន្តីជាអាវុធ (អាវុធស្ងៀម) ដូចព្រះសម្មាសម្ពុទ្ធក្នុងពេល ដែលត្រូវពួកនាងសមាវត្តីជេរ ។ ព្រះអានន្ទចង់បានប្រតិកម្មអំពីព្រះអង្គចំពោះជំនេរនេះ, តែព្រះអង្គមិនយល់ព្រម ។ ជសមួយគ្នានេះព្រះអង្គបានមានព្រះពុទ្ធដីកាថា ជំនេរទាំងឡាយនេះវាមិនអាចប្រព្រឹត្តទៅបានហួសថ្ងៃទី ៧ ទេ ។ យ៉ាងណាក៏ដោយចុះ, ការគិតតាមអត្ថរបស់ពាក្យក្នុងចំណុចថា ពៀររម្ងាប់ដោយគ្មានចំណង ។ ទំរើនេះកម្រអ្នកណា ធ្វើកើតណាស់, តែបើគេធ្វើបាន វាគាប់ប្រសើរជាងធ្វើមិនបាន ។ ព្រោះអ្វី? ព្រោះបើយើងឆ្លើយ ឬឲ្យតំណប ជម្លោះខាង ផ្លូវកាយវានឹងត្រូវកើតតាម ។ ឯលទ្ធផលនៃជម្លោះនេះគឺស្លាប់ ឬជិតតែនឹងស្លាប់ បើមិនគេក៏យើង ។

ខាងគតិលោក, ច្បាប់សម្រាប់ប្រទេស ពុំបានគាំទ្រសេចក្ដីព្យាបាទអាឃាតរករឿងនឹងគ្នាទេ, ជនដែលលុះអំណាចនៃកំហឹងរបស់ខ្លួន ហើយបានប្រព្រឹត្តនូវបទល្មើសទាំងឡាយ មានដាល់តបកាប់ចាក់ជាដើម ត្រូវទទួលកំហុសនិងទណ្ឌកម្មទាំងពីរនាក់ ធ្ងន់ស្រាលច្រើនតិច ស្រេចហើយតែអ្នកច្បាប់វិនិច្ឆ័យតាមផ្លូវយុត្តិធម៌ ។

កាលើបើច្បាប់សម្រាប់ជាតិ ឬអន្តរជាតិមិនគាំទ្រទំរើព្យាបាទ ឬជម្លោះគ្រប់បែបយ៉ាងដូចនេះទៅហើយ តើគតិធម៌នឹងគាទ្រយ៉ាងម៉េចបាន? ហេតុដូចនេះ, អ្នកបញ្ឈប់នូវទំរើឈ្លោះប្រកែក ឬខំប្រឹងបំបាត់នូវទំរើអាក្រក់នេះឲ្យបានបើមិនច្រើនក៏តិចនោះ, ទើបត្រូវបានអ្នកប្រាជ្ញលោកឲ្យឈ្មោះថា អ្នកជួញចំណេញច្រើនជាងជួញខាត ។ នេះគឺជាការពិចារណាតាមអត្ថរបស់ពាក្យថា ពៀររម្ងាប់បានដោយគ្មានចំណង ។ ប្រការ ២ ការពិចារណាតាមន័យរបស់ពាក្យដូចបានចែងមកហើយនោះ បញ្ហានេះ, ពុទ្ធសាសនារបស់យើង បានណែនាំឲ្យពិចារណាពីខាងក្នុងទៅខាងក្រៅ គឺពុទ្ធសាសនា ត្រូវការរកមធ្យោបាយធ្វើយ៉ាងណាកុំឲ្យភ្លើងឆេះ ច្រើនជាងបណ្ដោយឲ្យភ្លើងឆេះហើយ

ទើបរកមធ្យោបាយលត់ភ្លើង ។ ដើម្បីសម្រេចតាមគោលគំនិតនេះ, ទើបពុទ្ធសាសនាពុំបានបង្រៀនឲ្យមនុស្សឈរឱបដៃចាំកម្ចាត់បង់ពៀរ ក្នុងពេលពៀរកើតឡើង ហើយដល់ម្តងណាឡើយ ។ លោកបង្រៀនឲ្យយើងចេះទប់ចេះរម្ងាប់ពៀរ, តាំងពីពៀរមិនទាន់កើត ឬរឿងដែលជាឈ្នួររបស់ពៀរមិនទាន់មាននៅឡើយ ។ គឺបង្រៀនឲ្យចេះទុកដាក់រៀបចំខ្លួនឲ្យបានល្អ, ចេះធ្វើឲ្យអ្នករស់នៅជិតខាងមានទំនុកទុកចិត្ត, ផ្លាស់គំនិតបៀតបៀនមកជាគំនិតស្រឡាញ់រាប់អាន ព្រោះអាស្រ័យគុណសម្បត្តិល្អប្រសើររបស់យើង ។ ទន្ទឹមគ្នានេះ, លោកបង្រៀនឲ្យចេះខ្វល់ខ្វាយអើពើនឹងទុក្ខធុរៈអ្នកដទៃ ចេះប្រើពាក្យសម្តីទន់ភ្លន់ផ្អែមល្ហែម ចេះជួយខ្នះខ្នែងក្នុងផលប្រយោជន៍មួយអន្លើដោយកិច្ចការងារនៃអ្នកផង មិនឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ចេះតម្កល់ខ្លួននៅក្នុងភាពស្មោះស្មើគ្មានឆ្មើងឆ្មៃប្រកាន់ខ្លួនប្រាណ ។ល។ បើយើងចេះរៀបចំខ្លួន ឲ្យជាមនុស្សរស់នៅក្នុងភាពល្អ ភាពត្រឹមត្រូវដូចបានពោលមកហើយនេះខ្លួនយើងមិនត្រឹមតែគ្មានករណីយ៍ក្នុងការរម្ងាប់ពៀរទេ, គឺវាគ្មានពៀរ, គ្មានជម្លោះស្រេចតែម្តង ជាមួយនិងមនុស្សដែលមានគំនិតជាមនុស្សដូចគ្នា ។ ចំណែកមនុស្សដែលមានគំនិតជាសត្វតិរច្ឆាន ឬលើសសត្វទៅទៀតនោះបញ្ហានេះយើងពុំអាចនឹងឲ្យចម្លើយបានទេ ព្រោះវាលើសវិស័យនៃចំណេះវិជ្ជារបស់យើងទៅហើយ ។ តែយើងក៏គ្មានគំនិតថា មនុស្សបែបនេះនឹងចេះតែរស់នៅបែបនេះរហូតទេ ថ្ងៃណាមួយគំនិតរបស់គេអាចនឹងមានពន្លឺមាន គំហើញត្រូវ ដោយអាស្រ័យថ្វីបញ្ញានៃអ្នកប្រាជ្ញណាមួយ ។ ជាពិសេស ព្រះសម្មាសម្ពុទ្ធដែលនឹងមាន ក្នុងអនាគតកាល ។

ដោយអាស្រ័យហេតុនេះ, បើយើងធ្វើសេចក្តីសម្រេចចិត្ត ប្រព្រឹត្តប្រតិបត្តិ ឬអនុវត្តខ្លួនឲ្យសមរម្យល្មោក់ល្មមដល់ហេតុការណ៍ដែលអាចនឹងកើតមានឡើង ក្នុងថ្ងៃណាមួយក្នុងពេលខាងមុខនោះហើយ ខ្ញុំយល់ថាពុទ្ធភាសិតក្នុងចំណុចថា ពៀរមែងរម្ងាប់ដោយការមិនចងពៀរ នៅក្នុងក្របខ័ណ្ឌរបស់នៃថា ដើម្បីបំបាត់ពៀរ ត្រូវលះបង់ធម៌បង្កើតពៀរទាំងឡាយ មានជាអាទិ៍គំនិតស្អប់, គំនិតព្យាបាទ និងគំនិតអាឃាត ហើយខំប្រឹងធ្វើខ្លួនឲ្យជាទីស្រឡាញ់រាប់អានរបស់សកលមនុស្ស បើទំរើនេះ, មានប្រសិទ្ធភាពពិតៗនោះ, មនុស្សយើងមិនត្រឹមតែគ្មានពៀរវេរា នឹងគ្នាប៉ុណ្ណឹងទេ ។ គឺមានជីវិតប្រកបដោយសេចក្តីត្រជាក់ត្រជុំ សុខដុមរមនាជាមួយគ្នាគ្រប់កាល គ្រប់សម័យ មិនខានឡើយ ។

មិនចំពោះតែរឿងព្យាបាទប៉ុណ្ណឹងទេ ដែលពុទ្ធសាសនាបង្រៀនឲ្យយកឈ្នះដោយទំរើល្អ សូម្បីសេចក្តីមិនល្អដទៃៗទោះជារឿងអ្វីក៏ដោយ, ក៏លោកបង្រៀនឲ្យយកឈ្នះដោយទំរើល្អទាំងអស់ ។ ដូចនេះព្រោះអ្វី? ព្រោះគោលគំនិតនៃពុទ្ធសាសនា ត្រូវការឲ្យសកលមនុស្សមានកម្ពស់ខាងផ្លូវចិត្ត, មានជីវិតរស់នៅប្រកបដោយសេរីភាពជាន់ខ្ពស់ គឺមិនបណ្តោយខ្លួនឲ្យធ្លាក់ចុះជាទាសភាពនៃតណ្ហា, នៃគំនិតថោកទាបដែលជាមូលហេតុនៃទុក្ខគ្រប់ប្រភេទ ។

## មិនមើលហួសខ្លួនឯងក្នុងតំណោងនៃបញ្ហាសីលធម៌

តាមធម្មតា, មនុស្សតែងទាមទាររកសីលធម៌កាលបើខ្លួនបានជួបប្រទះនូវទំរើជិះជាន់ពីអ្នកដទៃ ដូចជាត្រូវគេបៀតបៀនលួចប្លន់បោកប្រាស់គៃបន្លំ ។ល។ ហេតុកាឬណ៍ដូចនេះ កើតឡើងក្នុងពេលណា ការអំពាវនាវស្រែកហៅរកយុត្តិធម៌, សីលធម៌, មនុស្សធម៌ ។ល។ ក៏តែធ្វើឡើងព្រមគ្នាក្នុងពេលនោះដែរ ទោះជាខ្លួនគេមិនធ្លាប់ឃើញតម្លៃឬការ ចាំបាច់នៃសីលធម៌, នៃយុត្តិធម៌, នៃមនុស្សធម៌ក្នុងកាលមុនៗមកក៏ដោយ ។

ក្នុងសម័យសង្គ្រាម គេធ្លាប់បានឮសំឡេងរអ៊ូរទាំទូទៅគ្រប់ទិសគ្រប់ទីថា សីលធម៌សាបសូន្យបាត់អស់ហើយ ។ សំឡេងប៉ប៉ាច់ប៉ប៉ោចនេះ វាបានរសាត់អណ្តែតត្រសែតទៅកាន់ទីដែលមានមនុស្ស ដូចជារានលក់កាហ្វេ គុយទាវ បបរ បាយ ផ្លូវថ្នល់ ។ល។ បញ្ហាវិបត្តិនៃសីលធម៌ទើបត្រូវគេលើកមកដោះស្រាយរួមគ្នា ទៅតាមសមត្ថកិច្ចដែលគេរកឃើញ ។

បើយើងពិនិត្យមើលដល់គោលគំនិតមួយអន្លើ និងគំនោលការនៃពុទ្ធសាសនារបស់យើង, យើងនឹងឃើញថា ពុទ្ធសាសនាបង្រៀនមិនឲ្យយើងភ្លេចខ្លួន, មិនឲ្យយើងមើលហួសខ្លួនឯងដល់ម្ដងណាឡើយ ។ ការពិត, ពុទ្ធសាសនា បង្រៀនឲ្យយើងមានស្មារតីចងចាំជានិច្ច, ឲ្យយើងចាត់ការខ្លួនឯងមុន, ឲ្យយើងរៀបចំក្របខ័ណ្ឌល្អសម្រាប់ខ្លួនយ៉ាងឆាប់រហ័សកុំឲ្យពេលវេលាដើរចោលយើងកុំបង្អង់ចាំនេះចាំនោះ លុះត្រាមនុស្សទូទាំងពិភពលោក, គេចាត់ការឲ្យខ្លួន គេធ្វើនូវទំរើល្អអស់ហើយ, ទើបយើងចាត់ការល្អដល់ខ្លួនយើងជាចុងក្រោយបង្អស់ ។

អ្នកអានគប្បីរឭកដល់ពុទ្ធភាសិតថា«**អជ្ជេវកិច្ចមាតប្បំ កោជញ្ញា មរណំ សុវេ** . . . . . **អត្តានមេវ បឋមំ បដិរូបេ និវេសយេ** . . . . . ។» ចំណងពុទ្ធភាសិតនេះ, ចង់ឲ្យយើងធ្វើអ្វីៗ ដែលអ្នកប្រាជ្ញហៅថា សេចក្ដីល្អឲ្យហើយស្រេចភ្លាមៗទៅ ព្រោះសេចក្ដីស្លាប់មិនដឹងជាមានដល់ជីវិតយើងក្នុងថ្ងៃណា . . . . ព្រោះបើយើង មិនធ្វខ្លួនយើងឲ្យបានល្អជាមុន, យើងក៏ពុំអាចដឹកនាំអ្នកដទៃឲ្យធ្វើសេចក្ដីល្អបានឡើយ ។ ដូចនេះ, យើងត្រូវជា មនុស្សទី ១ ក្នុងកិច្ចការល្អ ហើយយើងក៏ជាមនុស្សក្រោយគេបំផុតក្នុងកិច្ចការអាក្រក់ ប្រសិនណាហើយបើគ្មានផ្លូវគេចឲ្យផុត ។

ដូចខ្ញុំបានឲ្យយោបល់មកហើយថា ការបណ្ដុះ ឬគាំទ្រសីលធម៌ ឬកំណែបញ្ហាសីលធម៌សាបសូន្យនោះ ខ្ញុំបាន ចាត់ជា ២ គឺ :

១- ចាត់ការគ្រប់បែបយ៉ាងដែលមានរចនាសម្ពន្ធជាមួយនឹងបញ្ហាសេដ្ឋកិច្ច ឲ្យនៅក្នុងក្របខ័ណ្ឌនៃរបៀបរៀបរយត្រឹមត្រូវដូចមានក្នុងសំនេរខាងដើម ។

២- ចាត់ការជាមួយនឹងខ្លួនឯង, ឲ្យជាមនុស្សរស់នៅក្នុងសីលធម៌ បំបាត់សេចក្ដីសង្ស័យ កម្ចាត់ឲ្យអស់នូវសេចក្ដីខ្ចិលច្រអូស ។ ជាមួយគ្នានេះ, ជួយរិះរកមធ្យោបាយធ្វើយ៉ាងណា ឲ្យមនុស្សជាប់ចិត្ត ស្រឡាញ់យុត្តិធម៌នៃសង្គម, និយមគុណធម៌ល្អ ទាំងក្នុងទីស្ងាត់កំបាំង ទាំងក្នុងទីប្រជុំជន ។ ដើម្បីសន្តិសុខនៃជីវិតមនុស្សក្នុងសង្គម និងសន្តិភាពសកលពិភព ពុទ្ធសាសនាមិនត្រឹមតែបង្រៀនឲ្យមនុស្សម្នាក់ៗ ជួយខ្លួនឯងប៉ុណ្ណឹងទេ ។ គឺបង្រៀនឲ្យជួយអ្នកដទៃផង ព្រោះអ្វី? ព្រោះមនុស្សមិនអាចនឹងរស់នៅម្នាក់ឯងកើតទេ, មនុស្សត្រូវតែរស់នៅដោយ អាស្រ័យសង្គម ឬមានសង្គមទើបរស់នៅបាន ។ ដូចនេះ, បញ្ហាជួយខ្លួនឯងនិងបញ្ហាជួយអ្នកដទៃទើបជាធាតុចាំបាច់ សម្រាប់មនុស្ស ដល់កម្រិតមួយរយភាគរយតែម្ដង ។

ព្រោះហេតុនេះហើយ, បានជាពុទ្ធសាសនាបង្រៀនមនុស្សឲ្យចេះហ្វឹកហាត់ អប់រំចិត្តឲ្យប្រកបដោយមេត្តាករុណា . . . . . ដែលគេស្គាល់ជាទូទៅថា ផ្សាយព្រហ្មវិហារធម៌ឲ្យប្រព្រឹត្តទៅតាមលំដាប់លំដោយមាន ៤ យ៉ាងគឺៈ

១- ផ្សាយមេត្តាដល់ខ្លួនឯងមុន, ដើម្បីដឹងថា ខ្លួនឯងមានចិត្តស្រឡាញ់សុខ ស្អប់ទុក្ខយ៉ាងណា អ្នកដទៃគេស្រឡាញ់សុខ ស្អប់ទុក្ខយ៉ាងនោះដែរ ។

២- លុះហាត់ផ្សាយមេត្តាដល់ខ្លួនឯង បានដល់ភាពច្នឹកស្ទាត់មែនទែនហើយ ត្រូវហាត់ផ្សាយមេត្តាដល់បុគ្គល ជាទីស្រឡាញ់ទាំងឡាយ មានមាតា បិតា បុត្ត ភរិយា ស្វាមី ឬបុគ្គលជាញាតិមិត្តជាបន្តបន្ទាប់ទៅ ។

៣- ក្រោយពីបានផ្សាយមេត្តាដល់បុគ្គលជាទីស្រឡាញ់ ជាទីគោរពរាប់អានបានហើយ ត្រូវផ្សាយមេត្តាដល់បុគ្គលពួកកណ្ដាល គឺមនុស្សដែលខ្លួនមិនទាន់ស្រឡាញ់ មិនទាន់ស្អប់ ឬមិនសូវយកចិត្តទុកដាក់ មិនសូវគិតគូរដល់ ។

៤- ក្នុងទីបំផុត, ត្រូវហាត់ផ្សាយមេត្តាដល់មនុស្សដែលធ្លាប់មានពំនៀរ ឬដែលធ្លាប់ជាសត្រូវនឹងខ្លួន ។

ក្នុងសង្គមមនុស្សលោក គេគិតធ្វើយ៉ាងណាឲ្យមនុស្ស ឬសត្វដែលជាសត្រូវរបស់គេ ដល់នូវសេចក្ដីវិនាស ។ ដូចនេះ, ការហាត់ផ្សាយមេត្តាដល់ខ្លួន, ដល់មនុស្សជាទីស្រឡាញ់របស់ខ្លួន និងមនុស្សកណ្ដាលដែលខ្លួនមិនទាន់

ស្រឡាញ់ មិនទាន់ស្អប់, ទាំង ៣ ប្រភេទនេះគ្មានការលំបាកទេ ។ គឺមានតែបុគ្គលប្រភេទទី ៤ ប៉ុណ្ណោះដែលមានសេចក្ដីលំបាកយ៉ាងខ្លាំង ដល់បុគ្គលអ្នកហាត់ផ្សាយមេត្តា ប្រហាក់ប្រហែលគ្នានឹងបុគ្គលអ្នកស្វែងរកដុំមាសក្នុងកន្លែងដែលមិនទាន់មានអណ្ដូងជីកមាសឡើយ ។ ទោះជាដូចនេះក្ដី ក៏ពុទ្ធសាសនាខំប្រឹងបង្រៀនឲ្យមនុស្ស យើងមានចិត្តខ្ពស់ មានសេចក្ដីត្រាប្រណី ចេះមានចិត្តក្លាហានអត់ឱនមិនចាប់កំហុស, មិនប្រកាន់ទោសមនុស្សជា សត្រូវហូតដល់ថ្នាក់ដូរចិត្ត ដូរគំនិតយកសត្រូវធ្វើជាមិត្តបាន ។ នេះគឺជាករណីយ៍ជាន់ខ្ពស់របស់ពុទ្ធសាសនា នៃយើងដែលបានបង្ហាញមនុស្សធម៌, សន្តិសុខនៃជីវិត និងសន្តិភាពរបស់ពិភពលោកនៅក្នុងក្របខ័ណ្ឌនៃ ព្រហ្មវិហារធម៌ប្រកបដោយប្រាកដនិយម យ៉ាងមានប្រសិទ្ធភាព ប្រសើនបើមនុស្សលោកចាប់អារម្មណ៍ហើយ អនុវត្តតាម ។

សរុបសេចក្ដី : ដើម្បីវឌ្ឍនភាពនៃជីវិត មនុស្សត្រូវតែខំប្រឹងស្ថាបនាសេដ្ឋកិច្ច សម្រាប់លោកនេះត្រូវ បង្កើតផលគ្រប់យ៉ាង, សម្រាប់លោកខាងមុខត្រូវខំបង្កើតបុណ្យគ្រប់ប្រភេទ, សម្រាប់ជាទីបំផុតនៃលោកបង្កើតគំនិតអរិយសច្ចៈ។ ជាមួយគ្នានេះ, មនុស្សត្រូវតែមានគំនិតថា ពៀរក្ដី ជម្លោះក្ដី កំរោធក្ដី កំណាញ់ក្ដី សំអប់ក្ដី ។ល។ ត្រូវបានចប់ដោយ គ្មានចំណង គ្មានចម្លើយ គ្មានតំណប ។ល។ មតិថាសង្គ្រាមចប់ដោយសង្គ្រាម ។ល។ មតិនេះពុទ្ធសាសនាពុំបានយល់ស្រុបផងទេ ។ ព្រោះអ្វី? ព្រោះពុទ្ធពំនោលក្នុងអរិយសច្ចៈថា ទុក្ខទាំងឡាយជាផលរបស់ហេតុ គឺតណ្ហា, តណ្ហាជាធាតុច្រានមនុស្សឲ្យធ្វើសង្គ្រាម ឬសង្គ្រាមជាចំហេះរបស់តណ្ហា ។ បើមនុស្សលោកនៅតែមានគំនិតចចេសប្រកាន់យកសង្គ្រាម បំបាត់សង្គ្រាមនោះ ខ្ញុំយល់ថាគំនិតនេះពុំបានត្រឹមត្រូវតាមសេចក្ដីពិតទេ ។ អ្នកអានប្រសិនណាចង់ ពិសោធរកសេចក្ដីពិតក្នុងរឿងនេះ សូមមេត្តានឹកថយទៅក្រោយវិញ តាមផ្លូវប្រវត្តិសាស្ត្រក្ដី តាមផ្លូវស្រាជ្រាវផ្នែក មនុស្សជាតិខាងសាសនាក្ដី ធាតុទាំងអស់នេះនឹងបង្ហាញឲ្យយើងឃើញថា គតិដែលយកសង្គ្រាម បញ្ចប់សង្គ្រាម វាមិនមែនបានចប់រហូតទេ គឺវាបានចប់មួយសំណើៗ ដែលភាសាអ្នកប្រាជ្ញប្រវត្តិសាស្ត្រលោកថាចប់ដើម្បីកើត, កើតដើម្បីចប់ ។ ហើយកំណើតនៃសង្គ្រាមថ្មីៗទៀត វាកាន់តែរីកធំឡើងៗ តាមទំហំនៃតណ្ហារបស់មនុស្សដែលចេះតែ កើនឡើងៗ គ្រប់ពេលវេលា ។ ព្រឹត្តិការណ៍នៃពិភពលោករហូតដល់សព្វថ្ងៃនេះសង្គ្រាមទាំងតូច ទាំងធំមានចំនួន ច្រើនស្ទើរតែគ្មានលេខដាក់ទៅហើយ ។ សង្គ្រាមឧប្បត្តិម្ដងៗ មនុស្សត្រូវរងគ្រោះ បាត់បង់ជីវិត ពិការរូបកាយ ហិនហោចសម្ភារៈទ្រព្យសម្បត្តិកាន់តែធ្ងន់ឡើងៗ រកកលធ្វើលេខលែងត្រូវ ចុះបញ្ជីលែងកើត គឺវាកាន់តែរងគ្រោះធំ តាមលំដាប់ ។ ឧបមាថា : បើមានសង្គ្រាមលោកលើកទី ៣ កើតឡើងក្នុងពេលឆាប់ៗនេះក្ដី យូរបន្តិចទៀតក្ដី, ខ្ញុំមានគំហើញថា អរិយធម៌របស់មនុស្សនឹងត្រូវបានចប់ត្រឹមហ្នឹងហើយ ។ រីឯជំនះនិងចំណាញ់នៃសង្គ្រាមនេះទៀតសោត, ក៏វាទៅជាធាតុគ្មានន័យ, អ្នកឈ្នះក៏ដូចជាអ្នកចាញ់ អ្នកចាញ់ក៏ដូចជាអ្នកឈ្នះ ព្រោះវាត្រូវរងគ្រោះវិនាសហិនហោច ខ្លោចផ្សាដូចគ្នា ។ ឬវាអាចទៅដល់ថ្នាក់គ្មាននរណារស់នៅ ចាំទទួលយកឈ្នះ យកចាញ់ដូចសង្គ្រាមមុនៗ ផងក៏មិនដឹង ! ប្រសិនបើសង្គ្រាមនេះគេលេងគ្នាដោយគ្រាប់បែកបរមាណូ ដែលបាញ់ចេញដោយកាំជ្រួចអន្តរទ្វីប ។ សព្វថ្ងៃនេះគំនិតបញ្ចប់សង្គ្រាមដោយសង្គ្រាមហាក់ដូចមានល្បឿនថយចុះខ្លះហើយ ព្រោះគេបានបើកសន្និសិទបន្ថយសព្វាវុធ ដែលមានគ្រាប់បែកបរមាណូនៅក្នុងនោះផងដែរ ។ ចំណែកគំនិតពុទ្ធសាសនាក្នុងចំណុចថា ពៀរត្រូវចប់ដោយគ្មានចំណង ឬសង្គ្រាមត្រូវចប់ដោយគ្មានសង្គ្រាមឆ្លើយតប ក៏ត្រូវបានប្រទេសជប៉ុននិងសហរដ្ឋអាមេរិកអនុវត្តហើយដែរ ។ ព្រោះអ្វី? ព្រោះប្រទេសទាំងពីរនេះ, ក្នុងពេលចប់សង្គ្រាមពិភពលោកលើកទី ២ បានដាក់ផ្លែផ្កាដល់គ្នា និងគ្នាទៅវិញទៅមកតាមផ្លូវពាក្យសម្ដីគ្រប់ពេលវេលា ។ ជប៉ុនថា គ្រាប់បែកបរមាណូរបស់អាមេរិកាំងនៅកោះអូគីណាវ៉ា ជាអនុស្សាវរីយ៍នៃសេចក្ដីឈឺចាប់មួយ ដែលពុំអាចឲ្យប្រជាជាតិជប៉ុនបំភ្លេចចោលបានទេ ។ អាមេរិកាំងថា : គ្រាប់បែករបស់ជប៉ុននៅកំពង់ផែចម្បាំងហូនូលូលូនៃកោះហាវ៉ៃ ជាអនុស្សាវរីយ៍យ៉ាងជូរចត់ខ្លោចផ្សារមួយដែលពុំអាចឲ្យ អាមេរិកាំង

បំភ្លេចចោលបានឡើយ ។ ក្រោយពេលលេងពាក្យសម្ដីដល់គ្នានិងគ្នាទៅវិញទៅមកមិនយូរ ប៉ុន្មានស្រាប់តែប្រទេសទាំងពីរនេះបានចាប់ដៃគ្នាជាមិត្ត បានធ្វើសន្ធិសញ្ញាការពារសន្តិសុខរួម ។ ជាមួយគ្នានេះ បានព្រមព្រៀងគ្នាលើកធ្វើសង្គ្រាមរវាងគ្នានិងគ្នា ដោយយកការសេដ្ឋកិច្ចមកធ្វើជាមួយគ្នាវិញ ។ នេះបញ្ជាក់ឲ្យឃើញថា គំនិតពុទ្ធសាសនាត្រង់ថា សង្គ្រាមគេមិនអាចបញ្ចប់ដោយសង្គ្រាម ឬពៀរមិនអាចរម្ងាប់បានដោយចំណង គឺជាធាតុសច្ចៈដល់កម្រិតមួយរយភាគរយ គ្មាននរណាអាចបដិសេធបានឡើយ ។

## បទទី៨
## ការអភិវឌ្ឍន៍ជាតិ

ពុំនោលមានជានិច្ចថា ជាតចម្រើនរុងរឿងបាន ត្រូវមានការអភិវឌ្ឍន៍ ។ គំនិតដើមក្នុងរឿងនេះ នឹងមានសំណួរថា យើងត្រូវធ្វើការអភិវឌ្ឍន៍ដើម្បីអ្វី ។ យើងអភិវឌ្ឍន៍ដើម្បីឲ្យសង្គមនៃជាតិរបស់យើងមានលក្ខណៈ យ៉ាងណាទើបឈ្មោះថាសង្គមមានសេចក្ដីចម្រើន មានការជឿនលឿន ។ ខ្ញុំមានគំហើញថា ជាតណាក៏ដោយ សង្គមណាក៏ដោយ ដែលអាចចម្រើនរុងរឿងបានត្រូវមានលក្ខណៈ ៤ ប្រការនេះគឺ :

១- មនុស្សក្នុងសង្គមមានសមត្ថភាពគ្រប់វិស័យ,

២- មនុស្សក្នុងសង្គមមានសេរីភាពពេញបរិបូណ៌,

៣- សង្គមមានរបបគ្រប់គ្រងប្រកបដោយយុត្តិធម៌,

៤- បុគ្គលក្នុងសង្គមមានព្រហ្មវិហារធម៌ដល់គ្នានិងគ្នាជានិច្ច ។

១- សមត្ថភាព សមត្ថភាពក្នុងទីនេះ ខ្ញុំសំដៅយកសមត្ថភាពរបស់បុគ្គលម្នាក់ៗ ដែលរស់នៅក្នុងសង្គមកំពុងមានការអភិវឌ្ឍន៍ ឬកំពុងធ្វើឲ្យប្រជាពលរដ្ឋ មានកម្រិតជីវភាពខ្ពស់ នៅក្នុងក្របខ័ណ្ឌជឿនលឿន ៣ ប្រការគឺ៖

- ប្រយោជន៍ខ្ពស់ខាងផ្លូវសម្ភារៈ,
- ប្រយោជន៍ខ្ពស់ខាងគំនិតបញ្ញា,
- ប្រយោជន៍ខ្ពស់ខាងធម្មៈ ។

ប្រយោជន៍ខាងសម្ភារៈ, បានដល់ជីវិតរស់នៅក្នុងកម្រិតខ្ពស់, មានសេចក្ដីសុខកាយសប្បាយចិត្ត មានឋានៈសមសួនជាប្រជាពលលោក ដែលគេនិយមថាជារបស់សំខាន់សម្រាប់ជីវិតមនុស្ស ។ តែគំនិតរបស់មនុស្សភាគច្រើនគេមានចំណូលចិត្តថា សម្ភារៈមិនសូវសំខាន់ប៉ុន្មានដល់ជីវិតមនុស្សទេ ។ របស់ដែលគេចង់ថាសំខាន់ដល់ជីវិតមនុស្ស គឺគំនិត បញ្ញា និងធម្មៈ ។ បញ្ញាមានប្រយោជន៍ខាងធ្វើឲ្យអ្វីទាំងអស់ មានគុណភាពខ្ពស់ ។ ខាងសម្ភារៈក៏ដូចខាងចិត្តវិញ្ញាណដែរ ។ ប្រជាពលរដ្ឋម្នាក់ៗ មានគំនិតប្រកបដោយពន្លឺទូលំទូលាយ មានចំណេះវិជ្ជាយល់ស្គាល់បញ្ហាអភិវឌ្ឍន៍គ្រប់វិស័យ មានចិត្តសប្បាយរីករាយក្នុងមុខងាររបស់ខ្លួនមានវណ្ណកម្ម មានតន្ត្រីនិងទស្សនវិជ្ជានានាជាគ្រឿងកំណាន់របស់ជាតិ ។ ចំណែកខាងធម្មៈ ដែលចាត់ទុកជាប្រយោជន៍ទី ៣នោះ បានដល់បីតិប្រាមោទ្យដែលជាចំណីរបស់ចិត្ត ដែលប្រជាពលរដ្ឋខ្មែរធ្លាប់ប្រើ, ធ្លាប់បង្កើតឲ្យមានតាំងតែបូរាណ កាលកមព្រោះធាតុនេះជាអាហាររបស់ចិត្តនៃមនុស្សយើង ដូចសម្ភារៈជាអាហាររបស់រូបកាយនៃយើងអីចឹងដែរ ។

សមត្ថភាពនៃមនុស្សខ្លះ មានមកដោយអាស្រ័យបញ្ញាអំពីកំណើត, ខ្លះកើតមានដោយអាស្រ័យការសិក្សាអប់រំក្នុងបច្ចុប្បន្ន ។ បុគ្គលដែលមានសមត្ថភាពពីកំណើត គេមានសមត្ថភាពបង្កើតគ្រឿហឧបករណ៍នៃការងារគ្រឿងចក្រ, គ្រឿងយន្ត ។ល។ និង ។ល។ ឲ្យមានគុណភាពខ្ពស់ ប្រកបដោយប្រសិទ្ធភាពគួរជាទីពេញចិត្តត ។ គ្រឿងឧបករណ៍និងសមត្ថភាពរបស់គេបូកគ្នា កើតបានជាផលិតផលគ្រប់បែប គ្រប់យ៉ាង, មិនត្រឹមតែសម្រាប់ដំឡើងជីវភាពរបស់គេក្នុងបច្ចុប្បន្នប៉ុណ្ណឹងទេ គឺវាបានជាមរតកយុវជនរបស់ជាតិក្នុងអនាគតកាលផង ។ ព្រោះហេតុដូចនេះ, សមត្ថភាពទើបត្រូវគេចែកចេញជាពីរយ៉ាងគឺ សមត្ថភាពជាទុនរបស់សង្គមក្នុងបច្ចុប្បន្ន ១, សម្ថភាពជាទុនរបស់សង្គមក្នុងអនាគត ១ ។ ការសន្សំទុកខាងចំណេះវិជ្ជាត្រូវអាស្រ័យការវិនិច្ឆ័យ ឬវិភាគជាសំខាន់, ប្រទេសណា, ជាតិណា, ស្ថាប័នការសិក្សាអប់រំណា ។ល។ មិនមានការវិនិច្ឆ័យ ឬមានការវិនិច្ឆ័យស្ទើរៗមិនដិតដល់ ស្ថាប័ននោះរមែងត្រូវដើរថយក្រោយ ។ ម៉្យាងទៀត, សមត្ថភាពរបស់មនុស្សម្នាក់បើបូកចូលគ្នា វិធានការ ឬចំណាត់ ឬរបបគ្រប់គ្រងនៃសង្គមវានឹងមានកម្រិតកាន់តែខ្ពស់ កាន់តែល្អប្រសើរជាងសម្ថភាពដែលគេពុំទាន់បូកចូលគ្នា ។ ពុំនោល

ខ្លី, សម្ថភាពរបស់សង្គមគឺជាធាតុសំខាន់, ជាធាតុមានកម្លាំងខ្លាំងក្លា ទាក់ទាញសង្គមឲ្យមានដំណើរឆ្ពោះទៅកាន់វឌ្ឍនភាព និងវិសាលភាព ប្រកបដោយកម្រិតខ្ពស់ជាអតិបរមានេះឯងគឺការ «អភិវឌ្ឍន៍» ។

២- សេរីភាព, សេរីភាពរបស់មនុស្ស វាជាធាតុមួយធ្វើឲ្យមនុស្សមានលក្ខណៈខុសគ្នាពីរបស់គ្មានជីវិត ឬគ្រឿងចក្រ, គ្រឿងយន្ត ឬសត្វតិរច្ឆានគ្រប់ប្រភេទ ។ល។ បើមានតែសមត្ថភាព, តែមនុស្សដែលរស់នៅក្នុងសង្គមគ្មានសេរីភាព សង្គមនោះនឹងក្លាយទៅជាសង្គម «ទីងមោង» សង្គមបែបនេះ ទោះជាខំប្រឹងធ្វើការដើម្បីវឌ្ឍនភាពប្រកបដោយសេចក្ដីព្យាយាមយ៉ាងប្ដូរផ្ដាច់ក៏ដោយ ក៏ពុំមានភាពចម្រុងចម្រើនប៉ុន្មានទេ ។ ព្រោះមនុស្សគ្មានសេរីភាព ឬមានសេរីភាពមិនគ្រប់គ្រាន់ គ្មានសិទ្ធិជ្រើសរើសការងារតាមសេចក្ដីពេញចិត្តរបស់ខ្លួន ។ ការណាដែលមនុស្សធ្វើដោយបង្ខំ, គ្មានចំណង់ . . . . . ការនោះពុំអាចបានផលពេញតាមទំរើនៃជើងលេខឡើយ ។ កាលបើមនុស្សយើងធ្វើការនៅក្នុងក្របខ័ណ្ឌនៃពំនេញ ឬចំណូលចិត្ត ដែលពុទ្ធសាសនាថា ធ្វើការមានឆន្ទិទ្ធិបាទ គឺមានសេចក្ដីពេញចិត្ត ពេញអារម្មណ៍ ឬមានចំណូលចិត្តពេញចំនួន លោកថាបានផលច្រើនជាងធ្វើដោយគ្មានការពេញចិត្ត ឬក្លែងធ្វើ ឬធ្វើដោយបង្ខិតបង្ខំ ។ ដូចនេះសេរីភាពទើបជាធាតយចាំបាច់, ជាធាតុសម្រាប់បង្កបង្កើតគំនិតបញ្ញាស្មារតីរបស់មនុស្សបន្ទាប់ពីសមត្ថភាព ។

ម៉្យាងទៀត, មនុស្សម្នាក់ៗកើតមក រមែងមានធាតុចូលចិត្តគឺសេរីភាពជាប់មកជាមួយផង ធាតនេះជាមរតករបស់ធម្មជាតិ គ្មាននរណាអាចលុបចោលបានឡើយ, ទោះជាកំណើតរបស់គេមានឋានៈទាបក្ដី ខ្ពស់ក្ដី សេរីភាពវានៅតែសេរីភាពដដែល វាគ្មានខ្វីរវល់ដល់ថ្នាក់ជាន់ឡើយ ។ ព្រោះហេតុនេះ សេរីភាពទើបជាធាតុចាំបាច់របស់មនុស្ស ហើយជាគោលការណ៍សំខាន់ក្នុងការអភិវឌ្ឍន៍ជាតិ ។ គំនិតប្រជាធិបតេយ្យទើបជាគោលការណ៍មានកម្ពស់គួរឲ្យមនុស្សស្រឡាញ់គាំទ្រ ឬទំនុកបម្រុងឲ្យអស់ពីកម្លាំងនិងសមត្ថភាព នៅក្នុងលក្ខខ័ណ្ឌនៃគំនិតជាក់លាក់, ប្រកបដោយភាពប្រាកដនិយមគ្រប់ពេលវេលា ។ ឧត្ដមគតិនេះ មិនត្រឹមតែធ្វើឲ្យមនុស្សរស់នៅក្នុងសេរីភាពប៉ុណ្ណឹងទេ គឺធ្វើឲ្យការអភិវឌ្ឍន៍ជាតិបានដល់នូវ ទិសគូសដៅជាពិតប្រាកដ ។ ឧបសគ្គធំនៃគោលការណ៍ប្រជាធិបតេយ្យ, គឺសេចក្ដីលោភលន់គ្មានព្រំដែន, គំនិតរឹងរូសប្រកាន់ខ្លួន ប្រកាន់ទ្រឹស្ដីចាស់គំរឹល ប្រកបដោយគំនិតវង្វេងថាអញវិសេស, មានតែអញ ស្រេចនឹងអញ មួយអន្លើដោយត្រកូលអញ បក្សពួកអញ ។ល។ គំនិតគម្រក់នេះហើយ, ដែលវាបញ្ចាឲ្យមនុស្សគម្រក់រស់នៅក្នុងភាពព្រងើយកន្តើយ មិនខ្វីរវល់ដល់សេចក្ដីទុក្ខព្រួយរបស់អ្នកដទៃ ។ ព្រមគ្នានេះ, វាបំបិទសិទ្ធិ បំបាត់សេរីភាពគេ ។ ខ្លាំងជាងនេះ, វាដេករាំងទ្វារនៃសេចក្ដីចម្រើនរបស់ជាតិ មិនឲ្យធ្វើការអភិវឌ្ឍន៍កើត ។

៣- យុត្តិធម៌នៃសង្គម, មនុស្សរស់នៅក្នុងសង្គមមួយៗ សុទ្ធតែមានបំណងសម្រាប់ចងភ្ជាប់គ្នាពីម្នាក់ទៅម្នាក់រហូតកើតបានជាស្រុក ជាប្រទេស ចំណងហ្នឹងគ្មានអ្វីដទៃទេ, គឺច្បាប់និងសេចក្ដីយុត្តិធម៌ ។ ពំនោលថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ គឺជាគតិធម៌នៃពុទ្ធសាសនារបស់យើង ដែលជាមូលដ្ឋាននៃច្បាប់សម្រាប់ពិភពលោកទាំងមូល ។ សង្គមរស់នៅគ្មានការបែកបាក់គ្នា, ឬរស់នៅប្រកបដោយសាមគ្គីភាព ក៏ព្រោះមានយុត្តិធម៌ជាទីតាំងជាមូលដ្ឋាន ។ សេចក្ដីថ្នាំងថ្នាក់តូចចិត្ត សេចក្ដីច្រណែនឫស្យា បានប្រណាំងប្រជែងដណ្ដើមមុខមាត់ ដណ្ដើមកេរ្តិ៍ឈ្មោះ ។ល។ ក៏មិនមែនមកពីអ្វីដទៃឡើយ គឺមកតែពីមានទំរើអយុត្តិធម៌កើតឡើង ។ អយុត្តិធម៌មិនត្រឹមតែជាឈ្នួននៃទុក្ខប៉ុណ្ណឹងទេ គឺជាគ្រាប់បែកកម្ទេចសន្តិសុខរបស់ជីវិតមនុស្សផ្សេងទៀត ។ គ្រប់ស្រុក គ្រប់ប្រទេសគ្រប់សង្គមជាតិ ឬអន្តរជាតិ បើខ្វះយុត្តិធម៌ក្នុងសង្គម វិបត្តិនានាក៏ចាប់កើតមានឡើង ។ បើអយុត្តធម៌កើតក្នុងសង្គមជាតិសង្គ្រាមស៊ីវិល ឬសង្គ្រាមគ្នាឯងក៏កើតឡើងភ្លាម ។ បើអយុត្តិធម៌កើតមានក្នុងសង្គមអន្តរជាតិ សង្គ្រាមអន្តរជាតិ ឬសង្គ្រាមលោកក៏កើតឡើងភ្លាមដែរ ។ ដូចនេះយោបល់ថា : យុត្តិធម៌ជាធាតុនាំទៅកាន់សន្តិភាព ឬសន្តិភាពជា

មូលដ្ឋាននៃការអភិវឌ្ឍន៍ទើបជាយោបល់ត្រូវ គ្មាននរណាអាចបដិសេធបានឡើយ ។

៤- សេចក្តីមេត្តាករុណា, ធម្មជាតិបង្កើតមនុស្សឲ្យមានរូបកាយ, គំនិតបញ្ញានិងគុណសម្បត្តិនៃខួរក្បាល មិនស្មើគ្នាទេ ។ មនុស្សខ្លះឆ្លាត ខ្លះល្ងង់ ខ្លះពិការ ខ្លះរឹងប៉ឹង ខ្លះមានភ័យវិបត្តិដល់ជីវិត ខ្លះរស់នៅក្នុងកន្លែងមានការសិក្សា ខ្លះរស់នៅក្នុងកន្លែងគ្មានការសិក្សា ។ល។ បើគេផ្តើមគិតគូរដល់ភាពមិនស្មើ ឬមិនដូចគ្នារបស់មនុស្សបញ្ហានឹងចោទឡើងភ្លាមថា ម៉េចយ៉ាអីចឹង? ចម្លើយ : ខាងសង្គមសាស្ត្រថា ព្រោះរដ្ឋចាត់ការមិនត្រូវ ឬរបបគ្រប់គ្រងសង្គមគ្មានប្រសិទ្ធភាព ។ ខាងពុទ្ធសាសនាថា : ព្រោះខ្វះចក្រធម៌ ៤ យ៉ាងគឺ : ១- ប្រទេសគ្មានសម្បត្តិធម្មជាតិគ្រប់គ្រាន់ ឬអ្នកគ្រប់គ្រងចាត់ចែងការមិនត្រូវ ឬមិនសព្វគ្រប់ ឬមិនដិតដល់ ២- គ្មានអ្នកប្រាជ្ញគ្រប់វិស័យ ជាពិសេសវិស័យសេដ្ឋកិច្ច និងបច្ចេកទេសជាដើម ។ ៣- ពលរដ្ឋគ្មានបានធ្វើការល្អទុកពីមុនមក ។ ៤- ពលរដ្ឋគ្មានបានទុកដាក់ខ្លួនប្រាណឲ្យត្រឹមត្រូវតាមកាលៈទេសៈ ។ យ៉ាងណាក៏ដោយចុះ, បញ្ហាគ្មានសមត្ថភាព ឬមានភាពមិនស្មើគ្នានៃពលរដ្ឋ គេមិនអាចនឹងឲ្យកំហុសទៅលើអ្នកណា ក្រៅពីអ្នកដឹកនាំប្រទេសជាតិបានទេ ព្រោះពុទ្ធសាសនិកក្តី អ្នកជំនាញការក្តី អ្នកឯកទេសក្តី អ្នកបច្ចេកទេសក្តី ។ល។ មិនមែនជាអ្នកធ្វើចំណាត់ទេ គឺជាអ្នកទទួលចាំយកពីអ្នកគ្រប់គ្រងទៅអនុវត្ត ។ ដូចនេះ, ការគ្មានសមត្ថភាពរបស់ប្រជាពលរដ្ឋ វាជាកំហុសរបស់អ្នកដឹកនាំជាតិ, វាមិនមែនជាកំហុសរបស់អ្នកណាដទៃឡើយ ។ រឿងនេះ, ប្រធានាធិបតីម៉ែកសៃសៃនៃហ្វីលីពីន លោកមានពំនោលថា «ដើម្បីសង្គមមានវឌ្ឍនភាពគ្រប់វិស័យ គេត្រូវរៀបចំច្បាប់ ធ្វើកំណែជនខ្សត់ខ្សោយមុនជនមាំមួន» គំនិតលោកម៉ែកសៃសៃនេះ បានត្រូវនឹងគំនិតមេត្តាករុណារបស់ពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធនិងសាវ័កទាំងឡាយ លោកមានឧត្តមគតិជួយស្រោចស្រង់មនុស្សខ្សត់ខ្សោយ មុនជួយមនុស្សមានបានស្តុកស្តម្ភ ។ ដោយផ្អែកលើព្រហ្មវិហារធម៌, ខ្ញុំគ្មានគំនិតស្របជាមួយនឹងជនខ្លះ ក្នុងចំណុចដែលគេចង់ថា «ស្រេចនឹងច្បាប់នៃកម្ម» ដូចមនុស្សមានភ្នែកខ្វាក់ ត្រចៀកថ្លង់ ច្រមុះក្រងិត អណ្តាតគរ ដៃក្ញែង ជើងខ្វិន ។ល។ គេធ្វើព្រងើយកន្តើយ គេមិនខ្វីរវល់ធ្វើដឹង ធ្វើឮ ដោយប្រកាន់យក ឧបេក្ខាធម៌ជាគោលគំនិត ព្រោះគេឲ្យន័យថា ធ្វើម៉េចវាជាកម្មផលរបស់មនុស្ស, យើងគ្មានមធ្យោបាយជួយទេ, យើងប្រើចិត្តឧបេក្ខាជំនួសចិត្តមេត្តាករុណាមុទិតាទៅ ។ ព្រោះអ្វី? ព្រោះគេបានធ្វើអកុសលកម្មមកពីជាតិមុន ទើបជាតិនេះកើតមកមានភាពពិរាពិការបែបដូច្នេះ ។ នៅក្នុងបញ្ហានេះ, ខ្ញុំសូមស្នើយោបល់ថា ជំនឿនិងគំហើញខាងលើនេះ បើចេះតែនៅមានក្នុងសង្គមមនុស្ស ឬសង្គមជាតិយើងតទៅទៀតនោះ ភ័យវិបត្តិគ្រោះកាចរបស់ជាតិនឹងចេះតែមានកំណើនរីកធំឡើងៗជាមិនខានឡើយ ។ ជាមួយគ្នានេះទៀត, ជនប្រព្រឹត្តទំរើពុករលួយដោយកេងកម្រៃខុសច្បាប់ល្មោភយស ប្រាថ្នាអំណាចរស់នៅក្នុងរបរខុស របរទុច្ចរិត អយុត្តិធម៌ ប្រព្រឹត្តទំរើបាប ទំរើជិះជាន់មនុស្សគ្នាឯង ។ល។ ហើយខំធ្វើបុណ្យកឋិន ផ្កា ដារ វេរដាក់បិណ្ឌ ដាក់ទាន ។ល។ ទំរើទាំងអស់នេះ, មិនត្រូវតាមគំនោលធម្មៈរបស់ព្រះពុទ្ធឡើយ ។ ព្រោះអ្វី? ព្រោះទំរើបែបនេះ ពុំអាចនឹងសង្គ្រោះចូលក្នុងគំនោលធម្មៈនៃព្រហ្មវិហារធម៌បានទេ, ដោយហេតុថា គំនោលធម្មៈធំបំផុត ឬគំនោលធម្មៈជាប្រធាននោះ បានចែងយ៉ាងច្បាស់ថា កុំធ្វើបាបអ្នកដទៃ, ធ្វើបុណ្យដើម្បីបុណ្យ ជុសលាងចិត្តរបស់ខ្លួនឲ្យស្អាត ។ ក្នុងន័យថា : ពុទ្ធសាសនាមិនឲ្យធ្វើបាបដើម្បីបុណ្យទេ ។ កុំឲ្យធ្វើបាប គឺកុំឲ្យប្រព្រឹត្តទំរើជិះជាន់ពុករលួយ ។ ឲ្យធ្វើបុណ្យ គឺជួយអ្នកដទៃឲ្យរស់នៅក្នុងភាពស្មើគ្នា ក្នុងសេចក្តីសម្បូរសប្បាយជាពិសេស គឺរស់នៅក្នុងយុត្តិធម៌នៃសង្គម ។ ជុសលាងចិត្តរបស់ខ្លួនឲ្យស្អាត គឺធ្វើឲ្យមានព្រហ្មវិហារធម៌នៅក្នុងចិត្ត ជាមួយគ្នានេះខំបន្ថយលោភៈ ទោសៈ មោហៈបណ្តើរៗ ឲ្យមានចំនួនតិចក្នុងទីបំផុតរម្លាយឲ្យអស់តែម្តង ។ គឺធាតុមេត្តាករុណានេះហើយ ដែលមានរចនាសម្ពន្ធជាមួយនឹងសេរីភាព ដែលជាសម្បត្តិធម្មជាតិ សម្រាប់មនុស្សទាំងអស់គ្នា ។ មនុស្សកម្សោយម្នាក់ៗ, មានសិទ្ធិទាមទារយកសេរីភាពរបស់ខ្លួនភ្លាមៗ កុំដេកចាំឲ្យមនុស្សមានកម្លាំងដាក់ទានឲ្យ ។ អ្នកខ្លាំងជាង ឆ្លាតជាងត្រូវកុំឆ្មេចភ្នែកលេបសេរីភាពតែម្នាក់ឯង

ឬបក្សពួកឯង ត្រូវប្រញាប់ប្រញាល់ប្រគល់សេរីភាពនិងយុត្តិធម៌នៃសង្គម ឲ្យប្រជាពលរដ្ឋភ្លាមៗទៅ ប្រសិនបើខ្លួនបានដឹងគំនិតពុទ្ធសាសនាក្នុងចំណុចដឹកនាំឲ្យមនុស្ស រស់នៅក្នុងព្រហ្មវិហារធម៌ហើយ ។ ផ្ទុយទៅវិញ, បើមិនទាន់ដឹង, ត្រូវខំប្រឹងរៀនឲ្យចេះដឹងទៅ ។ ព្រោះអ្វី? ព្រោះសមត្ថភាពគ្មានព្រហ្មវិហារធម៌របស់មនុស្សម្នាក់ៗ ពួកមួយៗ វាអាចធ្វើឲ្យកើតអយុត្តិធម៌យ៉ាងងាយជាទីបំផុត ។ សង្គមមានធាតុអ្វីៗគ្រប់អស់ហើយ តែគ្មានធាតុមេត្តាករុណា . . . . នៅក្នុងនោះឯង ។ សេរីភាពរបស់មនុស្សទូទៅក៏ពុំអាចកើតបាន ។ សេរីភាពស្លាប់, ការអភិវឌ្ឍន៍សង្គម ឬអភិវឌ្ឍន៍ជាតិ ក៏ទៅមិនរួច ឬបើប្រើទៅរួចក៏មិនអាចទៅដល់ទិសដៅខ្ពស់បំផុតបានឡើយ ។

## ចំណាត់ការអភិវឌ្ឍន៍ជាតិ

រហូតមកដល់ឃ្លានេះ, ខ្ញុំសូមធ្វើសំណើថា លក្ខណៈរបស់សង្គមដែលធ្វើការអភិវឌ្ឍន៍បានល្អនោះ ត្រូវមានឬត្រូវប្រកបដោយគុណធម៌ណាខ្លះ ។ ខ្ញុំមានគំហើញថា ប្រជាជាតិមួយៗ ដែលអាចរស់នៅក្នុងភាពចម្រុងចម្រើនបានត្រូវមានលក្ខណៈ ៤ ប្រការដូចមានពំនោលក្នុងសំនេររបស់ខ្ញុំក្នុងខាងដើម ។ ការធ្វើគម្រោងការអភិវឌ្ឍន៍គេត្រូវធ្វើក្នុងលក្ខណៈ ៤ ប្រការនេះ ។ គម្រោងការអភិវឌ្ឍន៍ ។ អ្នកខ្លះចូលចិត្តថា ជាធាតុរបស់សេដ្ឋកិច្ច ខ្លះចូលចិត្តយ៉ាងទូលាយថា ជាធាតុនៃការសិក្សា និងការសាធារណៈសុខ ខ្លះប្រកាន់ថា ជារឿងរបស់អ្នកសេដ្ឋសាស្ត្រ ។ សេចក្តីពិត, ការនេះបើពិចារណាឲ្យល្អិតល្អន់ជ្រាលជ្រៅទៅ នឹងឃើញការអភិវឌ្ឍន៍នោះ វាជារបស់ធាតុទាំងអស់រួមគ្នា ឬជាទំរើដែលត្រូវធ្វើ ត្រូវមានធាតុទាំងអស់ជាកម្ម ។ បើស្តីដល់វិជ្ជា គឺមានវិជ្ជាគ្រប់ប្រភេទដែលមានវិជ្ជាសីលធម៌ចរិយានៅក្នុងនោះផង បើស្តីពីមនុស្ស គឺមានអ្នកបច្ចេកទេសគ្រប់វិស័យ អ្នកឯកទេសគ្រប់ប្រភេទ អ្នកវិទ្យាសាស្ត្រគ្រប់ផ្នែក ។ល។ និង ។ល។ ដូចគ្នានឹងអ្នកសង់ផ្ទះ, ដែលដំបូងគេត្រូវរៀបចំធ្វើដី, ដាំសសរ ។ល។ ឬដូចអ្នកដាំដំណាំគ្រប់ប្រភេទ ដែលត្រូវមានពូជ មានគ្រឿងឧបករណ៍ នង្គ័ល រនាស់ ចប ប៉ែល . . រហូតដល់ការថែទាំដាក់ជី ស្រោចទឹកជម្រះស្មៅ កម្ចាត់សត្វល្អិតដែលវាបំផ្លាញដំណាំ ។ល។ និយាយខ្លី : គឺអ្វីៗដែលគេធ្វើដើម្បីបានសម្រេចនូវវឌ្ឍនភាពខ្ពស់ ឬបានទទួលសេចក្តីចម្រុងចម្រើនយ៉ាងឆាប់រហ័ស ទោះជាការរៀនសូត្រក្តី ការប្រកបអាជីវកម្មក្តី គំនិតក្តី ពំនោលក្តី ។ល។ ទាំងឡាយនេះត្រូវបានឈ្មោះថា ការអភិវឌ្ឍន៍ទាំងអស់ ។ ការអភិវឌ្ឍន៍ ប្រសិនបើមានគ្រឿងឧបករណ៍មិនគ្រប់, ក៏ត្រូវបានឈ្មោះថា អភិវឌ្ឍន៍ដែរ, តែមិនបានទទួលផលពេញលេញទេ ដូចអភិវឌ្ឍន៍ការសិក្សា, ត្រូវមានបឋមសាលា, អនុវិទ្យាល័យ, វិទ្យាល័យ, មហាវិទ្យាល័យ, សកលវិទ្យាល័យ, វិទ្យាស្ថានគរុកោសល្យ, សាស្ត្រាចារ្យបច្ចេកទេស, កម្ពស់នៃវិជ្ជារបស់សាស្ត្រាចារ្យ សម្ភារៈសិក្សាពិសោធ សម្ភារៈសិក្សាទំនើប ។ល។ ឲ្យគ្រប់គ្រាន់ ។ មធ្យោបាយមានគ្រប់គ្រាន់ហើយ តែចំណាត់ការមិនទាន់សម័យ ឬមិនត្រូវតាមកាលៈទេសៈក៏ទៅមិនរួច ។ អភិវឌ្ឍន៍កសិកម្ម, មានគ្រឿងឧបករណ៍មិនទាន់សម័យ ឬមិនគ្រប់គ្រាន់, ខ្វះអ្នកបច្ចេកទេស, ខ្វះអ្នកជំនាញការ, ខ្វះអ្នកឯកទេសក៏ទៅមិនរួចដូចគ្នា ។ល។ ខ្ញុំយល់ថាការអភិវឌ្ឍន៍គ្រប់បែប គ្រប់យ៉ាង ត្រូវផ្អែកលើស្ថានការណ៍ផ្សេងៗ និងធាតុទាំងឡាយ ដែលអភិវឌ្ឍនកម្មត្រូវមានគឺ :

១- ជាតិត្រូវរស់នៅក្នុងសេចក្តីសុខស្ងប់រៀបរយទាំងខាងក្នុង ទាំងខាងក្រៅ, ការគ្រប់គ្រងប្រទេសត្រូវមានរបបមួយយ៉ាងល្អនៅក្នុងភាពជាប្រាកដនិយម ។

២- ត្រូវរៀបចំធ្វើគម្រោងការអភិវឌ្ឍន៍ ឲ្យមានលក្ខណៈជាវិទ្យាសាស្ត្រយ៉ាងត្រឹមត្រូវ, មានទិសដៅយ៉ាងជាក់លាក់ មានឧត្តមគតិជាតិ មានស្មារតីបដិវត្តយ៉ាងរឹងប៉ឹង ។

៣- វិធីចំណាត់ការអភិវឌ្ឍន៍, ត្រូវពឹងផ្អែកលើគំនោលវិជ្ជានានា ត្រូវអនុវត្តចំណាត់ការអភិវឌ្ឍន៍ នៅក្រោមក្របខ័ណ្ឌនៃគំនិតញឹកល្អិត ។

៤- បើមានការចាំបាច់, ត្រូវប្រើអំណាចក្នុងការអភិវឌ្ឍន៍ ត្រូវប្រើឲ្យតិច ឬល្មមសមគួរ, ត្រូវចាត់វិធានការ

ការពារ ឬដំណោះស្រាយមិនឲ្យមានប្រើអំណាចណាដែលជាធាតុនាំឲ្យមានភយន្តរាយដល់សង្គម ។

## សេចក្តីអធិប្បាយ

ប្រការទី ១, សេចក្តីស្ងប់រៀបរយ និងការគ្រប់គ្រងមានសមត្ថភាព ធាតុនេះវាជាជំនួយ ជាដើមទុននៃការអភិវឌ្ឍន៍ដើម្បីសម្រេចផលក្នុងអនាគត ទោះជាជិតក្តី ឆ្ងាយក្តី ។ ដូចនេះទំរើអភិវឌ្ឍន៍ គេមិនអាចធ្វើបានល្អទេ ប្រសិនបើប្រទេសគ្មានសន្តិសុខ ។ តួយ៉ាងដែលគេអាចឃើញបានយ៉ាងច្បាស់ គឺកសិករដែលមានលំនៅក្នុងភូមិភាគមានចម្បាំង ។ កសិករទាំងឡាយនោះធ្វើការសាបព្រោះក៏មិនបាន, ច្រូតកាត់ក៏មិនកើត ផលិតផលអ្វីផ្សេងៗទៀត ក្រៅពីនេះក៏ប្រព្រឹត្តទៅបានមិនស្រួល ។ ការធ្វើមិនចេញនេះ មិនមែនព្រោះគ្មានគម្រោងការអភិវឌ្ឍន៍ទេ, តែព្រោះមានសង្គ្រាម ទោះជាសង្គ្រាមជាតិក្តី, សង្គ្រាមអន្តរជាតិ ឬសង្គ្រាមពិភពលោកក្តី ។ សូម្បីសង្គ្រាមគ្មាន, តែអ្នកដឹកនាំជាតិគ្មានសមត្ថភាព គ្មានគំនិតសង្គម គ្មានស្មារតីយុត្តិធម៌ ។ល។ ចាត់ការគ្រប់គ្រងប្រទេសគ្មានប្រសិទ្ធភាព ប្រជាពលរដ្ឋស្តាប់មិនបាន, មើលមិនយល់, មិនដឹងជាអ្នកដឹកដៃខ្លួនចង់ដើរទៅផ្លូវណា ។ ព្រឹត្តិការណ៍ស្រុក ប្រទេសមានសភាពដូចនេះ កម្រនឹងគេចផុតពីអនាធិបតេយ្យ គឺភាពវឹកវរចលាចល ។ ជាពិសេសភាពអារាត់អារាយ ស្តាប់គ្នាលែងកើតរវាងអ្នកដឹកនាំនិងអ្នកដើរតាម ។ នេះក៏ជាកត្តាមួយទៀតដែលធ្វើឲ្យការអភិវឌ្ឍន៍ចេញមិនរួច ។ បុព្វហេតុនៃការគ្មានរបរ គ្មានសណ្តាប់ធ្នាប់ ដែលជាធាតុជាន់ពន្លិចការអភិវឌ្ឍន៍ គ្មានមកពីអ្នកណាដទៃទេ គឺមកតែពីអ្នកគ្រប់គ្រងគ្មានសមត្ថភាព, ធ្វើចំណាត់ការសេដ្ឋកិច្ចនយោបាយ, សង្គមកិច្ច, វប្បធម៌ គ្មានបានប្រសិទ្ធភាពហ្នឹងឯង ។ ព្រោះអ្វី? ព្រោះអ្នកដឹកនាំក្នុងស្រុកខ្លះ ប្រទេសខ្លះ, មិនត្រឹមតែគ្មានអនុវត្តពុទ្ធតម្រាស់ដែលបានទសន៍ទាយថា ដើម្បីវឌ្ឍនភាពខ្ពង់ខ្ពស់គ្រប់វិស័យ អ្នកដឹកនាំក្តី អ្នកដើរតាមក្តី ត្រូវកុំប្រព្រឹត្តល្បែង ៤ ដែលគេស្គាល់គ្រប់គ្នាថា អបាយមុខ គឺល្បែងបុរសស្ត្រី, ល្បែងស៊ីសង, ល្បែងស៊ីផឹក, ល្បែងគប់សេពជនពុករលួយ ។ ល្បែងទាំងឡាយនេះ ពុំមែនផ្តល់ឲ្យនូវផលវិបាកតែក្នុងពេលនេះទេ ក្នុងអតីតកាលយូរអង្វែងមកហើយ មានប្រទេសមួយ ដែលមានទីក្រុងឈ្មោះសាវត្ថី ក៏ត្រូវបានរងគ្រោះដោយមិនគោរពតាមពុទ្ធទំនាយនេះដែរ អនាធិបតេយ្យនិងភាពច្របូកច្របល់បានកើតមានឡើងពេញក្រុងសាវត្ថីព្រោះ៖

១- សេចក្តីស្រវឹងក្នុងកាមតណ្ហា,

២- សេចក្តីល្មោភលោភលន់គ្មានចប់,

៣- មិនត្រឹមតែគ្មានប្រកាន់យកសីលធម៌ជាគូជីវិតប៉ុណ្ណោះ ថែមប្រកាន់យកសៃយសាស្ត្រជាធំទៀត,

៤- វណ្ណៈខ្ពស់ជិះជាន់វណ្ណៈទាប, មន្ត្រីជិះជាន់រាស្ត្រ,

៥- តុលាការមិនឲ្យយុត្តិធម៌ដល់ប្រជាពលរដ្ឋ,

៦- គ្មានសេចក្តីគោរព, គ្មានគួរសមដល់គ្នានិងគ្នា, ឃើញខុសថាជាត្រូវ,

៧- បុគ្គលមានអំណាចមានសេចក្តីព្រហើនកោងកាច ប្រាសចាកសេចក្តីមេត្តាករុណា ប្រកាន់យកអំណាចជាធម្មៈ មិនយកធម្មៈជាអំណាច,

៨- អ្នករដ្ឋការមិនត្រឹមតែគ្មានបំពេញករណីយកិច្ច ដើម្បីសេចក្តីសុខសាន្តរបស់រាស្ត្រ ឬគោរពកោតខ្លាចរាស្ត្រ ថែមប្រើអំណាចសម្លុតរាស្ត្រទៀត ។

លក្ខណៈនៃផលវិបាក ដែលកើតឡើងក្នុងក្រុងសាវត្ថី ក្នុងសម័យនោះបានត្រូវគេដោះស្រាយដោយធាតុពីរ គឺ : ១/ អប់រំសីលធម៌ជាថ្មីក្នុងពួកប្រជាជន និងភ្នាក់ងាររដ្ឋការគ្រប់មជ្ឈដ្ឋាន តាមមធ្យោបាយសាសនាទាំងឡាយមានពុទ្ធសាសនាជាដើម ដែលខ្លួនគេធ្លាប់មានជំនឿ ។ ២/ បញ្ហាយ៉ាងដាច់ខាតឲ្យអ្នកធំៗ ទោះជាធំដោយវណ្ណៈក្តី ដោយយសស័ក្តិទ្រព្យសម្បត្តិក្តី ។ល។ ឲ្យអនុវត្តច្បាប់រដ្ឋ, រស់នៅក្នុងវិន័យសង្គមជាទូទៅ ។ រស់នៅក្នុងគំនិតថា

សង្គមមួយៗ បើអ្នកធំប្រព្រឹត្តច្បាប់, កាន់វិន័យ, ដុសខាត់ចរិយាមារយាទរបស់ខ្លួនបានហើយ ។ ការប្រមែប្រមូលអ្នកតូចឲ្យរស់នៅក្នុងផ្លូវល្អ ក្នុងរបៀបរៀបរយគេអាចធ្វើបានដោយងាយ ។ ក្នុងរឿងនេះ, ពុទ្ធភាសិតបានចែងយ៉ាងច្បាស់ថា នៅក្នុងសង្គមជនមួយៗ អ្នកដឹកនាំត្រូវរស់នៅក្នុងធម្មៈមុនគេជានិច្ច, ទើបអ្នកតូចសុខចិត្តដើរតាម ។ ជាមួយគ្នានេះ សុភមង្គលនឹងកើតមានដល់គេទាំងអស់គ្នាដោយស្វ័យប្រវត្តិ ។ ព្រមគ្នានេះ, លោកបានឲ្យន័យជាបុគ្គលាធិដ្ឋាន ឬបើជាសេចក្តីប្រៀបដូចលោកថា សត្វគោទាំងឡាយ បើគោដែលនាំពួកធ្លាក់ជ្រោះភ្នំ, សង្គមគោទាំងអស់ក៏ធ្លាប់ជ្រោះភ្នំដែរ ។ សេចក្តីនេះយ៉ាងណាមិញ សង្គមមនុស្សក៏មានទំនាក់ទំនងដូចគ្នាអីចឹងដែរ ។ មនុស្សណាដែលត្រូវគេសន្មត ឬគេតែងតាំងឲ្យធ្វើមេដឹកនាំ បើមនុស្សនោះបានប្រព្រឹត្តទំរើអធម៌ ប្រជាពលរដ្ឋក៏មុខជានឹងប្រព្រឹត្តទំរើអធម៌តាម ។ កាលបើចរិយានេះកើតមានហើយ អសន្តិសុខនិងអនាធិបតេយ្យក្នុងរដ្ឋនឹងកើតមានជាបន្តបន្ទាប់គ្នា ។ ផ្ទុយទៅវិញ, គោមេពួកចេះដឹកនាំពួកវាល្អ, សង្គមគោទាំងអស់នឹងបានរស់នៅស្រួលប្រាសចាកគ្រោះថ្នាក់ ។ នៅក្នុងសង្គមមនុស្សក៏ដូចគ្នា, បើមេដឹកនាំប្រព្រឹត្តប្រតិបត្តិទំរើយុត្តិធម៌ ប្រជាពលរដ្ឋអ្នកដើរតាមក៏អនុវត្តទំរើយុត្តិធម៌ សន្តិសុខរបស់ប្រទេសនិងរបៀបរៀបរយនៃសង្គម . . នឹងត្រូវមានដោយគ្មានចាំបាច់ត្រូវស្រែកហៅ, ត្រូវអញ្ជើញ, ។ ទន្ទឹមគ្នានេះ, ការអភិវឌ្ឍន៍គ្រប់វិស័យក៏ដណ្តើមគ្នាហុចដៃឲ្យអ្នកអភិវឌ្ឍន៍ចាប់ មួយហើយមួយទៀតគ្មានចាំបាច់ត្រូវរុករកឡើយ ។

ប្រការ ២, អ្នកធ្វើគម្រោង ឬគំនូសដៅនៃការអភិវឌ្ឍន៍ឲ្យមានលក្ខណៈជាវិទ្យាសាស្ត្រ ឬឲ្យមានគំនោលត្រឹមត្រូវតាមវិស័យមួយៗ ដែលត្រូវលើកយកមកអនុវត្ត ។ ការអភិវឌ្ឍន៍ស្រុក ប្រទេស ដែលគេធ្លាប់ចេះធ្លាប់ចូលចិត្តជាទូទៅនោះ បើនិយាយចំពោះតែការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយកការតាំងដំឡើងជីវភាពប្រជាជនឲ្យមានកម្រិតខ្ពស់ មានពលានាម័យស័ក្តិសិទ្ធិ មានការសិក្សានៅក្នុថ្នាក់ល្អប្រសើរ . . . . . តើធ្វើយ៉ាងណាឲ្យបានដល់ទីទិសដៅនេះ? ចម្លើយ : ខ្ញុំនឹងឲ្យក្នុងខាងមុខត្រង់ចំណុចស្តីដល់ក្បួនចំណាត់ការ ឬវិធីអនុវត្ត ។ ក្នុងទីនេះសូមបន្ថែមនិងសូមពង្រីកពាក្យថា «អភិវឌ្ឍន៍» ដែលបាននិយាយមកហើយម្តងទៀត ដើម្បីជាពន្លឺដល់គំនិតអ្នកអានផង ដើម្បីងាយស្រួលដល់ទំរើនៃអ្នកអនុវត្តផង ។ ចំណាត់ការ ឬគម្រោងការ ឬទិសដៅដែលខ្ញុំយល់ថា ត្រឹមត្រូវគ្រប់គ្រាន់អស់ជើង ក្នុងទំរើអភិវឌ្ឍន៍ជាតិនោះ ត្រូវមានឲ្យគ្រប់ ឬប្រកបដោយអង្គ ៤ គឺ :

១- ត្រូវខំលើកកម្ពស់ការរស់នៅនិងសុខភាពរបស់ប្រជាជន ដោយការធ្វើលេខគិតគូរដល់ប្រយោជន៍បច្ចុប្បន្ន និងអនាគត ។ បើយើងចំណាយទុនច្រើនពេក ជីវភាពបច្ចុប្បន្នរបស់ប្រជាពលរដ្ឋនឹងមានកម្រិតថយចុះ ។ បើយើងចំណាយទុនតិចពេក ជីវភាពបច្ចុប្បន្ននឹងមានកម្រិតនៅក្នុងថ្នាក់មធ្យម ឬថ្នាក់ខ្ពស់ ។ តែក្នុងអនាគតជីវភាពនឹងធ្លាក់ចុះទាប ។ ដូចនេះ, ទើបគេត្រូវលៃលកគន់គិតយ៉ាងណា រក្សាតុល្យភាពបច្ចុប្បន្ន និងអនាគតឲ្យទាល់តែបាន ដើម្បីឲ្យមានយុត្តិធម៌ដល់មនុស្សជំនាន់នេះនិងជំនាន់ក្រោយ ។

២- របស់ដែលយើងទុកដាក់ ជាទិសដៅនៃការអភិវឌ្ឍន៍ជាតិ ទោះជាសម្ភារៈក្តី ជាធាតុអ្វីៗ ដទៃក្តី គេត្រូវខំរក្សាស្ថេរភាពរបស់វា ។ ពាក្យថា «ស្ថេរភាព» សំដៅយកភាពស្មើចុងស្មើដើមឬភាពនឹងនគ្មានចុះគ្មានឡើងញឹកៗ ។ យើងត្រូវខំរក្សាសភាពរូបិយប័ណ្ណ, តម្លៃដើមរបស់រូបិយប័ណ្ណ និងអាជីវកម្មគ្រប់ប្រភេទរបស់ប្រជាពលរដ្ឋ ឲ្យប្រព្រឹត្តទៅដោយមានស្ថេរភាព បើធ្វើដូចនេះកើតការអភិវឌ្ឍន៍របស់យើង ប្រកដជានឹងបានផលល្អគ្មានប្រែប្រួលឡើយ ។

៣- ការអភិវឌ្ឍន៍ជាតិ, ត្រូវគិតដល់សុខភាព និងអនាម័យមួយអន្លើដោយវត្ថុជុំវិញរបស់ប្រជាជនផង ។ ក្នុងចំណុចនេះគេតែងតែបានឃើញ បានជួបប្រទះ ក្នុងពេលណាមួយ ដែលប្រទេសយើងមានការអភិវឌ្ឍន៍គ្រប់វិស័យ ។ ជាពិសេសវិស័យឧស្សាហកម្ម ដែលអ្នកសេដ្ឋសាស្ត្រមានគំហើញថា សេដ្ឋកិច្ចរបស់ជាតិ មានកម្លាំងរឹងប៉ឹងមាំមួន នៅលើឧស្សាហកម្មធម្មតា ឬឧស្សាហកម្មទំនើប ។ ឧស្សាហកម្មជាធាតុមួយមានគុណសម្បត្តិសម្រាប់

ផលិតវត្ថុសេដ្ឋកិច្ចរបស់ជាតិគ្រប់យ៉ាងមែន, តែធាតុនេះវាអាចឲ្យ ប្រជាជនបានទទួលគុណវិបត្តខ្លះដែរ ។ គឺកាលណាបើរោងចក្រផលិតវត្ថុកាន់តែមានច្រើន, កាន់តែសម្បូរ ។ ប្រជាពលរដ្ឋក៏កាន់តែមានសុខភាពមិនល្អដែរ ប្រសិនបើអ្នកចំណាត់ការ ឬអ្នកបច្ចេកទេសខាងឧស្សាហកម្ម គេមិនរៀបចំរោងចក្រឲ្យត្រូវតាមលក្ខណៈអនាម័យ, ឬមួយរោងចក្រមានលក្ខណៈត្រូវអនាម័យហើយ តែអ្នកប្រតិបត្តិការក្នុងរោងចក្រមិនអនុវត្តតាមក្បួនអនាម័យ, តួយ៉ាងដូចគេយករបស់សំណល់ស្មោកគ្រោក ប្រកបដោយពិសកំណាច ឬមានលក្ខណៈទំនាស់និងក្បួនអនាម័យ ទៅចាក់ចោលក្នុងទឹកស្ទឹង ទន្លេ ដែលប្រជាជនប្រើប្រាស់ជាប្រក្រតី ។ ទំរើនេះ, វាអាចបណ្តាលឲ្យកើតជម្ងឺ, កើតសម្ពប់ ជំនួសសេសចក្តីសុខសាន្តនិងភាពសប្បាយរីករាយ ដែលជាប្រយោជន៍រួមនោះទៅវិញ ។ ក្នុងករណីនេះ, រោងចក្រអាចផ្តល់ប្រយោជន៍ឲ្យរដ្ឋ, ឬអង្គារឧស្សាហកម្មនានាតែម៉្យាង ។ ចំណែកប្រជាជនទូទៅ ឬពលរដ្ឋដែលធ្លាប់រស់នៅក្នុងតំបន់ឧស្សាហកម្ម ត្រឡប់ជាបានជួបប្រទះនូវគុណវិបត្តិនានា ព្រោះភាពកខ្វក់នៃអាកាសនិងទឹកដែលភាសានិយាយធម្មតាថា អាកាសពិស ទឹកពុលងូតមិនកើត ផឹកមិនបាន បើចចេសនឹងខូចសុខភាព, បាត់បង់សេចក្តីសុខសាន្តពិតប្រាកដ ។ សំណង់និងសមិទ្ធិទាំងឡាយ, ដូចជាផ្លូវ, ថ្នល់, ស្ពាន, មណ្ឌលសុខភាព, មន្ទីរពេទ្យ, គិលានដ្ឋាន, ផ្សារ, សាលារៀន, សួនច្បារ, សួនសត្វ ។ល។ ក៏មានទំនាក់ទំនងប្រហាក់ប្រហែលគ្នានឹងរោងចក្រដែរធ្វើខុសក្បួនអនាម័យ, គ្មានលក្ខណៈវិទ្យាសាស្ត្រ, ជាបច្ចេកវិជ្ជា ។ល។ ក៏ត្រូវមានគ្រោះកាចដល់ប្រជាពលរដ្ឋ បើមិនច្រើនក៏តិចដែរ ព្រោះទំរើទាំងឡាយ ទោះជាចរាចរក្តី, គំនេងក្តី, ដំណេកក្តី, សំនីក្តី, សម្រាកក្តី, សន្និសិទ្ធក្តី, រៀនក្តី, ព្យាបាលជម្ងឺក្តី ។ល។ ឥរិយាបថទាំងអស់នេះ វាមានការទាក់ទងជាមួយនឹងវត្ថុជុំវិញនៃជីវិតមនុស្ស ក៏ដោយអាស្រ័យពិសពុលដែលកើតអំពីផ្សែងនៃវត្ថុគីមី ដែលរោងចក្រនិងរថយន្តយកមកប្រើ ។ល។ ការអភិវឌ្ឍន៍ប្រទេសដោយធ្វើសំណង់ទំនប់ទឹក ដោយកាប់គាស់ព្រៃឈើចោល ក៏អាចផ្តល់ផលអាក្រក់បានដែរ ប្រសិនបើយើងធ្វើដោយគ្មានពឹងផ្អែកលើអ្នកបច្ចេកទេស ឬលើអ្នកមានធរណីវិជ្ជានិងព្រឹក្សាវិជ្ជា គឺវាបានផលល្អដល់វិស័យកសិកម្ម, និងវិស័យអគ្គិសនី, តែវាឲ្យផលអាក្រក់ដល់ប្រជាពលរដ្ឋ ខាងកើតទឹកជំនន់និងខ្យល់ព្យុះ ។ល។ ដូចនេះមុននឹងយើងធ្វើការអភិវឌ្ឍន៍, យើងត្រូវពិចារណាឲ្យឃើញនូវគុណសម្បត្តិ និងគុណវិបត្តិជាមុនសិន ទើបកំហុសមិនអាចនឹងកើតមានដល់យើងក្នុងពេលអនាគតជិត ឬឆ្ងាយ ។

៤- គោលដៅនៃការអភិវឌ្ឍន៍ជាតិ, ជាធាតុសំខាន់បំផុតសម្រាប់ប្រទេសខ្មែរយើង ការចាំបាច់របស់យើងគឺត្រូវធ្វើយ៉ាងណាឲ្យការអភិវឌ្ឍន៍ បានរីកសាយទៅដល់ជនបទ កន្លែងដែលបងប្អូនរស់នៅយ៉ាងលំបាក ។ តាមការសង្កេតរបស់ខ្ញុំ, ការអភវឌ្ឍន៍ក្តី, ការអ្វីដទៃក្តី, រដ្ឋ ឬអ្នកចំណាត់ការមិនសូវមើលឃើញដល់ជនដែលរស់នៅក្នុងជនបទទេ ។ មានប្រទេសជាច្រើន, កាលណាការអភិវឌ្ឍន៍ កាន់តែធ្វើច្រើនឡើងពលរដ្ឋស្រុកក្រុង កាន់តែរស់នៅសម្បូរសប្បាយ ។ ពលរដ្ឋស្រុកជនបទកាន់តែរស់នៅ ប្រកបដោយសេចក្តីទុក្ខក្រលំបាក, អ្នកមានកាន់តែមានឡើងអ្នកក្រកាន់តែក្រទៅ, អ្នកចេះរឹតតែចេះ អ្នកល្ងង់រឹតតែល្ងង់ ។ ប្រសិនបើយើងប្រកាន់យកសេចក្តីយុត្តធម៌ និងសេចក្តីមេត្តាករុណាជាធំក្នុងសង្គមជាតិ ដូចមាត់យើងថា ជាទិសដៅ ឬជាទីតាំង ។ យើងត្រូវធ្វើការអភិវឌ្ឍន៍ក្នុងជនបទឲ្យបានច្រើនជាងអភិវឌ្ឍន៍ក្នុងទីក្រុង ។ ជាពិសេសអភិវឌ្ឍន៍កសិកម្ម និងបសុកម្មជនបទ គឺត្រូវចំណាយទុន ចំណាយកម្លាំង គំនិត បញ្ញា និងកម្លាំងរូបកាយ, ដើម្បីធ្វើពលិកម្មដល់អង្គារនេះ, ឲ្យនៅក្នុងកម្រិតខ្ពង់ខ្ពស់បំផុត ។ នៅក្នុងស្រុក ក្រុង ក៏មានមនុស្សក្រណាស់ និងមានណាស់រស់នៅជាមួយគ្នា ។ អ្នកមានសប្បាយពេកទៅភ្លេចសេចក្តីទុក្ខលំបាករបស់អ្នកក្រ, អ្នកក្រត្រូវទុក្ខលំបាកសង្កត់ធ្ងន់ពេកទៅ លែងចង់ឃើញមុខអ្នកមាន ។ ដូចនេះ, ចំណាត់ការអភិវឌ្ឍន៍របស់យើង ត្រូវដំឡើងជីវភាពអ្នកក្រមួយសំណើសិន ឲ្យគ្នារស់នៅបានស្រួលជាមួយអ្នកមានផង ។ ដើម្បីឲ្យគោលការនេះដើរទៅរួច គេត្រូវបញ្ឈប់អភិវឌ្ឍន៍ជីវភាពអ្នកមាន គឺឲ្យអ្នកមានរស់នៅក្នុងកម្រិតជីវភាពដែលកំពុង

មាន រហូតដល់កម្រិតជីវភាពអ្នកក្រឡើងស្មើ ឬតាមទាន់សិន ។ នេះគឺជាទំរើអភិវឌ្ឍន៍ជាតិ នៅក្នុងក្របខ័ណ្ឌនៃយុត្តិធម៌របស់សង្គម និងព្រហ្មវិហារធម៌ ដែលរដ្ឋ ឬអ្នកចំណាត់ការអភិវឌ្ឍន៍ត្រូវតែប្រកាន់យក ឬអនុវត្តព្រោះទំរើនេះមានគុណភាពត្រឹមតែបង្អិតបង្អំជីវភាពអ្នកមាន និងអ្នកក្រឲ្យរស់នៅជាមួយគ្នាបានប៉ុណ្ណឹងទេ គឺជាមូលដ្ឋាននៃសាមគ្គីជាតិ មានកម្រិតខ្ពស់ដល់ថ្នាក់មួយរយភាគរយតែម្តង ។

ចំណាត់ការអភវឌ្ឍន៍, កាលណាយើងបានរៀបចំគម្រោងការ, មានគោលដៅ, មានទ្រនិចទិសច្បាស់លាស់ហើយ ។ យើងត្រូវមានស្មារតីចងចាំថា ធាតុសំខាន់ជាងគេនៃការអភិវឌ្ឍន៍គឺវិជ្ជា ដូចខ្ញុំបានពោលមកហើយ ។ តែបើមានវិជ្ជាហើយ គ្មានដើមទុនក៏ធ្វើមិនចេញ មិនថាអភិវឌ្ឍន៍សេដ្ឋកិច្ច ឬអភវឌ្ឍន៍សង្គមកិច្ច ឬអភិវឌ្ឍន៍នយោបាយ ឬអភិវឌ្ឍន៍វប្បធម៌, ទាំងអស់សុទ្ធតែត្រូវអាស្រ័យដើមទុនដូចគ្នា ។ បើមានខុសគ្នាខ្លះ, គឺត្រង់ចំនួនតិចច្រើនប៉ុណ្ណោះ ។ គំនោលសេដ្ឋសាស្ត្រដែលអ្នកអភិវឌ្ឍន៍យកមកប្រើនោះ ជាគំនោលធម្មតា មិនមែនជាគំនោលពិស្តារអាចនាំផ្លូវអ្នកអភិវឌ្ឍន៍បានទាំងអស់ទេ ។ ចំណាត់ការអភិវឌ្ឍន៍ ក្នុងក្បួនអភិវឌ្ឍន៍ វាត្រឹមតែជាចំណាត់ការតាមបែបផែន នៃវិធីប្រតិបត្តិធម្មតាមិនខុសគ្នា នឹងកិច្ចការដទៃប៉ុន្មានទេ ។ និយាយឲ្យស្តាប់ងាយ គឺគេត្រូវធ្វើយ៉ាងណាឲ្យអស់ដើមទុនយ៉ាងតិចបំផុត ហើយឲ្យបានកម្រៃយ៉ាងច្រើនបំផុត នេះជាគោលគំនិត និងឧត្តគតិនៃអ្នកធ្វើការអភិវឌ្ឍន៍ជាតិ ។ អ្នកអភិវឌ្ឍន៍, ត្រូវមានគំនិតញឹកល្អិតជ្រាលជ្រៅ នៅក្រោមទ្រឹស្តីនៃការអនុវត្ត គឺមិនសម្លឹងមើលហួសទ្រឹស្តី មិនប្រព្រឹត្តល្មើសកន្លងគំនោល ឬបំណងធម្មជាតិ ។ មនុស្សយើងអាចប្រានចោល ឬបដិសេធគំនិតគ្នាឯងបាន, តែមនុស្សយើងមិនមានសេចក្តីខ្លាំងពូកែ អាចនឹងប្រព្រឹត្តល្មើសគំនោលធម្មជាតិ ឬគោលការសេដ្ឋសាស្ត្រ ឬទ្រឹស្តីនៃវិជ្ជានានាបានទេ បើរឹងទទឹងចចេសធ្វើក្នុងពេលណា លទ្ធផលគឺសូន្យក្នុងពេលនោះឯង ។

ការអភិវឌ្ឍន៍, ប្រសិនបើដើមទ្រព្យមានតិច, ពេលវេលាមិនមានល្មម មនុស្សមានថ្វីដៃថ្វីគំនិត និងវិជ្ជាចំណេះមានមិនធួន, គេមិនត្រូវធ្វើការអភិវឌ្ឍន៍ច្រើនប្រភេទរួមគ្នាទេ ឬធ្វើព្រមគ្នាទាំងអស់តែម្តងឡើយ ។ គេត្រូវធ្វើតាមការចាំបាច់ និងការសំខាន់របស់សង្គមជាតិ ម្តងមួយ ម្តងពីររៀងគ្នារហូតទៅ ។ គឺការណាចាំបាច់សំខាន់របស់សង្គមត្រូវធ្វើមុន, ការណាមិនសូវចាំបាច់, មិនសូវសំខាន់ដល់សង្គមត្រូវទុកធ្វើក្រោយ ។

ពួកអ្នកសេដ្ឋសាស្ត្រច្រើនចាប់អារម្មណ៍លើសេដ្ឋកិច្ច, ចូលចិត្តឲ្យអភិវឌ្ឍន៍សេដ្ឋកិច្ចមុន, តែអ្នកសង្គមសាស្ត្រចាប់អារម្មណ៍លើសង្គមកិច្ច, ចូលចិត្តឲ្យអភិវឌ្ឍន៍សង្គមកិច្ចមុន ។ ចំពោះរឿងនេះ, ដូចខ្ញុំបានឲ្យគំនិតមកហើយថាការអភិវឌ្ឍន៍ គេត្រូវធ្វើតាមការចាំបាច់ ឬសំខាន់ ។ ដូចនេះ, មុននឹងធ្វើយើងត្រូវពិចារណាមើលទៅ គួរធ្វើអ្វីមុនអ្វីក្រោយធ្វើតាមហ្នឹងទៅ ។ ការអភិវឌ្ឍន៍វាតែងស៊ីរហូតដល់ការសិក្សា, សាធារណសុខ និងសាធារណូបការ ។ ក្រៅពីនេះ អ្នកសេដ្ឋសាស្ត្រ ឬអ្នកអភិវឌ្ឍន៍ ត្រូវតែគិតគូរដល់ធាតុដែលជាប់ទាក់ទងជាមួយ នឹងជីវិតដូចជា ភាពល្អ, ភាពសច្ចៈ, សម្រស់, សិល្បៈ, កវីនិពន្ធ, តន្ត្រី ។ល។ របស់ទាំងអស់នេះក៏ជាធាតុសំខាន់ នៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ ។ ការវិនិច្ឆ័យ, ការវិភាគ, ការស្រាវជ្រាវ, ការពិសោធក្នុងមហាវិទ្យាល័យ ឬសកលវិទ្យាល័យក្នុងគោលគំនិតឧបត្ថម្ភសច្ចធម៌ និងគំនិតបញ្ញា, ត្រូវបានគេចាត់ទុកជារបស់សំខាន់ ឬរបស់ឯកនៃសង្គមមនុស្ស, ហើយគេដាក់ចូលក្នុងក្បួនអភិវឌ្ឍន៍តាំងពីកាលណា កាលណីមកហើយ ។

## អំណាចក្នុងការអភិវឌ្ឍន៍

ការប្រើអំណាចក្នុងការអភិវឌ្ឍន៍ បានដល់ការចុះទុន ឬចំណាយទុនសម្រាប់សង្គមមនុស្សឬប្រយោជន៍រួម ។ ធាតុនេះគេត្រូវប្រើច្រើនលើសប្រក្រតី ហើយជារបស់ចាំបាច់ខានប្រើមិនបានផង ព្រោះអ្វី? ព្រោះកាលណាមានការអភវិឌ្ឍន៍រមែងមានចំណាយ និងសំណង់មួយអន្លើ និងសមិទ្ធិកាន់តែច្រើនឡើងៗ កម្មករក៏ត្រូវកើនតាមលំដាប់ចិរការខាងចំណាយខ្ពស់ជាងប្រក្រតី, ចំណាត់ការក៏ត្រូវធ្វើឲ្យមានភាពរឹងប៊ឹងជាងធម្មតា ។ និយាយខ្លីៗ គឺបើមាន

ការអភិវឌ្ឍន៍ច្រើន, ប្រាក់ក៏ត្រូវមានច្រើន, ការក៏ត្រូវមានច្រើន ទ្វារច្រកកំណោងគ្នា ឬបំបាត់ប្រវ័ញ្ចគ្នា ក៏កាន់តែមានច្រើនឡើង ។ ចូលក្នុងគតិថា ប្រាក់កាសគឺការងារ, ការងារគឺប្រាក់កាស ជប់សេចក្តីសុខឲ្យដល់អ្នកមាន អំណាចណាដែលប្រាសចាកហិរិ ឧត្តប្បៈ ។ បុគ្គលអ្នកទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍, ទើបចាំបាច់ត្រូវចាត់វិធានការខាងផ្លូវអនុវត្តការពារទុច្ចរិតកម្មនានា ។ ការពារមិនឲ្យប្រើអំណាចគ្មានយុត្តិធម៌ ឬអំណាចមិនត្រឹមត្រូវលុះត្រាតែបានទើបញ៉ាំងអភិវឌ្ឍនកម្មរបស់ខ្លួនឲ្យបានផលខ្ពស់បាន ។ មានបុគ្គលក្នុងលទ្ធិសេដ្ឋកិច្ចខ្លះ មានគំនិតប្លែកខុសគេ គឺគេមានគំហើញថា ប្រទេសដែលកំពុងមានការអភិវឌ្ឍន៍ទន់ខ្សោយ ដូចប្រទេសខ្មែរយើងជាដើមនេះ គេមិនអាចនឹងបំបាត់នូវទំរើកោរគ្នាបានដោយងាយទេ ។ បើការអភិវឌ្ឍន៍កាន់តែមានច្រើន ទំរើការពារនូវគំនិតទុច្ចរិតស៊ីឡឹបគ្នា, ក៏រឹតតែលំបាកយ៉ាងខ្លាំង ។ គេនិយាយទៀតថា, បើយើងបណ្តោយឲ្យកោរគ្នា ឬកេងកម្រៃគ្នាខ្លះ ជួនកាលទំរើអភិវឌ្ឍន៍របស់យើងអាចមានដំណើរលឿនដែរ ។ គំហើញក្នុងលទ្ធិនេះ ខ្ញុំមានយោបល់ថា ជាលទ្ធិចង្រៃ ដោយខ្ញុំមានគំនិតថា មិនដឹងជាដឹកនាំការអភិវឌ្ឍន៍ដូចម្តេចកើតទេបើយើងបណ្តោយឲ្យសីលធម៌របស់មនុស្សសាបសូន្យអស់ទៅហើយ ។ ដើម្បីឲ្យការអភិវឌ្ឍន៍បានផលល្អតាមសេចក្តីសង្ឃឹម ឬសេចក្តីប្រាថ្នារបស់យើង គេត្រូវអភិវឌ្ឍន៍សីលធម៌របស់មនុស្សជាមុនសិន ។ ម្យ៉ាងទៀត, គំនិតនៃមនុស្សក្នុងលទ្ធិណា ដែលអ្នកអួតអាងថា ការអភិវឌ្ឍន៍ មិនចាំបាច់ត្រូវផ្អែកលើគំនោលនៃវិជ្ជាសេដ្ឋសាស្ត្រ, រដ្ឋសាស្ត្រ, សីលធម៌ទេ ។ល។ គំនិតនៃមនុស្សក្នុងលទ្ធិនោះ នឹងត្រូវទទួលបរាជ័យក្នុងមុខងារអភិវឌ្ឍន៍របស់ខ្លួនជាមិនខានឡើយ ។ ព្រោះអ្វី? ព្រោះថា បើប្រទេសណាមានមនុស្សរស់នៅក្នុងគំនិតកំណោរ, គំនិតប្រវ័ញ្ចបោកប្រាស់ច្រើនគ្នា ឧបសគ្គនៃការអភិវឌ្ឍន៍ក៏មានច្រើនដែរ ។ តួយ៉ាងនេះ, គេធ្លាប់បានឃើញច្រើនមកហើយសម្រាប់ប្រទេសក្នុងទ្វីបអាស៊ីខ្លះ អាហ្វ្រិកខ្លះ ។ នៅក្នុងប្រទេសខ្មែរយើង ខ្ញុំមានគំនិតនិងសេចក្តីសង្ឃឹមថា ប្រហែលជាមិនសម្លាប់ខ្លួន ដោយទំរើពុករលួយក្នុងការអភិវឌ្ឍន៍ជាតិនេះទេ ។

## ការអភិវឌ្ឍន៍មនុស្ស

ក្នុងឃ្លាទីបំផុតនៃការអភិវឌ្ឍន៍ ខ្ញុំសូមស្នើគំហើញខ្លះដែលខ្ញុំយល់ថា មានសេចក្តីសំខាន់ សម្រាប់វាសនា, សីលធម៌និងការអភិវឌ្ឍន៍ ដូចដែលខ្ញុំបានដាក់ចំណងជើងថា «ការអភិវឌ្ឍន៍មនុស្ស» ។ ការអភិវឌ្ឍន៍មនុស្សសំដៅយកការសិក្សា ដែលរដ្ឋមួយៗ បានចាត់សម្រាប់យុវជន ឬកុមារ ដែលមានវ័យចូលដល់ការសិក្សា ឬជនមានវ័យចំណាស់ ។ សង្គមជាតិ ឬរដ្ឋត្រូវធ្វើគម្រោងការ, ធ្វើចំណាត់ ធ្វើគំនោលឲ្យជនទាំងពីរប្រភេទនេះ បានសិក្សាមានចំណេះវិជ្ជាគ្រប់ៗអាត្មា ។ លទ្ធផលរបស់សង្គមជាតិ ឬរបស់រដ្ឋ គឺសម្បូរមនុស្សក្នុងរដ្ឋមានចរិយាល្អ, មានវិជ្ជាក្នុងវិញ្ញាណ មានពន្លឺក្នុងគំនិត, មានសមត្ថភាពក្នុងទំរើ ។ល។ ម្នាក់ៗអាចធ្វើការបម្រើខ្លួនឯងនិងសង្គមជាតិបានមានប្រសិទ្ធភាពតិចច្រើន តាមទំហំនិងសមត្ថកិច្ចរបស់ខ្លួន ។ កុមារតូចៗមានពីអាយុ ៦ ដល់ ៧ ឆ្នាំឡើងទៅ ។ រដ្ឋមានករណីយកិច្ច បង្កើតសាលា ផលិតគ្រូ ផ្តល់ជំនួយ ផ្តល់មធ្យោបាយគ្រប់បែប គ្រប់យ៉ាង ឲ្យកុមារានិងកុមារីទាំងឡាយបានចូលរៀនគ្រប់ៗគ្នា ។ រដ្ឋមិនអាចចាត់ការឲ្យកុមារទាំងឡាយ បានចូលរៀនទាំងអស់ត្រឹមត្រូវតាមកម្រិតអាយុនិងប្រមាណនៃចំនួនក្មេង ដែលមានកត់ត្រាទុកក្នុងបញ្ជីនៃអង្គាររដ្ឋបាល ក៏ពិតមែនហើយ ។ តែរដ្ឋត្រូវតែខំធ្វើយ៉ាងណាលុះត្រាចេញរួច ព្រោះទំរើនេះជាទំរើអភិវឌ្ឍន៍មនុស្ស, ជាករណីសំខាន់របស់ជាតិ ។ ដរាបណាកូនក្មេងរបស់យើង គ្មានសមត្ថភាពអានភាសាជាតិមិនរួច ។ សរសេរអក្សរជាតិមិនចេញ ឬចេញហើយតែមិនត្រូវ, ដរាបនោះ កូនចៅយើងមិនដឹងជាទៅភ្លឺឯណាទេ ។ រដ្ឋក្តី មាតាបិតាក្តី អាណាព្យាបាលក្តី ត្រូវចេះចាប់អារម្មណ៍ ត្រូវចេះឈឺចិត្ត ត្រូវមានសេចក្តីខ្មាសអៀនក្នុងទំរើមិនកើត, មិនខ្មោច មិនផេះរបស់ខ្លួនឲ្យណាស់ ។ ព្រោះអ្វី? ព្រោះភាពមោឃៈរបស់កុមារទាំងឡាយនេះ មិនមែនកើតឡើង ដោយព្រះអាទិទេពដាក់ទំនាយទេ គឺកើតដោយរដ្ឋ . . . . . ពុំបានធ្វើការអភិវឌ្ឍន៍មនុស្សហ្នឹងឯង ។ ការលើកគុណភាពក្នុងបឋមសិក្សាឲ្យមានកម្រិតខ្ពស់ ជាទំរើមួយល្អ

ប្រសើរណាស់ ព្រោះបឋមសិក្សា ជាតុនេះវាជាជណ្ដើរ ឬជាស្ពានរបស់មធ្យមសិក្សា, តែអ្នកចំណាត់ការផ្នែកនេះច្រើននិយាយថា ធ្វើមិនកើត ព្រោះគ្រូភាគច្រើនខ្វះសមត្ថកិច្ច, គ្មានគុណភាពគ្រប់គ្រាន់ ។ អំណាងនេះខ្ញុំមានគំហើញថា មិនសូវត្រូវប៉ុន្មានទេ ដោយគុណភាពសំទាត់ជំនាញរបស់គ្រូថ្នាក់បឋមសិក្សានោះ, ទំហំវិជ្ជានិងកម្ពស់នៃគរុកោសល្យនៅក្នុងកម្រិតថ្នាក់មធ្យមបានហើយ ។ តែការខិតខំបង្រៀនគឺជាតុឧស្សាហ៍ និងវិរិយៈ ជារបស់ចាំបាច់ដែលគ្រូម្នាក់ៗត្រូវមានឲ្យច្រើនបំផុត ទើបអភិវឌ្ឍន៍ ឬផលិតកូនសិស្សបាន ។ គ្រូខ្លះអាល័យតែខំរៀនខ្លួនឯងដើម្បីប្រឡងយកអីៗទៀត រហូតដល់ភ្លេចថា ខ្លួនធ្វើគ្រូបង្រៀនសិស្ស, គ្រូខ្លះមិនយកចិត្តទុកដាក់ដល់ការបង្រៀនត្រង់ៗតែម្តង គ្រូខ្លះហាក់ដូចជាបានភ្លេចអស់រលីង នូវមុខងារនៃខ្លួនជាគ្រូបង្រៀន ។ សិក្សាធិការ, អនុវិទ្យាធិការ, វិទ្យាធិការ, មហាវិទ្យាធិការ, សកលវិទ្យាធិការ ដែលមានមុខងារត្រួតពិនិត្យមើលសកម្មភាព ឬទំរើបង្ហាត់បង្រៀនរបស់គ្រូ និងសាស្ត្រាចារ្យទាំងឡាយ ក៏ពុំបានបំពេញករណីយកិច្ចរបស់ខ្លួនឲ្យបានពេញលេញ ។ នេះគឺជាគុណវិបត្តិរបស់ការអភិវឌ្ឍន៍មនុស្ស និងទំរើផលិតក្មេងឲ្យវាមានជីវិតប្រកបដោយគុណភាពខ្ពង់ខ្ពស់ សម្រាប់ជាអនាគតរបស់ប្រទេស ។ ជាមួយគ្នានេះទៀត, គ្រូទាំងឡាយ . . . មិនត្រឹមតែគ្មានមនសិការជាគ្រូរបស់ជិតប៉ុណ្ណឹងទេ, វាថែមមានការប្រព្រឹត្តល្មើសសីលធម៌ ដែលជាធាតុមានការទំនាក់ទំនងយ៉ាងខ្លាំងដល់ការអភិវឌ្ឍន៍ ខាងផ្នែកសិក្សាអប់រំទៀតផង ។

ក្នុងមធ្យមសិក្សា, រដ្ឋមួយណាក៏ដូចមួយណា, គ្មានបង្ខំ, គ្មានតម្រូវទេ កុមារ ឬយុវជនចង់រៀនក៏បាន មិនចង់រៀនក៏បាន ស្រេចតែចំណង់របស់ខ្លួន ។ តែរដ្ឋមួយៗ បើមានយុវជនចូលរៀនក្នុងមធ្យមសិក្សាច្រើន វឌ្ឍនភាពរបស់រដ្ឋគ្រប់វិស័យ នឹងមានចំហាប់ទាន់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋជាមិនខាន ។ រឿងនេះ, មានប្រទេសជប៉ុនជាតួយ៉ាង គឺប្រទេសជប៉ុនចំណាត់ការនិងជំនួយក្នុងមធ្យមសិក្សា គេចែកជាពីរគឺ : ១- គេពង្រីកនិងពង្រឹងវិជ្ជាទាំងឡាយក្នុងថ្នាក់នេះ ឲ្យមានកម្ពស់នៅក្នុងកម្រិតសមគួរល្មម ។ ២- ក្រៅពៅកម្រិតវិជ្ជាឲ្យមានគុណភាពសមគួរល្មម, គេចែកនិស្សិត ឬអ្នកសិក្សាជាពីរពួកទៀតគឺ : ក/ ពួកដែលឡើងទៅថ្នាក់ឧត្តមសិក្សា ។ ខ/ ពួកបញ្ចប់ការសិក្សារបស់ខ្លួនក្នុងមធ្យមសិក្សា ។ ពួក ក/ គេចំណាត់ការសិក្សាគ្រប់ផ្នែកវិជ្ជាក្នុងមធ្យមសិក្សា ឲ្យមានគុណភាពខ្ពស់ដើម្បីងាយស្រួលដល់និស្សិតដែលទៅសិក្សាក្នុងថ្នាក់ឧត្តមវិជ្ជា ។ ពួក ខ/ គេចំណាត់ការសិក្សាក្នុងថ្នាក់មធ្យមសិក្សាឲ្យមានគុណភាពខ្ពស់ចំពោះតែមុខវិជ្ជាខ្លះ ដើម្បីងាយស្រួលដល់និស្សិត ឬអ្នកសិក្សា ដែលត្រូវការបន្តការសិក្សារបស់ខ្លួនខាងផ្នែកវិជ្ជាជីវៈ ។

សម្រាប់អ្នកសិក្សា, ដែលបានបញ្ចប់ការសិក្សារបស់ខ្លួនត្រឹមថ្នាក់បឋមសិក្សា ឬមធ្យមសិក្សា ប្រសិនបើគ្មានការសិក្សាវិជ្ជាប្រកប ឬវិជ្ជាជំនួយ ជាពិសេសវិជ្ជាជីវៈ ។ ចំណេះប៉ុណ្ណេះរបស់គេ, មិនទាន់ធួនល្មមដល់ការរស់នៅស្រួលនិងការអភិវឌ្ឍន៍ជីវិតឡើយ ។ ដូចនេះសង្គមជាតិ ឬរដ្ឋត្រូវចាត់ឲ្យមានវិជ្ជាប្រកប ឬវិជ្ជាជំនួយ ឬវិជ្ជាជីវៈដើម្បីញ៉ាំងកំសាយជីវភាពនិងទម្ងន់នៃការអភិវឌ្ឍន៍ ឲ្យមានកម្លាំងរឹងប៉ឹង ដែលប្រជាពលរដ្ឋនិងប្រទេសត្រូវការ ។ និយាយខ្លីៗ គឺរដ្ឋត្រូវបង្កើតនិងបង្កើនសាលាអាជីវសិក្សាឲ្យមានច្រើន ហើយបង្រៀនសង្កត់ឲ្យធ្ងន់ទៅលើវិជ្ជាប្រកប វិជ្ជាជំនួយ ឬវិជ្ជាជីវៈ សម្រាប់កូនសិស្សថ្នាក់បឋមសិក្សាភាគចុង និងនិស្សិតមធ្យមសិក្សា ដែលមិនចូលមហាវិទ្យាល័យ ឬនិស្សិតឧត្តមសិក្សា ឬមហាវិទ្យាល័យ ឬសកលវិទ្យាល័យ, ត្រូវបានរាប់ចូលក្នុងថ្នាក់បញ្ញវ័ន្ត (អ្នកប្រាជ្ញ ឬបញ្ញាជន) ចំណាត់ការ ឬជំនួយការសិក្សាដែលរដ្ឋត្រូវធ្វើឲ្យជនពួកនេះ ក្រៅពីសម្ភារៈសិក្សាទាន់សម័យសាស្ត្រាចារ្យមានគុណភាពខ្ពស់ ទាំងគរុកោសល្យ ទាំងចិត្តសាស្ត្រមួយអន្លើដោយ ភាពស្ទាត់ជំនាញក្នុងមុខវិជ្ជាមួយៗ ។ល។ មានធាតុពិសេសមួយទៀត, ដែលរដ្ឋចាំបាច់ត្រូវធ្វើ ត្រូវចាត់ឲ្យកើត គឺកម្មវិធីសិក្សាមានលក្ខណៈទាន់សម័យ ឬមានលក្ខណៈជាសកល ។ ទំរើនេះរដ្ឋមិនត្រឹមតែអភិវឌ្ឍន៍ ឬផលិតនិស្សិតឲ្យកើតជាបញ្ញវ័ន្ត

ដើម្បីលើកកេរ្តិ៍ឈ្មោះរបស់ប្រទេសជប៉ុនហ្នឹងទេ, គឺពិតជាបានធ្វើឲ្យប្រទេសសម្បូរចង្កៀងមនុស្សជាតិ ។ ជាពិសេស ញ៉ាំងការអភិវឌ្ឍន៍គ្រប់វិស័យរបស់ជាតិ ឲ្យមានកម្រិតខ្ពង់ខ្ពស់ស្មើគេឯង ឬទាន់អរិយប្រទេស ដែលកំពុងដើរចោលយើងសព្វថ្ងៃនេះ ។ ក្នុងរឿងអភិវឌ្ឍន៍ដដែលនេះទៀត, យើងមិនត្រូវប្រកាន់ថា អ្នករៀនថ្នាក់បឋម, មធ្យម ឬឧត្តមទេ, ខ្មែរទាំងអស់គ្នាត្រូវប្រកាន់យកការងារជាធំ ត្រូវចេះចាំ ឬស្គាល់សីលធម៌ ហើយនាំគ្នារស់នៅក្នុងសីលធម៌ ។ ជាមួយនេះ, ត្រូវមានសេចក្តីក្លាហាន ហ៊ានទទួលខុសត្រូវ ហ៊ានបង្ហាញមុខចំពោះសេចក្តីពិត ។ ខ្ពស់ជាងនេះ, ត្រូវចេះខ្មាសបាបខ្លួនឯង កុំធ្វើទំរើអាក្រក់ទាំងឡាយ មានស៊ីសំណូកជាដើម ដោយផ្អែកលើគំនិតខុស ឬដោយសម្គាល់ថា គ្មានគេឃើញ គ្មានគេដឹងព្រោះចិត្តកខ្វក់គំនិតពុករលួយ, ចរិយាស្អុយគគ្រុក ។ល។ វាមិនមែនកើតព្រោះគេឃើញ, គេឲ្យទេ គឺវាកើតដោយខ្លួនឯង, ឬខ្លួនឯងធ្វើ ឬខ្លួនឯងឲ្យ ។ ព្រោះអ្វី? ព្រះសម្មាសម្ពុទ្ធព្រះអង្គបានបញ្ជាក់ថា បុណ្យបាបកើតពីអ្នកធ្វើ, មិនមែនកើតពីអ្នកឲ្យ ឬអ្នកឃើញទេ ។ ព្រះអង្គបានបន្ថែមថា, អ្នកធ្វើបាបបើ អ្នកដទៃមិនឃើញ បើអ្នកដទៃមិនដឹង, ខ្លួនឯងដឹង, បើអ្នកដទៃមិនឲ្យ, ខ្លួនឯងឲ្យ ។ ដូចនេះ, យើងត្រូវឈប់ធ្វើបាប ទាំងឡាយ មានស៊ីសំណូកជាដើមហ្នឹងទៅ ។

ការសំខាន់ក្នុងរឿងអភិវឌ្ឍន៍មនុស្ស, មិនអាចសម្រេចបានដោយអាស្រ័យ ឬពឹងផ្អែកត្រឹមតែសម្ភារៈបច្ចេកវិជ្ជា គរុកោសល្យ ។ល។ ប៉ុណ្ណឹងទេ គឺត្រូវអាស្រ័យតួយ៉ាង ឬគំរូផង ។ ដូចនេះបុគ្គលជាគ្រូអាចារ្យសាស្ត្រាចារ្យ មាតា បិតា អាណាព្យាបាលរបស់សិស្ស ឬនិស្សិត មិនមែនមានមុខងារ ឬករណីយកិច្ចត្រឹមតែចញ្ចឹម និងបង្ហាត់បង្រៀនតែម៉្យាងឡើយ ។ ទាំងអស់គ្នាត្រូវរស់នៅក្នុងចរិយាសម្បត្តិថ្លៃថ្នូរ សីលធម៌ខ្ពង់ខ្ពស់, គំនិតជាតិ, ស្មារតីការងារ, ឧត្តមគតិយុត្តិធម៌, មនសិការសង្គម ។ល។ ដើម្បីទាក់ទាញចិត្តវិញ្ញាណបុត្តធីតា និស្សិត យុវជនរបស់ជាតិ ឲ្យត្រាប់ទំរើរបស់ខ្លួន ។ ជាមួយគ្នានេះ, គេទាំងឡាយនឹងបានប្រកាន់យកនូវគោលការណ៍ឧត្តុង្គឧត្តមនេះជាខ្សែបន្ទាត់នៃជីវិតរបស់គេ ។ ភាសិតបូរាណថា «ពុតគ្រូកុំត្រាប់ ច្បាប់គ្រូឲ្យយក» ភាសិតនេះបើផ្អែកលើទ្រឹស្តី, ស្តាប់ពីរោះ, បានការខ្លះដែរ ។ តែខាងអនុវត្តតឹងណាស់ មិនសូវមានអ្នកណាធ្វើកើតទេ, ព្រោះទំរើ ឬចរិយាមារយាទរបស់មនុស្សវាជាជំហឺឆ្លងមួយដែរ ។ ព្រះបរមគ្រូបានមានព្រះតម្រាស់ថា មនុស្សធម្មតា ឬមនុស្សថ្មី ឬមនុស្សកណ្តាល រស់នៅជាមួយជនពាលក្លាយទៅជាពាល, រស់នៅជាមួយបណ្ឌិតក្លាយទៅជាបណ្ឌិត ។ បើយោលទៅតាមពុទ្ធភាសិតនេះ ឪពុកម្តាយផឹកសុរា, កូនក៏ផឹកសុរា គ្រូអាចារ្យមារយាទថោក, សិស្សក៏មារយាទថោកាំ ។ល។ ដើម្បីអភិវឌ្ឍន៍សង្គមជាតិ ឬអភិវឌ្ឍន៍មន្ស្ស, គេមិនត្រូវប្រើភាសិត «ពុទ្ធគ្រូកុំត្រាប់ ច្បាប់គ្រូឲ្យយក» ទេ, គេត្រូវធ្វើកំណែភាសិតនេះជាថ្មីថា «ពុទ្ធគ្រូឲ្យត្រាប់ ច្បាប់គ្រូឲ្យយក» ដូចនេះព្រោះអ្វី? ព្រោះពុទ្ធសាសនាបានបង្រៀនថា : ដើម្បីសេចក្តីថ្លៃថ្នូររបស់សង្គម ឬវឌ្ឍនភាពនៃជីវិតរបស់មនុស្ស ។ គ្រូម្នាក់ៗ ក្រៅពីមានមុខវិជ្ជាសីលធម៌ហើយត្រូវបង្ខំ ឬបង្រៀនខ្លួនឯង ឲ្យរស់នៅក្នុងសីលធម៌ជាមុន ទើបងាយស្រួលដល់ការបង្រៀនសិស្ស ទាំងវិជ្ជាទូទៅ ទាំងវិជ្ជាសីលធម៌ ។ នេះគឺជាពុទ្ធភាសិតដែលមានចំណាស់ ២៥១៦ ឆ្នាំមកហើយ ។ បំណងពុទ្ធភាសិតនេះ, ត្រូវការឲ្យមនុស្សធ្វើគ្រូដើម្បីគ្រូ ឬធ្វើគ្រូដើម្បីផលិតមនុស្ស ។ គ្មានត្រូវឲ្យមនុស្សធ្វើគ្រូ ដើម្បីផលិតខ្មោចទេ ។ ដូចនេះភាសិតថា «ពុតគ្រូកុំត្រាប់ ច្បាប់គ្រូឲ្យយក» ភាសិតនេះគឺជាភាសិតត្រូវបង្កើតឡើង ដោយគ្រូដែលបង្រៀនមនុស្សឲ្យធ្វើខ្មោចហ្នឹងឯង ។ ក្នុងកាលាមសូត្រប្រការទី ១០ មានចែងថា កុំជឿតាមគ្រូ ឬកុំប្រព្រឹត្តតាមទំរើគ្រូ ។ គ្រូក្នុងទីនេះគឺគ្រូគ្មានគ្រូ ឬគ្រូបង្រៀនខ្មោច, មិនមែនគ្រូបង្រៀនមនុស្សទេ ។ ព្រោះអ្វី? ព្រោះគ្រូនេះមានចំណេះវិជ្ជាជាគ្រូ តែមានមារយាទជាចោរ, មានគំនិតក្បត់សីលធម៌, មានសម្បជញ្ញអមនុស្សជាតិ, មានជីវិតរស់នៅជាខ្មោច ។ល។ ពំនោលនេះ និងចរិយារបស់គ្រូបែបនេះ កាលាមសូត្រហាមដាច់ខាតមិនឲ្យអនុវត្ត, មិនឲ្យរស់នៅជាមួយ និងមិនឲ្យប្រគល់ខ្លួនជាសិស្សឡើយ ។ សិស្សណាចចេសចង់រស់នៅជាមួយនឹងគ្រូបែបនេះ សិស្សនោះនឹងទៅជាខ្មោច

(**ឆនោ ឆនាយ សំវាសតិ**) ។

ទំនើរបស់ពុទ្ធសាសនាក្នុងការអភិវឌ្ឍន៍ជាតិ ដូចខ្ញុំបានពោលមកហើយក្នុងខាងដើម ។ ខ្ញុំសូមធ្វើសេចក្ដីបំភ្លឺយ៉ាងខ្លីថា បើមនុស្សគ្មានសីលធម៌ ការអភិវឌ្ឍន៍ប្រទេសនៅគ្រប់វិស័យទាំងអស់ មិនថាវិស័យណាទេ នឹងត្រូវបានទទួលបរាជ័យ គ្រប់ពេលវេលា ។ ហើយយូរៗទៅគេនឹងមានគំនិតថា ការអភិវឌ្ឍន៍ខាងសម្ភារៈមានតម្លៃខ្ពស់ជាងការអភិវឌ្ឍន៍ខាងបញ្ញានិងខាងធម្មៈ ។ កង្វះសីលធម៌អាចឲ្យពិភពលោកសូន្យបាន បើមិនឆាប់ក៏យូរដែរ ។ ខ្ញុំសូមស្នើគំនិតមួយថា សព្វថ្ងៃនេះពិភពលោកខ្វះសម្ភារៈ ឬធម្មៈ ។ គំនិតខ្ញុំថាខ្វះធម្មៈ ព្រោះខ្ញុំឃើញថា អ្វីៗក្រៅពីធម្មៈគេធ្វើកើត, គេអនុវត្តបានអស់ហើយ ។ តែបញ្ហាធម្មៈក្នុងចំណុចថា កុំសាងអាវុធចម្បាំង កុំប្រកាន់ជាតិសាសន៍ កុំប្រព្រឹត្តទំនើជិះជាន់ទាំងឡាយ ដូចជាតិជិះជាន់ជាតិ, វណ្ណៈជិះជាន់វណ្ណៈ, ត្រកូលជិះជាន់ត្រកូល ។ល។ គេគ្មានស្ដាប់ គ្មានអនុវត្តទេ ។ គេថាអភិវឌ្ឍន៍មនុស្សឲ្យមានជីវិត រស់នៅក្នុងភាពថ្លៃថ្នូរខ្ពង់ខ្ពស់, តែគេអភិវឌ្ឍន៍សង្គ្រាមបំផ្លេចបំផ្លាញជីវិតមនុស្សទៅវិញ ។ គេថាអីផ្ទុយពីតំហារបស់គេ, ផ្ទុយពីសេចក្ដីពិតរបស់ធម្មជាតិ, តែមិនទាំងអស់គ្នាទេ មានខ្លះគេធ្វើតាមតំហា តាមសេចក្ដីពិតរបស់ធម្មជាតិដែរ ។

ព្រះពុទ្ធសាសនារបស់យើង, ដែលមតិភាគច្រើនយល់ថា ជួយរំដោះទុក្ខរបស់មនុស្សក្នុងលោកជាទូទៅនោះជំនួយរបស់ពុទ្ធសាសនាបានផ្អែកទាំងស្រុងទៅលើធម្មៈ ។ ទំនើរបស់ពុទ្ធសាសនាចំពោះការអភិវឌ្ឍន៍មានដូចនេះ :

១- ពុទ្ធសាសនា ប្រកាន់យកភាពមិនជិះជាន់គ្នា, ភាពជួយសង្គ្រោះគ្នា និងភាពបរិសុទ្ធនៃចិត្ត ។ គ្មានលាយឡំដោយគំនិតផ្សងព្រេង, គំនិតសៃយសាស្ត្រ គំនិតទាសៈខ្មោចទេវតាឥន្ទព្រហ្ម ។ ជាមួយគ្នានេះទៀត, ជំនឿក្នុងគាថាមន្តអាគមនានា ។ ព្រះពុទ្ធបរមគ្រូរបស់យើង ព្រះអង្គបានមានព្រះតម្រាស់ថា ជនល្ងង់មានគំនិតស្រវឹងក្នុងទំនើគ្មានហេតុផល គឺគេគិតតែជំនុំពិភាក្សាគ្នាអំពីឫក្សល្អអាក្រក់នៃដួងផ្កាយ នៃខែឆ្នាំ ។ គេប្រកាន់យកពេលវេលាដែលគេមានជំនឿថា អាក្រក់ល្អជាធំ, គេគ្មានយល់ថា របស់ដែលធំបំផុតក្នុងពិភពលោកគឺការងារឡើយ ។ គំនិតនេះ, ខ្ញុំយល់ថា បើចេះតែនៅតទៅទៀតនោះ ការអភិវឌ្ឍន៍ជាតិរបស់យើងមុខជាគ្មានបានទៅដល់ទិសដៅដែលយើងបានគូសទុកឡើយ ។

២- ដោយផ្អែកលើពុទ្ធសាសនាដដែល, ខ្ញុំមានយោបល់ថា អ្នកអភិវឌ្ឍន៍ត្រូវមានជំនឿទៅលើមូលដ្ឋាននៃហេតុផលនិងវិជ្ជា ។ គឺកុំឆាប់ជឿងាយៗ ដោយមិនបានធ្វើការពិសោធ និងកុំរស់នៅជាមួយនឹងអវិជ្ជា ។ ក្នុងកាលាមសូត្រ, ព្រះសម្មាសម្ពុទ្ធបានមានព្រះតម្រាស់ថា «អ្នកទាំងឡាយកុំមានជំនឿក្នុងរបស់ដោយត្រឹមតែបានឮតៗគ្នា, កុំមានជំនឿក្នុងដំណឹងដែលចេញពីមាត់មួយទៅមាត់មួយ ឬប្រភពមួយទៅប្រភពមួយ, កុំមានជំនឿដោយផ្អែកទាំងស្រុងទៅលើក្បួនមាត្រា (បិដក) កុំមានជំនឿតាមការគូសដៅរបស់ខ្លួន, កុំមានជំនឿដោយការឲ្យន័យរបស់ខ្លួន, កុំមានជំនឿតាមតែសេចក្ដីត្រិះរិះ ឬអារម្មណ៍របស់ខ្លួន, កុំមានជំនឿតាមតែគំហើញរបស់ខ្លួន, កុំមានជំនឿតាមតែទម្លាប់ឃើញ ឬតាមតែផ្គត់គំនិតរបស់ខ្លួន, កុំមានជំនឿតាមតែពំនោលនៃលោកគ្រូរបស់ខ្លួន គឺពុទ្ធសាសនាមិនចង់ឲ្យមនុស្សយើងប្រញាប់ប្រញាល់ ឬប្រចុយ ឬអារកាត់ដាក់ជំនឿទៅលើរបស់ដែលខ្លួនបានឃើញ, បានឮ, បានជួបភ្លាមៗ ដោយអត់ទាន់បានប្រើគំនិតប្រាជ្ញាពិចារណាជាមុនឡើយ ។ នេះគឺជាទំនើមួយទៀតរបស់ពុទ្ធសាសនា, សម្រាប់ការអភិវឌ្ឍន៍ជាតិរបស់យើង ឲ្យមានដំណើរឆាប់រហ័សទាន់សេចក្ដីសង្ឃឹមរបស់ពលរដ្ឋ ។ ខ្ញុំមានចំណូលចិត្តថា, កាលាមសូត្រនេះ មិនត្រឹមតែយើងជាពុទ្ធសាសនិកទេ, ដែលមានសេចក្ដីពេញចិត្ត និយមប្រកាន់យកទុកជាមូលដ្ឋាននៃគំនិត ។ អ្នកសិក្សានិងអ្នកស្រាវជ្រាវទូទៅក្នុងពិភពលោក មិនថាសាសនាណាលទ្ធិណាទេ គេមានសេចក្ដីស្ងើចសរសើរដល់ពុទ្ធតម្រាស់ ក្នុងចំណុចនេះយ៉ាងខ្លាំងបំផុតផង ។ ចំណែកពុទ្ធសាសនិកក្នុងប្រទេសយើង, ប្រសិនណាព្រមព្រៀងគំនិតគ្នាសើរើពិនិត្យឡើងវិញ ប្រកបដោយវិចារណញ្ញាណ

គ្រប់ៗអាត្មា ហើយអនុវត្តគំហើញរបស់ខ្លួនតាមសូត្រនេះ, នោះការអភិវឌ្ឍន៍របស់យើង ទាំងផ្នែកធម្មៈ ទាំងផ្នែកសម្ភារៈនឹងបានសម្រេចដល់ទិសដៅជាមិនខានឡើយ ។

៣- ខ្ញុំមានគំហើញថា ការដែលយើងប្រកាន់យកពុទ្ធធម៌ ដែលជាគំនោលសីលធម៌មកប្រកបចូលជាមួយនិងសភាពការបច្ចុប្បន្ន ។ យើងមានការចាំបាច់ត្រូវរំពឹងគិតថា សភាពបច្ចុប្បន្ន និងលក្ខណៈនៃសង្គមមនុស្ស វាមានការប្រែប្រួលផ្លាស់ប្តូរជានិច្ច ។ ប្រសិនបើយើង ប្រកាន់ថាធម្មៈរបស់ព្រះពុទ្ធជា **អកាលិកោ** (ឲ្យប្រយោជន៍គ្មានកំណត់កាល) គឺជាធាតុគ្មានថ្ងៃស្លាប់ ប្រើបានគ្រប់កាលនោះគឺវាជារឿងពិត ។ តែការអនុវត្តមានការប្រែភាពខុសពីពុទ្ធកាលរឿយៗ ។ ដូចនេះ, ខ្ញុំយល់ថា ការទាក់ទាញចិត្តប្រជាពលរដ្ឋ ឲ្យដុះគំនិតជាពុទ្ធនិយម ។ ជាពិសេសក្នុងចំណោមយុវជន គេត្រូវធ្វើកំណែកម្មវិធីខ្លះ ដើម្បីឲ្យស៊ីនឹងនិស្ស័យយុវជនបច្ចុប្បន្ន ឲ្យកាន់តែច្រើនឡើងដោយចំពោះអ្នកសិក្សាជាតិយើងជាតួទៅ ។ ប្រសិនបើយើងទេសនាក្តី សន្ទនាធម្មៈក្តី ធម្មសាកច្ឆាក្តី សរសេរសៀវភៅក្តីតាមតែគំនិតដែលយើងធ្លាប់មានពីដើមមក ប្រាកដជាពុំសូវបានផលល្អប៉ុន្មានទេ ។ ព្រោះតាមដែលខ្ញុំបានជួបជាញឹកញាប់មកហើយ ពេលណាមាននិមន្តភិក្ខុទៅសម្តែងធម៌អប់រំ ដើម្បីកែនិស្ស័យសន្តានរបស់យុវជន ម្តងៗ ។ ប្រាកដថា : គេមិនសូវយកចិត្តទុកដាក់ស្តាប់ឡើយ ។ គេអង្គុយស្តាប់យូរៗ គេងលក់បណ្តោយទៅ ។ ខ្ញុំមានគំនិតថា សព្វថ្ងៃនេះប្រសិនបើ ធម៌ទេសនានោះមានបញ្ចូលរឿងខ្លះៗ ដែលសម័យបច្ចុប្បន្នគេកំពុងនិយម, តាមតែរឿងអីក៏ដោយ ដែលអាចធ្វើឲ្យយុវជនយើងចាប់អារម្មណ៍ ឬយកចិត្តទុកដាក់ ។ ខ្ញុំយល់ថា មានប្រយោជន៍ច្រើនណាស់ ។ ការលើកយកធម្មៈមកប្រើប្រកបជាមួយនឹងអ្វីៗ ដែលខ្ញុំចង់ថា គំនិតថ្មី, យោបល់ថ្មី តែនៅក្នុងក្របខ័ណ្ឌនៃអរិយសច្ចៈដដែល ទោះជាធម៌នោះមានលក្ខណៈជាពិធីការ (តុបតែងគ្រឿងសក្ការៈ) ជានិទាន (បុណ្យបាបគុណទោសនរកសួគ៌) ជាទស្សវិជ្ជា (គំហើញមានហេតុផល មានការពិសោធបាន) កំណែនៃកម្មវិធីថ្មីនេះអាចចុចអារម្មណ៍យុវជន ឬអ្នកសិក្សាទូទៅឲ្យកើតគំនិតវិភាគ (វិនិច្ឆ័យ) ។ ជាមួយគ្នានេះ, គេអាចនឹងមានមនោសញ្ចេតនាជាធម្មៈ មានទស្សនវិជ្ជា ឬមានចិន្តាយុត្តិធម៌ ឬមានព្រលឹងបដិវត្ត និងអភិវឌ្ឍន៍កើតឡើងជាមិនខាន ។

៤- ខ្ញុំមានគំហើញថា, ការអភិវឌ្ឍន៍គ្រប់វិស័យចាំបាច់ត្រូវអនុវត្តព្រមគ្នា ទាំងគតិលោក ទាំងគតិធម៌ដូចដែលខ្ញុំបាននិយាយមកហើយ ព្រោះសង្ឃក្តី ប្រជាពលរដ្ឋក្តីធាតុទាំងពីរនេះរួមរស់, រួមចិត្តគំនិត, រួមទំរើការងារយ៉ាងច្រើនជាមួយគ្នា អស់រយៈកាលយូរណាស់មកហើយ ។ មានករណីច្រើនដែលប្រទេសជាតិ មានឥរិយាបថហាក់ដូចព្រងើយកន្តើយចំពោះសេចក្តីសំខាន់របស់វត្តក្នុងជនបទ (ស្រុកក្រៅ) ឬក្នុងទីក្រុង ទីប្រជុំជន រហូតដល់ព្រងើយកន្តើយចំពោះសេចក្តីសំខាន់ នៃការដឹកនាំរបស់គណៈសង្ឃ ឬភិក្ខុដែលដឹកនាំគណៈសង្ឃក្នុងតំបន់ជនបទ ឬទីក្រុង ឬក្នុងប្រទេសទាំងមូល ។ តួយ៉ាងដែលអាចមើលឃើញងាយៗ គឺកាលណារដ្ឋាភិបាល ឬអង្គការរដ្ឋមួយណា ត្រូវការធ្វើការអភិវឌ្ឍន៍កសិកម្ម ។ គេមានគំនិតក្នុងទំនងថា ប្រទេសគេទាំងឡាយដទៃទម្លាប់ធ្វើយ៉ាងណា, មានអ្នកអភិវឌ្ឍន៍ប្រកបដោយសមត្ថភាពដូចម្តេច, មានការអប់រំកសិករតាមរបៀបណា ។ គេក៏ធ្វើតាមអារម្មណ៍ របស់គេទៅ ។ គេគ្មានគំនិតថា ជនបច្ចេកទេសសម្រាប់ដឹកដៃកសិករ ច្រើនមានវ័យក្មេងៗ ឬវ័យកណ្តាល ។ ជនពួក នេះត្រូវបានរដ្ឋ ឬអង្គការបញ្ចូលទៅជួយកសិករ ដើម្បីផលិតផលកសិកម្មឲ្យមានកម្រិតខ្ពស់ តាមសម័យនៃ វិទ្យាសាស្ត្រទំនើប ។ ទំរើនេះបានផលល្អខ្លះ មិនល្អខ្លះ ព្រោះកិច្ចការនេះគេធ្វើក្នុងវិស័យនៃឃរាវាស គឺគតិលោក តែម៉្យាង, គេគ្មានពឹងផ្អែកលើគតិធម៌ផងទេ ទើបបានផលមិនគ្រប់តាមសេចក្តីត្រូវការ ។ ព្រោះអ្វី? ព្រោះប្រជាកសិករភាគច្រើន មិនសូវនិយមរាប់អាន, មិនសូវយកចិត្តទុកដាក់ស្តាប់ ជនដែលមានវ័យនៅក្មេងជាង ខ្លួន

ដែលគ្នាទទួលបេសកកម្មរបស់រដ្ឋទៅបម្រើខ្លួនត្រង់ៗ ដោយនៅមានគំនិតប្រកាន់ថា អញចាស់ជាង អញជាឪពុកម្ដាយជីដូនជីតា ។ល។ ធ្លាប់ធ្វើស្រែចម្ការយកផលចញ្ចឹមពួកវា អស់រយៈកាលច្រើនរយឆ្នាំមកហើយ ។ ដើម្បីបំបាត់គំនិតសោះអង្គើយ ឬគំនិតប្រកាន់នេះ ប្រសិនបើរដ្ឋពឹងផ្អែកដល់វត្ត គឺសូមឲ្យព្រះសង្ឃជួយបណ្ដុះចិត្តថ្លើមប្រជាកសិករឲ្យនិយមរាប់អានអ្នកបច្ចេកទេស, ឲ្យខំយកចិត្តទុកដាក់ស្ដាប់សេចក្ដីពន្យល់ និងខំអនុវត្តតាមសេចក្ដីណែនាំនៃអ្នកបច្ចេកទេសទាំងឡាយ ។ ខ្ញុំយល់ថា ការអភិវឌ្ឍន៍របស់រដ្ឋមុខជាចេញរួចមិនខាន ព្រោះស្ថាប័នសង្ឃជាមួយនិងពលរដ្ឋជាប្រជាកសិករហើយជាពុទ្ធសាសនិក លោកធ្លាប់ធ្វើការជាមួយមានប្រសិទ្ធភាពមកហើយ ។ ខ្ញុំចូលចិត្តថា ការរួមដៃរវាងព្រះសង្ឃនិងឃរាវាស ប្រសិនបើធ្វើកើតតាមទម្លាប់ ដែលសង្គមខ្មែរយើងធ្លាប់ធ្វើមកហើយ វាអាចផ្ដល់ប្រយោជន៍ឲ្យទាំងសងខាង ទាំងរដ្ឋ ទាំងពុទ្ធសាសនា គឺខាងពុទ្ធសាសនាក៏បានមានមុខងារធ្វើពលិកម្មឲ្យរដ្ឋ ខាងរដ្ឋក៏មានពំនាក់ពំនឹងលើពុទ្ធសាសនា ។ ធាតុទាំងពីរបានធ្វើប្រយោជន៍ដល់គ្នានិងគ្នាទៅវិញទៅមក សមតាមព្រះគំនិតនៃព្រះពុទ្ធបរមគ្រូរបស់យើងក្នុងចំណុចថា ធម្មៈជាធាតុសម្រាប់រំដោះទុក្ខសត្វលោក ព្រះសង្ឃជាបុគ្គលអនុវត្តធម្មៈ និងជាស្រែបុណ្យនៃសកលមនុស្ស ។ រដ្ឋជានីតិបុគ្គលទទួលស្គាល់ធម្មៈ, ប្រតិបត្តិធម្មៈ និងទំនុកបម្រុងគណៈសង្ឃតាមគួរដល់កម្លាំង នៅក្នុងក្របខ័ណ្ឌនៃយុត្តិធម៌របស់សង្គមមនុស្ស និងសន្តិភាពនៃសកលជីវិត ។

# បទទី ៩

# បង្រៀនឲ្យប្រើសតិបញ្ញាដំណោះទុក្ខ

«ព្រះពុទ្ធសាសនា បង្រៀនសង្កត់ធ្ងន់លើសតិបញ្ញា ក្នុងទំរើរបស់ជីវិត ។ ឲ្យចេះកម្ចាត់សេចក្ដីទុក្ខ ដោយពិចារណាឲ្យឃើញដើមហេតុរបស់ទុក្ខ ហើយធ្វើកំណែនិងសម្រាយ ឲ្យត្រឹមត្រូវតាមសេចក្ដីពិត មិនឲ្យជឿ ឬប្រកាន់យកផ្លូវដោះស្រាយយ៉ាងធូរៗងាយៗ ប្រាសចាកហេតុផល» ។

ក្នុងចំណុចទី ១, ដែលថា ពុទ្ធសាសនាបង្រៀនសង្កត់ធ្ងន់លើសតិបញ្ញានោះ ។ «សតបញ្ញា» ក្នុងទីនេះប្រែមកពីពាក្យអង់គ្លេសថា «INTELLIGENCE» ។ បើនិយាយតាមភាសាសាសនាសតិបញ្ញា មិនមែនជាគូនិងគ្នាទេ ។ ព្រះពុទ្ធសាសនារបស់យើង បានប្រើសតិនិងសម្បជញ្ញៈជាគូនិងគ្នា ដោយបានឲ្យឈ្មោះធម៌នេះថា ជាធាតុមានឧបការៈច្រើន ដែលមានចែងក្នុងគម្ពីរអង្គុត្តរនិកាយទុក្កនិបាត ដូចយើងបានស្ដាប់គ្រប់គ្នាមកហើយ ។ ចំណែកសតិនិបញ្ញាលោកពុំបានប្រើជាគូ, តែលោកប្រើជាពួក នឹងមានក្នុងសំនេរខាងមុខ ។

ពាក្យថា «សតិនិងបញ្ញា» ប្រែមកពីពាក្យថា INTELLIGENCE នោះ ប្រសិនបើយើងចង់ប្រើជាពាក្យពុទ្ធសាសនាសុទ្ធ យើងប្រើតែបញ្ញាក៏បានណាស់ទៅហើយ ព្រោះបញ្ញាល្អ ឬបញ្ញាពិតៗ ដែលគម្ពីរអភិធម្មយើងបានឲ្យឈ្មោះថា «សោភណចេតសិក» នោះ ត្រូវមានសតិទៅក្នុងនោះផងដែរ ដែលលោកឲ្យឈ្មោះម៉្យាងទៀតថា បញ្ញាជាសហគតៈជាមួយនិងសតិ ។ អ្នកអាននឹងបានដឹងរឿងនេះជាថ្មី តាមសំនេររបស់ខ្ញុំក្នុងខាងមុខ ។ ដើម្បីដឹងជាបន្ទាន់, ខ្ញុំសូមអ្នកអានសង្កេតថា ធម្មៈជាទូទៅនៃពុទ្ធសាសនាមិនមានធម្មៈណាស្ដីដល់ជំនឿ ហើយគ្មានស្ដីដល់បញ្ញាផងទេ ។ សទ្ធានិងបញ្ញាត្រូវបានជាប់ទាក់ទងជាមួយគ្នាយ៉ាងណា សតិនិងបញ្ញាក៏ត្រូវបានជាសហគតៈធម៌និងគ្នាយ៉ាងនោះដែរ ព្រោះចេតសិកធម៌ទាំងអស់នេះ ត្រូវបានចាត់ចូលក្នុងសោភណចេតសិកដូចគ្នា ។

## ជំនឿមានបញ្ញាជាសហគតៈ

ដើម្បីឲ្យបានជាល័ខឋាន ឬគោលការណ៍ជាក់លាក់, ខ្ញុំសូមស្នើគំនោលធម្មៈ ដែលមានសតិនិងបញ្ញាត្រូវបានជាប់គូគ្នា ឬរួមសហប្រតិបត្តិការគ្នា តាមដែលខ្ញុំបានរកឃើញមានដូចនេះ :

១- សម្បរាយិកត្ថៈ ប្រយោជន៍អនាគត ឬពំនោលមួយទៀតថា ធម្មៈជាហេតុធ្វើឲ្យមនុស្សអ្នកអនុវត្តបានសម្រេចនូវអនាគតសុខ ឬបេលោកសម្បត្តិ ដែលកម្រនឹងរកបានមាន ៤ ប្រការគឺ :

១- សទ្ធាសម្បទា ដល់ព្រមដោយជំនឿ,

២- សីលសម្បទា ដល់ព្រមដោយសីល,

៣- ចាគសម្បទា ដល់ព្រមដោយការបរិច្ចាគ (ពលិកម្ម),

៤- បញ្ញាសម្បទា ដល់ព្រមដោយបញ្ញា ។

២- ធម្មៈដែលធ្វើឲ្យមនុស្សមានសេចក្ដីក្លាហាន (**វេសារជ្ជករណធម៌**) មាន ៥ ប្រការគឺ :

១- សទ្ធា ជឿរបស់ដែលគួរជឿ,

២- សីល រក្សាកាយវាចាឲ្យរៀបរយ,

៣- ពហុសច្ចៈ ភាពជាអ្នកបានស្ដាប់ត្រាប់ត្រងច្រើន,

៤- វីរិយារម្ភៈ ប្រារព្ធសេចក្ដីព្យាយាម,

៥- បញ្ញា ចេះដឹងជុំវិញរបស់ដែលគួរដឹង ។

៣- ធម្មៈដែលកម្លាំង (ពលៈ) និងជាធំ (ឥន្ទ្រីយ៍) មាន ៥ ប្រការគឺ :

១- សទ្ធា ជឿរបស់ដែលគួរជឿ,

២- វីរិយៈ សេចក្តីព្យាយាម,

៣- សតិ សេចក្តីរឭកបាន (ចាំបាន),

៤- សម្មាសមាធិ សេចក្តីតាំងចិត្តមាំមួន,

៥- បញ្ញា ការចេះដឹងជុំវិញហេតុការណ៍ ។

៤- ទ្រព្យប្រសើរ (អរិយទ្រព្យ) មាន ៧ ប្រការគឺ :

១- សទ្ធា ជឿរបស់ដែលគួរជឿ,

២- សីល រក្សាកាយវាចាឲ្យរៀបរយ,

៣- ហិរិ ខ្មាសអៀនចំពោះទំរើបាបទុច្ចរិត,

៤- ឱត្តប្បៈ ស្លុតខ្លាចចំពោះទំរើបាបទុច្ចរិត,

៥- ពាហុសច្ចៈ ភាពជាបុគ្គលបានឮបានស្តាប់ច្រើន,

៦- ចាគៈ លះកាត់ដើម្បីធ្វើអំណោយ,

៧- បញ្ញា ចេះដឹងស្គាល់របស់ដែលមានប្រយោជន៍ និងគ្មានប្រយោជន៍ ។

៥- ធម្មៈរបស់មនុស្សល្អ (សប្បុរសធម៌) មាន ៧ ប្រការគឺ :

១- សទ្ធា ជឿរបស់ដែលគួរជឿ,

២- ហិរិ ខ្មាសអៀនចំពោះទំរើបាបទុច្ចរិត,

៣- ឱត្តប្បៈ ស្លុតចំពោះទំរើបាបទុច្ចរិត,

៤- ពាហុសច្ចៈ ភាពជាបុគ្គលបានឮបានស្តាប់ច្រើន,

៥- វីរិយៈ ព្យាយាម,

៦- សតិ រឭក,

៧- បញ្ញា ចេះដឹងច្រើន ។

អ្នកសិក្សាគប្បីធ្វើសេចក្តីសង្កេតថា សតិនិងបញ្ញានៅកៀកហើយជិតដិតជាមួយគ្នា, តែមិនមែនជាគូនិងគ្នាទេ គឺមានតំណែងជាពួកនៃគ្នានិងគ្នា ។ ចំណែកសទ្ធានិងបញ្ញាជាសហគតៈធម៌ ក្នុងសហប្រតិបត្តិការដូចដែលយើងធ្លាប់បានដឹង ធ្លាប់បានធ្វើការកត់សម្គាល់មកហើយ ។

ការហាមឃាត់មិនឲ្យដាក់ជំនឿ ចូលទៅក្នុងផ្លូវប្រាសចាកហេតុផល ដែលអាចធ្វើឲ្យខុស ឬឲ្យភ្លាត់ចាកសេចក្តីពិតមាន ១០ ប្រការ ដែលពុទ្ធសាសនិកស្ទើរតែគ្រប់គ្នាធ្លាប់បានដឹងមកហើយ ។ ពុទ្ធភាសិតនេះមានមកក្នុងកាលាមសូត្រ ដែលខ្ញុំបានធ្វើសំនេរមកម្តងហើយ ។ ដើម្បីពង្រឹងគំនិត និងទំនាត់ចោលនូវគំហើញខុសរបស់អ្នកអាន នឹងឲ្យទៅជាធម្មៈមានលក្ខណៈពេញលេញដូចបានអាងមកហើយ, ខ្ញុំសូមសរសេរឡើងវិញទៀតមានដូខចនេះគឺ :

១- កុំជឿ ដោយបានឮតៗគ្នាមក,

២- កុំជឿ តាមល្បីល្បាញ,

៣- កុំជឿ តាមដំណឹងដែលចេញពីមាត់មួយទៅមាត់មួយ,

៤- កុំជឿ ដោយផ្អែកអាងទៅលើតម្រាក្បួនខ្នាត,

៥- កុំជឿ ដោយគូសដៅយកខ្លួនឯង,

៦- កុំជឿ ដោយគ្មានគ្នេគិតប៉ាន់ស្មាន,

៧- កុំជឿ ដោយត្រិះរិះគយគន់តាមអាការៈប្រហាក់ប្រហែល,

៨- កុំជឿ ដោយសម្អាងថាស្របគំនិត ឬសមតាមគំហើញរបស់ខ្លួន,

៩- កុំជឿ ដោយអាង ឬឃើញថាអ្នកឲ្យយោបល់ធ្លាប់មានកេរ្តិ៍ឈ្មោះគួរឲ្យជឿបាន,

១០- កុំជឿ ដោយរាប់អានថាអ្នកនេះជាគ្រូរបស់ខ្លួន ។

ព្រះសម្មាសម្ពុទ្ធ បានធ្វើសេចក្ដីបញ្ជាក់បន្ថែមទៀតថា «កាលណាខ្លួនអ្នកបានដឹងដោយខ្លួនឯងថា ធម្មៈទាំងឡាយនេះជាអកុសលមានទោស អ្នកប្រាជ្ញលោកតិះតិះដៀល ។ អ្នកប្រាថ្នាសេចក្ដីសុខ, កាលណាប្រព្រឹត្តប្រតិបត្តិធម៌នេះ ។ ការប្រព្រឹត្តប្រតិបត្តិរបស់ខ្លួន មិនត្រឹមតែមិនបានផ្ដល់សេចក្ដីសុខឲ្យប៉ុណ្ណឹងទេណ ។ គឺត្រឡប់ជាផ្ដល់ឲ្យនូវសេចក្ដីវិនាស និងសេចក្ដីទុក្ខទៀតផង ។ អ្នកត្រូវលះបង់ធម្មៈនេះចោលឲ្យអស់ ទើបសេចក្ដីសុខកើតមានដល់ខ្លួន ។ ទន្ទឹមគ្នានេះ, ធម្មៈទាំងឡាយណាគ្មានកំហុស, គ្មានប្រកបដោយទោស អ្នកប្រាជ្ញទាំងឡាយលោកសរសើរ ។ កាលណាខ្លួនអ្នកបាន ប្រព្រឹត្តប្រតិបត្តិតាម ឬបានអនុវត្តរមែងផ្ដល់ឲ្យនូវប្រយោជន៍ និងសេចក្ដីសុខជាទីពេញចិត្តរបស់ខ្លួន, អ្នកត្រូវខំរស់នៅជាមួយធម្មៈទាំងឡាយនោះគ្រប់ពេលវេលា» ។ ធម្មៈមានទំនាក់ទំនងប្រហាក់ប្រហែលគ្នានេះ មិនមែនមានតែក្នុងកាលាមសូត្រមួយទេ សូត្រទាំងឡាយដទៃទៀតមានភទ្ទិយសូត្រជាដើម ក៏មាននិយាយដូចនេះដែរ ។

ពុទ្ធឱវាទនេះ, បសិ្ចមជនគេមានការចាប់អារម្មណ៍ច្រើន ហើយគេប្រកាន់យកជាគំនិតស្រាជ្រាវ រកសេចក្ដីពិតដែលគេយល់ថា ត្រូវតាមគំនោលនៃវិទ្យាសាស្ត្រយ៉ាងច្បាស់លាស់ផង ។

## ជឿអ្នកដទៃឬជឿខ្លួនឯង

មានបញ្ហាចោទឡើងថា : បើយើងនិយាយតាមគោលគំនិតកាលាមសូត្រ ព្រះពុទ្ធសាសនាហាក់ដូចជាមិនបានបង្រៀនឲ្យពុទ្ធសាសនិក ឬមនុស្សទូទៅ ជឿអ្នកដទៃក្រៅពីខ្លួនឯងឡើយ ។ ដូចនេះបញ្ហាស្មុគស្មាញនឹងចេះតែមានតទៅទៀតគ្មានឈប់ទេ ព្រោះសេចក្ដីលំបាកលំបិន ដែលកំពុងកើតក្នុងលោកសព្វថ្ងៃ ឬដែលនឹងកើតតៗទៅក្នុងអនាគតនោះ ក៏ព្រោះមនុស្សមានជំនឿតែក្នុងខ្លួនឯង មិនព្រមស្ដាប់មតិ ឬសំឡេងអ្នកដទៃផងឡើយ ។ ន័យមួយទៀត, ដែលថា ពុទ្ធសាសនាជាប្រជាធិបតេយ្យ ស្ដាប់សំឡេងភាគខាងច្រើនជាប្រមាណ គឺពិភាក្សារឿងអ្វីៗបើមានមតិចែកគ្នាជាពីរពួក ឬច្រើនជាងនេះ ត្រូវសម្រេចយកជាបានការតាមមតិភាគច្រើន ។ ទ្រឹស្ដីនេះដូចជាស្រួលស្ដាប់ ស្រួលយល់ ហើយងាយដល់ការអនុវត្តផង, តែដល់បន្ថែមថា មនុស្សត្រូវជឿខ្លួនឯង នៅក្នុងគំនិតប្រកបដោយហេតុផលមកទៀត ។ រឿងនេះ, ដូចជាមិនអាចបញ្ចប់សំណួរនិងចំងល់បានឡើយ ។

បញ្ហាដែលគេយល់ថា លំបាក ឬមានសេចក្ដីស្មុគស្មាញនោះវាពិតជាអឺចឹងមែនហើយ ព្រោះរឿងនេះវាធ្លាប់មានការប្រឆាំងប្រទាំងប្រទើសគ្នាយូរមកហើយ, តែប្រសិនបើគេយល់ពុទ្ធចិន្ដាថា ជាធាតុមានលក្ខណៈជាវិទ្យាសាស្ត្រ ឬមានលក្ខណៈប្រកបដោយហេតុផលនោះ ភាពលំបាក និងភាពស្មុគស្មាញរបស់គេក្នុងរឿងនេះវាពុំអាចប្រព្រឹត្តទៅបានទៀតទេ ។ ដើម្បីជាពន្លឺដល់អ្នកអាន ខ្ញុំសូមឲ្យគំនិតដូចមានតទៅនេះគឺ :

ពំនោលក្នុងចំណុចថា ពុទ្ធសាសនាបង្រៀនមនុស្សតាមបែបយ៉ាងប្រជាធិបតេយ្យ ឬបង្រៀនតាមគោលគំនិតជាប្រជាធិបតេយ្យ ឬបង្រៀនមានលក្ខណៈជាប្រជាធិបតេយ្យនោះ គេមិនត្រូវភ្លេចថា ធាតុប្រជាធិបតេយ្យរបស់ពុទ្ធសាសនា គឺជាប្រជាធិបតេយ្យនៅក្នុងក្របខ័ណ្ឌនៃសីលធម៌ ឬនិយាយម៉្យាងទៀតថា គឺប្រជាធិបតេយ្យដែលមានលក្ខណៈជាប្រជាធិបតេយ្យពិតៗផង មានលក្ខណៈជាធម្មាធិបតេយ្យមែនៗផង ។ ជាពិសេសប្រជាធិបតេយ្យដែលមានធម្មាធិបតេយ្យជាមូលដ្ឋាន ។ គឺមតិភាគច្រើន ដែលបានទុកដាក់ជាគោលគំនិតនៃការអនុម័ត ឬការវិនិច្ឆ័យនៅក្នុងក្របខ័ណ្ឌនៃធម៌វិន័យ ឬច្បាប់រដ្ឋ ទើបយកជាបានការ ។ ប្រសិនបើគំនិតភាគច្រើនមិនប្រកាន់យកធម្មវិន័យ

ឬច្បាប់រដ្ឋជាបន្ទាត់នៃការអនុម័ត ក៏ពុំអាចអនុវត្តកើត ពុំអាចយកជាបានការឡើយ ។ ដោយអាស្រ័យហេតុនេះ, ទើបពុទ្ធសាសនា កាលណាមានបើកសម័យប្រជុំ លោកតម្រូវឲ្យស្នើញត្តិ ឬស្នើយោបល់ ដោយសូត្រប្រកាសឲ្យបានច្រើនដងដើម្បីទុកឲ្យសមាជិកប្រជុំ មានពេលត្រិះរិះពិចារណាឲ្យបានល្អិតល្អន់មធ្យ័ត, មុននឹងបញ្ចេញមតិថា «ទេ» ឬ «អើ» យ៉ាងណាក៏ដោយចុះមតិភាគច្រើនត្រូវតែមានភាពត្រឹមត្រូវ, មានប្រសិទ្ធភាពជាងមតិភាគតិច ។ ដូចនេះ, ទើបព្រះសម្មាសម្ពុទ្ធ ព្រះអង្គបដិសេធមតិបុគ្គល ឬគណៈ ហើយយកមតិសង្ឃជាមតិវិនិច្ឆ័យដាច់ខាត ។ ព្រោះអ្វី? ព្រោះមតិភាគច្រើនទោះជាដូចម្ដេចម្ដា ក៏គង់មានប្រសិទ្ធភាព មានពន្លឺជាងមតិភាគតិចជានិច្ច ។ ប្រសិនបើអង្គប្រជុំមានសមត្ថភាពប្រហាក់ប្រហែលគ្នា, តែបើភាគច្រើនមានសមត្ថភាពទន់ខ្សោយជាងភាគតិចនោះ បញ្ហាមុខជាមិនឈប់ចោទទេ ។ ដោយអាស្រ័យហេតុនេះ, ទើបពុទ្ធសាសនាទាញស្មារតីអ្នកវិនិច្ឆ័យ ឲ្យលះបង់អគតិធម៌ ៤ ។ ខ្ពស់ជាងនេះគឺហាមជនល្ងង់មិនឲ្យធ្វើការតំណាងជាតិ ។

ចំណុចមួយទៀត, ពុទ្ធសាសនាបានសរសើរបុគ្គលដែលមានការសិក្សាច្រើន មានបញ្ញាវាងវៃពីកំណើត មានការពិសោធក្នុងការងារ មានគំនិតប្រកបដោយពន្លឺក្នុងគតិលោក គតិធម៌ មានចាំបាច់ក្នុងការអនុវត្តបានទទួលផលល្អច្រើនលើក ច្រើនគ្រាមកហើយ មានជីវិតរស់នៅក្នុងព្រហ្មវិហារធម៌យូរមកហើយ ។ ជាមួយគ្នានេះ, ខ្លួនយើងជាមនុស្សរស់នៅលើបង្អែកនៃគំនិត ជាក់លាក់ច្បាស់លាស់ដែលពុទ្ធសាសនាចង់ថា **«អបរបច្ចយោ»** ប្រែថា មនុស្សរស់នៅដោយគ្មានអ្នកដទៃជាបច្ច័យ ។ ក្នុងន័យថា, គេគ្មានជំនឿ គ្មានសេចក្ដីទុកចិត្ត លើគំនិតគំហើញរបស់អ្នកដទៃ ដែលចេះតែបញ្ចេញយោបល់តាមអារម្មណ៍ តាមកម្លាំងបាយរបស់ខ្លួនគ្មានត្រូវតាមសេចក្ដីពិត ។ ដូចនេះ ព្រោះអ្វី? ព្រោះខ្លួនគេជាមនុស្សមានគំនិតភ្លឺ, មានយោបល់ស្វាង ដែលគេធ្លាប់បានធ្វើការពិសោធឃើញច្បាស់ព្រមទាំងធ្លាប់បានអនុវត្តចេញផលល្អមកហើយ ។ មនុស្សដែលគ្មានបានដឹងអ្វីដោយខ្លួនឯង, ដំណឹងអ្វីៗចាំតែគេប្រាប់ គេនិយាយ គេពន្យល់ ។ មនុស្សផុននេះគ្នាមានជីវិតរស់នៅឆ្ងាយពីពន្លឺ នៃសេចក្ដីពិតពន់ពេកណាស់ ។ ដូចនេះ ពុទ្ធភាសិត **«វីរិយេន ទុក្ខ មច្ចេតិ»** គេឆ្លងអន្លង់ទុក្ខបានដោយអាស្រ័យសេចក្ដីព្យាយាម ដែលមានបញ្ញាជាដៃគូនោះ ។ ភាសិតនេះបានសង្កត់ធ្ងន់លើកំហំនិងពន្លឺ ប្រសិនបើយើងអនុវត្តភាសិតនេះបានប្រជាធិបតេយ្យក្ដី ធម្មាធិបតេយ្យក្ដី នឹងមានវឌ្ឍនភាពដល់ទិសដៅរបស់មនុស្សជាមិនខាន ដរាបណាគេខំស្រាវជ្រាវសាកល្បងពិសោធឲ្យឃើញសេចក្ដីពិត ដោយខ្លួនឯងរឿយៗ លុះត្រាបានជួបសេចក្ដីពិត ឬភាពភ្លឺស្វាងដោយខ្លួនឯង ។ ដរាបនោះទើបគេមានជំនឿមួយបែប ដែលមិនចាំបាច់អាស្រ័យការគូសដៅ ឬស្ដាប់សេចក្ដីបំភ្លឺរបស់អ្នកដទៃ ។ នេះជាគុណសម្បត្តិពិសេសរបស់មនុស្ស ដែលពុទ្ធសាសនាត្រូវការចង់បាន ។ តែអស់រយៈកាលយូរណាស់មកហើយ មនុស្សបែបនេះនៅតែមានមិនច្រើនដដែល ។ តើដល់ពេលណាទៅទើបខ្មែរយើងមានប្រជាធិបតេយ្យ និងធម្មាធិបតេយ្យ សម្បូរបាន ។

ជាបុគ្គលាធិដ្ឋាន, ខ្ញុំសូមលើកយកតួយ៉ាង ២.៣ មកប្រកបរឿង, ដើម្បីឲ្យអ្នកសិក្សា មានគំនិតយោបល់សេចក្ដីច្បាស់លាស់មានដូចនេះ :

តួយ៉ាងសន្មតជា : បុរសឈ្មោះក, មិនធ្លាប់បរិភោគផ្លែទុរេនដល់ម្ដងណាសោះ បើគេឲ្យឈ្មោះក, ធ្វើសេចក្ដីបំភ្លឺអំពីរសជាតិទុរេន, ឈ្មោះកអាចបំភ្លឺគេបានដោយសេចក្ដីដៅស្មាន តាមបានឮអ្នកដទៃនិយាយប្រាប ។ តែបើឲ្យឈ្មោះខ, ដែលធ្លាប់អាស្រ័យផ្លែទុរេនធ្វើសេចក្ដីបំភ្លឺវិញ ទោះណាជាមានសេចក្ដីមិនច្បាស់លាស់ ដូចខ្លួនឯងដឹងក្នុងពេលទទួលទានផ្លែទុរេន ក៏គង់មានសេចក្ដីងាយស្ដាប់ ឬចូលចិត្តបានច្រើនជាងឈ្មោះក, ដែលគ្នាធ្វើសេចក្ដីបំភ្លឺដោយគ្មានបានដឹងរសជាតិទុរេនសោះហ្នឹងដែរ ។

តួយ៉ាងទី ២, ឈ្មោះក, មិនធ្លាប់បានទៅប្រទេសអាមេរិកដល់ម្ដងណាឡើយ, តែបានដឹងដោយសារអ្នក

ធ្លាប់ទៅគេនិយាយប្រាប់ថា យ៉ាងដូចនេះ យ៉ាងដូចនោះ ។ ដំណឹងនេះបើប្រៀបធៀបទៅនឹងឈ្មោះខ, ដែលគេធ្លាប់បានទៅស្រុកអាមេរិក ឃើញថាខុសគ្នាឆ្ងាយណាស់ ។ ដូចនេះ, ការជឿខ្លួនឯងល្អ ឬជឿអ្នកដទៃល្អ ត្រូវបានជាកម្មវត្ថុនៃការពិចារណាសម្រាប់ខ្លួនយើងទាំងអស់គ្នា ។

តួយ៉ាងទី ៣, ឈ្មោះក, អានអក្សរខ្លួនឯងមិនចេញ ត្រូវមានអ្នកដទៃអានជំនួស ។ ឈ្មោះខ, អានអក្សរខ្លួនឯងចេញ អ្នកទាំងពីរនាក់ បើយើងលើកយកមកប្រៀបធៀបតម្លៃគ្នា តើអ្នកណាគ្រាន់បើជាងអ្នកណា? នេះក៏ជាកម្មវត្ថុរបស់យើងក្នុងការវាយតម្លៃ នៃជនទាំងពីរនាក់នេះទៀតដែរ ។ ដើម្បីជាពន្លឺខ្ញុំសូមបញ្ជាក់ថា ជំនឿខ្លួនឯងក្រោយដែលគេបានពិសោធក្រោមបន្ទាត់នៃហេតុផល នៃវិចារណញ្ញាណ ឃើញបានច្បាស់តាមសេចក្តីពិតហើយជំនឿនេះជាធាតុល្អបំផុត ជាជំនឿគ្មានលាយឡំដោយចម្ងល់ ជាជំនឿដែលគេចូលចិត្តដោយខ្លួនគេ, ជាជំនឿដែលគេឃើញច្បាស់ដោយខ្លួនគេ ។ ជាមួយនឹងជំនឿបែបនេះ គេគ្មានការសម្គាល់ខុស គ្មានគំនិតស្រម័យ គ្មានភាពងងឹតនិងភាពគ្មានជាក់លាក់ ដែលពុទ្ធសាសនាហៅថា ជំនឿមានបញ្ញានៅខាងក្នុង ឬជំនឿប្រកបដោយពន្លឺដែលវិឞ្ញូជន និងអរិយជន ត្រូវការចង់បាន ។ និយាយខ្លីៗ គឺជំនឿមានបញ្ញាត្រួតត្រា មានពន្លឺគំនិតជួយបំភ្លឺផ្លូវដែលយើងអាចឲ្យឈ្មោះម៉្យាងទៀតថា ជំនឿមានកំណើតដោយអាស្រ័យចំបាស់របស់ខ្លួន ពុំមែនដោយអាស្រ័យពំនោលរបស់អ្នកដទៃ ។

## ចំណុចដែលគេត្រូវដឹងក្នុងរឿងបញ្ញា

ដើម្បីឲ្យឃើញថាបញ្ញា កាលបើរួមចូលជាមួយនិងធម៌ដទៃៗ ហើយដែលលោកបានឲ្យពន្ធុច្រើនជាងធម៌ទាំងឡាយដទៃ ព្រោះលោកមានគំហើញយ៉ាងណានោះ ក្រៅពីមើលឡើងវិញឲ្យឃើញថា សទ្ធាដែលមានបញ្ញាជាចង្កូត ឬជាចំរាន ឬជាទំនប់ដូចបានពោលមកហើយ ខ្ញុំសូមស្នើធម្មៈផ្នែកដទៃៗទៀតមានដូចនេះ :

### ១- ជាលំដាប់នៃការប្រតិបត្តិធម៌ ៣ ថ្នាក់

### (អនុបុព្វបដិបទា)

១- សីល រក្សាកាយវាចាឲ្យមានរបៀបរៀបរយ,

២- សមាធិ ធ្វើចិត្តឲ្យមានលំនឹងមាំមួន,

៣- បញ្ញា ធ្វើខ្លួនឲ្យមានសេចក្តីចេះដឹងច្រើន ។

### ២- ការអប់រំចិត្ត ២ ថ្នាក់

### (ភាវនា)

១- សមថភាវនា អប់រំសមាធិ,

២- សមថវិបស្សនា អប់រំបញ្ញា ។

### ២- រូបរួមលំខណ្ឌានដែលលើកតម្កើងបញ្ញា

១- មនុស្សដែលរស់នៅក្នុងលោកនេះ អ្នកមានទំរើប្រកបដោយបញ្ញា រមែងរកឃើញនូវសេចក្តីសុខដែលមាននៅក្នុងសេចក្តីទុក្ខ,

២- បញ្ញាជាពន្លឺរស្មី,

៣- បញ្ញាជាដួងកែវនៃជីវិតរបស់នរជន,

៤- សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងមានជីវិតរុងរឿងដោយបញ្ញា,

៥- បណ្ឌិតទាំងឡាយមានពំនោលថា បញ្ញាប្រសើរបំផុតដូចដួងចន្ទប្រសើរជាងដួងផ្កាយទាំងឡាយ, គុណធម៌ទាំងឡាយមានសីលធម៌ជាដើម របស់ជនអ្នកប្រព្រឹត្តធម៌ល្អរមែងជារបស់ប្រព្រឹត្តទៅតាមអ្នកមានបញ្ញា

(គឺបញ្ញាមាន, ហើយជាគុល្លដទៃៗ ដណ្ដើមជើងគ្នាដើរតាមបញ្ញា),

៦- អ្នកប្រាជ្ញទាំងឡាយស្ដីថា ជីវិតរបស់បុគ្គលរស់នៅដោយបញ្ញា, ជាជីវិតប្រសើរបំផុត,

៧- បញ្ញាគ្រប់គ្រងរក្សាមនុស្ស មានភាពស័ក្ដិសិទ្ធជាងអ្វីៗ ទាំងអស់,

៨- បញ្ញាដែលបុគ្គលមានហើយ ជាហេតុឲ្យគេទម្លាយកិលេសចោលបាន,

៩- បញ្ញាកើតបានដោយអាស្រ័យសេចក្ដីព្យាយាម,

១០- កាលណាបុគ្គលឃើញដោយបញ្ញាថា សង្ខារទាំងពួងមិនទៀង, ជាទុក្ខ ធម៌ទាំងពួងមិនមែនខ្លួនប្រាណ កាលនោះគេរមែងមានចិត្តធុញក្នុងទុក្ខ ។ នេះឯងគឺជាផ្លូវនៃសេចក្ដីបរិសុទ្ធ,

១១- បុគ្គលល្ងង់មានជីវិតរស់នៅ ១០០ ឆ្នាំ ពុំប្រសើរស្មើនឹងបុគ្គល ដែលមានជីវិតរស់នៅត្រឹមតែមួយថ្ងៃ, តែមានបញ្ញា ។

អាគតស្ថាននិងគុណភាពនៃបញ្ញា ដែលលើកយកមកបរិយាយដោយសង្ខេបនេះ បញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនាប្រកាន់យកបញ្ញាជាធំ ជាគុណធម៌សំខាន់ ព្រោះបញ្ញាជាចង្កៀង ឬជាពន្លឺនៃជីវិត, ឬជាធាតុនាំផ្លូវនៃវិញ្ញាណឲ្យចេញចាកទីងងឹតទៅកាន់ទីភ្លឺស្វាង ។ ព្រមគ្នានេះ, បញ្ញាជួយគ្រងរក្សាមនុស្សឲ្យរស់នៅក្នុងសេចក្ដីសុខ, ជួយកម្ចាត់ទុក្ខចាស់ និងជួយការពារទុក្ខថ្មី ។ ជាពិសេសជួយរកសេចក្ដីសុខ ដែលកប់នៅក្នុងសេចក្ដីទុក្ខជូនបញ្ញាជនបានគ្រប់ពេលវេលា ។

ប្រសិនបើមនុស្សយើង មិនស្គាល់សេចក្ដីពិតដោយបញ្ញា ឬដោយពន្លឺនៃគំនិត គេអាចសម្គាល់ទុក្ខថាជាសុខ, តែបើកាលណាគេមានបញ្ញា គេលែងច្រឡំ លែងចូលចិត្តខុស, គឺលែងច្រឡំទុក្ខថាជាសុខ ដូចធ្លាប់មានក្នុងកាលមុនហើយ ។

## បញ្ញា ២

១- លោកិយបញ្ញា　　បញ្ញាថ្នាក់លោកិយ,

២- លោកុត្តរបញ្ញា　　បញ្ញាថ្នាក់លោកុត្តរ ។

## បញ្ញា ២ ទៀត

១- សេក្ខបញ្ញា　បញ្ញារបស់បុគ្គលដែលនៅមានការសិក្សាទៀត,

២- អសេក្ខបញ្ញា　　បញ្ញារបស់បុគ្គលដែលអស់មានការសិក្សាទៀត ។

## បញ្ញា ៣

១- ចិន្តមយបញ្ញា　　បញ្ញាកើតពីគំនិត,

២- សុត្តាមយបញ្ញា　　បញ្ញាកើតអំពីសណ្ដាប់,

៣- ភាវនាមយបញ្ញា　　បញ្ញាកើតអំពីអប់រំ ។

## បញ្ញា ៣ ទៀត

១- អាយកោសល　　ចំលាតក្នុងភាពចម្រើន,

២- អបាយកោសល　　ចំលាតក្នុងភាពសូន,

៣-

## សតិជាគូនិងបញ្ញា

ដូចបាននិយាយមកហើយក្នុងសប្បុរសធម៌ (ធម៌មនុស្សល្អ) កម្រងធម៌នេះ មានសតិនិងបញ្ញានៅជាមួយគ្នា ឬជាគូគ្នា ។ ខ្មែរយើងខ្លះចូលចិត្តថា ការមានតែសតិក៏គឺមានតែចាំ តែគ្មានចេះ, ការមានតែបញ្ញាក៏គឺមានតែចេះ

តែគ្មានចាំ ។ អ្នកខ្លះមានមតិថា សតិសម្បជញ្ញៈមិនមែនជាធម៌អ្វីដទៃទេគឺសតិនិងបញ្ញាបូកគ្នាហ្នឹងឯង ។

## បញ្ញា ៤

១- ស្គាល់ទុក្ខ,

២- ស្គាល់ហេតុនៃទុក្ខ,

៣- ស្គាល់ភាពរលត់ទុក្ខ,

៤- ស្គាល់ផ្លូវប្រតិបត្តិឲ្យដល់ភាពរលត់ទុក្ខ ។

អ្នកសិក្សាគប្បីធ្វើសេចក្ដីសង្កេតថា ពុទ្ធសាសនាពុំបានប្រកាន់យកបញ្ញា ដែលមានមកអំពីកំណើតដែលយើងធ្លាប់ហៅថា សេចក្ដីវៃឆ្លាតទុកជាបញ្ញាជាន់ខ្ពស់, តែប្រកាន់យកបញ្ញា ដែលគេបានធ្វើឲ្យកើតដោយអាស្រ័យការគិត ការសិក្សានិងការប្រតិបត្តិធម៌ ឬការអនុវត្តទុកជាបញ្ញាជាន់ខ្ពស់បំផុត ដែលអាចជួយចម្លងមនុស្សឲ្យផុតទុក្ខបាន ។ ដូចនេះព្រោះអ្វី? ព្រោះសេចក្ដីវៃឆ្លាតជារបស់ដែលមនុស្សយើងមាននោះ មានភាពមិនដូចគ្នាទេ ។ ចំណែកបញ្ញាប្រភេទដែលគេអប់រំឲ្យកើតបាននោះ ជាធាតុដែលមនុស្សរាល់រូបមានសិទ្ធិ សិក្សារៀនសូត្រស្រាវជ្រាវនិងប្រតិបត្តិ ឬអនុវត្តឲ្យកើត ឲ្យមានស្រេចហើយតែសេចក្ដីត្រូវការរបស់ខ្លួន ។ បញ្ញា ឬសេចក្ដីវៃឆ្លាតពីកំណើតដែលមិនអាចប្រើការបានជាស្ថាពរ ឬគ្មានភាពឋិតនៅអស់ចិរកាលនោះ ក៏មានទំនាក់ទំនងមិនខុសគ្នា នឹងភ្លើងធម្មជាតិទាំងឡាយមានភ្លើងពញរៃជាដើម ដែលគេមិនអាចនឹងប្រើភ្លើងនោះ ឲ្យបានប្រយោជន៍គ្រប់ពេលវេលាដែលត្រូវការ ។ ដោយអាស្រ័យភាពមិនឋិតថេរនៃភ្លើងទាំងឡាយនេះហើយ ទើបបានមនុស្សយើងបង្កើតឈើគូសដែកភ្លើងរហូតដល់អគ្គិសនី និងគ្រឿងឧបករណ៍របស់អគ្គិសនី ដើម្បីយកភ្លើងប្រើឲ្យបានគ្រប់ឱកាសដែលត្រូវការ ។ សូម្បីបញ្ញាញាណនៃព្រះសម្មាសម្ពុទ្ធព្រះអង្គឯង ក៏ពុំមែនបានមកដោយទំរើផ្សងព្រេងឡើយ គឺកើតឡើងដោយអាស្រ័យសេចក្ដីព្យាយាម ជាមួយនិងការតស៊ូយ៉ាងប្ដូរផ្ដាច់ទើបបានសម្រេចក្នុងទីបំផុត ។ ពុទ្ធសាសនាមិនបានបង្រៀនមនុស្សឲ្យដេកចាំទទួលសេចក្ដីសុខ ដែលផ្ដល់ឲ្យដោយធម្មជាតិ ឬដោយអាទិទេព ឬរង់ចាំជោគវាសនាដែលឫក្សយាម ថ្ងៃ ខែ ឆ្នាំ ល្អផ្ដល់ឲ្យឡើយ ។ ពុទ្ធសាសនាបង្រៀនមនុស្សឲ្យធ្វើការគ្រប់យ៉ាង នៅក្នុងក្របខ័ណ្ឌនៃគំនិតបញ្ញា ឬក្របខ័ណ្ឌនៃហេតុផល ដើម្បីទទួលយកផលដែលមានគុណភាពខ្ពស់ សមតាមសេចក្ដីប្រាថ្នារបស់ខ្លួន ។ ពុទ្ធសាសនាគ្មានបានបង្រៀនឲ្យធ្វើជោគវាសនារបស់ខ្លួនលើគ្នាឯង ឬលើពួកទេពណាឡើយ ។

មតិនេះមានសម្អាងលើគម្ពីរអដ្ឋកថា ទុក្កនិបាត អង្គុត្តរនិកាយ ក្នុងចំណុចថា ការខ្វះសម្បជញ្ញៈ គឺគ្មានញាណ ឬបញ្ញា ។

## ការប្រើបញ្ញាដំណោះទុក្ខ

ពុទ្ធសាសនាមានជំនឿថា ដំណោះទុក្ខជាបញ្ហាសំខាន់ ហើយជាទិសដៅយ៉ាងខ្ពស់បំផុតរបស់បុគ្គលអ្នកឃើញទោសនៃសេចក្ដីទុក្ខ ។ ចំពោះបញ្ហានេះអ្នកផងសឹងបានឃើញហើយថា ទ្រឹស្ដីអរិយសច្ចៈ ៤ ប្រការ គឺទ្រឹស្ដីដំណោះទុក្ខយ៉ាងចំៗ, តែជាទ្រឹស្ដីមានភាពចម្លែកជាងធម្មតា ។ គឺទ្រឹស្ដីធម្មតាវាជារឿងនៃគំនិតប្រកាន់យក ឬទំរើសាកល្បងរៀបចំឲ្យមានជាគោលការណ៍មុន ទើបធ្វើការពិសោធជាខាងក្រោយ ។ តែទ្រឹស្ដីអរិយសច្ចៈរបស់ព្រះសម្មាសមពុទ្ធ មិនមែនជាគំនិតយល់សប្ដិ ឬគំនិតត្រិះរិះគ្មាន់គ្នេរ ហើយប្រកាន់យក ឬអនុវត្តទេ គឺព្រះអង្គបានប្រើជីវិតរបស់ព្រះអង្គឯង ជាដើមធាតុក្នុងការសាកល្បងស្រាវជ្រាវ លុះត្រាបានសម្រេចផល បានរួចផុតចាកទុក្ខទាំងពួងពិតប្រាកដហើយ ទើបបានប្រកាសទ្រឹស្ដីនេះចេញមក, ព្រមគ្នានេះបានធ្វើសេចក្ដីថ្លែងការណ៍បញ្ជាក់ថាដរាបណាព្រះអង្គមិនបានរកឃើញសេចក្ដីពិត ឬប្រតិបត្តិធម៌មិនបានសម្រេចផលដោយខ្លួនឯង ។ ព្រះអង្គនឹងមិនធ្វើសេចក្ដីប្ដេជ្ញាជាដាច់ខាតថា ព្រះអង្គជាព្រះពុទ្ធបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណឡើយ ។

ព្រោះហេតុដូចនេះ, ការពិចារណាដល់កំណៃ ឬដំណោះនៃសេចក្តីទុក្ខតាមលំអាននៃពុទ្ធសាសនា យើងត្រូវពិចារណាដោយត្រង់ៗចំៗ ទៅលើអរិយសច្ចៈមួយចំណែក ។ ជាមួយគ្នានេះគេត្រូវប្រើគោលការណ៍ និងគោលគំនិតនៅក្រោមខ្សែបន្ទាត់នៃអរិយសច្ចៈ ដើម្បីចម្អិនបញ្ហារឿយៗប្រកបដោយព្យាយាមយ៉ាងក្លាហានមោះមុត ។

## ក- កំណៃទុក្ខតាមគំនោលអរិយសច្ចៈ

១- មុនដំបូងឲ្យស្គាល់ថា អ្វីជាភាពទុក្ខ, ពេលខ្លះគេចូលចិត្តត្រឡប់ត្រឡន់សុខជាទុក្ខ ឬឃើញទុក្ខជាសុខ ។ ដូចនេះទើបគេត្រូវប្រកាន់គោលការណ៍ថា ទុក្ខមាន ៣ បែប គឺទុក្ខប្រចាំ បានដល់សេចក្តីកើត សេចក្តីចាស់ សេចក្តីឈឺ សេចក្តីស្លាប់ ។ ទុក្ខចរ, បានដល់សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីមិនសប្បាយកាយ សេចក្តីមិនសប្បាយចិត្ត សេចក្តីចង្អៀតចង្អល់ ។ល។

២- ឲ្យស្គាល់ថា អ្វីជាដើមហេតុរបស់ទុក្ខ, មានមនុស្សច្រើនណាស់ដែលមានប្រាថ្នាចង់រំដោះទុក្ខ ឬធ្វើកំណៃទុក្ខ ។ តែកំណៃរបស់គេ ពុំបានធ្វើដល់ដើមហេតុនៃទុក្ខ ត្រឡប់ជាររើរវាយទៅធ្វើលើផលនៃទុក្ខទៅវិញ ។ ដូចនេះ, ទើបកំណៃរបស់គេ វាទៅជាគ្មានបានផល បានប្រយោជន៍អ្វីគឺវានៅជាទុក្ខជាព្រួយដដែល ។ល។

៣- ឲ្យស្គាល់ភាពរលត់ទុក្ខថា បានដល់អ្វី ឬមានអ្វីជាធាតុសម្រាប់រម្លត់ទុក្ខ ។ ពុទ្ធសាសនាបានបង្ហាញផ្លូវថា ការរម្លត់ទុក្ខ មិនមែនរម្លត់ផលទេ, គឺត្រូវរម្លត់ហេតុ ។ បើរម្លត់តែផល ហេតុនៅដដែល ទុក្ខនឹងកើតឡើងទៀត ។ ដូចនេះ, ការរម្លត់ទុក្ខក្នុងទីនេះ គឺត្រូវរម្លត់ហេតុ បានដល់តណ្ហាទាំង ៣ ឲ្យបានដាច់ខាត ។

៤- ឲ្យស្គាល់ថា ភាពរលត់ទុក្ខមិនអាចនឹងកើតបានស្រួលៗធូរៗទេ ត្រូវមានការប្រតិបត្តិធម៌ឲ្យដល់នូវភាពរលត់ទុក្ខ ។ សេចក្តីប្រតិបត្តិនោះលោកហៅថា **មជ្ឈិមាបដិបទា** ។

(សេចក្តីពិស្តារនៃរឿងនេះ មានក្នុបទដទៃខ្លះហើយ បើមិនទាន់គ្រប់គ្រាន់តាមសេចក្តីត្រូវការ មេត្តាមើលសៀវភៅនិព្វានទស្សនៈ និងសៀវភៅទស្សនៈសកលរបស់ខ្ញុំបរកបផង) ។

កាលណាមានរឿងកើតទុក្ខ រឿងអស់សង្ឃឹម រឿងមិនសមតាមប្រាថ្នា សូមឲ្យនឹកជានិច្ចដល់ព្រះពុទ្ធតម្រាស់ថា តណ្ហាជាហេតុឲ្យកើតទុក្ខ ។ គំនិតនេះនាំឲ្យកើតបញ្ញា បង្រៀនខ្លួនឯងឲ្យចេះសន្តោស ចេះបន្ធូរបន្ថយចំណង់ក្នុងទីបំផុតសេចក្តីអផស្សុក ស្អុះស្អាប់ក្រវល់ក្រវាយចិត្ត បានត្រូវរលាយបាត់បន្តិចម្តងៗ, រហូតដល់សូន្យបាត់ក៏មាន ប្រសិនបើគេបានអនុវត្តមគ្គ ៨ ប្រការអស់ពីកម្លាំងនិងសមត្ថភាពក្នុងពេលនោះ ។ល។

ចំពោះរឿងសេចក្តីស្នេហា, ព្រះសម្មាសម្ពុទ្ធ បានមានព្រះតម្រាស់ថា ស្នេហាមួយមានទុក្ខមួយ, ស្នេហាមួយរយ, មានទុក្ខមួយរយ ។ល។ អ្នកណាថាមិនពិត ឬមានយោបល់ទំនាស់នឹងពុទ្ធតម្រាស់នេះ ក៏ស្រេចតែក្បាលចិត្តរបស់គេចុះ ។ គំនិតខ្ញុំឃើញថា ពុទ្ធតម្រាស់នេះ បើទុកដាក់ជាគណិតសាស្ត្រក៏បាន ព្រោះខាងគណិតសាស្ត្រតែងតែមានស៊ីមានសង ឬបើនឹងទុកដាក់ជាគ្រឿងប្រដាប់សម្រាប់ទប់ សម្រាប់ហាមក៏បាន ព្រោះបើគ្មានគ្រឿងប្រដាប់ហាមកង់ កង់ក៏មិនឈប់វិល រថយន្តក៏មិនឈប់បុក ឬភ្លូក ។ ចំណែកចិត្តមនុស្សវិញ, បើគ្មានធម្មៈសម្រាប់ទប់សម្រាប់ហាម សេចក្តីស្នេហាក៏មិនឈប់កើត ទុក្ខក៏មិនឈប់មាន ។ បើសេចក្តីស្នេហារបស់មនុស្សកាន់តែដើហួសព្រំដែន ម្នាក់ណាក៏ដូចជាម្នាក់ណា ពិភពលោកត្រូវតែឆេះដោយ **រាគគ្គិ** នៃប្រជាសត្វមិនខាន ។ ពំនោលនេះត្រូវចម្រើនលើពុទ្ធភាសិតថា : «គ្មានភ្លើងណាមានកម្តៅជាងភ្លើងស្នេហាគ្មានព្រំដែន, គ្មានស្កប់ ។ គ្មានកំហុសណាមានពិសកំណាចជាងកំហុសនៃកំហឹង ។ គ្មានសំណាញ់ណា មានជំនាប់មាំមួនជាងសំណាញ់គឺកម្លៅ ។ គ្មានស្ទឹងណាហូរជាប់អត់ឈប់ដូចស្ទឹងគឺស្នេហា» **«នត្ថិ រាគ សមោ អគ្គិនត្ថិ ទោសោ សមោគហោ នត្ថិ មោហ សមំ ជាលំ នត្ថិតណ្ហា សមា នទី»** មួយទៀត, «គ្មានភ្លើងណាមានកម្តៅខ្លាំងក្លាជាងសេចក្តីស្នេហាអត់មានចប់អត់មានព្រំដែន គ្មានកំហុសភ្លាំងភ្លាត់ណាបង្កើតគ្រោះថ្នាក់ស្មើដោយទោស គ្មានទុក្ខណាញាំញីកម្ទេចមនុស្សស្មើ

ដោយខន្ធ ៥ គ្មានស្នឹងណាហូរជាប់អស់កាលជានិរន្តរ៍ ស្មើដោយស្ទឹងគឺស្នេហាគ្មានចប់, គ្មានទីបំផុត **«នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសោ សមោ កលិ នត្ថិ ខន្ធា សមោ ទុក្ខា នត្ថិ តណ្ហា សមា នទី»** ជីវិតទាសៈនៃសេចក្តីស្នេហា (តណ្ហា) ឃើញពិភពលោកមានទំហំតូច, មានភាពចង្អៀត ។ ជីវិតសន្តោស (ស្កប់ចិត្ត) ឃើញពិភពលោកមានទំហំធំ មានសភាពទូលំទូលាយ ។ ពិភពលោកកើតសង្គ្រាមដោយភ្លើងរាគៈ ទោសៈ មោហៈ ដែលអាស្រ័យនៅក្នុងចិត្តមនុស្ស ឬដែលមានចិត្តសត្វលោកជាជើងក្រាន ។ ពិភពលោកមានសន្តិភាពដោយអាស្រ័យសេចក្តីសន្តោស ដែលមាននៅក្នុងចិត្តមនុស្ស ឬដែលមានចិត្តសត្វលោកជាលំនៅឋាន ។ ពិភពលោកមានសេចក្តីចម្រើនរុងរឿង ដោយអ្នកសាសនា ឬអ្នកវិទ្យាសាស្ត្រ មានចិត្តជាកុសល ឬរស់នៅក្នុងព្រហ្មវិហារធម៌ ។ ពិភពលោកវិនាស ដោយអ្នកសាសនា ឬអ្នកវិទ្យាសាស្ត្រ គ្មានសីលធម៌, គ្មានអនុវត្តព្រហ្មវិហារធម៌ ឬមានចិត្តជាអកុសល ។ល។

## ខ- កំណែទុក្ខដោយអនុលោមតាមគំនោលអរិយសច្ចៈ

គំនិតដែលនាំបង្កើតមនោសញ្ចេតនា អផ្សុកធុញទ្រាន់, ព្រោះមើលឃើញអ្វីៗទាំងអស់ សុទ្ធតែជាទុក្ខជាលំបាកនោះ, គំនិតបែបនេះប្រាកដជាមិនមែន ។ មនុស្សខ្លះឃើញលោកជាទុក្ខ ជាលំបាកគ្រប់ពេល សឹងត្រូវតាមគំនោលនៃអរិយសច្ចៈក្នុងចំណុច **«ទុក្ខ»** ហើយ, តែគ្មានគំនិតអនុវត្តកំណែនៃអរិយសច្ចៈក្នុងចំណុច **«មគ្គ»** ឡើយ ។ បានត្រឹមតែដេកគងថ្ងាស រអ៊ូរទាំត្អូញត្អែរតិះដៀលលោក រហូតដល់អាទិទេពសាងលោកថា បង្កើតលោកមកសម្រាប់តែធ្វើឲ្យមនុស្សកើតទុក្ខ កើតព្រួយ ។ គំនិតនេះបានខុសស្រឡះ នឹងគំនិតពុទ្ធសាសនារបស់យើង, ព្រោះពុទ្ធសាសនាដែលបង្កើតឡើង ដោយព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គបានឲ្យចម្លើយថា ពិភពលោកមួយអន្លើនិងវត្ថុទាំងឡាយដែល កើតជាមួយនិងពិភពលោករួមទាំងមនុស្សសត្វផង ទោះបីជាកើតដោយខ្លួនឯងក្តី កើតដោយមានអ្នកបង្កើតក្តី, រឿងនេះវាហួសអស់ទៅហើយ គិតទៅ, ខឹងទៅ, ជេរទៅក៏វាគ្មានប្រយោជន៍អ្វីដែរ ។ របស់ដែលគេត្រូវគិត ត្រូវធ្វើ ត្រូវនិយាយនោះ គឺការអនុវត្តការងារភ្លាមៗ ដើម្បីគាស់រម្លើងទុក្ខ, បណ្តុះដំណាំសុខឯងនេះវិញទេ ។ល។

## អផ្សុកក្នុងពេលនឹកដល់សេចក្តីស្លាប់

មនុស្សខ្លះ, មានចិត្តប្រាសប្រាលឆ្ពោរក្រមាល់អស់កាលជានិច្ច, មិនថានឹកដល់អ្វីជារឿងអ្វីឡើយ ឲ្យតែរឿងរបស់ពិភពលោក ។ កាលណាដុំគំនិតរបស់គេបានប៉ះទង្គិច នឹងដុំពិភពលោកមួយអន្លើនិងរបស់ទាំងឡាយដែលមានជំនាប់កំណើតជាមួយនិងពិភពលោក ។ គំនិតអស់សង្ឃឹមនិងគំនិតសុញ្ញ ហាក់ដូចជាស្រែកអំពាវនាវឲ្យគេឈប់ធ្វើសកម្មភាពទាំងអស់ ដែលខ្លួនគេធ្លាប់មាន ។ ជាមួយគ្នានេះទៀត, គំនិតកំសោយ, គំនិតគ្មានអាល័យរស់និងគំនិតគ្មានសង្ឃឹម វាបានខ្សឹបប្រាប់ថា មិនកើតទេ ! មិនស្រួលទេ ! ឈប់ធ្វើអ្វីៗទៅ មិនយូរប៉ុន្មានទេ សេចក្តីស្លាប់នឹងមកដល់ហើយ ព្រោះអ្វីៗទាំងអស់រួមទាំងជីវិតរបស់មនុស្សផង វាមានដំណាក់ចុងក្រោយ គឺរលាយសូន្យនិងស្លាប់បាត់ដូចគ្នា ។ នៅខាងក្រោយសូន្យក្រោយស្លាប់, មានតែភាពទទេ, ភាពវាលធេងល្ហល្ហេវ ។ ដូចនេះ, គំនិយក្តី ទំរើក្តី ពំនោលក្តី របស់មនុស្សទាំងឡាយ វាត្រឹមតែធាតុធម្មតា មិនមែនជាសត្វ, មិនមែនជាជីវិត, មិនមែនជាគ្មានសូន្យនៅក្នុងទីបំផុតទេ ។ តើយើងខំនាំគ្នាបង្កើតគំនិត, ទំរើ, ពំនោលគ្រប់បែប គ្រប់យ៉ាងហ្នឹងធ្វើអ្វី? គំនិតទាលច្រកនិងគំនិតសុញ្ញនេះ វាមិនត្រឹមតែជិះជាន់វិញ្ញាណឲ្យធ្លាក់ចុះ ក្នុងអន្លង់ទុក្ខធំៗទាំងឡាយមានកើត ចាស់ ឈឺ ស្លាប់ ។ល។ កាន់តែញឹកឡើង ច្រើនឡើងប៉ុណ្ណឹងទេ ។ បន្ថែមមកលើនេះទៀត, គឺវាប្រានវិញ្ញាណមនុស្សឲ្យធ្លាក់ក្នុងអន្លង់ទិដ្ឋិ (គំនិតយល់ខុស) លុះត្រាលែងដឹង លែងយល់ លែងធ្វើនូវទំរើរដោះទុក្ខតាមក្បួនអរិយសច្ចៈទាំងអស់ ដែលប្រកាសឲ្យអនុវត្តដោយព្រះសម្មាសម្ពុទ្ធ ។ តែគេឃើញពួកនេះ, នៅមានសកម្មភាពបន់ស្រន់

សុំជំនួយអំពីពួកទេព, សុំសេចក្ដីអនុគ្រោះភាពប្រោសប្រាណ អំពីព្រះអរិយមេត្តេយ្យ (ព្រះសិអារ្យមេត្រី) ឲ្យព្រះអង្គប្រញាប់មកគ្រាស់ស្រោចស្រង់មនុស្សលោក នៅក្នុងក្របខ័ណ្ឌនៃសេចក្ដីអង្វរក ជាមួយនឹងពាក្យឧទានគ្រប់ពេលវេលាថា «ពុទ្ធោអើយ ! ឆាប់ៗឡើងព្រះគុណម្ចាស់ថ្លៃខ្ញុំ» ។

## សំណួរដេញដោល

ដូចបាននិយាយមកហើយ ករណីយ៍ពុទ្ធសាសនិក គឺត្រូវដុសខាត់ឲ្យគំនិតរបស់ខ្លួនមានពន្លឺ ត្រូវខំកាច់បំបាក់មនោសញ្ចេតនារបស់ជនដែលមានគំនិត ច្រឡំដឹកនាំឲ្យសង្គមមានទុក្ខ, ត្រូវកុំគាំទ្រនូវហេតុដែលនាំឲ្យមានទុក្ខ ត្រូវខំរកផ្លូវ ឬមធ្យោបាយ ឬប្រមូលសតិបញ្ញាទាំងអស់ មកធ្វើការបកស្រាយន័យរបស់អរិយសច្ចៈ ឲ្យខ្លួនមានភាពជាក់លាក់ច្បាស់លាស់ ដើម្បីឲ្យចម្លើយដល់មនុស្សមានចម្ងល់ក្នុងអរិយសច្ចៈដូចមានតទៅនេះ :

១- អ្វីជាហេតុទាក់ទាញចិត្តយើង ឲ្យកើតគំនិតអផ្សុក? (ក្នុងចំណុចនេះសូមឲ្យរាវរកចម្លើយដែលនឹកឃើញថា នៅជិតអរិយសច្ចៈ ឬជុំវិញអរិយសច្ចៈ)

២- គំនិតដូចនេះ កើតពីអាយុប៉ុន្មាន? (បើមិនប្រាកដជាក់លាក់ដោយឆ្នាំ ក៏ឲ្យបានជារយៈប្រមាណ)

៣- គំនិតដូចនេះ កើតឡើងម្ដងៗ គឺកើតហើយបាត់ទៅ ឬកើតជាប់គ្នាៗ ឬយូរៗទើបកើតម្ដងមួយគ្រា?

៤- បើរយៈកាលដែលគំនិតនេះកើតឡើង ហើយរលាយបាត់ទៅវិញមានមែន តើធ្លាប់បានសង្កេតខ្លះ ឬទេថា រាល់ពេលដែលវាកើតឡើង វាកើតឡើងឯងៗ ឬមានអ្វីទាក់ទាញឲ្យវាកើតឡើង?

៥- ហេតុទាក់ទាញចិត្តឲ្យកើតគំនិតបែបនេះ បើស្រាវជ្រាវរកឃើញ ដើម្បីចំណាត់ជាប្រភេទឲ្យដឹងថា ហេតុណាជាប្រភេទណា? ដូចហេតុការណ៍មួយ ទាក់ទងគ្នានឹងសង្គ្រាម, ដំណឹងមរណៈភាពរបស់មនុស្សខ្លះ ឬពាក្យពេចន៍ទង្គិចគ្នា ដែលបានឮពីបុគ្គលផ្សេងៗ ឬនៅស្ងៀមព្រងើយៗនឹកឃើញខ្លួនឯង

៦- បើគំនិតបែបនេះកើតឡើង វាមានអំណាចលើចិត្តយើង ដោយប្រការទាំងពួង គឺបង្កបង្កើតឲ្យមានដំណុកដំណាន់សំអុះសំអាប់ ដោយគ្មានផ្លូវធ្វើកំណែបាន ឬនៅមានផ្លូវធ្វើកំណែបានខ្លះដែលនឹកឃើញខ្លួនឯង?

៧- គំនិតដែលធ្វើឲ្យខ្លួនឯងកើតទុក្ខដូចនេះ, តើចាត់ជាគំនិតល្ងង់ ឬគំនិតចេះ? (សូមព្យាយាមគិតមុនឲ្យបានល្អិតល្អន់មធ្យ័តទើបឲ្យចម្លើយបានល្អ)

៨- បើជាគំនិតល្ងង់, តើយើងសុខចិត្តឲ្យគំនិតល្ងង់នេះនៅរហូតទៅ? ឬត្រូវរកផ្លូវធ្វើកំណែ ដើម្បីកម្ចាត់ចោលនូវគំនិតល្ងង់នេះ?

៩- បើជាគំនិតចេះ, តើយើងត្រូវបានប្រយោជន៍អ្វីពីគំនិតនេះខ្លះ? ប្រសិនបើគ្មានប្រយោជន៍អ្វីដល់យើងរហូតទៅ, តើយើងត្រូវរក្សាទុកនូវគំនិតឆ្លាតគ្មានឲ្យប្រយោជន៍នេះតទៅទៀតឬទេ?

១០-គំនិតបែបនេះ មានចំណែកទាក់ទងមកពីពេញចិត្តរស់នៅម្នាក់ឯង មិនចូលចិត្តរស់នៅជាមួយជនដែរហូតដល់មិនស្រឡាញ់ការសមាគម ជាមួយនិងអង្គការនានាមែនឬទេ? បើមែន តើយើងត្រូវធ្វើកំណែខ្លួនចូលមកកាន់ការសមាគម, ការស្ដាប់ទេសន៍, ការរួមធ្វើសន្និសីទ ការស្ដាប់បាឋកថា ការទេសចរ ការហាលអាកាស ការសម្រាកព្រលឹងក្នុងរមណីយដ្ឋាននានា ។ល។ ដើម្បីឲ្យធម្មជាតិទាំងឡាយជួយកម្ចាត់ ហេតុនិងវត្ថុជុំវិញរបស់យើង ដែលគំនិតយើងយល់ថា អាក្រក់ ឬទំនាស់និងមនោសញ្ចេតនារបស់យើង នៅក្នុងក្របខ័ណ្ឌនៃការរបាយអារម្មណ៍នៃការបន្ទូរបរិយាកាស នៃការរម្លាយដុំគំនិតដូរចត់ ដែលបានធ្វើឲ្យវិញ្ញាណ បានក្លាយភាពជាមានរបួសស្លាកស្នាម ដោយស្វ័យប្រវត្តិ ដែលយើងខ្លួនឯងគ្មានដឹងសោះបានឬទេ?

១១- កាលណាបើគំនិតតានតឹងឆេះឆួលក្ដួលក្ដៅកើតឡើងក្នុងទ្រូង ឬក្នុងខួរក្បាលយើងយ៉ាងនេះហើយ តើជម្ងឺតក់ម៉ក់របស់ចិត្ត និងជម្ងឺចុកចាប់របស់រូបកាយយើង វាអាចកើតមានបានដែរឬទេ?

កាលបើយើងបានតាំងសំណួរ ជាមូលដ្ឋានដូចនេះហើយ, គំនិតរបស់យើងនឹងអាចឲ្យចម្លើយមួយម្តងៗ នៅក្នុងក្របខ័ណ្ឌនៃបញ្ញារបស់ខ្លួនដូចនេះ ដូចនោះខ្លះជាមិនខាន ។ ចម្លើយនេះ, យើងត្រូវធ្វើសំនេរទុកក្នុងសៀវភៅមួយ ដើម្បីធ្វើវិភាគទានដល់វិញ្ញាណរបស់យើងក្នុងពេលដែលភ្លេច ឬច្រឡំ ។ល។

## ហេតុផលនៃកខ្វែងពំនោល

ដើម្បីរកទ្វារចេញចាកទុក្ខ យើងត្រូវប្រមូលសតិបញ្ញាដែលម្នាក់ៗធ្លាប់មាន តាមផ្លូវគំនិតក្តី សណ្តាប់ក្តី ចម្រើនក្តី ហើយផ្តុំកម្លាំងគ្នា ជួយរកមធ្យោបាយតស៊ូជាមួយនិងគំនិតប្រឆាំង ដែលធ្វើយើងឲ្យកើតទុក្ខ កើតកម្តៅរឿយៗ ។ ដើម្បីបានសម្រេចតាមគំនិតនេះ, ជាដំបូងយើងត្រូវសមយោបល់ សមពំនោលគ្នា គឺធ្វើយ៉ាងណាឲ្យកង្វែងរបស់យើង បានដល់នូវភាពស្របគ្នាសិន ។ ព្រោះអ្វី? ព្រោះថាក្នុងចំណោមគ្នាយើង ដែលកំពុងព្យាយាមតស៊ូដើម្បីគាសរម្លើងនូវហេតុនៃទុក្ខ (សមុទយៈ) ក៏កំពុងខ្វែងពំនោល ខ្វែងយោបល់គ្នាក្នុងចំណុចខ្លះៗ ដោយអាស្រ័យគំនិតបញ្ញា ដែលខ្លួនយើងម្នាក់ៗ មានពុំទាន់ស្មើគ្នា ។ ដូចនេះ, ការរុករក ឬការរុលឲ្យដល់ទិសដៅសម្រាប់មនុស្សមានកម្លាំងមិនស្មើគ្នា, ខ្ញុំគ្មានឃើញផ្លូវណាដទៃ ក្រៅពីជួយយឹតយោងគ្នាដូចមនុស្សទូទៅក្នុងពិភពលោក គេធ្លាប់បានធ្វើមកហើយ ។ ប្រសិនបើអ្នកសិក្សាមានគំនិតឃើញដូចខ្ញុំដែរ សូមមេត្តាត្រិះរិះពិចារណាជាមួយគ្នាដូចនេះ :

«សេចក្តីស្លាប់មិនមែនជាភាពសោះសូន្យទេ ព្រោះចាប់ដើមតាំងពីមានមនុស្ស នៅលើពិភពលោកយើងនេះមករយៈពេលដែលកន្លងទៅ មិនដឹងជាមានប៉ុន្មានលានឆ្នាំទេ ។ អ្នកប្រាជ្ញខាងភូមិសាស្ត្រ និងបូរាណសាស្ត្រខ្លះគ្រាន់តែបានធ្វើសេចក្តីប៉ាន់ស្មានថា ពិភពលោកមានអាយុប្រមាណជាងពីរពាន់លានឆ្នាំហើយ ។ មនុស្សកើតមកមានចំនួនប៉ុន្មាន, មនុស្សស្លាប់ក៏មានចំនួនប៉ុណ្ណោះជាប់គ្នារឿយៗមក គ្មានឃើញមនុស្សណាម្នាក់ បានគេចផុតពីសេចក្តីស្លាប់បាន ។ ប្រសិនបើយើង ធ្វើលេខរកចំនួនមនុស្សដែលស្លាប់ទៅហើយ ឲ្យដឹងថាមានចំនួនប៉ុន្មានខ្ទង់ដើងលេខ ។ លទ្ធផលគឺគ្មានខ្ទង់លេខ, គ្មានចំនួនដែលអាចត្រាបានថា ប៉ុណ្ណោះ ប៉ុណ្ណោះឡើយ ។ តែមនុស្សនៅតែកើតមានពូជពន្ធុំជាប់តគ្នាហូរហែមក មនុស្សខ្លះមិនត្រឹមតែកើត មិនត្រឹមតែមានផៅសន្តានជាប់តគ្នា មកប៉ុណ្ណោះទេ ។ បន្ថែមលើនេះទៀត គឺមានមនុស្សរឭកជាតិបានដឹងថា ខ្លួនធ្លាប់កើតក្នុងជាតិមុនឈ្មោះដូចនេះ មានប្រពន្ធកូនប៉ុណ្ណោះ ប៉ុណ្ណោះ មានឈ្មោះយ៉ាងនេះ យ៉ាងនោះ នៅស្រុកនេះ ស្រុកនោះ ។ល។ ហេតុការណ៍ទាំងអស់នេះ, រឿងខ្លះត្រូវបានគេធ្វើសំណួរ សាមីខ្លួនមានលក្ខណៈជាវិទ្យាសាស្ត្រ ឬគំនោលនៃវិទ្យាសាស្ត្រ ។ ជាមួយគ្នានេះ, គេបានយកចម្លើយទាំងដែលសាមីខ្លួនបានធ្វើអំណោយ មកសរសេរជាសៀវភៅក៏មាន ។ មានមនុស្សអ្នកស្រាវជ្រាវរឿងនេះជាច្រើនរយបានរួមគំនិតគ្នា ចតរូបបញ្ជាក់ល័ខឋានសឹងមានលក្ខណៈគួរឲ្យជឿបាន គួរឲ្យប្រកាន់យកទុកជាកម្មវត្ថុសម្រាប់ត្រិះរិះពិចារណាក៏មានច្រើន ។ គម្ពីរពុទ្ធសាសនាខ្លះក៏មាននិយាយ ទាក់ទងដល់រឿងមនុស្សរឭកជាតិបាន ។ នៅក្នុងប្រទេសភាគខាងលិច (អឺរុប) និងប្រទេសភាគខាងកើត (អាហ្ស៊ី) ក៏មានតួយ៉ាងបញ្ជាក់អំពីមនុស្សរឭកជាតិបាន មានចំនួនមិនតិចឡើយ» ។

«សេចក្តីស្លាប់ ប្រសិនបើគំនិតក្នុងវិស័យមួយផ្សេងទៀត, ក៏មិនគួរយើងនាំគ្នាខ្លាច លុះត្រាតែមានកង្វល់កង្វាយច្រើនពេកទេ ។ ដូចនេះព្រោះអ្វី? ព្រោះត្រឹមតែជាក្បួនតម្រារបស់ធម្មជាតិ ឬរបស់វត្ថុ ដែលធ្វើអំណោយ ឬធ្វើវិភាគទាន កម្ទេចរបស់ចាស់ដែលប្រើមិនកើតចោល ដើម្បីបើកឱកាស ឬប្រគល់កន្លែងឲ្យរបស់ថ្មី ដែលត្រូវមកជំនួសប៉ុណ្ណោះ ។ ប្រសិនបើយើងសាកល្បងនឹកមើលថា បើពិភពលោកនេះគ្មានសេចក្តីស្លាប់ គឺមនុស្សដែលកើតមកក្នុងសម័យរាប់លានឆ្នាំមកហើយ រស់នៅទាំងអស់ ! តើយើងមានកន្លែងធ្វើការរកស៊ីឬទេ? ចម្លើយគ្មាន ! បើមានក៏បានត្រឹមតែដេកគរជើងលើគ្នាប៉ុណ្ណោះ ។ តើយើងរស់កើតទេ? មិនកើត ! និយាយខ្លីៗគ្មានស្លាប់, គ្មានកើតល្អ ចប់រឿងគ្មានបញ្ហាចោទ ។ មានតែកើតគ្មានស្លាប់ពិភពលោកយើង នឹងពេញណែនណាន់តាន់តាប់ គ្មានដីធ្វើផ្ទះនៅ គ្មានដី

ធ្វើរបររកស៊ីចិញ្ចឹមជីវិត គ្មានល្អ គ្មានចប់រឿង បញ្ហាតាមចោទជាប់មួយហើយ មួយទៀត ដោះគ្មានរួច រួចហើយចោទទៀតគ្មានទីបំផុត»

«សេចក្តីស្លាប់គឺជាទំរើទម្លាក់ចោលរបស់ដែលប្រើលែងកើត, ដាក់ចូលរបស់ដែលប្រើកើតជំនួស, មិនខុសគ្នានឹងចំណោលអាហារចាស់ ហើយចំណួលអាហារថ្មីជំនួស ដែលយើងកំពុងធ្វើគ្រប់គ្នាសព្វថ្ងៃ ហើយដែលពាក្យធម្មតាថា «ស៊ីជុះ» គឺបើយើងស៊ីរាល់ថ្ងៃ យើងក៏ត្រូវជុះរាល់ថ្ងៃដែរ ។ នេះគឺជាក្បួនទំរើធម្មជាតិ ដែលធ្វើឲ្យពិភពលោកឋិតនៅក្នុងភាពល្មម, មិនគួរយើងនាំគ្នាតក់ស្លុតភិតភ័យពេកទេ, ព្រោះយើងក៏មានដំណើរប្រព្រឹត្តទៅតាមក្បួនធម្មជាតិដូចតែគ្នា» ។

«ចំពោះពុទ្ធសាសនា, រឹតតែបង្រៀនមិនឲ្យយើងគិតដល់សេចក្តីស្លាប់ ប្រកបដោយភាពស្លុតស្លន់, តែឲ្យមានសេចក្តីក្លាហាន ប្រកបដោយសេចក្តីព្យាយាមយ៉ាងមោះមុត នៅក្នុងក្របខ័ណ្ឌនៃការងារ គឺខំកម្ចាត់បង់ទំរើអាក្រក់ សាងសន្សំទំរើល្អឲ្យកាន់តែអស់ទៅ, ឲ្យកាន់តែកើតច្រើនឡើង ។ កុំរស់នៅអួតពិភពលោកដោយយោបំដោយតំងួ, ជាមួយគ្នានេះទៀត កុំស្លាប់ទៅទទេៗ ដោយគ្មានបានធ្វើប្រយោជន៍អ្វីដល់ខ្លួនឯងនិងពិភពលោក ។

រួមសេចក្តីថា : កាលណាយើងមានបញ្ញាគ្រប់គ្រាន់ហើយ យើងអាចធ្វើកំណែទុក្ខបាន យើងមើលឃើញផ្លូវរម្លត់ទុក្ខ ។ នេះឯងគឺជាដំណោះស្រាយនៃបញ្ហាជីវិត តាមគំនិតនៃអរិយសច្ចធម៌ ដែលប្រកាសដោយព្រះសម្មាសម្ពុទ្ធបរមគ្រូ ។

# បទទី ១០
# ពឹងខ្លួនឯងនិងច្បាប់នៃកម្ម

«ពុទ្ធសាសនាបង្រៀនឲ្យចេះពឹងខ្លួនឯង នៅក្នុងក្របខ័ណ្ឌនៃគុណធម៌ល្អ, ដើម្បីលើកកម្ពស់នៃជីវិត ទាំងផ្លូវសម្ភារៈ ទាំងផ្លូវធម្មៈ ។ មិនបង្រៀនឲ្យស្វែងរកសេចក្តីល្អ ឬប្រយោជន៍គ្រប់យ៉ាង ដោយទំរើបន់ស្រន់ប្រកបដោយគំនិតកម្លៅ ។ គោលគំនិតបង្រៀននេះ ជាហេតុឲ្យកើតគោលការណ៍ ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ដែលហៅថា ច្បាប់នៃកម្ម (LAW OF KAMA) ជាធាតុមួយមានហេតុផលទាក់ទាញ ព្រលឹងអន្តរជាតិឲ្យមានជំនឿ មានការនិយាយរាប់អានយ៉ាងច្រើន» ។

ក្នុងចំណុចនេះ បានបញ្ជាក់ឲ្យឃើញថា ពុទ្ធសាសនាត្រូវការឲ្យមនុស្ស ធ្វើខ្លួនឯងជាមនុស្ស ចង់ធ្វើអ្វីធ្វើកើតខ្លួនឯង គ្មានចាំបាច់ត្រូវពឹងច្រមុះអ្នកដទៃដកដង្ហើមឡើយ ។ ដើម្បីជាពន្លឺអ្នកអានគប្បីពិចារណាដូចនេះគឺ :

១- ពុទ្ធសាសនាបង្រៀនឲ្យពឹងខ្លួនឯង ក្នុងការប្រកបគុណធម៌ប្រសើរថ្លៃថ្នូរគ្រប់យ៉ាង,

២- បង្រៀនឲ្យពឹងខ្លួនឯង ក្នុងការលើកកម្ពស់នៃជីវិតរបស់ខ្លួនក្នុងវត្ថុទូទៅ (វឌ្ឍនធម៌),

៣- មិនបង្រៀនឲ្យរុករកសេចក្តីល្អ ឬវឌ្ឍនភាពនៃជីវិត ដោយប្រើគំនិតបន់ស្រន់បួងសួង,

៤- បង្រៀនឲ្យចូលចិត្តច្បាប់នៃកម្ម ឬឲ្យមានពន្លឺក្នុងទំរើបរបស់ខ្លួន ។

ដើម្បីជាជំនួយដល់អ្នកសិក្សា ខ្ញុំសូមធ្វើសេចក្តីវែកញែក ជាមួយនឹងសេចក្តីបំភ្លឺមួយម្តងៗ ដូចមានតទៅ :

ពុទ្ធសាសនាបង្រៀនឲ្យពឹងខ្លួនឯង ក្នុងការប្រកបទំរើល្អ ឬសេចក្តីយុត្តិធម៌ ដែលខ្លួនឯងនិងសង្គមមនុស្សមានសេចក្តីត្រូវការយ៉ាងអស់លេខ យ៉ាងរកវត្ថុអ្វីដទៃប្រៀបផ្ទឹមពុំបាន ហើយដែលព្រះពុទ្ធបរមគ្រូ ព្រះអង្គបានទាក់ព្រះទ័យយ៉ាងខ្លាំងតាំងពីបានត្រាស់រហូតដល់និព្វាន សឹងមានសម្ពាងលើពុទ្ធភាសិតទាំងឡាយនេះ :

«សេចក្តីព្យាយាមក្នុងកិច្ចប្រតិបត្តិធម៌ ឬក្នុងទំរើការងារជាទូទៅ ជាករណីយ៍ដែលអ្នកទាំងឡាយត្រូវពឹងលើកម្លាំងខ្លួនឯង អនុវត្តខ្លួនឯង តថាគត មានមុខងារត្រឹមតែបង្ហាញទ្រឹស្តី និងចង្អុលប្រាប់ទ្រនិចនៃការអនុវត្តទ្រឹស្តីប៉ុណ្ណោះ»

«ខ្លួនអ្នកនឹងជាទីពឹងរបស់ខ្លួនអ្នក, ជនដទៃពុំអាចឲ្យពំនឹងដល់អ្នកបានទេ ប្រសិនបើអ្នកប្រគល់ខ្លួនអ្នកទាំងស្រុងទៅឲ្យគេ ដោយប្រាសចាកទំរើបរបស់ខ្លួន»

«ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយគប្បីជាបុគ្គលមានខ្លួនជាកោះ ជាទីពឹងនៃខ្លួនរបស់អ្នកចុះ, កុំមាន, កុំយករបស់ដទៃជាទីពឹងឡើយ ។ ចូរអ្នកមានធម្មៈជាកោះ ជាទីពឹងចុះ, កុំមាន, កុំយករបស់ដទៃជាទីពឹងឡើយ»

គំនិតសុភាសិតនេះ បញ្ជាក់ឲ្យឃើញថា ទំរើបុណ្យបាប គ្មាននរណាធ្វើជំនួសនរណាបានទេ, មនុស្សទាំងឡាយត្រូវធ្វើនូវទំរើនេះខ្លួនឯង សូម្បីព្រះពុទ្ធបរមគ្រូក៏ពុំអាចធ្វើជួសអ្នកណាបាន ព្រះអង្គមានភារៈត្រឹមចង្អុលបង្ហាញផ្លូវ, ចំណែកការអនុវត្ត ជាករណីយ៍របស់ពុទ្ធសាសនិក ។ រឿងនេះមិនខុសគ្នានិងរឿងទទួលទានអាហារទេ អ្នកណាបរិភោគ ចម្អែតកើតមានដល់អ្នកនោះ ។ ឯអ្នកមិនបានស៊ី ចម្អែតក៏មិនត្រូវបាន នេះជាសេចក្តីពិតគ្មានអ្នកណាអាចធ្វើកំណែ ឬបដិសេធបានទេ ។

ការពិត, រឿងបង្រៀនឲ្យពឹងខ្លួនឯងនេះ គឺជាទំរើធ្វើចិត្តឲ្យមានគ្រឹះមាំមួន, មានភាពរឹងប៉ឹង អស់ទម្ងន់, អស់កម្សោយ ។ ជាធម្មតាមនុស្សខ្សោយតែងពឹងអ្នកខ្លាំង មនុស្សទន់តែងពឹងអ្នករឹង នេះជាទម្លាប់អាក្រក់មួយដែលអ្នកចង់ធ្វើមនុស្ស ត្រូវធ្វើការវះកាត់ឲ្យអស់ ទើបអាចធ្វើជីវិតរបស់ខ្លួន ឲ្យទៅជាជីវិតទេព ជីវិតអរហន្តបាន ។ បុគ្គលដែលគេពង្រឹងជំហរនៃជីវិតរបស់គេបានហើយ គេគ្មានគំនិតពឹងអ្នកដទៃទេ ប្រសិនបើមានពឹង, មានអាងខ្លះដូចដែលអ្នកផងធ្លាប់និយាយ ធ្លាប់បានដឹងមកហើយនោះ ។ ពំនឹងនិងអំណាងនេះ, ពុទ្ធសាសនាមិនបានទទួល

ស្គាល់ មិនបានទទួលឲ្យឈ្មោះថា «**នាថៈ**» ទេ គឺឲ្យឈ្មោះថា «**សេវនៈ**» ទៅវិញ ។ ដូចនេះព្រោះអ្វី? ព្រោះពុទ្ធសាសនាមានយោបល់នៅក្នុងទ្រឹស្តីមួយថា «**អត្តាហិ អត្តនោ នាថោ** . . . . .» ដែលយើងធ្លាប់ស្គាល់គ្រប់ៗគ្នាមកហើយនោះ ។ ទ្រឹស្តីនេះ, មិនមែនជាទ្រឹស្តីធម្មតាទេ គឺជាទ្រឹស្តីប្រឆាំងចេញមុខ ដល់គំនិតមនុស្សដែលដាក់ខ្លួននៅក្នុងភាពថោកទាបហួសហេតុពេក គឺអន់ជាងសត្វតិរច្ឆានទៅទៀត ដោយគ្មានដឹងថា នៅក្នុងខ្លួនមនុស្សគ្រប់រូប មានកម្លាំងខួរក្បាល, កម្លាំងចិត្តវិញ្ញាណ, កម្លាំងរូបកាយគ្រប់គ្រាន់ ។ល។ ដែលធម្មជាតិបានផ្តល់ឲ្យដោយគ្មានរើសមុខ, តែមនុស្សមិនចេះប្រើ ឬមិនខ្វីរវល់ដល់កម្លាំងរបស់ខ្លួន ត្រឡប់ទៅជាប្រកាន់គំនិតមុខផ្អែ ស្រែជម្រៅ បង្អាប់បង្អោនកិត្តិយសខ្លួនឯង ឱនក្បាលជ្រកក្រោមជើងអាទិទេព, ទេវតា, ឥន្ទ, ព្រហ្ម, គ្រុឌ, នាគ, បិសាច, ខ្មោច ។ល។ សុំជំនួយសម្រោចសម្រង់គ្រប់ប្រកាតដោយមានជំនឿថា គេនឹងធ្វើអំណោយ គេនឹងអាណិតខ្លួន តែគេគ្មានអាណិត គ្មានធ្វើអំណោយអ្វីសោះ ។ ដោយអាស្រ័យកម្លៅរបស់មនុស្សយ៉ាងនេះហើយ ទើបព្រះសម្មាសម្ពុទ្ធបង្រៀនឲ្យចេះពឹងខ្លួន, ចេះស្រាយបញ្ហាដែលចោទមកលើខ្លួនឯង ។ ដើម្បីសិក្សាឲ្យបានយល់ពាក្យថា «**នាថៈ**» និង «**សេវនៈ**» ខ្ញុំសូមធ្វើសេចក្តីបំភ្លឺថា «**នាថៈ**» បានដល់ទំរើដែលមនុស្សម្នាក់ៗធ្វើខ្លួនឯង ដូចខំបង្កើតគំនិតខ្លួនឯង, បង្កើតទំរើខ្លួនឯង, បង្កើតពំនោលខ្លួនឯង, ។ល។ កំហំនេះចួនកាលសម្រេច, ចួនកាលមិនបានសម្រេច ព្រោះទំរើរបស់មនុស្សមិនថាអ្វីជាអ្វីទេ វាមានជំនាប់មកពីវត្ថុជុំវិញ កាលៈទេសៈ ធាតុអាកាស ដី ទឹក ភ្លើង ខ្យល់ និងព្រឹត្តិការណ៍នានាផងដែរ ។ល។ ដូចនេះ, បើយើងគិតមិនយល់ រៀនមិនចេះខ្លួនឯង ។ល។ យើងត្រូវស្វែងរកមិត្តដែលមានគំនិតបញ្ញាច្រើនជាងយើង ដើម្បីសុំដំណោះស្រាយ សូមពន្លឺស្វាងស្វៃអំពីគេ ។ ព្រោះនាថកម្មរបស់យើងទៅមិនរួច ត្រូវបន្ថែមសេវនកម្មមួយទៀត ទៅលើនាថកម្មរបស់យើង ។ ទំរើនេះត្រឹមត្រូវតាមព្រះតម្រាស់ដែលមានមកក្នុងវុឌ្ឍិធម៌ ៤ ថា **សប្បុរិសូបសំសេវ សទ្ធម្មសវន យោនិសោមនសិការ ធម្មានុធម្មបដិបត្តិ** និងចក្កធម៌ ៤ ថា **បដិរូបទេសវាស សប្បុរិសូបសំសេវ អត្តសម្មាបណិធិ, បុព្វេកតបុញ្ញតា ។** ក្នុងន័យថា មនុស្សត្រូវធ្វើនាថកម្មខ្លួនឯងមុន ធ្វើសេវនកម្មក្រោយ តួយ៉ាងកូនសិស្សរៀនខ្លួនឯងអស់ពីសមត្ថភាពនៃនាថកម្មរបស់ខ្លួនឯងហើយ ត្រូវធ្វើសេវនកម្ម គឺរកគ្រូជួយបំភ្លឺ ។ កុំភ្លេចថា សិស្សគ្មាននាថកម្ម គឺគ្មានមនសិការ គ្មានកំហំ គ្មានទម្ងន់ចិត្ត គ្មានសេចក្តីក្លាហាន ។ល។ ក្នុងមុខការសិក្សារបស់ខ្លួន គ្មានគ្រូណាបង្រៀនចេះទេ, កុំថាគ្រូមនុស្សធម្មតា សូម្បីគ្រូនោះមានឋានៈជាព្រះសម្មាសម្ពុទ្ធ ឬព្រះអាទិទេពណាក៏ទៅមិនរួចដែរ ។ អ្នកធ្វើការបានសម្រេចផល ព្រោះចេះពឹងគំនិតកំហំបញ្ញាស្មារតីរបស់គេ ។ល។ គេគ្មានសេចក្តីប្រមាទ គ្មានគំនិតពឹងអ្នកដទៃក្នុងកិច្ចការទាំងឡាយ ដែលនៅក្នុងសមត្ថភាពគេ, គេរៀបចំខ្លួនគេជាស្រេច ដើម្បីខ្លួនគេឯងគ្រប់ពេលវេលា ។

ក្នុងរឿងប្រាក់កាស, អ្នកពឹងខ្លួនឯង គេប្រើមធ្យោបាយសំច័យក្បិតក្បៀត គេមិនចាយវាយខ្ជះខ្ជាយ គេមិនចាយវាយដើម្បីបង្អួតអ្នកក្រ ឬប្រណាំងនឹងអ្នកមាន ។ គេអនុវត្តក្បួនសំច័យយ៉ាងមធ្យ័តនៅក្នុងក្របខ័ណ្ឌ នៃគំនិតបម្រុង គំនិតរក្សា គំនិតប៉ាន់លៃលកដើម្បីកុំឲ្យខ្វះប្រាក់ចាត់ការ ក្នុងពេលមានការចាំបាច់ ឬការបន្ទាន់កើតឡើង ។

ក្នុងរឿងការងារ, មនុស្សដែលចេះពឹងខ្លួនឯង គេខំហាត់ធ្វើការខ្លួនឯងឲ្យកើត ដើម្បីជួយខ្លួនគេឲ្យរស់នៅបានស្រួល, ឲ្យបានឋានៈជាមនុស្សមានលក្ខណៈគ្រប់ជ្រុង ។ អ្នកសិក្សាគប្បីធ្វើសេចក្តីសង្កេតថា ភិក្ខុក្នុងពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធបានអនុញ្ញាតឲ្យមានជាប់ជាមួយនិងខ្លួនជានិច្ច នូវម្ជុលចេស កាំបិតកោរ បំពង់ម្ជុល បាត្រ សំពត់តម្រងទឹក សំពត់រុំដំបៅ សំពត់ងូតទឹក ។ល។ នេះក៏គ្មានដើម្បីអ្វីទេ គឺដើម្បីឲ្យភិក្ខុចេះដេរ ចេះប៉ះ ចេះកោរ ចេះបិណ្ឌបាត្រ ចេះត្រងទឹក ចេះរុំដំបៅខ្លួនឯង ។ល។ ជាមួយគ្នានេះទៀត, មុខងាររបស់អ្នកពឹងខ្លួនឯងមិនត្រឹមតែរក្សាទុកនូវសមត្ថភាព ដែលខ្លួនមានហើយប៉ុណ្ណឹងទេ គឺត្រូវខំបង្កើតសមត្ថភាពថ្មីៗទៀត ដើម្បីប្រឈមមុខនឹងការចាំបាច់ ដែលកើតឡើងជាបន្ទាន់ ។ ក្នុងន័យថា អ្នកពឹងខ្លួនឯងត្រូវជួយខ្លួនឯងឲ្យរួច ក្នុងកាលៈទេសៈ

ធម្មតា ឬក្នុងកាលៈទេសៈពិសេស ដែលជីវិតរបស់ខ្លួនត្រូវបានឆ្លងកាត់ ។

ក្នុងរឿងសិក្សា, អ្នកពឹងខ្លួនឯង គេគ្មានគំនិតខ្ជិល គ្មានគំនិតគេចដោះ គ្មានគំនិតស្នេហាច្របូកច្របល់ គ្មានគំនិតស៊ីផឹកឥតរបប គ្មានអាងគ្រូ អាងសៀវភៅពេក គ្មានគំនិតគប់ភឿនកម្ជិល ឬដើរលាត់សើយ គ្មានគំនិតរវើរវាយ គ្មានគំនិតបន់ស្រន់ ។ល។

ក្នុងរឿងគ្រងរក្សាជីវិត, អ្នកពឹងខ្លួន គេខំរៀបចំគ្រឿងប្រដាប់សម្រាប់រស់ជាស្រេច ដើម្បីងាយស្រួលដល់ការប្រើប្រាស់ក្នុងគ្រួសារ ដោយមានកំណត់ពេលជាថ្ងៃខែឆ្នាំច្រើនតិច ស្រេចហើយតែការលៃលករបស់គេ ។ គ្រឿងប្រដាប់ទាំងអស់ បើគ្មានការអ្វីជាធំដុំក្នុងគ្រួសារទេ គេគ្មានការចាំបាច់ត្រូវខ្ចីអ្នកដទៃមកបន្ថែមឡើយ ។ ព្រមគ្នានេះ, គេត្រៀមដំណោះស្រាយបញ្ហាជីវិតដែលត្រូវចោទថ្មីៗទៀត, ជាមួយនិងទំរើការពារឧបសគ្គនៃជីវិតដែលកើតមានដោយចៃដន្យ ។ ជាពិសេស, គឺគេចំណាត់កម្មវិធីជីវិតឲ្យមានស្ថេរភាព ស្មើចុង ស្មើដើម នៅក្នុងក្របខ័ណ្ឌនៃមធ្យោបាយប្រុងប្រយ័ត្ន កុំឲ្យជីវភាពធ្លាក់ចុះដុនដាប លុះត្រាអស់ផ្លូវធ្វើកំណៃ ។ល។

ក្នុងរឿងការប្រព្រឹត្តប្រតិបត្តិធម៌, អ្នកពឹងខ្លួនឯងគេគ្មានគំនិតថា សេចក្ដីល្អអាចកើតមានដល់ខ្លួនគេងាយៗឡើយ ប្រសិនបើគ្មានស្គាល់ហេតុផលក្នុងទំរើ ឬគ្មានគំនិតបញ្ញាគ្រប់គ្រាន់ ដើម្បីអនុវត្តកម្មវិធីផ្នែកល្អ ។ ដូចនេះ កាលណាគេចង់បានសេចក្ដីល្អ គេខំបណ្ដុះគុណសម្បត្តិ និងបំបាត់ចោលនូវគុណវិបត្តិគ្រប់ពេលវេលា ។ល។

## រឿងពឹងខ្លួនឯងជារឿងរបស់ធម្មជាតិ

នៅក្នុងសេចក្ដីសង្កេតរបស់យើង យើងឃើញថា ក្មេងតូចៗវាជួយខ្លួនវាមិនសូវបាន ។ ដូចនេះ, ទើបធម្មជាតិបានផ្ដល់កម្លាំងទប់ទល់ឲ្យវាច្រើនជាងមនុស្សចាស់ ឬមនុស្សពេញវ័យ ដូចជាក្មេងកើតជម្ងឺគ្រុនក្ដៅ សីតុណ្ហភាពមានកម្រិតឡើងដល់ ៤០ អង្សា ឬ ៤២ អង្សាជាងក្មេងនៅធន់ទ្រាំបាន ។ ចំណែកមនុស្សចាស់ បើសីតុណ្ហភាពឡើងដល់កម្រិតនោះដូចក្មេងដែរ, ការរសាប់រសល់ក្រវល់ក្រវាយយ៉ាងខ្លាំង ស្ទើរទៅស្ទើរនៅតែម្ដង ។ ក្មេងចម្រើនវ័យ, ល្មមចេះចាប់អាហារដាក់មាត់វាបាន ឬលើកកែវផឹកទឹកខ្លួនវាបាន វាដណ្ដើមស៊ីបាយផឹកទឹកខ្លួនវា គឺវាមិនព្រមឲ្យគេបញ្ចុកបាយ បំផឹកទឹកវាទៀត វាហាត់ស៊ីបាយផឹកទឹកយ៉ាងចចេស ដោយខំរស់នៅខ្លួនឯងលែងពឹងកម្លាំងគេ ។ល។ នេះជាសញ្ញាបញ្ជាក់ឲ្យឃើញថា បំណងធម្មជាតិ ត្រូវការឲ្យមនុស្សពឹងខ្លួនឯង ឬជួយខ្លួនឯងជាពិតប្រាកដ ។

នៅក្នុងរាងរបស់មនុស្សនិងសត្វ កាលណាមានរបួសដាច់សាច់ស្រក់ឈាម ។ រូបកាយក៏ក្លាយទៅជាខ្វះសាច់ ខ្វះឈាមក្នុងចំណែកខ្វះភ្លាម ទំរើជួសជុលខ្លួនវា ដោយខ្លួនវាក៏ចាប់មានភ្លាមដែរ ។ ឯការព្យាបាលរបួស, ដែលធ្វើដោយគ្រូពេទ្យនោះ គឺគ្រាន់តែធ្វើការសម្អាតមុខរបួស មិនឲ្យមានមេរោគដទៃ ឆ្លៀតឱកាសចូលធ្វើអន្តរាគមន៍ បង្កើតជាជម្ងឺនេះ នោះវែងឆ្ងាយទៅទៀតប៉ុណ្ណោះ ។ ចំណែកខាងទំរើជួសជុល គឺជាឧបករណ៍របស់រូបរាងកាយដែលវាត្រូវបន្ថែមកោសិកាត្រង់មុខរបួស លុះត្រាតែពេញដូចប្រក្រតីដើមវិញ ។

កាលបើគោលការណ៍ពឹងខ្លួនឯង, ជាគំនោលធម្មជាតិ ដូចបានពោលមកហើយ ។ ទំរើបង្រៀនមនុស្សឲ្យចេះពឹងខ្លួន ទើបជាគោលការណ៍ត្រឹមត្រូវ តាមបំណងធម្មជាតិយ៉ាងពិតប្រាកដ ។ ដូចនេះព្រោះអ្វី? ព្រោះការពឹងអ្នកដទៃ វាមិនមែនជាធាតុត្រូវអាស្រ័យបានអស់កាលជានិច្ច ។ ពេញចិត្តគេឲ្យពឹង មិនពេញចិត្តគេមិនឲ្យពឹង សូម្បីគេឲ្យយើងពឹងហើយ, តែភាពមិនទៀងទាត់របស់ពិភពលោក អាចធ្វើឲ្យស្ថានភាពរបស់គេ ប្រែប្រួលធ្លាក់ចុះដុនដាបរហូតដល់មិនអាចឲ្យយើងពឹងគេតទៅទៀតបាន ឬគេអាចបាត់បង់ជីវិត សូន្យសង្ខារទៅតាមបច្ច័យនៃអាយុរបស់គេទៅមុនយើងក៏មាន ។ ហេតុនេះ, ការហាត់រៀនពឹងខ្លួនឯង ជាទំរើមានប្រយោជន៍ធំណាស់ ទាំងផ្លូវលោក ទាំងផ្លូវធម៌ ជាទំរើមានតែចំណេញ គ្មានកំហាតអ្វីសូម្បីបន្តិចបន្តួចឡើយ ។

សេចក្ដីពិត, យើងកើតមកក្នុងលោកនេះ ចាំបាច់ត្រូវពឹងអាស្រ័យគ្នាទៅវិញទៅមកមែន ។ ពុទ្ធសាសនា

មិនបានបដិសេធការពឹងគ្នាទេ, តែបង្រៀនឲ្យចេះពឹងខ្លួនឯង, ណែនាំឲ្យចេះជួយខ្លួនឯង ដើម្បីប្រើក្នុងពេលណាដែលពឹងគេមិនកើត, សុំជំនួយពីគេមិនបាន ពេលនោះការពឹងខ្លួនឯង និងការជួយខ្លួនឯង វាជាធាតុចាំបាច់ដែលខ្លួនយើងត្រូវធ្វើ, យើងក៏ធ្វើកើតមែន, នេះគឺជាគំនិតញឹកល្អិតរបស់ពុទ្ធសាសនា ដែលយើងត្រូវអនុវត្ត ប្រសិនបើយើងឃើញថា គំនិតនេះមិនត្រឹមតែញឹកល្អិតឥតប្រយោជន៍ទេ គឺមានហេតុផលគ្រប់គ្រាន់ផង ព្រោះពំនឹងទាំងឡាយវាមិនមែនជាធាតុមានភាពទៀងទាត់ ដូចគំនិតយើងប៉ាន់ស្មានឡើយ ។ ម្យ៉ាងទៀតពំនឹង វាជារបស់ធ្វើឲ្យយើងមានសេរីភាព, គ្មានចំណុចខ្សោយ គ្មានភាពទោរទន់ ចំពោះទម្ងន់ការ និងឧបសគ្គនៃជីវិតដែលយើងបានពើបប្រទះ ។ ក្មេងដែលមាតាបិតាទម្រើសពេក ឬថ្នាក់ថ្នមហួសពេកទៅ ពេលវាមានវ័យធំពេញកម្លាំងហើយ វាធ្វើការអីមិនកើតទេ វាទន់ខ្សោយទាំងសព្វ ទាំងគ្រប់, វាធំហើយនៅមានគេបីបមថ្នមទ្រ ។ ដូចនេះព្រោះអ្វី? ព្រោះគេគ្មានបង្រៀនឲ្យវាចេះពឹងខ្លួនវា មានពេលខ្លះវាខំរៀនពឹងខ្លួនវា ដូចជាខំប្រឹងអង្គុយ ខំប្រឹងដើរក៏គេមិនអនុញ្ញាតឲ្យវាធ្វើតាមចំណង់របស់វា វាក៏ក្លាយខ្លួនទៅជាក្មេងកម្សោយ ។ លុះពេលមួយមានភ្លើងឆេះផ្ទះ អ្នកនៅក្នុងផ្ទះភ័យតក់ស្លុតរត់យករួចជីវិតរៀងៗខ្លួន គ្មានបានឲ្យពំនឹងដល់វាតាមទម្លាប់ដូចកាលមុន វាក៏រលាយជីវិតក្នុងភ្លើងនោះទៅ ។ ដូចនេះការហាត់ពឹង ហាត់ជួយខ្លួនឲ្យកើត មុនគ្រោះថ្នាក់របស់ជីវិតមកដល់ ទើបជាទំរើខ្ពង់ខ្ពស់មួយ ដែលពុទ្ធសាសនាប្រកាន់យកជាគោលការណ៍ធំ សម្រាប់ជីវិតសត្វលោកដែលកំពុងធ្វការតស៊ូ ដើម្បីឆ្លងកាត់អន្លង់ទុក្ខ ដែលកំពុងត្រូវជួបប្រទះហើយនិងជួបប្រទះក្នុងពេលខាងមុខទៀត ។

ពុទ្ធសាសនាបង្រៀនឲ្យពឹងខ្លួនឯង ក្នុងការលើកកម្ពស់ជីវភាពរបស់ខ្លួន (វឌ្ឍនធម៌[១]) ។ ពុទ្ធសាសនាជាធាតុដើមមួយនៃវឌ្ឍនធម៌ យ៉ាងចាស់ទុំរបស់ពិភពលោក ព្រោះពុទ្ធសាសនាបានបង្រៀនមនុស្ស ឲ្យព្យាយាមលើកឋានៈជីវភាពរបស់ខ្លួន ឲ្យមានកម្រិតខ្ពស់ឡើងៗ ប្រណីតឡើងៗ អស់កាលជានិច្ច ទាំងខាងការសិក្សារៀនសូត្រការអប់រំហ្វឹកហាត់ធ្វើការងារ ការប្រកបអាជីវកម្មគ្រប់ប្រភេទ ជ្រើសរើសឲ្យស៊ីតាមសមត្ថភាពនៃអាត្មា កុំបណ្ដែតបណ្ដោយឲ្យជីវិតរស់នៅតាមយថាកម្ម ឬតាមគំនិតដេកផ្សងព្រេង ។

ពុទ្ធតម្រាស់មួយមានក្នុងទសកនិបាត អង្គុត្តរនិកាយមានសេចក្ដីថា :

«ម្នាលភិក្ខុទាំងឡាយ ! តថាគតមិនសរសើរមនុស្សដែលឈប់រស់នៅក្នុងមនុស្សធម៌ ព្រោះបើសរសើរមនុស្សធុននេះទៅ, គ្រោះថ្នាក់ទាំងឡាយនឹងកើតមានដល់ពិភពលោកជាមិនខាន ។ ម្នាលភិក្ខុទាំងឡាយ ! យើងសរសើរវឌ្ឍនភាពប្រកបដោយមនុស្សធម៌ទាំងឡាយ យើងមិនសរសើរនូវទំរើឈប់រស់នៅក្នុងមនុស្សធម៌ហើយត្រឡប់ទៅរស់នៅក្នុងទំរើអមនុស្សធម៌របស់សត្វទាំងឡាយឡើយ» ។

ដោយពុទ្ធសាសនាបង្រៀនឲ្យជីវិតទាំងឡាយ រស់នៅក្នុងភាពជឿនលឿន ឲ្យសាងសេចក្ដីចម្រើនរុងរឿងរឿយៗ កុំឈប់នៅមួយកន្លែងៗដូចនេះ ទើបពុទ្ធសាសនាគាំទ្រសេចក្ដីព្យាយាម ភាពរឹងប៉ឹង ភាពអត់ធន់ ភាពស្ដាប់ច្រើន រៀនច្រើន គំនិតសង្គម មនសិកាមនុស្ស សម្បជញ្ញៈយុត្តិធម៌ ។ល។ ថាជាគុណធម៌សំខាន់គ្រប់ចំណុច ។ ព្រោះពុទ្ធសាសនា បង្រៀនឲ្យលើកឋានៈជីវភាពរបស់ខ្លួន នៃមនុស្សម្នាក់ៗ ឲ្យមានកម្រិតខ្ពស់ដោយខ្លួនឯង, ដូចមានចែងមកក្នុងទីទាំងឡាយមាន **ទិដ្ឋធម្មិកត្ថៈ** ប្រយោជន៍បច្ចុប្បន្នជាដើម ទើបហុចឱកាសឲ្យយើងនិយាយថា ពុទ្ធសាសនាជាដើមកំណើតនៃវឌ្ឍនធម៌ យ៉ាងចាស់ទុំមួយរបស់ពិភពលោកដែរ ដែលយើងគួរដឹងដូចតទៅ ។

## **វឌ្ឍនធម៌គឺជាអ្វី?**

វឌ្ឍនធម៌គឺភាពចម្រើនរុងរឿង, ភាពល្អឡើងៗជាលំដាប់, ភាពប្រណីតលើសទម្រង់ដើម ។ល។

---

(១) វឌ្ឍនធម៌ជាពាក្យនាម ពាក្យនេះមានន័យទូលាយជាងវប្បធម៌ វប្បធម៌ គ្រាន់តែជាសាខាមួយរបស់វឌ្ឍនធម៌ប៉ុណ្ណោះ ។

ដោយអាស្រ័យគំនិតសិក្សា គំនិតអប់រំហ្វឹកហាត់ គំនិតត្រិះរិះពិចារណានូវជុំវិញព្រឹត្តិការណ៍នានា, គំនិតយុត្តិធម៌នៃសង្គម ។ល។ ភាពចម្រើនរុងរឿង ឬភាពល្អប្រសើរ ដែលចេះតែកើតឡើង មានឡើងរឿយៗតាមលំដាប់ ដោយឥតមានខ័ណ្ឌព្រំដែនក្នុងផ្លូវណាមួយ គឺស្រេចតែអ្វីដែលមានជំនាប់ជាមួយនិងជីវិត ជាមួយនឹងការរស់នៅរបស់ប្រជាសត្វលោក ដែលរួមគ្នានៅជាពួក ជាក្រុម ធាតុទាំងអស់នេះត្រូវឲ្យឈ្មោះថា «វប្បធម៌» ។

វប្បធម៌មានច្រើនសាខា ដូចជាវប្បធម៌ខាងសម្ភារៈ វប្បធម៌ខាងចិត្តវិញ្ញាណ ដែលជាប់ទាក់ទងជាមួយនិងជំនឿ ឬបុណ្យបាប ប្រពៃណីនិយមរបស់ជាតិមួយៗ និងសីលធម៌ប្រភេទខ្លះ ដែលមនុស្សជាតិក្នុងលោក ប្រកាន់យកប្រកបដោយលក្ខណៈ និងមនោសញ្ចេតនាផ្សេងៗគ្នា ។ នៅក្នុងប្រទេសយើង ក្នុងសម័យរាជានិយមក៏ដោយ សម័យសាធារណរដ្ឋក៏ដោយ, គេធ្លាប់ចែកវប្បធម៌ជាប៉ុន្មានៗ យើងបានដឹងគ្រប់គ្នាអស់ហើយ ។ គំនិតខ្ញុំក្នុងរឿងនេះ ខ្ញុំសូមចែកវប្បធម៌ជា ៥ ប្រភេទគឺ :

១- គតិធម៌ មានដល់វប្បធម៌ខាងធម្មចរិយា (សីលធម៌ មនុស្សធម៌) ឬការប្រព្រឹត្តទៅនៃចិត្តវិញ្ញាណ,

២- នីតិធម៌ បានដល់វប្បធម៌ខាងច្បាប់និងវិន័យ,

៣- វត្ថុធម៌ បានដល់វប្បធម៌ខាងសម្ភារៈ,

៤- សហធម៌ បានដល់វប្បធម៌ខាងសង្គម,

៥- ទ្រឹស្តីធម៌ បានដល់វប្បធម៌ខាងភាសិត ឬមេសូត្រ ។

ក្រៅពីនេះ មានវប្បធម៌ជាច្រើនប្រការទៀត ដូចជាវប្បធម៌ខាងទំនៀមទម្លាប់ ប្រពៃណី វណ្ណកម្មសិល្បៈ ។ល។ ទោះណាជាវប្បធម៌មានច្រើនបែប ច្រើប្រការយ៉ាងណាក៏ដោយ ព្រះពុទ្ធសាសនាធ្លាប់មានមុខងារគាំទ្រសត្វលោកនៅក្នុងក្របខ័ណ្ឌនៃមនុស្សធម៌ នៃសន្តិសុខ នៃសន្តិភាព សម្រាប់ពិភពលោកនិងសកលជីវិត ក៏នៅតែមានការគាំទ្រតទៅទៀត ដរាបណាសកលពិភព និងសកលមនុស្សចេះតែនៅមាន ។ ដើម្បីងាយស្រួលដល់ការពិចារណារបស់អ្នកអាន ខ្ញុំសូមសម្តែងអំពីល័ខឋាននៃទំរើគាំទ្រវប្បធម៌ប្រភេទខ្លះ ដែលពុទ្ធសាសនាបានធ្វើដូចមានតទៅ :

## សម្បត្តិមនុស្សល្អ

គុណធម៌ ឬវប្បធម៌ ដែលជាប់ទាក់ទងនិងចរិយមារយាទ ឬចរិយាមារយាទ ដែលត្រូវបានឈ្មោះថា គុណធម៌ ឬវប្បធម៌ដែលគេនិយមហៅថា សម្បត្តិមនុស្សល្អនោះ យើងអាចឃើញបានក្នុងវិន័យបិដក ដែលព្រះសម្មាសម្ពុទ្ធបានបញ្ញត្តិ និងអនុញ្ញាតមានដូចនេះ :

១- នៅក្នុងទីប្រជុំជន ឬចន្លោះស្រុកភូមិ ឬពេលកំពុងឆាន់អាហារ ភិក្ខុសាមណេរត្រូវស្លៀកដណ្តប់ឲ្យមានរបៀបរៀបរយ ។ល។ និង ។ល។

(មើលនិសគ្គិយបាចិត្តិយ, សុទ្ធិកបាចិត្តិយ និងសេចក្ខិយវត្តប្រកបផង)

ចំណុចសំខាន់ដែលបានលើកយកមក ធ្វើសំនេរយ៉ាងខ្លីនេះ ខ្ញុំមានសេចក្តីសង្ឃឹមថា អ្នកអានទាំងអស់គ្នាគង់យល់បានថា សម្បត្តិមនុស្សល្អនោះ ពុទ្ធសាសនារបស់យើងបានសម្តែងមកគ្រប់សព្វអស់ហើយ ។ ប្រសិនបើប្រៀបធៀបវប្បធម៌របស់ពុទ្ធសាសនា, សាសនាទាំងឡាយដទៃ និងការរស់នៅនៃសង្គមមនុស្សលោកនោះ ។ ខ្ញុំយល់ឃើញតាមគំនិតពិត មិនមែនជាគំនិតអួតថា មានតែពុទ្ធសាសនាមួយទេ ដែលសម្បូរវប្បធម៌ជាងគេ ។ ជាមួយគ្នានេះទៀត ខ្ញុំយល់ថាពិភពលោក កុំថាឡើយមានគំនិត ដល់ទៅបង្កើតវប្បធម៌ថ្មីទៀត សូម្បីតែវប្បធម៌ចាស់របស់ពុទ្ធសាសនា ក៏គេអនុវត្តតាមពុំទាន់ទាំងអស់ផង ។

## វឌ្ឍនធម៌ក្នុងចរិយានៃការបរិភោគនិងប្រើប្រាស់

១- ហាមមិនឲ្យភិក្ខុទុកសំណល់អាហារ កន្លងរាត្រីក្នុងបន្ទប់ដំណេករបស់ខ្លួន (ដែលហៅថា **អន្តោវុត្ថ**) ព្រោះប្រយ័ត្នមិនឲ្យបន្ទប់ដំណេក ក្លាយទៅជាបន្ទប់ទុកអាហារ ។

២- ហាមមិនឲ្យភិក្ខុចម្អិនអាហារ ក្នុងបន្ទប់លំនៅ(ដែលហៅថា **អន្តោបក្ក**) ព្រោះប្រយ័ត្នមិនឲ្យបន្ទប់លំនៅក្លាយទៅជាបន្ទប់ផ្ទះបាយ ។

៣- ហាមមិនឲ្យប្រើភាជនៈទឹក ឬភាជនៈអាហាររួមគ្នា[១] ។ ដែលក្នុងបច្ចុប្បន្ននេះខាងក្បួនអនាម័យប្រកាន់យកនូវទំនើនេះថា ការពារជម្ងឺឆ្លង ។ ដូចភិក្ខុ សាមណេរឆាន់អាហារជាវង់ ត្រូវមានស្លាបព្រាសមកណ្ដាល[២] ចំណែកភាជនៈដាក់ទឹក ត្រូវចាត់ឲ្យមានមួយៗ ក្នុងមួយអង្គ ។ គឺរួមតុថាស ឬស្ពក, តែកុំរួមចានស្លាបព្រាកែវទឹក . . . . . ។

៤- ហាមមិនឲ្យឆាន់អាហារដែលទុកឲ្យកន្លងរាត្រី ព្រោះខ្លាចក្រែងចូលក្នុងការសន្សំទុកធ្វើមាន និងភាពជូរផ្អូម ដែលបង្កើតជម្ងឺ ។ល។

## វឌ្ឍនធម៌ក្នុងការថែរក្សារបស់រួម

១- ភិក្ខុ សាមណេរ យកគ្រែ តុ តាំង ពូក កៅអីរបស់សង្ឃ ។ល។ ទៅប្រើ វេលាឈប់ប្រើមិនបានរៀបចំទុកដាក់ដោយខ្លួនឯង ឬមិនបានប្រើអ្នកដទៃឲ្យទុកដាក់ជំនួសត្រូវមានអាបត្តិ ។

២- ភិក្ខុ សាមណេរ យកកម្រាលគ្រប់យ៉ាងរបស់សង្ឃ ទៅប្រើក្នុងកន្លែងណាមួយ លែងប្រើមិនបានទុកដាក់វិញដោយខ្លួនឯង ឬមិនបានប្រើអ្នកដទៃឲ្យទុកដាក់ត្រូវមានអាបត្តិ ។ល។

## វឌ្ឍនធម៌ក្នុងការប្រតិបត្តិខ្លួនចំពោះសង្គម

១- របស់នៃគ្រហស្ថជ្រុះធ្លាក់ខាងក្រៅវត្ត ភិក្ខុ សាមណេរ រើសយកជារបស់ខ្លួន ដោយខ្លួនឯងក្ដី ប្រើអ្នកដទៃឲ្យរើសដើម្បីទុកដាក់ជារបស់ខ្លួនក្ដី ត្រូវមានអាបត្តិ ។ ផ្ទុយពីនេះ, របស់នៃគ្រហស្ថដែលធ្លាក់ ឬជ្រុះក្នុងវត្ត ត្រូវរើសទុកដើម្បីប្រគល់ឲ្យម្ចាស់គេ បើមិនរើសទុក ត្រូវមានអាបត្តិ ។

២- ភិក្ខុ សាមណេរ ជាភ្ញៀវទៅកាន់ទីវត្តដទៃ គប្បីសួរគេដល់កត្តិការ ឬបបទបញ្ញាផ្សេងៗរបស់វត្តនោះ ដើម្បីប្រតិបត្តិឲ្យបានត្រឹមត្រូវ សមរម្យនឹងកត្តិការ ឬបទបញ្ញានោះៗ ដែលវត្តមួយៗ បានរៀបចំឡើងនិងអនុវត្តជានិច្ចមកហើយ ។ល។

របៀបវឌ្ឍនធម៌ផ្សេងៗ ដែលខ្ញុំសរសេរដោយសង្ខេបនេះ អ្នកសិក្សាគង់យល់បានថា ពុទ្ធសាសនាបង្រៀនឲ្យមនុស្សលើកកម្ពស់គុណធម៌សម្រាប់ជីវិតរបស់ខ្លួន ឲ្យខ្ពស់ជាងប្រក្រតីដើម ឲ្យផុតចាកជីវិតព្រៃផ្សៃគ្រប់បែបយ៉ាង ។ ដូចនេះ, ទើបយើងអាចពោលបានថា ពុទ្ធសាសនាជាដើមកំណើតនៃវឌ្ឍនធម៌ យ៉ាងចាស់ទុំរបស់ពិភពលោកដោយពិតប្រាកដ គ្មាននរណាអាចធ្វើសេចក្ដីបដិសេធបាន ប្រសិនបើវិញ្ញាណរបស់គេគ្មានអគតិធម៌៤ ។

## ពុទ្ធសាសនាមិនបង្រៀនឲ្យប្រព្រឹត្តទំនើល្អដោយបន់ស្រន់ទេ

បន្ទាប់ពីគោលការណ៍ពឹងខ្លួន យើងបានដើរមកដល់ថ្នាក់មួយទៀត គឺពុទ្ធសាសនាមិនបង្រៀនឲ្យប្រកាន់យកទំនើបន់ស្រន់ថាជាទំនើល្អប្រសើរឡើយ ដើម្បីឲ្យអ្នកអាន មានពន្លឺក្នុងរឿងនេះ សូមមេត្តាពិចារណាដល់រឿងនេះជាមួយនិងខ្ញុំ តាមលំដាប់មួយៗដូចមានតទៅគឺ :

១- ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ មានពុទ្ធតម្រាស់ថា «យើងយកប្រេងចាក់ចូលទៅក្នុងទឹក ហើយយើងអង្វរបន់ស្រន់ សូមឲ្យប្រេងលិចទឹក ប្រេងពុំបានលិចទឹកដូចសំណូមពររបស់យើងឡើយ ។ ដំណាល

---

(១) ភិក្ខុ សាមណេរឆាន់ជាវង់រួមតុថាសស្ពក ។ល។ ជាមួយគ្នាបាន តែកម្ររួមចានកែវផ្ដិល ។ល។ (២) ស្លាបព្រាសមកណ្ដាល គឺជារបស់សម្រាប់ដួសដាក់ចាន . . . . . តែមិនដាក់មាត់ ។

គ្នានេះ, យើងចោលដុំថ្មទៅក្នុងទឹក ហើយយើងបន់ស្រន់បួងសួង សូមកុំឲ្យដុំថ្មលិចទឹក ដុំថ្មមិនអណ្ដែតទឹកតាមសំណូមពររបស់យើងឡើយ ។ សេចក្ដីនេះមានឧបមាយ៉ាងណាមិញ ទំរើបន់ស្រន់បួងសួងក៏គ្មានបានសម្រេចមានឧបមេយ្យយ៉ាងនោះដែរ ។ ព្រោះអ្វី? ព្រោះថា បើទំរើបន់ស្រន់នោះ វាចំទៅលើហេតុផល ឬបុណ្យវាសនាដែលតម្រូវឲ្យបាន ក៏វាបានទៅ បើវាមិនចំលើហេតុផល ឬលើបុណ្យ ក៏វាឥតបានទៅ ។ ម្នាលភិក្ខុទាំងឡាយ ! ទំរើអាក្រក់វាផ្ដល់ឲ្យនូវទិក្ខ ទំរើល្អវាផ្ដល់ឲ្យនូវសុខ ។ នេះជាសេចក្ដីពិតតាមច្បាប់នៃកម្ម ដែលអ្នកពុំអាចប្រកែកបានឡើយ»

២- ពុទ្ធតម្រាស់មួយទៀត ក្នុងសំយុត្តនិកាយ ខន្ធវគ្គ មានសេចក្ដីថា «បើមេមាន់មិនក្រាប សូម្បីពងមាន់ដែលធ្លាប់កើតកូនក៏កើតមិនបាន ។ ការចង់បានកូនមាន់ដែលមនុស្សបានធ្វើមកហើយ ក៏គ្មានប្រយោជន៍ ។ សេចក្ដីនេះយ៉ាងណាមិញ, សេចក្ដីប្រថ្នារបស់មនុស្ស ដើម្បីឲ្យចិត្តរបស់ខ្លួនរួចផុតចាកកិលេស, តែគ្មានប្រព្រឹត្តប្រតិបត្តិធម៌ ក៏គ្មានបានសម្រេចយ៉ាងនោះដែរ»

៣- ក្នុងបញ្ចកនិបាតអង្គុត្តរនិកាយ ព្រះសម្មាសម្ពុទ្ធ បានបង្រៀនអនាថបិណ្ឌិកសេដ្ឋីថា «ម្នាលគហបតី ! របស់ដែលជាទីប្រាថ្នារបស់មនុស្សលោកមាន ៥ គឺ **អាយុ, វណ្ណៈ, សុខៈ, យសៈ, សគ្គៈ** នោះ យើងមិននិយាយថា បានមកដោយហេតុបន់ស្រន់បួងសួង ឬសេចក្ដីប្រាថ្នាគ្មានទំរើទេ, ប្រសិនបើបំណន់គ្មានទំរើ បានសម្រេចផលតាមបំណងនោះ ពិភពលោកនៃសកលសត្វ នឹងពោរពេញទៅដោយមនុស្សខ្លាំង គ្មានមនុស្សខ្សោយទេ ។ ម្នាលគហបតី ! អរិយសាវ័កទាំងឡាយណា ដែលប្រាថ្នាចង់បានរបស់នោះ, គេពុំដែលបានធ្វើការបន់ស្រន់ទេ ។ ជាពិសេស, គេគ្មានសេចក្ដីត្រេកអរសប្បាយភ្លើតភ្លើនក្នុងរបស់នោះៗទេ ។ អរិយសាវ័កទាំងឡាយនោះគេខំប្រតិបត្តិធម៌ដើម្បីរបស់ជាទីប្រាថ្នាអស់ទាំងនោះ ហើយលះបង់របស់ជាទីប្រាថ្នាអស់ទាំងនោះទៅវិញ»

ចំណុចបង្រៀនឲ្យជួយខ្លួនឯង ដោយធ្វើការបង្កើតផល ដើម្បីចាប់យកប្រយោជន៍ជាទីត្រូវការនៃជីវិតដោយមិនចាំបាច់ធ្វើការបន់ស្រន់បួងសួង អំពាវនាវដល់វត្ថុស័ក្ដិសិទ្ធិសុំនេះ សុំនោះ ។ ទំរើនេះ, ប្រសិនបើយើងស្គាល់ចិន្ដាព្រះពុទ្ធបរមគ្រូច្បាស់លាស់ យើងគ្មានចាំបាច់រវល់ធ្វើការបដិសេធទេ គឺកំហុសនៃទំរើនេះវាបដិសេធខ្លួនវាស្រេចតែម្ដង ។ ព្រោះសេចក្ដីអស់សង្ឃឹមលើខ្លួនឯង ហើយធ្វើសេចក្ដីសង្ឃឹមទៅលើវត្ថុដទៃ វាជាទំរើផ្ទុយស្រឡះពីសេចក្ដីត្រាស់ដឹង នៃព្រះសម្មាសម្ពុទ្ធរបស់យើងដល់កម្រិតមួយរយភាគរយទៅហើយ ។

សឺរ៍អិតវិនអានូលដ៍ អ្នកកវីជនជាតិអង់គ្លេសម្នាក់ ដែលមានសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បាននិពន្ធបទកវីឈ្មោះ **ប្រទីបនៃអាស៊ីទ្វីប** បានពោលដល់ទំរើបន់ស្រន់ មានអត្ថន័យយ៉ាងពីរោះ ដែលខ្ញុំសូមប្រែសម្រួលសេចក្ដីជាពាក្យរាយមានដូចនេះ :

«ចូរអ្នកកុំអង្វរបន់ស្រន់ឡើយ ភាពងងឹតនិងភាពភ្លឺស្វាងមិនបានកើតមាន (ដោយទំរើនេះទេ) ។

ចូរអ្នកកុំសូមអ្វីអំពីភាពស្ងាត់ឈឹងឡើយ ព្រោះវាគ្មាននិយាយជាមួយនឹងយើងដល់មួយម៉ាត់ទេ ។

ចូរអ្នកកុំញាំញីចិត្តរបស់អ្នក ដែលកំពុងមានសេចក្ដីគ្រាំគ្រាគ្របសង្កត់ ដោយសេចក្ដីឈឺចាប់ ដ៏លាយឡំដោយសទ្ធាឡើយ ។

ឱបងប្អូនប្រុសស្រីទាំងឡាយអើយ !

ចូរអ្នកកុំសូមអ្វីៗអំពីពួកទេព ដែលជួយអ្វីអ្នកពុំបាន ដោយទំរើបន់ស្រន់និងពាក្យសូត្រសរសើររបស់អស់អ្នកឡើយ ។

ចូរអ្នកកុំឲ្យមានជាប់បំណុលដោយទឹកឈាមនិងចិញ្ចឹមពួកទេពដោយផ្លែឈើនិងនំរបស់អ្នកឡើយ ។

ការរួចផុតចាកគ្រោះថ្នាក់ និងដំណោះស្រាយបញ្ហានានាត្រូវស្រាវជ្រាវរាវរកក្នុងខ្លួនរបស់អ្នកឯង ។

ចូរអ្នកចងចាំកុំភ្លេចថា មនុស្សរាល់រូបត្រូវសាងគុក សាងវិមានដោយខ្លួនឯង» ។

មានកវីនិពន្ធខ្លះទៀត ដែលលោកបាននិពន្ធរឿងពឹងខ្លួនឯង តាមគោលការណ៍ធម្មៈនៃពុទ្ធសាសនា ហើយលោកសរសេរបទកវីអង្វរលន់តួព្រះអាទិទេព សូមកុំឲ្យជ្រៀតជ្រែកក្នុងមុខការរបស់សត្វលោក ។ កវីនិពន្ធនេះ ខ្ញុំភ្លេចឈ្មោះលោកទៅហើយ នៅចាំតែសេចក្ដីដែលលោកបាននិពន្ធ ។ ខ្ញុំមានសេចក្ដីស្ដាយពន់ពេកណាស់ ដោយស្វែងរកសៀវភៅរបស់លោក ដែលខ្ញុំធ្លាប់បានអានមិនឃើញ ។ សំដាយនេះ បានបង្ខំចិត្តឲ្យខ្ញុំសរសេរបទនិពន្ធគ្មានឈ្មោះរបស់លោកមានគំនោលដើមដូចនេះ :

«បពិត្រព្រះអាទិទេព ! បើព្រះអង្គមានព្រះទ័យអាណិតជួយស្រោចស្រង់ខ្ញុំ,

សូមមេត្តាកុំមកជ្រៀតជ្រែកក្នុងទំរើរបស់ខ្ញុំបានហើយ

សូមអនុញ្ញាតបើកឲ្យខ្ញុំ បានប្រើកម្លាំងសមត្ថភាព និងសតិបញ្ញារបស់ខ្ញុំ ដើម្បីតស៊ូនឹងសេចក្ដីលំបាកគ្រប់បែបយ៉ាង តាមផ្លូវដែលខ្ញុំរើសរកបានដោយខ្លួនឯងចុះ»

មានកវីនិពន្ធម្នាក់ទៀតឈ្មោះល៉ាំដែថេនីសុន បានសរសេរបទកវីនិពន្ធមួយ ដែលខ្ញុំសូមដកស្រង់ត្រឹមតែចំណុចមួយមកសរសេរក្នុងទីនេះ មានសេចក្ដីថា :

«ព្រោះមនុស្សយើងមានស្ថានភាពល្អជាងចៀមនិងពពែ ក្នុងចំណុចចិញ្ចឹមជីវិតងាយស្រួល នៅក្រោមខួរក្បាលរបស់ខ្លួនមានទំហំប៉ុន្មានៗនោះ បើយើងស្គាល់ព្រះអាទិទេពហើយ មិនលើកដៃសំពះអង្វរលន់តួចំពោះព្រះអង្គដើម្បីវឌ្ឍនភាពខ្លួនឯង និងបុគ្គលជាមេត្រីភក្ដិរបស់ខ្លួន ក៏គ្មានទំនងដែរ ព្រោះអ្វីៗទាំងអស់ក្នុងលោកវាសុទ្ធតែមានជំនាប់ ឬទំនាក់ ឬប្រព័ន្ធ ដោយច្រវាក់មាស ដែលចងក្រៀកភ្ជាប់នៅក្រោមព្រះបាទនៃព្រះអាទិទេព»

ខ្ញុំបានបង្ហាញហេតុផល ក្នុងបទកវីរបស់អ្នកនិពន្ធរាល់ផ្នែក ទាំងផ្នែកសំពះអង្វរ ទាំងផ្នែកមិនសំពះអង្វរ ដើម្បីអ្នកអានប្រើវិចារណញ្ញាណ អារកាត់សេចក្ដីខ្លួនឯង ហើយភ្ជាប់ជំនឿ ឬប្រកាន់យកបែបណាមួយតាមពន្លឺនៃគំនិតរបស់ខ្លួន នៅក្នុងក្របខ័ណ្ឌនៃសេរីភាពខាងផ្លូវចិត្តវិញ្ញាណ ដែលពុទ្ធសាសនិកធ្លាប់ប្រើហើយ នឹងប្រើតទៅទៀត ក្នុងពុទ្ធសាសនារបស់យើង ។

## ពុទ្ធសាសនាបង្រៀនឲ្យចូលចិត្តច្បាប់នៃកម្ម

ពាក្យថាច្បាប់នៃកម្ម បើនិយាយឲ្យស្ដាប់បានងាយៗ គឺច្បាប់នៃហេតុផល ដែលធ្លាប់ចូលចិត្តផងគ្នាមកហើយថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ព្រោះហេតុដែលពុទ្ធសាសនាប្រកាន់យកថា ពិភពលោករមែងប្រព្រឹត្តទៅតាមកម្ម គឺទំរើគ្រប់យ៉ាង ដែលលោកញែកចេញជាប្រភេទឲ្យឃើញថា មនុស្សនិងសត្វមានលក្ខណៈផ្សេងងៗគ្នា ខ្លះល្អ ខ្លះអាក្រក់ ទើបអាចធ្វើគម្រោហធម្មៈបាន ។

ពុទ្ធសាសនាមិនទទួលស្គាល់អ្វីៗ ដែលយើងចង់ថា ចៃដន្យ ឬអំណាចមានភាពស្ទាត់ ភាពអាថ៌កំបាំង ឬវត្ថុស័ក្តិសិទ្ធណាៗទាំងអស់ ។ ពុទ្ធសាសនាបានព្យាយាមប្រឈមមុខជាមួយនិងហេតុផលគ្រប់ប្រការ ដោយគ្មានបានប្រគល់ឲ្យវត្ថុស័ក្តិសិទ្ធសូម្បីបន្តិចបន្តួចឡើយ ។ ព្រោះហេតុនេះ ចម្លើយពុទ្ធសាសនា ទើបមានចំពោះហេតុការណ៍រាល់យ៉ាងក្នុងជីវិតមនុស្សថា គ្មានកើតឯងទទេៗបានឡើយ គឺមានជាប់ទាក់ទងមកពីហេតុផលទាំងអស់ ។

ដោយអាស្រ័យហេតុដូចបានពោលមកនេះ បុគ្គលម្នាក់ៗមិនត្រូវបើមើលងាយសេចក្ដីល្អ ឬបុណ្យថាគ្មានន័យឡើយ សេចក្ដីល្អទោះតិចក្ដី ច្រើនក្ដី ត្រូវតែមានន័យជាដរាប ដូចគ្នានឹងធាតុមាស ទោះណាជាមានចំនួនតិច មានទម្ងន់ស្រាល ក៏គង់មានតម្លៃច្រើនជាងធាតុខ្សាច់ ដែលមានចំនួនរាប់រយរាប់ពាន់រទេះ ។ ក្នុងទំនាក់ទំនងដូចគ្នានេះទៀត បុគ្គលមិនគប្បីមានគំនិតមើលងាយ ទំរើអាក្រក់ ឬបាបថា គ្មានន័យឡើយ ទំរើអាក្រក់ ទោះតិចក្ដីច្រើនក្ដីត្រូវតែមានន័យជាដរាប, ដូចគ្នានឹងដុំភ្លើង សូម្បីមានទំហំយ៉ាងតូចប៉ុនភ្នែកមាន់ ក៏គង់មានកម្ដៅធ្វើឲ្យរលាកដៃ ឬធ្វើឲ្យឆេះផ្ទះរាប់រយពាន់ខ្នងបានដែរ ។ នៅក្នុងព្រះទ័យប្រកបដោយសេចក្ដីមេត្តា ទើបព្រះសម្មាសម្ពុទ្ធបង្រៀន

ឲ្យស្នេហាសុខ ព្យាយាមគេចបាប ទោះជាបាបនោះមានទំហំតូចក្តី ធំក្តី ។ ជាមួយគ្នានេះ បង្រៀនឲ្យព្យាយាមជួបបុណ្យ ទោះជាបុណ្យនោះមានចំនួនតិចក្តី ច្រើនក្តី ។ ព្រោះធាតុទាំងពីរនេះ បានផ្តល់ឲ្យមនុស្សនូវភាពត្រជាក់ និងភាពក្តៅ ឬភាពសុខ និងភាពទុក្ខដែលយើងអាចស្តីម៉្យាងទៀតថា សុខទុក្ខក្តៅត្រជាក់ ជារង្វាន់របស់បុណ្យបាប ពុំមែនជាអំណោយរបស់ព្រះ អង្គណាមួយឡើយ ។

## កម្ម ១២ ប្រភេទ

ពុទ្ធសាសនាបានចំណាត់កម្ម គឺទំរើដែលមនុស្សបានធ្វើ ហើយត្រូវបានទទួលផលមានលក្ខណៈផ្សេងៗគ្នា នោះមាន ១២ ប្រភេទ ។ បើនិយាយជាពួកមានបីពួក ក្នុងពួកមួយៗមាន ៤ ចំណុច ។ល។

(សូមមើលសៀវភៅពុទ្ធវិទ្យារឿងបុណ្យបាបប្រកបផង) ។

## ពាក្យបង្រៀនរឿងមានខ្លួននិងមិនមានខ្លួន

ក្នុងបទនេះបាននិយាយរឿងត្រូវពឹងខ្លួនឯង ទាក់ទងជាប់គ្នាមួយចប់ នាំឲ្យមានបញ្ហាចោទឡើងថា ព្រះពុទ្ធសាសនាបានបង្រៀនគំនោលធម្មៈ សំខាន់មួយដែលហៅថា **ត្រៃលក្ខណ៍** គឺលក្ខណៈ ៣ យ៉ាង បានដល់ ភាពជារបស់មិនទៀង, ភាពធន់ទ្រាំនៅយូរពុំបាន, ភាពជារបស់មិនមែនខ្លួនប្រាណ ។ កាលបើដូចនេះ, មិបានន័យថា ពុទ្ធសាសនាបានបដិសេធខ្លួនចោលទៅហើយ ហេតុអ្វីទើបមានពាក្យបង្រៀនឲ្យមនុស្សពឹងខ្លួន មេរៀននេះ មិនទៅជាទំនាស់គ្នាទៅហើយឬ?

ចំពោះបញ្ហានេះ, ខ្ញុំសូមឲ្យចម្លើយថា គ្មានទំនាស់គ្នាទេ ព្រោះពុទ្ធសាសនាបង្រៀននៅក្នុងក្របខ័ណ្ឌពីរ គឺឲ្យមនុស្សប្រកាន់យក ឬអនុវត្តជាបទសម្មតិកម្មផង ជាបទបរមត្ថកម្មផង ជាបទសន្មត គឺរឿងដែលមនុស្សលោកធ្លាប់បានធ្វើការកត់សម្គាល់ ឬធ្លាប់ហៅ ធ្លាប់និយាយគ្នាស្តាប់បានចូលចិត្តបានយ៉ាងណា ធ្វើយ៉ាងនោះទៅ ។ ជាបទបរមត្ថគឺស្រាវជ្រាវរាវរកខ្លឹមសារ ឬភាពពិតប្រាកដដែលគ្មានជាប់ចំពាក់ទាក់ទិនអ្វីដល់សម្មតិសូម្បីបន្តិចបន្តួចឡើយ ។ ដើម្បីការពារគំនិតភ័ន្តច្រឡំ, ខ្ញុំសូមបញ្ជាក់ថា ព្រះពុទ្ធសាសនាបានទទួលស្គាល់, ទទួលប្រើប្រាស់ទាំងសម្មតិ ទាំងបរមត្ថ សឹងមានក្នុងគម្ពីរបាលីមួយអន្លើនិងគំនិតស្រាវជ្រាវជាស្រេចមកហើយ ។ ប្រែថាបរមត្ថកម្មជាធាតុស្រាវជ្រាវរុករកឃើញតាមសច្ចធម៌ ចាត់ចូលក្នុងពួកធម៌មានខ្លឹមសារពិតៗមែនៗ មិនត្រឹមតែជាសម្មតិកម្មឡើយ ។ ដើម្បីជាពន្លឺក្នុងរឿងនេះ, ខ្ញុំសូមឲ្យតួយ៉ាងដូចមានតទៅ :

ព្រះសម្មាសម្ពុទ្ធ បង្រៀនឲ្យមនុស្សយើង ចេះស្រឡាញ់រាប់អានបងប្អូនគ្រូអាចារ្យមាតាបិតាញាតិមិត្រ ។ល។ ឲ្យរៀបចំទុកដាក់ខ្លួនប្រាណ ឬឲ្យរស់នៅក្នុងភាពគោរពប្រតិបត្តិគួរសម ជាមួយនិងបុគ្គលទាំងឡាយនោះ នៅក្នុងក្របខ័ណ្ឌនៃចរិយាថ្លៃថ្នូរអស់កាលជានិច្ចនិរន្តរ៍ ដែលលោកហៅថា **បរិសញ្ញុតា** ស្គាល់ឋានៈប្រជុំជន ឬ **បុគ្គលញ្ញុតា** ស្គាល់បុគ្គលដែលត្រូវគោរព ត្រូវប្រាស្រ័យទាក់ទង គឺចេះប្រើឥរិយាបថឲ្យស៊ីនឹងឋានៈនៃមនុស្ស ដោយប្រកាន់យកសីលធម៌ ឬធម្មៈចរិយាជាបទ្ធាន់ ។ ការបង្រៀនដូចនេះ ឈ្មោះថាពុទ្ធសាសនាបានទទួលស្គាល់ សម្មតិធម៌របស់ពិភពលោកហើយ ។

តែការបង្រៀនឲ្យមនុស្សចេះធ្វើការពិចារណា ដល់របស់ទាំងឡាយ ទាំងពួង ដើម្បីឲ្យស្គាល់ទាន់តាមភាពពិតនៃរបស់ទាំងឡាយ ទាំងពួងបន្ថែមទៅលើសម្គាល់ដែលសព្វសត្វធ្លាប់មានមកហើយនោះ គឺព្រះអង្គត្រូវការឲ្យមនុស្សយើងមើលឃើញនូវភាពនៃសេចក្តីពិត ដែលមាននៅក្នុងមនុស្សសត្វបុគ្គល និងរបស់អ្វីៗទាំងអស់ថា របស់ទាំងនេះវាមានភាពត្រូវគ្នា គឺមិនទៀងទាត់ ធន់ទ្រាំមិនបាន គ្មានខ្លួនប្រាណ គ្មានសត្វបុគ្គល គ្មានគេយើង ។ ទាំងរបស់ទាំងខ្លួនគេ ទាំងខ្លួនយើង វាមានលក្ខណៈត្រឹមជាធាតុផ្សេងៗមករួមគ្នា ហើយកើតបានជាវចីសម្មតិថា អ្នកនេះ អ្នកនោះ របស់នេះ របស់នោះ ។ ភាពទាំងឡាយនេះកាលណាត្រូវញែកចេញពីគ្នា ឬត្រូវផ្លាសគម្រោង

ឬផ្លាស់ទម្រង់ ក៏កើតមានសម្មតិវោហារថា «ស្លាប់» នេះគឺជាសេចក្ដីពិតនៃក្បួនធម្មជាតិ ដែលយើងស្គាល់ថាកើតស្លាប់ ឬផ្លាស់ប្ដូរភាព ដែលមាននៅក្នុងលោកយើងនេះអស់កាលជានិរន្តរ៍ ។

ព្រះពុទ្ធសាសនារស់នៅបាន ព្រោះចេះប្រើសម្មតិកម្ម និងចេះប្រើបរមត្ថកម្មត្រឹមត្រូវតាមចំណុចរឿង ។ មនុស្សលោកសឹងធ្លាប់រស់នៅ ជាមួយនិងសម្មតិជាយូរណាស់ហើយ ក៏មានការចាប់អារម្មណ៍ពេញចិត្តថាពុទ្ធសាសនាមានគំនិតឆ្លៀវឆ្លាត ចេះពន្យល់យ៉ាងល្អប្រសើរ សមគួរដល់សេចក្ដីត្រូវការរបស់មនុស្សលោកផងឲ្យមនុស្សលោករស់នៅក្នុងសេចក្ដីសុខចម្រើនផង ។ ជាមួយគ្នានេះ, អ្នកប្រតិបត្តិធម៌ ក៏កើតគំនិតចេះពិចារណាឃើញទាន់នូវអ្វីៗ ទាំងអស់រួមទាំងពិភពលោកផង ថាជារបស់ប្រព្រឹត្តទៅតាមសភាវពិត ។ ដោយអាស្រ័យគំហើញនេះ, គេទាំងឡាយតែងមានសម្បជញ្ញៈអប្បមាទ គ្មានចំពាក់ គ្មានច្រឡំរឿងលុះត្រាជ្រុលហួសព្រំដែននៃសច្ចធម៌ ។

រឿងអត្តា ការប្រកាន់ថាមានខ្លួនប្រាណក៏មានទំនាក់ទំនងប្រហែល នឹងរឿងដែលបាននិយាយមកហើយដែរ, មនុស្សលោកគេមានជំនឿយ៉ាងណា មានគំនិតប្រកាន់យ៉ាងម៉េច ក៏យ៉ាងនោះទៅ ។ ពុទ្ធសាសនាមិនបដិសេធមិនជំទាស់ទេ ។ ពុទ្ធសាសនាព្រមទទួលយកពំនោល និងគំនិតរបស់គេមកប្រើ ដើម្បីបង្រៀនគេឲ្យចេះស្គាល់ខ្លួនឯង, ចេះពឹងខ្លួនឯង, តែក្នុងពេលព្រមគ្នានេះ ខាងធម្មៈជាន់ខ្ពស់ក៏ត្រូវបានលើកយកមកបង្រៀន ឲ្យគេដឹងថារបស់នេះជារបស់ដែលកើតឡើងដោយសន្មត (សម្មតិ) ។ សម្មតិនេះត្រូវបានគេអនុវត្ត គឺគេព្រមព្រៀងហៅឬនិយាយថា មនុស្សសត្វបុគ្គលទ្រព្យសម្បត្តិ ។ល។ ជាហូរហែរហូតមក ។ ការពិត, វាមិនមែនជាមនុស្សសត្វទេពឥន្ទព្រហ្មអ្វីទេ គឺវាជាទម្លាប់នៃគំនិត នៃពំនោលរបស់មនុស្ស ដែលយើងស្គាល់ថា សន្មតដើម្បីធ្វើការកត់សម្គាល់ដើម្បីហៅ ឬដើម្បីនិយាយប៉ុណ្ណោះ ។ ចំណែកខាងក្បួនសច្ចធម៌ឯណោះវិញ ដុំមួយៗក្ដី ភាពមួយៗក្ដី រូបមួយៗក្ដីដែលយើងអាចស្គាល់បានថា មនុស្សសត្វ ភ្នំដើមឈើនោះ ។ល។ ប្រសិនបើធ្វើការវែកញែកតាមគំនិតបរមត្ថឲ្យដល់ទីបំផុតរបស់វានោះហើយ ក៏គ្មានឃើញអ្វីទាំងអស់ គឺវាគ្មានសត្វ គ្មានមនុស្ស គ្មានខ្លួនប្រាណហ្នឹងមែនៗ ។

សេចក្ដីចេះដឹងរបស់យើងនេះ, លោកថាជាសេចក្ដីចេះដឹងបានគ្រប់ទាំងពីរវិស័យ គឺវិស័យសម្មតកម្ម និងបរមត្ថកម្ម ឬវិស័យខាងក្រៅនិងវិស័យខាងក្នុងឈ ដោយគ្មានទំនាស់គ្នាត្រង់ប្រការណាមួយឡើយ ។

# បទទី ១១

## ពុទ្ធសាសនាជាមួយនិងវិទ្យាសាស្ត្រ

«ព្រះពុទ្ធសាសនាមានគោលការណ៍ និងកម្មវិធីបង្ហាត់បង្រៀនមួយអន្លើនិពាក្យឱវាទ (ដំបូន្មាន) ជាវិទ្យាសាស្ត្រ តាំងពីមុនវិជ្ជាវិទ្យាសាស្ត្ររបស់ពិភពលោក នៅមិនទាន់កើតបានជាដុំកំភួននៅឡើយ»

## ដំណើងវិទ្យាសាស្ត្រ

ពាក្យថា «វិទ្យាសាស្ត្រ» ដែលយើងប្រើជាភាសាខ្មែរសព្វថ្ងៃ ។ ពាក្យនេះប្រែមកពីពាក្យអង់គ្លេសថា SEINENCE ។ អង់គ្លេសបានខ្ចីពាក្យនេះ មកពីភាសាឡាទីនថា SEINTIA ម៉្យាងទៀតប្រែថា សេចក្តីដឹង ឬស្គាល់ KNOWLEDGE ។ ព្រំដែននៃវិជ្ជាវិទ្យាសាស្ត្រនោះ បានដល់បណ្តាដំណឹង ស្តីដោយឯកភាពផ្នែកខាងវត្ថុ ឬរូបធាតុទាំងពួង (PHYSICAL UNIVERSE) ។ និយាយយ៉ាងងាយៗ គឺរបស់ទាំងពួងក្នុងលោកនេះ និងលោកដទៃដែលមានរូប, មានខ្នាត ឬមានទម្ងន់ អាចធ្វើការកត់សម្គាល់បាន ដោយប្រសាទសម្ផស្ស ឬប្រព័ន្ធប្រសាទទាំង ៥ គឺភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត និងកាយ ។ ក្នុងចំណុចថា របស់ទាំងពួងក្នុងលោកនេះ និងលោកដទៃ ដែលមានរូបរាងនោះ ។ លោកនេះគឺពិភពលោក ដែលយើងរស់នៅ យើងស្គាល់សព្វថ្ងៃនេះ ។ លោកដទៃ ដៅយកដួងអាទិត្យ ដួងចន្ទ និងដួងផ្កាយនពគ្រោះនានា ទាំងនៅក្នុងសុរិយចក្រវាលនេះ និងក្នុងសុរិយចក្រវាលដទៃ ។ វិទ្យាសាស្ត្រ, មានគម្រោងការសិក្សាប្រកបដោយរបៀបយ៉ាងញឹកល្អិត មានការល្បងពិសោធ ការសង្កេត ការត្រួតពិនិត្យនៅក្នុងក្របខ័ណ្ឌនៃសច្ចភាព នៃហេតុផល គឺគ្មានប្រើជំនឿប្រាសចាកសច្ចភាវៈឡើយ ។

## វិទ្យាសាស្ត្រ ២ ប្រភេទ

១- វិទ្យាសាស្ត្រកាយភាព ឬរូបនិយម (PHYSICAL SEIENESS) ជាវិទ្យាសាស្ត្រស្តីដល់វត្ថុ ដែលមិនមានចិត្តគ្រប់គ្រង ឬដែលគ្មានជីវិតទាំងឡាយ ។ ពោលតាមភាសាវិទ្យាសាស្ត្រ បានដល់ការត្រួតពិនិត្យ រាវរកប្រាកដការដ៏ជាមូលដ្ឋាននៃរូបធាតុ ។ ពាក្យថារូបធាតុ បានដល់របស់ដែលមានខ្នាត, មានទម្ងន់ ឬមានកំណាន់ទី (មានកន្លែងនៅអាស្រ័យ) ។

២- វិទ្យាសាស្ត្រជីវភាព ឬជីវៈ (BIOLOGICAL, SEIUCES) ជាវិទ្យាសាស្ត្រស្តីដោយវត្ថុមានជីវិតទាំងឡាយ មានដើមឈើគ្រប់ពីជៈ (ពូជ) និងសត្វគ្រប់បប្រភេទ ដែលហៅម៉្យាងទៀតថា ឥន្ទ្រីយ៍ (ORGANISM) និយាយតាមភាសាវិទ្យាសាស្ត្រ បានដល់ការត្រួតពិនិត្យ រុករកប្រាកដការ មានច្រើនជាន់ ច្រើនស្រទាប់ ដែលកប់នៅក្នុងជីវិតទាំងឡាយ ។

វិទ្យាសាស្ត្រជីវភាពនេះ ចួនកាលហៅថា (NATURAL SCIENCE) ។ វិទ្យាសាស្ត្រធម្មជាតិនេះ ក្នុងសម័យបូរាណគេហៅថា NATURAL HISTORY សេចក្តីចេះដឹងក្នុងរឿងធម្មជាតិ សឹងដៅយកវិជ្ជាស្តីដោយពីជៈនិងសត្វ គឺរុក្ខសាស្ត្រនិងសត្វសាស្ត្រ (នឹងស្តីពិស្តារក្នុងខាងមុខ) ។

## វិទ្យាសាស្ត្រ ៣ ប្រភេទ

ក្នុងរយៈកាលតៗមក មនុស្សបានកំណត់វិជ្ជាវិទ្យាសាស្ត្របន្ថែមមួយទៀត លើប្រភេទ ២ ខាងដើម ហៅថា វិទ្យាសាស្ត្រសង្គម (SOCIAL SCIENCES) តែក្នុងប្រទេសខ្មែរយើងមិនសូវនិយមហៅថា វិទ្យាសាស្ត្រ, យើងច្រើនប្រើពាក្យថា សង្គមសាស្ត្រជំនួសវិញ ។ យ៉ាងណាក៏ដោយ, ពិភពលោកបានទទួលស្គាល់វិទ្យាសាស្ត្រប្រភេទនេះស្រេចហើយ ដោយបានចំណាត់វិជ្ជាទាំងឡាយនេះ គឺសង្គមវិទ្យា មនុស្សវិទ្យា សេដ្ឋសាស្ត្រ ទន្ទវិទ្យា និងចរិយាសាស្ត្រជាដើម ចូលក្នុងវិជ្ជានៃវិទ្យាសាស្ត្រផ្នែកសង្គម ។ តែចំពោះចិត្តវិទ្យាមួយ, អ្នកវិទ្យាសាស្ត្របានចាត់ចូលក្នុងវិទ្យាសាស្ត្រទាំងពីរប្រភេទ គឺប្រភេទចិត្តនិយមផង រូបនិយមផង (នៅក្នុងចន្លោះចិត្តនិងរូប) គឺចិត្តវិទ្យាទូទៅ នៅក្នុង

វិទ្យាសាស្ត្រជីវភាព ចិត្តវិទ្យាសង្គមត្រូវនៅក្នុងវិទ្យាសាស្ត្រផ្នែកសង្គម ។ ហេតុដែលអ្នកវិទ្យាសាស្ត្រ ចាត់វិជ្ជាផ្សេងៗ ផ្នែកខាងសង្គម ចូលជាវិទ្យាសាស្ត្រក៏ព្រោះត្រូវការឲ្យមានស្ថិតិពិតច្បាស់លាស់ ការត្រួតពិនិត្យ ការសង្កេត ការល្បងពិសោធ ទាំងអស់នេះជាពិធីការនៃវិទ្យាសាស្ត្រ ឬជាលក្ខណៈនៃវិទ្យាសាស្ត្រ គ្រប់ជ្រុងទាំងអស់តែម្តង គឺកុំឲ្យនិយាយតាមតែមាត់ចង់, ចិត្តនិយម ដោយគ្មានអ្វីជាគោលការណ៍ឲ្យបានជាក់លាក់ ។

## ពំនោលពិស្តារដល់មែកធាងនៃវិជ្ជាវិទ្យាសាស្ត្រ

កាលណាគេបានចែកវិទ្យាសាស្ត្រ ជាវិទ្យាសាស្ត្រកាយភាព (ស្តីដោយរបស់គ្មានជីវិត) មួយអន្លើដោយ វិទ្យាសាស្ត្រជីវភាព (ស្តីដោយរបស់មានជីវិត) និងវិទ្យាសាស្ត្រសង្គមដូចនេះហើយ ។ អ្នកសិក្សាគប្បីដឹងថា វិទ្យាសាស្ត្រក្នុងប្រភេទមួយៗ បានមានវិជ្ជាសាខាទៅទៀតយ៉ាងណាខ្លះ នេះត្រឹមតែជាសេចក្តីចូលចិត្តខ្លីៗ នៃធាតុ ដែលមានឈ្មោះថា វិទ្យាសាស្ត្រ ។ ព្រមគ្នានេះទៀត, យើងត្រូវចូលចិត្តក្របខ័ណ្ឌជាប្រយោជន៍នៃវិទ្យាសាស្ត្រ ដើម្បី ប្រៀបធៀប ជាមួយនិងប្រយោជន៍នៃព្រះពុទ្ធសាសនារបស់យើង ។

### ក- វិទ្យាសាស្ត្រកាយភាព

វិទ្យាសាស្ត្រចំណែកនេះ មានវិជ្ជាហ្វីសិក្ស៍ និងគីមីជាវិជ្ជាដែលគេចាត់ទុកជាវិជ្ជាមូលដ្ឋាន ហើយមានវិជ្ជា ច្រើនទៀតដែលកើតមកពីវិជ្ជាមូលដ្ឋាននេះ គឺធរណីវិទ្យា តារាវិទ្យា ឧតុនិយមវិជ្ជា ។ល។ ក្នុងទីនេះ, ខ្ញុំសូមលើក យកខ្នែងវិជ្ជាមួយៗ មកធ្វើសេចក្តីអធិប្បាយខ្លីៗ តាមតម្រាវិទ្យាសាស្ត្រដូចមានតទៅ ។

#### ១- ហ្វីសិក្ស៍ (PHYSICES)

ប្រែតាមតួអក្សរ វិជ្ជានេះ បានផ្តល់រូបកាយ, វត្ថុ ឬរូបធម៌ ។ និយាយខ្លីៗ គឺជាវិជ្ជាស្តីដោយរបស់ផ្សេងៗ ដែលគ្មានទាក់ទងគ្នាជាមួយនិងជីវិត ។ ចែកចេញជាសាខាមាន ៦ យ៉ាងទៀតគឺ : កលសាស្ត្រ, កម្តៅ, សំឡេង, ពន្លឺ, មេដែកនិងអគ្គិសនី ។ ដើមឡើយវិជ្ជហ្វីសិក្ស៍ គេហៅថា NATURAL PHILOSOPHY (ទស្សនវិជ្ជាស្តីដោយ ធម្មជាតិ) សំដៅយកវិជ្ជា ស្តីអំពីវត្ថុគ្មានជីវិតជាពាក្យគូនិងពាក្យថា NATURAL HISTORY (សេចក្តីដឹងស្តីដោយ ធម្មជាតិ) សឹងដៅយកវិជ្ជាស្តីដោយរបស់មានជីវិត ដូចជាព្រឹក្សាសាស្ត្រនិងសត្វវិទ្យា ។ ដើម្បីជាពន្លឺដល់អ្នកអាន ខ្ញុំសូមធ្វើការវែកញែក ជាមួយនិងសេចក្តីអត្ថាធិប្បាយខ្លីៗ អំពីសាខានៃវិជ្ជាហ្វីសិក្ស៍ទាំង ៦ យ៉ាងនោះឲ្យឃើញថា មានអត្ថន័យផ្សេងគ្នាយ៉ាងណាខ្លះ ដូចមានតទៅ ។

**១- កលសាស្ត្រ**(១) (MECHANICS)វិជ្ជាស្តីដោយភាពចលនានិងចក្រវាល ។ ចែកចេញជាកលសាស្ត្រ ផ្នែករបស់រឹង, កលសាស្ត្រផ្នែករាវ និងកលសាស្ត្រផ្នែកហ្គាស ។ កលសាស្ត្រផ្នែករឹង ស្តីដោយការសិក្សាដល់កម្លាំង និងចលនា (ការកម្រើករញ្ជួយ ) ដែលចេះតែមានការលូតលាស់ចម្រើនឡើង កើតបានដោយវិជ្ជាវិស្វកម្មចក្រកល ។ កលសាស្ត្រផ្នែករបស់រាវ ស្តីដោយការសិក្សាដល់ភាព ប្រព្រឹត្តទៅនៃរបស់រាវ និងភាពប្រព្រឹត្តទៅនៃរបស់រឹង កាលនៅខាងក្នុងរបស់រាវនិងច្បាប់នៃការអណ្តែតជាដើម ។ កលសាស្ត្រផ្នែកហ្គាស ស្តីដោយការសិក្សាអំពី គុណសម្បត្តិរបស់ហ្គាសខាងក្រោមនៃភាពអំណូសផ្សេងៗ ។

**២- កម្តៅ** (HEAT)ស្តីដោយកម្តៅក្នុងវិស័យផ្សេងៗ និងសេចក្តីប្រព្រឹត្តទៅរបស់លោកធាតុទាំងឡាយ ក្នុងពេលត្រូវកម្តៅ ។ វិទ្យាសាស្ត្រដែលស្តី ដោយកម្លាំងថាមពលដ៏ទាក់ទងជាមួយនិងកម្តៅគ្រប់បែប សឹងជាហេតុ ឲ្យកើតការប្រតិស្នកម្ម ឬការបង្កបង្កើតគ្រឿងចក្រចំហាយទឹក និងរថយន្តគ្រប់ប្រភេទ ។ ទំរើ ឬចលនាទាំងអស់នេះ សុទ្ធតែត្រូវអាស្រ័យការចេះដឹង ជាប់ទាក់ទងគ្នាជាមួយនិងកម្តៅជាមូលដ្ឋាន ឬជាឫសគល់ ។

**៣- សំឡេង**(SIGHT)ស្តីដោយរឿងស្នូរសំឡេង, រលកសំឡេងមូលហេតុឲ្យចេញសំឡេង ឬឲ្យកើត

---

(១) កលសាស្ត្រ, តម្រាស្តីអំពីល្បិចអាថ៌កំបាំងរបស់ធម្មជាតិទាំងឡាយ ។

សំឡេង ឬឲ្យសំឡេហាធ្វើចលនា ។ គេសិក្សាឲ្យចេះរឿងនេះ ដើម្បីបង្កើតគ្រឿងតន្ត្រី ថាសសំណួរ គ្រឿងពង្រីងសំឡេង វិទ្យុ ភាពយន្តនិយាយបាន និងគ្រឿងចាប់ ឬគ្រឿងថតសំឡេងជាដើម ។

**៤- ពន្លឺ** (LIGHT)ស្ដីដោយចំណាំងពន្លឺ ធ្វើឲ្យកើតការសិក្សាដល់គ្រឿងទស្សនសាស្ត្រ (OPTICS) សឹងឲ្យចំណេះដំណឹងរឿងលេ៉នស៍ ជាហាតុឲ្យប្រតិស្នកម្ម ឬប្រអប់ថតរូប, ប្រអប់ទូរទស្សន៍, ប្រអប់អតិសុខុមទស្សន៍ គ្រឿងបញ្ចូល និងគ្រឿហទទួលទូរទស្សន៍កែវជំនួយភ្នែក (វ៉ែនតា) និងភាពយន្ត ។ល។

**៥- មេដែក** (MAGNETISM)ស្ដីដោយគុណសម្បត្តិ ដែលធ្វើឲ្យរូបធាតុមួយ មានអំណាចធក់ស្រូបរូបធាតុមួយទៀត, វិជ្ជានេះមានភាពប្រព័ន្ធយ៉ាងជិតដិតជាមួយនិងវិជ្ជាអគ្គិសនី ។ កាលណាគេបានសិក្សាវិជ្ជានេះ គេមានសមត្ថភាពដឹងរឿងរបស់ទូរស័ព្ទ, ទូរលេខ, វិទ្យុទូរលេខ និងគ្រឿងចក្រ ដែលធ្វើឲ្យកើតកម្លាំងថាមពលនានា ។ល។

**៦- អគ្គិសនី** (ELECTRICITY)ស្ដីដោយចំណែកប្រកបរបស់រូបធាតុទាំងឡាយ នៅក្នុងក្របខ័ណ្ឌនៃការកាត់ច្រៀកឲ្យជាភាគតូចៗ ល្អិតៗ បន្តិចម្ដងៗ ឲ្យដល់ទីបំផុត លុះត្រាចេញជាកម្លាំងថាមពល ។ អគ្គិសនីបូកនិងអគ្គិសនីលុប ស្ដីដោយចរន្តអគ្គិសនី រលកអគ្គិសនី រលកវិទ្យុនិងទំរើនានា ដែលឲ្យកំណើតប្រតិស្នកម្មគ្រប់បែបយ៉ាងទាក់ទងជាមួយគ្នានិងចរន្តអគ្គិសនី, ផ្លិតវិល, រថត្រាំវ៉េ, រថភ្លើងដែលដើរដោយចរន្តអគ្គិសនី ។ល។

## ២- គីមី (CHEMISTRY)

វិជ្ជានេះស្ដីដោយចំណែក ប្រកបចូលរបស់រូបធាតុ និងបន្លាស់ដំណូររបស់រូបធាតុក្នុងពេលរួមចូលគ្នា ឬញែកចេញពីគ្នា (រូបធាតុបានដល់របស់ដែលមានខ្នាត មានទំហំ មានទម្ងន់ និងកន្លែងនៅអាស្រ័យ ទោះជារបស់រឹង (ខាប់) ឬរាវ (ជ្រាយ) ឬហ្គាសក៏ដោយ) ។

វិជ្ជាហ្វីសិក្ស៍និងគីមីទាំងពីរនេះ ជាវិជ្ជានៅជិតគ្នាយ៉ាងច្រើន ដើម្បីជៀសវាងការភ័ន្តច្រឡំ គេត្រូវដឹងនូវភាពផ្សេងគ្នានៃវិជ្ជាទាំងពីរដូចនេះគឺ ហ្វីសិក្ស៍និយាយអំពីកម្លាំង ភាពញ័ររញ្ជួយ កម្ដៅ សំឡេង ពន្លឺ មេដែកនិងអគ្គិសនី ។ បើសិក្សាដល់រូបធាតុ គេត្រូវសិក្សាដល់គុណសម្បត្តិ សាមញ្ញទូទៅរបស់រូបធាតុគ្រប់បែបយ៉ាងព្រោះបន្លាស់រូប និងបន្លាស់សភាវៈសូម្បីមាន ក៏គ្មានបន្លាស់បែប ឬទម្រង់ឡើយ តួយ៉ាង : ដូចដើមឈើ ត្រូវគេផ្លាស់រូបវាជាតុ ទូ កៅអី ។ល។ តែឋានៈដើមរបស់វាគេគ្មានផ្លាស់ គ្មានដូរកើតទេ គឺវានៅជាឈើដដែល ។ ចំណែកគីមីស្ដីដោយប្រាកដការផ្សេងៗរបស់រូបធាតុ, ក្នុងពេលរួមគ្នា ឬញែកគ្នា ឬក្នុងពេលត្រូវកម្ដៅ ។ល។ ដូចឈើផ្លាស់ភាពជាធ្យូងកាលត្រូវភ្លើងឆេះ ឬដែកត្រូវផ្លាស់ជាច្រេះ ជាស្នឹម កាលណាត្រូវទុកចោលហាលភ្លៀងខ្យល់យូរពេក ព្រោះដែកមានទំរើប្រតិកម្មជាមួយនិងអាកាសអុកហ្ស៊ីហ្សែនជានិច្ចកាល ។

## ៣- តារាសាស្ត្រ (ASTRONOMY)

ជាវិជ្ជាស្ដីអំពីទេហវត្ថុ(១) គឺរបស់ដែលមានរូបរាងនៅលើផ្ទៃមេឃ (HEAVENLY BODIES) ដូចដួងអាទិត្យ (SUN) ផ្កាយគ្រោះ គឺផ្កាយដែលគ្មានពន្លឺរស្មីនៅក្នុងខ្លួន វាមានពន្លឺរស្មីដោយត្រូវអាស្រ័យ ឬត្រូវបានមកអំពីពន្លឺរស្មីនៃដួងអាទិត្យ ។ ផ្កាយគ្រោះទាំងឡាយ មានពិភពលោកយើង ពិភពអង្គារ ពិភពពុធ ពិភពព្រហស្បតិ៍ ពិភពសុក្រ ពិភពសៅរ៍ជាដើម ហៅថា PLANETS ។ ដួងចន្ទ (MOONS) បានដល់បរិវាររបស់ផ្កាយគ្រោះដែលគោចរព័ទ្ធជុំវិញពិភពលោករបស់យើង ក្នុងកំណត់វេលាមួយខែ ។ ចំណែកផ្កាយគ្រោះទាំងឡាយដទៃៗទៀត, ផ្កាយខ្លះមានដួងចន្ទជាបរិវារច្រើន ដូចផ្កាយព្រហស្បតិ៍ និងផ្កាយសៅរ៍មានដួងចន្ទជាបរិវារ ៩ ដួងរហូតដល់ ១០ ដួង ។ ផ្កាយដុះកន្ទុយ ឬផ្កាយមានដំណើរមិនសូវទៀងទាត់ និងផ្កាយ គឺដួងអាទិត្យទាំងឡាយដទៃៗទៀត, មានចំនួនច្រើន

(១) ទេហវត្ថុ, ពាក្យប្រើជាមួយនិងរូបធាតុនិងកាយធាតុដែរ ។

ឥតគណនា ។ តែនៅឆ្ងាយលានឆ្ងាយ, ទើបយើងមើលឃើញត្រឹមតែភាពដួងតូចៗ ល្អិតៗ រហូតដល់មើលមិនឃើញដោយភ្នែកធម្មតា, ហើយផ្កាយទាំងឡាយ ដែលយើងមើលឃើញតូចៗ នោះទៀតសោត ក៏ក្លាយទៅជាភាពគ្មានន័យ ព្រោះយើងពុំអាចធ្វើការកត់សម្គាល់កើតដោយទំហំតូចពេក ។ តែពិភពលោកដែលយើងបានដឹងដោយអាស្រ័យតម្រា និងពំនោលអ្នកតារាសាស្ត្រនោះ គេថាដួងផ្កាយខ្លះ មានទំហំធំជាងដួងអាទិត្យរបស់យើងជាងមួយពាន់ភាគ រហូតដល់ជាងមួយលានភាគក៏មាន គឺធំក្រៃលែងធំ ឆ្ងាយក្រៃលែងឆ្ងាយហ្នឹងឯង ។

### ៤- **ធរណីវិទ្យា** (GEOLOGY)

វិជ្ជានេះស្ដីអំពីគម្រោងសំណង់ចំណែកប្រកបចូល និងប្រវត្តិរបស់ពិភពលោក ចែកចេញជាសាខាធំៗ ២ គឺធរណីវិទ្យាទូទៅ (GENERAL GEOLOGY) ជាមួយនិងធរណីវិទ្យាប្រវត្តិសាស្ត្រ (HISTORICAL GEOLOGY) ក្នុងសាខាមួយៗ ចែកចេញទៅជាអនុសាខា មានយ៉ាងច្រើនទៀត ។

### ៥- **ឧតុនិយមវិទ្យា** (METEOROLOGY)

វិជ្ជានេះស្ដីដោយការសិក្សា ឲ្យស្គាល់ភាពកម្រើករញ្ជួយ ឬចលនាអាកាសធាតុ និងប្រាកដការរបស់បរិយាកាស (ATMOSPHERE) គឺអាកាសដែលមាននៅជុំវិញពិភពលោករបស់យើង ដើម្បីឲ្យដឹងថា អាកាសមានលក្ខណៈយ៉ាងណា បង្កើតឲ្យមានទំរើផ្លាស់ប្ដូរ របស់អាកាសទូទៅក្នុងភូមិភាគ នៃសកលពិភពលោក ឬក្នុងភូមិភាគនៃអាកាសទូទៅ ។ ក្នុងចំណុចនេះ, គេត្រូវសិក្សាឲ្យស្គាល់សីតុណ្ហភាព, ភាពសង្កត់អូសទាញរបស់អាកាស ទិសផ្លូវ និងភាពលឿនរហ័សនៃដំណើរខ្យល់ ។ ដើម្បីឆាប់ចេះវិជ្ជានេះ គេត្រូវមានគ្រឿងឧបករណ៍សម្រាប់វាស់សីតុណ្ហភាព គ្រឿងឧបករណ៍សម្រាប់ចាប់ពន្លឺរស្មីដួងអាទិត្យ គ្រឿងវាស់ទឹកភ្លៀងនិងទឹកសន្សើម ឬទឹកកក គ្រឿងវាស់ភាពកៀបសង្កត់ អូសទាញរបស់អាកាស ។ល។

## ខ- **វិទ្យាសាស្ត្រជីវភាព**

វិទ្យាសាស្ត្រប្រភេទនេះ ស្ដីដោយរបស់ដែលមានជីវិត, ទាំងពីជៈ (រុក្ខជាតិ) និងសត្វ ចែកចេញជាសាខាធំៗ មានពីរគឺ :

**១- រុក្ខសាស្ត្រ** (BOTANY) ស្ដីដោយពីជៈ(១) (ពូជ) និងដើមឈើគ្រប់បែប ។

**២- សត្វវិទ្យា** (ZOOLOGY) ស្ដីដោយសត្វគ្រប់បែប ទាំងសត្វសេល្ល៍ (កោសិកា) មួយ រហូតដល់ សេល្ល៍ច្រើនឥតគណនា ។

### ១- **រុក្ខសាស្ត្រ** (BOTANY)

ជាវិជ្ជាស្ដីដោយពីជៈពន្ធុឈើគ្រប់បែប ចែកចេញទៅទៀតជាច្រើនសាខាដូច :

១- BACTERILFGY វិទ្យាបែកតេរី ជាវិជ្ជាស្ដីដោយចុលិន្ទ្រីយ៍ (អតិសុខុមប្រាណ) ដែលមានចំណាត់នៅក្នុងប្រភេទពីជៈ មានរឿងដែលត្រូវសិក្សា ដូចជាបែកតេរីវីរ៉ែស ពីជសេល្ល៍ ។ល។

២- MYCOLOGY វិទ្យាមីកូ ជាវិជ្ជាស្ដីអំពីតិណជាតិផ្សិតផ្សេងៗ ទោះជាផ្សិតដុះលើដីក្ដី ដុះជាមួយនិងដើមឈើទាំងឡាយក្ដី ។

### ២- **សត្វវិទ្យា** (ZOOLOGY)

ជាវិជ្ជាសិក្សាអំពីសត្វគ្រប់បែប ចែកចេញទៅទៀតជាច្រើនសាខាដូច :

១- PROTO ZOOLOGY វិទ្យាប្រូតូហ្សូ ស្ដីដោយសត្វក្នុងថ្នាក់បឋមភូមិ ឬជាន់ដំបូង បានដល់សត្វសេល្ល៍មួយជាដើម ។

---

(១) ពីជៈជាពាក្យបាលី ខ្មែរហៅពូជ ច្រើនប្រើចំពោះរុក្ខជាតិនិងសត្វតិរច្ឆាន ។

២- GENERAL ZOOLOGYសត្វវិទ្យាទូទៅ ចែកចេញជាវិជ្ជាស្ដីអំពីស្លាបល្អិតៗ តូចៗ ក្នុងពួករុយ ពួកកណ្ដូប ឬកីដវិទ្យា[១] (ENTOMOLOGY) និវិជ្ជាស្ដីដោយសត្វបក្សី (ORNITHOLOGY) វិទ្យាស្ដីដោយត្រី ដែលហៅថា មិនវិទ្យា (ICHTHYOLOGY) វិជ្ជាស្ដីអំពីគ្រំ ឬខ្ចង (CONCHOLOGY) វិជ្ជាស្ដីដោយស៊ុត (ពង) និងវិជ្ជាទាំងឡាយដទៃទៀត ។ល។

ក្រៅអំពីព្រឹក្សាសាស្ត្រ និងសត្វសាស្ត្រនេះ នៅមានវិជ្ជារួមចូលគ្នាទៀត ដើម្បីអ្នកអានសិក្សាឲ្យបានជ្រៅជ្រះបន្តិច ខ្ញុំសូមធ្វើសំនេរតាមលំដាប់ដូចនេះ :

១- វិទ្យាស្ដីដោយគម្រោងសំណង់ ឬទម្រង់សមិទ្ធិ ឬសណ្ឋានវិទ្យា (MORPHOLOGY),

២- វិទ្យាស្ដីដោយចំណាត់ប្រភេទទាំងពីជៈនិងសត្វដែលហៅថា TAXONOMY,

៣- វិទ្យាស្ដីដោយទំរើការងាររបស់អវយវៈរាងកាយទាំងអស់របស់សត្វ និងរបស់ពីជៈ (ពូជ) ឬសរីរវិទ្យា PHYSIOLOGY,

៤- វិទ្យាស្ដីដោយភាពធ្លាប់ ភាពញៀន លំនៅដ្ឋាននិងប្រព័ន្ធភាព ក្នុងរវាងពីជៈនិងពីជៈ រវាងសត្វនិងសត្វ ដែលហៅថា ECOLOGY,

៥- ស្ដីដោយការសិក្សាដល់ទំរើអភិវឌ្ឍន៍ នៃជីវិតមួយៗទូទៅគ្រប់ជីវិតហៅថា វិទ្យាអេមបរីអូEMBRYOLOGY,

៦- វិទ្យាស្ដីអំពីការសិក្សាដល់អតីតប្រវត្តិ ដើម្បីឲ្យបានដឹងថា ពីជៈ ឬសត្វបែបនេះ មាននៅក្នុងបរភេទណា ។ ដើម្បីចេះដឹងវិជ្ជាប្រភេទនេះ អ្នកសិក្សាមានការចាំបាច់ត្រូវស្វែងរកល័ខឋាន អំពីសំណាកដែលមានសល់នៅក្នុងដី ឬក្នុងថ្ម ទោះជាសាច់ក្ដី ឆ្អឹងក្ដី ។ល។ ប្រយោជន៍ដើម្បីជាជំនួយ ក្នុងការធ្វើសេចក្ដីអធិប្បាយរបស់ខ្លួនឲ្យបានត្រឹមត្រូវ ហៅថា PALACONTOLOGY ។

## គ- វិទ្យាសាស្ត្រសង្គម

បើគេចាត់វិទ្យាសាស្ត្រត្រឹមតែពីរប្រភេទ ។ វិទ្យាសាស្ត្រខាងសង្គមគ្រប់យ៉ាង ត្រូវយកទៅរួមបញ្ចូលក្នុងវិទ្យសាស្ត្រជីវភាព ។ បើចែកចេញជា ៣ យ៉ាង វិទ្យាសាស្ត្រខាងសង្គមក៏ជាវិទ្យាសាស្ត្រមានសាខាច្រើន ដូចជាវិទ្យាសាស្ត្រទាំងឡាយដទៃដែរ គឺមានសាខាច្រើនប្រភេទដូចគ្នាគឺ :

១- សង្គមវិទ្យា (SOCIOLOGY)

២- មនុស្សវិទ្យា (ANTHROPOLGY)

៣- សេដ្ឋសាស្ត្រ (ECONOMICE)

៤- ទណ្ឌវិទ្យា (PENOLOGY) ស្ដីដោយការដាក់ទណ្ឌកម្ម ឬវិនិច្ឆ័យទោស ឬធ្វើកំណៃ,

៥- ភាសាសាស្ត្រ (LINGUISTICS)

៦- ចិត្តវិទ្យាសង្គម (SOCIAL PRYCHOLOGY)

៧- ចរិយាសាស្ត្រ (ETHICS) ។ល។

## សរុបសេចក្ដីផ្នែកវិទ្យាសាស្ត្រ

យើងបានអានផែនទីសង្ខេបនៃវិទ្យាសាស្ត្រគ្រប់សាខាហើយ, កំណាត់ព្រំដែននៃវិទ្យាសាស្ត្រ យើងអាចចែកបានជា ៣ ប្រការគឺ :

---

(១) កីដវិទ្យា, វិជ្ជាដែលស្ដីអំពីកណ្ដូប, តែគោលគំនិតនៃវិទ្យាប្រភេទនេះ ពុំបានសំដៅយកតែកណ្ដូបទេ គឺសំដៅយកសត្វ មានស្លាបតូចៗ ទាំងអស់មានកណ្ដូបជាដើម ។

១- ស្តីដោយអាណាចក្រ នៃរបស់ដែលមានជីវិតនិងកម្លាំងនៃថាមពល ចាប់តាំងពីដំណក់នៃទឹកសន្សើមលើផែនដី រហូតដល់ដួងផ្កាយ តាំងតែពីរឿងនៃអគ្គិសនី លុះត្រាដល់ច្បាប់នៃទំវើស្រូបទាញទាំងឡាយ របស់រូបធាតុមានផែនដីជាដើមហៅថា សកលបរិវេណ COSMOPHERE

២- ស្តីដោយអាណាចក្រនៃពីជៈនិងសត្វហៅថា ជីវបរិវេណ BIOSPHERE

៣- ស្តីដោយសង្គមមនុស្ស និងស្ថាប័នទាំងឡាយនៃមនុស្ស ទំនៀមទម្លាប់ ប្រពៃណី មរតកសង្គម (វប្បធម៌) សិល្បៈ វណ្ណកម្មនិងផលិតផលនានាហៅថា សង្គមបរិវេណ SOCIOS PHERE ។

ដើម្បីបង្កើតពន្លឺដល់គំនិតរបស់យើង, យើងគួរសិក្សាតទៅទៀត ដល់ក្របខ័ណ្ឌនៃព្រះពុទ្ធសាសនារបស់យើងខ្លះ ទើបចាប់ផ្តើមពិគ្រោះពិភាក្សាគ្នាក្នុងខាងក្រោយ តើពុទ្ធសាសនា ដែលជាវិទ្យាសាស្ត្រ ឬមានលក្ខណៈជាវិទ្យាសាស្ត្រ ឬប្រៀបបាននិងវិទ្យាសាស្ត្រ ដែលយើងធ្លាប់បានជជែកគ្នា ហើយមានយោបល់ស្របគ្នាក្នុងចំណុចខ្លះ និងមិនស្របគ្នាក្នុងចំណុចខ្លះនោះត្រូវផ្អែកលើអ្វី, ត្រូវធ្វើសេចក្តីបំភ្លឺដូចម្តេច?

## ការស្គាល់រឿងពុទ្ធសាសនា

ក្នុងរោហិតស្សសូត្រនៃសុត្តន្តបិដក មានព្រះពុទ្ធតម្រាថា «យើងបញ្ញត្តិលោក (ធ្វើឲ្យមនុស្សទូទៅស្គាល់លោក) ហេតុឲ្យកើតលោក ភាពរលត់នៃលោក និងសេចក្តីប្រតិបត្តិឲ្យដល់ភាពរលត់នៃលោក នៅក្នុងរូបកាយមានទំហំប្រមាណមួយហត្ថ(១) មានសញ្ញា មានចិត្តវិញ្ញាណគ្រងរក្សានេះឯង»

ចំណុចនៃពុទ្ធភាសិតនេះ មានន័យថា ព្រះសម្មាសម្ពុទ្ធ ព្រះអង្គសម្តែងធម៌បញ្ញត្តិវិន័យបញ្ចូលក្នុងខ្លួនមនុស្សដែលមានរូបទំហំមួយហត្ថ (វាស់ទទឹង) មានចិត្តសញ្ញានិងនាមធម៌នានាអាស្រ័យនៅខាងក្នុង ។ ព្រមគ្នានេះ, ព្រះអង្គបំព្រួញពិភពលោកទាំងមូល ឲ្យមកនៅក្នុងរាងកាយនិងចិត្តវិញ្ញាណ សូម្បីហេតុឲ្យកើតលោក ភាពរលត់លោក និងការអនុវត្ត ឬការប្រព្រឹត្តប្រតិបត្តិធម៌ ឲ្យដល់នូវភាពរម្លត់លោក ក៏បំព្រួញមកនៅត្រឹមកាយនិងចិត្តដូចដែលមានចែងក្នុងអភិធម្មថា ចិត្តចេតសិករូបនិព្វាន ។ ចិត្តបូកនឹងចេតសិក លទ្ធផលនៅត្រឹម ១, រូបបូកនឹងនិព្វាន លទ្ធផលនៅត្រឹម ១ ។

ជាសេចក្តីសារុបបណ្តោះអាសន្ន, ក្របខ័ណ្ឌនៃពុទ្ធសាសនា ទោះណាជាមានគំនោលធម្មៈ វិចិត្រពិស្តារទូលំទូលាយយ៉ាងដូចម្តេច ក៏ចំណុចអនុវត្ត ឬប្រតិបត្តិ នៅត្រឹមតែកាយនិងចិត្តប៉ុណ្ណោះ ។ សូម្បីតែឧត្តមគតិខ្ពង់ខ្ពស់បំផុត ក៏នៅត្រឹមតែទំវើ ធ្វើយ៉ាងណាឲ្យរួចផុតចាករាងកាយចិត្តវិញ្ញាណ មិនត្រូវឲ្យធ្លាក់ចុះ នៅក្នុងភាពវិលវល់តទៅទៀត ។ កាលបរឿងផ្តើមកើតមានមុនដំបូងបង្អស់ នឹងផ្តើមរលត់សោះសូន្យចុងក្រោយបំផុត វានៅលើរូបកាយនិងចិត្តវិញ្ញាណ មួយអន្លើនិងទំវើ ដែលធ្វើឲ្យកើត ។ ដើម្បីរម្លត់កាយចិត្តបុណ្យបាប ។ល។ ដូចនេះ, យើងត្រូវធ្វើសេចក្តីសង្កេត និងការកត់សម្គាល់ថា គោលការណ៍ ៣ ប្រការរបស់ពុទ្ធសាសនាគឺ :

១- វៀរចាកទំវើអាក្រក់គ្រប់យ៉ាង

២- ធ្វើទំវើល្អគ្រប់បែប

៣- ជម្រះចិត្តឲ្យស្អាតបរិសុទ្ធ ។

ទាំង ៣ ប្រការនេះ ជាធាតុនៅក្នុងក្របខ័ណ្ឌនៃព្រំដែនកាយនិងចិត្ត ដូចពោលមកហើយ ។

តែបើយើងពិចារណានៅក្នុងគំនិតថា ពុទ្ធសាសនាបង្រៀនសង្កត់ធ្ងន់ ទៅលើរឿងអ្វីផ្សេងទៅវិញ យើងគង់អាចឃើញបានថា បញ្ហាចិត្តបានទទួលការយកចិត្តទុកដាក់ ពីពុទ្ធសាសនាច្រើនជាពិសេស ដូចមានចែងក្នុងពុទ្ធភាសិតត្រង់ចំណុចថា :

(១) មួយហត្ថវាស់ទទឹងខ្លួនមនុស្ស ពុំមែនវាស់បណ្តោយទេ ។

១- ត្រូវដឹកនាំដោយចិត្ត (**ចិត្តេន នីយតិ លោកោ**)

២- ធម្មៈទាំងឡាយមានចិត្តជាប្រធាន (**មនោ បុព្វង្គមា ធម្មា**)

ពុទ្ធភាសិតនេះ, យើងសង្កេតឃើញបានថា ព្រះពុទ្ធសាសនាបង្រៀនសង្កត់ធ្ងន់ទៅលើចិត្ត គឺមិនថាលោក មិនថាធម៌ទេ ធាតុទាំងពីរនេះ សុទ្ធតែត្រូវដឹកនាំដោយចិត្ត ។ កាលបើចិត្តជាធាតុដឹកនាំ ទំរើអប់រំដុសខាត់សម្អាតចិត្ត ទើបជារបស់សំខាន់ក្នុងការអនុវត្ត ។

## ទិសដៅរបស់ពុទ្ធសាសនា

កាលបើពោលដោយទូទៅ ទិសដៅ ឬគោលដៅរបស់ពុទ្ធសាសនា គឺគ្មានអ្វីដទៃក្រៅពីប្រយោជន៍ទេ អ្វីៗដែលពុទ្ធសាសនាធ្វើ គឺធ្វើទៅរកប្រយោជន៍ រកសុខ រកវឌ្ឍនភាព រកសីលធម៌ ។ល។ ដែលយើងធ្លាប់ស្គាល់ថាមាន ៣ ប្រការគឺ :

១- ប្រយោជន៍បច្ចុប្បន្ន បានដល់ការរៀបចំខ្លួនឲ្យមានជំហររឹងប៉ឹង ដើម្បីរស់នៅក្នុងលោកនេះបានស្រួល,

២- ប្រយោជន៍អនាគត បានដល់ការរស់នៅក្នុងសីលធម៌ជាហេតុជួយឲ្យជីវិតអនាគត មានពន្លឺរស្មីត្រចាស់ត្រចង់,

៣- ប្រយោជន៍ខ្ពង់ខ្ពស់ បានដល់សមត្ថភាពរម្លត់ភ្លើងកិលេស ភ្លើងទុក្ខបានអស់ដោយដាច់ខាត ដោយគ្មានធ្លាក់ចុះ កប់ជ្រកនៅក្រោមអំណាចនៃភាពអាក្រក់របស់ចិត្ត និងសេចក្ដីទុក្ខក្ដៅក្លួលឆួលឆេះតទៅទៀត ។

ទិសដៅរបស់ពុទ្ធសាសនា បើនិយាយឲ្យខ្លីបំផុត ក៏មានត្រឹមតែប្រយោជន៍ខ្ពង់ខ្ពស់ គឺប្រយោជន៍ទី ៣ ដែលលោកឲ្យឈ្មោះម៉្យាងទៀតថា **វិមុត្តិ** (ភាពរួចផុត) ដូចមានក្នុងពុទ្ធភាសិតថា :

«ម្នាលភិក្ខុទាំងឡាយ ទឹកមហាសមុទ្រមានរសតែមួយ គឺរសប្រៃយ៉ាងណាមិញ ធម្មវិន័យរបស់តថាគត ក៏មានរសតែមួយ គឺវិមុត្តិរសយ៉ាងនោះដែរ»

## សេចក្ដីសរុប

ការបង្រៀនជាទូទៅ, ពុទ្ធសាសនាបង្រៀនឲ្យអនុវត្តធម្មៈ ទៅលើកាយនិងចិត្តស្មើគ្នា តែជម្រៅនៃគំនិត ឬសេចក្ដីសំខាន់ ពុទ្ធសាសនាបង្រៀនសង្កត់ធ្ងន់ទៅលើចិត្តជាពិសេស ។ ទិសដៅនៃការបង្រៀនជាទូទៅ គឺដើម្បីឲ្យអ្នកប្រព្រឹត្តប្រតិបត្តិធម៌ បានទទួលប្រយោជន៍គ្រប់ទាំង ៣ ជាន់ ហើយជាន់ដែលពុទ្ធសាសនា ត្រូវការដល់កម្រិតខ្ពស់ មួយរយភាគរយនោះ គឺជាន់កំពូល បានដល់ភាពរួចផុតចាកទុក្ខដោយដាច់ខាត ឬជាស្ថាពរ ដែលជាឧត្តមគតិខ្ពស់បំផុតរបស់ពុទ្ធសាសនាហ្នឹងឯង ។

ព្រោះហេតុដែលពុទ្ធសាសនា បង្អាត់បង្រៀនឲ្យចាត់ការជាមួយនិងចិត្តជាពិសេស ទើបមានចំណុចអនុវត្តយ៉ាងច្រើន ដែលមានទាក់ទងជាមួយនិងចិត្ត (សមថកម្មដ្ឋាន សមថវិបស្សនា) ហើយសុទ្ធសឹងជាចំណុចប្រតិបត្តិប្រកបដោយហេតុផលផងទៀត ។ ទំរើរបស់ពុទ្ធសាសនាច្រង់ចំណុចនេះ អ្នកសិក្សានិងអ្នកអនុវត្តធម៌ អាចធ្វើការត្រិះរិះពិចារណាតាមន័យនិងល្បងពិសោធ តាមគំនោលនៃអរិយសច្ចៈ ឲ្យឃើញភាពប្រាកដច្បាស់បាន ប្រសិនបើគេមានគំនិតជាធម្មៈ ប្រកបដោយហេតុផល ។ ប្រជាជាតិក្នុងបស្ចិមប្រទេស ដែលគេមានសេចក្ដីស្រឡាញ់រាប់អាន និងមានជំនឿក្នុងពុទ្ធសាសនា គេទើបនឹងបានរួមគ្នាធ្វើសេចក្ដីសម្រេចចិត្ត ឲ្យកិត្តិនាម ឬតាំងឈ្មោះពុទ្ធសាសនាថា ជាសាសនាវិទ្យាសាស្ត្រខាងចិត្តវិញ្ញាណ (SPIRITUAL AND MENTAL SCIENCE) ។

## បន្ទាត់ខ័ណ្ឌតំណាងឈ្មោះរវាងពុទ្ធសាសនានិងវិទ្យាសាស្ត្រ

តាមការញែកនិយាយដល់វិទ្យាសាស្ត្រ ដោយល្អិតនៅក្នុងព្រំដែននៃក្របខ័ណ្ឌមកហើយនោះ, គេត្រូវតែនិយាយដល់ពុទ្ធសាសនា ឲ្យនៅក្នុងក្របខ័ណ្ឌនៃព្រំដែនរហូតដល់ចំណុចទិសដៅ ដើម្បីឲ្យឃើញថា ធាតទាំងពីរ

នេះ ធាតុណាមានទិសដៅរបស់ខ្លួនទៅខាងណា ឲ្យមានភាពប្រាកដនិយម ។ ទំរើដូចនេះ រលោយកមកប្រៀបធៀប គ្នា អាចធ្វើឲ្យយើងអស់ការភាន់ច្រឡំផង, អស់មានគំនិតលឿនជ្រុល ឬគំនិតគ្មានទំនប់ គឺគំនិតថា ពុទ្ធសាសនាជាធាតសម្រប និងដំណោយជាមួយនិងវិទ្យាសាស្ត្រគ្រប់ផ្លាប់ ។ រីឯវិទ្យាសាស្ត្រវិញ ក៏មានដំណើរបោះជើងតាមព្រះពុទ្ធសាសនាគ្រប់ជំហាន ។ ពុទ្ធសាសនានិងវិទ្យាសាស្ត្រទាំងពីរនេះ ធាតុមួយៗសុទ្ធតែមានគោលដៅ និងគម្រោងការរបស់ខ្លួនយ៉ាងជាក់លាក់ ។ ដំនួបចំណែកនៃធាតុទាំងពីរនេះ វាមិនមែននៅលើទិសដៅ ឬទីដៅទេ ព្រោះទិសដៅ ទីដៅ គ្មានអ្វីក្រៅពីធ្វើឲ្យជីវិតមនុស្សមានវឌ្ឍនភាពហ្នឹងទេ ។ តែវាខុសគ្នាត្រង់រៀបចំកម្មវិធីធ្វើការ ចំណាត់វិធានការ ចំណាត់គោលការណ៍ ជាពិសេសគឺអនុវត្តធាតុទាំងឡាយនេះ ឲ្យបានត្រឹមត្រូវតាមគំនោលវិជ្ជា និងទិសដៅតែប៉ុណ្ណោះ ។ ពុទ្ធសាសនាជាវិទ្យាសាស្ត្រ គឺនៅត្រង់ពុទ្ធសាសនា ធ្វើឲ្យមនុស្សអស់ទុក្ខ ដោយផ្អែកលទំរើការងារ ផ្អែកលើចំណេះវិជ្ជា ផ្អែកលើពន្លឺគំនិត ផ្អែកលើសេរីភាពនៃជីវិត ផ្អែកលើយុត្តិធម៌នៃសង្គម ផ្អែកលើទំរើបំបាត់វណ្ណៈ ។ល។ វិទ្យាសាស្ត្រជាពុទ្ធសាសនា គឺនៅត្រង់វិទ្យាសាស្ត្រ ធ្វើឲ្យមនុស្សអស់ទុក្ខ ដោយផ្អែកលើទំរើការងារ ផ្អែកលើជំនឿមានហេតុផល ផ្អែកលើវិជ្ជានានា ។ល។ ធាតុទាំងពីរនេះ ខាងផ្លូវទ្រឹស្តីមិនសូវជាមានខុសគ្នាប៉ុន្មានទេ សម្រាប់ជីវិតសត្វក្នុងបច្ចុប្បន្ន ។ តែខាងផ្នែកអនុវត្ត, ពុទ្ធសាសនាគ្មានបានអនុញ្ញាតឲ្យធ្វើអាវុធសម្រាប់ច្បាំងទេ, គ្មានបានឲ្យធ្វើថ្នាំពិសពុលទេ, គ្មានបានឲ្យធ្វើជំនួញលក់មនុស្ស, គ្មានបានឲ្យធ្វើគ្រឿងស្រវឹង និងគ្រឿងញៀនសម្រាប់បំផ្លាញស្មារតីមនុស្សទេ ។ល។ ឲ្យធ្វើតែគ្រឿងប្រដាប់បរិក្ខានានា សម្រាប់ធ្វើឲ្យមនុស្សរស់នៅស្រួលមានជាអាទិ៍ វត្ត, ផ្លូវ, ថ្នល់, ស្ពាន, សាលារៀន, មន្ទីរព្យាបាល, រថយន្ត, អាកាសយាន, រទេះ, ទូក, សំពៅ, នាវា ។ល។ ដូចនេះ, វិទ្យាសាស្ត្រ ឬវិទ្យាករុណា ផលិតវត្ថុសម្រាប់ជួយឲ្យមនុស្សរស់នៅសុខសប្បាយ, ឲ្យពិភពមនុស្សមានសន្តិភាព, ឲ្យជីវិតមនុស្សមានសន្តិសុខ ។ល។ វិទ្យាសាស្ត្រនោះជាពុទ្ធសាសនាហើយ ។ ប្រភេទធម្មៈរបស់ពុទ្ធសាសនា ក្នុងចំណុចណាដែលបង្រៀនមនុស្សឲ្យធ្វើការ ឲ្យពឹងខ្លួនឯង ឲ្យឈប់ពឹងខ្មោចបិសាចទេពឥន្ទព្រហ្ម ។ល។ ធម្មៈនៃពុទ្ធសាសនានោះជាវិទ្យាសាស្ត្រហើយ ។

នៅក្នុងបស្ចិមប្រទេស, ប្រជាជនក្នុងទ្វីបនោះក្រោយពីបានគិតគូរជាមួយគ្នាយ៉ាងយូរមក គេមានគំហើញថា វិជ្ជាវិទ្យាសាស្ត្រ ជាផ្នែកសម្ភារៈ ចំណែកវិជ្ជាពុទ្ធសាសនាជាវិទ្យាសាស្ត្រខាងផ្នែកចិត្តវិញ្ញាណ ។ គំនិតខ្ញុំថា យោបល់គេនោះ ក៏ម៉្យាងដែរ ព្រោះអ្វី? ព្រោះគេមានចំណេះវិជ្ជាខាងពុទ្ធសាសនាមិនទាន់គ្រប់ជ្រុង ។ ការពិត, ពុទ្ធសាសនាមានទ្រឹស្តីសម្រាប់ឥធលោក, បរលោកនិងអលោក គឺបង្រៀនឲ្យមនុស្សរស់នៅក្នុងលោកនេះផង, ក្នុងបរលោកផង, ក្នុងអលោកផង ដូចមានក្នុងសំនេររបស់ខ្ញុំជាហូរហែមកហើយ ។ ដូចនេះ, ខ្ញុំយល់ថា ពុទ្ធសាសនាត្រូវតែបានឈ្មោះថា ពុទ្ធសាសនាផង វិទ្យាសាស្ត្រផង ទស្សនវិជ្ជាផង ទើបត្រឹមត្រូវតាមយុត្តិធម៌ និងគោលបំណងមួយអន្លើ និងឧត្តមគតិនៃព្រះពុទ្ធបរមគ្រូរបស់យើង ។

ដើម្បីជាពន្លឺដល់គំនិតអ្នកអានជាថ្មីទៀត, ខ្ញុំសូមស្រង់សេចក្តីក្នុងសៀវភៅឈ្មោះ WHAT IS BUDDHISM? (ពុទ្ធសាសនាគឺអ្វី?) របស់ពុទ្ធសមាគមនៅក្រុងឡុងដ្រ៍ មកប្រែជាភាសាខ្មែរយើងជូនអ្នកអានពិចារណា ដូចតទៅនេះ :

«ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានធ្វើសេចក្តីអធិប្បាយ បញ្ជាក់គោលការណ៍ទូទៅរបស់ចិត្ត ក្នុងឋានៈជាមូលដ្ឋាននៃទំរើបង្ហាត់បង្រៀនរបស់ព្រះអង្គ ។ ចំណែកខាងសម្ភារៈ ឬខាងវត្ថុជាធាតុនៅក្នុងក្របខ័ណ្ឌនៃទំរើបង្ហាត់បង្រៀន របស់អ្នកវិទ្យាសាស្ត្រក្នុងសម័យបច្ចុប្បន្ន ។ ប្រព័ន្ធភាពរវាងលោកខាងផ្លូវចិត្តវិញ្ញាណ និងខាងផ្លូវវត្ថុសម្ភារៈ ទាំងពីរនេះជាប្រព័ន្ធភាព មានសារសំខាន់ ជាមួយនិងរបស់ដែលត្រូវឡប់ឃ្លាតចេញ ពីភាពមានសារសំខាន់ ។ អ្នកសិក្សាអំពីរបស់មួយ ដោយឧបមាន (ANALOGY ប្រៀបធៀប) និងដោយអនុមាន (INFERENCE)

គំនាន់គំនេអំពីហេតុផលរមែងត្រូវបានស្គាល់របស់មួយទៀត ដែលខ្លួនពុំទាន់បានស្គាល់ ក្នុងពេលជាមួយគ្នានោះឯង ។ ព្រោះអ្វី? ព្រោះពុទ្ធសាសនាក្តី វិទ្យាសាស្ត្រក្តី ធាតុទាំងពីរនេះមានឫសគល់នៅលើទំរើវិភាគប្រកបដោយការ (នៅក្នុងបន្ទាត់នៃមគ្គវិថី) របស់ខ្លួនតាមលំដាប់ក្នុងការសរុបផល, ទើបមានសភាពត្រូវចូលគ្នាបាន ។ វិទ្យាសាស្ត្រ ឬវិទ្យា ប្រែថា «សម្គាល់, ចំណេះ, ដំណឹង . . .» ។ ពុទ្ធសាសនា ឬពុទ្ធ ប្រែថា «របៀនស្គាល់, របៀនចេះ, របៀនដឹង, . . . . ឬតម្រាស់គំហើញគំនិតយលបល់ . . . .» ។ ធាតុទាំងពីរនេះ គឺពុទ្ធសាស្ត្រនិងវិទ្យាសាស្ត្រ ត្រូវការឆ្លាក់ថ្មែខួរក្បាល ឬចិត្តវិញ្ញាណ មួយអន្លើនិងប្រព័ន្ធប្រសាទរបស់មនុស្សនិងសត្វទូទៅ ឲ្យចេញជាគំនិតបញ្ញាប៉ាធី, ឲ្យកើតជាកាំពន្លឺរស្មីសម្រាប់ប្រើក្នុងទំរើឆ្លុះបញ្ចាំង ដើម្បីស្គាល់ធម្មៈនិងសម្ភារៈ ហើយអនុវត្តឲ្យត្រូវតាមចុងព្រួញរបស់ទ្រឹស្តីពុទ្ធ៍ និងទ្រឹស្តីវិទ្យ៍ ក្នុងបំណងបម្រើសន្តិភាពនៃជីវិត, បម្រើយុត្តិធម៌នៃសង្គម ដែលជាទីត្រូវការរបស់មនុស្សលោក ។ ដូចនេះទំរើនៃធាតុទាំងពីរ គឺពុទ្ធ៍និងវិទ្យ៍មិនថាទមរើណាជាទំរើណាទេ គ្រប់តែទំរើ តែងប្រកាន់យកហេតុផល, វិភាគកម្ម, ពិសោធកម្ម, វិចារណកម្ម, ចិន្តាកម្ម ។ល។ ជាធំជាដៃគូ ។ ពុទ្ធសាសនាដំបូងបង្រៀនឲ្យចាំ រួចពីចាំបង្រៀនឲ្យចេះ ឬឲ្យយល់ ក្នុងទីបំផុតបង្រៀនឲ្យអនុវត្តទាំងសីលធម៌ ទាំងអាជីវកម្មនៅក្រោមបន្ទាត់នៃគំនិតបញ្ញាក្នុងក្របខ័ណ្ឌនៃហេតុផល ។ ចំណែកវិទ្យាសាស្ត្រក៏ដូចជាពុទ្ធសាសនាដែរ ទំរើទាំងអស់បានផ្អែកលើពន្លឺគំនិតលើវិភាគកម្ម លើពិសោធកម្ម លើវិចារណកម្ម ។ល។ គឺធាតុទាំងពីរនេះ បានទាត់ចោលជំនឿខុស ទំរើគ្មានហេតុផល គំនិតកម្លៅ ស្មារតីរវើរវាយ ។ល។ និយាយខ្លីៗ ពុទ្ធសាសនិករបស់យើង ដែលរស់នៅដោយមានបញ្ញាមានធម្មៈប្រកបដោយហេតុផលជាចង្កៀង ទើបត្រូវបានឈ្មោះថា ជាវិទ្យាសាស្ត្រ ឬជាអ្នកវិទ្យាសាស្ត្រ ទាំងផ្នែកសម្ភារៈ ទាំងចិត្ត ។ ព្រោះអ្វី? ព្រោះពុទ្ធសាសនាមានទាំងទ្រឹស្តីរូប មានទាំងទ្រឹស្តីចិត្ត ។ ចំណែកការអនុវត្តពុទ្ធសាសនិកខ្លះ អនុវត្តទ្រឹស្តីរូបច្រើន, ខ្លះអនុវត្តទ្រឹស្តីចិត្តច្រើន ស្រេចហើយតែចំណូលចិត្តរបស់គេ ។ យោបល់ខ្ញុំក្នុងរឿងនេះ ក៏ដូចគ្នានិងយោបល់ពុទ្ធសមាគមលុងដ្រ៍ដែរ ។ តែយោបល់ពុទ្ធសមាគមថា គំនិតពុទ្ធសាសនានិងគំនិតវិទ្យាសាស្ត្រ ជាគំនិតស្របគ្នាតែមួយ ។ គំនិតនេះ, ខ្ញុំមិនត្រឹមតែបដិសេធទេ ខ្ញុំព្រមទទួលស្គាល់ថា ត្រឹមត្រូវហើយ ។ តែខ្ញុំមានគំនិតមួយទៀតថា គំនិតវិទ្យាសាស្ត្របច្ចុប្បន្នមិនមែនជាគំនិតថ្មីទេ គឺជាគំនិតរបស់ពុទ្ធសាសនាក្នុងចំណុចទ្រឹស្តីរូបធាតុហ្នឹងឯង ។ តែពុទ្ធសាសនា ឬពុទ្ធសាសនិក មិនសូវបានអនុវត្តទ្រឹស្តីសម្ភារៈ ច្រើនអនុវត្តទ្រឹស្តីចិត្ត ទើបបានយូរៗមកគេមានគំនិតថា ពុទ្ធសាសនាមិនមែនសម្ភារៈនិយមទេ គឺជាចិត្តនិយមតែម៉្យាង ។ បន្ថែមលើនេះទៀត, គេមានគំនិតថា ពុទ្ធសាសនាមិនមែនជាវិទ្យាសាស្ត្រទេ គឺជាសាសនាតែម៉្យាង ។ ប្រសិនបើយើងមានគំហើញ តាមគំនិតរបស់គេទាំងស្រុង យើងហាក់ដូចជាមិនដឹង មិនស្គាល់ ឬមិនយល់ថា ពុទ្ធសាសនាគឺអ្វីឡើយ ។ ដូចនេះព្រោះអ្វី? ព្រោះទ្រឹស្តីនៃពុទ្ធសាសនារបស់យើង ដែលបានចែងអំពីប្រយោជន៍ ៣ ប្រការនោះ វានឹងក្លាយទៅជាធាតុមោឃៈ ។ ហើយពុទ្ធសាសនា ក៏អស់ន័យត្រឹមហ្នឹង ដោយគ្មានអ្វីធ្វើឲ្យគេមានជំនឿ ឬចាប់អារម្មណ៍ទៀតទេ ។ ព្រោះពុទ្ធសាសនិកដែលកំពុងរស់នៅសព្វថ្ងៃចេះតែទុក្ខទៅ ចេះតែក្រឡើង, ចេះតែទន់ខ្សោយគ្រប់វិស័យបន្តិចម្តងៗ ។ រីឯពុទ្ធសាសនិកដែលស្លាប់ទៅក៏មិនដឹងជាទៅឯណា, ទៅឯណី, គ្មានវិលមកប្រាប់, គ្មានធ្វើសំបុត្រឲ្យដំណឹងអ្វីបន្តិចបន្តួចសោះ ។ អាស្រ័យហេតុនេះ, យើងពុទ្ធសាសនិក កុំចេះតែបណ្តោយឲ្យគេយកធាតុទាំងឡាយជារបស់ពុទ្ធសាសនា ដូចជាវិទ្យាសាស្ត្រ (ទ្រឹស្តីរូបធាតុនៃពុទ្ធសាសនា) ទស្សនវិជ្ជា (គំនិតហេតុផលនៃពុទ្ធសាសនា) សីលធម្មចរិយា, សង្គហធម៌, ឥទ្ធិបាទ, នយោបាយធ្វើសង្គមមនុស្សឲ្យមានយុត្តិធម៌, នយោបាយធ្វើជីវិតមនុស្សឲ្យមានសន្តិភាព ។ល។ ទៅប្រើជារបស់គេ ហើយគេលេងពាក្យសម្តីដាក់ផ្លែផ្កា ឲ្យពុទ្ធសាសនាថា ជារបស់គ្មានប្រយោជន៍នាំធ្ងន់សង្គមមនុស្ស ។ មិនតែប៉ុណ្ណោះ, ភិក្ខុ សាមណេរ ពុទ្ធសាសនិកដែលមានចិត្តខ្ពស់ត្រូវបានអ្នកនយោបាយពុករលួយ ទុច្ចរិត អយុត្តិធម៌ ។ល។ បោកប្រើដើម្បីបម្រើសេចក្តីជិះជាន់ ទំរើអយុត្តិធម៌ គំនិតអញ

និយម និងកិលេសតណ្ហារបស់គេ ដោយគ្មានទាំងបានដឹងនូវកំហុសរបស់ខ្លួនឯងផង ។ នេះគឺជាគ្រោះកាច ដែលពុទ្ធសាសនាយើងត្រូវបានទទួលមកហើយ, ហើយនិងចេះតែបានទទួលតទៅទៀត ប្រសិនបើយើងចេះតែនាំគ្នាធ្មេចភ្នែក មិនព្រមស្រុះស្រួលមូលគំនិតគ្នា ដើម្បីធ្វើកំណែក្នុងពេលឆាប់ៗនេះ ។

## សម្គាល់ទាំងពីរវិស័យនាំឲ្យមានចំណូលចិត្តល្អ

កាលណាគេចូលចិត្តថា ពុទ្ធសាសនាជាវិទ្យាសាស្ត្រផ្នែកចិត្ត ជាគូនគ្នានិងវិទ្យាសាស្ត្រផ្នែកសម្ភារៈ តាមគំនិតពុទ្ធសមាគមក្រុងឡុងដ្រ៍ក្តី ជាវិទ្យាសាស្ត្រទាំងគូ, តែពុទ្ធសាសនាមិនសូវបានអនុវត្តខាងសម្ភារៈ ច្រើនអនុវត្តតែខាងចិត្ត តាមគំហើញរបស់ខ្ញុំក្តី ។ យើងត្រូវតែចូលចិត្តន័យ ចូលចិត្តទំរើនៃធាតុទាំងពីរនេះ ឲ្យបានច្បាស់លាស់ ដើម្បីការពារភាពច្រឡូកច្របល់ ត្រឡប់ត្រឡិន ម្តងដូចនេះ ម្តងដូចនោះ នៃវិទ្យាសាស្ត្រនិងពុទ្ធសាសនាដែលអ្នកផងធ្លាប់មានគំនិតភាន់ច្រឡំមកហើយ ។ ដើម្បីអ្នកអានដឹងជាបន្ទាន់, ខ្ញុំសូមធ្វើសេចក្តីបញ្ជាក់ថា «ពុទ្ធ» និង «វិទ្យា» ពាក្យពីរម៉ាត់នេះ មានសំឡេងខុសគ្នា តែមានន័យត្រូវគ្នា គឺ «ពុទ្ធ» ប្រែថា «ចេះដឹងទូលំទូលាយ» «វិទ្យា» ប្រែថា «ចេះដឹងទូទៅ» ។ ប្រសិនបើពុទ្ធសាសនាត្រូវបានដាក់ឈ្មោះថា «សិទ្ធត្ថសាសនា» ឬ «សមណគោតមសាសនា» នេះបញ្ហាវាត្រូវចប់ត្រឹមហ្នឹង គឺវាជាសាសនារបស់ត្រកូល ឬសាសនាប្រពៃណីស្រេចទៅហើយ ព្រោះយកឈ្មោះមនុស្សមកប្រកាស ឬបុគ្គលអ្នកស្ថាបនា មកធ្វើជាឈ្មោះសាសនា ។ តែនេះ, គេយក «ពុទ្ធ» ដែលជាឈ្មោះនៃគំនិតចេះដឹងយ៉ាងជ្រាលជ្រៅ សឹងរកកំណត់ព្រំដែនមិនបាន រកទីបំផុតនៃជម្រៅមិនឃើញ ។ ដូចនេះតែមិនឲ្យឈ្មោះថាសាសនានេះថា ជាវិទ្យាសាស្ត្រដូចម្តេចកើត ។ បើវិទ្យាសាស្ត្រក៏មានសកម្មភាព មានទំរើផ្អែកលើសេចក្តីចេះដឹងផ្អែកលើហេតុផល ។ល។ ពុទ្ធសាសនាក៏មានសកម្មភាព មានទំរើផ្អែកលើសេចក្តីចេះដឹង ផ្អែកលើហេតុផល ។ល។ ដូចគ្នា ។ អ្វីដែលវិទ្យាសាស្ត្រមាន ពុទ្ធសាសនាក៏មាន ។ តែមានរបស់ពិសេសមួយដែលវិទ្យាសាស្ត្រគ្មាន ហើយពុទ្ធសាសនាមាន តើរបស់នោះគឺអ្វី? ចម្លើយ ! របស់នោះគឺសីលធម៌ ។ ដូចនេះពុទ្ធសាសនាទើបត្រូវបានឈ្មោះថា «សាសនា» ព្រោះមាននិយាយអំពីមនុស្សសត្វនរកសួគ៌ ។ល។ ដូចសាសនាទាំងឡាយដទៃ ដែលមាននៅក្នុងលោកយើងនេះដែរ ។ ត្រូវបានឈ្មោះថា «វិទ្យាសាស្ត្រ» ព្រោះទំរើទាំងឡាយរបស់ពុទ្ធសាសនា បានផ្អែកទាំងស្រុងទៅលើបញ្ញា ។ ត្រូវបានឈ្មោះថា «ទស្សនវិជ្ជា» ព្រោះគ្មានជំនឿប្រាសចាកហេតុផល ។ល។

ដើម្បីជាគំនិតដល់អ្នកអានជាបន្តទៅទៀត, ខ្ញុំសូមលើកយកតួយ៉ាងនៃពាក្យថា ធាតុ (ELEMENTS) មានអ្នកវិទ្យាសាស្ត្រខ្លះមិនចូលចិត្ត ឬមិនធ្លាប់បានសិក្សាធម្មៈនៃពុទ្ធសាសនា បាននិយាយថា ធាតុទាំងឡាយដែលគេចូលចិត្តក្នុងពុទ្ធសាសនានោះ គឺជាចំណូលចិត្តខុស ជាទំរើមិនស្គាល់ធាតុសុទ្ធពិតៗ ។ ធាតុពិតគេត្រូវធ្វើវិភាគរឿយៗ លុះត្រាដល់ទីបំផុត វាក៏ចេញមកជាបរមាណូ ។ ទំរើវិភាគទោះជាគេធ្វើប៉ុន្មានលើក ប៉ុន្មានគ្រាទៅទៀត ចំណែកប្រកប ឬគម្រោងសំណង់របស់វា ក៏គង់នៅជាបរមាណូ (ATOMIC STRUCTURE) ដូច្នោះដដែល គ្មានផ្លាស់ គ្មានប្តូរទៅជាអ្វីទៀតទេ ។ ធាតុមួយបែបក្នុងវិទ្យាសាស្ត្ររមែងមានកំណត់របស់វាយ៉ាងទៀងទាត់ ។ តាមដែលអ្នកវិទ្យាសាស្ត្របានស្រាវជ្រាវឃើញមកហើយ គឺបរមាណូមួយៗ មានទម្ងន់មួយៗប៉ុនគ្នា ។ ដោយប្រើទម្ងន់បរមាណូនៃធាតុអ៊ីដ្រូហ្សែន ដែលមានសម្រាលជាទីបំផុតជាគំនោល ។ ការញែក ឬទំរើវិភាគខាងគីមី គេមិនអាចធ្វើឲ្យច្រើន ឬឲ្យលើសពនេះបានឡើយ ។ កាលបើធាតុបរមាណូមួយៗ ជារបស់មានទម្ងន់ (ATOMIC WEIGHT) ដែលពុំអាចវាស់បាន ថ្លឹងកើត ទើបមិនត្រូវបានចាត់ជាធាតុ ។ ទំរើដែលពុទ្ធសាសនានិយាយថា ធាតុទាំង ៤ គឺ : ដី, ទឹក, ភ្លើង, ខ្យល់ មួយៗជាធាតុមួយផ្សេងៗគ្នានោះ គេថា ចំណូលចិត្តនេះខុសព្រោះដីក៏មិនមែនជាធាតុដីសុទ្ធ ក្រោយពេលធ្វើការញែកធាតុ គេឃើញថា ធាតុនេះជាធាតុផ្សំ គឺមានធាតុផ្សេងលាយផ្សំជាមួយនិងដី ។ ទឹកក៏មិនមែនជាធាតុសុទ្ធ ជាធាតុផ្សំគ្នា គឺមានធាតុអ៊ីដ្រូហ្សែន ២ ភាគបូកនិង អុកស៊ីហ្សែន ១ ភាគ ។

ភ្លើងរឹតតែមិនមែនជាធាតុឡើយ ព្រោះភ្លើងគ្មានទម្ងន់ គ្មានខ្នាត ថ្លឹងមិនបាន វាស់មិនកើត វែកញែករកបរមាណូមិនឃើញ, ខ្យល់ក៏ជាធាតុផ្សំ ព្រោះមានធាតុអុកស៊ីហ៊្សែន និងធាតុដទៃៗក្រៅពីនេះទៀត ។ អ្នកវិទ្យាសាស្ត្រមានគំហើញស្របគ្នាថា ពុទ្ធសាសនាចូលចិត្តរឿងធាតុខុសទាំងស្រុង ។ អ្នកស្គាល់ត្រឹមតែវិស័យមួយៗ ដូចនេះមើលសព្វៗទៅឃើញហាក់ពិតខ្លះដែរ ។ តែកាលណាបើគេសិក្សា ឲ្យបានស្គាល់ន័យ នៃការបញ្ញត្តិពាក្យប្រើក្នុងផ្លូវសាសនា, គេនឹងបាត់ការចូលចិត្តខុសទៅវិញ ព្រោះគេបានស្គាល់ព្រំដែននៃសេចក្តី ឬពាក្យនិយាម (DEFINITION) ក្នុងផ្លូវមួយៗ ឬវិជ្ជាមួយៗ រមែងមានន័យនិងទិសដៅផ្សេងគ្នា កន្លែងខ្លះប្រើពាក្យត្រូវគ្នា, តែមានន័យខុសគ្នាឬដោយយ៉ាងពីគ្នា ដូចពាក្យថា **«អារម្មណ៍»** ដែលប្រើក្នុងពុទ្ធសាសនា មានន័យទៅម៉្យាង មិនស្របនិងន័យដែលគេធ្លាប់ចូលចិត្តក្នុងភាសាខ្មែរយើង ត្រង់និងពាក្យថា សេចក្តីរំភើបចិត្ត ឬពាក្យថា EMOTION ក្នុងភាសាអងគ្លេសឡើយ ។ ក្នុងភាសាខ្មែរយើងមានពាក្យនិយាយថា អារម្មណ៍ល្អ ។ តែនៅក្នុងពុទ្ធសាសនា ពាក្យថា អារម្មណ៍ ដោយករបស់ដែលបានឆ្លងកាត់ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, ចិត្ត, បានដល់រូប សំឡេង ក្លិន រស ផ្សព្វ (របស់ដែលប៉ះពាល់ដោយកាយ) ធម្មៈ (របស់ដែលដឹងបានដោយចិត្ត) ។ យើងយកពាក្យនេះមកប្រើលុះត្រាធ្លាប់ចូលចិត្តបាន ស្តាប់យល់ថា សេចក្តីរំភើបចិត្ត ឬញាប់ញ័រចិត្ត តែស្តាប់ជាខ្មែរ យកន័យជាខ្មែរមិនមែនស្តាប់ជាពុទ្ធសាសនា ឬយកន័យជាពុទ្ធសាសនាឡើយ ។ ខាងពុទ្ធសាសនាមានន័យទៅម៉្យាងទៀត ។ ការប្រើពាក្យដូចនេះ និងថាអ្នកខុស ក៏ថាមិនពេញមាត់ដែរ ។ ដើម្បីស្គាល់ខុសត្រូវ ឬដឹងថាមានន័យចំ ឬមិនចំ គេត្រូវសិក្សាឲ្យបានយល់ន័យរបស់ពាក្យទាំងពីរនេះទើបបាន ។

ពាក្យថា **«ធាតុ»** ក្នុងផ្លូវសាសនាក៏ដូចគ្នា គេមិនបានសំដៅយករបស់ដែលញែកចេញទៅទៀតមិនបានដូចខាងគីមី ដែលគេប្រកាន់យកតាមគ្រប់ខ័ណ្ឌនៃវិទ្យាសាស្ត្រ ។ គេកំណត់យកលក្ខណៈត្រឹមតែមើលឃើញងាយចូលចិត្តធូរ, ញែកប្រភេទបានស្រួល, តែប៉ុណ្ណឹងនេះជាមុខងាររបស់ពុទ្ធសាសនាចំពោះធាតុទាំងឡាយ ។ ទំរើនេះ, ពុទ្ធសាសនាធ្វើឡើង ដើម្បីងាយស្រួលដល់ការកត់សម្គាល់សម្រាប់មនុស្សទូទៅ មិនមែនសម្រាប់មនុស្សសម្បូរគំនិតជ្រៅល្អិតឡើយ ។ ចំណែកយោបល់របស់អ្នកវិទ្យាសាស្ត្រដែលឲ្យកំហុសដល់ពុទ្ធសាសនា ក្នុងចំណុចយកដី, ទឹ, ភ្លើង, ខ្យល់មកធ្វើជាធាតុ ឬឲ្យឈ្មោះធាតុមិនត្រឹមត្រូវតាមសេចក្តីពិត ព្រោះរបស់ទាំងអស់នេះ ក្នុងមួយមុខៗមានត្រឹមតែមួយនោះ ពាក្យរិះគន់នេះ វាជ្រុលពេកណាស់ ។ ព្រោះអ្វី? ព្រោះ **«ធាតុ»** ពាក្យនេះជាភាសារបស់ពុទ្ធសាសនា, ពុទ្ធសាសនាកាលណានិយាយថា **«ធាតុ»** ដូចជាធាតុដី មិនមែនមានតែដីមួយមុខទេ គឺមានទឹក ភ្លើង ខ្យល់ សម្បុរ ក្លិន រស ឱជៈ ។ល។ នៅក្នុងដីនោះផងដែរ ។ ដូចនេះ, កាលណាបើមិនទាន់ស្គាល់ធាតុញែកនិងធាតុសង្គ្រោះចូល ដែលមានចែងក្នុងគម្ពីរបរមត្ថអភិធម្ម សឹងមានធាតុដុំ ធាតុញែក ធាតុសង្គ្រោះយ៉ាងច្រើនអនេកនោះនៅឡើយទេ សូមមេត្តាកុំទាន់អាលប្រមាថមើលងាយព្រះពុទ្ធ ដែលពិភពលោកបានទទួលស្គាល់ព្រះអង្គគ្រប់ចំណុចនៃព្រះគំនិតទាំងឡាយ ហើយបានប្រគល់ខ្លួនជាសិស្សរបស់ព្រះអង្គ បើមិនទាំងអស់ក៏ច្រើនណាស់មកហើយចាប់តាំងពីបានត្រាស់រហូតដល់បរិនិព្វាន មកដល់បច្ចុប្បន្នកាល ព.ស ២៥១៦ ឆ្នាំនេះទៀត គ្មានទាន់អស់មនុស្សដែលត្រូវប្រគល់ខ្លួនជាសិស្សរបស់ព្រះអង្គឡើយ ។

## ចំណុចដែលពុទ្ធសាសនាត្រូវគ្នានិងវិទ្យាសាស្ត្រ

ខ្ញុំសូមប្រមូលគោលការណ៍ធំៗ ដែលត្រូវគ្នារវាងពុទ្ធសាសនា និងវិទ្យាសាស្ត្រមកធ្វើសំនេរក្នុងទីនេះទៀត, ដើម្បីងាយស្រួលដល់ការពិចារណា ប្រៀបធៀបដូចមានតទៅនេះ :

១- ព្រះពុទ្ធសាសនាបង្រៀនមិនឲ្យជឿអ្វីៗ យ៉ាងងាយៗធូរៗ, តែឲ្យជឿយ៉ាងមានហេតុផល មានការល្បងពិសោធ និងការពិនិត្យត្រួតត្រាយ៉ាងមធ្យ័ត ។ វិទ្យាសាស្ត្រក៏មានបង្រៀនយ៉ាងនេះដូចគ្នា ។

២- ព្រះពុទ្ធសាសនាបង្រៀនថា ផលគ្រប់យ៉ាងរមែងមកអំពីហេតុ មិនមែនកើតឡើងឯងៗ ឬចៃដន្យទេ ។ ទំរើដាក់ទោសថាចៃដន្យនោះ ព្រោះរកហេតុនៅមិនទាន់ឃើញប៉ុណ្ណឹងទេ ។ ព្រះពុទ្ធសាសនា ពុំបានបង្រៀនថា ទេវតា ឬព្រះអាទិទេព បង្កើតសេចក្ដីល្អអាក្រក់ ឬសុខទុក្ខឲ្យសត្វលោក, តែបង្រៀនថា ទំរើរបស់បុគ្គលម្នាក់ៗ ជាគ្រឿងធ្វើឲ្យកើតសេចក្ដីអាក្រក់ល្អ ។ វិទ្យាសាស្ត្រក៏មានជំនឿយ៉ាំងនេះដូចគ្នា ។

៣- ព្រះពុទ្ធសាសនាបង្រៀនមិនឲ្យជឿ ឬជំពាក់ចិត្ត ឬញៀនក្នុងជោគលាភ ឬគំនិតផ្សងព្រេង ដែលមនុស្សក្នុងអតីតកាលធ្លាប់ប្រកាន់យក ។ ចំណែកវិទ្យាសាស្ត្រក៏បង្រៀនយ៉ាងដូចនេះដែរ ។

៤-ព្រះពុទ្ធសាសនាបង្រៀនឲ្យចូលចិត្ត លក្ខណៈ ៣ ប្រការនៃរបស់ទាំងឡាយ គឺមិនទៀងទាត់ ធន់នៅមិនបានយូរ គ្មានខ្លឹមសារអាត្មាប្រាណ, ដើម្បីមិនឲ្យជាប់ជំពាក់ទាក់ទិន, មិនឲ្យមានកំណាន់ស្វិតស្វាញរហូតដល់ប្រកាន់យកដាច់ខាត ។ វិកទ្យាសាស្ត្រទាំងកាយភាព (រូបនិយម) និងជីវភាព ក៏បង្រៀនឲ្យចូលចិត្តដល់ច្បាប់នៃភាពផ្លាស់ប្ដូររបស់វត្ថុទាំងឡាយ យ៉ាងនេះដូចគ្នាដែរ ។

៥- ព្រះពុទ្ធសាសនាបង្រៀនថា ផលវិបាកដែលកើតចេញមកអំពីហេតុមួយហើយ អាចជាហេតុនៃផលវិបាកដទៃតទៅទៀតបាន ។ ដូចធម្មទេសនារឿងវដ្ដ (វិលវល់ ៣) មានកិលេសជាហេតុឲ្យកើតទំរើកម្ម, ទំរើកម្មជាហេតុឲ្យកើតផលវិបាក, ផលវិបាកជាហេតុឲ្យកើតកិលេស, កិលេសជាហេតុឲ្យកើតទំរើកម្ម ។ល។ ឬទ្រឹស្ដីបច្ចយាការដែលថា អវិជ្ជាជាហេតុឲ្យកើតសង្ខារ សង្ខារជាផលនៃអវិជ្ជានោះ ដូរមកជាហេតុឲ្យកើតវិញ្ញាណ, វិញ្ញាណដែលជាផលនោះ ដូរមកជាហេតុឲ្យកើតនាមរូប កើតតៗគ្នាទៅទៀតតាមលំដាប់ ។ល។ ចំណែកវិទ្យាសាស្ត្រ ក៏មានបង្រៀនដល់ភាពប្រទាក់ប្រតោងគ្នា ដូចគ្រាប់ពីជៈ (ពូជ) ជាហេតុឲ្យកើតដើមឈើ, ដើមឈើជាហេតុឲ្យកើតផ្លែ (ពីជៈ, ពូជ) យ៉ាងនេះដូចគ្នា ។

៦- ពុទ្ធសាសនាបង្រៀនថា រូបកាយរបស់មនុស្សដែលរួមគ្នាជាដុំ ជាគំនរ អាចញែកចេញបានជាធាតុ ៤ គឺ ដី, ទឹក, ភ្លើង, ខ្យល់ ។ វិទ្យាសាស្ត្រក៏បានបង្រៀនថា រូបកាយរបស់មនុស្សសត្វប្រកបដោយធាតុផ្សេងៗ មានច្រើនបែប ច្រើនប្រការយ៉ាងនេះដូចគ្នា ។ល។

៧- ពុទ្ធសាសនាមានពំនោលដល់ដួងអាទិត្យ ដួងចន្ទនិងពិភពលោកដែលមានមនុស្សនៅសព្វថ្ងៃថា មិនមែនមានទំហំប៉ុននឹងភាពដែលយើងមើលឃើញ អំពីលោករបស់យើង ឬមានចំនួនតាមដែលភ្នែកធម្មតារបស់យើងឃើញឡើយ, តែមានច្រើនណាស់ទៅទៀត ដែលភ្នែកកំណើតរបស់យើងមើលមិនឃើញ ។ អ្នកតារាសាស្ត្រក៏បានពោលថា ដួងអាទិត្យ ដួងចន្ទ និងដួងផ្កាយគ្រោះបែបដូចគ្នានិងពិភពមនុស្សយើងនេះ ដែលគេអាចមើលឃើញដោយអាស្រ័យប្រអប់ ឬអាប់ប៉ារីទូរទស្សន៍ខ្នាតធំមហិមាយ៉ាងនេះដូចគ្នា ។ល។

៨- ពុទ្ធសាសនាបាននិយាយដល់ច្បាប់ធម្មជាតិនៃទំរើឆក់ស្រូបថា ដុំទឹកឬធាតុទឹកដែលស្រក់ធ្លាក់ចុះ, អំពីទីខ្ពស់រមែងហូរចុះទៅកាន់ទីទាប (**ឧន្នតោ ឧទកំ ថុដ្ឋំ យថា និន្នំ បវត្តតិ**) ម៉្យាងទៀត, ពុទ្ធសាសនាបាននិយាយដល់រឿងរបស់ចិត្តថា ចិត្តរបស់មនុស្សសត្វ ដែលត្រូវចរន្តពិភពលោកឆក់ស្រូប ឲ្យហូរចាក់ស្រោចទៅតាមប្រឡាយលោកចិត្តបែបនេះហៅថា **លោកិយចិត្ត** ។ ចិត្តថ្នាក់ខ្ពស់ ដែលឋិតនៅលើចរន្តកាមលោក រូបលោក អរូបលោក ឬចិត្តឆ្លងចាកលោក, តែមិនមែនខ្ពស់ឡើងបានដោយខ្លួនឯងទទេៗឡើយ គឺត្រូវមានកម្មវិធីហ្វឹកហាត់អប់រំ ។ ចិត្តប្រភេទនេះ, លោកឲ្យឈ្មោះថា **លោកុត្តរចិត្ត** ។ ក្នុងវិទ្យាសាស្ត្រកាយភាព ឬរូបនិយម មានទ្រឹស្ដីថា ទឹកតាមធម្មតារមែងហូរពីទីខ្ពស់ទៅកាន់ទីទាប, តែអាចហូរពីទីទាបទៅកាន់ទីខ្ពស់បានដែរ ប្រសិនបើមានកម្លាំងឆក់ស្រូប ឬកម្លាំងរុញច្រាន ។ល។

# ទំនើនៃពុទ្ធសាសនាជាវិទ្យាសាស្ត្រ

ពំនោលដល់ដំណើរល្អនៃពាក្យបង្រៀនរបស់ពុទ្ធសាសនាជាវិទ្យាសាស្ត្រ ជាទំរើធ្វើឲ្យយើងមានពេលពិចារណា ដល់ការបង្រៀនយ៉ាងមានហេតុផលផង, ជាតួវិទ្យាសាស្ត្រសុទ្ធៗផង នៃពុទ្ធសាសនារបស់យើង ។ ដើម្បីអ្នកអានកាន់តែមានពន្លឺច្រើនក្នុងរឿងនេះម្តងទៀត ខ្ញុំសូមធ្វើសំនេរមួយចំណុចម្តងៗដូចតទៅះ

១- សម្តែងអំពីផល គឺសេចក្តីទុក្ខ ដោយបានបញ្ជាក់ថា កើតមកពីអ្វី ឬមានអ្វីជាប្រភពនៃទុក្ខ,

២- សម្តែងអំពីហេតុនៃសេចក្តីទុក្ខ ដោយបានបញ្ជាក់ថា កើតមកពីតណ្ហា,

៣- សម្តែងអំពីផល គឺភាពរលត់ទុក្ខ ដោយបានបញ្ជាក់ថា បានដល់ការរម្លត់តណ្ហា,

៤- សម្តែងអំពីហេតុ គឺផ្លូវប្រតិបត្តិឲ្យដល់ភាពរលត់ទុក្ខ ដោយបានបញ្ជាក់ថា បានដល់អរិយមគ្គ ឬអដ្ឋង្គិកមគ្គ ។

គុណលក្ខណៈពិសេសក្នុងទំរើនៃអរិយសច្ច ដែលបានប្រកាសយ៉ាងក្លាហាន ហើយដែលថា ជាវិទ្យាសាស្ត្រពិតប្រាកដនោះ គឺនៅត្រង់ពុទ្ធវាចាសរុបក្នុងចំណុចថា ដរាបណាព្រះអង្គបានប្រព្រឹត្តធម៌អស់ជើង ឬគ្រប់សព្វអស់ហើយ, នៅតែមិនបានឃើញអរិយសច្ចៈ ៤ ប្រការនេះ ដរាបនោះព្រះអង្គនៅតែមិនប្រកាសថា ខ្លួនព្រះអង្គបានត្រាស់ជាព្រះពុទ្ធជាដាច់ខាត ។ ជាមួយគ្នានេះទៀត, ព្រះអង្គបានធ្វើសេចក្តីបញ្ជាក់បន្ថែមថា បើអរិយសច្ចៈ ៤ មានភាពនៅជាទ្រឹស្តីទទេ មិនមែនមានភាពជាភាគប្រតិបត្តិ ឬត្រាស់ដឹង ឬអនុវត្តទេ ព្រះអង្គនឹងមិនធ្វើការអ្វីៗទាំងអស់ នៅក្នុងក្របខ័ណ្ឌនៃគំនិតស្មាន, សម្បជញ្ញៈកេរ្តិ៍ឈ្មោះ, មនសិការឆ្គួត, ស្មារតីអំនួតឡើយ ។ល។

បង្រៀនផ្លូវកណ្តាល (THE MIDDLE WAY) ជាទំរើមួយមិនចូលទៅក្នុងផ្នែកទីបំផុតណាមួយ ក្នុងបណ្តាទីបំផុតទាំងពីរ (EXLREMES) ក្តី បង្រៀនពីធម្មញ្ញតា ភាពបុគ្គលស្គាល់ប្រមាណ (MODERBVION) គឺភាពល្មមសមគួរក្តី, ភាពនេះមានទំនងដំណើរជាវិទ្យាសាស្ត្រ ក៏ព្រោះវាមាននៅក្នុងវិទ្យាសាស្ត្រខ្លួនឯងតែម្តង ទោះណាជាមានគ្រឿងឧបករណ៍ផ្សេងៗ ដែលគេបង្កើតឡើង ដើម្បីវាស់ថ្លឹងរកភាពល្មម ភាពសមគួរ ឬភាពត្រឹមត្រូវ ដូចជាគ្រឿងប្រដាប់វាស់កម្តៅ (សីតុណ្ហភាព) វាស់ភាពលឿន វាស់ភាពជ្រាបសើម វាស់ចរន្តអគ្គិសនី វាស់អំណួសនៃចំហាយទឹក ។ល។ ទំរើទាំងអស់នេះគ្រាន់តែជាជំនួយប៉ុណ្ណោះ ព្រោះភាពល្មម ឬភាពគ្រប់គ្រាន់តាមចំនួនតាមកម្រិតវាមានមុខងារត្រឹមតែការពារភាពភ្លាំងភ្លាត់ទាំងឡាយ ដែលអាចកើតមានឡើងដោយចៃដន្យ ព្រោះតែខ្វះគ្រឿងឧបករណ៍ជំនួយទាំងអស់នេះឯង ។

បង្រៀនបដិច្ចសមុប្បាទ ដែលលោកចែកជាហេតុផលខាងខ្សែសម្រាប់កើតមួយចំណែក សម្រាប់រលត់មួយចំណែក ។ យើងមើលវិស័យកើតឃើញរហូតដល់វិស័យរលត់ ព្រោះវិស័យទាំងពីរនេះ វាបានបញ្ចូលចរន្តបន្តៗគ្នា គ្មានពេលឈប់ កុំថាច្រើនសូម្បីត្រឹមកន្លះវិនាទី ក៏អ្នកស្រាវជ្រាវខាងផ្លូវចិត្តថា មិនដែលឃើញមានដល់ម្តងណាផង ។ ព្រះសម្មាសម្ពុទ្ធ បានមានព្រះពំនោលដល់អវិជ្ជាថា ជាឫសគល់ធ្វើឲ្យសត្វលោកវិលវល់កើតចាស់ឈឺស្លាប់ព្រមគ្នានេះបានពោលដល់អវិជ្ជាដដែលថា បើសត្វលោករលត់ ឬស្រាយរួច, ការស្គាល់សេចក្តីពិត ដែលជាហេតុឲ្យរួចផុតចាកសេចក្តីទុក្ខ ក៏នឹងកើតឡើងភ្លាមបាន, កំណើតអន្ទោលក៏អស់ទៅឯងដោយស្វ័យប្រវត្តិ ។ ពុទ្ធពំនោលនេះជាចំណុចនៃវិទ្យាសាស្ត្រ ហួសពីមានលក្ខណៈជាវិទ្យាសាស្ត្រ ឬប្រៀបបាននឹងវិទ្យាសាស្ត្រ គឺជាវិទ្យាសាស្ត្រត្រង់ៗចំៗហ្នឹងតែម្តង ។

ពុទ្ធសាសនាមានលក្ខណៈពិសេស ដោយមានគំនោលបង្រៀនជាវិទ្យាសាស្ត្រ ផលិតវិញ្ញាណមនុស្សមិនឲ្យជឿអ្វីៗគ្មានហេតុផល ឲ្យមានគំនិតស្រាវជ្រាវមុននឹងធ្វើទំរើទាំងឡាយ ដែលជាប្រយោជន៍សម្រាប់ចិត្តក្តី សម្រាប់រូបក្តី ឲ្យធ្វើការសាកល្បងពិសោធជាមុនសិន ។ នេះបញ្ជាក់ឲ្យឃើញថា ពុទ្ធសាសនាមាបន្ទាត់គំនិតជាវិទ្យាសាស្ត្រ

មានបំណងឲ្យវត្ថុគ្រប់បែប គ្រប់យ៉ាងទោះជាសមិទ្ធិក្ដី សំណង់ក្ដី សម្ភារៈប្រើប្រាស់ក្ដី សម្ភារៈអាហារក្ដី ។ល។ កើតមានឡើងនៅក្នុងក្របខ័ណ្ឌវិទ្យាសាស្ត្រ ។

អ្នកសិក្សាប្រវត្តិសាស្ត្រ, គង់ធ្លាប់បានដឹងមកហើយថា អ្នកវិទ្យាសាស្ត្រជាច្រើន បានត្រូវពួកសាសនាចាប់ខ្លួនយកទៅដុតភ្លើងទាំងរស់ ព្រោះតែមានជំនឿមិនស្របគ្នា ឬមានគំនិតផ្ទុយគ្នាក្នុងហេតុការណ៍ខ្លះ ឬវត្ថុធម្មជាតិខ្លះ ដូចជាអ្នកវិទ្យាសាស្ត្រមានគំហើញថា ដួងផ្កាយដែលឋិតនៅលើផ្ទៃមេឃ ឬលំហនៃអាកាសមួយៗ ជាពិភពលោកមួយៗ ដូចជាពិភពមនុស្សដែរ ។ តែប្រវត្តិនៃទំរើកៀបសង្កត់ជិះជាន់ ឬប្រឆាំងនិងមតិបែបនេះ ពុំដែលមានក្នុងព្រះពុទ្ធសាសនារបស់យើងឡើយ ។ ដូចនេះ, ពុទ្ធសាសនាមិនត្រឹមតែគ្មានទំរើជិះជាន់សេរីភាពខាងផ្លូវគំនិតរបស់មនុស្សទាំងឡាយប៉ុណ្ណឹងទេ គឺមានគំនោលធម្មៈការពារសេរីភាពរបស់មនុស្សដូចបានពោលមកហើយក្នុងចំណុចស្ដីដល់គំនោលធម្មៈ (វៀរចាកទំរើជិះជាន់, បង្កើតទំរើសង្គ្រោះ, រស់នៅក្នុងគំនិតស្អាត ឬព្រហ្មវិហារធម៌) ។

សូម្បីគំនិតគំហើញ ក្នុងរឿងមានពិភពលោកនិងវត្ថុទាំងឡាយ រួមទាំងមនុស្សសត្វផង កើតឡើងខ្លួនឯង ឬមានអ្នកបង្កើត ។ ព្រះពុទ្ធសាសនាគ្មាននិយាយ គ្មានបង្រៀនរឿងនេះនឹងគេទេ ។ អ្នកណាយល់យ៉ាងណាទៅយ៉ាងនោះទៅ ។ ប្រសិនបើមានគេលើកយករឿងនេះមកចោទសួរ ព្រះសម្មាសម្ពុទ្ធព្រះអង្គបានឲ្យចម្លើយថា កុំចង់ដឹងរឿងហ្នឹងធ្វើអ្វី ដឹងទៅក៏គ្មានប្រយោជន៍ដល់ការរស់នៅរបស់មនុស្សដែរ ។ របស់ដែលយើងត្រូវដឹងនោះ គឺធ្វើយ៉ាងណាឲ្យទំរើរបស់យើងមានវឌ្ឍនភាពគ្រប់វិស័យ ។ ជាមួយគ្នានេះទៀត, ត្រូវខំរៀនឲ្យច្រើន ដើម្បីឲ្យគំនិតរបស់យើងមានប្រសិទ្ធភាព ក្នុងទំរើស្រាយបញ្ហាជីវិត នៅក្នុងក្របខ័ណ្ឌនៃសន្តិសុខជីវិត នៃយុត្តិធម៌សង្គម នៃសន្តិភាពជាស្ថាពររបស់ពិភពលោក ។ល។ គំនិតស្រាយបញ្ហាមនុស្ស ដោយរកដើមកំណើតទឹកដី . . . . ឬពិភពលោកកើតពីត្រឹមណា កើតឯង ឬមានអ្នកបង្កើត មានអាយុប៉ុន្មានឆ្នាំមកហើយ ។ បញ្ហានេះ, ត្រូវតែប្រញាប់នាំគ្នាបញ្ចប់ទៅ ហើយនាំគ្នាដាំពោតស្លូងស្រូវ ចិញ្ចឹមសត្វប្រើប្រាស់ ។ល។ ទៅវាចប់ចំណោទប៉ុណ្ណឹងហើយ ។ ឧបមាថា បើយើងរកឃើញថា ពិភពលោកកើតឯង ក៏ពុំអាចយកឯងនេះមកធ្វើបាយស៊ីបានទេ, បើថាពិភពលោកនេះ ព្រះអាទិទេពលោកបង្កើត ក៏ពុំអាចយកទំរើបង្កើតនេះ មកធ្វើជានំបញ្ចុកស៊ីបានឡើយ ។ ព្រោះទំរើកំហូចរបស់យុវមាណពឈ្មោះ **អាដាំ** និងកញ្ញាឈ្មោះ **អេវា** បានបណ្ដាលឲ្យព្រះអាទិទេព **យ៉ះហូវ៉ា** ខ្ញាល់យ៉ាងខ្លាំងហើយជាមួយគ្នានិងកំណាល់នេះ ព្រះអង្គបានដាក់ទំនាយថា កំហុសរបស់ឯងទាំងពីរនាក់នេះ, នឹងធ្វើឲ្យមនុស្សត្រូវទទួលសេចក្ដីលំបាករហូតហើយ ។ អាទិទេពទំនាយនេះ យើងអាចធ្វើសេចក្ដីបកស្រាយថា ព្រះអង្គគ្មានកំហុសទេ គឺ **អាដាំ** និង **អេវា** ពីរនាក់ហ្នឹងឯងបង្កើតទុក្ខសោកឲ្យមនុស្សគ្នាឯង ។ **យ៉ះហូវ៉ា** ដែលបង្កើតអ្វីៗទាំងអស់រួមទាំង **អាដាំ** និង **អេវា** ផង ហើយដែលប្រហែលដល់ **សាតាំង** ផងដែរនោះ ព្រះអង្គបានរួចខ្លួនទទេ ។ យ៉ាងណាក៏ដោយ, រឿងនេះជារឿងរបស់គ្រិស្តសាសនិក ។ តែបើឲ្យអស់ជើង ឲ្យមានន័យទូលំទូលាយ ដើម្បីស្រួលងាយដល់ទំរើវិភាគរបស់ពុទ្ធសាសនិកយើង ។ បញ្ហានេះមិនមែនមានតែក្នុងសាសនាគ្រិស្តមួយទេ សាសនាឥស្លាមនិងសាសនាព្រាហ្មណ៍ក៏មានបញ្ហានេះដែរ ។ បើមិនដូចគ្នាទាំងអស់ក៏ត្រូវគ្នាច្រើនក្នុងចំណុចធំៗ ។ ជាពិសេសដូចបញ្ហាអាទិទេពសាងលោក, សាសនាទាំង ៣ មានគំហើញត្រូវគ្នាមួយចំនួនដល់មួយរយភាគរយតែម្ដង ។ គឺគំនិតអាទិទេពកសាងលោកនេះហើយ ដែលជាមូលដ្ឋាននៃគំនិតផ្ញើសេចក្ដីសុខទុក្ខ លើព្រះអាទិទេព គោរពអាទិទេព បន់ស្រន់អាទិទេព សូត្រធម៌ថ្វាយបង្គំចំណុះចំណូលចិត្តព្រះអាទិទេព ។ បើនិយាយតាមន័យជាពាក្យបច្ចេកទេស គឺសាសនាទាំង ៣ នេះ ជាសាសនាដែលសាសនិកមិនជាប់កិច្ចសន្យា ឬមានប្រព័ន្ធករណីយ៍ជាមួយគ្នានិងព្រះអាទិទេពរបស់ខ្លួន ។ដោយមានទំរើនេះជាហេតុបច្ច័យ ទើបសាសនាទាំង ៣ នេះ ត្រូវបានដាក់ឈ្មោះថា «RELIGION» ប្រែថាមានទំរើ ឬមានព័ន្ធកិច្ចរវាងមនុស្សនិងព្រះអាទិទេព ។ ចំណែកពុទ្ធសាសនារបស់

យើង ដែលជាសាសនាមានទ្រឹស្តី មានទំរើ មានលក្ខណៈ មានការអនុវត្តជាវិទ្យាសាស្ត្រ ឬជាវិទ្យាសាស្ត្រផង ជាទស្សនវិជ្ជាផង ដូចពោលមកហើយក្នុងខាងដើមនោះ ។ ពុទ្ធសាសនិកទាំងឡាយគ្មានជាប់កិច្ចសន្យា គ្មានប្រព័ន្ធកិច្ច ឬសម្ពន្ធករណីយ៍ជាមួយគ្នា និងព្រះពុទ្ធបរមគ្រូរបស់យើងទេ ខាងផ្នែកប្រព្រឹត្តប្រតិបត្តិធម៌ ឬអនុវត្ត, តែខាងផ្នែកទ្រឹស្តី ឬធម្មទេសន៍ យើងមានព្រះពុទ្ធអង្គជាសរណៈ ជានាថៈ ឬជាគ្រូអាចារ្យរបស់យើងពេញទី ។ ខាងក្រោយបរិនិព្វានរបស់ព្រះអង្គ យើងមានធម្មៈជាពន្លឺ ជាសរណៈ ឬជាទ្រឹស្តីរបស់វិញ្ញាណ យើងអនុវត្តទំរើតាមទ្រឹស្តី ឬធម្មៈ យើងគ្មានការចាំបាច់ត្រូវធ្វើប្រព័ន្ធកិច្ចជាមួយនិងព្រះអង្គទៀតទេ, តែយើងនៅតែព្យាយាមសូត្រធម៌រម្លឹកព្រះគុណរបស់ព្រះអង្គ ដើម្បីអនុវត្តចិត្តវិញ្ញាណរបស់យើង ឲ្យមានគុណធម៌ល្អប្រសើរដូចព្រះគុណរបស់ព្រះអង្គ (បញ្ញាគុណ វិសុទ្ធិគុណ ករុណាគុណ) ។ ប្រែថា ទំរើអាក្រក់ល្អរបស់យើង ជាទំរើគ្មានប្រព័ន្ធកិច្ចជាមួយនិងព្រះសម្មាសម្ពុទ្ធឡើយ ។ បើនិយាយឲ្យច្បាស់ៗត្រង់ៗចំៗ ដើម្បីពុទ្ធសាសនិកស្តាប់បាន ដោយគ្មានចាំបាច់ត្រូវធ្វើការបកស្រាយនាំខាតពេល ។ ទំរើបុណ្យបាបរបស់យើង អ្នកណាធ្វើ អ្នកនោះទទួល ព្រះសម្មាសម្ពុទ្ធគ្មានទំរើផ្តល់និងទំរើទទួលជំនួសយើងទេ ។ ដើម្បីជាពន្លឺដល់អ្នកអានក្នុងរឿងនេះជាថ្មីទៀត : យើងកុំភ្លេចពុទ្ធភាសិតក្នុងចំណុចមួយថា អ្នកណាឃើញធម៌, អ្នកនោះឃើញអញតថាគត, អ្នកណាគោរពធម៌, អ្នកនោះគោរពអញតថាគត ។ល។ ដោយមានហេតុ មាបច្ច័យដូចពោលមកនេះ ទើបពុទ្ធសាសនាត្រូវបានដាក់ឈ្មោះថា «BUDDHISM» មិនត្រូវបានដាក់ឈ្មោះថា «RELIGION» ដូចសាសនាទាំងឡាយដទៃឡើយ ។ កំណើតពិភពលោកទាំងឡាយ ព្រះសម្មាសម្ពុទ្ធរបស់យើង ព្រះអង្គបានបង្រៀនបែបកណ្តាលៗថា របស់ដែលមានបច្ច័យតុបតែងទាំងឡាយ រមែងប្រព្រឹត្តទៅតាមហេតុ តាមបច្ច័យ ។ ពាក្យថា **បច្ច័យ** ក្នុងទីនេះជាពាក្យកណ្តាល ។ អ្នកវិទ្យាសាស្ត្រផ្នែកខាងតារាវិទ្យា គេមានជំនឿថា ដុំពពកភ្លើង (NEBULA) ជាដើមធាតុឲ្យកើតដួងអាទិត្យ, ដួងអាទិត្យជាហេតុឲ្យកើតពិភពលោក, ពិភពលោក ឬផ្កាយគ្រោះ (PLANETS) ជាហេតុឲ្យកើតដួងចន្ទ ។ គំនិតនេះ មានការទំនាស់នឹងសាសនាដទៃខ្លះ, តែគ្មានទំនាស់នឹងគំនោលហេតុបច្ច័យ ដែលសម្តែងដោយព្រះសម្មាសម្ពុទ្ធឡើយ ។ ព្រោះហេតុដូចនេះ, អ្នកសិក្សាវិជ្ជាពុទ្ធសាសនា បើមានការយកចិត្តទុកដាក់ ក្នុងវិជ្ជាវិទ្យាសាស្ត្រ គេអាចនឹងធ្វើការសិក្សាប្រៀបធៀបគ្នាបានយ៉ាងល្អប្រសើរក្រៃលែង ។ ព្រោះពុទ្ធសាសនា មានគំនិតជ្រៅទូលំទូលាយណាស់ និយាការអ្វីៗមិនសូវនិយាយចំៗទេ ច្រើននិយាយក្បែរៗ ផ្អែកលើហេតុ លើបច្ច័យនានា ដើម្បីឲ្យមនុស្សរៀនប្រើគំនិតឲ្យបានមធ្យ័តសិន ។ មនុស្សយើងបានស្គាល់អ្វីមួយ ដោយអាស្រ័យគំនិតជ្រៅល្អិត សម្គាល់របស់គេនោះ និងគ្មានការផ្លាស់ប្តូរប្រែប្រួលងាយៗឡើយ ។ ពុទ្ធសាសនានិងវិទ្យាសាស្ត្រ ធាតុទាំងពីរនេះ មានពេលខ្លះជាធាតុតែមួយមានពេលខ្លះចែកគ្នាជាពីរ ។ តែមួយព្រោះទំរើទាំងអស់បានផ្អែកលើហេតុផលនិងបញ្ញាដូចគ្នា ។ល។ ទៅជាពីរព្រោះពុទ្ធសាសនាប្រកាន់យកសីលធម៌ជាធំ សម្រាប់ជីវិតមនុស្សរស់នៅក្នុងសង្គម ។ ចំណែកវិទ្យាសាស្ត្រមិនសូវប្រកាន់យកសីលធម៌ជាធំរបស់សង្គម ឬមានពេលខ្លះរហូតដល់ទៅគ្មានខ្វីរវល់ដល់សីលធម៌តែម្តង ។ ដូចនេះដើម្បីសន្តិភាពនៃជីវិតសកល ពុទ្ធសាសនិកនិងវិទ្យាសាដែលជាធាតុផ្ទុយគ្នានិងធាតុសន្តិភាពក៏ចប់ប៉ុណ្ណឹងដោយគ្មានការចាំបាច់កោះប្រជុំ ធ្វើសន្និសីទបញ្ចប់សង្គ្រាមនៅ លើតុមូលក្នុងកន្លែងណាមួយឡើយ ។

# បទទី ១២
## ប្រជាធិបតេយ្យ

«ព្រះពុទ្ធសាសនារបស់យើង ជាតួយ៉ាងនៃលទ្ធិប្រជាធិបតេយ្យ បរមបូរាណរបស់ពិភពលោក មានគោលការណ៍និងពិធីកម្មយ៉ាងទាន់សម័យតាំងពីកាលនោះមក រហូតដល់សព្វថ្ងៃនេះ»

ជាដំបូងនេះយើងត្រូវស្គាល់ថា : ពាក្យប្រជាធិបតេយ្យ ដែលគេបានប្រែពីភាសាអង់គ្លេសថា : DEMOCRACY នោះមានអត្ថន័យដូចម្តេច រួចហើយយើងត្រូវពិចារណាតទៅទៀតថា : ព្រះពុទ្ធសាសនាដែលរាប់ថា ជាតួយ៉ាងនៃលទ្ធិប្រជាធិបតេយ្យយ៉ាងមានចំណាស់ជាទីបំផុត របស់ពិភពលោក, ធាតុនេះមានគោលការណ៍ និងពិធីកម្មទាន់សម័យដូចម្តេចខ្លះ ។

ពាក្យថាប្រជាធិបតេយ្យ, យើងត្រូវញែកជាពីរបទគឺ ប្រជានិងអធិបតេយ្យ អធិបតេយ្យគឺភាពធំ ។ ប្រជាធិបតេយ្យប្រែថា ប្រជាជនមានភាពជាធំ, ពាក្យនេះមានន័យប៉ុនគ្នា ជឬជិតតែនឹងស្មើគ្នានឹងពាក្យរបស់អង់គ្លេសហើយ ។ គឺពាក្យអង់គ្លេសថា DEMOCRACY មកពីពាក្យក្រិកថា DEMOKRATIA ។ ពាក្យនេះញែកបានជាពីរ : DEMOS = ប្រជាជន, KRATIA = អំណាច, កាលបើប្រែរួមគ្នាមានសេចក្តីត្រូវនឹងពាក្យអង់គ្លេសថា : PEOPLE´S POWER (អំណាចរបស់ប្រជាជន) ។

ពាក្យនិយាមរបស់ប្រជាធិបតេយ្យយ៉ាងខ្លីថា : «ប្រជាធិបតេយ្យគឺជារូបនៃការគ្រប់គ្រង ឬរបបគ្រប់គ្រង ដែលប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់មានអំណាចខ្ពង់ខ្ពស់បំផុត ព្រមទាំងប្រើអំណាចនោះតាមអ្នកតំណាងរបស់ខ្លួន (តំណាងរាស្ត្រ) DEMOCRACY IS A FORM OF GOVERNMENT IS ROHICH THE PEOPLE RETAIN SUPREME POWER AND EXERCISE THEIR POWER TROUGH (REPRESENTATIVE)

ប្រទេសក្រិកត្រូវបានអ្នកប្រវត្តិសាស្ត្រឲ្យឈ្មោះថា ប្រទេសឲ្យកំណើតនៃលទ្ធិប្រជាធិបតេយ្យមុនគេក្នុងពិភពលោក ។ ព្រោះហេតុដូចនេះ, ពាក្យអង់គ្លេសដែលមានន័យត្រូវគ្នានឹងពាក្យបាលីថា ប្រជាធិបតេយ្យ ដូចបានពោលមក, ទើបត្រូវជាពាក្យដែលមានឫសគល់មកអំពីភាសាក្រិកហ្នឹងឯង ។

កាលណាគេត្រួតពិនិត្យមើលប្រវត្តិសាស្ត្រក្នុងចំណុចថា: ប្រជាធិបតេយ្យរបស់ក្រិកផ្តើមកើតមានក្នុងពេលណា អ្នកណាបង្កើត ។ គេនឹងបានឃើញនូវពាក្យជជែកគ្នានៃអ្នកប្រវត្តិសាស្ត្រ ដែលមានការមិនស្របយោបល់គ្នាជាច្រើន ។ អ្នកខ្លះថា : សូលូន (SOLON) អ្នកមានកំណើតប្រមាណ ៥៣៨ ឆ្នាំមុនគ្រិស្តសករាជ : ក្នុងរយៈវេលាស្របាលនឹងព្រះពុទ្ធបានត្រាស់ ។ បុគ្គលនេះត្រូវបានគេដាក់ឈ្មោះថា ជាបិតានៃប្រជាធិបតេយ្យរបស់ក្រិក, អ្នកខ្លះថា គ្លិសធេនីស (GLEISTHENES) ដែលកើតក្រោយសូលូនប្រមាណ ១០០ ឆ្នាំ ជាអ្នកបង្កើតនិងត្រូវបានគេលើកតម្កើងជាបិតាប្រជាធិបតេយ្យរបស់ក្រិក ។ តែដែលគេទទួលស្គាល់ទាំងអស់គ្នានូវសេចក្តីចម្រើននៃប្រជាធិបតេយ្យរបស់ក្រិកនោះវិញ គឺក្នុងសម័យរបស់ប៉េរិសគ្លិស (PERICLES) ជាសម័យផងគ្នានិងសូក្រាត (SOCRATES) និងប្លាតូ (FLATO) ទាំងអស់គ្នានេះ សុទ្ធតែជាទស្សនវិទូមានកេរ្តិ៍ឈ្មោះរន្ទឺឮលេចរបស់ជនជាតិក្រិក, ដែរគេប៉ាន់ស្មានថា មានរយៈវេលាបន្តបន្ទាប់គ្នាមកពីសម័យនៃគ្លិសធេនីសមិនដល់ ១០០ ឆ្នាំ ។

សរុបសេចក្តីថា : បើគេចង់ដឹងកំណើតប្រជាធិបតេយ្យរបស់ក្រិក, គេអាចនឹងមើលបានដោយញែករយៈវេលាស្របាលគ្នា ឬឃ្លាតឆ្ងាយពីគ្នាមិនដល់ ១០០ ឆ្នាំ គឺ៖

១- រយៈដំបូង, កាលពី ៥៩៤ ឆ្នាំ មុនគ្រិស្តសករាជ សម័យដែលសូលូនកែប្រែរដ្ឋធម្មនុញ្ញរបស់ក្រិក ជាគ្រាទី ១ ដែលមានសភាប្រជាជន (POPULER ASSEMBEY) ។

២- រយៈបន្ទាប់, កាលពី ៥០៩ ឆ្នាំ មុនគ្រិស្តសករាជ សម័យគ្លិសធេនីស កែប្រែរដ្ឋធម្មនុញ្ញរបស់ក្រិកម្តង

ទៀត ដោយឲ្យប្រជាជនបានទទួលសិទ្ធិសេរីភាពកាន់តែមានចំនួនច្រើនឡើងជាងមុន ។

៣- រយៈចុងក្រោយ, កាលពី ៤៦១ ឆ្នាំ មុនគ្រិស្តសករាជ ដែលរាប់ថា ជាសុវណ្ណយុគរបស់ក្រិក គឺជាយុគដែលប៉េរីសគ្លិស អ្នកប្រកាន់យកយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យតាមបែបគ្លិសធេនីស បានស្ថាបនាពង្រឹងបន្ថែមឲ្យលទ្ធិប្រជាធិបតេយ្យរបស់គ្លិសធេនីសរីកចម្រើនដល់ថ្នាក់ទីបំផុតក្នុងយុគនោះ ។

ទាំង ៣ រយៈនេះ, មានវេលាជិតៗគ្នាក្នុងចំនួន ៣០០ ឆ្នាំ ប៉ុណ្ណោះ ។ រយៈដំបូង, ជារយៈស្របាលគ្នានឹងពុទ្ធកាល, ចំណែករយៈទី ២ ក្រោយពុទ្ធកាល ឬក្រោយពុទ្ធបរិនិព្វាន ( ព្រះសម្មាសម្ពុទ្ធនិព្វានកាលពី ៥៤៣ ឆ្នាំមុនគ្រិស្តសករាជ) ។

ដើម្បីឲ្យអ្នកអានឆាប់ចូលចិត្តរឿងនេះច្បាស់លាស់ ខ្ញុំសូមផ្តល់គំនិតជាថ្មីទៀតចំពោះដំណើរប្រព្រឹត្តទៅនៃព្រឹត្តិការណ៍ដែលជាប់ទាក់ទងគ្នាជាមួយនឹងប្រជាធិបតេយ្យរបស់ក្រិកទាំង ៣ រយៈកាល ។ ដើម្បីងាយស្រួលដល់ការប្រៀបផ្ទឹមគ្នារវាងប្រជាធិបតេយ្យរបស៉ក្រិក និងប្រជាធិបតេយ្យដែលព្រះសម្មាសម្ពុទ្ធបានប្រទានទុកមក ។ តែយើងទាំងអស់គ្នាមិនត្រូវភ្លេចថា : ប្រជាធិបតេយ្យរបស់ក្រិកជាធាតុនយោបាយប្រើបានទាំងផ្នែកកុសល និងអកុសល ។ ចំណែកប្រជាធិបតេយ្យរបស់ពុទ្ធសាសនា ជាធាតុនយោបាយប្រើបានតែខាងផ្នែកកុសល ។ ធាតុទាំងពីរយ៉ាងនេះ យើងមិនអាចចាត់ទុកថា ដូចគ្នាទាំងអស់បានទេ, ចំណុចដែលយើងត្រូវធ្វើសេចក្តីកត់សម្គាល់នូវភាពត្រូវគ្នា និងភាពប្លែកគ្នានៃធាតុទាំងឡាយ (ប្រជាធិបតេយ្យរបស់ក្រិកនិងប្រជាធុបតេយ្យរបស់ពុទ្ធសាសនា) នោះមិនមែនផ្អែកទៅលើរបស់អ្វីដទៃក្រៅពីគោលការណ៍នៃធាតុទាំងអស់នេះទេ ។

ក្នុងសម័យសូលូនកែប្រែរដ្ឋធម្មនុញ្ញរបស់ក្រិកនោះ វាជាធាតុមួយលើកតម្កើងឲ្យខ្លួនគាត់បានទទួលកិត្តិយសថា ជាបិតាប្រជាធិបតេយ្យរបស់ក្រិក ។ គឺក្នុងសម័យដែលប្រទេសក្រិក កំពុងមានការគ្រប់គ្រងបែបអភជនាធិបតេយ្យ (ARISTO CRACY) គឺមានបនជនដែលគេទុកដាក់ថា មានជីវិតរស់នៅក្នុងថ្នាក់ជាន់ខ្ពស់មានភាពជាធំ, ជាអ្នកកាន់អំណាចទូទៅក្នុងប្រទេស, ហើយដែលគេហៅម៉្យាងទៀតថា ជនកើតក្នុងត្រកូលខ្ពស់ហ្នឹងឯង ។ គឺមានតែជនពួកនេះប៉ុណ្ណោះទេ, ដែលមានអំណាចគ្រប់គ្រងប្រទេស, មានអំណាចត្រួតត្រាបង្គាប់បញ្ជាលើជនតូចតាចក្រីក្រ ។ ជនពួកទាបថោកទាំងអស់នេះ សុទ្ធតែកូនបំណុលរបស់ជនថ្នាក់ខ្ពស់ស្ទើរតែគ្មានសល់ម្នាក់ឡើយ ។ កូនបំណុលទាំងឡាយ, ប្រសិនបើគ្មានសមត្ថភាពរកប្រាក់សងម្ចាស់បំណុល តាមពេលដែលគេបានកំណត់ឲ្យនោះទេ ។ ទាំងអស់គ្នា, គេចមិនផុតពីត្រូវគេរឹបអូសយកខ្លួនធ្វើជាទាសៈឡើយ ។ ទោះជាបំណុលនោះត្រូវកើតមានឡើងមួយដងមួយកាល តាមការចាំបាច់ដែលគេត្រូវឲ្យខ្ចី ឬចងការនោះក៏ដោយ ។ ការចាំបាច់ ឬពេលចាំបាច់របស់អ្នកក្រីក្រនោះ មានជាអាទិ៍ ពេលច្រូតកាត់ផលស្រូវ, ពេលផ្តើមប្រកបរបរដំណាំ, ពេលមានគ្រោះថ្នាក់ដោយមិនដឹងខ្លួនជាមុន ។ សូលូន, ជាអ្នកអារកាត់សម្រេចសេចក្តីលើកចោលច្បាប់ជំពាក់បំណុល, មិនយល់ព្រមឬមិនអនុញ្ញាតឲ្យម្ចាស់បំណុលរឹបអូសយកកូនបំណុលទៅធ្វើជាទាសៈរបស់ខ្លួន ឬយកទៅលក់ឲ្យធ្វើទាសៈអ្នកណាដទៃទៀត ។ យ៉ាងណាក៏ដោយចុះ, ការការកែប្រែរដ្ឋធម្មនុញ្ញរបស់សូលូនក្នុងសម័យនោះ ក៏នៅពុំទាន់មានប្រសិទ្ធភាពសម្រាប់មនុស្សលោកពេញលេញនៅឡើយទេ ។ សូលូនឯង, នៅតែចែកមនុស្សជា ៤ ថ្នាក់គឺ : អ្នកមានធំ, អ្នកមានមធ្យម, អ្នកមានតិច និងអ្នកទីទាល់ ។ នៅក្នុងន័យនេះមានតែអ្នកមានស្តុកស្តម្ភមួយពួកប៉ុណ្ណទេ, ដែលមានសិទ្ធិធ្វើនយោបាយដោយគ្មានកំណត់ក្របខ័ណ្ឌ ។ មនុស្សដែលគេទុកដាក់ថាមានធំ, មានមធ្យម, មានតិចនិងទីទាល់ក្រនោះ, គេមានកំណត់បរិមាណ ឬចំនួនយ៉ាងទៀងទាត់ពីប៉ុណ្ណេះទៅប៉ុណ្ណោះ ត្រូវបានធ្វើជាអ្នកមានធំ ។ល។ ប្រហាក់ប្រហែលគ្នានឹងប្រទេសឥណ្ឌាក្នុងជំនាន់ព្រះពុទ្ធបានត្រាស់, គេបាកំណត់ចំនួនទ្រព្យសម្រាប់អ្នកមានតាមថ្នាក់ជាន់អីចឹងដែរ ។ អ្នកអានគួរធ្វើសេចក្តីកំណត់សម្គាល់និងសេចក្តីចងចាំថា មនុស្សដែលជាកម្មករ

ឬទីទាល់ក្រនោះ ត្រូវបានគេចាត់ទុកក្នុងប្រភេទទី ៤ (ប្រភេទទន់ខ្សោយ) ។

បុគ្គលទាំង ៤ ប្រភេទនេះ, ប្រភេទទី ១ (ប្រភេទមានច្រើន) ជាអ្នកមានសិទ្ធិនៅក្នុងថ្នាក់ជាជនគ្រប់គ្រងប្រទេស ដោយត្រូវគេជ្រើសតាំងឲ្យធ្វើជាអភិរដ្ឋមន្ត្រី កាន់តំណែងខ្ពស់ជាមនុស្សជាន់ទី ១ ឬជាន់ខ្ពស់ ។ ចំណែកតំណែងកណ្ដាលនិងតំណែងទាបបានដល់ប្រភេទជនទី ២ និង ៣ ។ ដូចនេះឃើញថា : ក្នុងបណ្ដាប្រភេទទាំង ៤ នេះ មានតែមនុស្សប្រភេទទី ៤ (ក្រខ្សត់) មួយប៉ុណ្ណោះទេ, ដែលមិនត្រូវបានទទួលតំណែងការងាររដ្ឋ សូម្បីបន្តិចបន្តួចឡើយ ។

នៅក្នុងសម័យជាមួយគ្នានេះ : ព្រះសម្មាសម្ពុទ្ធបានបញ្ញត្តិវិន័យ ឲ្យភិក្ខុសង្ឃមានអំណាចគ្រប់គ្រងពួកគណៈ (នីតិប្រតិបត្តិ) មានសិទ្ធិបញ្ចេញមតិបដិសេធចោលនូវច្បាប់ណាដែលខ្លួនមិនយល់ស្របផង ។ ទាំងអស់នេះភិក្ខុសង្ឃធ្វើបានដោយមិនមានព្រំដែន គឺគ្មានកំណត់ថា ភិក្ខុណាកើតក្នុងត្រកូលខ្ពស់ ឬត្រកូលទាបឡើយ ។ នៅក្នុងន័យនេះ, ព្រះសម្មាសម្ពុទ្ធបានធ្វើសេចក្ដីបញ្ជាក់ថា ភិក្ខុទាំងឡាយតាមតែចេញចាកត្រកូលណាក៏ដោយ, ស្ដុកស្ដម្ភ ឬខ្សត់ខ្សោយ ។ កាលណាមកបួសជាភិក្ខុ សាមណេរ ឬប្រគល់កាយថ្វាយខ្លួនជាមួយនិងចិត្តវិញ្ញាណ ហើយរស់នៅជាគ្រហស្ថប្រតិបត្តិធម្មវិន័យក្នុងសាសនាតថាគត អ្នកទាំងអស់គ្នានេះ ត្រូវមានសិទ្ធិស្មើគ្នាតាមកម្ពស់នៃធម៌ដែលខ្លួនរស់នៅ ។ សំមើក្នុងរឿងនេះ ពុំមែនត្រូវកម្រិតដោយត្រកូល, អម្បូរ, ជាតិសាសន៍, យសស័ក្តិវណ្ណៈទេ ។ល។ គឺត្រូវកម្រិតដោយសិក្ខានទ ឬធម្មៈដែលម្នាក់ៗ បានប្រព្រឹត្តប្រតិបត្តិ ។ ដូច្នេះ គេមិនត្រូវធ្វើសេចក្ដីបកស្រាយន័យថា «ស្មើ» ដែលព្រះសម្មាសម្ពុទ្ធប្រទាន ទៅលើវណ្ណៈយសស័ក្តិទ្រព្យសម្បត្តិត្រកូលពូជអម្បូរជាតិសាសន៍ទេ ។ ព្រោះអ្វី? ព្រោះការបកស្រាយទៅលើធាតុទាំងឡាយនេះ វាមិនមែនត្រឹមតែវាយតម្លៃមនុស្សខុសទទេៗហ្នឹងទេ គឺវាជាធាតុបង្កើឧបាទាន (សេចក្ដីប្រកាន់រឹងត្អឹង) ឲ្យមានកម្លាំងកាន់តែច្រើនឡើងៗ ហើយផលវិបាកនៃការប្រកាន់យកខុសនេះ វាជាប្រភពនៃជម្លោះតាំងពីតូចៗរហូតដល់ធំបំផុត ដែលគេនិយមហៅថា ចម្បាំងសព្វថ្ងៃនេះ ។

ដើម្បីការពារគំនិតភាន់ច្រឡំ ខ្ញុំសូមបញ្ជាក់ថា ព្រះសម្មាសម្ពុទ្ធ ពិតជាបានប្រទានសមភាព ឬភាពស្មើគ្នាដល់ពុទ្ធសាសនិកទាំងឡាយ ។ ជាពិសេសគឺភិក្ខុសង្ឃមែន តែសមភាពនេះ ពុំមែនជាសកម្មភាពគ្មានព្រំដែនទេ គឺមានព្រំដែនជាក់លាក់ថា រស់នៅក្នុងយុត្តិធម៌ស្មើគ្នា, រស់នៅក្នុងសិក្ខាបទស្មើគ្នា, រស់នៅក្នុងធម្មវិន័យស្មើគ្នា មានសិទ្ធិបញ្ចេញមតិដូចគ្នា, មានសិទ្ធិគិតគូរបានដូចគ្នា ។ល។ តែត្រូវរស់នៅក្នុងការគោរពគ្នាតាមចំនួនវស្សាតាមលំដាប់អាយុធម៌ដែលខ្លួនប្រព្រឹត្តប្រតិបត្តិ, តាមឋានៈគ្រូសិស្សមាតាបិតា ។ល។ នេះជាសិទ្ធិស្ដីពីសមភាពរបស់ពុទ្ធសាសនា ។

ក្នុងសម័យបន្ទាប់ពីសូលូនមិនដល់ ១០០ ឆ្នាំ, អ្នកប្រវត្តិសាស្ត្របានជួបប្រជាធិបតេយ្យថ្មីមួយទៀតមានលក្ខណៈទូលំទូលាយគួរជាទីស្រឡាញ់ពេញចិត្ត គឺសម័យរបស់គ្លិសធេនីស ។ ទស្សនវិទូរូបនេះ, ត្រូវបានគេទទួលស្គាល់ជាមួយនឹងការលើកតម្កើងថា ជាអ្នកបានបណ្ដេញបំបរបង់លទ្ធិអភិជនាធិបតេយ្យឲ្យអស់ពីក្រុងអាថែនរបស់ក្រិក ហើយបានស្ថាបនាបង្កើតឲ្យមានលទ្ធិប្រជាធិបតេយ្យ និងរដ្ឋធម្មនុញ្ញថ្មីឡើងទៀត ។

តួយ៉ាងប្រជាធិបតេយ្យដែលមានសូត្រស្មើញត្តិមួយដង សូមសេចក្ដីយល់ស្របមួយដងដែលហៅថា «ញត្តិទុតិយកម្ម» ក្នុងទីនេះស្ដីចំពោះតែរឿងឲ្យសំពត់កឋិនមួយ ដែលមានចែងក្នុងវិន័យបិដក ដើម្បីទុកជាគំរូដល់គំនិតរបស់អ្នកអានដូចនេះ :

«លោកដ៏ចម្រើន ! សូមសង្ឃស្ដាប់ពាក្យរបស់ខ្ញុំ សំពត់កឋិននេះកើតឡើងហើយដល់សង្ឃ បើសេចក្ដីព្រមព្រៀងរបស់សង្ឃមានក្នុងទីនេះហើយ សង្ឃគប្បីប្រគល់ឲ្យនូវសំពត់កឋិននេះ ដល់ភិក្ខុមានឈ្មោះដូចនេះដើម្បីក្រាលកឋិន នេះជាញត្តិ» ។

«លោកដចម្រើន ! សូមសង្ឃស្ដាប់ពាក្យរបស់ខ្ញុំ, សំពត់កឋិននេះកើតឡើងហើយដល់សង្ឃ សង្ឃឲ្យសំពត់នេះដល់ភិក្ខុមានឈ្មោះដូចនេះ ដើម្បីក្រាលកឋិន, ការឲ្យសំពត់នេះដល់ភិក្ខុមានឈ្មោះដូចនេះ ដើម្បីក្រាលកឋិន (ទំរើនេះរបស់សង្ឃ) បើភិក្ខុរូបណាមានសេចក្ដីយល់ស្រប ភិក្ខុរូបនោះគប្បីឋិតនៅក្នុងឥរិយាបទស្ងៀម, បើមិនពេញចិត្តដល់ភិក្ខុរូបណា ភិក្ខុរូបនោះគប្បីឆ្លើយមក ។ សំពត់កឋិននេះ សង្ឃបានប្រគល់ឲ្យហើយដល់ភិក្ខុមានឈ្មោះដូចនេះ ដើម្បីក្រាលកឋិន ការឲ្យនេះមានការយល់ស្របពីសង្ឃហើយ ហេតុនេះទើបសង្ឃស្ងៀមស្ងាត់គ្មានចម្លើយ, ខ្ញុំសូមធ្វើសេចក្ដីកត់សម្គាល់នូវសេចក្ដីសម្រេចចិត្តរបស់សង្ឃ ដោយប្រការដូចនេះ » ។

ចំណុចខាងលើនេះ បានបញ្ជាក់ឲ្យឃើញថា ពុទ្ធសាសនាជាគំរូនៃលទ្ធិប្រជាធិបតេយ្យ ដោយឥតប្រកែកបានឡើយ ។ (អ្នកអានចង់ដឹងសេចក្ដីពិស្ដារ សូមមើលសៀវភៅប្រជាធិបតេយ្យចាស់ទុំប្រកបផងចុះ) ។

## បទទី ១៣
## ការលុបបំបាត់ទាសៈ

«ព្រះពុទ្ធសាសនា ជាសាសនាដំបូងបង្អស់ដែលទំនុកបម្រុងនិងគាំទ្រសិទ្ធិមនុស្ស ដោយបានបង្រៀនឲ្យលុបបំបាត់ទាសៈ មិនឲ្យយកមនុស្សមកធ្វើជាទំនិញសម្រាប់លក់ទិញ ហាមមិនឲ្យភិក្ខុមានទាសៈទុកសម្រាប់ប្រើ ។ ជាមួយគ្នានេះទៀត, ឲ្យលុបំបាត់ទាសៈខាងក្នុង គឺមិនឲ្យធ្វើជាទាសៈនៃលោភៈ ទោសៈ មោហៈ» ។

ប្រពៃណីមានទាសៈ ទំរើទិញទាសៈ លក់ទាសៈ អ្នកស្រាវជ្រាវមានគំហើញថា ប្រហែលមានទូទៅពេញទាំងពិភពលោក ។

អ្នកប្រវត្តិសាស្ត្រឯកទេសដែលបានយកចិត្តទុកដាក់ក្នុងបញ្ហារបបទាសៈ បានសម្ដែងសេចក្ដីយល់ឃើញព្រមទាំងបានធ្វើរបាយការណ៍រួមគ្នា ពន្យល់អំពីរឿងនេះយ៉ាងល្អិតល្អន់ ហើយបានបញ្ជាក់ថា របបទាសៈជាបញ្ហារបស់ពិភពលោក ។ ទំរើអ្នកស្រាវជ្រាវបានពឹងផ្អែកលើសៀវភៅទាំងឡាយ មានជាអាទិ៍ ENEYCLOPAEDIA OF SOCIAL SEIENCES ។ THE NEW POPULA ENCY CLOPAEDIA ។ ENCYCLOPAEDIA, BRITANNICA និងបណ្ដាសៀវភៅទាំងឡាយដទៃខាងផ្នែកប្រវត្តិសាស្ត្រ និងសៀវភៅច្បាប់ចាស់ៗ ក្នុងចំណុចដែលមានទាក់ទងជាមួយនឹងព្រះពុទ្ធសាសនា ។

ប្រភពនៃរបបទាសៈនិងព្រឹត្តិការណ៍ដែលមនុស្សបានក្លាយខ្លួនជាទាសៈនោះ អ្នកស្រាវជ្រាវទាំងឡាយបានចែកជា ៥ ប្រភេទ គឺ :

១- ជាទាសៈដោយសសៃលោហិត គឺឪពុកម្ដាយជាទាសៈ កូនកើតមកក៏ជាទាសៈទៀត ដោយជនជាម្ចាស់នៃទាសៈនោះ គេប្រកាន់ថា វាកើតពីទាសៈរបស់គេ (BIRTH) ។

២- ឪពុកម្ដាយមិនមែនជាទាសៈទេ, តែព្រោះខ្លួនទីទាល់ពេក ឬមានការចាំបាច់យ៉ាងណាមួយ លកកូនរបស់ខ្លួនឲ្យទៅធ្វើជាទាសៈអ្នកដទៃ (SALE OF CHILDREN BY THEIR OWN PARENTS) ។

៣- ស្រុកមានសង្គ្រាម ពួកខាងឈ្នះកៀរយកមនុស្សទៅធ្វើជាទាសៈ (CATURA IN WAR) ។

៤- ទំរើពួកចោរស្ទាត់ ឬចោរធម្មតាលួចពង្រត់មនុស្សយកទៅធ្វើជាទាសៈ (PIRACY KIDNAPPING) ។

៥- អាជីវកម្មទាសៈ ដែលគេបានធ្វើយ៉ាងចេញមុខ ទាំងក្នុងប្រទេសក្រិក ទាំងក្នុងប្រទេសទាំងឡាយដទៃទៀត ជាហេតុឲ្យកើតជំនួញទាសៈដោយវិធីផ្សេងៗទៀតយ៉ាងច្រើន (COMMERCE) ។

មានទាសៈម៉្យាងទៀត, តែខ្ញុំយល់ថា វាជាទាសៈដូចគ្នាដែរនោះ គឺកូនបំណុលដែលគ្មានទ្រព្យសម្បត្តិជម្រះបំណុល តាមកិច្ចសន្យាដែលខ្លួនបានធ្វើជាមួយនឹងម្ចាស់បំណុល ។ តាមបទបញ្ញត្តិច្បាប់របស់ក្រិកនិងរ៉ូម៉ាំងបូរាណដែលបានអនុញ្ញាតឲ្យម្ចាស់បំណុលអូសយកកូនបំណុលទៅធ្វើជាទាសៈ ដោយច្បាប់នេះបានប្រគល់សិទ្ធិឲ្យម្ចាស់បំណុល នាំខ្លួនកូនបំណុលទៅធ្វើជាទាសៈ ។ ច្បាប់នេះ, សូលូន បានប្រកាសលើកឈប់ឲ្យប្រើតាំងពី ៥៩៤ ឆ្នាំ មុនគ្រិស្តសករាជ ។ ប្រហែលយ៉ាងនេះហើយ, បានជាអ្នកស្រាវជ្រាវមិនបាននិយាយដល់ គឺរបបទាសៈមានត្រឹមតែ ៥ គ្មានដល់ ៦ ។ យោបល់ខ្ញុំថា បើដាក់ទាសៈប្រភេទនេះក្នុងលំដាប់លេខ ៦ ក៏គ្មានទាស់ខុសដែរ ព្រោះច្បាប់ទាសៈក្នុងសម័យនោះ ទោះណាជាត្រូវប្រកាសលើកក៏គ្មានអនុវត្តដែរ ។

មានទាសៈ ២ ប្រភេទទៀត ក៏អាចចាត់ចូលក្នុងលំដាប់លេខ ៧-៨ បានដែរ ។ គឺប្រភេទទី ៧ បានដល់បុគ្គលស្ម័គ្រចិត្តលក់ខ្លួនធ្វើជាទាសៈគេ ដើម្បីយកប្រាក់ទៅឲ្យមាតាបិតាក្នុងគំនិតតបស្នងសងគុណ ។ ទំរើនេះ, ចួនកាលឲ្យមាតាបិតារបស់ខ្លួនជម្រះបំណុលទៅវិញក៏មាន, បើមិនដូចនេះទេ កូននឹងទៅជាទាសៈរបស់គេអស់មួយជីវិត ។ មនុស្សខ្លះទៀត, រកផ្លូវរស់ខ្លួនឯងមិនឃើញ ព្រោះគ្មានរបរអាជីវកម្ម គ្មានទ្រព្យដើម សុខចិត្តយកខ្លួនទៅធ្វើ

ទាំសៈគេដើម្បីរស់ ។ ប្រភេទទី ៨ បានដល់ទាសៈកម្មករ (FORCED LABOUR) គឺមនុស្សពួកមួយដែលត្រូវគេដាក់បញ្ជាឲ្យធ្វើការបែបទាសៈ ទាំងដែលខ្លួនមិនមែនជាទាសៈ ។ រឿងនេះមានជាប់រហូតដល់សព្វថ្ងៃនេះនៅក្នុងប្រទេសទាំងឡាយ ដែលមានប្រទេសខ្មែរយើងនៅក្នុងនោះផងដែរ ។ បញ្ហានេះអង្គការសហប្រជាជាតិបានប្រើកំហំអស់ពីសមត្ថភាព ដើម្បីកម្ចាត់ឲ្យអស់នូវចំណុចខ្សោយនិងចំណុចខ្លាំងរបស់មនុស្ស (មនុស្សខ្សោយសុខចិត្តឲ្យគេប្រើដូចសត្វតិរច្ឆាន ដើម្បីឲ្យក្រពះរបស់ខ្លួនបានសើម ។ ចំណែកអ្នកខ្លាំងគិតតែពីប្រើ គ្មាននឹកឃើញដល់សីលធម៌ដែលខ្លួនកើតមកជាមនុស្សត្រូវបំពេញ) ។ ទំរើនៃអង្គការសហប្រជាជាតិធ្វើចុះ ធ្វើឡើង លទ្ធផលបានត្រឹមប្រកាសប្តេជ្ញាជាសកលស្តីដោយសិទ្ធិមនុស្សកាលពីថ្ងៃទី ១០ ខែធ្នូ ព.ស ២៤៩១ (គ.ស ១៩៤៨) ។ ក្នុងន័យថា អង្គការនេះទទួលស្គាល់សិទ្ធិមនុស្ស, តែការអនុវត្តលទ្ធផលបានសូន្យ ។ ដូចជាការចាប់ខ្លួនឃុំខឃាំងតាមក្បាលចិត្ត, របបទាសៈ, របបទាសកម្មករ (FORCED LABOUR) ។ល។ ការអនុម័ត្តិទទួលស្គាល់សេចក្តីថ្លែងការស្តីដោយសិទ្ធិមនុស្សក្នុងពេលនោះមានសំឡេងដល់ទៅ ៤៨ ប្រទេស ប្រទេសយល់ទាស់គ្មាន ប្រទេសអនុប្បវាទមានខ្លះបន្តិចបន្តួច ។

## សេចក្តីព្យាយាមរបស់សន្និបាតជាតិ

ក្នុងពេលចប់សង្គ្រាមលោកលើកទី ១ ហើយ ប្រជាជាតិទាំងឡាយបានមានការប្រជុំ បង្កើតអង្គការពិភពលោកមួយឲ្យឈ្មោះថា «មហាសន្និបាតជាតិ» មានទីស្នាក់ការនាក្រុងហ្សឺណែវក្នុងប្រទេសស្វីស ក្នុងវត្ថុបំណងដើម្បីស្ថាបនានិងគាំទ្រសន្តិភាព ។ ជាពិសេសចាត់ការលុបបំបាត់របបទាសៈ ដែលនៅមានសេសសល់ក្នុងប្រទេសនានារបស់ពិភពលោក ដោយបានចាត់វិធានការជាថ្នាក់ៗមានដូចនេះ :

១- ប្រើអនុសញ្ញា គ.ស ១៩១៩ (ព.ស ២៤៦២) ស្តីដោយការលើកទាសៈ ក្នុងគំនិតប្រាថ្នាឲ្យអស់របបទាសៈគ្រប់ករណី រួមទាំងជំនួញទាសៈខាងផ្លូវគោកនិងផ្លូវទឹកយ៉ាងដាច់ខាត ។

២- បានតាំងគណៈកម្មាធិការ ប្រកបដោយអ្នកជំនាញការ ខាងការលើករបបទាសៈដោយចំពោះ ហៅថា COMMITTEE OF EXPERTS ក្នុងឆ្នាំ ១៩២៤ (ព.ស ២៤៦៧) ។

៣- បានប្រើអនុសញ្ញាស្តីដោយរបបទាសៈ SALAVERY, CONVENTION គ.ស ១៩២៦ (ព.ស ២៤៦៩) ដែលមានប្រទេសនានាឲ្យសត្យាប័នរួម ២៦ ប្រទេស ។

៤- បានប្រើអនុសញ្ញាស្តីដោយទាសៈកម្មករ (FORCED LABOUR CONVENTION) ដើម្បីកម្ចាត់ឲ្យអស់នូវបញ្ហាការបង្ខាប់ប្រើកម្លាំង ដោយគ្មានយុត្តិធម៌ គ.ស ១៩៣០ (ព.ស ២៤៧៣) ។

៥- បានតាំងគណៈកម្មាធិការក្រុមទី ២ ឡើងទៀត ហៅថា SECOND SALACERY COMMITTEE ក្នុង គ.ស ១៩៣២ (ព.ស ២៤៧៥) ។

៦- បានតាំងគណៈកម្មាធិការស្តីដោយរបបទាសៈ ជាស្ថាពរ, ជាគណៈកម្មាធិការមានមុខងារជាទីប្រឹក្សាប្រកបដោយបុគ្គលអ្នកជំនាញការក្នុង គ.ស ១៩៣២ គឺក្នុងឆ្នាំ ព.ស ២៤៧៥ ហ្នឹងឯង ។

## ព្រះពុទ្ធសាសនាជាមួយរបបទាសៈ

ចំពោះរបបទាសៈនេះ មានមកក្នុងវិន័យបិដកផង សុត្តន្តបិដកផង ។ ក្នុងវិន័យបិដក, ព្រះសម្មាសម្ពុទ្ធព្រះអង្គមិនអនុញ្ញាតឲ្យភិក្ខុមានទាសៈទុកសម្រាប់ប្រើឡើយ ។ ក្នុងសុត្តន្តបិដក, ព្រះសម្មាសម្ពុទ្ធ ព្រះអង្គមិនអនុញ្ញាតឲ្យឧបាសក ឧបាសិកាធ្វើជំនួញមនុស្សយ៉ាងដាច់ខាត ។

## ល័ខម៉ានក្នុងវិន័យបិដក

១- ហាមមិនឲ្យភិក្ខុ មានទាសៈប្រុស្រីទុកសម្រាប់ប្រើ, ភិក្ខុណាល្មើងប្រព្រឹត្តកន្លង ត្រូវអាបត្តិទុក្កដ ។

២- ទាសៈដែលចូលមកបួសក្នុងពុទ្ធសាសនា ត្រូវបានទទួលសិទ្ធិស្មើនឹងភិក្ខុទាំងឡាយដទៃ ។ រដ្ឋក្នុងសម័យនោះបានទទួលស្គាល់, ទទួលគោរពព្រះពុទ្ធអធ្យាស្រ័យ ។ ជាមួយគ្នានេះ, បានប្រកាសជាផ្លូវការថា : ទាសៈណាបានចូលខ្លួនមកបួសក្នុងពុទ្ធសាសនា ទាសៈនោះត្រូវបានរួចខ្លួនពីការចាត់ចែងរបស់អាជ្ញាធររដ្ឋ និងបុគ្គលជាម្ចាស់របស់ទាសៈ ។ តែដើម្បីចៀសវាងការប្រទាំងប្រទើសគ្នា រវាងរដ្ឋនិងសាសនា, ព្រះបរមសាស្តាចារ្យរបស់យើងព្រះអង្គបានបញ្ញត្តិសិក្ខាបទ មិនឲ្យភិក្ខុបំបួសទាសៈណាដែលគ្មានបានទទួលអនុញ្ញាតពីម្ចាស់របស់ខ្លួន ។ ដូចនេះ, ទើបមានសំណួរក្នុងកណ្ដាលជំនុំសង្ឃមុនប្រកាសឲ្យចូលពួកថា ខ្លួនអ្នកមិនមែនជាទាសៈ របស់បុគ្គលណាម្នាក់ទេឬ? ចំណុចនេះយើងគួរធ្វើការកត់សម្គាល់ថា ពុទ្ធសាសនាត្រូវការឲ្យចូលពួក (បួស) ចំពោះតែមនុស្សណាដែលមានសេរីភាពហើយ ។ ប្រសិនបើមានសំណួរថា ទំរើរបស់ពុទ្ធសាសនាក្នុងរឿងនេះ ជាទំរើមានយុត្តិធម៌ឬទេ? ចម្លើយ ! ទំរើនេះវាមានយុត្តិធម៌ណាស់ទៅហើយ ព្រោះពុទ្ធសាសនា គ្មានត្រូវការឲ្យពិភពលោកមានទាសៈ, វណ្ណៈ, អម្បូរ, ត្រកូល, គោត្ត, សែ, ជាតិសាសន៍ ។ល។ នេះគឺជាអន្លង់ធម្មៈ ដែលព្រះដម្មាសម្ពុទ្ធបានទូងទៅលើព្រលឹងនៃមនុស្សលោក នៅក្នុងក្របខ័ណ្ឌនៃព្រហ្មវិហារធម៌របស់ព្រះអង្គ ។ និយាយខ្លីៗចំៗ គឺព្រះអង្គមិនអនុញ្ញាតឲ្យភិក្ខុបំបួសកុលបុត្រជាទាសៈនោះ ពុំមែនមានន័យថា ព្រះអង្គស្អប់ខ្ពើមទាសៈទេ គឺមានន័យថា ព្រះអង្គអាណិតអាសូរទាសៈ ចង់ឲ្យទាសៈទាំងអស់ មានគំនិតក្លាហានតស៊ូរំដោះខ្លួនឲ្យបានជាអ្នកជា រួចផុតពីដង្កាប់របស់ចៅហ្វាយនាយជាមុនសិនសិមចូលមកបួសជាខាងក្រោយ ។ល។

ល័ខឋានក្នុងសុត្តន្តបិដក

- ព្រះសម្មាសម្ពុទ្ធ បានសម្ដែងអំពីជំនួញ ៥ យ៉ាង ដែលឧបាសក ឧបាសិកាត្រូវវៀរចាក (មិនត្រូវធ្វើ) ជំនួញនេះមានរឿងលក់ទិញមនុស្ស សម្រាប់ប្រើជាទាសៈនៅក្នុងនោះផងដែរ ។
- ព្រះសម្មាសម្ពុទ្ធបានសម្ដែងអំពីគុណរបស់អ្នកបួស ដោយបញ្ជាក់ថា អ្នកបួសទាំងឡាយ ក្រៅពីមានចិត្តប្រកបដោយគុណធម៌ផ្សេងៗ តាមប្រពៃណីអ្នកបួសនោះហើយ ត្រូវមានចិត្តមេត្តាករុណា កុំទទួលយកទាសៈ ដែលគ្រហស្ថគេប្រគេន ដើម្បីទុកសម្រាប់បម្រើខ្លួន, តែបើទទួលដើម្បីលែងឲ្យគ្នាមានសេរីភាពទំរើនេះល្អប្រសើរណាស់ គ្មានទាស់ខុសអ្វីទេ ទទួលប៉ុន្មានក៏បានដែរ ។ល។ស

ជាមួយគ្នានេះទៀត, អ្នកអានគប្បីធ្វើការកត់សម្គាល់ថា ក្នុងករណីយ៍ដែលព្រះសម្ពុទ្ធ ហាមលក់ទិញទាសៈមិនទាន់បាន, ទើបព្រះអង្គហាមមិនឲ្យធ្វើការសង្កត់សង្កិន ជិះជាន់ទាសៈប្រកបដោយគំនិតអយុត្តិធម៌ ។ ទន្ទឹមគ្នានេះ, ឲ្យទំនុកបម្រុងផ្ដល់សុខ, ផ្ដល់សេរីភាពឲ្យទាសៈដូចជា ផ្ដល់ឲ្យនូវអ្វីៗ ទាំងអស់ដល់បុត្តធីតាភរិយារបស់ខ្លួនដែរ ។ ប្រសិនបើអនុវត្តទំរើលើកទាសៈមិនបាន ឬបើកឲ្យមានសេរីភាពជាស្ថាពរមិនទាន់កើតនោះ ទំរើប៉ុណ្ណេះគេមិនត្រូវខានធ្វើ ខានអនុវត្តឡើយ ព្រោះអ្វី? ព្រោះយើងជាមនុស្សត្រូវខំរស់នៅក្នុងមនុស្សធម៌ លុះត្រាតែបានទើបមានឧបនិស្ស័យជាមួយនិងព្រះពុទ្ធក្នុងអនាគតកាល ។

## ព្រះពុទ្ធសាសនាជាមួយនិងទំរើស្ដារខ្លួនចេញពីទាសៈខាងក្នុង

ពាក្យថា ទាសៈខាងក្នុងសំដៅសេចក្ដីថា ពេលខ្លះមនុស្សយើងមានសេរីភាពខាងរូបកាយ ចង់ទៅណាមកណាបាន ឬបើមានតំណែងការផ្សេងៗ ចង់បញ្ជាឲ្យអ្នកធ្វើការក្រោមបង្គាប់របស់ខ្លួន ធ្វើតាមខ្លួនយ៉ាងណាក៏បាន ។ តែសេរីភាពខាងរូបកាយ ពុំបានមានន័យថា មនុស្សយើងមានសេរីភាពសម្បូរទេ ព្រោះមានពេលខ្លះយើងធ្លាក់ខ្លួនជាទាសៈនៃអំណាចទាបថោក ដូចជាសេចក្ដីល្មោភលោភលន់ហួសព្រំដែននៃសេចក្ដីត្រូវការប្រាសចាកក្របខ័ណ្ឌនៃយុត្តិធម៌របស់សង្គម គឺគ្មានគិតថា ខ្លួនជាមនុស្សត្រូវខំរស់ក្នុងសីលធម៌ ក្នុងភាពថ្លៃថ្នូរ គឺកុំគិតតែធ្វើទាសៈបម្រើសេចក្ដីសប្បាយរបស់ខ្លួន (តណ្ហាទាសោ) ភ្លេចទុក្ខ ភ្លេចព្រួយអ្នកដទៃ ឆ្លុតប្រុស ឆ្លុតស្រី

ឆ្កួតល្បែងភ្នាល់ ឆ្កួតស្រា ឆ្កួតមិត្តពាល (គប់មិត្តខូចកម្លៅ) ។ លោភៈ ទោសៈ មោហៈ តណ្ហា . . . . នេះ វាជាចៅហ្វាយនាយត្រួតត្រាចិត្តរបស់យើង ។ យើងធ្លាក់ខ្លួនជាទាសៈរបស់មនុស្សគ្នាឯង ផលវិបាកមានត្រឹមតែខាងផ្លូវរូបកាយ គឺយើងត្រូវខកខ្លួនដោយគេបំបាត់សេរីភាពខាងរូបកាយ ដោយទំរើជិះជាន់គ្រប់បែបយ៉ាងស្រេចហើយតែក្បាលចិត្តរបស់គេ ។ល។ តែទំរើអមនុស្សធម៌នេះ វាមានអំណាចត្រឹមតែធ្វើឲ្យរូបកាយយើងមានសេចក្ដីទុក្ខក្ដៅក្រហាយប៉ុណ្ណោះ ។ វាគ្មានអំណាចវាយកម្ទេចចិត្តវិញ្ញាណរបស់យើងបានទេ, តែបើចិត្តយើងធ្លាក់ខ្លួនជាទាសៈនៃលោភៈ ទោសៈ មោហៈ តណ្ហា . . . . ចៅហ្វាយនាយ ៣-៤ នេះ វានឹងកម្ទេចឧត្តមគតិជាតិ, ស្មារតីធម្មៈសម្បជញ្ញៈយុត្តិធម៌ មនសិការមនុស្សអស់រលីងហើយ ។ មិនតែប៉ុណ្ណោះ, វារុញច្រានយើងទម្លាក់ទៅក្នុងទំរើពុករលួយ ទំរើក្បត់ជាតិ ក្បត់សាសនា ក្បត់វប្បធម៌ ក្បត់សីលធម៌ ក្បត់ខ្លួនឯង ។ល។ អាស្រ័យហេតុនេះទើបព្រះសម្មាសម្ពុទ្ធមានព្រះតម្រាស់ថា «ជ័យជម្នះណាដែលត្រឡប់ចាញ់វិញ ជ័យជម្នះនោះ ជាជ័យជម្នះមិនល្អ (ឈ្នះមនុស្សគ្នាឯង) ជ័យជម្នះណាដែលមិនត្រឡប់ចាញ់វិញ ជ័យជម្នះនោះជាជ័យជម្នះល្អ (ឈ្នះតណ្ហា)» នេះជាសំនួនពាក្យខ្មែរ ។ សំនួនពាក្យបាលីថា **«ន តំ ជិតំ សាធុ យំជិតំ អវជិយតិ តំ ខោជិតំ សាធុ, ជិ តំ, ជិតំ នាវជិយតិ»** ព្រះពុទ្ធតម្រាស់មានទំនាក់ទំនងប្រហែលគ្នានេះទៀតថា «អ្នកឈ្នះដេកសោយពំនៀរ អ្នកចាញ់ដេកកើតទុក្ខ អ្នកមានចិត្តស្ងប់ដេកជាសុខ (ព្រោះហេតុនេះបុគ្គលអ្នកត្រូវការឲ្យជីវិតមានសន្តិភាព) គប្បីលះបង់ចោលនូវជម្នះនិងចំណាញ់ឲ្យអស់» នេះជាសំនួនពាក្យខ្មែរ ។ សំនួនពាក្យបាលីថា **«ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ ឧបសន្តោ សុខំ សេតិ ហិត្វា ជយ បរាជយំ»** ។ មានពុទ្ធតម្រាស់បន្ថែមមួយទៀតថា «ឈ្នះខ្លួនឯង (ឈ្នះតណ្ហា) ជាជម្នះប្រសើរបំផុត» នេះជាសំនួនពាក្យខ្មែរ ។ សំនួនពាក្យបាលីថា **«អត្តា ហវេ ជិតំ សេយ្យោ»** ។

## បទទី ១៤

## បដិវត្តន៍ទំនើបុណ្យដោយសម្លាប់សត្វជាកម្មវិធីសង្គមសង្គ្រោះ

«ពុទ្ធសាសនា ជាសាសនាដំបូង ដែលបង្រៀនទំនើបដិវត្តរឿងធ្វើបុណ្យ ដោយវិធីសម្លាប់សត្វ ឬសម្លាប់មនុស្សបូជាវត្ថុស័ក្តិសិទ្ធិដែលខ្លួនប៉ាន់ស្មាន ឬទំនើធ្វើឲ្យអ្នកដទៃក្តៅក្រហាយ ព្រោះសេចក្តីសប្បាយរបស់ខ្លួន ។ តែបង្រៀនឲ្យធ្វើសង្គមកិច្ច ឬសង្គមសង្គ្រោះ ជំនួសទំនើបៀតបៀនបំផ្លិចបំផ្លាញ ។ ចុងក្រោយបង្អស់បង្រៀនឲ្យរកមធ្យោបាយ ជម្រះចិត្តឲ្យបរិសុទ្ធស្អាតថាជាបុណ្យខ្ពង់ខ្ពស់»

## ប្រពៃណីប្រទេសឥណ្ឌាមានការបូជាយញ្ញ

ប្រជាជាតិឥណ្ឌាក្នុងសម័យបុរាណ មានជំនឿថា សម្លាប់សត្វ ឬយកសត្វទាំងរស់ដុតបូជាយញ្ញ ឧទ្ទិសថ្វាយទេវតា ឬព្រះអាទិទេពបានបុណ្យច្រើន ទេវតាទាំងឡាយនិងព្រះអាទិទេព (ព្រះសេវៈ វិស្ណុ) ចូលចិត្តសព្វព្រះទ័យប្រាថ្នាចង់បានអីបានសម្រេចដូចបំណង ។

វត្ថុធាតុនៃយញ្ញវិធី មានតាំងពីសត្វតូចៗ រហូតដល់សត្វធំៗ ដូចជាគោក្របីពពែចៀមដំរី ។ល។ ជាពិសេស, មានដល់មនុស្សផង ។ អ្នកបូជាយញ្ញធំៗ ច្រើនតែវណ្ណៈស្តេច និងវណ្ណៈព្រាហ្មណ៍ ។ ទំនើដុតមនុស្សបូជាយញ្ញច្រើនតែវណ្ណៈស្តេច ។ល។ នេះគឺជាគនិតសត្វតិរច្ឆានដល់កម្រិតមួយរយភាគរយ ដែលពួកស្តេចបានប្រព្រឹត្តលើមនុស្សជាតិ ។ល។

## គំនោលធម្មៈពុទ្ធសាសនាបានបដិសេធសម្លាប់សត្វបូជាយញ្ញ

ព្រះសម្មាសម្ពុទ្ធបានសរសើរ, បានណែនាំឲ្យមនុស្សមានមេត្តាដល់គ្នានិងគ្នាទៅវិញទៅមក មានសេចក្តីដូចនេះ :

«បុគ្គលណាមានស្មារតីមនុស្សជាតិ, ចម្រើនមេត្តាធម៌គ្មានកំណត់ព្រំដែន បុគ្គលនោះបានឈ្មោះថាឃើញធម៌ជាទីអស់ទៅនៃកិលេស រមែងមានកិលេសជាគ្រឿងទាក់ចងថយចំនួនចុះ ។ បុគ្គលមានចិត្តមិនប្រទុស្តផ្សាយមេត្តាធម៌ដល់សត្វ សូម្បីមានខ្លួនត្រឹមតែមួយ ទំនើនេះរបស់គេជាទំនើមានកុសល ។ បើគេមានចិត្តអនុគ្រោះក្នុងសត្វទាំងពួង ទំនើនេះក៏ត្រូវបានឈ្មោះថា ជាទំនើប្រសើរ ជាទំនើបានបុណ្យយ៉ាងច្រើន, ជាទំនើដែលសប្បុរសទាំងឡាយលោកលើកតម្កើងជាកំពូល ដូចព្រះចន្ទជាកំពូលរបស់ផ្កាយទាំងឡាយ ។ល។

## ហេតុផលក្នុងទំនើហាមសម្លាប់សត្វ

ពុទ្ធសាសនាមិនបានបង្រៀនមនុស្សឲ្យសម្លាប់សត្វ បៀតបៀនសត្វ មិនបានបង្រៀនឲ្យឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ជាន់ឈ្លីជីវិតឈាមសាច់អ្នកដទៃ ។ បង្រៀនឲ្យនឹកដល់ចិត្តគេ ចិត្តយើង ទ្រូងគេ ទ្រូងយើង ។ ដរាបណាយើងឃើញតែប្រយោជន៍ផ្ទាល់ខ្លួន កាលណាមានធាតុអ្វីមួយទំនាស់នឹងផលប្រយោជន៍របស់យើង យើងកម្ទេចចោលភ្លាម យើគ្មានជំនឿក្នុងការប្រតិបត្តិធម្មៈរបស់ពុទ្ធសាសនា ព្រោះយើងមានគំនិតថា បើមនុស្សទាំពិភពលោកគេគិតតែប្រយោជន៍ផ្ទាល់ខ្លួនជាធំទៅហើយ តើទំនើគិតប្រយោជន៍អ្នកដទៃ ដែលដឹកនាំដោយពុទ្ធសាសនានោះយើងនឹងប្រកាន់យកម្តេចបាន ។ គំនិតនេះក៏ត្រូវម៉្យាងដែរ, តែបើមនុស្សលោកមានគំនិតយ៉ាងនេះដូចគ្នាទាំងអស់តើការប្រណាំងប្រជែង, ទំនើជិះជាន់, ទំនើកាប់ប្រចាក់, ទំនើចម្បាំង, ។ល។ វាអាចចប់បានឬទេ? សន្តិភាពនៃពិភពលោកដែលជាទីត្រូវការរបស់សកលមនុស្ស វាអាចមានបាន ឬពុំបានទេ? ព្រះសម្មាសម្ពុទ្ធ ពុំដែលបានបង្រៀនឲ្យសម្លឹងឃើញតែប្រយោជន៍ផ្ទាល់ខ្លួននៃមនុស្សម្នាក់ៗដល់ម្តងណាទេ, ព្រះអង្គតែងបង្រៀនឲ្យសម្លឹងមលើប្រយោជន៍អ្នកដទៃផង ។ ព្រោះអ្វី? ព្រោះប្រយោជន៍របស់ខ្លួន បើគ្មានអ្នកដទៃទោះជាយើងខំប្រឹងធ្វើយ៉ាងណាក៏កើតមិនបានដែរ ។ ក្នុងទីណាក៏ដោយ បើគ្មានការយកចិត្តគេ មកដាក់ក្នុងចិត្តរបស់យើងហើយ ក្នុងទីនោះគេមិន

អាចនឹងរកសេចក្តីសុខស្ងប់បានឡើយ ។ តាមគោលការណ៍នឹកដល់ទ្រូងគេ ទ្រូងយើង ។ ទំរើនេះអាចពង្រីកចេញទៅជាគំនោលសីលធម៌ខាងពុទ្ធសាសនាជាន់សាមញ្ញ ដែលយើងហៅថា បញ្ចសីល បញ្ចធម៌គឺ : សីល ៥ ធម៌ ៥ ។

## បញ្ចសីល បញ្ចធម៌

សីលដោយកការវៀរចាកទំរើអាក្រក, ធម៌ដោយកដល់ការបណ្តុះបំពូនទំរើល្អ មួយៗចែកចេញជា ៥ ជាគូៗនិងគ្នាដូចនេះ :

ក- វៀរចាកសម្លាប់សត្វនិងមនុស្សជាសីលទី ១, មានមេត្តាករុណាចំពោះមនុស្សនិងសត្វជាធម៌ទី ១,

ខ- វៀរចាកលួចទ្រព្យសម្បត្តិសម្បត្តិជាសីលទី ២, ប្រកបសម្មាអាជីព និងមានចិត្តអើពើធ្វើអំណោយផ្សាយសេចក្តីសុខចម្រើនដល់អ្នកដទៃជាធម៌ទី ២,

គ- វៀរចាកទំរើប្រព្រឹត្តខុសក្នុងប្រពៃណីកាមជាសីលទី ៣, សន្តោស ឬសង្រួមក្នុងកាម ត្រេកអរចំពោះតែគូគ្រងរបស់ខ្លួនជាធម៌ទី ៣,

ឃ- វៀរចាកនិយាយកុហកជាសីលទី ៤, និយាយពាក្យពិតជាធម៌ទី ៤,

ង- វៀរចាកផឹកសុរាមេរ័យ ឬគ្រឿងស្រវឹងទាំងឡាយដែលជាទីតាំងនៃសេចក្តីប្រមាទជាសីលទី ៥, មានសតិស្មារតីនឹងនជាធម៌ទី ៥ ។

## ព្រះពុទ្ធសាសនាជាមួយនិងសង្គមសង្គ្រោះ

ពំនោលថា : ពុទ្ធសាសនា បង្រៀនឲ្យធ្វើសង្គមកិច្ច ជំនួសទំរើសម្លាប់សត្វ បៀតបៀនសត្វ គឺសម្លាប់សត្វបូជាយញ្ញនោះ ។ យើងគួរដឹងថា សង្គមកិច្ចរបស់ពុទ្ធសាសនាយ៉ាងដូចម្តេចខ្លះ ។

គោលការណ៍សង្គមសង្គ្រោះ ដែលត្រូវនឹងពាក្យអង់គ្លេសថា (SOCIAL, WORK) នោះដៅដល់សង្គ្រោះមនុស្សដែលគ្នាគ្មានមធ្យោបាយជួយខ្លួនឯងបាន ដើម្បីឲ្យគ្នាមានសមត្ថភាពជួយខ្លួនឯង ដោយគ្មានប្រាថ្នាយកកម្រៃជំនួសវិញ ។ ទំរើនេះត្រូវតែធ្វើដោយមានការពិនិត្យ សាកសួរដេញដោលជាមុន, ដោយហេតុថា បញ្ហានេះមិនមែនធូរស្រួលងាយធ្វើទេ ព្រោះមនុស្សពួកមួយខ្ជិលធ្វើការដើម្បីរស់ គិតតែពីផ្ញើរស់លើអ្នកដទៃតែម្តង ។ ពួកមួយខំធ្វើការដើម្បីរស់ខ្លួនឯង តែខ្វះមធ្យោបាយរកធ្វើមិនចេញ ។ មនុស្សទាំងពីរពួកនេះ ព្រះពុទ្ធសាសនាក្តី អ្នកសង្គមសាស្រ្តក្តី បង្រៀនឲ្យយើងធ្វើសង្គមកិច្ច ។ ចំណែកមនុស្សខ្ជិល ព្រះអង្គមិនត្រឹមតែ មិននិយាយឲ្យជួយប៉ុណ្ណឹងទេ ។ ព្រះអង្គថែមទាំងធ្វើពំនោលបញ្ញើថា «មនុស្សបែបនេះគេកើតមកត្រឹមតែជាដង្កត់ ឬជាភក់ដល់ជើងកប់កង់ នៃសេចក្តីចម្រើនរបស់ពិភពលោក» (**នសិយា លោក វឌ្ឍនោ**) ។ ដូច្នេះហើយ, បានជាក្នុងធម្មៈដែលមានឈ្មោះថា **«ទាន»** ព្រះអង្គបញ្ជាក់ហើយ បញ្ជាក់ទៀតថា អ្នកធ្វើអំណោយជាមនុស្សមានគុណធម៌ល្អហើយ, តែគេត្រូវធ្វើអំណោយចំពោះមនុស្សណាដែលមានរូបកាយអន់ ខ្វះមធ្យោបាយគ្រប់បែបយ៉ាង ។ ចំណែកមនុស្សដែលមានសុខភាពល្អ, រូបកាយរឹងប៉ឹងមាំមួន ដៃជើងធំៗ ហើយខ្ជិលធ្វើការមិនត្រូវឲ្យទេ ។ បើនៅតែចចេសឲ្យ, សង្គមមនុស្សយើងនឹងអស់មនុស្សធ្វើការហើយ, មានតែមនុស្សសុំទានពេញផែនដីទាំងមូល ។ ទំរើសុំទាន, ទំរើគ្មានមនុស្សធ្វើការ, ទំរើធ្វើការមិនគ្រប់ម៉ោង, ទំរើធ្វើការមិនគ្រប់មនុស្ស ឬអ្នកធ្វើការមានចំនួនតិច អ្នកមិនធ្វើការមានចំនួនច្រើន ។ល។ ទំរើទាំងឡាយនេះ ជាទំរើនាំសេចក្តីស្លាប់មកឲ្យស្រុកប្រទេស ឬពិភពលោក ។ នេះជាសេចក្តីយល់ឃើញរបស់អ្នកសេដ្ឋកិច្ច ដែលស្របគ្នានឹងយោបល់ពុទ្ធសាសនាដល់កម្រិតមួយរយភាគរយឥតប្រកែក ។

ព្រះពុទ្ធសាសនា មានគំនោលធម្មៈបង្រៀនឲ្យសង្គ្រោះមនុស្ស ដោយសេចក្តីមេត្តាករុណា គ្មានប្រាថ្នាយកកម្រៃតបស្នងវិញ គឺសង្គ្រោះដោយទឹកចិត្តល្អបរិសុទ្ធ ។ ចំណែកការត្រួតពិនិត្យ សាកសួរដើម្បីដឹងមិនឲ្យអ្នកមកសុំទាន ឬសុំជំនួយបោកបញ្ឆោតនោះ ក៏ជាទំរើមួយទៀតរបស់អ្នកធ្វើអំណោយ, ដែលត្រូវតែប្រើបញ្ញាពិចារណា

រកហេតុផល ដើម្បីឲ្យឃើញថា ស្នូមនោះត្រូវការដើម្បីក្រពះ ឬដើម្បីសេដ្ឋី ឬដើម្បីសប្បាយហ៊ឹកហ៊ាក់ហ៊ឹហា ។ ព្រោះអ្វី? ព្រោះថាទំរើគ្រប់យ៉ាងហ ពុទ្ធសាសនាបង្រៀនឲ្យយកបញ្ញាធ្វើជាបង្អែក មិនមែនឲ្យធ្វើដោយកម្លៅឡើយ ។ ការធ្វើទានមានស្រួល, មានមិនស្រួលដែរ ធ្វើដល់មនុស្សទន់ខ្សោយពិតៗ ស្រួលហើយឈ្មោះថាបាបបំពេញមនុស្សធម៌យ៉ាងប្រសើរ ធ្វើដល់អ្នកបោកប្រាស់មិនស្រួលទេ ។ ខាងផ្លូវធម៌គេថា ពុទ្ធសាសនាបានប្រព្រឹត្តនូវទំរើមិនល្អ គឺធ្វើឲ្យមនុស្សលែងចេះពឹងខ្លួនឯង ដែលពុទ្ធសាសនាធ្លាប់បានបង្រៀនឲ្យមនុស្សពឹងខ្លួនឯង កុំឲ្យពឹងអ្នកដទៃ ។ ខាងផ្លូវសេដ្ឋកិច្ចជាតិ គេថាមនុស្សរស់ដោយអំណោយយូរៗទៅជាតិស្លាប់ ។ គេឲ្យសេចក្ដីប្រៀបធៀបថា ដូចអ្នកស្រែយកពស់វែកធ្លាក់ទឹក មកកៀកឱបនឹងដើមទ្រូងរបស់ខ្លួន ដើម្បីចែកកម្ដៅដល់វា លុះវាបានកម្ដៅគ្រប់គ្រាន់ វាចឹកអ្នកស្រែសម្លាប់ទៅ យ៉ាងណាមិញប្រទេសជាតិក៏អីចឹងដែរ បើមានតែអ្នករស់ដោយអំណោយ គ្មានអ្នកធ្វើការបង្កើតផល ប្រទេសជាតិក៏ត្រូវស្លាប់ ដោយសារតែអ្នកសុំទានយ៉ាងនោះដែរ ។ យោបល់ខ្ញុំក្នុងរឿងនេះថា ការធ្វើកំណែនៃសេចក្ដីកំណាញ់របស់អ្នកមានស្ដុកស្ដម្ភ ដោយធ្វើអំណោយ និងការធ្វើកំណែអ្នកខ្សត់ខ្សោយអត់ឃ្លានដោយទទួលអំណោយនោះ ទំរើនេះវាគ្រាន់តែជាប្រពៃណីចាស់ សម្រាប់មនុស្សកម្លៅប៉ុណ្ណោះទេ ។ ចំណែកទំរើមានហេតុផល ឬកំណែស្របក្បួនសេដ្ឋកិច្ច គឺរកមធ្យោបាយធ្វើយ៉ាងណា ឲ្យមនុស្សមានការធ្វើគ្រប់គ្នា ទើបស្រាយបញ្ហាសេដ្ឋកិច្ចសង្គមរួច ។ នេះឯងគឺជាព្រះពុទ្ធតម្រាស់ក្នុងចំណុចថា សម្បុរសលោកធ្វើទានដល់មនុស្សណាដែលគួរធ្វើ, គួរឲ្យ ។ មនុស្សណាខ្លះដែលគួរធ្វើ, គួឲ្យ? មនុស្សខ្វះមធ្យោបាយ ធ្វើខ្លួនឲ្យរស់ ឬរស់នៅដោយខ្លួនឯងមិនកើត មានជាអាទិ៍ មនុស្សបាក់ដៃ បាក់ជើង ខ្វាក់ភ្នែក មានជំហឺរ៉ាំរ៉ៃក្នុងខ្លួន ឬខ្វះខាតដើមទុនពិតៗមែនៗ ។ល។

## គំនោលធម្មៈក្នុងទំរើសង្គ្រោះដែលមានឈ្មោះថា សង្គហៈវត្ថុ ៤

មនុស្សគ្រប់មជ្ឈដ្ឋាន ទោះជាអ្នករដ្ឋការដែលរដ្ឋឲ្យតំណែងខ្ពង់ខ្ពស់ក្ដី កណ្ដាលក្ដី ទាបក្ដី ។ ប្រជារាស្ត្រ ឬប្រជាពលរដ្ឋ ទោះជាមានក្ដី កណ្ដាលក្ដី ទាបក្ដី ។ល។ ត្រូវតែនាំគ្នារស់នៅក្នុងសង្គហៈធម៌ ៤ នេះ ទើបជាតិរស់សាសនាចម្រើនបាន ។ ព្រះសម្មាសម្ពុទ្ធ បានឲ្យឈ្មោះសង្គហៈធម៌ ៤ ថា ជាកង់ធម៌សម្រាប់បង្វិលមនុស្ស ទៅកាន់សេចក្ដីចម្រើនគ្រប់ប្រការផង ថាជាប្រភពនៃសាមគ្គីធម៌ផង ។

## ការធ្វើបុណ្យតាមន័យរបស់ពុទ្ធសាសនា

ពាក្យថាបុណ្យក្នុងពុទ្ធសាសនា មានន័យបីយ៉ាងគឺ :

១- ពំនោលដោយសភាវៈ, បានដល់គុណជាតិសម្រាប់ជម្រះសន្តានចិត្តសត្វឲ្យស្អាតផូរផង់ ព្រោះបុណ្យប្រែថា ជម្រះ ឬលាង គឺលាងជម្រះមន្ទិលសៅហ្មងដែលមាននៅក្នុងចិត្ត,

២- ពំនោលដោយហេតុ, បានដល់ការធ្វើគុណផ្សេងៗ ឬទំរើល្អនានា,

៣- ពំនោលដោយផល, បានដល់សេចក្ដីសុខចម្រុងចម្រើន ។

ជនភាគច្រើនមានចំណូលចិត្តថា ទំរើបុណ្យត្រូវមានលុយកាក់ទើបធ្វើបាន ព្រោះគេមានយោបល់ថា មានតែការបរិច្ចាគទ្រព្យប៉ុណ្ណោះទើបឈ្មោះថា ធ្វើបុណ្យ ។ បើដូចគំនិតនេះពិត, បុណ្យគឺគេត្រូវទិញដោយប្រាក់ ឬដូរដោយទ្រព្យសម្បត្តិទើបបានបុណ្យ ។ តែបើយើងស្គាល់ន័យរបស់បុណ្យថា បុណ្យបានដល់ទំរើជម្រះចិត្តឲ្យស្អាតបរិសុទ្ធ យើងនឹងចូលចិត្តបានភ្លាមថា ប្រភពសម្រាប់ឲ្យកើតបុណ្យមានច្រើនបែប ច្រើនប្រការណាស់ អ្នកក្រខ្សត់ខ្សោយអាចធ្វើបុណ្យបានច្រើនជាងអ្នកមានស្ដុកស្ដម្ភទៅទៀតក៏មានដែរ ប្រសិនបើគេមានចិត្តចង់ធ្វើ ឬចាំបាចត្រូវធ្វើ, គេចេះតែធ្វើកើតមិនខានឡើយ ។

## បទទី ១៥

## ធម្មាធិបតេយ្យ

«ព្រះពុទ្ធសាសនា ជាសាសនា ដែលបង្រៀនឲ្យប្រកាន់យកធម្មៈ គឺភាពត្រឹមត្រូវ តាមហេតុផលជាប្រមាណ ដែលហៅថា ធម្មាធិបតេយ្យ ។ មិនបង្រៀនឲ្យប្រកាន់យកខ្លួនឯងជាធំ ។ គំនោលបង្រៀនក្នុងចំណុចថា អ្នកណាឃើញធម្មៈ អ្នកនោះឈ្មោះថា ឃើញព្រះសម្មាសម្ពុទ្ធ ។ គំនោលបង្រៀនរឿងអាមិសបូជានិងបដិបត្តិបូជា និងការតែងតាំងធម្មវិន័យទុកជាគ្រូអាចារ្យ ឬបរមសាស្ត្រាចារ្យ ជំនួសអង្គព្រះសម្មាសម្ពុទ្ធ ។ ជាទំរើបង្រៀនបែបធម្មាធិបតេយ្យ ។

## អធិបតេយ្យ ៣

**១- អត្តាធិបតេយ្យ** ប្រកាន់ខ្លួនជាធំ ប្រារព្ធខ្លួន ឬប្រយោជន៍ខ្លួនជាគោលដៅ ។ កាលណាគេមានគំនិតបែបនេះកើតឡើងហើយ គេខំធ្វើទំរើល្អឲ្យល្អជាងមនុស្សដទៃ, គេមិនធ្វើសេចក្តីល្អដើម្បីសេចក្តីល្អឡើយ ។ បុគ្គលប្រភេទនេះ, បើនឹងធ្វើទំរើល្អទាំងឡាយណាមួយ ទោះជាបរិច្ចាគទ្រព្យសម្បត្តិ ឬកម្លាំងកាយវាចាចិត្តក្តី គេត្រូវការឲ្យចុះបញ្ជី ឬប្រកាសផ្សាយដំណឹងឈ្មោះរបស់គេឲ្យអ្នកដទៃបានដឹង បានឮដើម្បីមានកិត្តិយសដល់ខ្លួនគេ, ទើបគេធ្វើ ។ ជនខ្លះបើនឹងធ្វើបុណ្យអ្វី ការសង្គ្រោះអ្វី គេធ្វើលេខមើលកម្រៃមុន ឃើញគ្មានចំណេញគេមិនធ្វើទេ, ឃើញមានចំណេញទើបគេធ្វើ ។

**២- លោកាធិបតេយ្យ** ប្រកាន់យកលោកជាធំ គេធ្វើយ៉ាងណា ក៏ធ្វើតាមគេយ៉ាងនោះទៅ ។ ទំរើប្រពៃណីចួនកាលវាបង្កើតជាសេចក្តីក្តៅក្រហាយយ៉ាងខ្លាំង ដល់មនុស្សដែលរស់នៅក្នុងសង្គមដូចគ្នា ដូចជាគ្រួសារណាមួយមានមនុស្សស្លាប់ ។ តាមប្រពៃណីត្រូវតម្កល់សព សូត្រមន្តទេសន៍ឆាន់យ៉ាងតិចណាស់ ៣ ថ្ងៃ ៣ យប់ ។ បន្ទាប់មកត្រូវធ្វើក្នុងថ្ងៃគម្រប់ ៧ ឬគម្រប់ ១០០ ។ ពិធីកម្មនេះ, មាននិមន្តព្រះសង្ឃឆាន់, មានលៀងភ្ញៀវជាមហាឡារិក ។ ទំរើនេះសម្រាប់អ្នកមានទ្រព្យច្រើន វាគ្មានចោទជាបញ្ហាអ្វីទេ, តែសម្រាប់អ្នកទីទាល់ក្រ វាចោទជាបញ្ហាធំខ្លាំងណាស់ រហូតសមីកម្មពិធីខ្ចី ឬចងការប្រាក់គេ មកបំពេញកង្វះលុះត្រាជំពាក់បំណុលគេសងមិនរួច ខ្លះលក់ដីធ្លីផ្ទះសម្បែងសងគេ ខ្លះធ្លាក់ចុះរហូតដល់យកខ្លួនទៅបម្រើបំណុលគេ ។ ប្រពៃណីលោកនេះ វាមានឥទ្ធិពលខ្លាំងក្លាណាស់ អ្នកក្រមិនហ៊ានដុតខ្មោចឪពុកម្តាយ ឬស្វាមីប្រពន្ធកូនខ្លួន ដោយខុសមួយបាច់ ធូបមួយបំពង់ ទៀនមួយដើមដែលខ្លួនមាន ហើយខ្វប់ឆ្អឹងដោយកំណាត់ក្រមាចាស់ ដោយគ្មានខ្ចីបុលអ្នកណាទុកជាការស្រេចទេ ។ ព្រោះខ្លាចសង្គមមនុស្ស គេថាគ្មានធម៌កតញ្ញូកតវេទិតា ។ ខ្លាំងជាងនេះទៅទៀត, ខ្មោចគ្រួសារអ្នកមានស្តុកស្តម្ភ ដាចខ្យល់ស្ទើរមិនទាន់មានជំនួយសង្គ្រោះ ឬសង្គមកិច្ចពីមនុស្សគ្នាឯងក្នុងស្រុកវាល់ម៉ឺន វាល់សែន វាល់លានរៀល ។ ចំណែកខ្មោចគ្រួសារអ្នកក្រខ្សត់ស្លាប់ស្អុយនៅលើផ្ទះ គ្មានបានទទួលជំនួយពីអ្នកណាទេ, បើមានខ្លះតែពីគ្រួសារអ្នកក្រខ្សត់ដូចគ្នា ទៀន ៥ ធូប ៥ អង្ករមួយចានហ្នឹងហើយ ។ រីឯអ្នកមានស្តុកស្តម្ភគ្មានឃើញអើតក្បាលធ្វើជំនួយទេ, បើបែរជាមាន, មានតែជំនួយដោយពាក្យមួយម៉ាត់ថា អឺ ! អាណិតដែរឯងធ្លាប់ប្រើឲ្យគ្នាជូតឡាន (រថយន្ត) ។

ចំពោះសង្គមធុននេះ សម្រាប់មនុស្សដែលមិនមែនជាពុទ្ធសាសនិកវាជាការធម្មតាទេ, ចុះមនុស្សជាពុទ្ធសាសនិក ដែលព្រះសម្មាសម្ពុទ្ធបានបង្រៀនស្ទើរតែបែកព្រះឱស្ឋ បាក់ព្រះទន្ត អស់ជន្មថា «បុគ្គលជាសប្បុរសគេធ្វើទានដល់មនុស្សណាដែលគេគួរធ្វើ, គេធ្វើអំណោយ ដល់មនុស្សណាដែលគួរធ្វើអំណោយ, គេធ្វើសង្គមសង្គ្រោះដល់មនុស្សណាដែលគួរសង្គ្រោះ» តើពុទ្ធភាសិតនេះ មានអ្វីជាគោលដៅ? តើធ្វើទាននឹងអ្នកក្រខ្សត់ហើយនិងអ្នកមានស្តុកស្តម្ភឯណាត្រូវជាង ឯណាបានផលច្រើនជាង? តើឲ្យទានអ្នកមាននិងអ្នកក្រ ឬជួយសង្គ្រោះអ្នកមាន និងជួយសង្គ្រោះអ្នកក្រ ឯណាជាពាក្យដំបូន្មានរបស់ព្រះពុទ្ធ? ចំពោះសំណួរទាំងអស់នេះ អ្នកអានសូមនឹក

ឲ្យចម្លើយខ្លួនឯងចុះ (មើលសប្បុរិសទានប្រកបផង) ។ ប្រពៃណីដុតខ្មោច, ប្រពៃណីមង្គលការ, ប្រពៃណីបំបួសកូនចៅ ដែលគេចាយប្រាក់ច្រើនៗ ប្រពៃណីធ្វើបុណ្យមាននេះ មាននោះ ដែលមិនដឹងជាមានពីដៃគម្ពីរណា ។ល។ ប្រពៃណីទាំងឡាយនេះ ជាប្រពៃណីសម្រាប់លោក (លោកាធិបតេយ្យ) ។ ឯខាងធម្មាធិបតេយ្យ ឬពុទ្ធសាសនាលោកថា ដុតខ្មោចយ៉ាងម៉េចក៏ដុតទៅ ឲ្យតែឆេះអស់ ការកូនចៅយ៉ាងម៉េចក៏ធ្វើទៅ ឲ្យតែបានគ្នាជាប្តីប្រពន្ធ បំបួសយ៉ាងម៉េចក៏បំបួសទៅ ឲ្យតែកើតជាភិក្ខុ សាមណេរ ធ្វើបុណ្យយ៉ាងម៉េចក៏ធ្វើទៅ ឲ្យតែត្រូវ (គឺជ្រើសរើសមើលទៅបុណ្យទាំង ១០ បុណ្យណាមួយដែលខ្លួនអាចធ្វើបាន) ។ ប្រសិនបើបុណ្យកឋិនទានវិញឲ្យតែមានទេយ្យវត្ថុ ត្រឹមតែស្បង់មួយក៏ធ្វើបានហើយ ប្រសិនបើសង្ឃលោកមានសេចក្តីមេត្តាព្រមទទួល ។ តែបើសង្ឃលោកមិនព្រមទទួល, ទាយកនៃកឋិនទានក៏ឈ្មោះថា បានធ្វើកឋិនទានស្រេចហើយ បានផលក៏ជាកឋិនទានហើយ ព្រោះយើងបានបំពេញករណីយ៍កិច្ច តាមពុទ្ធានុញ្ញាតហើយ, ប៉ុន្តែធ្វើម៉េចបើសង្ឃលោកគ្មានចិត្តអនុគ្រោះ ។ ដូចគ្នានឹងនាងផ្កាននោងព្រៃនិងមដ្ឋកុណ្ឌលីកុមារ ដែលមានផ្កាននោងព្រៃ ហើយគោលដល់ស្លាប់ទៅមិនទាន់ដល់កន្លែងបូជា, មានចិត្តជ្រះថ្លាចំពោះព្រះរតនៈត្រៃហើយ, តែគ្មានទៀនធូបអុជថ្វាយ) បុរសស្ត្រីទាំងពីរនាក់ បានធ្វើទេពនិងទេពធីតានឹងគេដែរ ។ល។ ប្រពៃណីលោក ឬលោកាធិបតេយ្យ មិនត្រឹមតែមានអំណាចលើធម្មៈនៃពុទ្ធសាសនា ឬបង្វិលបំបែរធម្មៈទាំងឡាយ ឲ្យឃ្លាតចាកបន្ទាត់នៃសេចក្តីពិត និងឧត្តមគតិរបស់ព្រះសម្មាសម្ពុទ្ធប៉ុណ្ណឹងទេ ។ ទន្ទឹមគ្នានេះទៀត, វាបានប្រទាញលទ្ធិប្រជាធិបតេយ្យ ឲ្យខ្វាតចេញពីផ្លូវដែកនៃលទ្ធិនេះ ក្នុងចំណុចថា អំណាចធិបតេយ្យទាំងអស់របស់រដ្ឋ ឬរបស់ប្រទេស ចេញមកពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ (អំណាចរបស់រដ្ឋមាន ៣ គឺអំណាចបង្កើតច្បាប់ រចងច្បាប់ អំណាចប្រតិបត្តិច្បាប់ ឬអនុវត្តច្បាប់ អំណាចថ្លឹងទោសដែលកើតអំពីបទល្មើស ឬវិនិច្ឆ័យកំហុសនៅក្របខ័ណ្ឌនៃយុត្តិធម៌របស់ច្បាប់) អំណាចនេះបានធ្លាក់ទៅនៅក្នុងដៃស្តេច (រាជាធិបតេយ្យ) ធ្លាក់ទៅលើដៃអ្នកផ្តាច់ការ (ឯកាធិបតេយ្យ) ធ្លាក់ទៅនៅក្នុងដៃអ្នកធំៗ (អភិជនាធិបតេយ្យ) ធ្លាក់ទៅក្នុងដៃជនពួកតិច (អប្បជនាធិបតេយ្យ) ។ អំណាចនៃប្រពៃណីលោក វាបានកម្ទេចពន្លឺគំនិតរបស់មនុស្ស ហើយវាច្រានសេចក្តីយល់ឃើញរបស់មនុស្សឲ្យចុះក្នុងអណ្តូងនៃកម្លៅយ៉ាងជ្រៅកោដិជ្រៅ ។ លុះត្រាមនុស្សខ្លះមានគំហើញថា ស្តេចជាកូនរបស់ឋានសួគ៌ ស្តេចចង់ធ្វើអ្វីធ្វើទៅចុះ ព្រោះស្តេចជាប្រតិភូរបស់ឋានសួគ៌ ឬជាកូនរបស់អាទិទេពទៅហើយ ។ លោកប្រពៃណីក្នុងចំណុចនេះ បានត្រូវព្រះសម្មាសម្ពុទ្ធរបស់យើង វាយកម្ទេចអស់ពីកម្លាំងព្រះហស្តដោយអន្លូងគឺទសពិធរាជធម៌ ១០ ដែលពុទ្ធសាសនិកធ្លាប់ស្គាល់ធម៌នេះគ្រប់ៗគ្នាមកហើយ ។ ក្នុងន័យថា ព្រះសម្មាសម្ពុទ្ធបានលុបបំបាត់ស្តេចក្នុងផ្លូវអមដោយទសពិធរាជធម៌ផង ដោយព្រហ្មវិហារធម៌ផង ។ ជាមួយគ្នានេះ បានលុបបំបាត់ដោយផ្លូវត្រង់ ដោយសាធារណធម៌ផង ដោយសិទ្ធិមនុស្សផង ដោយរាជភ័យផង ។ល។ ព្រះសម្មាសម្ពុទ្ធបានប្រកាសជាឱឡារិកថា គ្មានមុខតំណែងណា មុខការងារណា មុខសិទ្ធិណា ។ល។ ដែលមនុស្សម្នាក់ត្រូវបានហើយមនុស្សដទៃទៀតមិនត្រូវបានទេ ។ អ្នកណាចង់ធ្វើស្តេច ត្រូវបំពេញធម៌ជាករណីយ៍របស់ស្តេច (ធម៌ ១០), អ្នកណាចង់ធ្វើទេវតា ត្រូវបំពេញធម៌ ៥, អ្នកណាចង់ធ្វើរូបព្រហ្ម ត្រូវបំពេញរូបជ្ឈាន ៤, អ្នកណាចង់ធ្វើអរូបព្រហ្ម ត្រូវបំពេញអរូបជ្ឈាន ៤, អ្នកណាចង់ធ្វើព្រះពុទ្ធភូមិ ត្រូវបំពេញពុទ្ធការកធម៌ ១៨ ។ល។ ចំពោះរឿងធ្វើស្តេច គេគ្មានឃើញមុខស្តេចណា បំពេញធម៌ ១០ នេះបានទេ ។ ដូចនេះស្តេចត្រូវព្រះសម្មាសម្ពុទ្ធលុបចោលហើយ អ្នកណាចង់ឲ្យមានស្តេចដោយគ្មានធម៌ ១០ អ្នកនោះឈ្មោះថា បានចេញមុខប្រឆាំងនឹងព្រះសម្មាសម្ពុទ្ធ ពេញទីតែម្តង ។ បើគេហ៊ានប្រឆាំងនឹងព្រះសម្មាសម្ពុទ្ធ ក្នុងរឿងយកធម៌ ១០ មកលុបបំបាត់ស្តេច ។ គេក៏ជាមនុស្សប្រឆាំងពេញទីនឹងទំរើរបស់ព្រះសម្មាសម្ពុទ្ធក្នុងរឿងមួយទៀត គឺប្រជាធិបតេយ្យជាគូនិងធម្មាធិបតេយ្យដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានបង្កើតឡើង ដើម្បីលុបចោលនូវលោកាធិបតេយ្យ ដែលជាធាតុគេបង្កើតនៅក្នុង

ក្របខ័ណ្ឌគិតប្រយោជន៍ផ្ទាល់ខ្លួន និងទំរើជិះជាន់មនុស្សដទៃ ។ ជាពិសេស, គឺលុបបំបាត់នូវសេរីភាពនៃប្រជាពលរដ្ឋហ្នឹងឯង ។ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គមិននិយមស្តេចទេ កាលសោយព្រះជាតិជាតេមិយៈ ក៏ព្រះអង្គមិនធ្វើស្តេច, នន្ទនិងរាហ៊ុល ដែលជាប្អូនបង្កើត និងកូនបង្កើត ក៏ព្រះអង្គមិនយល់ព្រមឲ្យធ្វើស្តេច ។ល។ ក្នុងបច្ឆិមជាតិ (សិទ្ធត្ថ) ក៏ព្រះអង្គលះបង់តំណែងស្តេចចេញបួស ។ ដូចនេះព្រោះអ្វី? ព្រោះទំរើស្តេច វាផ្ទុយនឹងប្រយោជន៍សាធារណៈ ដោយធម្មៈទាំងឡាយ ដែលព្រះអង្គបានរៀបចំ បានសម្តែងទាំងប៉ុន្មាន សុទ្ធតែជាធម្មៈនិយមប្រយោជន៍សង្ឃ ឬប្រយោជន៍សាធារណៈ គ្មាននិយមប្រយោជន៍គណៈ ឬបុគ្គលឡើយ ។

**៣- ធម្មាធិបតេយ្យ** ប្រកាន់យកធម៌ជាធំ ប្រារព្ធដល់ភាពត្រឹមត្រូវ អនុវត្តគំនិតមានហេតុផល ។ ដែលអាចនិយាយបានម៉្យាងទៀតថា ជាទំរើល្អ ជាគំនិតល្អ ជាគំហើញល្អ ព្រោះឃើញប្រយោជន៍ សង្គមធំជាងប្រយោជន៍ ឯកជន ។ ទំរើនេះអ្នកស្រាវជ្រាវ មានយោបល់ស្របគ្នាថា ល្អហើយ ត្រឹមត្រូវហើយ ។ អ្នកណាឃើញថាមិនត្រឹមត្រូវ មិនល្អ ស្រេចតែគេចុះ ព្រោះការសម្តែង មតិឲ្យគេស្របតាមទាំងអស់ ជាទំរើមួយមិនត្រឹមតែហួសវិស័យមនុស្សធម្មតាទេ គឺវាហួសវិស័យពុទ្ធភូមិទាំងឡាយផងដែរ ។ អ្នកនិយមធម្មាធិបតេយ្យ គេធ្វើបុណ្យអ្វី ឬធ្វើទំរើល្អទាំងឡាយ ចង់អ្នកណាដឹងក្តី[1] មិនដឹងក្តី ឃើញក្តី មិនឃើញក្តី ផ្សាយឈ្មោះឲ្យក្តី មិនផ្សាយក្តី ឲ្យពរក្តី មិនឲ្យក្តី ទទួលអំណរគុណក្តី មិនទទួលក្តី ។ល។ គេគ្មានខ្វីរវល់ទេ ព្រោះគេធ្វើបុណ្យដើម្បីបុណ្យ គឺធ្វើឲ្យចិត្តគេបានស្អាតល្អបរិសុទ្ធ ។ គេគ្មានចង់ធ្វើទេពតន្ទព្រហ្មស្តេចអាមាត្យមន្ត្រីសេដ្ឋីកុដុម្ពីក៏អ្វីទេ ។ បំណងរបស់គេគឺចង់ធ្វើជាមនុស្សស្អាតបរិសុទ្ធត្រឹមត្រូវ, ជាមនុស្សគ្មានទំរើពុករលួយ, មានតែទំរើយុត្តិធម៌ ។ល។ ខ្ពស់ជាងនេះ, គឺគេចង់បានឲ្យធម្មាធិបតេយ្យបានឋិតនៅជាមូលដ្ឋាន នៃប្រជាធិបតេយ្យ ដើម្បីប្រជាធិបតេយ្យមានលក្ខណៈជាប្រជាធិបតេយ្យពេញទី គឺឲ្យជាគុអ្វៗ សុទ្ធតែជាប្រជាធិបតេយ្យទាំងអស់ ដូចជារដ្ឋាភិបាលរបស់ប្រជាជាតិ, ដើម្បីប្រជាជាតិ, ដោយប្រជាជាតិ គឺអំណាចអធិបតេយ្យអ្វីៗទាំងអស់ ជារបស់ប្រជាពលរដ្ឋពិតៗមែនៗ ។ កុំឲ្យទៅជាប្រជាធិបតេយ្យបោកប្រាស់, ប្រជាធិបតេយ្យក្លែងក្លាយ ប្រជាធិបតេយ្យមានសោរស្រាបាយ ឬប្រជាធិបតេយ្យពាក់មុខយក្ស, មនុខហនុមាន ។ ព្រោះប្រជាធិបតេយ្យ មិនជាធាតុកើតឡើងដោយគំនិតមនុស្សស្រវឹងប្រយោជន៍ ស្រវឹងបុណ្យស័ក្តិទេ ។ល។ គឺកើតឡើង ដោយអាស្រ័យគំនិតមនុស្សគ្មានល្មោភលោភលន់ មានគំនិតព្រហ្មវិហារ ។ល។ អ្នកបង្កើតទ្រឹស្តីលទ្ធិប្រជាធិបតេយ្យមុនគេគឺ ព្រះពុទ្ធបរមគ្រូនៃយើងហ្នឹងតែម្តង ព្រោះអ្វី? ព្រោះអ្នកស្រាវជ្រាវខាងផ្នែកសាសនា បានឃើញគំនោលធម្មៈរបស់ព្រះអង្គ ជាធាតុផ្តល់សេរីភាព សមភាព ភាតរភាព ។ល។ ឲ្យមនុស្សគ្រប់វណ្ណៈ ត្រកូល អម្បូរ ជាតិសាសន៍ ។ល។ រហូតដល់សត្វតិរច្ឆាន ដើមឈើ ។ល។ គឺព្រះសម្មាសម្ពុទ្ធ បានផ្តល់សេរីភាពឲ្យដែរ, ខាងផ្នែកទ្រឹស្តី (អ្នកអានចង់ដឹងសេចក្តីពិស្តារក្នុងរឿងនេះ សូមត្រឡប់ទៅមើលបទទី ១៣ និងសៀវភៅប្រជាធិបតេយ្យចាស់ទុំ របស់ខ្ញុំប្រកបផងចុះ) ។ នៅក្នុងរបបធម្មាធិបតេយ្យ, ពុទ្ធសាសនាបានឆ្លុះសេចក្តីបំភ្លឺថា នយោបាយគ្រប់គ្រង ទោះជាគ្រប់គ្រងគ្រួសារក្តី ទូកក្តី នាវាក្តី យន្តហោះក្តី ប្រទេសក្តី រដ្ឋក្តី ។ល។ គេត្រូវប្រើធម្មៈជាអំណាច កុំប្រើអំណាចជាធម្មៈ ។ អ្នកប្រើធម្មៈជាអំណាច និងប្រើអំណាចជាធម្មៈ ។ ចំណុចខុសគ្នានៅត្រង់នេះ គឺអ្នកប្រើធម្មៈជាអំណាច គេអនុវត្តនូវទំរើអ្វីៗទាំងអស់តាមច្បាប់ ឬតាមធម៌ដែលនៅជាធរមាន ។ ចំណែកអ្នកប្រើអំណាចជាធម៌ គេអនុវត្តនូវអ្វីៗទាំងអស់ ដោយទាញយកច្បាប់ យកធម៌នៅក្នុងក្របខ័ណ្ឌនៃគំនិតបោកប្រាសថាទំរើរបស់ខ្ញុំនេះ ធ្វើឡើងដោយត្រូវតាមច្បាប់ តាមធម៌ជាធរមានហើយ, តែកុហកសោះ ។

បុគ្គលដែលប្រើធម្មៈជាអំណាច ដោយគ្មានអត្តាអំណាច និងលោភាអំណាចនោះ បានដល់ព្រះអរិយបុគ្គល

---

(១) ព្រះសម្មាសម្ពុទ្ធ គ្មានពំនោលថា បុណ្យបាបកើតពីអ្នកដទៃបានឃើញ បានដឹងទេ, គឺកើតពីអ្នកធ្វើបុណ្យបាបបានឃើញ បានដឹងដោយខ្លួនឯង ។

ទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ដូចមានចែងក្នុងគម្ពីរព្រះវិន័យថា :

ថ្ងៃមួយជាថ្ងៃបវារណាកម្ម ព្រះសម្មាសម្ពុទ្ធ ព្រះអង្គគង់ក្នុងវត្តបុព្វារាម មានព្រះអរហន្តសាវ័កចំនួនប្រមាណ ៥០០ អង្គ រស់នៅជាមួយ ។ ក្នុងពេលនោះព្រះសម្មាសម្ពុទ្ធ ត្រូវបានបវារណាមុនគេ ព្រះអង្គបានបើកឱកាសឲ្យសង្ឃចោទប្រកាន់នូវទំរើមិនល្អរបស់ព្រះអង្គ ទោះជាដោយឃើញក្តី ឮក្តី សង្ស័យក្តី ។ ព្រះសារីបុត្តបានបវារណាជាបន្ទាប់ លោកបានពោលពាក្យសរសើរ ព្រះសម្មាសម្ពុទ្ធ ក្នុងចំណុចដែលព្រះអង្គបានរស់នៅក្រោម បន្ទាត់នៃធម្មៈវិន័យយ៉ាងទៀងទាត់ ហើយលោកបានបវារណាជាលំដាប់ទី ២ ។ នេះបញ្ជាក់ឲ្យឃើញថា ព្រះសម្មាសម្ពុទ្ធព្រះអង្គប្រកាន់យកធម្មៈជាធំ (ធម្មាធិបតេយ្យ) ។ ដោយអាស្រ័យព្រះទំរើនៃព្រះសម្មាសម្ពុទ្ធនេះ, ទើបសកលពុទ្ធសាសនិក អនុវត្តទំរើគ្រប់យ៉ាងជាធម្មាធិបតេយ្យ ឬមានធម្មាធិបតេយ្យជាបន្ទាត់នៃការអនុវត្ត ។ល។និង។ល។

កាលណាគេចូលចិត្តគំនោលធម្មាធិបតេយ្យជ្រៅជ្រះហើយ គេនឹងមានការចេះដឹងភ្លាមថា អ្វីៗទាំងអស់ក្នុងពិភពលោក ទោះជាធាតុនយោបាយគ្រប់គ្រងក្តី, សេដ្ឋកិច្ចជាតិក្តី, សង្គមកិច្ចរដ្ឋក្តី, វប្បធម៌ប្រទេសក្តី ។ល។ ដែលមានយុត្តិធម៌ ដែលត្រឹមត្រូវ ដែលជាកុសល ។ល។ សុទ្ធតែមានកំណើត មានមូលដ្ឋានអំពីធម្មាធិបតេយ្យទាំងអស់ ។ ជាពិសេសគឺ លទ្ធិប្រជាធិបតេយ្យហ្នឹងតែម្តង ។

ខ្ញុំសូមទាញអារម្មណ៍មិត្តអ្នកអានថា យើងជឿជើងគម្ពីរ ដែលថា ធ្វើបុណ្យច្រើនបានទៅកើតឋានទេវតា ចុះពីទេវតាមកកើតជាស្តេច, តែយើងមិនជឿជើងគម្ពីរខ្លះទៀតដែលថា ស្តេចទុចរិតបៀតបៀនជិះជាន់រាស្ត្រជាសត្វតិរច្ឆាន (មនុស្សតិរច្ឆានោ) ឬស្តេចជាភ័យ ជាធាតុឲ្យកម្លាច (រាជភ័យ) របស់សត្វលោក ។ យើងជឿងថាស្តេចជាកូនឋានសួគ៌, តែយើងមិនជឿថា ឋានសួគ៌គ្មានទំរើក្បត់សិទ្ធិរបស់មនុស្សទេ, ប្រសិនបើឋានសួគ៌ជាឋានសួគ៌មែនទែន ។ យើងស្រឡាញ់យុត្តិធម៌, តែយើងគ្មានគោរព គ្មានស្តាប់ គ្មានជឿព្រះពុទ្ធក្នុងចំណុចថា កុំស្រឡាញ់ កុំរាប់អាន កុំរស់នៅជាមួយអយុត្តិធម៌ (មនុស្សពាល) យើងស្រឡាញ់រាជអាណាចក្រ, តែយើងមិនដឹងថាពុទ្ធសាសនាបានទាត់ចោលរាជអាណាចក្រ ក្នុងគំនោលធម្មៈថា មនុស្សមិនត្រូវប្រកាន់យកនូវរបស់ទាំងឡាយទោះជាទឹកដីក្តី តំណែងក្តី បុណ្យស័ក្តិក្តី ។ល។ ថាជារបស់ខ្លួនម្នាក់ៗទេ ។ ព្រោះអ្វី? ព្រោះរបស់ទាំងនេះជារបស់សាធារណៈសម្រាប់មនុស្សទាំងអស់ ។ គឺស្រេចហើយតែមនុស្សណា មានចំណេះវិជ្ជា មានគុណវុឌ្ឍិមានសមត្ថភាព ឬជាពលរដ្ឋរបស់ប្រទេស ។ល។ មនុស្សនោះមានសិទ្ធិត្រូវបានទទួល ត្រូវបានតែងតាំង ទោះជាដោយចំណាត់ការប្រឡងប្រជែង ដែលធ្វើឡើងដោយអង្គការរដ្ឋក្តី ទោះជាដោយទំរើជ្រើសរើស ដោយវិធីបោះឆ្នោតសម្ងាត់ ឬចំហជាសកល ឬអសកលក្តី ដែលធ្វើឡើងដោយប្រជាពលរដ្ឋក្នុងប្រទេសទាំងមូល ឬតាមភូមិភាគក្តី ។ ទំរើនេះមិនត្រឹមតែជាធាតុមានយុត្តិធម៌ក្នុងសង្គមប៉ុណ្ណឹងទេ គឺជាទំរើបង្កើតនូវគំនិតរួមរស់ផង ជាចំណងនៃគំនិតរួមរស់ផង ។ ដូចនេះ, ទំរើលុបបំបាត់ស្តេច លុបបំបាត់ជនផ្តាច់ការ អ្នកណាបានធ្វើ អ្នកនោះឈ្មោះថា បាបគោរពបូជាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដល់ថ្នាក់ខ្ពស់បំផុត ព្រោះទំរើរបស់គេនេះ ជាទំរើអនុវត្ត មិនមែនជាទំរើទ្រឹស្តី ឬទំរើប្រាជ្ញព្រោក បង់ខាតទឹកមាត់ឥតប្រយោជន៍ ។ អ្នកថ្វាយបង្គំព្រះពុទ្ធរាប់កោដិដង, តែគ្មានទំរើធ្វើឲ្យមនុស្សសុខ, មានសេរីភាព, សមភាព, ភាតរភាព, វឌ្ឍនភាព, សុភមង្គល, យុត្តិធម៌នៃសង្គម ស៊ូមនុស្សលុបរបបស្តេច របបផ្តាច់ការពុំបានឡើយ ។ ព្រះសម្មាសម្ពុទ្ធ បានទេសន៍ហើយ ទេសន៍ទៀត បង្រៀនហើយ បង្រៀនទៀតថា មនុស្សទាំងឡាយកុំបណ្តោយខ្លួនឲ្យល្ងង់ ។ ព្រះអង្គយល់ថា ភាពល្ងង់នេះ វាធ្វើឲ្យមនុស្សបាត់បង់សេរីភាព សមភាព ។ល។ អសរលើង ។ ព្រោះពំនោលដាស់តឿននេះ វាត្រូវ កោដិត្រូវតែម្តងហើយ ។ ព្រោះអ្វី? ព្រោះមនុស្សខ្លះឃើញស្តេចគេអង្គុយលើច្បាប់ (ធម្មាធិបតេយ្យ) ។ល។ គេសប្បាយ គេរាំច្រៀង គេស៊ីផឹកអាហារថ្នាក់ខ្ពស់ គេមាននារីក្មេងៗចោមរោម គេមានប្រពន្ធច្រើន ។ល។ និង ។ល។ គេយកលុយកាក់រាស្ត្រ ចែករាស្ត្រ គេយកដីរាស្ត្រ

ចែកឲ្យរាស្ត្រ គេគ្មានខ្វីរវល់អ្វីដល់សេចក្តីសុខទុក្ខមានក្ររបស់រាស្ត្រ ។ល។ ទំរើប្រកបអាជីវកម្មរបស់រាស្ត្រ ដូចជា ស្រែចម្ការនេសាទចិញ្ចឹមសត្វ សប្បិយកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម ។ល។ និង ។ល។ កើតក្តី មិនកើតក្តី បានក្តី មិនបានក្តី គេគ្មានឈឺក្បាលទេ ។ ទោះបីជាគេមានគំនិតពាលយង់ឃ្នង កាចសាហាវកាប់សម្លាប់ ក្បត់ជាតិ, ក្បត់ប្រទេស យកដីដូរស្រី យកជាតិដូរបល្ល័ង្ក អស់ទឹក អស់ដី អស់មនុស្ស ៩៥ ភាគរយទៅហើយ (ក្នុងប្រទេសខ្មែរ យើង) ។ ក៏គំនិតកម្លៅរបស់យើងនៅតែប្រកាន់យកថា ស្តេចល្អ ។ ត្រង់ព្រះតម្រាស់របស់ព្រះសម្មាសម្ពុទ្ធ ក្នុងចំណុចថា ស្តេចពាល ស្តេចគ្មានទសពិធរាជធម៌ មិនល្អទេ មិនត្រូវសេពគប់ទេ មិនត្រូវរស់នៅជាមួយទេ, មិនមែនជាស្តេចទេ ឋានសួគ៌គ្មានបានចាត់មនុស្សឲ្យមកធ្វើស្តេចទេ ។ល។ យើងគ្មានខ្វីស្តាប់ ខ្វីតាមព្រះអង្គ ឡើយ ។

## បទទី ១៦

# ពុទ្ធសាសនានិងតក្កវិទ្យា

«មានតែពុទ្ធសាសនាមួយទេ, ដែលមានសេចក្តីក្លាហានបដិសេធតក្កវិទ្យា (LOGIC) ដែលប្រជាពលលោក, បានប្រកាន់យក ជាសាស្ត្រដើម្បីសាស្ត្រ ឬសាស្ត្ររបស់សាស្ត្រទាំងឡាយ (SCIENCE OF SCIENCES) ដោយបានស្មើគំនោលវិជ្ជាដទៃ ដែលមានគុណភាពខ្ពស់ជាង មើលឃើញផលជាក់លាក់ជាងជំនួសវិញ»

ដើម្បីជាពន្លឺក្នុងការវិនិច្ឆ័យរឿងនេះឋយើងត្រូវស្គាល់តក្កវិទ្យាឲ្យបានល្អិតល្អន់ជាបង្គួរសិន ទើបយល់នូវទំរើបដិសេធតក្កវិទ្យារបស់ពុទ្ធសាសនា ។ តក្កវិទ្យាប្រើបានល្អនៅក្នុងកម្រិតណា ហើយដល់ទៅកម្រិតណាដែលពុទ្ធសាសនាមិនប្រើ មិនទទួលស្គាល់ ។

## ការស្គាល់តក្កវិទ្យា

ពាក្យថា «តក្កវិទ្យា» យើងប្រែមកពីភាសាអង់គ្លេសថា «LOGIC» ត្រូវនឹងពាក្យនាមក្នុងភាសាក្រិកដែលថា «LOGOS» ពាក្យនេះក្នុងភាសាក្រិកមានន័យថា ភាពគិត, ភាពនឹក ឬគំនិត ។ ឬបើនឹងនិយាយម៉្យាងទៀតថា ពាក្យជាធាតុសម្រាប់សម្តែងចេញនូវគំនិត ឬបង្ហាញគំនិតដូចនេះវិញក៏បាន ។

យ៉ាងណាក៏ដោយ អ្នកសរសេរតម្រាតក្កវិទ្យាជាច្រើនបានព្យាយាម ធ្វើឲ្យពាក្យនេះមានន័យនៅក្នុងព្រំដែននៃសេចក្តីរបស់ខ្លួន ហើយយំរើបម្រាស់នឹងគំនិតទំនាស់របស់អ្នកដទៃ ដែលមានយោបល់ថា វិជ្ជានេះមានលក្ខណៈមិនទាន់សម្បូរ ។ ក្រោយមកគេបានប្រមូលគំនិត គំហើញទាំងអស់មកធ្វើជាលេខបូក ចេញសេចក្តីមានន័យនៅក្នុងកំណត់ព្រំដែន (DEFINITION) នៃពាក្យថាតក្កវិទ្យា, ហើយគេអាចញែកបានជាចំណុចៗ តាមគំហើញរបស់បុគ្គលម្នាក់ៗ មានដូចនេះ :

១- លោក វ៉ែលទិលី (WHATELY) បានកំណត់ព្រំដែននៃសេចក្តីថា «តក្កវិទ្យាគឺជាសិល្បវិទ្យាស្តីដោយទំរើស្វែងរកហេតុផល» ។

២- លោកថមសុន (THOMSON) មានពំនោលថា «តក្កវិទ្យា គឺជាវិជ្ជាស្តីដោយច្បាប់នៃគំនិត» ។

៣- លោកហែមិលតុន (HAMILTON) មានពំនោលថា «តក្កវិទ្យា គឺជាវិជ្ជាស្តីដោយច្បាប់សម្បូរបែបនៃគំនិត» ។

៤- លោកអារ៍នូលដ៍ (ARNOLD) មានពំនោលថា «តក្កវិទ្យា គឺជាវិជ្ជាស្តីដោយចំណូលចិត្តក្នុងទំរើជំនាប់គំនាម ឬការស្រាវជ្រាវរកសេចក្តីពិត» ។

៥- លោកមិលល៍ (MILL) មានពំនោលថា «តក្កវិទ្យា គឺជាវិជ្ជាស្តីដោយចំណាត់ការជំនាប់ទាក់ទិនជាមួយចំណូលចិត្ត សឹងជាប្រយោជន៍ដល់ទំរើគំនាន់គំនេ ។

## ព្រំដែនរបស់តក្កវិទ្យា

ដោយហេតុថា តក្កវិទ្យាស្តីដោយក្បួនទំរើ ឬវិធីគិតនិងផលរបស់គំនិត និងភាពប្រទាក់ប្រគោងគ្នាដល់ភាពពិត តាមបែបផែននិងភាពពិត តាមទំនាក់ទំនងនៃដំណើរសេចក្តី ។ ព្រំដែនរបស់តក្កវិទ្យាមិនមែនជាធាតុមួយដែលមានភាពច្បាស់លាស់ជាក់លាក់ដល់រឿងនេះ រឿងនោះទាំងអស់ទេ ។ ភាពពិតដោយអាស្រ័យបែបផែន គឺទំរើស្រាវជ្រាវរកសេចក្តីពិត ឲ្យប្រព្រឹត្តទៅតាមបែបផែនគោលការណ៍របស់គំនិត គឺជាទំរើមានធម្មតា ដែលធ្លាប់មានមកមែនហើយ, តែវាអាចប្រែប្រួលទៅជាពិត ឬមិនពិតដោយអាស្រ័យដំណើរនៃសេចក្តីក៏មានដែរ ។ ដូចគេនិយាយថា មនុស្សរាល់រូបត្រូវមានម្រាមដៃ ១០ ។ ឈ្មោះ **ក**, ជាមនុស្សដូចនេះ ទើបគេមានម្រាមដៃ ១០ ។ យ៉ាងនេះហៅថា វិធីរកហេតុផលត្រូវតាមបែបផែន ។ ការពិតដែលគេរកបាននោះ ជាសេចក្តីពិតតាមបែបផែន (FOMAL TRUTH)

តែក៏អាចទៅជាពិត ឬមិនពិតតាមដំណើរសេចក្ដីវិញក៏បាន ។ ព្រោះអ្វី? ព្រោះបើឈ្មោះ ក, មានម្រាមដៃដុះចេញមកជាពិសេសមួយទៀតត្រូវជា ១១ ។ ការពិតតាមដំណើរសេចក្ដីនោះ ត្រឡប់ជាឈ្មោះ ក, ត្រូវបានជាមនុស្សដដែល, តែមានម្រាមដៃ ១១ ។ រឿងព្រំដែននៃតក្កវិទ្យានេះ វាមានការទាក់ទងចំពោះសេចក្ដីដឹង តាមផ្លូវដែលត្រូវប្រើវិធីអនុមាននិងទំរើស្រាវជ្រាវរកហេតុផលផ្សេងៗទៀត ដូចនឹងមាននិយាយទៅក្នុងខាងមុខ ។

## ប្រភេទរបស់តក្កវិទ្យា

តក្កវិទ្យាដូចបានពោលមកហើយ យើងអាចធ្វើចំណាត់បានជា ២ បែបគឺ :

**ក**

១- តក្កវិទ្យាបែប (FOMAL LOGIE) ជាតក្កវិទ្យាដែលបានឲ្យគោលការណ៍ និងវិធីគិតរកហេតុផលតាមបែប ឬតាមកម្មវិធីដែលបានសម្រេចហើយ ។

២- តក្កវិទ្យាសង្វែង (MATERIAL LOGIE) គឺតក្កវិទ្យាដែលជាជំនួយ ធ្វើឲ្យតក្កវិទ្យាមានបែប បានប្រព្រឹត្តទៅត្រឹមត្រូវពេញលេញបរិបូណ៌ តាមទំរើស្វែងរកសេចក្ដីពិត ។

**ខ**

១- តក្កវិទ្យានិរន័យ (DEDUCTIVE LOGIE) ជាតក្កវិទ្យាដែលរកហេតុផល ដោយធ្វើជាគំនោលធំៗមុន ហើយធ្វើការពិសោធរកតាមគំនោល តាមវិធីញែកគំនោលធំៗ ជាគំនោលតូចៗ ដើម្បីបញ្ជាក់ថាមែន ឬមិនមែនដូច :

មនុស្សរាល់រូបត្រូវស្លាប់

ឈ្មោះ ក, ជាមនុស្ស

ឈ្មោះ ក, ត្រូវស្លាប់

ទំរើនេះឈ្មោះថា បានតាំងគោលការណ៍ធំៗ ដែលថា មនុស្សរាល់រូបនឹងត្រូវស្លាប់នោះ ជាហេតុផលសំខាន់ដែលអាចនឹងធ្វើការពិសោធថា កាលបើឈ្មោះ ក, សឹងជាឯកជន ជាមនុស្សម្នាក់ក្នុងបណ្ដាមនុស្សទាំងឡាយ ឈ្មោះ ក, ទើបត្រូវស្លាប់ ។

២- តក្កវិទ្យាឧបន័យ (INDU ETIRIE LOGIE) ជាតក្កវិទ្យាដែលចែកជាចំណែកតូចៗ ដោយធ្វើការពិសោធដើម្បីតាំងគំនោលធំឡើងដូច :

ខែមករាមានតិចជាង ៣២ ថ្ងៃ

ខែកុម្ភៈរហូតដល់ខែធ្នូក៏មានតិចជាង ៣២ ថ្ងៃ

រាល់ៗខែមានតិចជាង ៣២ ថ្ងៃ

**ឬ**

ទ្វីបអឺរុបមានស្ទឹងធំ

ទ្វីបអាហ្វ្រិកនិងទ្វីបដទៃៗក៏មានស្ទឹងធំ

រាល់ទ្វីបមានស្ទឹងធំ

## ដំណឹងនិងប្រភពនៃដំណឹង

តក្កវិទ្យាបានពោលដល់សេចក្ដីដឹង (KNOWLEDGE) ចែកចេញជាលក្ខណៈមាន ៣ ប្រការគឺ :

១- ជារបបគំនិតក្នុងចិត្ត ។

២- របបគំនិតក្នុងចិត្តនេះបានភ្ជាប់ទៅជាមួយ និងរបស់ដែលមានពិតៗ មិនមែនជាទំរើគិតអណ្ដែតត្រសែតគ្មានខ្សែបន្ទាត់ ។

៣- មានជំនឿក្នុងរឿងដែលមាននេះផង ។

អ្នកសរសេរតម្រាតក្កវិទ្យាបានឲ្យតួយ៉ាងប្រកបលក្ខណៈទាំង ៣ មានដូចនេះ :

យើងឃើញផ្លេកបន្ទោរ យើងដឹងថាមានពន្លឺរស្មី

យើងឮសំឡេងផ្គលាន់ យើងដឹងថាមានសូរសំឡេង

យើងស៊ីផ្លែស្វាយទុំ យើងដឹងថាមានរសផ្អែម

យើងថើបផ្កាកូឡាប យើងដឹងថាមានក្លិនក្រអូប ។

តួយ៉ាងទាំងអស់នេះ បញ្ជាក់ឲ្យឃើញថា អ្វីក៏ដោយដែលយើងបានឃើញ, បានឮ, បានស៊ី, បានថើប យើងរមែងត្រូវបានដំណឹង ។ ដោយអាស្រ័យន័យនេះ សេចក្ដីដឹងទើបមានលក្ខណៈ ៣ ប្រការ ដូចពោលមកហ្នឹងឯង ។ បើយើងពិចារណាមើល ដើម្បីធ្វើចំណូលចិត្តនៃតក្កវិទ្យាត្រង់ៗ ។ ខ្ញុំសូមបញ្ជាក់ថា សេចក្ដីដឹងបែបនេះ បើតាមគំហើញរបស់ពុទ្ធសាសនាថា មិនមែនជាដំណឹងដែលត្រូវប្រើបញ្ញា ឬអាស្រ័យជាមួយបញ្ញាទេ គឺជាដំណឹងដែលកើតឡើងដោយអាស្រ័យ ប្រាសាទសម្ពស្សដែលហៅថា «ប្រព័ន្ធវិញ្ញាណ» មានចែងក្នុងក្បួន ៣ យ៉ាងគឺ : ១/ អាយតនៈខាងក្រៅ បានដល់រូប, សំឡេង, ក្លិន, រស, ផ្សព្វ (របស់ប៉ះពាល់ត្រូវបានដោយកាយ) និងធម្មៈ (របស់ដែលនឹងបានដោយចិត្ត), ២/ ធាតុទាំងនេះបានឆ្លងកាត់តាមផ្លូវភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, កាយ, ចិត្ត ។ ៣/ មានភាពនៃធាតុបង្កើតជាដំណឹងឡើងហៅថា វិញ្ញាណ ។ ក្បួនទំរើតាមគំនិតពុទ្ធសាសនានេះ គេអាចប្រើពាក្យអង់គ្លេសថា COUSCIOUSNESS THRONGH SIX SPHERES, OFSENSE ក៏បាន ។

អាគស្ថាននៃដំណឹង ខាងផ្លូវតក្កវិទ្យាស្ដែងទីមកនៃដំណឹងមាន ៣ ប្រការគឺ :

១- ដំណឹងដោយត្រង់ៗចំៗ ឬដំណឹងមានភាពច្បាស់លាស់ជាក់លាក់ មិនថាដំណឹងដែលបានមកដោយអាស្រ័យវត្ថុខាងក្រៅ ឬអាស្រ័យធម្មៈខាងក្នុង (មនោធាតុ) ។

២- ការអនុមាន គឺទំរើគ្មាន់គ្នេ ឬរុករកហេតុផលដោយអាស្រ័យពឹងផ្អែកលើធាតុណាមួយ ដែលគេបានស្គាល់ច្បាស់ដូចឃើញផ្សែង គេអនុមានយកថា គង់មានភ្លើងនៅត្រង់កន្លែងដែលមានផ្សែងចេញ ឃើញមនុស្សមានទឹកមុខញញឹមស្រស់ស្រាយ គេអនុមានថា គេកំពុងពេញចិត្តនឹងរឿងអ្វីមួយ ។ តែការអនុមាន (ប៉ាន់ដៅ) នេះអាចទៅជាខុសក៏មានដែរ ព្រោះផ្សែងអាចកើតអំពីប្រតិកម្មគីមី ឬទំរើបាញ់ថ្នាំ ដេ ដេ តេ (ឌី. ឌី. ធី.) ជាធាតុមានផង់ល្អិតជាអតិបរមា លុះត្រាភ្នែកធម្មតាមើលឃើញជាផ្សែង ។ ចំណែកចលនាញញឹមរបស់មនុស្ស អាចញញឹមដោយមិនសប្បាយចិត្ត ឬដោយវិកលចរិត ឬដោយទំរើលួងលោមខ្លួនឯងក្នុងពេលកំពុងប្រឈមមុខនឹងឧបសគ្គនានាក៏មាន ។

៣- សក្ខីភាព ឬល័ខឋានរបស់ទាំងពីរនេះ ក៏ជាគ្រឿងជួយឲ្យកើតដំណឹងមួយដែរ, តែក៏អាចមានសក្ខីភាព ឬល័ខឋានទាំងពីរ ឬណាមួយ ដែលមានភាពពិតខ្លះ មិនពិតខ្លះ គួរជឿខ្លះ មិនគួរជឿខ្លះដែរ ។

បើប្រមូលប្រភពដំណឹង ៣ ប្រការចូលគ្នា គេអាចចែកប្រភេទនៃភាពដំណឹងនេះបាន ២ គឺ :

១- ដំណឹងដោយចំៗត្រង់ៗ (IMMEDIATE KNOWLEDGE) ជាភាពដឹងច្បាស់លាស់ជាក់លាក់ គ្មានធ្វើដោយការគូសដៅ ឬគ្មាន់គ្នេប៉ាន់ស្មាន ។

២- ភាពដឹងតាមផ្លូវដោយអម ឬដោយមិនចំពោះ (MEDIATE KNOWLEDGE) ភាពដឹង ឬភាពស្គាល់ដែលត្រូវប្រើទំរើអនុមាន គឺសេចក្ដីគ្មាន់គ្នេប៉ាន់ស្មាន ឬគូសដៅ ឬប្រើត្រឹមតែសក្ខីភាពល័ខឋានព្រោះគ្មានបានដឹងច្បាស់លាស់ ។

## ល័ខឋាននៃពុទ្ធសាសនាដែលស្ដីដោយដល់តក្កវិទ្យា

១- ព្រះសម្មាសម្ពុទ្ធ មានព្រះតម្រាស់ក្នុងកាលាមសូត្រ អង្គុត្តរនិកាយមានស្ដីថា **«មា តក្កហេតុ»**

«កុំប្រកាន់យក ឬកុំធ្វើជំនឿដោយអាស្រ័យតក្កៈ គឺកុំប្រើគំនិតគូសដៅ ឬគំនិតប៉ាន់ស្មាន»

មានពុទ្ធភាសិតមួយទៀត ក្នុងជាតកនៃសុត្តន្តបិដកថា **«អបណ្ណកដ្ឋានមេកេ ទុតិយំ អាហុ តក្កិកា ឯតទញ្ញាយ មេធាវី តំ គណ្ហេ យទបណ្ណកំ»** «ជនពួកខ្លះ ពោលធម្មៈដែលមិនខុស អ្នកតក្កវិទ្យាពោលធម្មៈទី ២ អ្នកបានស្គាល់ន័យក្នុងចំណុចនោះហើយគប្បីប្រកាន់យកធម្មៈដែលមិនខុស»

សេចក្ដីនៃពុទ្ធភាសិតនេះ មានន័យលំបាកយល់បន្តិច ។ ដូចនេះ, ខ្ញុំសូមធ្វើសេចក្ដីបំភ្លឺថា បើចែកភាពពិត ឬភាពដឹង ឬឋានៈចេញជាពីរយ៉ាង យ៉ាងមួយភាពពិតដែលមានលក្ខណៈច្បាស់លាស់ ហើយយ៉ាងមួយទៀតភាពពិតដែលត្រូវអាស្រ័យទំរើអនុមាន ដែលត្រូវគ្មានឹងភាពដឹងដោយត្រង់ៗចំៗ និងភាពដឹងដោយអមឬដោយមិនចំពោះដូចពោលមកហើយក្នុងខាងដើម ប្រាកដជាមានមនុស្សខ្លះប្រកាន់យកភាពដឹងជាក់លាក់ ឬភាពដឹងត្រង់ៗ ចំៗ ជាប្រមាណ ។ ចំណែកអ្នកតក្កវិទ្យា បានបង្គាប់ឲ្យចាំបាច់ត្រូវស្ដី ត្រូវនិយាយចំពោះទី ២ គឺភាពដឹងដោយអម ដោយមិនចំពោះ ។ ក្នុងទីបំផុត, ពុទ្ធសាសនាបានសរុបគំនិតឲ្យប្រកាន់យកចំពោះស្ថានទី ១ គឺស្ថានដែលមិនខុស ឬភាពពិតដែលគ្មានត្រូវអាស្រ័យទំរើគូសដៅប៉ាន់ស្មាន»

## ហេតុដែលពុទ្ធសាសនាមិនប្រកាន់យកគំនិតដៅស្មាន

ព្រោះពុទ្ធសាសនាបានរាវរកឃើញសេចក្ដីពិតដល់កម្រិតទីបំផុតហើយ គឺព្រះសម្មាសម្ពុទ្ធ បានចុះដៃប្រតិបត្តិដោយព្រះអង្គឯង ។ បានឆ្លងកាត់ទំរើស្រាវជ្រាវល្បងពិសោធ ខុសខ្លះ ត្រូវខ្លះអស់រយៈកាលយ៉ាងយូរ ។ ចុងក្រោយបង្អស់, ព្រះអង្គបានត្រាស់ដឹងនូវសេចក្ដីពិតយ៉ាងច្បាស់លាស់ជាក់លាក់ គ្មានការគូសដៅប៉ាន់ស្មានដូចក្នុងកាលមុន ។ តម្រាស់នេះរបស់ព្រះអង្គ មានស្ថានខ្ពស់ជាងតក្កវិទ្យា ព្រោះតក្កវិទ្យានៅកំពុងស្វែងរកសេចក្ដីពិតផ្អែកលើគំនិតប៉ាន់ស្មាននៅឡើយ ។

ម៉្យាងទៀត, កាលព្រះសម្មាសម្ពុទ្ធ រកសេចក្ដីពិតឃើញហើយ ។ ដំណាលគ្នានេះបានរកឃើញវិធីប្រតិបត្តិតាមភាពពិត ភាពមែន ដែលព្រះអង្គបានឆ្លងកាត់មកហើយដោយខ្លួនឯង ។ តើព្រះអង្គត្រឡប់ថយក្រោយទៅបង្ហាត់បង្រៀនវិធីគូសដៅប៉ាន់ស្មានធ្វើអ្វីទៀត? ដរាបណាមនុស្សយើងនៅកំពុងមានគំនិតដៅស្មាន គំនិតគ្មាន់គ្នេ គំនិតអនុមាន គំនិតស្វែងរកហេតុផលនៅឡើយ ។ ដរាបនោះទំរើ, គំនិត, ពំនោលរបស់គេ នៅតែជាធាតុគ្មានពិតប្រាកដច្បាស់លាស់ជាក់លាក់ឡើយ ។

## តក្កវិទ្យាគ្មានប្រយោជន៍អ្វីទេឬ?

ទំរើបដិសេធតក្កវិទ្យារបស់ពុទ្ធសាសនា បានចោទជាបញ្ហាថា តក្កវិទ្យាគ្មានប្រយោជន៍អ្វីសោះទេឬ? ទម្ងន់យោបល់ខាងលោកគេប្រកាន់ថា តក្កវិទ្យានៃរបស់ទាំងឡាយ គឺសិល្បៈផង វិទ្យាផង ។

បញ្ហានេះពុទ្ធសាសនា ត្រូវឲ្យចម្លើយគេយ៉ាងណា?

ចម្លើយរបស់ពុទ្ធសាសនាថា តក្កវិទ្យាមានប្រយោជន៍ច្រើនដល់គតិលោក, ព្រោះក្នុងគតិលោកនៅមានសេចក្ដីពិតដែលកើតឡើងអាស្រ័យការស្រាវជ្រាវ ជាមួយនិងគំនិតត្រិះរិះគ្នេគ្នាន់ច្រើនបែប ច្រើនប្រការ ប្រសិនបើគ្មានប្រើគំនិតប៉ាន់ស្មានផ្សំខ្លះផង ក៏គ្មានផ្លូវចេញរួច ។ល

ចំណុចថា តក្កវិទ្យា ជាជំនួយក្នុងទំរើផ្សព្វផ្សាយសាសនាមានន័យថា អ្នកមានតក្កវិទ្យា ជាអ្នកមានគំនិតល្អិតមានពំនោលយ៉ាងមានល័ខឋាន ជាអ្នកនិយមហេតុផល មានសមត្ថភាពបំភ្លឺអ្នកស្ដាប់ ឲ្យមានចំណូលចិត្តតាមវិធីខាងតក្កៈរបស់ខ្លួន, តែគ្មានសមត្ថភាពស្រាជ្រាវរកសេចក្ដីពិត ឲ្យសត្វលោករួចផុតចាកសេចក្ដីទុក្ខ នៃសង្សារវដ្តបានទេ ។ល។

# បទសរុប
## ចំណុចកំលីចំនាក់ចំនង

ចំណុចដែលបានធ្វើសំនេរមកហើយគ្រប់បទ ជាហេតុបញ្ជាក់ឲ្យឃើញថា ពុទ្ធសាសនាមានលក្ខណៈពិសេសចម្លែកខុសពីសាសនាទាំងឡាយដទៃ, ជាសាសនាមានហេតុផល, មានពន្លឺរស្មី, មានគំនោលសកល, មានធម្មៈជាអំណាច, មានទំរើទាន់សម័យ, មានគំហើញដឹកមុខពិភពលោកជានិច្ច ។

ដូចនេះ, សូមមិត្តរួមជាតិ រួមសាសនា ។ ជាពិសេសមិត្តបដិវត្ត ១៨ មិនា ដែលបានធ្វើការបដិវត្តបំបាត់របបស្តេច បង្កើតសារធារណៈរដ្ឋ ដោយផ្អែកលើច្បាប់រដ្ឋធម្មនុញ្ញផង ច្បាប់ធម្មតាផង ក្បួននយោបាយជាកុសលផង ។ល។ ទំរើនេះអស់មិត្តទាំងឡាយ បានធ្វើត្រឹមត្រូវតាមឧត្តមគតិនៃពុទ្ធសាសនារបស់យើង ដល់កម្រិតមួយរយភាគរយហើយ ។ សូមមើលគំនិតសច្ចធម៌, គំនិតយុត្តិធម៌នៃសង្គម, គំនិសេរីភាព ។ល។ របស់ពុទ្ធសាសនា ដូចមានតទៅនេះ :

- ពុទ្ធសាសនាពុំបានបង្រៀនយើងឲ្យនិយមរបបស្តេចទេ ព្រោះ :

ក/ រាជាធិបតេយ្យ (របស់ប្រពៃណី) និងធម្មាធិបតេយ្យ (របស់ពុទ្ធសាសនា) ជាគុទាំងពីរនេះ មានគំនោលការ វត្ថុបំណងនិងឧត្តមគតិផ្ទុយគ្នាស្រឡះ ។

ខ/ ចំណុចផ្ទុយគ្នា គឺស្តេច ឬរាជាធិបតេយ្យប្រើអំណាចផ្ទាល់ខ្លួនជាធំ, ធម្មៈ ឬធម្មាធិបតេយ្យ ប្រើច្បាប់ ឬប្រើធម៌ជាធំ ។ គំនោលការ, ស្តេចរៀបចំធ្វើយ៉ាងណាឲ្យប្រជារាស្ត្រស្រឡាញ់ខ្លួន នៅក្នុងគំនិតបោកប្រាស់ឲ្យគេកោតខ្លាចលុតក្រាបចុះចាញ់ខ្លួន ប្រកបដោយគំនិតអញនិយម ។ វត្ថុបំណង, ស្តេចចង់ឲ្យរាស្ត្រល្ងង់ងាយដល់ទំរើជិះជាន់របស់ខ្លួន ។ ឧត្តមគតិ, អ្វីៗទាំងអស់ស្តេចចង់ឲ្យប្រជារាស្ត្រចងចាំ ឬធ្វើសេចក្តីកត់សម្គាល់ថា ជារបស់ស្តេចទាំងអស់ ដោយកុហកថា ខ្លួនជាកូនឋានសួគ៌, ឋានសួគបានបញ្ជាឲ្យខ្លួនមកធ្វើស្តេច របស់ទាំងឡាយឋានសួគ៌បានប្រគល់ឲ្យស្តេច ស្តេចចង់ឲ្យ ចង់មិនឲ្យទៅអ្នកណាក៏បាន ។ល។

- បង្រៀនឲ្យមនុស្សប្រុងប្រៀបខ្លួន, ប្រយ័ត្នកម្លាចដែលត្រូវបង្កើតឡើងដោយស្តេច គឺស្តេចជាកម្លាចមួយធំបំផុត នៅក្នុងកម្រិតលេខ ១ ក្នុងបណ្តាកម្លាចទាំងឡាយ ៤ គឺ :

១- រាជភ័យ, កម្លាចដែលកើតឡើងដោយទំរើជិះជាន់សេរីភាព, របស់ស្តេច,

២- ចោរភ័យ, កម្លាចដែលកើតឡើងដោយទំរើរបស់ចោរទាំងឡាយ មានចោរធម្មតានិងចោរសង្គ្រាមជាដើម,

៣- ឧទកភ័យ, កម្លាចដែលកើតឡើងដោយចលនារបស់ទឹកទាំងឡាយ មានទឹករបឹងនិងទឹកជំនន់ជាដើម,

៤- អគ្គិភ័យ, កម្លាចដែលកើតឡើងដោយសកម្មភាពរបស់ភ្លើងធម្មតា, ភ្លើងព្រះអាទិត្យ និងភ្លើងសង្គ្រាមជាដើម ។

- មិនបង្រៀនឲ្យពុទ្ធសាសនិកប្រកាន់យករបបស្តេចទេ, ព្រោះស្តេចទាំងឡាយ បានប្រព្រឹត្តនូវទំរើផ្ទុយពីយុត្តិធម៌ក្នុងសង្គមមនុស្ស ។
- គ្មានបានអនុញ្ញាតឲ្យមនុស្សធ្វើស្តេចទេ, ព្រោះទំរើធ្វើស្តេច (ជាប្រពៃណីកាន់កាប់សិទ្ធិម្នាក់ឯង) ប្រាសជើងគ្នានឹងពុទ្ធចិន្តា ដែលចេញមកជាពុទ្ធពំនោលថា បាដិបុគ្គលិកទាន ជាទាននាំឲ្យសង្គមមនុស្សមានកម្លាំងធ្លាក់ចុះទន់ខ្សោយ ។ សង្ឃទាន ឬសាធារណៈទាន ឬសប្បុរិសទានក្នុងចំណុចខ្លះ ជាទានធ្វើឲ្យសង្គមមនុស្សមានកម្លាំងរឹប៉ឹងមាំមួន ។ល។
- ពុំមែនមិនឃើញនូវទំរើមនុស្សជិះជាន់មនុស្ស ដែលធ្វើឡើងដោយស្តេចពិតៗមែនៗ នោះទេ ។ ជាពិសេសគឺព្រះតេមិយៈពោធិសត្វក្នុងអតីតជាតិនិងព្រះសិទ្ធត្ថៈពោធិសត្វក្នុងបច្ចិមជាតិ ។ ព្រះពោធិសត្វ

ទាំងពីរអង្គនេះ បានឃើញផ្ទាល់ព្រះនេត្រនូវទំរើពាលយង់ឃ្នង ដែលស្ដេចឳពុករបស់ព្រះអង្គបានប្រព្រឹត្ត ទៅលើប្រជារាស្ត្រ ឬប្រជាពលរដ្ឋ ។ ទំរើនេះ មិនត្រឹមតែធ្វើឲ្យព្រះពោធិសត្វមានគំនិតតក់ស្លុតលាយឡំ ដោយគំនិតឆ្អើមប៉ុណ្ណឹងទេ, គឺធ្វើឲ្យព្រះអង្គដាច់ចិត្តលះបង់ទំរើធ្វើស្ដេច ដែលត្រូវគេប្រគល់ឲ្យតាម ប្រពៃណី, ហើយចេញសាងផ្នួសដោយគ្មានព្រលឹងនៅស្រណោះអាឡោះអាល័យ បុណ្យស័ក្តិស្ដេច សូម្បី បន្តិចបន្តួចឡើយ ។ ចំណែកព្រះពោធិសត្វសិទ្ធត្ថៈ ក្នុងពេលកំពុងបួស, ស្ដេចពិម្ពិសារមានចិត្តអាណិត អាសូរ និយាយអង្វរសូមឲ្យសឹកជាគ្រហស្ថវិញ ព្រះអង្គនឹងប្រគល់រាជអាណាចក្រពាក់កណ្ដាលរបស់ ព្រះអង្គឲ្យសោយរាជ្យ ។ ព្រះសិទ្ធត្ថៈបានឲ្យចម្លើយបដិសេធប្រកបដោយភាពម៉ឺងម៉ាត់ ជាមួយនឹង ពំនោលដាក់ផ្លែផ្កាថា អរគុណច្រើនមហារាជ ! តែសម្រាប់ខ្លួនខ្ញុំរាជសម្បត្តិ ខ្ញុំបានទុកដាក់វាដូចកំហាក ទៅហើយ ព្រោះធាតុនេះមនុស្សលោកគេស្អប់ខ្ពើមខ្លាំងណាស់, ខ្ញុំខ្ពើមវាណាស់ ខ្ញុំពុំអាចលេបកំហាក ដែលខាកចោលឲ្យវាចូលទៅនៅក្នុងពោះវិញបានទេ ។ ខ្ញុំសូមលាមហារាជសិនហើយ ! សូមមហារាជ រស់នៅក្នុងរាជសម្បត្តិរបស់ព្រះអង្គឲ្យបានប្រកបដោយសេចក្ដីសុខសប្បាយចុះ ។ល។

- ព្រះពុទ្ធបរមគ្រូ ក្នុងពេលបានត្រាស់ហើយ, បានឃើញស្ដេចទាំងឡាយគ្មានកាន់ច្បាប់, គ្មានអាណិត អាសូរប្រជារាស្ត្រ ។ ហុតឈាម ស៊ីសាច់, ស៊ីកម្លាំងរាស្ត្រជាឈ្លើងរាស្ត្រ, បញ្ជើក្អែករាស្ត្រ, ព្រួនរាស្ត្រ, ខ្លារាស្ត្រ, ពស់វែករាស្ត្រ ។ល។ ព្រះអង្គមានវិតុកវិចារណ៍កង្វល់កង្វាយក្នុងព្រះចិន្តាយ៉ាងខ្លាំង ព្រោះមុខងារ ឬករណីយកិច្ចរបស់ព្រះអង្គជាព្រះពុទ្ធ ត្រូវស្រាយបញ្ហាដែលមានចោទឡើងដល់មនុស្ស គឺធ្វើយ៉ាងណាឲ្យគេរស់នៅក្នុងលោកនេះប្រកបដោយយុត្តិធម៌ មានជីវិតរស់នៅក្នុងសេរីភាព សមភាព ភាតរភាព វឌ្ឍនភាព ទាំងខាងចិត្ត (សីលធម៌) ទាំងខាងកាយ (សម្ភារៈ) ។ល។ ឲ្យគេរស់នៅក្នុងលោក ដទៃទៀត បានស្រួលដូចលោកនេះ និងឲ្យគេបានរួចផុតចាកទុក្ខទាំងអស់ក្នុងសកលលោក ។ ដូចនេះ ទើបព្រះអង្គណែនាំឲ្យគេអនុវត្តប្រយោជន៍បច្ចុប្បន្ន ៤ (ទិដ្ឋធម្មិកត្ថៈ)ប្រយោជន៍អនាគត ៤ (សម្បរាយិកត្ថៈ) ប្រយោជន៍បរមត្ថ ៤ (អរិយសច្ចៈ) ជាមួយនិងស្ដេចព្រះអង្គបានបញ្ញាជាពិសេស គឺឲ្យ អនុវត្តទសពិធរាជធម៌ ១០ ថែមទៅលើប្រយោជន៍ ៣ នេះទៀត ។
- ព្រះពុទ្ធបរមគ្រូ, ពុំបានផ្ដាំផ្ញើទុកដាក់សាសនារបស់ព្រះអង្គជាមួយស្ដេចទេ, តែព្រះពុទ្ធបានផ្ដាំផ្ញើនឹង ពុទ្ធបរិស័ទ ៤ (ភិក្ខុ, ភិក្ខុនី, ឧបាសក, ឧបាសិកា) ចំពោះបញ្ញើនេះ ប្រសិនបើស្ដេចណាបានអនុវត្ត ទសពិធរាជធម៌ ១០, ស្ដេចនោះក៏ត្រូវ បានអស់កាល អស់ឈ្មោះជាស្ដេចហើយ ។ ព្រមគ្នានេះ, មានឈ្មោះថា ឧបាសក ក៏ត្រូវបានជួយថែទាំរក្សាបញ្ញើនេះដែរ, តែបើស្ដេចគ្មានទសពិធរាជធម៌ ១០, ព្រះសម្មាសម្ពុទ្ធ បានដាក់លក្ខខ័ណ្ឌថា ជាស្ដេចពាល ។ មនុស្សពាល, ព្រះសម្មាសម្ពុទ្ធ បានបញ្ញាមិនឲ្យ ពុទ្ធសាសនិក ឬមនុស្សដែលនឹងធ្វើជាពុទ្ធសាសនិកសេពគប់រាប់រក ឬរស់នៅជាមួយឡើយ ។ ដូចនេះ, រឿងស្ដេចវាចប់គ្នា ត្រឹមព្រះសម្មាសម្ពុទ្ធទាត់ចោលហើយ ទសពិធរាជធម៌ហ្នឹងហើយ ធ្វើស្ដេចក៏មិនបាន ទទួលបញ្ញើធម្មៈក៏មិនកើត ។ ជាមួយគ្នានេះទៀត, មិនត្រឹមតែស្ដេចមានរាជ្យ គ្មានរាជ្យ មន្ត្រីមានតំណែង គ្មានតំណែងទេ ។ល។ ត្រូវនាំគ្នាឈប់ប្រព្រឹត្តទំរើពុករលួយ (បាបអកុសល) ព្រោះទំរើពុករលួយកាលបើ មាននៅក្នុងខ្លួន ឬក្នុងវិញ្ញាណជនណា ព្រះសម្មាសម្ពុទ្ធព្រះអង្គដកឈ្មោះមនុស្សចេញភ្លាម ហើយដាក់ ឈ្មោះសត្វតិរច្ឆានចូលជំនួស ហៅថា «មនុស្សតិរច្ឆានោ» ដោយគ្មានយល់មុខថា ស្ដេច មន្ត្រី កវី បណ្ឌិត មិត្ត សហាយណាមួយទេ ។ល។ ចំណែពលរដ្ឋវិញ បើខ្លួនបានដឹងច្បាស់ហើយថា ខ្លួនហ្នឹងឯងហើយ ជាម្ចាស់នៃអំណាចអធិបតេយ្យរបស់រដ្ឋ, ត្រូវតែមានសេចក្ដីក្លាហាន ហ៊ានចញមុខបោះឆ្នោតសម្ងាត់ជា

សកលក្តី អសកលក្តី ឬអនុម័តិដោយសញ្ញាណាមួយក្តី ឲ្យតំណែងសភាតំណាងរាស្ត្រ ព្រឹទ្ធសភា, ប្រធានាធិបតី ឬអនុប្រធានាធិបតី ទៅបុគ្គលស្អាតស្អំ (បណ្ឌិត) មានគុណវុឌ្ឍិ មានសមត្ថភាពអាចដឹកនាំសាធារណៈរដ្ឋ ទៅកាន់វឌ្ឍនភាពគ្រប់វិស័យទាំងឡាយ មានវិស័យសេដ្ឋកិច្ច មួយអន្លើដោយវឌ្ឍនធម៌ និងសីលធម៌ជាដើម ។ អធិបតេយ្យរបស់ខ្លួនទៅឲ្យជនពាលពុករលួយ ទោះជាខ្លួនគេមានសញ្ញាប័ត្រខ្ពស់ ដែលហ៊ានមនុស្សចេញឲ្យ ឬហ៊ានសួគ៌ចេញឲ្យក៏ដោយ ។ នេះគឺលទ្ធិប្រជាធិបតេយ្យ ដែលបង្កើតដោយលទ្ធិធម្មាធិបតេយ្យ ដែលរកឃើញដោយព្រះសម្មាសម្ពុទ្ធមុនគេ, ហើយដែលត្រូវបានគេដូរឈ្មោះពីធម្មាធិបតេយ្យ មកជាប្រជាធិបតេយ្យសព្វថ្ងៃនេះ ។ ព្រោះអ្វី? ព្រោះធម្មាធិបតេយ្យជាឈ្មោះច្បាប់ ឬឈ្មោះធម៌ (ជាធម្មាធិដ្ឋានៈ) ប្រជាធិបតេយ្យ ជាឈ្មោះប្រជាពលរដ្ឋ ដែលប្រើអំណាចអធិបតេយ្យច្បាប់ ឬអនុវត្តច្បាប់ ឬចងច្បាប់ ។ គឺធម្មាធិបតេយ្យជាឈ្មោះនៃអំណាចច្បាប់ ឬអំណាចធម៌, ប្រជាធិបតេយ្យ ជាឈ្មោះមនុស្ស ឬប្រជាពលរដ្ឋដែលចងច្បាប់ ឬអនុវត្តច្បាប់ ។ល។ នេះគឺជាសិទ្ធិ ជាករណីយកិច្ចធំបំផុតរបស់ប្រជាពលរដ្ឋ ក្នុងទំរើចង់រស់នៅក្នុងលទ្ធិប្រជាធិបតេយ្យនៃរបបសាធារណៈរដ្ឋ នៅក្នុងក្របខ័ណ្ឌរបស់សង្គមជាតិ ។ ទន្ទឹមគ្នានេះទៀត, អ្នកអានសូមធ្វើការកត់សម្គាល់ថា គឺ «អត្តាធិបតេយ្យ» នេះហើយដែលវាចេញទៅជា «រាជាធិបតេយ្យ» «លោកាធិបតេយ្យ» នេះហើយ ដែលវាចេញទៅជា «កុហកាធិបតេយ្យ» ។ ខ្ពស់ជាងនេះទៀត, គឺយើងត្រូវបោះត្រចៀកបង្កើតគំនិតចងចាំថា «អត្តាធិបតេយ្យ និងលោកាធិបតេយ្យ» ទាំងពីរនេះហើយ, ដែលត្រូវបដិសេធចោលដោយព្រះសម្មាសម្ពុទ្ធ ។ គឺព្រះសម្មាសម្ពុទ្ធហ្នឹងឯងហើយ ដែលជាអ្នកប្រជាធិបតេយ្យយុត្តិធម៌ មានកម្រិតយ៉ាងខ្ពស់បំផុត ហើយជាអ្នកកំពូលនយោបាយជាកុសល (កុសលាធម្មា . . . . ខាងផ្នែកទ្រឹស្តី) ព្រោះអ្វី? ព្រោះព្រះសម្មាសម្ពុទ្ធ ពុំមែនត្រាស់មកដើម្បីបម្រើទំរើអយុត្តិធម៌ គឺត្រាស់ដើម្បីបម្រើយុត្តិធម៌ ឬបម្រើសង្គមមនុស្សពិតៗមែនៗ ។ ចម្លើយរបស់ព្រះអង្គ ក្នុងបឋមទេសនាធម្មចក្កប្បវត្តនសូត្រ ព្រះអង្គបានផ្តើមថា ពិភពលោក គឺមនុស្សសត្វនេះជាធាតុទុក្ខ ។ ព្រះអង្គមានព្រះតម្រាស់ពីទុក្ខរាប់ស្ទើរមិនអស់ ។

ប៉ុន្តែមានទុក្ខមួយ ដែលព្រះអង្គហាក់ដូចជាចាប់អារម្មណ៍ជាងគេ គឺទុក្ខកើតអំពីទំរើជិះជាន់ ដែលយើងកំពុងជួបប្រទះសព្វថ្ងៃ ។ ទំរើទាន, ទំរើសីល, ទំរើភាវនា គឺជាទំរើបំបាត់នូវទុក្ខនេះឯង ។ មនុស្សគ្មានសេរីភាព ក៏ព្រោះតែពុំបានអនុវត្តនូវទំរើទាំងឡាយខាងលើហ្នឹងឯង ។ល។ (សូមមើលសៀវភៅឈ្មោះ «ពុទ្ធសាសនា, ប្រជាធិបតេយ្យ, សាធារណៈរដ្ឋ» របស់ខ្ញុំប្រកបផង) ។ គំនិតធម្មចក្រ, គឺជាគំនិតចង់ប្រាប់ ចង់និយាយថា កំណើតមនុស្សពោរពេញទៅដោយទុក្ខគ្រប់គ្នាអស់ទៅហើយ គ្មានករណីយ៍អ្វី ដែលមនុស្សគ្នាឯង ទោះជាម្នាក់ៗក្តី, ទោះជាច្រើននាក់ក្តី នាំគ្នាបង្ហាត់បង្កើតទុក្ខឲ្យគ្នានិងគ្នាដោយទំរើជិះជាន់បៀតបៀនបំបិទសិទ្ធិ បំបាត់សេរីភាព រំលោភច្បាប់ រម្លាយមនុស្សធម៌, ដែលជាទំរើបន្ថែមទុក្ខទៅលើទុក្ខដល់គ្នានិងគ្នាហ្នឹងទៀតទេ ។ ដើម្បីបន្ធូរបន្ថយ ឬសម្រាលទុក្ខរវាងគ្នានិងគ្នា, មនុស្សត្រូវតែបបួលគ្នារស់នៅក្នុងធម្មាធិបតេយ្យ, ប្រជាធិបតេយ្យសារធារណៈរដ្ឋ, យុត្តិធម៌ សីលធម៌ មនុស្សធម៌គ្រប់ៗគ្នាទៅ ។ ជាពិសេស, រស់នៅក្នុងព្រហ្មវិហារធម៌ទើបឈ្មោះថា បានស្រឡាញ់ព្រះពុទ្ធ គោរពព្រះពុទ្ធ ។ល។ ដែលទាំងអស់គ្នាបានសូត្រប្តេជ្ញាថា ពុទ្ធំ សរណំ គច្ឆាមិ ។

- បង្រៀនឲ្យខំរៀន ឲ្យមានវិជ្ជាគ្រប់យ៉ាងដើម្បីស្រាយបញ្ហាជីវិតខ្លួនឯង និងសង្គមមនុស្សបាន ។ល។
- បង្រៀនថា ការរស់នៅក្រោមអំណាចអ្នកដទៃជាទុក្ខ ត្រូវខំធ្វើកំណែឲ្យមានសេរីភាព ឬឥស្សរភាពទាំងខាងក្នុងខ្លួន (ចិត្តជាទាសភាពនៃតណ្ហា . . .) ទាំងខាងក្រៅខ្លួន (មានខ្លួនជាទាសភាពនៃជនដទៃ ឬសាសន៍ជាតិដទៃ) ។ល។

- បង្រៀនឲ្យប្រកបហេតុ ដើម្បីផល ។ល។
- បង្រៀនឲ្យប្រតិបត្តិធម៌តាមសេចក្ដីពិត ដើម្បីទទួលផល ឬស្គាល់ផល ដោយពន្លឺរស្មីនៃគំនិតរបស់ខ្លួន ។
- បង្រៀនឲ្យមានសេចក្ដីអត់ធន់ តស៊ូជំពោះឧបសគ្គផ្សេងៗ គ្មានបង្រៀនឲ្យរស់នៅក្នុងគំនិតភ័យតក់ស្លុត ឬភាពទន់ខ្សោយណាមួយទេ ។ល។
- បង្រៀនយ៉ាងទូលំទូលាយ គឺបង្រៀនឲ្យគាមបាលី, ខណ្ឌបាលី, ខេត្តបាលី, រដ្ឋបាលី, តុលាការបាលី, រដ្ឋធម្មី (រដ្ឋសភា) ព្រឹទ្ធធម្មី (ព្រឹទ្ធសភា) រដ្ឋាភិបាលី . . . . អនុវត្ត ឬរស់នៅក្នុងលោកបាលីធម៌ ។ល។
- បង្រៀនឲ្យមនុស្សរស់នៅក្នុងភាពជឿនលឿន «អភិវឌ្ឍនភាព» ដូចជាខំរៀនឲ្យចេះដឹងខ្ពស់ ។ ជាពិសេសមិនសរសើរអ្នកឈប់នៅក្នុងដំណាក់មួយ ប្រកបដោយគំនិតថា ល្មមហើយ, តែសរសើរអ្នកដើរទៅមុខជានិច្ច នៅក្នុងក្របខ័ណ្ឌមួយថា ការងារគ្មានចប់, ចំណេះវិជ្ជាគ្មានត្រើយទេ ។ល។
- បង្រៀនឲ្យយកចិត្តទុកដាក់ទាំងខាងសម្ភារៈ ទាំងខាងចិត្ត ដើម្បីសុខរួមគ្នាក្នុងសង្គមមនុស្ស ។ល។
- បង្រៀនមិនឲ្យសាងសត្រូវ ឬមនុស្សគ្នាឯងជាសត្រូវ ។ ជាពិសេស, មិនឲ្យមានចិត្តស្អប់ខ្ពើមសាសនិកក្នុងសាសនាទាំងឡាយដទៃ ។ល។
- បង្រៀនមិនឲ្យប្រើវិធីបន់ស្រន់បួងសួង ដើម្បីសម្រេចផលអ្វីមួយ, បង្រៀនឲ្យធ្វើការ ដើម្បីផលដែលខ្លួនចង់បាន ។ល។
- បង្រៀនឲ្យស្គាល់លោកតាមសភាវៈពិត (អនិច្ចំ, ទុក្ខំ, អនត្តា) ។ល។
- បង្រៀនឲ្យប្រកាន់យកធម្មៈ គឺភាពត្រឹមត្រូវជាធំ ជាបន្ទាត់នៃជីវិត គឺត្រូវប្រកាន់យកធម៌ ឬច្បាប់ជាធំ ។ល។
- បង្រៀនអំពីបរមត្ថធម៌ គឺនិព្វាន ។ល។ (មើលបទទី ១ ឬសៀវភៅនិព្វានទស្សនៈរបសខ្ញុំប្រកបផង) ។
- បង្រៀនពីធម៌ថ្នាក់ទាបរហូតដល់ធម៌ថ្នាក់ខ្ពស់ ។ល។
- បង្រៀនថា បញ្ញាជាចង្កៀងនៃជីវិតនិងជាពន្លឺរស្មីនៃពិភពលោល ។ល។
- បង្រៀនសង្កត់ធ្ងន់ទៅលើមនុស្សដែលមានកតញ្ញូកតវេទិតាធម៌ ។ល។
- បង្រៀនឲ្យរម្លត់ទុក្ខ, ដោយគំនិតឃើញច្បាស់ថា អ្វីជាហេតុនៃទុក្ខ (អរិយសច្ចៈ) ។ល។
- បង្រៀនមិនឲ្យប្រើទំរើញាំញីសង្កត់ទៅលើមនុស្សដែលប្រព្រឹត្តខុស ជ្រុលហួសទៅហើយ, ហើយព្រមទទួលកំហុស, ទោះជាដោយចេតនាក្ដី អចេតនាក្ដី ។ល។
- បង្រៀនឲ្យចេះខ្មាសចិត្តខ្លួនឯង ខ្មាសទំរើអាក្រក់ខ្លួនឯង ។ល។
- បង្រៀនឲ្យចេះស្ដាប់ គំនិតគំហើញរបស់អ្នកដទៃផង, បើមិនចេះស្ដាប់ក៏មិនអាចនឹងដឹងថា គំនិតគំហើញរបស់ខ្លួន ខុស ឬត្រូវទេ ។ល។
- បង្រៀនដោយវិធីវែកញែកហេតុផលលុះត្រាបានឃើញសេចក្ដីត្រឹមត្រូវពិតប្រាកដ ។ល។
- បង្រៀនថា ជនពាលមានការឃើញទោសខ្លួនឯងជាកម្លាំង ។ល។
- ពុទ្ធសាសនាជាប្រភពនៃវឌ្ឍនធម៌និងជាសម្បត្តិនៃជនល្អ ។ល។
- បង្រៀនឲ្យស្គាល់កំណើត, ហើយចេះរៀបចំកំណើតឲ្យត្រូវ, ឲ្យបានល្អតាំងពីដំបូង ។ល។
- ព្រះសម្មាសម្ពុទ្ធ បានត្រាស់ថា បើគ្មានសេចក្ដីកើតចាស់ឈឺស្លាប់ និងទំរើជិះជាន់គ្នាគ្រប់បែបយ៉ាងរបស់យើង ព្រះអង្គក៏គ្មានការចាំបាច់អ្វីត្រូវមកកើត ឬត្រាស់នៅក្នុងពិភពលោកនេះទេ ។ល។
- បង្រៀនឲ្យចេះធ្វើពលិកម្មដល់មនុស្សគ្នាឯង ។ ជាពិសេស មនុស្សដែលធ្លាក់ចុះក្នុងរណ្ដៅនៃសេចក្ដីទុក្ខ

។ល។

- បង្រៀនឲ្យព្រមទទួលយក កំហូចកំហាតបន្តិចបន្តួច, កុំឲ្យខូចខាតដល់របស់ច្រើន ។ល។
- បង្រៀនដោយប្រមូលរួមថា មនុស្សត្រូវរស់នៅក្នុងសេចក្ដីមិនប្រមាទ, ក្នុងភាពមិនភ្លេចខ្លួន, ក្នុងភាពប្រុងប្រយ័ត្ន ។ ដោយធ្វើសេចក្ដីបញ្ជាក់ថា សេចក្ដីប្រមាទជាផ្លូវស្លាប់ សេចក្ដីមិនប្រមាទជាផ្លូវរស់ ។ ដូចនេះ, យើងគួររៀបចំរស់នៅក្នុងសេចក្ដីមិនប្រមាទគ្រប់ៗគ្នា ទើបជីវិតរបស់យើងមានជោគជ័យគ្រប់វិស័យនៅក្នុងពិភពនៃមនុស្សនេះ ដែលគេតែងតែបានឃើញនូវទំរើ ប្រណាំងប្រជែងគ្នា, ជាទិសដៅ, ជាធាតុដែលមនុស្សទាំងឡាយតែងប្រកាន់យក អត់មានមនុស្សណា សូម្បីម្នាក់ ដែលស្ម័គ្រចិត្តរស់នៅក្រៅសង្វៀននៃការប្រយុទ្ធនេះឡើយ

សៀមរាប, ថ្ងៃ១ ៤ ខែ៧ ឆ្នាំ៥ ចត្វាស័ក ព.ស ២៥៥៦<br>
ត្រូវនឹងថ្ងៃទី៨ ខែកក្កដា គ.ស ២០១២<br>
វាយអត្ថបទសារជាថ្មីទាំងស្រុងដោយ<br>
ខ្ញុំព្រះករុណា ខ្ញុំបាទ<br>
ឧបាសក : **ផាន ពុទ្ធានុភាព**<br>
ទូរស័ព្ទលេខ : ០១២ ៥០៨ ៦២០<br>
រីករាយនឹងទទួលនូវការរិះគន់ដើម្បីស្ថាបនា